# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

# និង

# បរមត្ថមញ្ជូសាមហាដីកា

# សីលនិទ្ទេស

ដឹកនាំបកប្រែដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុជាត

ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៤

# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

# និង

# បរមត្ថមញ្ជូសាមហាដីកា

# សីលនិទ្ទេស

ដឹកនាំបកប្រែដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុជាត

ថ្ងៃ ៨ កើត ខែពិសាខ ពុទ្ធសករាជ ២៥៥៤

*ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុជាត*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ២២.៥ សរណ៣

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ពិតថេរដីកា**
**ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត**

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ ។

**យោង** : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

***ចម្លងជូន :***
- ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
- សាលាខេត្តបាត់ដំបង
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

# និទានវចនៈ

*វិសុទ្ធិមគ្គ* ជាបករណ៍វិសេស ដែលព្រះថេរៈ អ្នកស្រុកជម្ពូទ្វីប មានឈ្មោះបោះសំឡេងមួយរូប បានរចនាឡើង កាលព្រះពុទ្ធសាសនាកន្លងទៅហើយបានប្រមាណ ១.០០០ ឆ្នាំ នៅកោះលង្កាទ្វីប ព្រះថេរៈរូបនេះ គឺ **ព្រះពុទ្ធឃោសៈ** ឯលោកក៏បានរចនាគម្ពីរទុកជាច្រើន នៅក្នុងបវរនៃព្រះពុទ្ធសាសនា ជាការងារដ៏ធំ និងជាមរតក រហូតមកដល់សព្វថ្ងៃ ។ ការប្រែ **គម្ពីរព្រះត្រៃបិដក អដ្ឋកថា** ពី **ភាសាសីហឡ** មកជា **ភាសាមគធៈ** ឬ **ភាសាបាលី** ព្រះពុទ្ធឃោសៈបានប្រមូលធម៌នៅក្នុងព្រះត្រៃបិដក មកសម្ដែងទុកជាពួកៗ តាំងពី **សីល សមាធិ** និង **បញ្ញា** តាមលំដាប់ ។

ឯការរៀបរៀងជាការតែងសំណួរ ឬលំដាប់នៃការឆ្លើយសំណួរធម៌ក្នុងបច្ចុប្បន្ន គឺអធិប្បាយសេចក្ដីសង្ខេបឲ្យពិស្ដារ បទសំណួររបស់ **វិសុទ្ធិមគ្គ** ពោលដោយត្រៃសិក្ខា ដែលជាមាតិកាធំក្នុងព្រះពុទ្ធសាសនា បទសំណួរទាំងអស់ គឺជាបេះដូងនៃការបដិបត្តិតែម្យ៉ាង ព្រោះព្រះពុទ្ធឃោសៈ បានអធិប្បាយ ដោយវិចិត្រពិស្ដារ និងមានរបៀបរៀបរយ បានអាងព្រះពុទ្ធវចនៈជាអាគតដ្ឋានទុកក្នុងទីនោះៗ

ទូទៅ នេះសម្ដែងឲ្យដឹងថា លោកមានការបែកធ្លាយក្នុងព្រះត្រៃបិដក អាចលើកយកធម៌ ដែលពោលដោយសីល មករួបរួមទុកក្នុងពួកសីល លើកយកធម៌ដែលទាក់ទងជាមួយសមាធិ មករួបរួមទុកក្នុងពួកសមាធិ លើកយកធម៌ដែលទាក់ទងជាមួយបញ្ញា មករួមទុកជាមួយពួកបញ្ញា ដោយចែកជានិទ្ទេសៗ រួមទាំងអស់មាន **២៣ និទ្ទេស**, រីឯប្រវត្តិនៃការតែងវិសុទ្ធិមគ្គ ក៏បានក្លាយជាការប្រឡូងដេញដោល, ព្រោះព្រះថេរៈ ជាអ្នកស្រុកសីហឡ: បានផ្ដើមបញ្ហាឲ្យលោកតែងជាមុន កាលបើលោកធ្វើបានជាទីពេញចិត្ត ទើងលើក **គម្ពីរអដ្ឋកថាភាសាសីហឡ:** ឲ្យលោកប្រែជាភាសាមគធ:តទៅ ព្រះពុទ្ធឃោសាចារ្យបានធ្វើយ៉ាងរហ័ស និងល្អក្រៃលែង ជាទីពេញចិត្តរបស់ព្រះថេរៈអ្នកស្រុកសីហឡ:ទាំងពួង, ដូច្នោះ **គម្ពីរវិសុទ្ធិមគ្គនេះ** ជាវិជ្ជានិពន្ធដើម្បីសាកល្បងចំណេះដឹងរបស់ព្រះពុទ្ធឃោសៈ ។

ព្រះពុទ្ធឃោសៈ មានដើមកំណើតនៅ **ប្រទេសឥណ្ឌា** នាតំបន់ **ពុទ្ធគយា** បានសិក្សាជំនាញនៅក្នុងព្រះពុទ្ធវចនៈ ទ្រទ្រង់ព្រះត្រៃបិដកមានបញ្ញាដ៏ក្រៃលែង លោកបានធ្វើដំណើរទៅ **លង្កាទ្វីប** ក្នុងរវាងពុទ្ធសករាជ ៩៥០-១០០០ ហើយ បានរចនាគម្ពីរវិសុទ្ធិមគ្គនៅទីនោះ

និងប្រែ ព្រះបាលីអដ្ឋកថា ពីភាសាសីហឡ: មកជាភាសាមគធ: ( ភាសាបាលី ) ។

ព្រះថេរ: មានឈ្មោះដែលគ្រូទាំងឡាយកាន់យកហើយថា **ពុទ្ធឃោស:** ជាអ្នកមានភាពបរិសុទ្ធបរិបូណ៌ ប្រដាប់ដោយសទ្ធា វិជ្ជា និងសេចក្តីព្យាយាមដ៏បរិសុទ្ធយ៉ាងក្រៃលែង ជាបុគ្គលរុងរឿងដោយធម៌ ជាហេតុកើតនៃសេចក្តីល្អ មានសីលាចារ:ទៀងត្រង់ និងការឱនលំទោនជាដើម អាចឈោងចុះកាន់ជជ: គឺលទ្ធិរបស់ខ្លួន និងលទ្ធិរបស់បុគ្គលដទៃ ប្រកបដោយការមុតស្រួចនៃបញ្ញា មានចំណេះដឹងមិនទើសទាក់ក្នុងសត្ថុសាសន: ដោយបរិយត្តិផ្សេងៗ គឺព្រះត្រៃបិដកព្រមទាំង **អដ្ឋកថា** ជា **មហាវេយ្យាករណ៍** ប្រកបដោយភាពវិចិត្រនៃពាក្យសម្តី ទាំងទន់ភ្លន់ទូលំទូលាយ បន្លឺចេញបានស្អាត់ជំនាញ សន្សំឲ្យកើតករណសម្បត្តិ មានវាទ:ប្រសើរត្រឹមត្រូវ បុគ្គលដទៃយល់បានងាយ **ជាមហាកវី** ហែហមដោយបដិសម្ភិទាដែលបែកធ្លាយ ជាអលង្ការនៃវង្ស ព្រះថេរ:ដែលនៅក្នុងមហាវិហារទាំងឡាយ ដែលជាប្រទីបនៃថេរវង្ស មានការដឹងតាំងមាំល្អហើយ ក្នុង **ឧត្តរិមនុស្សធម្ម** ដែលប្រដាប់ដោយគុណផ្សេងៗ មាន **អភិញ្ញា ៦** ជាដើម ហែហម

ដោយ **បដិសម្ភិទា** បានរចនាវិសុទ្ធិមគ្គនេះចប់ហើយ ។

វិសុទ្ធិមគ្គនេះ តាំងនៅក្នុងលោក សម្តែងន័យដល់កុលបុត្រទាំងឡាយ ដែលស្វែងរកធម៌ ជាគ្រឿងដកចេញនូវលោក ដរាបប៉ុនដែលព្រះនាមថា **ពុទ្ធោ** របស់ព្រះលោកជេដ្ឋ: ដែលស្វែងរកគុណដ៏ធំ មានព្រះទ័យដ៏បរិសុទ្ធជាតាទិបុគ្គលប្រព្រឹត្តទៅក្នុងលោក ។

គម្ពីរវិសុទ្ធិមគ្គនេះបានរចនាដោយ

**ព្រះពុទ្ធឃោសាចារ្យ**

# ព្រះធម្មបាលត្ថេរ

## ព្រះថេរៈជាអ្នករចនាព្រះគម្ពីរបរមត្ថមញ្ជូសាមហាដីកាវិសុទ្ធិមគ្គ

ខ្ញុំម្ចាស់ ( ព្រះធម្មបាលត្ថេរ ) ដែលព្រះទាឋានាគត្ថេរ ជាអ្នកមានសីល និងអាចារៈដល់ព្រមហើយ មានបញ្ញាជាគ្រឿងទ្រទ្រង់ មានការប្រព្រឹត្តបរិសុទ្ធ មានចិត្តតាំងមាំ អារាធនាហើយ ។ សូមថ្វាយវន្ទាព្រះពុទ្ធជាម្ចាស់ ប្រៀបដូចជាព្រះអាទិត្យ ទ្រង់មានព្រះសទ្ធម្មដូចជាក្លួងរស្មី ទ្រង់កម្ចាត់ងងឹត គឺមោហៈធំអស់ហើយ ទ្រង់ញ៉ាំងពួកវេនេយ្យសត្វ ដែលប្រៀបដូចជាផ្កាឈូក ឲ្យរីកវិសេស ទ្រង់មានព្រះបញ្ញាគុណដ៏វិសេស ដូចដួងព្រះអាទិត្យ មានព្រះវិសុទ្ធិគុណ និងព្រះករុណាគុណ ដូចជាពន្លឺអរុណដែលមិនមានភាពសៅហ្មងរះឡើងក្នុងលោក គួរដល់ការបូជា សូមថ្វាយវន្ទាព្រះធម៌ដែលបំភ្លឺដល់លោក រុងរឿងដោយរស្មី គឺព្រះគុណ និងសូមនមស្ការព្រះអរិយសង្ឃ ដែលដូចជាផ្កាឈូកបរិសុទ្ធហើយ ដោយតេជះនៃបុណ្យចំពោះការថ្វាយវន្ទាព្រះរតនត្រ័យ ដែលកើតឡើងហើយ ដោយប្រការនោះៗ សូមប្រាសចាកអន្តរាយក្នុងទីគ្រប់ស្ថាន ខ្ញុំម្ចាស់នឹងអាស្រ័យបោរាណកថាមគ្គ ដើម្បីពណ៌នាខ្លឹមសារនៃបករណ៍វិសេស ឈ្មោះ

**វិសុទ្ធិមគ្គ** ដែលប្រដាប់ដោយន័យដ៏បរិសុទ្ធ មានលំដាប់បទយ៉ាងប្រណីត ដែលព្រះអាចារ្យពុទ្ធឃោសៈបានពោលដើម្បីជាឧបាយក្នុងការសម្រេចភាពបរិសុទ្ធិ ដែលលោកជា **នាថ** មានព្រះចរិយាបរិសុទ្ធ មានហឫទ័យ ដែលព្រះករុណាឲ្យឧស្សាហ៍ហើយ លោកបានសម្រេចហើយ សម្តែងទុកមិនឲ្យខុសពីលទ្ធិរបស់ព្រះថេរៈឯសម្នាក់មហាវិហារ ឲ្យបរិសុទ្ធយ៉ាងល្អ មិនរាត់រាយ មានវិនិច្ឆ័យសេចក្តីដ៏សុខុម ឲ្យបរិសុទ្ធ និងប្រកបដោយរបៀបរៀបរយ ។

សូមសាធុជនទាំងឡាយ តាំងចិត្តសិក្សានូវខ្លឹមសារនៃព្រះវិសុទ្ធិមគ្គនេះ ឲ្យបានល្អ ខ្ញុំប្រាថ្នាឲ្យព្រះសទ្ធម្មតាំងនៅអស់កាលយូរដោយប្រការដូច្នេះចុះ ។

**ព្រះធម្មបាលត្ថេរ** ជាជនជាតិស្រីលង្កា លោកបានសិក្សានៅក្នុងសំណាក់ **មហាវិហារ** នាក្រុង **អនុរាធបុរៈ** ក្នុង **លង្កាទ្វីប** បានចូលរួមរចនា **គម្ពីរអដ្ឋកថា** ជាមួយព្រះពុទ្ធឃោសាចារ្យដែរ, លោកបានរចនាអដ្ឋកថា និងមហាដីកា ទើបបានទទួលការលើកសរសើរថាជា ព្រះអដ្ឋកថាចារ្យ និង ព្រះដីកាចារ្យ នៅ កោះលង្កាទ្វីប ក្នុងរវាងពុទ្ធសករាជ ៩៥០-១០០០ ។

គម្ពីរបរមត្ថមញ្ជូសាមហាដីកានេះរចនាដោយ **ព្រះធម្មបាលត្ថេរ**

# អារម្ភកថា

ការបកប្រែរៀបរៀងឡើងនូវ **គម្ពីរវិសុទ្ធិមគ្គ** និង **បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេសនេះ** យើងខ្ញុំបានរៀបរៀងដោយល្អមកជាខេមរភាសា និងរៀបរៀងទៅតាមលំដាប់នៃមាតិកានីមួយៗ យ៉ាងផ្ចិតផ្ចង់បំផុត មិនឲ្យឃ្លៀងឃ្លាតពីច្បាប់ដើម ដើម្បីជាប្រយោជន៍ដល់កុលបុត្តអ្នកជ្រះថ្លាក្នុងព្រះរតនត្រ័យ និងជាពិសេស ដើម្បីជាប្រយោជន៍ដល់ការសិក្សាផងខ្លួន ។

សូមសាធុជនទាំងឡាយ ដែលមានចិត្តភក្តីចំពោះព្រះរតនត្រ័យនោះ **អនុមោទនា** នូវបុណ្យរបស់ខ្ញុំ ដែលសម្រេចហើយដោយប្រការយ៉ាងនេះ ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាម **ខេត្ត-ក្រុង** ជាច្រើន នៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណាអាត្មាភាពបានសម្តែងព្រះធម៌នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗ កន្លែង ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥០ ប្រាក់ខ្មែរបាន ១៨.៤៩៥០០០ រៀល ( ១៨

លាន ៤ សែន ៩ ម៉ឺន ៥ ពាន់រៀល ) និងប្រាក់ដុល្លារ ៦៤៥ ដុល្លារសហរដ្ឋអាមេរិក ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុងប្រទេសឥណ្ឌា ដែលមានពុទ្ធបរិស័ទទៅ ប្រមាណ ៦៥ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ១០ ព្រះអង្គផងដែរ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅថ្វាយបង្គំបាន ៥១ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសក ឡាយ សុខុម និងឧបាសិកា ឱម លក្ខណា នៅក្នុង ព.ស. ២៥៥០ ( ១០.០២.២០០៧ ) ។

## នឹកឃើញស្រុកព្រះ

នឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្តា
សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្តា
ជ្រះថ្លាក្រៃលែង ។
៦៥ អង្គា គាល់ព្រះភគវា ៥១ កន្លែង
នៅស្រុកឥណ្ឌា ចងចាំមិនលែង សោមនស្សពន់ពេក
ក្នុង ព.ស. ២៥៥០ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥១ ផ្នែកខាងសម្តេចព្រះធម្មិ ដូចគ្នានឹង ព.ស. ២៥៥០ ផងដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល ( ១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់រៀល ) និងប្រាក់ដុល្លារ ៤៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណាអាត្មាភាព បានទៅថ្វាយបង្គំនៅ ពុទ្ធស្ថាន នានានៅក្នុង ប្រទេសស្រីលង្កា ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១២១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៤ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៩ កន្លែង ដោយបានការជួយជ្រោមជ្រែងឧបត្ថម្ភមកអំពីឧបាសក ឡាយ សុខុម និងឧបាសក សោម រតនៈ ឧបាសិកា ស៊ុំបវណ្ណា នៅក្នុងព.ស.២៥៥១ (០៤.០៤.២០០៨) ។

## នឹកឃើញលង្កា

នឹកឃើញលង្កា នឹកឃើញកាលណា ជ្រះថ្លាក្រៃលែង
នៅពុទ្ធស្ថាន ១៩ កន្លែង ដែលខ្ញុំបានស្វែង
ទៅថ្វាយបង្គំ ។

១២១ អង្គា គាល់ព្រះបាទា នាស្ថានមនោរម
លើសុមនកូដ ជេស្ឋាឧត្តម ជាកំពូលភ្នំ
ក្នុងប្រវត្តិពុទ្ធ ។

ទឹកដីលង្កា ទឹកដីអស្ចារ្យ ពេញពោរដោយឫទ្ធិ
នឹកឃើញកាលណា ជ្រះថ្លាក្រៃពិត ធម្មយាត្រាប្រណីត
ក្នុង ព.ស. ២៥៥១ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥២ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥១ ផងដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥២ ប្រាក់ខ្មែរបាន ២៧. ១២៨០០០ រៀល ( ២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់រៀល ) និងប្រាក់ដុល្លារ ១៩៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណាអាត្មាភាព បានទៅថ្វាយបង្គំនៅ ពុទ្ធស្ថាន នានានៅក្នុង ប្រទេសឥណ្ឌាជាលើកទីពីរ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស មានលោកគ្រូធម្មបណ្ឌិត រស់ សុផាត និងលោកគ្រូធម្មាចារ្យ អឿ សៅ ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ៦៧ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ

បានការឧបត្ថម្ភពីឧបាសក ឃឹត សុណាត ឧបាសិកា ហ៊ុន ម៉ារ៉ានី M.SUSOKUNORAetMmeINN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា អ៊ឹង រិទ្ធារី ឧបាសិកា សួន កល្យាណ ឧបាសិកា សួន ចរណៃ នៅក្នុង ព.ស.២៥៥២ ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង
ច្រើនពុទ្ធសកកាជ សាសនាអង្វែង ល្អហួសការថ្លែង
ឱ ! ព្រះសាសនា ។
នៅស្រុកឥណ្ឌា ៦៧ អង្គា រួមគ្នានមស្ការ
១០៩ ពុទ្ធស្ថាន ព្រមចិត្តផ្ចង់ថ្វា បីតិអស្ចារ្យ
ក្នុង ព.ស. ២៥៥២ ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុងប្រទេសស្រីលង្កាជាលើកទី ២ ដែលមានលោកគ្រូធម្មបណ្ឌិត រស់ សុផាត ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែល

មានពុទ្ធបរិស័ទទៅប្រមាណ ៣៦ នាក់ នៅក្នុងនោះទៀត ក៏មាន ព្រះសង្ឃ ៣ ព្រះអង្គផងដែរ បានការឧបត្ថម្ភពីឧបាសក ឆាយ អ៊ីវស៊ាង ឧបាសិកា ហុង គឹមសែ ក្រោមការជ្រោមជ្រែងពីឧបាសក យន្ត សួន នៅក្នុង ព.ស. ២៥៥២ ( ១១.០៣.២០០៩ ) ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៣ ផ្នែកខាងសម្ដែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥២ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៣ ប្រាក់ខ្មែរបាន ១៣.០៨០០០០ រៀល ( ១៣ លាន ០ សែន ៨ ម៉ឺន ) និងប្រាក់ដុល្លារ ២០៨ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅ ពុទ្ធស្ថាន នានានៅក្នុង ប្រទេសឥណ្ឌាជាលើកទី ៣ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១១១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៦ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៣ ( ២៥.០១.២០១០ ) ។

# ស្រណោះស្រុកព្រះ

ស្រណោះស្រុកព្រះ ធ្លាប់តែល្អល្អះ ឥឡូវអនិច្ចា !
យើងខ្ញុំទាំងឡាយ បានទៅនមស្ការ ស្ងប់ស្ងែងអស្ចារ្យ
ឱះ ឱ ! ពុទ្ធស្ថាន ។
នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន
១១១ អង្គា ៨៦ ពុទ្ធស្ថាន ព.ស.រាប់បាន
២៥៥៣ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៤ ផ្នែកខាងសម្តេចព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥៣ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៤ ប្រាក់ខ្មែរបាន ៣១.៩៩០០០០ រៀល ( ៣១ លាន ៩ សែន ៩ ម៉ឺន ) និងប្រាក់ដុល្លារ ៧២០ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅ ពុទ្ធស្ថាន នានានៅក្នុង ប្រទេសឥណ្ឌាជាលើកទី ៤ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១១១

នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៤ ( ២៧.០២.២០១១ ) ។

## គួរឱ្យសង្វេគ

គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន
ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែប្រាន
ប្រៀបបានព្រៃស្ងាត់ ។

២៧៧ អង្គា ប្រណម្យវន្ទា បង្គំថ្វាយថ្វាត់
បូជនីយដ្ឋាន ១២ នាដែនពុទ្ធរដ្ឋ ធម្មយាត្រាកំណត់
ក្នុងពុទ្ធសករាជ ២៥៥៤ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស.២៥៥៥ ផ្នែកខាងសម្តេចព្រះធម្មិ ដូចគ្នានឹង ព.ស. ២៥៥៤ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៥ ប្រាក់ខ្មែរបាន ៣៥.២៨២០០០ រៀល ( ៣៥ លាន ២ សែន ៨ ម៉ឺន ២ ពាន់រៀល ) និងប្រាក់ដុល្លារ ២៧៥៨ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀតគឺបុណ្យកុសលដែលខ្ញុំព្រះករុណាអាត្មា

កាព បានទៅថ្វាយបង្គំនៅ ពុទ្ធស្ថាន នានានៅក្នុង ប្រទេសឥណ្ឌា លើកទី ៥ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ៦៨ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៤ កន្លែងធំៗ បានការជ្រោមជ្រែងអំពីឧបាសិកា អ៊ឹងរិទ្ធារី នៅក្នុង ព.ស. ២៥៥៥ ( ០២.០២.២០១២ ) ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង ប្រទេសស្រីលង្កា លើកទី ៣ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១៤០ នាក់ នៅក្នុងនោះទៀត ក៏មាន ព្រះសង្ឃ ១៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩ កន្លែងធំៗ បានការជ្រោមជ្រែងពីឧបាសិកា អ៊ឹង រិទ្ធារី នៅក្នុង ព.ស. ២៥៥៥ ( ២៧.០៣.២០១២ ) ។

## បានយល់ស្រុកព្រះ

| | | |
|---|---|---|
| ជ្រះថ្លាខ្លាំងណាស់ | បានយល់ស្រុកព្រះ | ជាតិភូមិសាស្ត្រ |
| ១៤ កន្លែង | ៦៨ អង្គា | បានក្រាបវន្ទា |
| | បូជាគ្រប់ប្រាណ ។ | |
| សិរីលង្កា | ១៤០ អង្គា | ៩ ពុទ្ធស្ថាន |
| ជ្រះថ្លាខ្លាំងណាស់ | ដែលពួកខ្ញុំបាន | នមស្ការពុទ្ធស្ថាន |
| | ក្នុងពុទ្ធសករាជ ២៥៥៥ ។ | |

ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិសមហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស **យង់ សុង** ( ស្លាប់ ) និងញោមស្រី **ឈឹម ហយ** ( ស្លាប់ ) ម្យ៉ាងទៀត ញាតិកានៅក្នុងសង្សារវដ្ដ ជាពិសេសនោះ សូមលើកមហាកុសលទាំងអស់នេះ ជូនចំពោះលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** លោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **គាំ អ៊ីវ** ជាដើម សូមឲ្យបាននូវចំណែកបុណ្យកុសលនេះស្មើនឹងអាត្មាភាពផងដែរ សូម**អនុមោទនា !!!** ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗ គ្នា **សូមអនុមោទនា** នូវ

ចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាព ផងដែរ ។

ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគត កុំបីអាក់ខានឡើយ ( សូមឲ្យបានជាសាវកបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គណានីមួយ ដែលជាឯតទគ្គៈ ផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១ ) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូល បានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធ ទ្រង់ត្រាស់ថា នត្ថិ សន្តិ បរំ សុខំ ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៤

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម៉ី សាលួន ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ សឿង កុសល ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ គីម ម៉ានិត ជួយប្រែ

លោកអ្នកដ៏មានអាយុ ម៉ុន ប៊ូរ៉ា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ អ៊ឹម សុផាន ជួយប្រែ

លោកអ្នកដ៏មានអាយុ មាន វណ្ណនា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ ពេជ្រ ឧត្តម ជួយវាយកុំព្យូទ័រ

ឧបាសក អ៊ឹម វ៉ៃយ៉ា ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឡាន សុខុម ជួយប្រែ

ឧបាសក ជិម ជំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ប៊ូ ស៊ីជូ ជួយពិនិត្យអក្ខរាវិរុទ្ធ

# សមាជិកសមាគមធម្មទានអរិយទ្រព្យយង់សុផាត

សម្ដេចព្រះសង្ឃរាជគណមហានិកាយ **នន្ទ ង៉ែត** ជាប្រធានកិត្តិយស

ភិក្ខុ អគ្គបណ្ឌិតោ **យង់ សុផាត** ជាប្រធានសមាគម

លោកអភិបាលស្រុក **ស្រេង ស្រ៊ាង** ជាទីប្រឹក្សាសមាគម

ឧបាសក **អ៊ឹម វ៉ៃយ៉ា** ជាអនុប្រធានសមាគម

ឧបាសិកា **ង៉ែត យូអេង** ជាអនុប្រធានសមាគម

សាមណេរ **ម៉ី សាលួន** ជាលេខាធិការ

ឧបាសក **ឡាន សុខុម** ជាលេខាធិការរង

ឧបាសិកា **តាំង ប៉េងជីង** ជាហេរញ្ញិក

ឧបាសិកា **ជា នាង** ជាបេឡា

លោកគ្រូធម្មបណ្ឌិត **អៀ សៅ** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក **ឡាយ សុខុម** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **អ៊ុង វិទ្ធារី** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **ហោ ភាព** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **គួ ប៊ុនគាង** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **ឈុំ គីមហួយ** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ប៉ែន រមណីយ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឱម លក្ខណា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក អ៊ឹង ប៊ុនហួរ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា បួ ម៉ាឡា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ប៊ុន ហេង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ជុំ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា មាស ម៉ូនីកា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឡឹក ពេញចិត្ត សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា សៀក ឆាយគីម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក បញ្ញា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា កែវ កល្យាណ ជាសមាជិកសកម្ម

ឧបាសិកា ឡេង ធីតា ជាសមាជិកសកម្ម

ឧបាសិកា ម៉ៅ នី ជាសមាជិកសកម្ម

ឧបាសិកា ហេង ចន្ទបុញ្ញាវតី ជាសមាជិកសកម្ម

ឧបាសក ហុង សុវណ្ណារិទ្ធ ជាសមាជិកសកម្ម

ឧបាសក ហុង សុវណ្ណារ៉េត ជាសមាជិកសកម្ម

# មាតិកា

# សីលនិទ្ទេស

មាតិកា លេខទំព័រ


១. អត្ថនៃបញ្ហាព្យាករណ៍ ..................................... ១

២. សីលនិទ្ទេស ................................................ ៨៣

សំវរ ៥ ......................................................... ៨៤

លក្ខណាទិចតុក:របស់សីល .......................... ៨៧

៣. អានិសង្សរបស់សីល ..................................... ១០៦

៤. ប្រភេទរបស់សីល ........................................ ១១៥

៥. បាតិមោក្ខសំវរសីល ...................................... ១៥១

អាចារ-អនាចារ ............................................. ១៦១

គោចរ ៣ ....................................................... ១៦៦

៦. ឥន្ទ្រិយសំវរសីល ........................................ ១៨៧

៧. អាជីវបារិសុទ្ធិសីល ...................................... ២០៩

៨. បច្ចយសន្និស្សិតសីល .................................... ២៤៦

៩. ហេតុឲ្យសីលសម្រេចដល់ព្រម ........................ ២៩១

១០. សីលពួក ៥ ទី ១ ........................................ ៣៤៧

១១. សីលពួក ៥ ទី ២ ........................................ ៣៦៣

១២. ភាពសៅហ្មង និងផូរផង់នៃសីល .................. ៣៨៦

១៣. មេថុនសំយោគ ៧ ........................................ ៣៨៧

១៤. ទោសនៃសីលវិបត្តិ ........................................ ៣៩៣

## ធុតង្គនិទ្ទេស

១៥. ធុតង្គនិទ្ទេស ................................................ ៤២០

លក្ខណាទិចតុក:របស់ធុតង្គ.............................. ៤២៨

អំពីការសមាទានធុតង្គ .................................. ៤២៨

១៦. បង្សុកូលិកង្គ ................................................ ៤៤១

១៧. តេចីវរិកង្គ ................................................ ៤៥៦

១៨. បិណ្ឌបាតិកង្គ ................................................ ៤៦៣

១៩. សបទានចារិកង្គ ................................................ ៤៧៤

២០. ឯកាសនិកង្គ ................................................ ៤៨១

២១. បត្តបិណ្ឌិកង្គ ................................................ ៤៨៨

២២. ខលុបច្ឆាភត្តិកង្គ .............................................. ៤៩៤

២៣. អារញ្ញិកង្គ ...................................................... ៤៩៩

២៤. រុក្ខមូលិកង្គ .................................................... ៥០៩

២៥. អព្ភោកាសិកង្គ ................................................. ៥១៦

២៦. សោសានិកង្គ .................................................... ៥២៤

២៧. យថាសន្ថតិកង្គ ............................................... ៥៣៤

២៨. នេសជ្ជិកង្គ ..................................................... ៥៤០

២៩. បកិណ្ណកកថាទាក់ទងធុតង្គ .............................. ៥៤៦


.......................

# វិសុទ្ធិមគ្គ

## និង

# បរមត្ថមញ្ជូសាមហាដីកា

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស*

...............

## ពណ៌នាអត្ថនៃបញ្ហាព្យាករណ៍

*ភិក្ខុដែលជាអ្នកឆ្លាត មានសេចក្ដីព្យាយាម មានបញ្ញាជាគ្រឿងរក្សាខ្លួនតាំងនៅក្នុងសីលហើយ អប់រំចិត្តនិងបញ្ញា គប្បីស្រាងនូវគ្រឿងចាក់ស្រែះនេះបាន ពាក្យនេះព្រះមានព្រះភាគទ្រង់ត្រាស់ទុក ។*

*ហេតុអ្វី ទើបទ្រង់ត្រាស់ពាក្យនេះទុក ?*

*បានឮថា ទេវបុត្តមួយអង្គបានចូលគាល់ព្រះមានព្រះភាគ កាលទ្រង់គង់នៅក្រុងសាវត្ថី ក្នុងមជ្ឈិមយាម ទូលសួរនូវបញ្ហានេះ ដើម្បីដោះនូវការសង្ស័យរបស់ខ្លួនថា ធម្មជាតិម្យ៉ាងដែលជាគ្រឿងចាក់ស្រែះទាំងខាងក្នុង ទាំងខាងក្រៅ ប្រជាត្រូវគ្រឿងចាក់ស្រែះនោះរួបរឹតហើយ បពិត្រព្រះគោតម ព្រោះហេតុនោះ ខ្ញុំម្ចាស់សូមទូលសួរព្រះអង្គថា នរណាអាចស្រាងនូវគ្រឿងចាក់ស្រែះនេះបាន ។*

ការអត្ថាធិប្បាយនៃបញ្ហានោះមានដូចតទៅនេះ :

ពាក្យថា **គ្រឿងចាក់ស្រែះ** នេះ ជាឈ្មោះរបស់តណ្ហា ដែលជាធម្មជាតិដូចអន្ទាក ពិតហើយ តណ្ហានោះឈ្មោះថា **គ្រឿងចាក់ស្រែះ** ព្រោះដូចជាព្រៃក្រាស់ ពោល គឺគ្រឿងទាក់របស់ដើមឈេ (ដែលមានមែកដូចជាសំណាញ់) ទាំងឡាយ មានឫស្សីជាដើម ដោយអត្ថថា រួបរឹត ព្រោះកើតឡើងរឿយៗ ក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ប្រព្រឹត្តទៅទាំងក្នុងអារម្មណ៍ថ្នាក់ទាប ទាំងក្នុងអារម្មណ៍ថ្នាក់ខ្ពស់ ។

**តណ្ហានោះ** ទេវបុត្រហៅថា **គ្រឿងចាក់ស្រែះទាំងខាងក្នុង គ្រឿងចាក់ស្រែះទាំងខាងក្រៅ** ព្រោះវាកើតឡើងទាំងបរិក្ខាររបស់ខ្លួន និងបរិក្ខាររបស់អ្នកដទៃ ទាំងអត្តភាពរបស់ខ្លួន ទាំងអត្តភាពរបស់អ្នកដទៃ ទាំងក្នុងអាយតនៈខាងក្នុង ទាំងក្នុងអាយតនៈខាងក្រៅ **ប្រជា** ដែលគ្រឿងចាក់ស្រែះ (គឺតណ្ហា) កើតឡើងហើយ រមែងរួបរឹត មានន័យថា **ប្រជា** ពោល គឺពួកសត្វទាំងអស់ ដែលគ្រឿងចាក់ស្រែះ គឺតណ្ហានោះរួបរឹត គឺចងរឹតទុក ដូចជាដើមឈើដែលស្ទុកទាំងឡាយ មានដើមឫស្សីជាដើម, គ្រឿងចាក់ស្រែះ មានព្រៃឫស្សីជាដើម រួបរឹតយ៉ាងនេះ ព្រោះថា ពួកសត្វដែលគ្រឿងចាក់ស្រែះ គឺតណ្ហារួបរឹតហើយយ៉ាងនេះ បពិត្រព្រះគោតម ព្រោះហេតុនោះ ខ្ញុំម្ចាស់សូមទូលសួរ

ព្រះអង្គ ក្នុងន័យថា **តំ តំ គោតម បុច្ឆាមិ** មានន័យថា ព្រោះហេតុនោះ ខ្ញុំម្ចាស់សូមទូលសួរព្រះអង្គ ។ ទេវបុត្តទូលចេញព្រះនាមរបស់ព្រះមានព្រះភាគ ដោយព្រះគោត្ត **គោតម** ក្នុងន័យថា នរណាអាចគ្គារគ្រឿងចាក់ស្រែះនេះបាន គឺទេវបុត្តទូលសួរថា នរណានឹងគប្បីគ្គារ គឺនរណាអាចនឹងគ្គារនូវគ្រឿងចាក់ស្រែះនេះ ដែលរួបរឹតត្រៃ (លោក) ធាតុ ឲ្យតាំងនៅយ៉ាងនេះបាន ។

ចំណែកឯព្រះមានព្រះភាគ ជ្រាបដោយព្រះញាណមិនមានអ្វីទើសទាក់ក្នុងធម៌ទាំងពួង ជាទេពនៃទេព ជាទេពក្រៃលែងជាងទេព ជាសក្កៈក្រៃលែងជាងសក្កៈ ជាព្រហ្មក្រៃលែងជាងព្រហ្ម ជាអ្នកមោះមុតដោយវេសារជ្ជញាណ ៤ ជាអ្នកដែលទ្រទ្រង់ទុកនូវទសពលញាណ ទ្រង់មានព្រះញាណ រកគ្រឿងទើសទាក់ មិនមាន ទ្រង់មានសមន្តចក្ខុ កាលទេវបុត្តទូលសួរយ៉ាងនេះហើយ កាលនឹងវិសជ្ជនាសេចក្តីនោះ ដល់ទេវបុត្តនោះ ទើបត្រាស់ព្រះគាថានេះថា **ភិក្ខុដែលជាអ្នកឆ្លាត មានសេចក្តីព្យាយាម មានបញ្ញាជាគ្រឿងរក្សាខ្លួន តាំងនៅក្នុងសីលហើយ អប់រំចិត្ត និងបញ្ញានោះ គប្បីគ្គារនូវគ្រឿងចាក់ស្រែះនេះបាន** ដូច្នេះ ។

ឥឡូវនេះខ្ញុំម្ចាស់ កាលនឹងពណ៌នាខ្លឹមសារដែលប្រកបដោយគុណផ្សេងៗមានសីលជាខាងដើមនៃព្រះគាថាដែលទ្រង់ជាអ្នកស្វែង

រកនូវគុណដ៏ធំ ត្រាស់ហើយដោយប្រពៃ ទើបពោលនូវវិសុទ្ធិមគ្គ ដែលអាស្រ័យន័យនៃទេសនារបស់ព្រះថេរៈនៅឯមហាវិហារ ដែលមានការវិនិច្ឆ័យយ៉ាងហ្មត់ចត់ល្អ ជាគ្រឿងបង្កើតឡើងនូវបាមោជ្ជដល់ព្រះយោគីទាំងឡាយក្នុងព្រះពុទ្ធសាសនានេះ ដែលបានបព្វជ្ជាក្នុងសាសនានៃព្រះជិនស្រីជាម្ចាស់ដោយកម្រ ហើយបើមិនបានដឹងនូវវិសុទ្ធិមគ្គ ដែលត្រង់ ដែលក្សេម ប្រមូលមកនូវគុណ មានសីលជាដើម ឲ្យបានត្រឹមត្រូវ សូម្បីប្រាថ្នានូវសេចក្តីបរិសុទ្ធិ សូម្បីព្យាយាមក៏មិនសម្រេចនូវវិសុទ្ធិនោះបានឡើយ ។

ហៃ! សាធុជនទាំងឡាយ ពេលខ្ញុំម្ចាស់ពោលនូវវិសុទ្ធិមគ្គ ដោយគោរព សូមអ្នកទាំងឡាយ ដែលប្រាថ្នានូវវិសុទ្ធិ ចូរតាំងចិត្តស្តាប់នូវវិសុទ្ធិមគ្គនោះ ដោយគោរពផងចុះ ។

បទថា **វិសុទ្ធិ** ក្នុងពាក្យថា ខ្ញុំម្ចាស់នឹងពោលនូវវិសុទ្ធិមគ្គនោះ គប្បីជ្រាបថា សំដៅយកព្រះនិព្វានដែលប្រាសចាកមន្ទិលទាំងពួង ដែលបរិសុទ្ធពិត ផ្លូវនៃសេចក្តីបរិសុទ្ធិនោះឯង ឈ្មោះថា **វិសុទ្ធិមគ្គ** ឧបាយជាគ្រឿងសម្រេច លោកហៅថា ផ្លូវ ខ្ញុំម្ចាស់នឹងសម្តែងផ្លូវនៃវិសុទ្ធិនោះ ។

ដូចក្នុងព្រះបាលីកន្លែងខ្លះ ទ្រង់សម្តែងទាក់ទងដោយធម៌ត្រឹមវិបស្សនាតែម្យ៉ាង ដូចដែលត្រាស់ថា កាលបុគ្គលឃើញដោយបញ្ញា

ថា សង្ខារទាំងពួងមិនទៀង ពេលនោះ គេរមែងនឿយណាយក្នុងទុក្ខ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធិ ។កន្លែងខ្លះទ្រង់សម្ដែងទាក់ទងដល់ឈាន និងបញ្ញា ដូចជាទ្រង់ត្រាស់ថា ឈានរមែងមិនមានដល់អ្នកដែលមិនមានបញ្ញា បញ្ញារមែងមិនមានដល់អ្នកដែលមិនមានឈាន, ឈាននិងបញ្ញា រមែងមាននៅក្នុងបុគ្គលណា បុគ្គលនោះជាអ្នកនៅជិតព្រះនិព្វាន ។

កន្លែងខ្លះទ្រង់សម្ដែងទាក់ទងដោយធម៌ មានកម្មជាដើម ដូចទ្រង់ត្រាស់ថា មច្ចៈ ទាំងឡាយរមែងបរិសុទ្ធដោយធម៌ ៥ ប្រការ គឺ កម្ម វិជ្ជា ធម្ម សីល និងជីវិតដ៏ឧត្ដម មិនមែនដោយគោត្ត ឬដោយទ្រព្យឡើយ ។

កន្លែងខ្លះទ្រង់សម្ដែងទាក់ទងដោយធម៌ មានសីលជាដើម ដូចដែលត្រាស់ទុកថា ភិក្ខុបរិបូរដោយសីល មានចិត្តតាំងមាំល្អហើយ មានបញ្ញា មានសេចក្ដីព្យាយាមប្រារព្ធហើយ មានខ្លួនបញ្ជូនទៅហើយគ្រប់កាលទាំងពួង រមែងឆ្លងឱឃៈ ដែលឆ្លងបានដោយកម្រ ។

កន្លែងខ្លះទ្រង់សម្ដែងទាក់ទងដោយពោធិបក្ខិយធម៌ មានសតិប្បដ្ឋានជាដើម ដូចបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះជាផ្លូវតែមួយ តែងប្រព្រឹត្តទៅព្រម ដើម្បីសេចក្ដីបរិសុទ្ធិនៃសត្វទាំងឡាយ ។ល។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះគឺអ្វី គឺសតិប្បដ្ឋាន ៤

ស្ដូម្បីក្នុងពោធិបក្ខិយធម៌ដទៃ មានសម្មប្បធានជាដើម ក៏មានន័យដូចគ្នា តែក្នុងបញ្ហាព្យាករណ៍នេះផ្លូវនៃវិសុទ្ធិនោះទ្រង់សម្ដែងទាក់ទងនឹងត្រៃសិក្ខាមានសីលជាដើម នេះជាសេចក្ដីពណ៌នាដោយសង្ខេបក្នុងគាថានេះ ។

ពាក្យថា **សីលេ បតិដ្ឋាយ** ប្រែថា តាំងនៅក្នុងសីល ភិក្ខុជាអ្នកធ្វើសីលឲ្យបរិបូណ៌នោះ ហៅថា ជាអ្នកតាំងនៅក្នុងសីលក្នុងទីនេះ ព្រោះដូច្នោះ ខ្លឹមសារក្នុង **សីលេ បតិដ្ឋាយ** គឺមានន័យថា តាំងនៅក្នុងសីលដោយធ្វើសីលឲ្យបរិបូណ៌ ។

បទថា **នរោ** បានដល់ សត្វ ។

បទថា **សបញ្ញោ** មានន័យថា មានបញ្ញា ជាបញ្ញាមានព្រមជាមួយបដិសន្ធិត្រៃហេតុកើតពីកម្ម ។ ពាក្យថា **ចិត្តំ បញ្ញញ្ច ភាវយំ** មានន័យថា ញុំាងសមាធិ និងវិបស្សនាឲ្យចម្រើន ពិតហើយ ក្នុងពាក្យនេះ សមាធិទ្រង់សម្ដែងដោយមាតិកា គឺចិត្ត ចំណែកវិបស្សនាទ្រង់សម្ដែងដោយមាតិកា គឺបញ្ញា ដូច្នេះ ។

បទថា **អាតាបី** ប្រែថាមានការព្យាយាម ការព្យាយាមលោកហៅថា **អាតាប** ព្រោះអត្ថថា ជាហេតុដុតនូវកិលេសឲ្យក្ដៅ សេចក្ដីព្យាយាមជាហេតុដុតកម្ដៅនូវកិលេសរបស់ភិក្ខុនោះមានហើយ ហេតុនោះ ភិក្ខុនោះទើបឈ្មោះថា **អាតាបី** ( អ្នកមានសេចក្ដីព្យាយាម

ជាគ្រឿងដុតកម្តៅនូវកិលេស ) ។

**បញ្ញា** លោកហៅថា **នេបក** ក្នុងពាក្យថា **និបកោ** មានន័យថា អ្នកប្រកបដោយបញ្ញានោះ ព្រះសាស្តាសម្តែងនូវបារិហារិយប្បញ្ញា ដោយបទនេះ ក្នុងបញ្ហាព្យាករណ៍នោះ បញ្ញាមាន ៣ យ៉ាង គឺ

**១- សជាតិប្បញ្ញា** ( បញ្ញាមានពីកំណើត ) ។

**២- វិបស្សនាបញ្ញា** ។

**៣- បារិហារិយប្បញ្ញា** ( បញ្ញាបរិហារ ) ដែលជាអ្នកនាំក្នុងកិច្ចគ្រប់យ៉ាង ។

បទថា**ភិក្ខុ**មានវិគ្រោះថា អ្នកណារមែងឃើញភ័យក្នុងសង្សារ ហេតុនោះ អ្នកនោះ ទើបឈ្មោះថា ភិក្ខុ ។ បទចុងក្រោយថា **សោ ឥមំ វិជដយេ ជដំ** មានន័យថា ភិក្ខុនោះ គឺភិក្ខុដែលប្រកបដោយធម៌ ៦ ប្រការ មានដោយសីល ដោយសមាធិ ដែលសម្តែងចេញជាមាតិកា គឺចិត្ត ដោយបញ្ញា ៣ ប្រការនេះ និងដោយសេចក្តីព្យាយាមដុតកិលេស ឈរនៅលើផែនដី គឺសីល ហើយលើកសស្រ្តា គឺវិបស្សនាបញ្ញាដែលសំលៀងល្អហើយដោយសិលាគឺសមាធិដោយដៃ គឺបារិហារិយប្បញ្ញា ដោយកម្លាំង គឺវីរិយៈមាំទាំហើយ គប្បីផ្តារ គឺគប្បីកាត់ ទម្លាយនូវគ្រឿងចាក់ស្រេះ គឺតណ្ហា ដែលមានហើយនៅក្នុងសន្តានរបស់ខ្លួននោះទាំងអស់បាន ប្រៀបដូចជាបុរសដែល

ឈរនៅលើផែនដី លើកសស្ត្រាដែលសំលៀងល្អហើយ ក្តារនូវគុម្ព ឫស្សីធំដូច្នោះ ក្នុងខណៈនៃមគ្គ ភិក្ខុនោះ ឈ្មោះថា កំពុងក្តារនូវគ្រឿងចាក់ស្រែះនោះឯង ក្នុងខណៈនៃផល ឈ្មោះថា ក្តារគ្រឿងចាក់ស្រែះនោះរួចហើយរមែងជាអគ្គទក្ខិណេយ្យបុគ្គលរបស់មនុស្សលោក ព្រមទាំងទេវលោក ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់ថា

**ភិក្ខុដែលជាអ្នកឆ្លាត មានសេចក្តីព្យាយាម មានបញ្ញារក្សាខ្លួន តាំងនៅក្នុងសីលហើយអប់រំចិត្ត និងបញ្ញានោះ គប្បីក្តារនូវគ្រឿងចាក់ស្រែះនេះបាន ។**

ព្រះមានជោគត្រាស់ទុកក្នុងព្រះគាថានោះថា ជាអ្នកឆ្លាតដោយបញ្ញាណា កិច្ចនោះដែលគប្បីធ្វើក្នុងបញ្ញានោះក៏ទេ ព្រោះបញ្ញានោះសម្រេចដល់គេដោយអានុភាពនៃបរិកម្មហើយតែម្យ៉ាង តែអ្នកនោះគប្បីជាអ្នកធ្វើជាប់តគ្នាដោយអំណាចនៃវីរិយៈជាអ្នកធ្វើដោយអំណាចនៃការដឹងដ៏ប្រពៃ ដោយអំណាចនៃបញ្ញា ទ្រង់ត្រាស់ទុកក្នុង ២ បទថា **អតាបី និបកោ** នោះតាំងនៅក្នុងសីលហើយ អប់រំសមថ និងវិបស្សនា ទ្រង់ត្រាស់ដោយអំណាចចិត្ត និងបញ្ញានោះ ព្រះសាស្តាជាម្ចាស់ សម្តែងនូវផ្លូវនៃវិសុទ្ធិនេះ ដោយចំពោះ គឺ **សីល សមាធិ** និង **បញ្ញា** ក្នុងព្រះគាថានោះ ដូច្នេះឯង ។

ឯព្រះធម៌ទេសនាត្រឹមប៉ុណ្ណេះ ព្រះពុទ្ធអង្គទ្រង់បានប្រកាស :

១- សិក្ខា ៣ ។

២- សាសនាមានលំអ ៣ យ៉ាង ។

៣- ឧបនិស្ស័យនៃគុណវិសេស មានភាពជាអ្នកបាននូវវិជ្ជា ៣ ជាដើម ។

៤- ការវៀរចាកនូវទីបំផុត ២ យ៉ាង និងការសេពនូវមជ្ឈិមាបដិបទា ។

៥- ឧបាយជាគ្រឿងកន្លងចាកគតិ មានអបាយជាដើម ។

៦- ការលះបង់នូវកិលេសដោយអាការ ៣ ។

៧- ធម៌ជាបដិបក្ខដល់ទោសមាន វីតិក្កម ជាដើម ។

៨- ការជម្រះសង្កិលេស ៣ ។

៩-ហេតុនៃភាពជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម

សួរថា ទ្រង់ប្រកាសដូចម្ដេច ?

ឆ្លើយថា ក្នុងបញ្ហាកម្មនេះ **អធិសីលសិក្ខា** ទ្រង់ប្រកាសដោយសីល, **អធិចិត្ត សិក្ខា** ទ្រង់ប្រកាសដោយសមាធិ, **អធិប្បញ្ញាសិក្ខា** ទ្រង់ប្រកាសដោយបញ្ញា ។

ម្យ៉ាងទៀត លម្អបទដើមនៃព្រះសាសនា ទ្រង់ប្រកាសដោយសីល ពិតហើយ សីល ឈ្មោះថា ខាងដើមនៃព្រះសាសនា ព្រោះព្រះបាលីថា **អ្វីឈ្មោះថាខាងដើមនៃកុសលទាំងឡាយ** ឆ្លើយថា សីល

ដែលបរិសុទ្ធល្អហើយ ឈ្មោះថា ខាងដើមនៃកុសលធម៌ទាំងឡាយ និងព្រោះព្រះបាលី ( ឱវាទបាតិមោក្ខ ក្នុងសេចក្តីខាងដើម ) សម្តែងថា **ការមិនធ្វើបាបទាំងពួង** ដូច្នេះជាដើម, ឯសីលនោះ ឈ្មោះថា ល្អាត ព្រោះជាហេតុនាំមកនូវគុណ មានការមិនក្តៅក្រហាយជាដើម ។

លម្អបទកណ្តាល ទ្រង់ប្រកាសដោយសមាធិ ពិតហើយ សមាធិ ឈ្មោះថា ជាគុណក្នុងលម្អបទកណ្តាលនៃព្រះសាសនា ព្រោះព្រះបាលី ( ឱវាទបាតិមោក្ខ សេចក្តីកណ្តាល ) ពោលថា **ការញ៉ាំងកុសលធម៌ឲ្យដល់ព្រម** ដូច្នេះជាដើម, សមាធិនោះឈ្មោះថា ល្អាត ព្រោះជាហេតុនាំមកនូវគុណ មានឥទ្ធិវិធីជាដើម ភាពល្អាតក្នុងលម្អបទចុងដែលទ្រង់ប្រកាសដោយបញ្ញា គឺបញ្ញា ឈ្មោះថា ជាទីបំផុតនៃសាសនា ព្រោះព្រះបាលី ( ឱវាទបាតិមោក្ខ សេចក្តីខាងចុង ) ពោលទុកថា **ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ** ដូច្នេះ និងព្រោះព្រះពុទ្ធសាសនាមានបញ្ញាជាគុណយ៉ាងក្រៃលែង, បញ្ញានោះ ឈ្មោះថា ល្អាតល្អ ព្រោះជាហេតុនាំមកនូវភាពជាអ្នកមាំទាំក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ សមដូចព្រះពុទ្ធដីកាត្រាស់ទុកថា

*ភ្នំថ្មតាន់រមែងមិនកម្រើក ព្រោះខ្យល់យ៉ាងណា បណ្ឌិតទាំងឡាយ រមែងមិនកម្រើកព្រោះនិន្ទា និងសរសើរ ក៏ដូច្នោះដែរ*

ម្យ៉ាងទៀត ឧបនិស្ស័យនៃអ្នកបាននូវវិជ្ជា ៣ ក៏ទ្រង់ប្រកាសដោយសីល ព្រោះបុគ្គលអាស្រ័យនូវសីលសម្បត្តិ ទើបសម្រេចនូវវិជ្ជា ៣ បាន មិនមែនអាស្រ័យនូវហេតុដទៃនោះទេ, ឧបនិស្ស័យនៃភាពជាអ្នកបានអភិញ្ញា ៦ ទ្រង់ប្រកាសដោយសមាធិ ព្រោះបុគ្គលអាស្រ័យនូវសមាធិសម្បត្តិទើបសម្រេចអភិញ្ញា ៦ បាន នឹងបានអាស្រ័យហេតុដទៃក្រៅពីសមាធិនោះក៏ទេ ឧបនិស្ស័យនៃការបែកធ្លាយក្នុងបដិសម្ភិទា ទ្រង់ប្រកាសដោយបញ្ញា ព្រោះបុគ្គលអាស្រ័យនូវបញ្ញាសម្បត្តិ ទើបសម្រេចនូវបដិសម្ភិទា ៤ បាន មិនមែនដោយហេតុដទៃទេ ។

ម្យ៉ាងទៀត ការវៀរចាកនូវទីបំផុត គឺកាមសុខល្លិកានុយោគ ទ្រង់ប្រកាស ដោយសីល ការវៀរចាកនូវទីបំផុត គឺអត្តកិលមថានុយោគ ទ្រង់ប្រកាសដោយសមាធិ ការសេពនូវមជ្ឈិមាបដិបទា ទ្រង់ប្រកាសដោយបញ្ញា ។

ដូចគ្នាដែរ ឧបាយជាគ្រឿងឈានកន្លងអបាយ ទ្រង់ប្រកាសដោយសីល ឧបាយជាគ្រឿងឈានកន្លងកាមធាតុ ទ្រង់ប្រកាសដោយសមាធិ ឧបាយជាគ្រឿងឈានកន្លងភព ទ្រង់ប្រកាសដោយបញ្ញា ។ ការលះបង់កិលេសដោយអំណាចតទង្គប្បហាន ទ្រង់ប្រកាសដោយសីល ការលះបង់កិលេសដោយអំណាចវិក្ខម្ភនប្បហាន ទ្រង់ប្រកាសដោយសមាធិ ការលះបង់កិលេស ដោយអំណាចសមុច្ឆេទប្បហាន

ទ្រង់ប្រកាសដោយបញ្ញា ។

ម្យ៉ាងទៀត ធម៌ដែលជាបដិបក្ខដល់វីតិក្កម ( ការកន្លងល្មើសតាមកាយវាចា ) នៃកិលេស ទ្រង់ប្រកាសដោយសីល ធម៌ដែលជាបដិបក្ខដល់បរិយុដ្ឋាន ( ការរុំព័ទ្ធចិត្ត ) នៃកិលេស ទ្រង់ប្រកាសដោយសមាធិ ធម៌ដែលជាបដិបក្ខដល់អនុស័យ ( គ្រឿងដេកត្រាំនៅក្នុងចិត្ត ) នៃកិលេស ទ្រង់ប្រកាសដោយបញ្ញា ។ ការជម្រះសង្កិលេស គឺទុច្ចរិត ទ្រង់ប្រកាសដោយសីល ការជម្រះសង្កិលេស គឺតណ្ហា ទ្រង់ប្រកាសដោយសមាធិ ការជម្រះសង្កិលេស គឺទិដ្ឋិ ទ្រង់ប្រកាសដោយបញ្ញា ។

តាមន័យនោះ ហេតុនៃភាពជាព្រះសោតាបន្ន និងព្រះសកទា-គាមិបុគ្គល ទ្រង់ប្រកាសដោយសីល, ភាពជាព្រះអនាគាមី ទ្រង់ប្រកាសដោយសមាធិ, ភាពនៃព្រះអរហន្ត ទ្រង់ប្រកាសដោយបញ្ញា ព្រោះថា ព្រះសោតាបន្ន ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ព្រះសកទាគាមី ក៏ដូចគ្នា ចំណែកព្រះអនាគាមី ទ្រង់ត្រាស់ថា ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ព្រះអរហន្ត ទ្រង់ត្រាស់ថា ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងបញ្ញា ។

ដោយព្រះធម្មទេសនាត្រឹមប៉ុណ្ណោះ ទ្រង់ប្រកាសនូវគុណ ៩ យ៉ាង គឺ

១- សិក្ខា ៣ ។

២- សាសនាមានលម្អ ៣ យ៉ាង ។

៣- ឧបនិស្ស័យនៃគុណវិសេស មានភាពជាអ្នកបាននូវវិជ្ជា ៣ ជាដើម ។

៤- ការវៀរចាកនូវផ្លូវខុស ២ យ៉ាង និងការសេពនូវមជ្ឈិមាបដិបទា ។

៥- ឧបាយជាគ្រឿងកន្លងផុតពីគតិ មានអបាយជាដើម ។

៦- ការលះបង់កិលេស មានដោយអាការ ៣ ។

៧- ធម៌ដែលជាបដិបក្ខដល់ទោស មានវីតិក្កមៈជាដើម ។

៨- ការជម្រះសង្កិលេស ៣ ។

៩- ហេតុនៃភាពជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម

ម្យ៉ាងទៀត គុណពួក ៣ ដទៃៗ ទៀតមាន ( កាយវិវេកដោយសីល ចិត្តវិវេកដោយសមាធិ ឧបធិវិវេកដោយបញ្ញា ) ក៏ទ្រង់ប្រកាសផងដែរ ដោយប្រការ ដូច្នេះ ។

( ចប់ ពាក្យនិទាន )

# មហាដីកា

## ពណ៌នាកថាពោលដោយពាក្យនិទាន

ព្រះវិសុទ្ធិមគ្គនេះលោកអាចារ្យអាស្រ័យបទព្រះសូត្រ បានផ្ដើមតាំងទុកហើយ ដើម្បីនឹងលើកព្រះសូត្រនោះតាំងឡើងទុកជាមុនហើយពណ៌នាសេចក្ដី ដោយប្រការផ្សេងៗ ដោយមាតិកា គឺការអធិប្បាយនូវពាក្យនិទានជាខាងដើមនៃព្រះវិសុទ្ធិមគ្គនោះ ក៏ផ្ដើមពាក្យមានជាអាទិ៍ថា **សីលេ បតិដ្ឋាយ** ដូច្នេះ ។

ពិតហើយ លោកអាចារ្យកាលនឹងពណ៌នាព្រះធម៌ គប្បីពោលនូវពាក្យដែលជានិទាននៃព្រះធម៌នោះជាខាងដើម បន្ទាប់ពីនោះគួរពោលនូវប្រយោជន៍ ការរួបរួមសេចក្ដីនៃបទ សេចក្ដីសម្ពន្ធ គោលបំណងពាក្យសួរ ពាក្យឆ្លើយ ព្រមទាំងលោកអាចារ្យក៏បានបដិបត្តិហើយ យ៉ាងនោះឯង ។

ក្នុងអធិការនេះ ពាក្យថា **ភគវន្តំ កិរ** ជាដើម ជាពាក្យអធិប្បាយនូវពាក្យ និទាន និងជាប្រយោជន៍នៃទេសនា ។

ពាក្យថា **វិសុទ្ធិមគ្គំ ភាសិស្សំ** ជាដើម ជាពាក្យអធិប្បាយសេចក្ដីរួម ។

ពាក្យថា **សីលេ បត្វា** ជាដើម ជាពាក្យអធិប្បាយសេចក្ដីចំពោះ

បទនៃសេចក្តី សម្ពន្ធ និងគោលបំណង ។

ពាក្យថា កឹ សីលំ ជាដើម ជាពាក្យសួរ, បន្ទាប់ពីនោះជាពាក្យឆ្លើយ សូម្បីក្នុងសមាធិកថា និងបញ្ញាកថា ក៏មានន័យដូចគ្នា ។

មានពាក្យសួរមកថា ហេតុអ្វី ក្នុងព្រះវិសុទ្ធិមគ្គនេះ លោកអាចារ្យលើកព្រះគាថា វិសជ្ជនា ឡើងទុកជាខាងដើម មិនលើកព្រះគាថា បុច្ឆា ទុកជាខាងដើម ព្រោះពាក្យវិសជ្ជនាមានពាក្យបុច្ឆាជាខាងដើម... ។

រឿងនេះសូមឆ្លើយដូច្នេះ គប្បីជ្រាបថា ព្រោះសេចក្តីនៃព្រះគាថាវិសជ្ជនានោះជាមង្គល ១, ព្រោះសម្តែងសេចក្តីនៃព្រះសាសនាមានលម្អបទដើមជាដើម ១, ព្រោះកម្ចាត់នូវអន្តរាយដោយការហាមនូវឧបទ្រវៈ មានភ័យជាដើម ១ និងព្រោះរួបរួមធម៌ដែលគប្បីពណ៌នាតទៅ ១ ។

ក្នុងអធិការនេះ អាចារ្យអ្នកសួរពោលថា ព្រោះហេតុអ្វី ការពោលវិសុទ្ធិមគ្គនេះ បានជាលោកអាចារ្យផ្តើមរឿងរ៉ាវឡើងមុន មិនបានផ្តើមអំពីការលើកសរសើរព្រះសាស្តាមុន ? សេចក្តីនេះសូមឆ្លើយថា ព្រោះព្រះវិសុទ្ធិមគ្គនេះ មិនមែនជាកថាពណ៌នាចំពោះព្រះគម្ពីរខាងដើមនោះទេ ។ ពិតហើយ វិសុទ្ធិមគ្គកថា នេះមិនមែនជាការពណ៌នាចំពោះព្រះគម្ពីរនៃនិកាយទាំងឡាយ មានទីឃនិកាយជាដើម

ដូចជាអដ្ឋកថាទាំងឡាយ មានសុមង្គលវិលាសិនីជាដើមនោះទេ ។

ម្យ៉ាងទៀត មិនមែនជាបករណ៍ដទៃ ដូចជាគម្ពីរអភិធម្មាវតា និង **សុមតាវតា** ជាដើម ។ ប៉ុន្តែជាការពណ៌នាអធិប្បាយពិសេសរបស់អដ្ឋកថាទាំងឡាយ មាន **សុមង្គលវិលាសិនី** ជាដើម ។ ព្រោះហេតុនោះឯង លោកអាចារ្យក៏ពោលពាក្យជាដើមថា វិសុទ្ធិមគ្គជាផ្លូវកណ្តាល ដូច្នេះ ។

ម្យ៉ាងទៀត គប្បីឃើញថា ព្រះវិសុទ្ធិមគ្គនេះ ជាកថាដែលផ្តើមដោយការលើកសរសើរក៏បាន មិនមែនផ្តើមដោយការលើករឿងរ៉ាវតែម្យ៉ាងនោះទេ ។

ពិតហើយ ការសម្តែងរឿងរ៉ាវក្នុងព្រះសាសនាជារឿងសុទ្ធៗ ដូចជាផ្លូវលោកក៏ទេ ។ ការប្រកាសព្រះគុណរបស់ព្រះសាស្តា តែងស្តែងចេញទៅដោយការសម្តែងចំពោះព្រះមានជោគ ដែលមានការសម្តែងនូវព្រះធម៌មិនវិបរិត គឺជាការសម្តែងនូវសម្បត្តិរបស់ព្រះសាសនា ។ លោកអាចារ្យនឹងពោលតទៅថា តាមលំដាប់នៃពាក្យត្រឹមប៉ុណ្ណោះឯង ដែលលោកប្រកាសនូវសិក្ខា ៣ ដូច្នេះជាដើម។

ដោយ អាទិ-ស័ព្ទ ក្នុង ២ បទថា **សោតាបន្នាទិភាវស្ស ច ករណំ** នេះជាការប្រកាសហេតុ នៃភាពជាព្រះអរិយបុគ្គលមានព្រះសោតាបន្នជាដើម លោកអាចារ្យរមែងសង្គ្រោះព្រះអរហន្តទាំងអស់ ដូចនឹង

ព្រះសកទាគាមី និងព្រះអនាគាមីគ្រប់ជំពូក ព្រោះមិនបានលើកវិភាគទុក ។

ដោយហេតុនោះឯង ទើបឃើញថា ធម៌ទាំងឡាយមានសីលជាដើម ដែលប្រព្រឹត្តក្នុងចំណែកនៃការទម្លាយកិលេសរបស់ព្រះពោធិសត្វទាំង ៣ ជំពូក លោកក៏សង្គ្រោះចូលដោយពាក្យថា **សីលេ បតិដ្ឋាយ** ជាដើម ក្នុងទីនេះ ។

ពិតហើយ ការឃើញភ័យក្នុងសង្សារ ជាពិសេសក្នុងភពចុងក្រោយរបស់ព្រះពោធិសត្វទាំង ៣ ពួកនោះ និងការបដិបត្តិដោយការតាំងនៅក្នុងសីលតាមសមគួរចំពោះខ្លួន ឲ្យសមថៈ និងវិបស្សនាឈានមុខ កម្ចាត់នូវគ្រឿងចាក់ស្រេះ គឺតណ្ហាបាន, ជារឿងដូចគ្នា ។

ម្យ៉ាងទៀត ដោយពាក្យជាទូទៅថា **សោ ឥមំ វិជដយេ ជដំ** លោកសំដៅយកការធ្វើឲ្យដាច់សូន្យនូវគ្រឿងចាក់ស្រេះ គឺតណ្ហា ដែលជាការដ៏ប្រសើរក្រៃលែង និងដែលប្រសើរបំផុតជាងអ្វីៗ ។ ក្នុងការកម្ចាត់នូវគ្រឿងចាក់ស្រេះ ទាំង ២ យ៉ាងនោះ ដោយការធ្វើឲ្យដាច់សូន្យនូវគ្រឿងចាក់ស្រេះ គឺតណ្ហា ដោយអស់ជើង ព្រោះភាវៈគឺការលះកិលេស និងវាសនា ក៏ជាការសម្តែងដល់បហានសម្បទារបស់ព្រះសាស្តា និងញាណសម្បទា ដែលមានបហានសម្បទាជាហេតុ ។ ដោយការកម្ចាត់នូវគ្រឿងចាក់ស្រេះ គឺតណ្ហា ទាំង ២ ប្រការនោះ

ទ្រង់ក៏សម្ដែងនូវសម្បទាទាំងឡាយ មានអានុភាវសម្បទាជាដើម ព្រោះជាសម្បទាដែលមិនមានអ្វីបិទបាំង ដូច្នេះ ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា ព្រះវិសុទ្ធិមគ្គនេះ ជាការពោលដែលផ្ដើមដោយការលើកសរសើរដោយប្រការដូច្នេះ ។ ម្យ៉ាងទៀតគប្បីឃើញថា ព្រះវិសុទ្ធិមគ្គនេះជាការពោលដែលផ្ដើមដោយការលើកសរសើរតែម្យ៉ាង ព្រោះលោកអាចារ្យផ្ដើមអធិប្បាយបំណាងចំពោះមុខ គឺការលើកសរសើរព្រះសាស្ដា ដោយពាក្យជាដើមថា **សព្វធម្មេសុ អប្បដិហតញ្ញាណចារោ** ព្រះមានព្រះភាគ មានការត្រាច់ទៅនៃព្រះញាណមិនមានអ្វីទើសទាក់ក្នុងធម៌ទាំងពួង ។

ម្យ៉ាងទៀត ព្រោះការពោលនូវវិសុទ្ធិមគ្គនេះនោះ លោកអាចារ្យបានរៀបចំហើយ ដោយទាក់ទងជាមួយនឹងការសម្ដែងរបស់ព្រះមុនីដែលទ្រង់ជាអ្នកអាចក្នុងការព្យាករណ៍ តាមសមគួរដល់អធ្យាស្រ័យរបស់ទេវបុត្តដែលជាអ្នកទូលសួរ និងជាការសរសើរយ៉ាងក្រៃលែងចំពោះព្រះសាស្ដា ក្នុងវារៈចាប់ផ្ដើមអធិប្បាយតាមសមគួរនៃធម៌ដែលអធិប្បាយ នេះជាធម្មទំនៀម ដែលលោកអាចារ្យបានប្រព្រឹត្តហើយ ព្រោះហេតុនោះ ក្នុងការពោលនូវព្រះវិសុទ្ធិមគ្គនេះ លោកអាចារ្យបានធ្វើការលើកសរសើរយ៉ាងនេះដោយហេតុនេះឯង លោកអាចារ្យកាលនឹងលើកនូវហេតុនៃអាការលើកសរសើរ ដែលកំពុងពោល

ទើបតាំងព្រះគាថាវិសជ្ជនាមុន ហើយសម្ដែងគាថាដែលជាបុច្ឆាដោយសរុប និងដោយអត្ថ ដោយមានមាតិកាគឺ ការសួរដើមហេតុនៃគាថាដែលបុច្ឆានោះ មានបំណងថ្វាយនូវការលើកសរសើរព្រះមានជោគជ័យ ដោយបញ្ចាំងនូវភាពដែលទ្រង់អាចក្នុងការព្យាករណ៍មិនវិបរិត ចំពោះការបុច្ឆានោះ ហើយបានធ្វើការអធិប្បាយនូវព្រះធម៌តាមបំណង ។ ដោយហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា **សីលេ បតិដ្ឋាយ** ជាដើម ។

ខ្លឹមសារនៃព្រះគាថាក្នុងព្រះបាលីនោះ នឹងអធិប្បាយដូចតទៅ

នឹងមានវិនិច្ឆ័យក្នុងពាក្យទាំងឡាយ មានពាក្យថា **ឥតិ** ជាដើម ដូចតទៅ

និយាយចំពោះពាក្យ **ឥតិ** មុន, ឥតិ-ស័ព្ទនេះមានអត្ថច្រើនយ៉ាងជាដើម អត្ថ គឺហេតុ ( ប្រែថា ព្រោះហេតុនោះ ), មានអត្ថគឺបរិសមាបន ( ប្រែថា ដូច្នេះឯង ), មានអត្ថ គឺអាទិ ( ប្រែថា ជាដើម ), មានអត្ថគឺ **បទត្ថវិបរិយាយ** ( ប្រែថា ជាពាក្យប្រែខ្លឹមសារចំពោះបទ ), មានអត្ថគឺបការ ( ប្រែថា ដោយប្រការដូច្នេះ ), មានអត្ថ គឺ **អវធារណ** ( មានខ្លឹមសារផ្សេង ), មានអត្ថ គឺ **និទស្សន** ( ដូចជា ) ។

ពិតហើយ ឥតិ-ស័ព្ទនេះ មានក្នុងអត្ថ គឺហេតុ ដូចមានក្នុងពាក្យជាដើមថា **រុប្បតីតិ ខោ ភិក្ខវេ តស្មា** ( **រូបន** ) **តិ វុច្ចតិ** ម្នាល

ភិក្ខុទាំងឡាយ ព្រោះការបែកធ្លាយទៅទើបហៅថា រូប ។ មានក្នុងអត្ថ គឺ **បរិសមាបន** ដូចមានក្នុងពាក្យជាដើមថា **តស្មាតិហ មេ ភិក្ខវេ ធម្មទាយាទា ភវថ មា អាមិសទាយាទា អត្ថិ មេ តុម្ហេសុ អនុកម្បា កិន្តិ មេ សាវកា ធម្មទាយាទា ភវេយ្យុំ នោ អាមិសទាយាទា** ម្នាល ភិក្ខុទាំងឡាយ ព្រោះហេតុនោះឯង ពួកអ្នកចូរជាធម្មទាយាទរបស់តថាគតចុះ កុំជាអាមិសទាយាទរបស់តថាគតឡើយ ។ តថាគតមានការគិតគូរចំពោះអ្នកទាំងឡាយជានិច្ចថា ធ្វើយ៉ាងណាហ្ន៎ សាវកទាំងឡាយរបស់តថាគតនឹងគប្បីជាធម្មទាយាទ មិនជាអាមិសទាយាទ ។

មានក្នុងអត្ថ គឺ **អាទិ** ដូចក្នុងពាក្យជាដើមថា **ឥតិ វា ឥតិ ឯវរូបា នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ** ភិក្ខុវៀរចាកការរាំរែក ការប្រគុំតន្ត្រី និងការមើល ការលេងសម្ដែងដែលជាសត្រូវដល់កុសលធម៌យ៉ាងនេះជាដើម ។

មានក្នុងអត្ថគឺ **បទត្ថវិបរិយាយ** ( ពាក្យប្រែខ្លឹមសារចំពោះបទ ) ដូចមានក្នុងពាក្យជាដើមថា **មាគណ្ឌិយោតិ តស្ស ព្រាហ្មណស្ស សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោ** ពាក្យថា **មាគណ្ឌិយ** ជាគ្រឿងកំណត់ ជាទីសម្គាល់ឲ្យដឹង ជាបញ្ញត្តិ ជាវោហារ ជាឈ្មោះ ជាការតាំងឈ្មោះ ជានាមធេយ្យ ជានិរុត្តិ ជាព្យញ្ជនៈ ជាពាក្យហៅរបស់ព្រាហ្មណ៍នោះ ។

មានក្នុងអត្ថ គឺ **បការ** ដូចក្នុងពាក្យជាដើមថា **ឥតិ ខោ ភិក្ខវេ សប្បដិភយោ ពាលោ អប្បដិភយោ បណ្ឌិតោ សឧបទ្ទវោ ពាលោ អនុបទ្ទវោ បណ្ឌិតោ សឧបសគ្គោ ពាលោ អនុបសគ្គោ បណ្ឌិតោ** ប្រែថា ម្នាលភិក្ខុទាំងឡាយ ដោយប្រការដូច្នេះឯង បុគ្គលពាលមានភ័យចំពោះមុខ បណ្ឌិតមិនមានភ័យចំពោះមុខ បុគ្គលពាលមានអន្តរាយ បណ្ឌិតមិនមានអន្តរាយ បុគ្គលពាលមានឧបសគ្គ បណ្ឌិតមិនមានឧបសគ្គ ។

មានក្នុងអត្ថគឺ **អវធារណ** អធិប្បាយថា ក្នុងការព្រមព្រៀងនៃចិត្ត ដូចក្នុងពាក្យជាដើមថា **អត្ថិ ឥទប្បច្ចយា ជរាមរណន្តិ ឥតិ បុដ្ឋេន សតា អានន្ទ អត្ថីតិស្ស វចនីយំ កឹ បច្ចយា ជរាមរណន្តិ ឥតិ ចេ វទេយ្យ ជាតិប្បច្ចយា ជរាមរណន្តិ ឥច្ចស្ស វចនីយំ** ម្នាលអានន្ទ បើគេសួរថា ជរា និងមរណៈមាន វត្ថុជាបច្ច័យឬ ? អ្នកគប្បីឆ្លើយថា មាន, បើគេសួរថា ជរា និងមរណៈមានអ្វីជាបច្ច័យ ? អ្នកគប្បីឆ្លើយថា ជរានិងមរណៈមាន ព្រោះមានជាតិជាបច្ច័យ ។

មានក្នុងអត្ថគឺ **និទស្សន** ដូចក្នុងពាក្យជាដើមថា **អត្ថីតិ ខោ កច្ចាន អយមេកោ អន្តោ នត្ថីតិ ខោ កច្ចាន អយំ ទុតិយោ អន្តោ** ប្រែថា ម្នាលកច្ចានៈ ចំណែកទីបំផុតទី ១ នេះមានហើយ ចំណែកទីបំផុតទី ២ នេះមិនមាន ។

សុម្បីក្នុងទីនេះ ឥតិ-ស័ព្ទ គប្បីយល់ថា ប្រើក្នុងអត្ថ គឺនិទស្សន និងពោលថា ប្រើក្នុងអត្ថ គឺបការ ក៏គួរដូចគ្នា ។ ចំណែក ឥតិ-ស័ព្ទ ដើមដំបូងគប្បីយល់ថា ប្រើក្នុងអត្ថ គឺបរិសមាបន ។

ស័ព្ទថា **ហិ** ប្រើក្នុងអត្ថ គឺអវធារណ ។ បទថា **ឥទំ** ជាពាក្យនិយាយចំពោះវត្ថុដែលប្រចក្សក្នុងទីជិត ព្រោះធ្វើបទព្រះសូត្រតាមដែលបានប្រសព្វហើយ ទុកចំពោះមុខ ។ នឹងអធិប្បាយបទថា **វុត្តំ** តទៅ វុត្ត-ស័ព្ទនេះ មានឧបសគ្គ និងមិនមានឧបសគ្គ ឃើញប្រើក្នុងអត្ថទាំងឡាយជាដើមថា អត្ថ គឺវប្បន ការសាបព្រោះអត្ថ គឺវាបសមីករណ ធ្វើទីសំណាបឲ្យរាប, អត្ថគឺកេសោហារណ ការដាក់ចុះនូវកេសា, អត្ថ គឺជីវិតវុត្តិ ការចិញ្ចឹមជីវិត, អត្ថ គឺបមុត្តភាវ ការរួចផុត, អត្ថ គឺបាវចនបវត្តិត ឲ្យប្រព្រឹត្តទៅក្នុងភាពជាបាវចនៈ, អត្ថ គឺអជ្ឈេសន ការគោរពអញ្ជើញ និងអត្ថគឺកថន ការពោល ។ពិតហើយ វុត្ត-ស័ព្ទនេះ មានក្នុងអត្ថ **វប្បន** ការសាបព្រោះ ដូចមានក្នុងពាក្យជាដើមថា បុគ្គលណាមិនប្រទូសរ៉ាយមិត្ត គោរបស់អ្នកនោះរមែងកើតមក ពូជដែលសាបព្រោះក្នុងស្រែរមែងលូតលាស់ល្អ អ្នកនោះរមែងបរិភោគនូវផលនៃពូជដែលបានសាបព្រោះហើយនោះ ។មានក្នុងអត្ថ គឺវាប-សមីករណ ធ្វើទីសាបព្រោះឲ្យរាបស្មើដោយវត្ថុទាំងឡាយ មានរនាស់ដែលមានធ្មេញ ៨ ជាដើម, ដូចក្នុងប្រយោគជាដើមថា **នោ ច ខោ**

**បដិវុត្តំ** តែមិនទាន់បានត្រឡប់ ។ មានក្នុងអត្ថ គឺកេសោហារណា ការដាក់ចុះនូវកេសា ដូចក្នុងប្រយោគជាដើមថា **កាបទិកោ មាណវោ ទហរោ វុត្តសិរោ** កាបទិកមាណពនៅក្មេងដាក់ចុះនូវកេសាហើយ ។ មានក្នុងអត្ថ គឺជីវិតវុត្តិ ការចិញ្ចឹមជីវិត ដូចក្នុងប្រយោគជាដើមថា **បន្នលោមោ បរទវុត្តោ មិគភូតេន ចេតសា វិហរតិ** ភិក្ខុដែលមានរោមធ្លាក់ចុះ ចិញ្ចឹមជីវិតដោយបច្ច័យដែលអ្នកដទៃថ្វាយ មានចិត្តដូចជុំសាច់ ។

មានក្នុងអត្ថ គឺ **ពន្ធនតោ បមុត្តភាវ** ការជ្រុះផុតចាកពីថ្នាំង ដូចក្នុងប្រយោគជាដើមថា **សេយ្យថាបិ នាម បណ្ឌុបលាសោ ពន្ធនា បវុត្តោ អភព្វោ ហរិតតាយ** ស្លឹកឈើពណ៌លឿងដាច់ចេញពីថ្នាំង សូម្បីយ៉ាងណា ក៏មិនអាច ជារបស់ខៀវទៀត ។ មានក្នុងអត្ថ គឺ **បាវចនភាវេន បវត្តិត** ឲ្យប្រព្រឹត្តទៅ ដោយភាពជាបាវចនៈ, ដូចក្នុងប្រយោគជាដើមថា **យេសមិទំ ឯតរហិ បោរាណំ មន្តបទំ គីតំ បវុត្តំ សមីហិតំ** ក្នុងបច្ចុប្បន្ននេះ បទមន្តជារបស់ចាស់ ដែលពួកព្រាហ្មណ៍ទាំងឡាយណា ចងក្រងរក្សាទុក ឲ្យប្រព្រឹត្តទៅជាបាវចនៈ ។

សូម្បីក្នុងលោកវោហារ វុត្ត-ស័ព្ទ មានក្នុងអត្ថ គឺ **អជ្ឈេសន** គោរពអញ្ជើញ ដូចក្នុងពាក្យថា **វុត្តោ គុណោ** អ្នកដែលទ្រទ្រង់នូវគុណគេគោរពអញ្ជើញហើយ **វុត្តោ បារាយនោ** អ្នកដែលដល់នូវត្រើយ

គេគោរពអញ្ជើញហើយ ដូច្នេះជាដើម ។ មានក្នុងអត្ថ គឺកថន ពោល ដូចពាក្យថា **វុត្តំ ហេតំ ភគវតា ធម្មទាយាទា មេ ភិក្ខវេ ភវថ មា អាមិសទាយាទា** ព្រះមានព្រះភាគត្រាស់ពាក្យនេះទុកថា ម្នាល ភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជាធម្មទាយាទរបស់តថាគត កុំជា អាមិសទាយាទឡើយ ដូច្នេះជាដើម ។ សូម្បីក្នុងទីនេះ វុត្ត-ស័ព្ទ គប្បី ឃើញថា ប្រើក្នុងអត្ថ គឺកថន ( ពោល ) នោះឯង ។ ព្រោះហេតុនោះ លោកអាចារ្យទើបសម្ដែងពន្យល់គាថាដែលលើកឡើងដោយសេចក្ដី ជាគាថាដែលព្រះមានព្រះភាគទ្រង់សម្ដែងថា ព្រះសូត្រនេះ ព្រះមុនី ព្រះភាគ ទ្រង់សម្ដែងទុកហើយដូច្នេះឯង គឺយ៉ាងនេះប៉ុណ្ណោះ ។ ឬ រមែងហាមអាការដែលព្រះសាស្ដាទ្រង់សម្ដែងហើយនៃគាថានោះ ។

បទថា **កស្មា** ជាបញ្ចមីវិភត្តិចុះក្នុងអត្ថ គឺហេតុ ។ស័ព្ទថា **បន** ត្រឹមតែជាវចនាលង្ការ ។ ដោយបទទាំងពីរ លោកអាចារ្យរមែងសួរ នូវហេតុ ។ បទថា **ឯតំ** លោកអាចារ្យរំលឹកបទព្រះសូត្រ តាមដែល បានពោលហើយ ។

បទថា **វុត្តំ** ជានិមិត្តនៃពាក្យសួរ ។ លោកអាចារ្យអាស្រ័យ សេចក្ដីនៃខ្លឹមសារនោះ ដែលផ្លាស់ប្ដូរទៅក្នុងការយល់របស់ខ្លួន ក៏ ពោលថា **ឥទំ** ដូច្នេះហើយ ក៏ពោលទៀតថា **ឯតំ** សំដៅយកអាការ ដែលព្រះមានព្រះភាគត្រាស់ទុក ។ ដោយពាក្យទាំងអស់នេះ លោក

អាចារ្យសួរដល់ហេតុនៃទេសនា ព្រោះពោលពាក្យថា **ភគវន្តំ កិរ** ជាដើមទុក ដើម្បីនឹងញ៉ាំងអ្នកសម្ដែងស្ថានទី កាលអ្នកទទួលទេសនា នោះឲ្យច្បាស់លាស់ ។

ក្នុងបណ្ដាពាក្យទាំងនោះ សព្ទថា **កិរ** ជានិបាតចុះក្នុងអត្ថ គឺ អនុស្សវន ( បានឮ បានស្ដាប់មក ) ។ ដោយសព្ទថា **កិរ** នោះ លោក អាចារ្យសម្ដែងនូវសេចក្ដីដែលកំពុងពោលដល់ខ្លឹមសារ ជាខ្លឹមសារ ដែលបានស្ដាប់តាមៗ គ្នាមក ។

បទថា **រត្តិភាគេ** មានន័យថា ក្នុងចំណែកមួយនៃរាត្រី, អធិប្បាយ ថា ក្នុងមជ្ឈិមយាម ។ ទេវនោះឯងឈ្មោះថា ទេវបុត្រ ឈ្មោះថា បុគ្គលណាមួយ ព្រោះមិនមានឈ្មោះប្រាកដ ដូចជាស្ដេចវេស្សវ័ណ ជាដើម ។ ពាក្យថា ដើម្បីដកនូវការសង្ស័យ មានពាក្យប្រកបថា បានទូលសួរដើម្បីដកនូវកូនសរ គឺវិចិកិច្ឆា ។

ម្យ៉ាងទៀត ដោយពាក្យថា ដើម្បីដកនូវសេចក្ដីសង្ស័យ នេះ លោកអាចារ្យសម្ដែងថា បណ្ដាពាក្យបុច្ឆា ៥ យ៉ាង ពាក្យទូលសួរ នេះជាវិមតិច្ឆេទនាបុច្ឆា ( គឺជាពាក្យសួរកាត់សេចក្ដីសង្ស័យ ) ។

តណ្ហា ព្រះសាស្ដាត្រាស់ថា គ្រឿងចាក់ស្រែះ ដោយអត្ថណា ដើម្បីនឹងសម្ដែងនូវអត្ថនោះៗ ឯង ទើបលោកអាចារ្យពោលពាក្យថា **ជាលិនិយា** មានសំណាញ់ជាដើម ។ ពិតហើយ តណ្ហានោះត្រាស់

ហៅថាជាលិនី ព្រោះអត្ថថា មានសំណាញ់ដែលជាអវយវៈរបស់ខ្លួននោះឯង មានប្រភេទជាតណ្ហាវិចរិត ១០៨ ។

ឥឡូវនេះ ដើម្បីនឹងសម្តែងភាពប្រព្រឹត្តិទៅ ដោយអាការជាគ្រឿងចាក់ស្រេះនៃតណ្ហានោះ ទើបលោកអាចារ្យពោលថា ពិតហើយតណ្ហានោះ ដូច្នេះជាដើម ។

ក្នុងបណ្តាពាក្យទាំងឡាយនោះ លោកអាចារ្យពោលដល់ស្ថានទីប្រព្រឹត្តទៅនៃតណ្ហានោះថា ក្នុងអារម្មណ៍ទាំងឡាយមានរូបជាដើម ព្រោះតណ្ហាវិស័យផុតចាកអារម្មណ៍ ៦ មានរូបជាដើមក៏ទេ ។

ពាក្យថា ដោយអំណាចការប្រព្រឹត្តិទៅក្នុងចំណែកខាងក្រោម និងខាងលើ មានន័យថា ដោយអំណាចការប្រព្រឹត្តិទៅក្នុងចំណែកខាងក្រោម និងខាងលើយ៉ាងនេះ គឺពេលខ្លះប្រព្រឹត្តទៅក្នុងរូបារម្មណ៍ ពេលខ្លះប្រព្រឹត្តទៅរហូតដល់ធម្មារម្មណ៍ ពេលខ្លះប្រព្រឹត្តទៅក្នុងធម្មារម្មណ៍ ពេលខ្លះប្រព្រឹត្តទៅរហូតដល់ក្នុងរូបារម្មណ៍ ។

ក្នុងទីនេះ គប្បីឃើញនូវសភាពរបស់តណ្ហា ដែលប្រព្រឹត្តទៅក្នុងចំណែកខាងក្រោម និងខាងលើតាមលំដាប់ទេសនា ។ គប្បីជ្រាបការប្រព្រឹត្តិទៅដោយអំណាចនៃការប្រព្រឹត្តិទៅក្នុងចំណែកខាងក្រោម និងខាងលើ, ក្នុងពាក្យនេះ សូម្បីថា គ្រាខ្លះប្រព្រឹត្តទៅក្នុងកាមភព គ្រាខ្លះប្រព្រឹត្តទៅក្នុងរូបភព គ្រាខ្លះប្រព្រឹត្តទៅក្នុងអរូបភព ឬគ្រាខ្លះ

ប្រព្រឹត្តទៅក្នុងអរូបភព ។ល។ គ្រាខ្លះប្រព្រឹត្តទៅក្នុងកាមភព ។

ការកើតឡើងរឿយៗឈ្មោះថាជាការជាប់ក្នុងភពនេះព្រោះថា សង្ខារទាំងពួង មានការបែកធ្លាយទៅជាសភាវៈគ្រប់ៗ ខណៈ ហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះកើតឡើងរឿយៗ ។

ពាក្យថា ដោយអត្ថថា រួបរឹត នេះជាពាក្យសម្ដែងសេចក្ដីសម្ពន្ធដែលជាហេតុឲ្យគ្រឿងចាក់ស្រែះ និងតណ្ហា ជាពាក្យឧបមា និងឧបមេយ្យថា តណ្ហា ឈ្មោះថា ជាគ្រឿងចាក់ស្រែះ ព្រោះអត្ថថា ដូចជាគ្រឿងចាក់ស្រែះ ។

ក្នុងពាក្យនេះមានខ្លឹមសារដូច្នេះ :

មែកនៃគុម្ពឫស្សីដែលមានគ្រឿងទាក់ និងសំបុកដង្កូវនាងជាដើម តែងចងខ្លួនទុកដោយខ្លួនឯង គឺរួបរឹតទុកដោយអវយវៈខ្លួនឯង ទើបហៅថា គ្រឿងចាក់ស្រែះយ៉ាងណា, សូម្បីតណ្ហាក៏ទ្រង់ត្រាស់ហៅថា គ្រឿងចាក់ស្រែះដោយសភាព គឺការចងទុកយ៉ាងដូច្នោះឯង ។ ម្យ៉ាងទៀត បាឋៈថា **សំសិព្វិតដ្ឋេន** មានន័យថា ដោយភាវៈដែលខ្លួនត្រូវចងទុកដោយខ្លួនឯង ។ ពិតហើយ តណ្ហានេះប្រៀបដូចជាដង្កូវនាង រមែងប្រព្រឹត្តទៅដើម្បីចងខ្លួនឯង ។ ដោយហេតុនោះ ទើបព្រះមានជោគត្រាស់ថា រូបតណ្ហាជាទីស្រឡាញ់ ជាទីពេញចិត្តក្នុងលោក តណ្ហានេះ ពេលកើតឡើងរមែងកើតឡើងក្នុងទីនេះ ពេលតាំងនៅ

រមែងតាំងនៅក្នុងទីនេះ ដូច្នេះជាដើម ។

សត្វទាំងនេះ កាលសម្គាល់នូវវត្ថុខ្លួនដែលហួងហែងថា នេះរបស់យើងមិនឲ្យជារបស់ផ្សេងក្រៅពីខ្លួន រមែងធ្វើឲ្យនៅខាងក្នុង ។

ក៏ **អន្តោ**-ស័ព្ទ មានអត្ថថា ខាងក្នុង ព្រោះហេតុនោះ តណ្ហាពេលកើតឡើង ក្នុងបរិក្ខាររបស់ខ្លួន លោកហៅថា គ្រឿងចាក់ស្រែះខាងក្នុង, បរិក្ខាររបស់ខ្លួន សម្រាប់បព្វជិតមានបាត្រជាដើម សម្រាប់គ្រហស្ថ មានដីជាដើម ។

ឈ្មោះថា អត្តភាព ព្រោះមានការសម្គាល់ថា ជាទីមាននៅនៃឈ្មោះថា អត្តា បានដល់ ឧបាទានក្ខន្ធ ៥ ។ អាចារ្យពួកខ្លះពោលថា បានដល់ សរីរៈ ។

គប្បីជ្រាបអាការកើតឡើង នៃតណ្ហាក្នុងអត្តភាពរបស់ខ្លួនជាដើមថា ដោយន័យមានជាអាទិ៍ថា អត្តភាពរបស់យើងគប្បីជាអត្តភាពដែលល្អ ឬថា អត្តភាពរបស់យើង គប្បីដូចនឹងរបស់បុគ្គលឯណោះ ។ អាយតនៈទាំងឡាយ មានចក្ខុជាដើមរបស់ខ្លួនឈ្មោះថា អាយតនៈខាងក្នុង ។ អាយតនៈទាំងឡាយ មានរូបជាដើមរបស់ខ្លួន និងរបស់បុគ្គលដទៃឈ្មោះថា អាយតនៈខាងក្រៅ ។

ម្យ៉ាងទៀត អាយតនៈទាំងឡាយ មានចក្ខុជាដើម របស់បុគ្គលទាំងឡាយដទៃ ឬដែលជាប់ទាក់ទងដោយសន្តតិរបស់ខ្លួន និងបុគ្គល

ផងទៃឈ្មោះថា អាយតនៈខាងក្នុង ។ អាយតនៈទាំងឡាយ មានរូបជាដើមដូច្នេះ ឈ្មោះថា អាយតនៈខាងក្រៅ ។ គប្បីជ្រាបសេចក្ដីដែលតណ្ហាជាគ្រឿងចាក់ស្រែះខាងក្នុង និងគ្រឿងចាក់ស្រែះខាងក្រៅ សូម្បីប្រព្រឹត្តទៅក្នុងកាមាវចរភព និងមហគ្គតភព ។

ពិតហើយ កាមភពទោះយ៉ាងណាក៏មិនផុតឡើយ ព្រោះមិនបានគ្របសង្កត់កិលេស សូម្បីអ្វីៗ ក៏ជាបច្ច័យពិសេសនៃការប្រកាន់ខាងក្នុងដែរ ហេតុនោះ ទើបលោកហៅថា **អជ្ឈត្តំ** និង **អន្តោ** ប្រែថា ខាងក្នុង ។ រូបភព និង អរូបភព លោកហៅថា **ពហិទ្ធា** និង **ពហិ** ប្រែថា ខាងក្រៅ ដោយបរិយាយក្រៅពីកាមភពនោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា បុគ្គលមានសំយោជនៈខាងក្នុង ១ បុគ្គលមានសំយោជនៈខាងក្រៅ ១ ដូច្នេះ ។

លោកអាចារ្យកាន់យកតណ្ហានោះដោយប្រភេទផ្សេងៗ មិនមែនតិច ដោយភាពផ្សេងៗ នៃវិស័យ និងដោយភាពផ្សេងនៃអាការប្រព្រឹត្តទៅថា តែម្យ៉ាង ដោយសេចក្ដីថា ជាគ្រឿងចាក់ស្រែះស្មើគ្នា ទើបពោលថា គ្រឿងចាក់ស្រែះ កើតឡើងយ៉ាងនេះ ដូច្នេះ ។

តណ្ហានោះ ជាធម្មជាតិជាប់ជំពាក់តាមសន្តានចិត្តរបស់សត្វ ដែលទ្រង់ត្រាស់ទុកថា **បជា** នោះឯង, រុំព័ទ្ធ គឺចងពួកសត្វនោះទុកឲ្យប្រព្រឹត្តទៅរឿយៗ ហេតុនោះ ទើបទ្រង់ត្រាស់ថា ប្រជាត្រូវតណ្ហា

រួបរឹតទុក ដូច្នេះ ។

ពិតហើយ ពោលដោយបរមត្ថ សេចក្ដីរួម រមែងមិនមានដោយការវៀរចាក សេចក្ដីលម្អិត សូម្បីពិតយ៉ាងនោះ ចំណែកសេចក្ដីលម្អិតមួយ ក៏មិនឈ្មោះថា ជាសេចក្ដីរួម ព្រោះហេតុនោះ ទើបលោកអាចារ្យកាលសម្ដែងពាក្យឧបមា និងឧបមេយ្យ បានធ្វើសេចក្ដីរួមឲ្យបែកចេញពីសេចក្ដីលម្អិត ទើបពោលថា រុក្ខជាតិទាំងឡាយមានដើមឫស្សីជាដើម ត្រូវព្រៃឫស្សីជាដើមទាក់ទុកយ៉ាងណា ប្រជា ពោលគឺពួកសត្វទាំងអស់នេះក៏ត្រូវគ្រឿងចាក់ស្រែះ ពោល គឺតណ្ហា រុំព័ទ្ធគឺរួបរឹត, អធិប្បាយថា ប្រមូលទុក ដូច្នោះដែរ ។

សម្ព័ន្ធសេចក្ដីថា **ឥមំ ជដំ** មានន័យថា គ្រឿងចាក់ស្រែះដែលទាក់ពួកសត្វទុកនៅក្នុងធាតុទាំង ៣ តាំងនៅដោយការប្រមូលទុកមិនឲ្យសល់ សូម្បីតែធាតុមួយក្នុងបណ្ដាធាតុទាំង ៣ ហេតុនោះ ទើបលោកអាចារ្យពោលថា តណ្ហានោះជាធម្មជាតិមានវិស័យធំ និងសាងឡើងនូវរឿងដែលធ្វើបានដោយសែនលំបាក ។

ដោយសេចក្ដីថា នរណានឹងអាចធ្វើបាន លោកអាចារ្យរមែងសម្ដែងថា បទថា **វិជដយេ** ជាបទមានសត្តិ ( សមត្ថភាព ) ជាអត្ថមិនមែនមានវិធី ( ការធ្វើ ) ជាដើម ជាអត្ថទេ ។

សេចក្ដីថា ព្រះមានព្រះភាគ ដែលទេវបុត្តទូលសួរដោយពាក្យ

ថា **អន្តោជដា** គ្រឿងចាក់ស្រែះខាងក្នុងដូច្នេះជាដើម ហើយទើបទ្រង់ត្រាស់ព្រះគាថានេះដល់ទេវបុត្តនោះ ។

លោកអាចារ្យបានសម្តែងចំពោះព្រះសាស្តាដោយគុណថា ព្រះមានព្រះភាគ ដូច្នេះឯង ទើបវិសជ្ជនាបញ្ហានោះបាន ទើបពោលពាក្យថា មានការប្រព្រឹត្តិទៅនៃព្រះញាណ មិនមានអ្វីទើសទាក់ក្នុងធម៌ទាំងពួង ដូច្នេះជាដើម ។

បណ្តាពាក្យទាំងនោះ ពាក្យថា ក្នុងធម៌ទាំងពួង គឺក្នុងញេយ្យធម៌ទាំងឡាយ ទាំងពួងដែលផ្សេងដោយប្រភេទ មានអតីតជាដើម ។

ពាក្យថា មានការប្រព្រឹត្តិទៅនៃព្រះញាណមិនមានអ្វីទើសទាក់ មានន័យថា មានការប្រព្រឹត្តិទៅនៃព្រះញាណមិនមានព្រំដែន ព្រោះមានការប្រព្រឹត្តិទៅ មិនទើសទាក់ក្នុងការបើកនូវញេយ្យធម៌ទាំងពួងមិនមានចំណែកសល់ ។

ដោយពាក្យនេះ គប្បីជ្រាបថា លោកអាចារ្យកាន់យកធម៌ពិសេសដែលនៅសល់របស់ព្រះមានជោគទុក ដោយមានលក្ខណៈតែម្យ៉ាងដូចគ្នាជាមួយញាណនោះដោយការកាន់យកនូវធម៌ពិសេស ៣ ខាងដើម ក្នុងការសម្តែងសេចក្តីដែលព្រះមានព្រះភាគ មានព្រះញាណ មិនមានអ្វីទើសទាក់ក្នុងកាលទាំង ៣ និងព្រោះមិនប្រាសចាកញាណដែលមិនទើសទាក់នោះ ធម្មវិសេសទើបមានបាន ។

ឈ្មោះថា **ទេព** ព្រោះមានការសម្គាល់ថា **លេង** គឺសប្បាយរីករាយដោយកាមគុណជាដើមឬនៅក្នុងកាមគុណជាដើមទាំងឡាយនោះ, ព្រោះមានការសម្គាល់ថា ប្រាថ្នាដើម្បីឈ្នះសត្រូវទាំងឡាយដោយភាពជាអ្នកអាចក្នុងការសម្គាល់ថា ពោលដល់ការធ្វើការទទួលទានពីរនេះ គឺសក្ការៈ មានឥស្សរិយៈ និងទ្រព្យជាដើម ព្រមទាំងអំណោយផលនោះៗ ព្រោះមានការសម្គាល់ថា រុងរឿងដោយភាពរុងរឿងដែលបានដល់នូវអានុភាពប្រកបដោយបុណ្យវិសេស និងមានការសម្គាល់ថា ទៅកាន់វិស័យតាមសេចក្ដីប្រាថ្នាបាន មិនទើសទាក់ព្រមទាំងអាចក្នុងការញ៉ាំងវិស័យតាមបំណងឲ្យសម្រេចបាន ។

ន័យម្យ៉ាងទៀត ឈ្មោះថា ទេព ព្រោះមានការសម្គាល់ថា ដែលបុគ្គលមានសេចក្ដីប្រាថ្នា ហើយចេញចាកពីសេចក្ដីវិនាសនោះៗ គប្បីទៅរក គឺដើម្បីដល់ជាសរណៈ គឺជាទីទៅក្នុងខាងមុខ ឬព្រោះមានការសម្គាល់ថា គួរសរសើរយ៉ាងក្រៃលែង ឬព្រោះមានការសម្គាល់ថា គួរស្រឡាញ់ដោយការប្រកបនូវភាពស្អាតវិសេស ។

ទេពទាំងឡាយនោះមាន ៣ ជំពូក គឺ

១- សម្មតិទេព ២- ឧប្បត្តិទេព ៣- វិសុទ្ធិទេព ។

ព្រះមានព្រះភាគទ្រង់ជាទេពដ៏ប្រសើរបំផុត គឺខ្ពង់ខ្ពស់លើសទេពទាំងឡាយនោះ ព្រោះព្រះអង្គគ្របសង្កត់ទេពទាំងឡាយនោះ

ដោយព្រះគុណទាំងឡាយនោះ ដោយការសម្តែងអភិញ្ញាដ៏ប្រសើរ ក្រៃលែងដោយការនៅ គឺទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ ដែលខ្ពង់ខ្ពស់ដោយការពោលយ៉ាងវិសេស ពោល គឺការទទួលនូវទាន ជាសក្ការៈដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងសម្មាបដិបត្តិ មានឥស្សរិយៈនៃព្រះទ័យ និងទ្រព្យ ៧ ប្រការជាដើម ព្រោះការសម្រេចនៃសេចក្តីប្រាថ្នាក្នុងការឈ្នះជាដាច់ខាតនូវមារ ៥ ប្រការ ដែលនៅក្នុងសន្តានរបស់ព្រះអង្គ និងអ្នកដទៃ ពោល គឺអនុសាសនីដែលសមគួរដល់សភាវៈនៃធម៌ និងអធ្យាស្រ័យនៃបុគ្គលដោយការបំភ្លឺ គឺរស្មី គឺព្រះញាណ និងរស្មីនៃព្រះសរីរៈដ៏ប្រសើរដែលលោក ព្រមទាំងទេវលោកគួរដល់ជា **សរណៈ** គួរសរសើរយ៉ាងក្រៃលែង និងគួរប្រាថ្នាដោយភាពជាភក្តី ព្រោះថា ព្រះអង្គទ្រង់ប្រកបដោយការទៅនៃព្រះញាណ និងព្រះសរីរៈដែលមិនទូទៅដល់អ្នកដទៃ និងដោយអំណាចមិនទើសទាក់ក្នុងការឈ្នះមារ គុណនៃព្រះសព្វញ្ញូទាំងពួងនឹងញ៉ាំងនូវប្រយោជន៍ដ៏ក្រៃលែងឲ្យសម្រេច ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ទេវទេវោ** ប្រែថា ទេពប្រសើរជាងទេព ។ មួយ៉ាងទៀត ទ្រង់ជាទេពដែលទេពទាំងពួងគប្បីបូជាក្រៃលែង ហេតុនោះ ទើបទ្រង់ព្រះនាមថា **ទេវទេវោ** ប្រែថា ជាទេពដែលទេពបូជា ។

ម្យ៉ាងទៀត ទ្រង់ជាទេពដ៏ប្រសើររបស់មនុស្សទេពទាំងឡាយ

ដទៃ ព្រោះទ្រង់បានសម្រេចនូវភាពជាវិសុទ្ធិទេព និងអលង្ការ គឺគុណនៃព្រះសព្វញ្ញូ ហេតុនោះ ទើបទ្រង់ឈ្មោះថា **ទេវទេវោ** ប្រែថា ទ្រង់ជាទេពដែលប្រសើរជាងមនុស្សទេព ។

ព្រះមានព្រះភាគទ្រង់ជាសក្កៈ និងទ្រង់ជាព្រហ្មដ៏ក្រៃលែង គឺប្រសើរក្រៃលែង ព្រោះទ្រង់គ្របសង្កត់ដោយគុណនៃសក្កៈទាំងឡាយ និងចំពោះមហាព្រហ្មទាំងឡាយ ដែលមិនមានប្រមាណក្នុងលោកធាតុដែលរកប្រមាណមិនបាន ហេតុនោះ ទើបទ្រង់ព្រះនាមថា **សក្កានំ អតិសក្កោ** ទ្រង់ជាសក្កៈក្រៃលែងជាងសក្កៈទាំងឡាយ, **ព្រហ្មានំ អតិព្រហ្មា** ទ្រង់ជាព្រហ្មប្រសើរជាងព្រហ្មទាំងឡាយ ។ ទ្រង់ក្លាហានដោយវេសារជ្ជញ្ញាណទាំង ៤ ព្រោះមិនមានការភ័យខ្លាចពីទីណាៗ ព្រោះហេតុដែលទ្រង់តាំងនៅក្នុងឋានៈដែលនរណាៗ ក្នុងលោក ព្រមទាំងទេវលោកមិនអាចធ្វើឲ្យញាប់ញ័របាន ក្នុងភាពផ្សេងគ្នានៃញាណប្បហាន និងទេសនា ហេតុនោះ ទើបទ្រង់ព្រះនាមថា **ចតុវេសារជ្ជវិសារទោ** ទ្រង់ក្លាហាន ដោយវេសារជ្ជញ្ញាណទាំង ៤ ។

ព្រះអង្គបានត្រាស់ទុកថា សមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬនរណាៗ ក្នុងលោកដែលនឹងជំទាស់ជាមួយតថាគតដោយសហធម៌ ក្នុងសេចក្តីថា ជាអ្នកប្តេជ្ញាខ្លួនថា ជាព្រះសម្មាសម្ពុទ្ធ ធម៌ទាំងឡាយនេះ ទ្រង់មិនទាន់បានត្រាស់ដឹងដូច្នេះ, ម្នាលសារីបុត្ត កាលមិនឃើញ

ហេតុនោះតថាគតក៏ដល់នូវការរួចភ័យ ដល់នូវការមិនមានភ័យ ដល់នូវភាពជាអ្នកក្លាហាន ដូច្នេះ ។

ទ្រង់ព្រះនាមថា **ទសពលធរោ** ទ្រង់បរិបូរដោយកម្លាំង ១០ ព្រោះទ្រង់មានកម្លាំង គឺព្រះញាណ ១០ ប្រការ មានឋានាឋានញ្ញាណជាដើម ។

ទ្រង់ត្រាស់ទុកថា ព្រះតថាគតរមែងដឹងឋានៈក្នុងលោកនេះ ដោយភាពជាឋានៈ និងទ្រង់ដឹងហេតុមិនមែនឋានៈតាមសេចក្ដីពិត ដូច្នេះជាដើម ។

ទ្រង់ព្រះនាមថា **អនាវរណញ្ញាណោ** មានព្រះញាណមិនមានអ្វីទើសទាក់ ព្រោះទ្រង់មានញាណមិនមានអ្វីជាគ្រឿងទើសទាក់ក្នុងធម៌យ៉ាងណាមួយ ឈ្មោះថា គួរទាំងអស់តែម្យ៉ាង ។

ទ្រង់ព្រះនាមថា **សមន្តចក្ខុ** មានព្រះចក្ខុល្អ ព្រោះទ្រង់ប្រកបដោយចក្ខុគឺព្រះញាណដែលអាចឃើញធម៌ទាំងពួងនោះ ជាក់ច្បាស់ដោយប្រពៃដោយអាការទាំងពួង ដូចឃើញអំពិលអំពែកដាក់លើបាតដៃ អធិប្បាយថា ជាព្រះសព្វញ្ញូ ។

ពីរបទនេះ លោកអាចារ្យកាន់យកអសាធារណញ្ញាណទាំងពីរជាខាងចុង ។

ទ្រង់ព្រះនាមថា **ភគវា** ដោយហេតុទាំងឡាយ ដែលទ្រង់មាន

ភាគ្យជាដើម ពាក្យណាដែលគួរក្នុងរឿងនេះ ពាក្យនោះនឹងមានមក ដោយពិស្ដារក្នុងពុទ្ធានុស្សតិនិទ្ទេសខាងមុខ ។

ក្នុងអធិការនេះ ពេលលោកអាចារ្យបានសម្ដែងអំពីព្រះសាស្ដា ទ្រង់ជាអ្នកអាច ទ្រង់ព្យាករពាក្យបុច្ឆាដែលលើកឡើងកាន់កាលទាំង ៣ ដោយពាក្យថា មានការប្រព្រឹត្តិទៅនៃព្រះញាណមិនមានអ្វីទើសទាក់ ក្នុងធម៌ទាំងពួងនេះ សម្រាប់សេចក្ដីសង្ស័យថា តើព្រះមានព្រះភាគ ទ្រង់អាចព្យាករពាក្យបុច្ឆារបស់ពួកទេវតាបាន ឬទេ កាលហាមនូវ សេចក្ដីសង្ស័យនោះឯង ទើបលោកអាចារ្យពោលថា **ទេវទេវោ** ។

សក្កមហារាជ ជាទេពប្រសើរជាងទេពទាំងឡាយតែងវិសជ្ជនា នូវបញ្ហារបស់ទេវតាទាំងឡាយបាន កាលបើបុគ្គលទាំងឡាយគិតថា ព្រះមានព្រះភាគមានអ្វីប្រសើរជាងសក្កៈនោះ ដើម្បីហាមនូវការគិត នោះ ទើបលោកអាចារ្យពោលថា ទ្រង់ជាសក្កៈប្រសើរជាងសក្កៈ ទាំងឡាយ ។

ព្រហ្មទាំងឡាយមានសនង្កុមារព្រហ្មជាដើម តែងវិសជ្ជនា ខ្ទឹមសារ ដែលសក្កមហារាជទូលសួរ ពេលបុគ្គលទាំងឡាយគិតថា ព្រះមានព្រះភាគមានអ្វីប្រសើរជាងព្រហ្មនោះ ដើម្បីហាមការគិតនោះ ទើបលោកអាចារ្យពោលថា ទ្រង់ជាព្រហ្មប្រសើរជាងព្រហ្មទាំងឡាយ ដើម្បីនឹងសម្ដែងភាពពិសេសរបស់ព្រះមានជោគនោះ ដែលប្រាកដ

ហើយដោយវេសារជ្ជញ្ញាណ ៤ និងទសពលញ្ញាណ ទើបលោកអាចារ្យពោលថា ទ្រង់ក្លាហានដោយវេសារញ្ញាណ ៤ ទ្រង់តម្កល់នូវទសពលញ្ញាណ ដូច្នេះ ។ ដើម្បីនឹងសម្តែងថា ឯញ្ញាណទាំងឡាយនេះដល់ព្រមដោយការសម្រេចនូវញ្ញាណទាំងពីរនេះ ទើបលោកអាចារ្យពោលថា ទ្រង់ជាព្រះអនាវរណញ្ញាណ ( មានព្រះញ្ញាណមិនមានអ្វីទើសទាក់ ) ទ្រង់ គឺជាព្រះសមន្តចក្ខុ ( មានចក្ខុជុំវិញ ) ។

លោកអាចារ្យសម្តែងថា ញ្ញាណទាំង ២ នោះ សម្រេចហើយព្រោះព្រះមានព្រះភាគទ្រង់ជាអ្នកមានទោសបានទម្លាយហើយដែលសម្រេចដោយការសន្សំបុញ្ញសម្ភារ និងញ្ញាណសម្ភារ ទើបបានពោលថា ព្រះមានព្រះភាគ ។ បណ្ឌិតគប្បីជ្រាបនូវប្រយោជន៍ និងលំដាប់ក្នុងការកាន់យកបទទាំងឡាយដោយប្រការ ដូច្នេះចុះ ។

ញ្ញាណទាំង ២ គឺអនាវរណញ្ញាណ សព្វញ្ញុតញ្ញាណទាំងពីរនោះ សម្តែងដោយអត្ថមិនផ្សេងគ្នាទេ ។ ពិតហើយ ញ្ញាណនោះជាញ្ញាណតែមួយប៉ុណ្ណោះ លោកអាចារ្យពោលឲ្យជា ២ យ៉ាង ដើម្បីសម្តែងដល់ភាពជាញ្ញាណដែលមិនទូទៅដល់ជនដទៃ ដោយភាពជាធំគឺការប្រព្រឹត្តិទៅនៃវិស័យ ។

ឈ្មោះថា **សព្វញ្ញុតញ្ញាណ** ព្រោះជាធម្មជាតិដែលមានសង្ខតធម៌ អសង្ខតធម៌ និងសម្មតិធម៌មិនមានចំណែកសល់ជាអារម្មណ៍

លោកហៅថា **អនាវរណញ្ញាណ** ដូច្នេះក៏មាន ព្រោះអាស្រ័យការប្រព្រឹត្តិទៅមិនទើសទាក់ ព្រោះមិនមានការរារាំងក្នុងសព្វញ្ញុតញ្ញាណនោះ ។ ពាក្យណាដែលគួរពោលពាក្យនោះ ខ្ញុំម្ចាស់នឹងពោលទុកក្នុងពុទ្ធានុស្សតិនិទ្ទេសខាងមុខ ។

ព្រះមានព្រះភាគអង្គណាស្វែងរកនូវគុណដ៏ធំ បានដល់ គុណមានសីលក្ខន្ធជាដើម ហេតុនោះ ទើបព្រះមានព្រះភាគនោះ ព្រះនាមថា **មហេសី** ( អ្នកស្វែងរកគុណដ៏ធំ ) ។ ព្រះមានព្រះភាគទ្រង់ស្វែងរកនូវគុណដ៏ធំយ៉ាងនេះ ។

ពាក្យថា ពេលនឹងពណ៌នា គឺពេលនឹងបើកបង្ហាញ បានដល់ពេលនឹងឲ្យពិស្តារ ។ ពាក្យថា តាមសេចក្តីពិត គឺមិនវិបរិត ។ ពាក្យថា ដែលផ្សេង ដោយគុណមានសីលជាដើម គឺដែលចែកដោយគុណមានសីល សមាធិ បញ្ញាជាដើម ។ ពាក្យថា ដែលបានសែនលំបាក គឺ បានដោយលំបាកយ៉ាងក្រៃលែង ព្រោះគប្បីបានដោយខណៈទី ៩ លើកទុក ៨ ខណៈ ។ ពាក្យថា សង្គ្រោះដោយគុណមានសីលជាដើម គឺសង្គ្រោះដោយខន្ធ ៣ មានសីលក្ខន្ធជាដើម ។

ពិតហើយ អរិយមគ្គសង្គ្រោះដោយខន្ធ ៣ ព្រោះជាធម៌មានចំណែកទីអាងបាន ដូចជានគរសង្គ្រោះដោយភាពជាព្រះរាជា ។ ខន្ធ ៣ មិនសង្គ្រោះចូលក្នុងអរិយមគ្គ ព្រោះមិនមានចំណែកដែលអាងបាន ។

សេចក្តីនេះ សមដូចពាក្យព្រះនាងធម្មទិន្នាថេរីពោលទុកថា ម្នាលអាវុសោវិសាខៈ ខន្ធ ៣ ព្រះមានព្រះភាគមិនបានសង្រ្គោះដោយអរិយមគ្គមានអង្គ ៨ ទេ, ម្នាលអាវុសោវិសាខៈ ឯអរិយមគ្គ អង្គ ៨ ទ្រង់សង្គ្រោះដោយខន្ធ ៣ ដូច្នេះឯង ។

ឈ្មោះថា ដែលក្សេម ព្រោះជាធម៌ដែលចោរ គឺកិលេសទាំងឡាយមិនអាចធ្វើឲ្យអន្តរាយបាន ។

ឈ្មោះថា ត្រង់ ព្រោះវៀរចាកទីបំផុត ២ យ៉ាង និងព្រោះលះបង់នូវមាយាជាដើម ព្រមទាំងភាពកោងតាមផ្លូវកាយជាដើម ។

ឈ្មោះថា មគ្គ ព្រោះទៅ គឺប្រព្រឹត្តទៅ ដោយការសម្លាប់សង្កិលេសធម៌ទាំងពួង ព្រោះស្វែងរកនិព្វាន ព្រោះបុគ្គលដែលត្រូវការព្រះនិព្វានទាំងឡាយ គប្បីស្វែងរក ។

ពាក្យថា ដើម្បីវិសុទ្ធិ គឺដើម្បីនិព្វាន ឬដើម្បីភាវៈ គឺសេចក្តីបរិសុទ្ធិ, អធិប្បាយថា ដើម្បីអរហត្ត ។

ពាក្យថា កាលមិនដឹងតាមសេចក្តីពិត មានន័យថា កាលមិនបានដឹងតាមសេចក្តីពិតថា វិសុទ្ធិមគ្គដែលយោគី គប្បីសម្រេចបានដោយសេចក្តីជាប់តគ្នានៃវិសុទ្ធិ មានសីលវិសុទ្ធិជាដើម យ៉ាងនេះ សភាពបែបនេះ មានកិច្ចយ៉ាងនេះ មានអត្ថយ៉ាងនេះ ដូច្នេះ ។

យោគីទាំងឡាយណារមែងប្រាថ្នា គឺរមែងប្រាថ្នាសេចក្តីបរិសុទ្ធិ

គឺការផុតចាកពីសង្កិលេសទាំងអស់ និងផុតចាកសង្សារ ហេតុនោះ យោគីទាំងឡាយនោះឈ្មោះថា**សុទ្ធិកាមា**អ្នកប្រាថ្នាសេចក្ដីបរិសុទ្ធិ។ អបិ-ស័ព្ទ ចុះក្នុងសម្ភាវនៈ ។ ដោយ អបិ-ស័ព្ទ នោះលោកអាចារ្យក៏សម្ដែងថា មិនមែនរីករាយដោយត្រឹមសីលតែម្យ៉ាង តាមពិតជាអ្នកប្រាថ្នាសេចក្ដីបរិសុទ្ធិ ។

បទថា **ឥធ** មានសេចក្ដីស្មើគ្នានឹង **ឥមស្មឹ យោគ សាសនេ** ប្រែថា ក្នុងព្រះសាសនានេះ ។

ពាក្យប្រកបសេចក្ដីថា ឈ្មោះថា យោគី ព្រោះភាពជាអ្នកប្រកបហើយ ខ្វាយខ្វល់ហើយក្នុងភាវនា សូម្បីព្យាយាមជានិច្ច គឺសូម្បីធ្វើសេចក្ដីព្យាយាមពុះពារ តម្រង់ឆ្ពោះសេចក្ដីបរិសុទ្ធិ ក៏រមែងមិនសម្រេចនូវសេចក្ដីបរិសុទ្ធិ ព្រោះមិនបានសម្រេចនូវឧបាយ ។ បទថា **តេសំ យោគ យោគីនំ** ប្រែថា ដល់យោគីទាំងនោះ។

វិសុទ្ធិមគ្គនោះ ធ្វើភាពជាបាមោជ្ជដល់បុគ្គលទាំងពួងដែលខ្វល់ខ្វាយក្នុងការស្ដាប់ ការទ្រទ្រង់ទុក និងការសន្សំជាដើម ព្រោះមានភាពស្អាតដោយជុំវិញពិត ។

សូម្បីយ៉ាងនោះ ក៏ជាបាមោជ្ជយ៉ាងពិសេសក្រៃលែង ដល់យោគីទាំងឡាយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ធ្វើសេចក្ដីរីករាយដល់យោគីទាំងឡាយនោះ ។ ឈ្មោះថា មានវិនិច្ឆ័យ

ហ្មត់ចត់ល្អ ព្រោះមានវិនិច្ឆ័យ ហ្មត់ចត់ដោយល្អ ដោយសេចក្ដីថា មិនលាយចូលជាមួយនិកាយខាងក្រៅ និងលទ្ធិដទៃ ។ ពាក្យថា របស់ព្រះថេរៈនៅឯមហាវិហារ លោកអាចារ្យសម្ដែងនូវនិកាយដែលជាទីអាងអាស្រ័យរបស់ខ្លួន ។ ពាក្យថា អាស្រ័យន័យនៃទេសនា គឺ អាស្រ័យន័យនៃសំវណ្ណនាធម៌ ។

ក្នុងអធិការនេះ ដោយពាក្យថា ធ្វើសេចក្ដីរីករាយ ដល់យោគីទាំងឡាយនោះជាដើម លោកអាចារ្យក៏សម្ដែងថា កថាមគ្គរបស់ព្រះថេរៈ នៅឯមហាវិហារទាំងឡាយ ឈ្មោះថា មានវិនិច្ឆ័យបរិសុទ្ធល្អ ដោយជុំវិញ ព្រោះព្រះថេរៈទាំងឡាយជាអ្នកមានបញ្ញាដ៏កំពូល ជាអ្នកបដិបត្តិល្អ បានសម្រេចហើយ ធ្វើសេចក្ដីរីករាយ ព្រោះនាំមកនូវសេចក្ដីបរិសុទ្ធិនោះ ដោយចំណែកតែម្យ៉ាង ដល់យោគីទាំងឡាយដែលប្រាថ្នានូវសេចក្ដីបរិសុទ្ធិ គឺនិព្វាន ព្រោះជាធម្មជាតិបរិសុទ្ធ ចាកមន្ទិល គឺសង្កិលេសទាំងពួង ។ គប្បីប្រកបនូវសេចក្ដីថា ពេលខ្ញុំម្ចាស់ពោលដោយសេចក្ដីគោរព សូមអ្នកទាំងឡាយចូរតាំងចិត្តស្ដាប់ដោយសេចក្ដីគោរពចុះ ។

ក្នុងអធិការនេះ ពាក្យថា នៃព្រះគាថានេះ លោកអាចារ្យសម្ដែងទីអាស្រ័យនៃការពោលវិសុទ្ធិមគ្គ ដោយពាក្យថា ព្រះមានព្រះភាគស្វែងរកនូវគុណដ៏ធំ បានត្រាស់ហើយ នេះសម្ដែងអំពីការពោលនូវ

វិសុទ្ធិមគ្គនោះជាសំខាន់, ដោយពាក្យថា **ខ្លឹមសារដែលប្រកបដោយគុណផ្សេងៗ មានសីលជាដើម តាមសេចក្តីពិត** នេះសម្តែងដល់ភាពរួម មិនវិបរិត ដោយពាក្យថា យោគីទាំងឡាយណាក្នុងសាសនានេះ បានបព្វជ្ជាក្នុងព្រះសាសនារបស់ព្រះជិនស្រីបានសែនកម្រ កាលមិនដឹងតាមសេចក្តីពិតនៃវិសុទ្ធិមគ្គ ដែលសង្គ្រោះដោយគុណ មានសីលជាដើម ដែលក្សេម ដែលត្រង់ សូម្បីប្រាថ្នានូវសេចក្តីបរិសុទ្ធិ សូម្បីព្យាយាមជានិច្ច ក៏មិនសម្រេចនូវសេចក្តីបរិសុទ្ធិបាន នេះសម្តែងដល់និមិត្ត ដោយពាក្យថា ធ្វើសេចក្តីរីករាយដល់យោគីទាំងឡាយនោះ ជាការសម្តែងដល់ប្រយោជន៍, ដោយពាក្យថា កាលពណ៌នាខ្លឹមសារដែលមានវិនិច្ឆ័យល្អ អាស្រ័យន័យនៃទេសនារបស់ព្រះថេរៈដែលនៅឯសម្នាក់មហាវិហារនោះ និងដោយពាក្យថា ដោយសេចក្តីគោរព ជាការសម្តែងដល់វិធីការតុបតែង ហើយបបួលសាធុជនទាំងឡាយក្នុងការស្តាប់ដោយគោរពក្នុងវិសុទ្ធិមគ្គនោះ ដោយពាក្យថា ហៃ ! សាធុជនទាំងឡាយ សូមអ្នកទាំងឡាយដែលប្រាថ្នានូវសេចក្តីបរិសុទ្ធិ ចូរតាំងចិត្តស្តាប់ចុះ ពិតហើយ សម្បត្តិនៃព្រះសាសនាទាក់ទងដោយការស្តាប់យ៉ាងល្អ ។

ការពោលអំពីវិសុទ្ធិមគ្គ ចំពោះខ្លឹមសារសាមញ្ញ គឺផ្លូវនៃសេចក្តីបរិសុទ្ធិដែលព្រះមានព្រះភាគទ្រង់ប្រកាសហើយ ពោលដល់ហើយ

រមែងញុំាងការពេញចិត្តយ៉ាងក្រៃលែងឲ្យកើតឡើងបាន ដោយការអធិប្បាយខ្លឹមសារនៃពាក្យ ព្រោះហេតុនោះ ដើម្បីនឹងអធិប្បាយនូវវិសុទ្ធិមគ្គនោះដោយខ្លឹមសារចំពោះបទ ទើបលោកអាចារ្យផ្ដើមពាក្យថា **តត្ថ វិសុទ្ធិ** ដូច្នេះជាដើម ។

ក្នុងបណ្ដាពាក្យទាំងឡាយនោះ បទថា **តត្ថ** មានន័យថា ក្នុងបទថា **វិសុទ្ធិមគ្គ** ដែលលោកអាចារ្យពោលទុកក្នុងពាក្យថា **វិសុទ្ធិមគ្គំ ភាសិស្សំ** នោះ ។

ពាក្យថា វៀរចាកមន្ទិលទាំងពួង មានន័យថា វៀរ គឺប្រាសចាកមន្ទិល បានដល់ កិលេស មានរាគៈជាដើមទាំងពួង និងប្រាសចាកមន្ទិល គឺសង្កិលេសទាំងពួង ។ ព្រោះហេតុនោះ ទើបឈ្មោះថា វិសុទ្ធិមគ្គយ៉ាងពិត, អធិប្បាយថា បរិសុទ្ធគ្រប់ពេល និងគ្រប់ប្រការ ។ បុគ្គលរមែងស្វែងរក គឺរាវរកដើម្បីសម្រេចនូវសេចក្ដីបរិសុទ្ធិ តាមដែលពោលហើយដោយធម៌នេះ ហេតុនោះ ទើបធម៌នេះ ឈ្មោះថា វិសុទ្ធិមគ្គោ ប្រែថា ធម៌ជាហេតុស្វែងរកសេចក្ដីបរិសុទ្ធិ ។

ដោយហេតុនោះ ទើបលោកអាចារ្យពោលថា ឧបាយជាហេតុឲ្យសម្រេច លោកហៅថា មគ្គ ។

ក្នុងលោកុត្តរធម៌ គប្បីជ្រាបថា វិសុទ្ធិមគ្គដោយត្រង់ ចំណែកផ្លូវដែលជាបុព្វភាគនិងពាក្យប្រព័ន្ធ (ដែលតែងឡើង) ជាទីអាស្រ័យ

នៃផ្លូវដែលជាបុព្វភាគនោះ ក៏ហៅថាវិសុទ្ធិមគ្គដូចគ្នា ព្រោះជាឧបាយនៃលោកុត្តរមគ្គនោះ ។

លោកអាចារ្យបំណងនឹងសម្ដែងថា វិសុទ្ធិមគ្គនោះ ព្រះសាស្ដាទ្រង់សម្ដែងដោយន័យផ្សេងៗ ដោយវិលាសភាពនៃទេសនា និងដោយអធ្យាស្រ័យនៃវេនេយ្យសត្វក្នុងបណ្ដាន័យទាំងអស់នោះន័យនេះក៏ជាន័យមួយដែលព្រះសាស្ដា ទ្រង់កាន់យក ទើបផ្ដើមពាក្យថា វិសុទ្ធិមគ្គនោះ ដូច្នេះជាដើម ។

ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា ក្នុងទីកន្លែងខ្លះ បានដល់ក្នុងព្រះសូត្រខ្លះ ។ ដោយអវធារណៈថា វិបស្សនាមត្តំ សេនេវ (ទាក់ទងដោយធម៌ត្រឹមតែវិបស្សនាប៉ុណ្ណោះ) លោកហាមសមថ ។ ព្រោះថា **សមថ** នោះ មានការប្រកបផ្សំជាមួយនឹងវិបស្សនានោះធម៌មានសីលជាដើម មិនមែនជាធម៌មានសេចក្ដីប្រកបផ្សំគ្នានោះទេ ។ដោយមត្ត-ស័ព្ទដែលមានការហាមសេចក្ដីផ្សេងៗ លោកអាចារ្យហាមនូវសមាធិដែលមានសេចក្ដីផ្សេងគ្នា មានប្រភេទជា **ឧបចារសមាធិ** និង **អប្បនាសមាធិ**, មិនមែនហាមគ្រប់សមាធិ ដោយគ្រាន់តែព្រោះធ្វើពាក្យអធិប្បាយថា ជាទេសនាសម្រាប់យោគាវចរ ដែលជាវិបស្សនាយានិកនោះទេ ។ ពិតហើយ វៀរខណិកសមាធិចេញវិបស្សនា រមែងមិនសម្រេច ។

ពាក្យថា វិបស្សនា គប្បីជ្រាបអនុបស្សនាទាំង ៣ យ៉ាងផង មិនមែនមានការឃើញត្រឹមតែការមិនទៀងក៏ទេ តែក្នុងព្រះគាថា សេចក្ដីដែលព្រះមានព្រះភាគ ទ្រង់ធ្វើការកាន់យកអនិច្ចលក្ខណៈតែម្យ៉ាង ក៏ដោយអំណាចនៃព្រះយោគីមានអនិច្ចលក្ខណៈនោះប៉ុណ្ណោះ ប្រាកដច្បាស់យ៉ាងល្អ ។

យោគីនោះក៏បានធ្វើលក្ខណៈ ២ ដទៃទៀត ឲ្យជាក់ច្បាស់ពិចារណាហើយ សម្រេចគុណវិសេស, មិនមែនចំពោះតែអនិច្ចលក្ខណៈ តែម្យ៉ាងនោះទេ ។

ពាក្យថា សង្ខារទាំងពួងមិនទៀង មានន័យថា សង្ខារទាំងពួង គឺប្រព្រឹត្តទៅ ក្នុងភូមិ ៣ ព្រោះសង្ខារទាំងឡាយនោះ គួរដល់ការពិចារណា ។

ពាក្យថា មិនទៀង គឺមិនមែនជារបស់ទៀង មិនយឺនយូរ តិចតួច មានសេចក្ដីទ្រុឌទ្រោមទៅគ្រប់ខណៈ ។

ពាក្យថា ដោយបញ្ញា បានដល់ ដោយវិបស្សនាបញ្ញា ។ ពាក្យថា រមែងឃើញ បានដល់ រមែងពិចារណា ។ ពាក្យថា ពេលនោះ បានដល់ ខាងក្រោយ គឺក្នុងកាលបន្ទាប់ពីញាណទាំងឡាយ មានឧទយព្វយញ្ញាណជាដើម កើតឡើងហើយ ។

ពាក្យថា រមែងនឿយណាយក្នុងទុក្ខ គឺរមែងនឿយណាយ

បានដល់ រមែងបាននិព្វិទាញាណក្នុងទុក្ខ ពោល គឺខន្ធ ៥ ដែលប្រព្រឹត្ត ទៅក្នុងភូមិ ៣ ដែលទ្រង់ត្រាស់ថា សង្ខារទាំងពួង បានឃើញដោយ អាការមិនទៀងនោះៗ ឯង ។

ពាក្យថា នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធិ មានន័យថា នេះ គឺធម៌ ពោល គឺនិព្វិទានុបស្សនាជាហេតុនៃធម៌ទាំងឡាយ មានវិរាគៈជាដើម ជាឧបាយឲ្យសម្រេចនូវព្រះនិព្វាន ។ ពាក្យថា ដោយអំណាចឈាន និងបញ្ញា មានន័យថា ដោយអំណាចសមថៈ និងវិបស្សនា ។ ពាក្យ ថា ឈាន នេះទ្រង់បំណងយកឈានដែលជាបាទនៃវិបស្សនា ។

បទថា **យម្ហិ** មានន័យស្មើ **យស្មឹ** **យោគ** **បុគ្គលេ** ប្រែថា ក្នុង បុគ្គលណា ។

ក្នុងពាក្យថា ឈាន និងបញ្ញា មានខ្លឹមសារដូច្នេះ បុគ្គលណា ធ្វើឈានឲ្យជាបាទ ផ្ដើមតាំងវិបស្សនា ហើយធ្វើវិបស្សនានោះ ឲ្យ ឈានទៅមុខ ។ ពាក្យថា បុគ្គលនោះឯងនៅជិតព្រះនិព្វាន មានន័យ ថា បុគ្គលនោះនៅជិតព្រះនិព្វានជាប្រាកដ គឺរមែងសម្រេចព្រះនិព្វាន តែម្យ៉ាង ។

ពាក្យថា កម្ម បានដល់ មគ្គចេតនា ។ ព្រោះថា មគ្គចេតនានោះ រមែងនាំមកនូវសេចក្ដីបរិសុទ្ធិដល់សត្វទាំងឡាយ ព្រោះជាឧបច្ចយ- គាមិធម៌ ( ធម៌ជាហេតុឲ្យដល់ព្រះនិព្វាន ) ។

ពាក្យថា វិជ្ជា បានដល់ សម្មាទិដ្ឋិ ។

ពាក្យថា សីល បានដល់ សម្មាវាចា និងសម្មាកម្មន្តៈ ។

ពាក្យថា ជីវិតដ៏ឧត្ដម បានដល់ សម្មាអាជីវៈ ។

ពាក្យថា ធម្ម បានដល់ ធម៌ គឺអរិយមគ្គ ៤ ។

ន័យម្យ៉ាងទៀត ពាក្យថា កម្ម លោកកាន់យកសម្មាកម្មន្តៈ ។ ព្រោះបាលីថា ម្នាលអាវុសោវិសាខៈ សម្មាទិដ្ឋិណា និងសម្មាសង្កប្បៈណា ធម៌ទាំងឡាយនេះ សង្គ្រោះចូលក្នុងបញ្ញាខន្ធ ដូច្នេះ ។

ពាក្យថា វិជ្ជា លោកសំដៅយក សម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ។ ពាក្យថា ធម្ម បានដល់ សមាធិ ដូចជាក្នុងពាក្យថា **ឯវំ ធម្មា តេ ភគវន្តោ អហេសុំ** ព្រះមានព្រះភាគទាំងឡាយនោះទ្រង់មានធម៌ ( សមាធិ ) យ៉ាងនេះ មានហើយ ដូច្នេះជាដើម ។ ដោយស័ព្ទថា សមាធិនោះឯង គប្បីកាន់យកនូវសម្មាវាយាមៈ និងសម្មាសតិផង ព្រោះមានព្រះបាលីថា ម្នាលអាវុសោវិសាខៈ សម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ ធម៌ទាំងឡាយនេះសង្គ្រោះចូលក្នុងសមាធិខន្ធ ។

ពាក្យថា សីល បានដល់ សម្មាវាចា និង សម្មាអាជីវៈ ។

ពាក្យថា ជីវិតដ៏ឧត្ដម អធិប្បាយថា អរិយមគ្គមានអង្គ ៨ គប្បីជ្រាបថា លោកពោលទុកក្នុងពាក្យថា ជីវិតដ៏ឧត្ដមនេះ យ៉ាងនេះថា ជីវិតរបស់ព្រះអរិយបុគ្គលបែបនេះជាជីវិតដ៏ឧត្ដម ។ ពាក្យថា ទាក់ទង

ជាមួយធម៌មានសីលជាដើម គឺទាក់ទងជាមួយសីល សមាធិ បញ្ញា និងវីរិយៈ ។ ពាក្យថា គ្រប់ពេល គឺអស់កាលទាំងពួង ចាប់តាំងពីបានសមាទាន ។ ពាក្យថា ដល់ព្រមដោយសីល គឺដល់ព្រម បានដល់ប្រកបដោយចតុប្បារិសុទ្ធិសីលសម្បទា ។ ពាក្យថា មានបញ្ញា គឺប្រកបដោយបញ្ញាដែលជាលោកិយ និងលោកុត្តរ ។ ពាក្យថា មានចិត្តតាំងមាំល្អហើយ គឺមានចិត្តតាំងមាំហើយដោយល្អ ដោយសមាធិដែលសម្បយុត្តជាមួយនឹងបញ្ញានោះ ។ ពាក្យថា មានសេចក្ដីព្យាយាមដែលប្រារព្ធហើយ គឺមានសេចក្ដីព្យាយាមផ្គងឡើងហើយ ដើម្បីលះបង់នូវអកុសលធម៌ ដើម្បីញុំាងកុសល ធម៌ឲ្យចូលទៅដល់ព្រម ។

ពាក្យថា មានខ្លួនបញ្ជូនទៅហើយ គឺមានចិត្តមិនសម្លឹងកាយ និងជីវិត ព្រោះភាពជាអ្នកមានខ្លួនបញ្ជូនទៅកាន់ព្រះនិព្វាន ។

ពាក្យថា ឱឃ បានដល់ ឱឃៈទាំង ៤ យ៉ាង មានកាមោឃៈជាដើម ឬបានដល់ ឱឃៈធំ គឺសង្សារនោះឯង ។

បទថា **ឯកាយនោ** ប្រែថា ផ្លូវតែមួយ ។ ពិតហើយ អយន-ស័ព្ទក្នុងទីនេះជាបរិយាយរបស់មគ្គ ដែលប្រែថា ផ្លូវ ព្រោះហេតុនោះ ទើបមានសេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវឯកមិនមែនជាផ្លូវបែកជាពីរ ។ ន័យម្យ៉ាងទៀត មានអត្ថវិគ្រោះថា ឈ្មោះថា **ឯកាយន** ព្រោះអត្ថថា ដល់ គឺទៅកាន់ធម៌ឯក បានដល់ ព្រះនិព្វាន ។

ន័យម្យ៉ាងទៀត ឈ្មោះថា **ឯកាយន** ព្រោះអត្ថថា ដែលបុគ្គលម្នាក់ គឺជាអ្នកលះបង់ការស្និទ្ធស្នាលដោយពួកគណៈហើយជាអ្នកស្ងប់ គប្បីដល់ គឺគប្បីបដិបត្តិ ។ ន័យម្យ៉ាងទៀត ធម៌ឈ្មោះថា **អយន** ព្រោះអត្ថថា ជាគ្រឿងដល់, ធម៌ជាគ្រឿងដល់តែមួយព្រះអង្គឯង គឺជាអ្នកប្រសើរបំផុត បានដល់ ព្រះមានព្រះភាគ ព្រោះជាធម៌ដែលទ្រង់ឲ្យកើតឡើងហើយ ហេតុនោះ ទើបឈ្មោះថា **ឯកាយន** ។

ន័យម្យ៉ាងទៀត ធម៌ជាគ្រឿងដល់ក្នុងធម៌ជាឯក គឺក្នុងព្រះធម្មវិន័យនេះប៉ុណ្ណោះ ហេតុនោះ ទើបឈ្មោះថា **ឯកាយន** ។

ពាក្យថា ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ គឺដើម្បីប្រយោជន៍ដល់សេចក្តីបរិសុទ្ធិ បានដល់ ដើម្បីប្រយោជន៍ដល់ភាពបរិសុទ្ធិនៃសត្វទាំងឡាយ ចាកមន្ទិលគឺកិលេស មានរាគៈជាដើម និងចាកឧបក្កិលេស មានអភិជ្ឈាវិសមលោភៈជាដើម ។ បទថា **យទិទំ** ជានិបាត មានន័យស្មើគ្នានឹង **យេ ឥមេ** ។ ព្រះមានព្រះភាគត្រាស់ថា **ចត្តារោ សតិប្បដ្ឋានា** ដូច្នេះ ព្រោះព្រះធម៌ដែលត្រាស់ដល់មគ្គដោយលក្ខណៈ ព្រមទាំងកិច្ចក្នុងពេលមុន និងដោយអត្ថថា ជាផ្លូវនោះឯង, បើជាធម៌មាន ៤ យ៉ាង ដោយភាពផ្សេងគ្នានៃអារម្មណ៍ មានកាយជាដើម ។

ដោយ អាទិ-ស័ព្ទក្នុងបទថា **សម្មប្បធានាទីសុ** ក្នុងធម៌ទាំងឡាយ

មានសម្មប្បធានជាដើម, គប្បីជ្រាបការសង្គ្រោះធម៌ទាំងឡាយ មានសេចក្ដីរីករាយក្រៃលែងក្នុងសេចក្ដីមិនប្រមាទជាដើម ។ ពិតហើយ ក្នុងទីកន្លែងខ្លះ ព្រះមានព្រះភាគ ក៏ទ្រង់សម្ដែងវិសុទ្ធិមគ្គទាក់ទងជាមួយធម៌ មានការរីករាយក្នុងសេចក្ដីមិនប្រមាទជាដើម ។

ដូចដែលត្រាស់ថា ភិក្ខុរីករាយក្នុងសេចក្ដីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្ដីប្រមាទ, មិនមានសេចក្ដីវិនាស រមែងនៅជិតព្រះនិព្វានតែម្យ៉ាង ដូច្នេះ ។

បទថា **តត្ថ** មានន័យស្មើនឹង **តស្សំ យោគ គាថាយំ** ប្រែថា ក្នុងព្រះគាថានោះ ការសំវណ្ណនាដោយពិស្ដារនៃព្រះគាថាដែលនឹងពោលខាងមុខ ត្រូវនៅក្នុងឋានៈជានិទ្ទេស ( ការអធិប្បាយសេចក្ដី ) និងបដិនិទ្ទេស ( ការសរុបសេចក្ដី ) ការពណ៌នាសេចក្ដីដែលសង្ខេបជាងនោះ តាំងនៅក្នុងឋានៈជាឧទ្ទេស ( លើកឡើងសម្ដែង ) ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា តទៅនេះជាការពណ៌នាដោយសង្ខេប ព្រោះការនិទ្ទេស និងបដិនិទ្ទេសនូវខ្លឹមសារតាមដែលបានឧទ្ទេសហើយ រមែងធ្វើបានងាយ និងធ្វើឲ្យយល់បានងាយផងដែរ ។

វិនិច្ឆ័យក្នុងពាក្យថា តាំងនៅក្នុងសីលតទៅ ពាក្យថា ក្នុងសីល បានដល់ ក្នុងសីលដែលជាកុសល ។ សូម្បីអកុសលទាំងឡាយ ក៏ឈ្មោះថា សីល ដូចក្នុង

ពាក្យថា **ម្នាលថបតិ** អកុសលសីលដូចម្ដេច ? ដូច្នេះយ៉ាង ពិត ។ ដូច្នេះ សូម្បីកិរិយាសីល ក៏មិនគួរដើម្បីជាទីតាំងនៃការចម្រើន ចិត្ត និងបញ្ញានឹងពោលថ្វីដល់អកុសលសីល ព្រោះហេតុនោះ ក្នុង ទីនេះ ទើបលោកពោលសំដៅយកកុសលសីលតែម្យ៉ាង ។

វិនិច្ឆ័យក្នុងពាក្យថា ធ្វើសីលឲ្យបរិសុទ្ធជាដើមតទៅ, ពាក្យថា ធ្វើឲ្យបរិសុទ្ធ បានដល់ រាំងដោយជុំវិញ ឬធ្វើឲ្យចម្រើនដោយជុំវិញ, អធិប្បាយថា សង្រួមជានិច្ច និងមិនល្មើសដោយចំណែកទាំងពួង បុគ្គលមានសភាពបែបនោះ មិនលះនូវសីលនោះ ឈ្មោះថា ជាអ្នក តាំងនៅក្នុងសីលនោះ ។

បទថា **សីលេ** ជាសត្តមីវិភត្តិចុះក្នុងអាធារៈ ។ ពាក្យថា តាំងនៅ មានន័យថា ទីតាំងអាស្រ័យមាន ២ យ៉ាង ដោយចែកចេញជានិស្សយប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។ ក្នុងពីរយ៉ាងនោះ ទីតាំងអាស្រ័យ ដែលជាឧបនិស្សយប្បច្ច័យជាលោកិយ ទីតាំងដែលជានិស្សយប្បច្ច័យ ជាលោកុត្តរ ព្រោះការកាន់យកមិនបែកគ្នា តែក្នុងការកាន់យកដែល បែកគ្នា ទីតាំងអាស្រ័យដែលជានិស្សយប្បច្ច័យ និងឧបនិស្សយប្បច្ច័យ រមែងមានក្នុងចិត្តុប្បាទ ដែលជាលោកិយទាក់ទងជាមួយធម៌ ដែលកើតរួមគ្នា ធម៌ដែលកើតមុន និងធម៌ដែលកើតក្រោយ យ៉ាងណា, សូម្បីទីតាំងអាស្រ័យជាឧបនិស្សយប្បច្ច័យ ក៏រមែងមានក្នុងលោកុត្តរ

ទាំងឡាយដោយអំណាចសីលក្នុងមគ្គនិងផលខាងក្រោមយ៉ាងនោះ ។

គប្បីជ្រាបសេចក្តីនៃបទថា **បតិដ្ឋាយ** ជាបុព្វកាលកិរិយា ដូចជាក្នុងពាក្យថា **សទ្ធំ ឧបនិស្សាយ** អាស្រ័យសទ្ធាជាដើម ក្នុងពេលប្រាថ្នាទីតាំងអាស្រ័យដែលជាឧបនិស្សយប្បច្ច័យ ។ ដោយហេតុនោះព្រះមានព្រះភាគត្រាស់ថា ក្នុងកាលមុន កាយកម្ម វចីកម្ម អាជីវៈរបស់ពួកគេជារបស់បរិសុទ្ធ ។

តែពេលបំណងយកទីអាស្រ័យទីដែលជានិស្សយប្បច្ច័យគប្បីជ្រាបសេចក្តីទាក់ទងជាសមានកាលកិរិយា ដូចជាពាក្យថា **ចក្ខុញ្ច បដិច្ច** អាស្រ័យចក្ខុដូច្នេះជាដើម ។ ពិតហើយ ធម៌ទាំងឡាយមានសម្មាវាចាជាដើម រមែងជានិស្សយប្បច្ច័យ ព្រោះជាធម៌ដែលកើតរួមជាមួយនឹងធម៌ទាំងឡាយ មានសម្មាទិដ្ឋិជាដើម ដែលសម្បយុត្តជាមួយខ្លួន ។

សត្វណាតែងនាំមុខ គឺបដិបត្តិជាតួយ៉ាង ហេតុនោះ សត្វនោះឈ្មោះថា **នរ** បានដល់ បុរស ។ ដូចយ៉ាងថា សត្វដែលជាធម្មតាប្រព្រឹត្តិមុនគេ ប្រព្រឹត្តទៅជាប្រក្រតី គឺប្រព្រឹត្តទៅយ៉ាងប្រសើរ គឺក្នុងឋានៈដ៏ក្រៃលែង ដោយអត្ថថា ប្រសើរជាង ការប្រព្រឹត្តតាមធម្មតាហេតុនោះ សត្វនោះ ទើបហៅថា **បុរិស** អ្នកដ៏ប្រសើរ យ៉ាងណាបុរស ហៅថា **នរ** ក៏ដោយការសម្គាល់ថា នាំមុខ ដូច្នេះឯង ។ ពិត

ហើយ បុគ្គលសូម្បីជាបុត្ត បងប្រុស ប្អូនប្រុស ក៏រមែងតាំងនៅក្នុងឋានៈជាបិតារបស់មាតា និងជាបងស្រីបាន ចាំបាច់ពោលថ្វីដល់បុរសក្រៅពីនេះដែលតាំងនៅក្នុងឋានៈជាបិតារបស់ស្ត្រីក្រៅពីនេះ ។

ស្ត្រីដែលឈ្មោះថា **នារី** ព្រោះប្រកបដោយ **នរ** ឬព្រោះសេចក្តីថា ស្ត្រីនេះជារបស់ **នរ** ។ ក្នុងទីនេះ ស្ត្រីនោះ ក៏អាចធ្វើឲ្យវិនាសខ្ទាត់ខ្ទាយនូវគ្រឿងចាក់ស្រែះគឺតណ្ហាបានដោយពិត សូម្បីយ៉ាងនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងចំពោះសត្វដែលជាប្រធានប៉ុណ្ណោះ ទើបត្រាស់ថា **នរ** ដូចពាក្យថា **សត្ថា ទេវមនុស្សានំ** ជាសាស្តានៃមនុស្សនិងទេវតាទាំងឡាយ ។ តែក្នុងអដ្ឋកថា លោកពោលថា **នរ** បានដល់សត្វ ដូច្នេះ ។ កាលនឹងសម្តែងថា នរ នេះជាបរិយាយនៃបុគ្គល ព្រោះមិនទាន់បានចែកចេញទៅ ។ ពាក្យថា មានបញ្ញា មានន័យថា សត្វណាប្រព្រឹត្តទៅមានបញ្ញាជាវិបាក ហេតុនោះ សត្វនោះ ឈ្មោះថា មានបញ្ញា ។ ពិតហើយ សត្វនោះរមែងគួរដល់នូវភាវៈដែលនឹងគប្បីពោលថា មានបញ្ញា ព្រមទាំងគុណវិសេសដោយបញ្ញានោះ ទើបប្រព្រឹត្តទៅក្នុងចំណែកជាច្រើន ដែលទាក់ទងជាមួយសន្តានតាំងតែពីដើម ។ បញ្ញាជាវិបាក រមែងជាឧបនិស្ស័យដល់ការកើតឡើងនៃភាវនាបញ្ញា ដោយការធ្វើនូវសន្តានឲ្យផ្សេងគ្នា ព្រោះអហេតុកសត្វ និងទុហេតុកសត្វ មិនមានបញ្ញាជាវិបាកនោះទេ ។

ម្យ៉ាងវិញទៀត គួរនិយាយបានថា មានបញ្ញាដោយអំណាចនៃបញ្ញាធ្វើកិច្ចនោះៗដែលហៅថា**សម្បជញ្ញៈ**ៗតែក្នុងអដ្ឋកថាលោកកាន់យកបញ្ញាដែលប្រព្រឹត្តទៅក្នុងការរក្សាដោយ និបក-ស័ព្ទ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលនូវអត្ថទុកក្នុងទីនេះ ទាក់ទងជាមួយនឹងបញ្ញាដែលជាវិបាកតែម្យ៉ាង ។

បទថា កម្មជតិហេតុកបដិសន្ធិបញ្ញាយ គប្បីភ្ជាប់ **តិហេតុក**-ស័ព្ទចូលគ្នា, បដិសន្ធិ-ស័ព្ទ មិនមែនចូលជាមួយ បញ្ញា-ស័ព្ទ យ៉ាងនេះថា **កម្មជាយ តិហេតុក បដិសន្ធិយំ បញ្ញាយ** ប្រែថា ដោយបញ្ញាក្នុងបដិសន្ធិ ដែលជាតិហេតុកៈកើតអំពីកម្ម ។ ព្រោះមិនមានបញ្ញាដែលជាតិហេតុកៈ ។ បញ្ញាដែលប្រព្រឹត្តទៅតាំងពីបដិសន្ធិ លោកហៅថាបញ្ញាក្នុងបដិសន្ធិ ព្រោះមានបដិសន្ធិនោះជាមូល មិនមែនប្រព្រឹត្តទៅតែក្នុងខណៈបដិសន្ធិប៉ុណ្ណោះទេ ។

ធម្មជាតិឈ្មោះថា ចិត្ត ព្រោះអត្ថថា គិត គឺសម្លឹងអារម្មណ៍បានដល់ សមាធិ ។

ពិតហើយ សមាធិនោះ មានការចូលទៅសម្លឹងយ៉ាងជិតជាកិច្ច ។ ព្រោះធម៌ទាំងឡាយ មានវិតក្កៈជាដើម វៀរចាកសមាធិនោះហើយ រមែងញុំាងប្រយោជន៍ឲ្យសម្រេចក៏ទេ ចំណែកសមាធិ សូម្បីវៀរចាកធម៌មានវិតក្កៈជាដើមនោះក៏អាចញុំាងប្រយោជន៍ឲ្យសម្រេច

បានដូច្នេះឯង ។ ធម្មជាតិឈ្មោះថា ចិត្ត ដោយអត្ថថា ដែលបច្ច័យទាំងឡាយសន្សំហើយ ឲ្យដល់ភាពជាធម្មជាតិរហ័សរហួន និងមានកម្លាំង ។ ឈ្មោះថា ចិត្ត ដោយអត្ថថា សន្សំសន្តានយ៉ាងនោះក៏មានបានដល់ សមាធិ ។ សមាធិ ឈ្មោះថា ចិត្ត ព្រោះជាធម្មជាតិវិចិត្រដោយចិត្ត ដោយអំណាចឈាន មានបឋមជ្ឈានជាដើម និងព្រោះធ្វើឲ្យវិចិត្រ មានការសម្តែងឫទ្ធិបានជាដើម ព្រោះហេតុនោះ ទោះវៀរចាកការអាង១.ដទៃ សមាធិនោះ ក៏មានបរិយាយថាជាចិត្តដែរ ។ តែក្នុងអដ្ឋកថា លោកពោលថា សមាធិទ្រង់សម្តែងអធិប្បាយក្នុងទីនេះ ដោយលើកចិត្តជាសំខាន់ ព្រោះធ្វើអធិប្បាយថា ចិត្ត-ស័ព្ទ ប្រើសាំដែលនៅក្នុងរឿងនៃវិញ្ញាណ ។

ធម្មជាតិឈ្មោះថា បញ្ញា ព្រោះអត្ថថា ដឹងសភាវៈតាមសេចក្តីពិត ដោយប្រការទាំងពួង ។ បញ្ញានោះមានច្រើនយ៉ាងដោយសេចក្តីផ្សេងគ្នានៃបញ្ញាដែលជាកុសលជាដើមដោយពិត, សូម្បីយ៉ាងនោះ បញ្ញាដែលគប្បីចម្រើន ទ្រង់សំដៅយកក្នុងទីនេះ ព្រោះព្រះបាលីថា **ភាវយំ** ( ចម្រើនហើយ ) ហេតុនោះ ទើបលោកអាចារ្យពោលថា វិបស្សនា ដើម្បីនឹងសម្តែងនូវបញ្ញាដែលគប្បីចម្រើន។

បទថា **ភាវយំ** គប្បីប្រកបក្នុងបទមួយថា **ចិត្តញ្ច ភាវយំ បញ្ញញ្ច ភាវយំ** ប្រែថា ចម្រើនចិត្ត និងចម្រើនបញ្ញាឲ្យដូច្នេះ ។ សួរថា ចិត្ត

និងបញ្ញាទាំង ២ នេះ ជាលោកិយ ឬជាលោកុត្តរ ? ឆ្លើយថា គប្បីឃើញថា ជាលោកុត្តរ ព្រោះសម្តែងកំណត់យ៉ាងខ្ពស់ ។

ពិតហើយ ភិក្ខុកាលចម្រើនចិត្តនិងបញ្ញានោះ លោកហៅថា កំពុងផ្តារដោយអំណាចនៃការកាត់ជាសមុច្ឆេទនូវគ្រឿងចាក់ស្រែះ គឺតណ្ហា ក្នុងខណៈនៃអរិយមគ្គ ទើបមិនមែនជាលោកិយ ។ តែក្នុងទីនេះកាន់យកចិត្ត និងបញ្ញា ដែលជាលោកិយតែម្យ៉ាង ដោយភាវៈមិនមែនជាអនន្តរិយកធម៌ ( ធម៌ដែលមិនមានអ្វី ឃាំងរវាងបាន ) ព្រោះវៀរចាកសមថៈ និងវិបស្សនាដែលជាលោកិយ, សមថៈ និងវិបស្សនាដែលជាលោកុត្តរ ក៏កើតឡើងមិនបាន ។ ព្រោះថា សម្រាប់យោគាវចរដែលជាសមថយានិក វៀរសមាធិមានឧបចារៈនិងអប្បនា, សម្រាប់យោគាវចរដែលជាវិបស្សនាយានិក វៀរខណិកសមាធិ, សម្រាប់ទាំង ២ ពួក វៀរវិមោក្ខមុខទាំង ៣ ចេញហើយ នឹងមានការសម្រេចនូវលោកុត្តរធម៌ក្នុងកាលណាៗ ក៏មិនបាន ។

ហេតុនោះ ទើបលោកអាចារ្យពោលថា ចម្រើនសមថៈ និងវិបស្សនា ក្នុងពីរប្រការនោះ លោកសំដៅយកសមថៈ និងវិបស្សនាដែលជាលោកិយ ។ បទថា **ភាវយំ** នេះ ពោលដល់កិរិយា គឺការចម្រើនជាហេតុ អធិប្បាយថា ព្រោះហេតុនៃការចម្រើន ។ ព្រោះថា កិរិយា គឺការផ្តារមានការចម្រើនសមថៈ និងវិបស្សនានោះជាហេតុ ។

តែពេលសំដៅយកធម៌ដែលជាលោកុត្តរ ក៏សម្តែងភាវៈដែលជាបុព្វ-ភាគ តែម្យ៉ាង ព្រោះថា ជាការធ្លាក់នូវគ្រឿងចាក់ស្រែះ គឺតណ្ហា មានព្រមជាមួយនឹងការចម្រើន ចិត្ត និងបញ្ញា ទាំង ២ នោះឯង ។

ពីរបទថា **អាតាបី** ( មានសេចក្តីព្យាយាម ) **និបកោ** ( មានបញ្ញារក្សាខ្លួន ) នេះជាពាក្យកំណត់ធម៌ដែលជាឧបការៈដល់ភាវនា តាមដែលពោលហើយ ។ ព្រោះថា ធម៌ ៣ ប្រការ នេះ គឺវីរិយៈ សតិ សម្បជញ្ញៈ ជាធម៌មានឧបការៈច្រើនដល់អ្នកប្រកបកម្មដ្ឋាន ។ ពិតហើយ កម្មដ្ឋានដែលមានវីរិយៈឧបត្ថម្ភ មានសតិ និងសម្បជញ្ញៈបម្រុងរក្សា រមែងមិនធ្លាក់ចុះ និងរមែងនាំមកនូវគុណវិសេសជាន់ខ្ពស់ឡើង ។

ក្នុងបណ្តាធម៌ទាំងឡាយនេះ ការសម្រេចនៃសទ្ធា រមែងមានបានដោយការសម្រេច នៃទីតាំងអាស្រ័យនិងដោយការសម្រេចនៃធម៌មានវីរិយៈជាដើម ព្រោះសីលមានសទ្ធាជាឧបនិស្សយប្បច្ច័យ ។

ពិតហើយ ពេលបុគ្គលមិនជឿវត្ថុដែលគួរជឿ ធម៌ទាំងឡាយមានវីរិយៈជាដើម តាមដែលពោលហើយ មិនអាចនឹងមានបាននោះទេ សូម្បីទាំងសមាធិក៏ដូច្នោះដែរ ដូចជាការសម្រេចនៃសទ្ធា បានដោយធម៌ មានវីរិយៈជាដើម ព្រោះភាពជាហេតុ យ៉ាងណា ការសម្រេចនៃសមាធិ ក៏បានដោយធម៌ មានវីរិយៈជាដើមដែរ ព្រោះជាផលដូចគ្នា ។

ព្រោះថា ពេលធម៌ទាំងឡាយមានវីរិយៈជាដើមដល់ព្រមហើយ សមាធិក៏ជាធម៌ដល់ព្រម ព្រោះបុគ្គលមិនមានសមាធិ ក៏មិនមានវីរិយៈ ។

ក្នុងសេចក្ដីនេះ ការសម្រេចនៃសតិមានដូចម្ដេច ? ឆ្លើយថា មានព្រោះ ស័ព្ទថា **និបក** ប្រែថា អ្នកមានបញ្ញារក្សាខ្លួន ។

ពិតហើយ សតិដល់នូវភាវៈរឹងប៉ឹងរហ័សរហួន លោកហៅថា **នេបក្កំ** ដូចដែលទ្រង់ត្រាស់ថា **បរមេន សតិនេបក្កេន សមន្នាគតោ** ប្រកបដោយបញ្ញារក្សាខ្លួនគឺបរិបូរដោយសតិដូច្នេះ ។តែក្នុងអដ្ឋកថា លោកសម្ដែងខ្លឹមសារទុក ដូច្នេះថា **នេបក** បានដល់ បញ្ញា សូម្បីសតិក៏សំដៅយក នេបក-ស័ព្ទនោះដែរ ។ព្រោះបញ្ញាវៀរចាកសតិហើយ ក៏មានមិនបាន ។

តែអាចារ្យពួកខ្លះពោលសេចក្ដីនៃ បទថា **និបកោ** បានដល់ **សតោ** ប្រែថា មានសតិ ព្រោះសូម្បីបារិហារិយប្បញ្ញា គឺបញ្ញាដែលប្រកបក្នុងការរក្សា លោកកាន់យកដោយបទថា សបញ្ញា ( មានបញ្ញា ) នោះឯង ។

ការលះកិលេសទាំងឡាយ ជាការធ្វើកិលេសឲ្យក្ដៅ ការលះកិលេសនោះមាន ដោយធម៌ទាំងឡាយមានសម្មាទិដ្ឋិជាដើម យ៉ាងពិត ។

សូម្បីយ៉ាងនោះ អាតប-ស័ព្ទ ក៏ប្រើជាប់មាត់ក្នុងវីរិយៈតែម្យ៉ាង ដូចជា អាតប-ស័ព្ទ, ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **អាតាបី** ប្រែថា មានសេចក្តីព្យាយាម ។

ម្យ៉ាងទៀត ការញ៉ាំងកិលេសនោះឲ្យក្តៅវិសេសក្រៃលែង បានដល់ វីរិយៈ ដែលប្រព្រឹត្តទៅ ដោយអំណាចការធ្វើសម្បយុត្តធម៌ទាំងឡាយ ឲ្យឧស្សាហ៍ក្រៃលែង ក្នុងការលះបង់ធម៌ដែលជាបដិបក្ខ ដូច្នេះ ទើបលោកហៅចំពោះវីរិយៈ តែម្យ៉ាងប៉ុណ្ណោះ មិនហៅចំពោះធម៌ដទៃនោះទេ ។

ឦ-អក្សរថា **អាតាបី** សម្តែងដល់ការសរសើរ ឬន័យថា វិសេសក្រៃលែង ។

សូម្បី វា-ស័ព្ទ ក្នុងពាក្យថា **វីរិយវា** ក៏គប្បីឃើញថា មានការសម្គាល់ដូច្នេះ ដូចគ្នា ។ ដោយបទថា **វីរិយវា** នោះ លោកអាចារ្យពោលដោយភាពជាអ្នកមានការព្រមព្រៀងដោយសម្មប្បធាន ។

ហេតុនោះ ទើបលោកអាចារ្យពោលថា ញ៉ាំងកិលេសឲ្យក្តៅទូទៅ និងឲ្យក្តៅដោយជុំវិញ ។

ក្នុងពាក្យនោះ ដោយស័ព្ទថា **អាតាបន** លោកអាចារ្យពោលដល់អារម្ភធាតុ ( ការប្រារព្ធ ) ព្រោះធ្វើអធិប្បាយថា បានដល់ ការផ្តើមនូវសេចក្តីព្យាយាមតាំងពីដើម, ដោយស័ព្ទ **បរិតាបន** លោក

ពោលដល់ **និក្កមធាតុ** និង **បរក្កមធាតុ** ព្រោះអាស្រ័យភាពជាអ្នកចេញចាកធម៌ដែលជាបដិបក្ខដោយប្រការទាំងពួង និងការដល់នូវគុណវិសេសខ្ពស់ឡើងៗ ។ ភិក្ខុឈ្មោះថា **និបកោ** ព្រោះអត្ថថា ញុំាងធម៌ដែលជាបដិបក្ខឲ្យស្ងួត គឺឲ្យហួតអស់ ឬព្រោះអត្ថថា រក្សា គឺឃុំគ្រងខ្លួនពី ធម៌ដែលជាបដិបក្ខនោះ បានដល់ អ្នកមានសម្បជញ្ញៈ ។

បញ្ញា ឈ្មោះថា **បារិហារិកា** ព្រោះអត្ថថា ប្រកបក្នុងការរក្សាកម្មដ្ឋាន ។

បញ្ញា ឈ្មោះថា **សព្វកិច្ចបរិណាយិកា** ព្រោះអត្ថថា កំណត់នាំទៅនូវកិច្ចគ្រប់យ៉ាង មានការឈានទៅខាងមុខជាដើម ដោយអំណាចសម្បជញ្ញៈ មានសាត្ថកសម្បជញ្ញៈជាដើម ។

ម្យ៉ាងទៀត បញ្ញាកំណត់នាំទៅនូវកិច្ចទាំងពួង មានជាអាទិ៍យ៉ាងនេះ គឺការរៀនកម្មដ្ឋាន ការសាកសួរ ការផ្ដើមភាវនា វិធីមនសិការ និងភាពជាអ្នកធ្វើដោយគោរពក្នុងកម្មដ្ឋាននោះ ភាពជាអ្នកធ្វើជាប់តគ្នា ភាពជាអ្នកធ្វើដោយសប្បាយ ជាអ្នកឆ្លាតក្នុងនិមិត្ត ជាអ្នកមានខ្លួនបញ្ជូនទៅហើយ ជាអ្នកមិនស្ទុតចិត្តក្នុងចន្លោះៗ ការញុំាងភាពស្មើគ្នានៃឥន្ទ្រីយ៍ឲ្យសម្រេច ការប្រកបសេចក្ដីព្យាយាមឲ្យស្មើគ្នា ឈ្មោះថា សព្វកិច្ចបរិណាយិកា ប្រែថា កំណត់នាំទៅនូវកិច្ចទាំងពួង ។

ដោយការពោលលក្ខណៈនៃភិក្ខុជាទូទៅថា ឈ្មោះថា ភិក្ខុ

ព្រោះអត្ថថា ឃើញភ័យ ដូច្នេះលោកអាចារ្យសម្ដែងថា ភាពជាភិក្ខុមានដោយការបដិបត្តិ មិនមែនមានដោយការសុំ និងភាពជាអ្នកប្រើផ្ទាំងសំពត់ជាច់ជាចជាដើមក៏ទេ ។ ដូច្នេះ ក៏សង្គ្រោះបុគ្គលទាំងឡាយនោះ មានសាមណេរជាដើម ជាអ្នកមានកិច្ច បានធ្វើហើយ និងអ្នកបដិបត្តិទាំងឡាយសូម្បីមិនបានបួស ។ ក្នុងទីនេះ គប្បីជ្រាបសេចក្ដីទាក់ទងជាមួយអ្នកបដិបត្តិ ។

ន័យម្យ៉ាងទៀត ឈ្មោះថា ភិក្ខុ ព្រោះអត្ថថា ទម្លាយអកុសលធម៌ដ៏លាមកទាំងឡាយ ។ ពាក្យថា គប្បីគ្នារនូវគ្រឿងចាក់ស្រែះ មានន័យថា ភិក្ខុណាជានរៈ ដែលមានបញ្ញាតាំងនៅក្នុងសីល មានការព្យាយាម មានបញ្ញារក្សាខ្លួន, ដែលទ្រង់ត្រាស់ថា អប់រំចិត្ត និងបញ្ញាហើយ, ភិក្ខុនោះអាចគ្នារនូវគ្រឿងចាក់ស្រែះគឺតណ្ហានេះបាន ។ ឥឡូវនេះ លោកអាចារ្យមានបំណងនឹងសម្ដែងនូវការគ្នារ គ្រឿងចាក់ស្រែះនោះ ប្រៀបធៀបជាមួយនឹងការគ្នារគុម្ពឫស្សី ទើបបញ្ជាក់នូវធម៌មានសីលជាដើម តាមដែលទ្រង់ត្រាស់ទុកក្នុងគាថាដោយពាក្យថា ដោយសីលនេះ ដូច្នេះជាដើម ។

ក្នុងបណ្ដាពាក្យទាំងឡាយនោះ កាលលោកអាចារ្យកាន់យកធម៌ មានសីលជាដើមនោះរួមគ្នា ក៏ពោលថា អ្នកប្រកបដោយធម៌ ៦ ប្រការ ដូច្នេះ ព្រោះធម៌ មានសីលជាដើម ដែលនៅក្នុងសន្តានរបស់

យោគាវចរកើតក្នុងខណៈផ្សេងគ្នា, ព្រះមានព្រះភាគកំណត់យកក្នុងព្រះគាថានេះដោយការបញ្ចូលគ្នា ។ ព្រោះធម៌ ៦ ប្រការ នោះនឹងបានក្នុងខណៈជាមួយគ្នាក្នុងសន្តានតែមួយក៏ទេ ។

ម្យ៉ាងទៀតព្រះភគវាទ្រង់ភាសិតព្រះគាថាដោយបុគ្គលាធិដ្ឋានដូច្នេះ ពេលលោកអាចារ្យសម្ដែងឧបមាដែលជាបុគ្គលាធិដ្ឋាននេះឯងទើបពោលពាក្យថា ប្រៀបដូចជាបុរស ដូច្នេះ ។

ក្នុងបណ្ដាពាក្យទាំងឡាយនោះ ពាក្យថា សំលៀងល្អហើយ គឺខាត់ឲ្យស៊ឹក យ៉ាងល្អ អធិប្បាយថា មុតយ៉ាងក្រៃលែងមិនអាចនឹងប្រៀបបាន ។ លោកអាចារ្យពោលឧបមាធ្វើនាទីទាំង ២ ប្រការនេះគឺការសំលៀងសស្ត្រាឲ្យជារបស់មុត ខ្លាំងលើថ្មសម្រាប់សំលៀង ១ ការលើកសស្ត្រានោះដោយកម្លាំងដៃ ១ ដូច្នេះ ពេលសម្ដែងនាទីទាំង ២ នោះ ទុកក្នុងពាក្យឧបមា ទើបពោលថា លើកសស្ត្រា គឺវិបស្សនាដែលសំលៀងល្អហើយលើសិលា គឺសមាធិ ដោយដៃ គឺបារិហារិយប្បញ្ញា ដែលកម្លាំង គឺវិរិយៈផ្គងហើយ ដូច្នេះ ។

ពិតហើយ បញ្ញាជាធម្មជាតិមុតក៏ដោយគុណ គឺសមាធិ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា អ្នកមានចិត្តតាំងមាំរមែងដឹងច្បាស់តាមសេចក្ដីពិត ។ ម្យ៉ាងទៀត វិរិយៈ ក៏ជាអ្នកឧបត្ថម្ភបញ្ញានោះ ព្រោះការផ្គងទុក ។ ពាក្យថា គប្បីច្ឆារ គឺអាចដើម្បីនឹងច្ឆារ ។

ពេលវុដ្ឋានគាមិនីវិបស្សនាប្រព្រឹត្តទៅហើយ ទើបយោគាវចរជាអ្នក ឈ្មោះថា អាចផ្ការនូវគ្រឿងចាក់ស្រែះ គឺតណ្ហា ។ ឯការផ្ការក្នុងទីនេះ បានដល់ ការលះបង់ដោយអំណាចសមុច្ឆេទប្បហាន ដូច្នេះ ទើប លោកអាចារ្យពោលថា គប្បីកាត់ គប្បីទម្លាយ បុគ្គលណាគួរដល់នូវ ទក្ខិណា ហេតុនោះបុគ្គលនោះ ឈ្មោះថា **ទក្ខិណេយ្យោ** ប្រែថា អ្នក គួរដល់ទក្ខិណា, បុគ្គលគួរដល់ទក្ខិណានោះផង ជាអ្នកដ៏លើសផង ហេតុនោះទើប ឈ្មោះថា **អគ្គទក្ខិណេយ្យោ** ប្រែថា អ្នកដែលគួរដល់ ទក្ខិណាដ៏លើស ។

ម្យ៉ាងវិញទៀត ទក្ខិណាដ៏លើស ឈ្មោះថា **អគ្គទក្ខិណា** ប្រែថា ទក្ខិណាដ៏ប្រសើរ បុគ្គលណា រមែងគួរដល់នូវទក្ខិណាដ៏លើសនោះ ហេតុនោះបុគ្គលនោះ ឈ្មោះថា **អគ្គទក្ខិណេយ្យោ** ប្រែថា អ្នកគួរដល់ ទក្ខិណាដ៏លើស ។

បទថា **តត្រ** មានន័យស្មើនឹង **តស្សំ** យោគ **គាថាយំ** ប្រែថា ក្នុងព្រះគាថានោះ ។ បទថា **អយំ** យោគ **នរោ ភិក្ខុ តិ ច វុត្តោ យោគាវចរោ** ប្រែថា យោគាវចរដែលត្រាស់ថា **នរះ** និងថា ភិក្ខុ ។ បទថា **តត្រ** តទៅ មានន័យស្មើនឹង **តស្សំ** យោគ **បញ្ញាយំ** ប្រែថា ក្នុងបញ្ញានោះ ។ បទថា **អស្ស** យោគ **ភិក្ខុនោ** ប្រែថា ភិក្ខុនោះ ។ បទថា **អស្ស** នេះជាឆដ្ឋីវិភត្តិចុះក្នុង **កត្តុ** មានន័យស្មើគ្នានឹង **អនេន**

ប្រែថា ភិក្ខុនោះ ។ កិច្ចដែលភិក្ខុនោះនឹងគួរធ្វើមិនមាន ព្រោះបញ្ញាក្នុងតិហេតុកបដិសន្ធិ គ្មានការកំណត់សេចក្ដីផ្សេងៗ ទេ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះបញ្ញានោះសម្រេចហើយដោយអានុភាពនៃកម្ម ក្នុងកាលមុននោះឯង ។ បទថា **តេន យោគយោគិនា** ប្រែថា ដែលយោគីនោះ ។ ឈ្មោះថា ជាអ្នកធ្វើជាប់តគ្នាព្រោះភាពជាអ្នកមានព្យាយាមប្រព្រឹត្តទៅជាប់តគ្នាក្នុងភាវនា ។ ពាក្យថា ដោយអំណាចនៃបញ្ញា គឺដោយអំណាចនៃបញ្ញា ពោល គឺបញ្ញារក្សាខ្លួនតាមដែលបានពោលហើយ ។ កិច្ចយ៉ាងណាមួយដែលគួរធ្វើ, ភិក្ខុធ្វើនូវកិច្ចនោះទាំងអស់ជាប្រក្រតី ដោយអំណាចការដឹងដ៏ប្រពៃ ហេតុនោះភិក្ខុនោះ ឈ្មោះថា **សម្បជានការី** អ្នកមានការប្រព្រឹត្តិជាប្រក្រតី ដោយអំណាចការដឹងត្រូវ,ម្យ៉ាងទៀត ការធ្វើការយល់ត្រូវក្នុងកិច្ចនោះ មានដល់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះឈ្មោះថា សម្បជានការី អ្នកមានការប្រព្រឹត្តិត្រូវល្អ,ន័យម្យ៉ាងទៀតភិក្ខុណាធ្វើការដឹងខ្លួន គឺការមិនវង្វេង បានដល់ ឲ្យកើតឡើង ហេតុនោះ ភិក្ខុនោះ ឈ្មោះថា សម្បជានការី ជាអ្នកធ្វើសេចក្ដីដឹងខ្លួន, ភិក្ខុជាអ្នកធ្វើការដឹងដ៏ប្រពៃ ។ បទថា **អត្រ** មានន័យស្មើ **អស្សំ យោគ គាថាយំ** ប្រែថា ក្នុងគាថានោះ ។ ព្រោះការព្យាយាមជាអង្គរបស់ធម៌ទាំងឡាយនោះ ក្នុងការញ៉ាំងគុណ មានសីលជាដើម ឲ្យដល់ព្រម ទើបលោក

អាចារ្យមិនកាន់យកការព្យាយាមនោះជាផ្នែកមួយ ពោលថា ដោយមុខ គឺសីល សមាធិ និងបញ្ញា ។

លោកអាចារ្យ កាលពោលសេចក្ដីរួមនៃទេសនា ដោយមិនចែកថា ព្រះមានព្រះភាគសម្ដែងផ្លូវនៃសេចក្ដីបរិសុទ្ធិ ដូច្នេះហើយ បំណងនឹងសម្ដែងសេចក្ដីរួមនោះ ដោយការចែកទៀត ទើបពោលពាក្យថា ដោយលំដាប់នៃពាក្យមានប្រមាណប៉ុណ្ណោះគឺដោយទេសនាត្រឹមប៉ុណ្ណោះ ដូច្នេះជាដើម ។

ក្នុងបណ្ដាពាក្យទាំងឡាយនោះពាក្យថា ដោយលំដាប់នៃពាក្យត្រឹមប៉ុណ្ណោះ គឺដោយទេសនាត្រឹមប៉ុណ្ណោះ ។ ពាក្យថា សិក្ខា មានន័យថា ឈ្មោះថា សិក្ខា ព្រោះអត្ថថា គួរសិក្សា ។ គប្បីយល់ថា ការសិក្សាក្នុងទីនេះ បានដល់ ការសេពរហូតបានជាទម្លាប់ ។

ពិតហើយ បុគ្គលពេលសេពរហូតដល់ធ្លាប់ក្នុងធម៌ មានសីលជាដើម ដោយអំណាចការសង្រួមជាដើម ហៅថា សិក្សាធម៌មានសីលជាដើមទាំងឡាយនោះ ។

ពាក្យថា **សាសនា** បានដល់ បដិបត្តិសាសនា ។ ឧបនិស្ស័យ បានដល់ ហេតុដែលមានកម្លាំង ។ ការវៀរ បានដល់ ការមិនចូលទៅជិត ។ ការសេព បានដល់ ការចម្រើន ។ ពាក្យថា **បដិបក្ខ** បានដល់ បដិបក្ខដែលជាគូលះបង់ ។

ក្នុងព្រះគាថា ព្រះមានព្រះភាគត្រាស់ទុកជាសាមញ្ញថា ក្នុងសីល ត្រាស់ថា ក្នុងអធិសីល ក៏ទេ ។ សូម្បីយ៉ាងនោះ ក៏ទ្រង់ត្រាស់បំណងយកសីលនោះ ដែលជាទីតាំងនៃការផ្ការទូវគ្រឿងចាក់ស្រែះ គឺតណ្ហា ព្រោះហេតុនោះ ទើបលោកពោលថា អធិសីលសិក្ខានេះទ្រង់ប្រកាសហើយដោយសីល ។

ពិតហើយ សីលដែលជាហេតុញ៉ាំងសត្វឲ្យទៅកាន់ភព គឺជាសីល ( ធម្មតា ) នោះឯង សីលដែលញ៉ាំងសត្វឲ្យបានដល់ព្រះនិព្វាន គឺជាអធិសីលសិក្ខា ។

ក៏ពាក្យក្រើនរំលឹកដោយសាមញ្ញ រមែងតាំងចុះក្នុងសេចក្ដីពិសេសបាន ក្នុងសិក្ខាដ៏សេស ក៏មានន័យដូចគ្នា ។

ពាក្យថា ដោយសីល គឺដោយសីលដែលជាអធិសីលសិក្ខា ។

ពិតហើយ សីលនោះរមែងប្រកាសអំពីសាសនាដែលមានលម្អបទដើម ព្រោះជាពាក្យប្រៀនប្រដៅដែលមិនទូទៅដល់សាសនាដទៃ, សីល ត្រឹមតែថា សីល មាន **យមសីល** និង **និយមសីល** ជាដើម ក៏ប្រកាសមិនបាន ។ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សីលដែលបរិសុទ្ធល្អហើយ ១ និងការមិនធ្វើបាបទាំងពួង ដូច្នេះ ។

ពាក្យថា នៃកុសលធម៌ទាំងឡាយ បានដល់ នៃមគ្គកុសលទាំងឡាយ ។

ម្យ៉ាងវិញទៀត ពាក្យថា នៃកុសលធម៌ទាំងឡាយ បានដល់ នៃធម៌ទាំងឡាយដែលមិនមានទោស ។ តាមពាក្យថា **នៃកុសលធម៌ទាំងឡាយនោះ** ក៏ជាការសម្រេចនូវការប្រមូលធម៌ គឺអរិយផលទាំងឡាយចូលផងដែរ ។

ពាក្យថា មិនធ្វើបាបទាំងពួង បានដល់ ការមិនធ្វើ ការមិនត្រូវកម្ម មានទោសទាំងពួង ។ ដោយពាក្យថា រមែងធ្វើការកាន់យកសីលទាំងពួងដែលផ្សេង ដោយចារិត្តសីលនិងវារិត្តសីល ។ ពិតហើយ ការមិនធ្វើកម្មទាំងពួងក៏មានទោស ដូចគ្នាដូច្នេះឯង ។ បទថា **អាទិវចនតោ** មានន័យថា ព្រោះទ្រង់ត្រាស់ទុកជាខាងដើមនៃសមាធិ និងបញ្ញាដែលត្រាស់ទុកក្នុងគាថា ។ សីលនោះឯងជាខាងដើម ព្រោះឧត្តរិមនុស្សធម៌ទាំងឡាយមានសីលនោះជាមូល ។ ន័យម្យ៉ាងទៀត ការត្រាស់នូវធម៌ដែលជាខាងដើមទាំងឡាយ ឈ្មោះថា **អាទិវចនំ** ប្រែថា ការត្រាស់នូវធម៌ដែលជាខាងដើម ។ ដោយ អាទិ-ស័ព្ទ ក្នុងទីនេះ គប្បីជ្រាបនូវការសង្គ្រោះធម៌ទាំងឡាយជាអាទិយ៉ាងនេះ គឺសីល សមាធិ បញ្ញា និងវិមុត្តិ ដែលជាកំពូល ។ ព្រោះសីលជាគុណជាតិបរិសុទ្ធ ទើបសីលនាំមកនូវគុណ មានការមិនមានវិប្បដិសារីជាដើម ព្រោះធ្វើហេតុនៃវិប្បដិសារីជាដើមឲ្យឃ្លាតឆ្ងាយ ។

បណ្ឌិតគប្បីយល់ដោយពាក្យថា ព្រោះនាំមកនូវគុណ មានការ

មិនមានវិប្បដិសារីជាដើមនេះ ព្រះមានព្រះភាគទ្រង់សម្តែងនូវសីល ដោយគុណ មានភាពស្អាតតែម្យ៉ាងនោះក៏ទេ តាមពិត ទ្រង់សម្តែង នូវភាពជាខាងដើមផងដែរ ។ ពិតហើយ ព្រះមានព្រះភាគត្រាស់នូវ សីលនោះជាបច្ច័យតៗ នៃធម៌ទាំងឡាយ មានការមិនមានវិប្បដិសារី ជាដើម មានវិមុត្តិញ្ញាណជាទីបំផុតទុកក្នុងព្រះសូត្រ ។

ពាក្យថា ដោយសមាធិ គឺដោយសមាធិដែលជាអធិចិត្តសិក្ខា ។

ក្នុងព្រះគាថា ដែលរួបរួមព្រះសាសនាទាំងអស់ ដោយហេតុ ព្រោះសីល គប្បីបដិបត្តិជាខាងដើម ទើបលោកកាន់យកដោយបទ ដើម ព្រោះបញ្ញាគប្បីបដិបត្តិក្នុងទីបំផុត ទើបលោកកាន់យកដោយ បទទី ៣ លោកអាចារ្យកាន់យកសមាធិ ដែលគប្បីបដិបត្តិក្នុងបទ កណ្តាលដោយបទទី ២ ដោយបារិសេសន័យ ។ ទើបលោកអាចារ្យ ពោលទុកថា ពិតហើយ សមាធិជាបទកណ្តាលនៃព្រះសាសនា ព្រោះ ព្រះបាលីថា **កុសលស្ស ឧបសម្បទា** ការញុំាងកុសលធម៌ឲ្យដល់ព្រម ដូច្នេះជាដើម, មិនមែនពោលព្រោះកុសលស័ព្ទជាបរិយាយរបស់ សមាធិនោះទេ ។ ព្រះយោគីដែលមានឧបនិស្ស័យក្នុងកាលមុន ជា អ្នកគួរដល់អភិនីហារដែលប្រកបដោយអង្គ ៨ មានភាពជាអ្នកមាន ចិត្តតាំងមាំជាដើម ជាការនាំមកនូវគុណ មានឥទ្ធិវិធី ការសម្តែងឫទ្ធិ បានជាដើមនៃសមាធិ, កាលបានសម្រេចនូវបញ្ញាក្នុងអរិយមគ្គហើយ

កុលបុត្តរមែងបួសដើម្បីប្រយោជន៍ណា ប្រយោជន៍នោះសម្រេចហើយ ព្រោះហេតុនោះ ទើបបញ្ញាជាទីបំផុតនៃព្រះសាសនា ។

ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកនៅចប់ព្រហ្មចរិយនេះហើយ មានសិក្ខាជាអានិសង្ស មានសទ្ធាជាធំ មានបញ្ញាជាកំពូល មានវិមុត្តិជាខ្លឹម ដូច្នេះ ។ចិត្តរបស់ខ្លួន ឈ្មោះថា **សចិត្តំ** ប្រែថា ចិត្ត របស់ខ្លួន ។ ការធ្វើចិត្តរបស់ខ្លួនឲ្យបរិសុទ្ធដោយការលះកិលេសបានជាសមុច្ឆេទ ដោយប្រការទាំងពួង ឈ្មោះថា ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ ។គប្បីជ្រាបសេចក្តីដែលព្រះសាសនាមានបញ្ញាជាកំពូល ព្រោះពេលកិច្ចនៃបញ្ញាដល់ទីបំផុត យ៉ាងនេះក៏មិនមានកិច្ចដែលគប្បីធ្វើឲ្យក្រៃលែងឡើងទៅទៀតទេ ។

ពាក្យថា ព្រោះភាពជាអ្នកនាំមកនូវភាពមាំទាំ សេចក្តីថា ជាបុគ្គលធម្មតា ក្នុងឥដ្ឋារម្មណ៍ទាំងឡាយនិងក្នុងលោកធម៌ មានលាភជាដើម, ព្រោះមិនមានភាពរីករាយ ក៏ដូចគ្នាក្នុងអនិដ្ឋារម្មណ៍ទាំងឡាយនិងក្នុងសេចក្តីវិនាសលាភជាដើម ព្រោះមិនមានការទាស់ចិត្ត ។ន័យម្យ៉ាងទៀត ព្រោះហេតុនោះឯង បុគ្គលធម្មតា ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ដែលមិនទាន់មកកាន់គន្លង ក៏ដូចគ្នាក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ដែលមកកាន់គន្លងហើយ ព្រោះហេតុនោះ បុគ្គលនោះទើបឈ្មោះថា **តាទី** ( ប្រែថា បុគ្គលដូច្នោះ សំដៅដល់អ្នកមាំទាំ ) ។

ភាវៈនៃបុគ្គលដែលជា **តាទី** នោះ ឈ្មោះថា **តាទិភាវ** ( ប្រែថា ភាពជាអ្នក ដូច្នោះ គឺភាពជាអ្នកមាំទាំ ) ព្រោះនាំមកនូវភាពជាអ្នករឹងមាំនោះ ។ ពាក្យថា ដោយខ្យល់ គឺព្រោះខ្យល់ជាហេតុ ។ បទថា **ន សមីរតិ** ប្រែថា រមែងមិន ញាប់ញ័រ ។ បទថា **ន សមិញ្ជតិ** ប្រែថា មិនកម្រើក អធិប្បាយថា ភាពញាប់ញ័រ នឹងមានមកពីទីណា ។

បទថា **តថា** មានន័យថា តថា-សទ្ទ មានអត្ថថា រូបរូមវិធី ប្រកាសធម៌ទាំងឡាយនោះថា ធម៌ទាំងឡាយមានសីលជាដើម ប្រកាសធម៌ទាំងឡាយ មានអធិសីលសិក្ខាជាដើម យ៉ាងណា, ក៏ប្រកាសឧបនិស្ស័យនៃភាពជាអ្នកបានវិជ្ជា ៣ ជាដើមដូច្នេះ ។ ព្រោះសីល កាលបើបរិសុទ្ធ រមែងបរិសុទ្ធដោយកម្លាំងនៃសតិសម្បជញ្ញៈ និងរមែងប្រាសចាកនូវមន្ទិល គឺសង្កិលេស ហើយដល់នូវភាពបរិបូរណ៍ដោយកម្លាំង គឺកម្មស្សកតាញាណ, ដូច្នោះសីលសម្បទាពេលសម្រេច រមែងញុំាងកម្លាំង គឺសតិ និងកម្លាំង គឺញាណឲ្យចូលទៅតាំងទុកដោយភាពជាឧបនិស្សយសម្បត្តិ ព្រោះហេតុនោះ គប្បីជ្រាបថា សេចក្តីដែលសីលសម្បទាជាឧបនិស្ស័យនៃវិជ្ជា ៣ ព្រោះញុំាងហេតុដែលជាសភាគៈគ្នាឲ្យសម្រេច ។

ពិតហើយ វិជ្ជា គឺបុព្វេនិវាសញ្ញាណសម្រេចបានក៏ដោយសតិរក្សាខ្លួន, វិជ្ជាទី ២ ដែលទាក់ទងដោយចុតូបបាតញ្ញាណសម្រេចបាន

ដោយសម្បជញ្ញៈ ដោយភាពធ្លាប់ ឬភាពជាអ្នកមានប្រក្រតីឃើញបានក្នុងកិច្ចទាំងពួង, វិជ្ជាទី ៣ សម្រេចបានក៏ដោយភាពបរិសុទ្ធិនៃអធ្យាស្រ័យដោយអំណាចនៃឧបនិស្ស័យនៃវិវដ្ដៈ ព្រោះភាវៈគឺការលះសង្កិលេសដោយមិនមានការកន្ទុំងល្មើស ។ ការដែលសីលជាឧបនិស្ស័យនៃអាសវក្ខយញ្ញាណ ដោយរៀវភាពបរិបូរណ៍នៃសមាធិនិងបញ្ញាដែលសម្រេចមកពីពេលមុន បណ្ឌិតគប្បីសម្ដែងដោយព្រះទីណាស្រេចដែលជាសុខវិបស្សកៈ ។

លោកអាចារ្យពោលថា មិនមែនអាស្រ័យហេតុដទៃក្រៅពីសីលនោះ ព្រោះធ្វើអធិប្បាយថា សីលមិនមែនជាហេតុដែលជាសភាគៈគ្នានៃអភិញ្ញា និងបដិសម្ភិទា ដូចជាសមាធិ និងបញ្ញានោះទេ ។សមាធិសម្បទាជាឧបនិស្ស័យនៃការបានអភិញ្ញា ៦ ព្រោះព្រះបាលីថា អ្នកដែលមានចិត្តតាំងមាំ រមែងដឹងច្បាស់តាមសេចក្ដីពិត ។ សមាធិមិនមែនជាហេតុ ជាសភាគៈគ្នានៃបដិសម្ភិទាទាំងឡាយ ដូចជាបញ្ញាទេ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា មិនមែនអាស្រ័យហេតុដទៃក្រៅពីសមាធិនោះ ។ បញ្ញាសម្បត្តិ ដែលបានអប់រំមកហើយដោយការប្រកបមកក្នុងអតីតដោយព្រះបាលីថា បញ្ញាតែងកើតព្រោះការប្រកប និងដោយការនៅជាមួយគ្រូ ភាពជាអ្នកឆ្លាតក្នុងភាសាតាមតំបន់ និងរៀនពិនិត្យតាមជាដើម ជាឧបនិស្ស័យនៃការ

បែកធ្លាយដោយបដិសម្ភិទា សូម្បីបច្ចេកពោធិញ្ញាណ និងសម្មាសម្ពោធិញ្ញាណ ក៏មានបញ្ញាសម្បត្តិជាទីអាស្រ័យ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា មិនក្រៃលែងជាងនោះ ជាខាងក្រោយពោលថា មិនមែនដោយហេតុដទៃ ព្រោះគុណវិសេសដែលមិនសម្រេចដោយបញ្ញាមិនមាន ព្រោះបញ្ញានោះឯង គឺជាហេតុតែម្យ៉ាងក្នុងការបែកធ្លាយនៃបដិសម្ភិទា ។

ក្នុងអធិការនេះលោកអាចារ្យពោលថា ព្រោះបុគ្គលអាស្រ័យសីលសម្បត្តិ ដូច្នេះ អភិញ្ញាទាំង ៦ ដែលជាអាការរបស់សមាធិមិនទាន់បានសម្រេចដល់ព្រះអរិយបុគ្គលណា សមាធិសម្បទាដែលកំណត់យ៉ាងឧក្រិដ្ឋ ឈ្មោះថា មិនទាន់មានដល់ព្រះអរិយបុគ្គលនោះដែរ ។

សូម្បីមានវិជ្ជាទាំងឡាយ ជាចំណែកមួយរបស់អភិញ្ញា ក៏លោកកាន់យកវិជ្ជា ៣ ដែលកើតឡើងព្រោះសីលសម្បត្តិប៉ុណ្ណោះ ។

ដូចជាបដិសម្ភិទា ៤ ដែលកើតឡើងដោយបញ្ញាសម្បត្តិ រមែងសម្រេចដោយមគ្គប៉ុណ្ណោះ ចំពោះបុគ្គលដែលដល់ព្រមដោយឧបនិស្ស័យ ព្រោះបដិសម្ភិទាប៉ុណ្ណោះ ដែលគប្បីបានចំពោះក្នុងខណៈនៃមគ្គនោះឯង យ៉ាងណា វិជ្ជា ៣ ដែលកើតឡើងដោយសីលសម្បត្តិ និងអភិញ្ញា ៦ដែលកើតឡើងដោយសមាធិសម្បត្តិក៏រមែងបានសម្រេច

ដោយមគ្គនោះឯង ដល់បុគ្គលដែលជាអ្នកដល់ព្រមដោយឧបនិស្ស័យ ព្រោះហេតុនោះ គប្បីជ្រាបនូវការសម្រេចវិជ្ជា និងបដិសម្ភិទាទាំងឡាយនោះដោយការសម្រេចមគ្គនោះ ។ ការសម្រេចគុណវិសេសទាំងឡាយនេះរបស់ព្រះអរិយៈទាំងឡាយនេះ ដូចគ្នានឹងការសម្រេចបច្ចេកពោធិញ្ញាណរបស់ព្រះបច្ចេកពុទ្ធ និងការសម្រេចសម្មាសម្ពោធិញ្ញាណរបស់ព្រះសម្មាសម្ពុទ្ធ ។ សូម្បីសីលដែលជាឧបនិស្ស័យដល់ភាពជាអ្នកបានវិជ្ជា ៣ ជាដើម ដោយការបដិបត្តិល្អក្នុងព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្ម បណ្ឌិតគប្បីជ្រាបតាមវិធីដូចដែលបានពោលហើយចុះ ។

ការវៀរទីបំផុតខាងដំបូង លោកអាចារ្យពោលដោយសីល ព្រោះបុគ្គលដែលមានសីលដល់ព្រមហើយ មិនមានការសេពកាម ។ ពិតហើយ សត្វទាំងឡាយ ដែលមានប្រយោគមិនបរិសុទ្ធ សូម្បីទាក់ទងជាមួយបាណាតិបាតជាដើម ក៏ព្រោះកាមជាហេតុដោយច្រើន ។ អ្នកដែលមានប្រក្រតីបានសេចក្តីសុខក្នុងឈាន ក៏រមែងមិនមានការកើតនូវការលំបាកកាយដូចគ្នា ព្រោះហេតុនោះ ទើបលោកអាចារ្យពោលនូវការវៀរ ទីបំផុតខាងទី ២ ដោយសមាធិ ព្រោះជាអ្នកមានរូបកាយប្រណីត ដែលមានឈានជាសម្ពុដ្ឋានពាល់ត្រូវហើយ ។ ពាក្យថា ដោយបញ្ញា បានដល់ដោយមគ្គប្បញ្ញា ។ ពិតហើយ ដោយការកំណត់

យ៉ាងឧក្រិដ្ឋអរិយមគ្គប៉ុណ្ណោះ ឈ្មោះថា មជ្ឈិមាបដិបទាតែម្យ៉ាង ។ សូម្បីយ៉ាងនេះ ក៏គប្បីអធិប្បាយនូវការវៀរចាកទីបំផុតទាំង ២ សូម្បីដោយអំណាចលោកិយប្បញ្ញា ។ សីលជាហេតុនៃការរួចផុតពីអបាយទាំង ៤ ព្រោះញ៉ាំងបុគ្គលដែលមានការព្រមព្រៀង ដោយសីលនោះឲ្យកើតក្នុងកាមសុគតិប៉ុណ្ណោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា រមែងប្រកាសឧបាយជាគ្រឿងឈានកន្លងអបាយដោយសីល ដូច្នេះ ។

ពិតហើយការវៀរចាកបាបកម្មមានបាណាតិបាតជាដើម រមែងមិននាំមក នូវភាពសៅហ្មងក្នុងទុគ្គតិ ។

សមាធិ រមែងញ៉ាំងបុគ្គលឲ្យរួចផុតចាកកាមភពទាំងអស់ដោយការញ៉ាំងបុគ្គលដែលមានការព្រមព្រៀងដោយសមាធិនោះ ឲ្យកើតក្នុងមហគ្គតភូមិនោះឯង ហេតុនោះទើបលោកអាចារ្យពោលថា រមែងជាការប្រកាសឧបាយ ជាគ្រឿងឈានកន្លងកាមធាតុដោយសមាធិ ដូច្នេះ ។ ពិតហើយ ឈានដែលគ្របសង្កត់នីវរណៈមានកាមច្ឆន្ទៈជាដើម ដែលចាំថែមកម្លាំងឲ្យដល់កាមាវចរកម្ម មិនមែនជាធម្មជាតិដែលនាំសេចក្តីសៅហ្មងក្នុងកាមធាតុមកឲ្យទេ ។ ក្នុងសេចក្តីនេះមិនគប្បីសម្តែងដោយឧបចារសមាធិ ព្រោះលោកសំដៅយកអប្បនា-សមាធិ ។ ទាំងមិនមែនជាឱកាសក្នុងការពោលថា អបាយភព ឈាន

កន្លងបានដោយសីលតែប៉ុណ្ណោះ (ដោយពិត) ឈានកន្លងបានដោយសមាធិដែរ ដូច្នេះ ។ អ្នកដែលឈានកន្លងសុគតិភពទៅហើយ ចាំបាច់ពោលថ្វីដល់ការឈានកន្លងទុគ្គតិ ។

ពាក្យថា ឧបាយជាគ្រឿងឈានកន្លងភពទាំងពួង បានដល់ឧបាយជាគ្រឿងកន្លងភពទាំង៩មានកាមភពជាដើម ។ភពទាំងឡាយសូម្បីឈានកន្លង ហើយដោយសីល និងសមាធិ ក៏មិនទាន់ឈានកន្លង ព្រោះលះហេតុមិនទាន់បាន តែភពទាំងឡាយនោះឈានកន្លងបាន ព្រោះលះបង់ហេតុនោះបានយ៉ាងល្អដោយបញ្ញា ។

ពាក្យថា ដោយអំណាចតទង្គប្បហាន មានន័យថា ដោយអំណាចលះអង្គនៃអកុសលនោះៗ ដោយអង្គនៃកុសលនោះៗ ក្នុងបុញ្ញកិរិយាវត្ថុដូចជាលះបង់ភាពងងឹតបានដោយពន្លឺនៃប្រទីបដូច្នោះ ។

ពាក្យថា ការលះកិលេសដោយអំណាចវិក្ខម្ភនប្បហាន ដែលទ្រង់ប្រកាស ដោយសមាធិ មានន័យថា ការលះកិលេសដោយអំណាចការលះនីវរណធម៌ជាដើមនោះៗ ដោយការហាមការប្រព្រឹត្តទៅ ដូចជាការការពារលើផ្ទៃទឹកដោយការប្រើថ្នាំងបណ្ដែតទៅ ទ្រង់ប្រកាសដោយសមាធិដែលផ្សេងដោយឧបចារ និងអប្បនា ។ ពាក្យថា ដោយបញ្ញា បានដល់ ដោយអរិយមគ្គប្បញ្ញា ។ ពាក្យថា ដោយអំណាចសមុច្ឆេទប្បហាន មានន័យថា ដោយអំណាចការលះបាន

យ៉ាងដាច់ខាត ពោល គឺប្រព្រឹត្តទៅមិនបានយ៉ាងដាច់ខាតរបស់ពួកកិលេសដែលចាត់ជាសមុទយៈ ដូចទ្រង់ត្រាស់ដោយន័យថា ពេលលះទិដ្ឋិជាដើមក្នុងសន្តានរបស់ខ្លួន របស់អ្នកដែលមានមគ្គនោះ ព្រោះបានញុំាងអរិយមគ្គ ៤ ឲ្យកើតឡើងហើយ ។ ពាក្យថា ធម៌ដែលជាបដិបក្ខដល់វីតិក្កមនៃកិលេស មានន័យថា ធម៌ដែលជាបដិបក្ខដល់វីតិក្កមៈ គឺការប្រព្រឹត្តិកន្លងផ្លូវកាយទ្វារ និងវចីទ្វារនៃសង្កិលេសធម៌ ឬកម្មកិលេសទាំងឡាយ លោកប្រកាសហើយដោយសីល ព្រោះសីលមានភាវៈមិនឈានកន្លង ។ កិលេសដែលតាំងឡើងគ្របសង្កត់ការប្រព្រឹត្តិទៅនៃកុសលក្នុងចិត្ត ដោយអំណាចការមិនឲ្យឱកាសឈ្មោះថា **បរិយុដ្ឋាន** ។ សមាធិរមែងគ្របសង្កត់បរិយុដ្ឋាននោះដូច្នោះ ទើបលោកពោលថា ធម៌ដែលជាបដិបក្ខដល់បរិយុដ្ឋាន ទ្រង់ប្រកាសដោយសមាធិ ។ ព្រោះសមាធិជាធម៌លះបរិយុដ្ឋាន ។ កិលេសដែលដេកត្រាំរឿយៗក្នុងសន្តាន ព្រោះមិនទាន់លះបង់បាន កាលមានហេតុដល់ព្រមហើយក៏កើតឡើង ឈ្មោះថា អនុសយ,អនុស័យទាំងឡាយនោះ មានហេតុសមគួរហើយ ក៏កើតឡើង គប្បីជ្រាបថា បានដល់កិលេស ៧ មានកាមរាគៈជាដើមដែលខ្លាំងក្លា ។ កិលេសទាំងឡាយនោះនឹងលះបានដោយប្រការទាំងពួងក៏ដោយអរិយមគ្គប្បញ្ញា ដូច្នោះទើបលោកពោលថា ធម៌ដែលជាបដិបក្ខដល់អនុស័យ ទ្រង់ប្រកាស

ហើយដោយបញ្ញា ។

ធម្មជាតិឈ្មោះថា ទុច្ចរិត ព្រោះអត្ថថា ការប្រព្រឹត្តិអាក្រក់ មានកាយទុច្ចរិតជាដើម ឬការប្រព្រឹត្តិដែលត្រូវកិលេសប្រទូស្តរាយហើយ ទុច្ចរិតនោះៗឯងកើតឡើងក្នុងសន្តានណាក៏ធ្វើសន្តាននោះឲ្យសៅហ្មង គឺឲ្យលំបាក និងចូលទៅដុតកម្តៅ ដូច្នោះទើបឈ្មោះថា សង្កិលេស, ការជម្រះសង្កិលេសនោះ គឺការលះបង់ដោយអំណាចតទង្គប្បហាន ដោយសីល ព្រោះសីលជាបដិបក្ខនូវសេចក្តីល្មើស ។ ការជម្រះសង្កិលេសគឺតណ្ហា គឺលះដោយអំណាចវិក្ខម្ភនប្បហាន ព្រោះសមាធិជាបដិបក្ខដល់បរិយុដ្ឋាន ហើយសមាធិនោះឯងជាបដិបក្ខដោយត្រង់ចំពោះតណ្ហា ។ ការជម្រះសង្កិលេស គឺទិដ្ឋិ លះដោយអំណាចសមុច្ឆេទប្បហាន ព្រោះបញ្ញាជាបដិបក្ខដល់អនុស័យ និងព្រោះបញ្ញាមានប្រក្រតីកាន់យកតាមសេចក្តីពិត ដែលជាបដិបក្ខដោយត្រង់ចំពោះទិដ្ឋិ ដែលមានប្រក្រតីកាន់យកការមិនពិត ។

ពាក្យថា ហេតុ គឺឧបនិស្សយប្បច្ច័យ ។ ពាក្យថា ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ មានន័យថា ព្រោះលោកមិនល្មើសក្នុងសិក្ខាបទទាំងឡាយ ដែលជាមហាសីល ពោល គឺបារាជិក និងសង្ឃាទិសេសដែលជាអាទិនៃព្រហ្មចារិយសិក្ខា ព្រោះជាខាងដើមរបស់មគ្គព្រហ្មចារ្យ ពេលលោកត្រូវអាបត្តិតូចៗ កិច្ចណា ដែលគប្បីធ្វើ

ក្នុងសីលទាំងឡាយដោយការចេញចាកអាបត្តិតូចៗ ទាំងឡាយនោះ ភ្លាមៗ លោកតែងធ្វើកិច្ចនោះឲ្យបរិបូណ៌ គឺឲ្យពេញលេញ ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ។ ដោយ តថា-ស័ព្ទ ក្នុងពាក្យថា **តថា សកទាគាមី** រមែងពង្រីកពាក្យនេះថា **សីលេសុ បរិបូរីការី** ។

ព្រះអរិយៈ ២ ជំពូកនេះ កាលចម្រើនសមាធិ និងបញ្ញា ព្រោះហេតុដែលលោកលះមិនទាន់បាន ដោយប្រការទាំងពួងនូវកាមរាគៈ និងព្យាបាទ ដែលជាអន្តរាយដល់សមាធិ និងមោហៈ ជាតួបិទបាំងនូវសច្ចៈ ដែលជាអន្តរាយដល់បញ្ញា ក៏រមែងធ្វើកិច្ចដែលគប្បីធ្វើក្នុងសមាធិនិងបញ្ញាតែល្មមប្រមាណ ត្រឹមចំណែកខ្លះប៉ុណ្ណោះ ដូច្នេះ អ្នកមានប្រក្រតីធ្វើឲ្យល្មមប្រមាណក្នុងសមាធិនិងបញ្ញាលោកក៏ហៅ ថា **សីលេសុ បរិបូរីការិនោ** ជាអ្នកមានប្រក្រតីធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ដូចគ្នា ។ ចំណែកព្រះអនាគាមី ឈ្មោះថា មានប្រក្រតីធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ព្រោះលះកាមរាគៈ និងព្យាបាទ បានជាសមុច្ឆេទហើយ ។

ព្រះអរហន្តឈ្មោះថា **ធ្វើឲ្យបរិបូណ៌ក្នុងបញ្ញា** ព្រោះលះបង់សម្មោហៈបានជាសមុច្ឆេទហើយ ដោយប្រការទាំងពួង ។

សមដូចព្រះសាស្តាត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុង

ធម្មវិន័យនេះជាអ្នកធ្វើសីលឲ្យបរិបូណ៌,ជាអ្នកធ្វើឲ្យល្មមប្រមាណក្នុងសមាធិ ជាអ្នកធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា ។ ជាអ្នកកន្លងសិក្ខាបទតូចៗ ខ្លះ រមែងចេញចាកអាបត្តិខ្លះ សេចក្តីនេះព្រោះហេតុអ្វី ? ម្នាលភិក្ខុទាំងឡាយ ព្រោះមិនមាននរណាពោលនូវភាពជាបុគ្គលអភ័ព្វ ព្រោះកន្លងសិក្ខាបទនេះ ។តែថា សិក្ខាបទទាំងឡាយនោះជាខាងដើមនៃព្រហ្មចរិយៈ សមគួរដល់ព្រហ្មចរិយៈ លោកជាអ្នកមានសីលជានិច្ច និងជាអ្នកមានសីលតាំងមាំនៅក្នុងសិក្ខាបទទាំងឡាយនោះ សមាទានសិក្សាក្នុងសិក្ខាទាំងឡាយ ។លោកជាព្រះសោតាបន្នព្រោះលះបង់សំយោជនៈ ៣ អស់ទៅ ជាអ្នកដែលមានការមិនធ្លាក់ចុះជាធម្មតា ជាអ្នកទៀងតែនឹងបានត្រាស់ដឹងនាពេលខាងមុខ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះជាអ្នកធ្វើសីលឲ្យបរិបូណ៌ ជាអ្នកធ្វើឲ្យល្មមប្រមាណក្នុងសមាធិ និងជាអ្នកធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា រមែងជាអ្នកកន្លងអាបត្តិតូចៗ ខ្លះ រមែងជាអ្នកចេញចាកអាបត្តិខ្លះ សេចក្តីនោះព្រោះហេតុអ្វី ? ព្រោះមិនមាននរណាពោលនូវភាពជាបុគ្គលអភ័ព្វ ព្រោះកន្លងសិក្ខាបទនេះតែថា សិក្ខាបទទាំងឡាយណាដែលជាខាងដើមនៃព្រហ្មចរិយៈ សមគួរដល់ព្រហ្មចារ្យ លោកជាអ្នកមានសីលជានិច្ច និងមានសីលតាំងមាំនៅក្នុងសិក្ខាបទទាំងឡាយនោះ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ លោកជា

ព្រះសកទាគាមី ព្រោះសំយោជនៈ ៣ អស់ហើយ និងព្រោះរាគៈ ទោសៈ មោហៈ ស្រាលស្តើងនឹងមកកាន់លោកនេះម្តងទៀតប៉ុណ្ណោះ ហើយក៏ធ្វើទីបំផុតនៃទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីល ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ជាអ្នកធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា រមែងជាអ្នកកន្លងសិក្ខាបទតូចៗខ្លះ រមែងចេញចាកអាបត្តិខ្លះ សេចក្តីនោះព្រោះហេតុអ្វី ? ព្រោះមិនមាននរណាពោលថា ជាបុគ្គលអភ័ព្វក្នុងការកន្លងសិក្ខាបទនេះ តែសិក្ខាបទទាំងឡាយណាជាខាងដើមនៃព្រហ្មចរិយៈ សមគួរដល់ព្រហ្មចារ្យ ជាអ្នកមានសីល ជានិច្ច មានសីលតាំងមាំក្នុងសិក្ខាបទទាំងឡាយនោះ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ជាអ្នកទៅកាន់ខាងលើនឹងបរិនិព្វានក្នុងភពនោះមិនត្រឡប់ចាកភពនោះជាធម្មតា ព្រោះឱរម្ភាគិយសំយោជនៈ ៥ អស់ទៅ ។ល។ សមាទានសិក្សាក្នុងសិក្ខាទាំងឡាយ ។ភិក្ខុនោះព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ល។ ចូលដល់ហើយដូច្នេះ ។

លោកអាចារ្យដើម្បីនឹងសួរថា យ៉ាងណា ទើបចែកសិក្ខាជាដើម សរុបសេចក្តីដែលពោលហើយនោះឯង ទើបពោលថា ឯវំ ដូច្នេះជាដើម ។ ក្នុងបទទាំងឡាយនោះ ពាក្យថា ម្យ៉ាងទៀត គុណដែលជាពួក ៣ ដទៃៗ បានដល់ គុណដែលជាពួក ៣ ជាដើមយ៉ាងនេះ គឺ

វិវេក ៣ កុសលមូល ៣ វិមោក្ខ ៣ ឥន្ទ្រីយ៍ ៣ និងគុណដែលជាពួក៣ ដទៃទៀត អាចជាគុណពួក ៣ នៃសិក្ខាបទដើម។

ពាក្យថា សភាពបែបនេះ បានដល់ ដូចគ្នានឹងសិក្ខាបទ ៣ ជាដើម ដែលទ្រង់ប្រកាសទុកដោយសីលជាដើមក្នុងអធិការនេះ ។

ក្នុងទីនេះ ទ្រង់ប្រកាសកាយវិវេកដោយសីល ព្រោះក្នុងទីនេះ លោកសំដៅយកសីលដែលអាស្រ័យវិវដ្ដៈ, ប្រកាសចិត្តវិវេកដោយសមាធិ, ប្រកាសឧបធិ វិវេកដោយបញ្ញា ។ ម្យ៉ាងវិញទៀត **អទោសៈ** ដែលជាកុសលមូលទ្រង់ប្រកាសដោយសីល ព្រោះសីលមានសេចក្ដីអត់ធន់ជាប្រធាន និងមានសភាវៈមិនបៀតបៀនអ្នកដទៃ ។ **អលោភៈ** ដែលជាកុសលមូល ទ្រង់ប្រកាសដោយសមាធិ ព្រោះសមាធិជាបដិបក្ខដល់លោភៈ និងព្រោះមានអលោភៈជាប្រធាន ។ តែ **អមោហៈ** តែម្យ៉ាងទ្រង់ប្រកាសដោយបញ្ញា ។ ម្យ៉ាងវិញទៀត ទ្រង់ប្រកាស អនិមិត្តវិមោក្ខមុខដោយសីល ។ ពិតហើយ អ្នកដែលអាស្រ័យសីលសម្បត្តិមានអទោសៈជាប្រធានមានប្រក្រតីឃើញទោសក្នុងទោសៈ, **អនិច្ចានុបស្សនា** រមែងសម្រេចបានដោយងាយពិត, ហើយអនិច្ចានុបស្សនា ឈ្មោះថា **អនិមិត្តវិមោក្ខមុខ** ។ ទ្រង់ប្រកាសអប្បណិហិតវិមោក្ខមុខដោយសមាធិ, ទ្រង់ប្រកាសសុញ្ញតវិមោក្ខមុខ ដោយបញ្ញា, អ្នកដែលអាស្រ័យសមាធិសម្បត្តិ ជាគ្រឿងចេញចាកកាមដែលមាន

អលោភៈជាប្រធាន មានប្រក្រតីឃើញទោសក្នុងកាមទាំងឡាយ, ទុក្ខានុបស្សនា រមែងសម្រេចបានយ៉ាងងាយ, ទុក្ខានុបស្សនាជា **អប្បណិហិតវិមោក្ខ** ។

អនត្តានុបស្សនា អាស្រ័យបញ្ញាសម្បត្តិ រមែងសម្រេចបានដោយងាយពិត, ហើយអនត្តានុបស្សនា ក៏ជា **សុញ្ញតវិមោក្ខមុខ** ។

ម្យ៉ាងទៀត ទ្រង់តែងប្រកាសអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ៍ដោយសីល ព្រោះអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ៍នោះ ជាឥន្ទ្រិយ៍របស់ព្រះអរិយបុគ្គលទី ៨ ដែលធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ។ ទ្រង់ប្រកាសអញ្ញិន្ទ្រិយ៍ដោយសមាធិ ព្រោះអញ្ញិន្ទ្រិយ៍នោះ ជាឥន្ទ្រិយ៍របស់ព្រះអនាគាមី ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសមាធិយ៉ាងឧក្រិដ្ឋ និងជាឥន្ទ្រិយ៍របស់អ្នកដែលតាំងនៅក្នុងមគ្គដ៏លើស ។ ទ្រង់ប្រកាសអញ្ញាតាវិន្ទ្រិយ៍ដោយបញ្ញា ព្រោះព្រះអរហន្តទាំងឡាយ នឹងធ្វើឲ្យបរិបូណ៌ក្នុងបញ្ញាបាន ដោយសារតែអញ្ញាតាវិន្ទ្រិយ៍នោះកើតឡើង ។

ម្យ៉ាងទៀត គប្បីប្រកាសគុណដែលជាពួក ៣ ( ពួក ៣ នៃគុណ ) បែបនេះ យ៉ាងដទៃ ដោយសីលជាដើម ដោយន័យនេះឯង ។

( មហាដីកា ពាក្យនិទាន ចប់ )

# សីលនិទ្ទេស

វិសុទ្ធិមគ្គនេះ ទ្រង់សម្តែងដោយមុខ គឺសីល សមាធិ និងបញ្ញា ដែលប្រមូលទុកនូវគុណជាអនេកយ៉ាងនេះហើយ ក៏នៅរាប់ថា ទ្រង់សម្តែងដោយសង្ខេបដដែល ព្រោះដូច្នោះ ទើបមិនល្មមនឹងជួយដល់ជនគ្រប់ជំពូកបានហេតុនោះដើម្បីនឹងសម្តែងភាពពិស្តារនៃវិសុទ្ធិមគ្គនោះ ទើបមានបញ្ហាកម្ម (ការតាំងបញ្ហា) នេះ ប្រារព្ធសីលជាមុន គឺ

-អ្វីជាសីល ?

-ដែលហៅថា សីល ព្រោះអត្ថជាដូចម្តេច ?

-អ្វីជាលក្ខណៈ កិច្ច បច្ចុប្បដ្ឋាន បទដ្ឋាន របស់សីលនោះ ?

-សីលមានអានិសង្សយ៉ាងណា ?

-សីលនោះមានប៉ុន្មានយ៉ាង ?

-អ្វីជាសេចក្តីសៅហ្មងរបស់សីល និងជាសេចក្តីផូរផង់របស់សីលនោះ ? ( តទៅ ) នេះជាពាក្យឆ្លើយក្នុងបញ្ហាកម្មនោះ... ។

# អ្វីជាសីល

បញ្ហាថា **អ្វីជាសីល** ឆ្លើយថា ធម៌ទាំងឡាយណាមានចេតនាជាដើមរបស់បុគ្គលដែលវៀរចាកទោស មានបាណាតិបាតជាដើមក្តី របស់បុគ្គលដែលបំពេញវត្តបដិបត្តិក្តី ជាសីល សេចក្តីនេះ សមដូច

ពាក្យដែលព្រះធម្មសេនាបតីពោលទុកក្នុងបដិសម្ភិទាថា សួរថា អ្វីជាសីល ឆ្លើយថា ចេតនាជាសីល ចេតសិកក៏ជាសីល សំវរៈក៏ជាសីល ការមិនឈានកន្លងក៏ជាសីល ដូច្នេះ ក្នុងសីលទាំងឡាយនោះ ចេតនារបស់បុគ្គលដែលវៀរចាកទោស មានបាណាតិបាតជាដើមក្តីរបស់បុគ្គលអ្នកបំពេញវត្តបដិបត្តិក្តី ឈ្មោះថា **ចេតនាសីល**, ការវៀរចាករបស់បុគ្គលដែលវៀរចាកទោស មានបាណាតិបាតជាដើម ឈ្មោះថា **ចេតសិកសីល** ន័យម្យ៉ាងទៀត ចេតនាក្នុងកម្មបថ ៧ របស់បុគ្គលដែលលះបង់ទោស មានបាណាតិបាតជាដើម ឈ្មោះថា **ចេតនាសីល**, ធម៌ គឺអនភិជ្ឈា អព្យាបាទ និងសម្មាទិដ្ឋិ ដែលទ្រង់ត្រាស់ទុកដោយន័យថា ភិក្ខុលះអភិជ្ឈា មានចិត្តប្រាសចាកអភិជ្ឈាហើយ ដូច្នេះជាដើម ឈ្មោះថា **ចេតសិកសីល** ។

## សំវរៈ៥

ក្នុងសេចក្តីថា សំវរៈក៏ជាសីល គប្បីជ្រាបថា សំវរៈដោយអាការ ៥ គឺបាតិមោក្ខសំវរៈ សតិសំវរៈ ញាណសំវរៈ ខន្តិសំវរៈ វីរិយសំវរៈ ។

ក្នុងសំវរៈ ៥ នោះ សំវរៈដែលទ្រង់ត្រាស់ទុកថា ភិក្ខុជាអ្នកចូលដល់ហើយ ជាអ្នកប្រកបព្រមហើយដោយបាតិមោក្ខសំវរៈ នេះ

ឈ្មោះថា **បាតិមោក្ខសំវរៈ** ។ សំវរៈដែលត្រាស់ទុកថា ភិក្ខុរមែងរក្សាឥន្ទ្រិយ៍ គឺចក្ខុ រមែងដល់នូវការសង្រួមក្នុងឥន្ទ្រិយ៍ គឺចក្ខុ ( ជាដើម ) នេះឈ្មោះថា **សតិសំវរៈ** ។ សំវរៈដែលពោលទុកថា ព្រះសាស្តាត្រាស់តបថា ម្នាលអជិតៈ ក្រសែ ( នៃតណ្ហា ) ទាំងឡាយណាមាននៅក្នុងលោក សតិជាគ្រឿងរាំងក្រសែនៃតណ្ហាទាំងឡាយនោះ តថាគតពោលថា សតិជាគ្រឿងរាំងក្រសែតណ្ហាទាំងឡាយ តែក្រសែ តណ្ហាទាំងឡាយនោះ អ្នកបដិបត្តិលះបានដោយបញ្ញា នេះឈ្មោះថា **ញាណសំវរៈ** ។

សូម្បីការសេពបច្ច័យ ក៏រួមចុះក្នុងញាណសំវរៈនេះផងដែរ ដូចគ្នា ។ ចំណែកសំវរៈដែលមានមកដោយន័យថា ភិក្ខុជាអ្នកអត់ធន់ចំពោះរងា ចំពោះក្តៅ ដូច្នេះជាដើម នេះឈ្មោះថា **ខន្តិសំវរៈ** ។ សំវរៈដែលមានមកដោយន័យថា ភិក្ខុរមែងមិនរក្សាទុកនូវកាមវិតក្កដែលកើតឡើងហើយ ដូច្នេះជាដើម នេះឈ្មោះថា **វិរិយសំវរ** សូម្បីអាជីវ-បារិសុទ្ធិសីល ក៏រួមចុះក្នុងវិរិយសំវរនេះដែរ ។

សំវរៈទាំង ៥ ប្រការ នេះដែលពោលមកដូច្នេះក្តី ការវៀរចាកវត្ថុដែលជួបប្រទះនៃកុលបុត្តទាំងឡាយដែលជាអ្នកខ្លាចបាបក្តី ទាំងអស់នេះ គប្បីជ្រាបថា ឈ្មោះថា **សំវរសីល** ។

សេចក្តីថា ការមិនឈានកន្លងសីលនោះបានដល់ ការមិនកន្លង

សីលនោះ បានដល់ ការមិនកន្លងល្មើសផ្លូវកាយ និងវាចានៃអ្នកសមាទានសីលហើយ ។ នេះជាពាក្យឆ្លើយបញ្ហាក្នុងសេចក្តីថា អ្វីជាសីលជាលើកដំបូងសិន ។

## អត្ថរបស់សីល

នឹងឆ្លើយក្នុងបញ្ហាដែលសល់ ( តទៅ ) បញ្ហាថា ដែលហៅថាសីល ព្រោះអត្ថដូចម្តេច ? ឆ្លើយថា ដែលហៅថាសីល ព្រោះអត្ថថា **សីលន** ( គឺជាឬសគល់ ) ឈ្មោះថា **សីលន** នេះ តើដូចម្តេច ? ឈ្មោះថា **សីលន** នេះគឺកិរិយា ដែលសង្រួមយ៉ាងល្អ សំដៅដល់កម្មក្នុងទ្វារ មានកាយកម្មជាដើមមិនរប៉ាត់រប៉ាយ ដោយការមានរបៀបល្អ ១ គឺការចូលទៅទទួលទុក សំដៅដល់ការដែលទ្រទ្រង់ ដោយភាពជាទីតាំងនៃកុសលធម៌ទាំងឡាយ ១ អាចារ្យដែលដឹងលក្ខណៈនៃស័ព្ទទាំងឡាយយល់ត្រូវដោយអត្ថ ២ យ៉ាងប៉ុណ្ណោះ ក្នុង **សីល**-ស័ព្ទនេះ អាចារ្យដទៃៗ ពណ៌នាអត្ថក្នុង **សីល**-ស័ព្ទនេះ ទុកដោយន័យ ( ផ្សេងៗ ) ថា **សីល**-ស័ព្ទនេះ មានអត្ថថា **សិរ** មានអត្ថថា **សីស** មានអត្ថថា **សីតល** ( ត្រជាក់ ) មានអត្ថថា **សិវ** ( ក្សេម ) ដូច្នេះជាដើម ។

## លក្ខណាទិចតុក្កៈរបស់សីល

## លក្ខណៈ រស បច្ចុប្បដ្ឋាន បទដ្ឋាន របស់សីល

ឥឡូវនេះនឹងឆ្លើយក្នុងបញ្ហាថា អ្វីជាលក្ខណៈ រស បច្ចុប្បដ្ឋាន និងជាបទដ្ឋានរបស់សីល **សីលន** ( ភាពជាឫសគល់ ) ជាលក្ខណៈរបស់សីលនោះ សូម្បី ( មានប្រភេទ ) ផ្សេងគ្នា ដោយច្រើន ប្រៀបដូចជាវត្ថុដែលមានវិស័យគួរនឹងឃើញបាន (ដោយចក្ខុ) ជាលក្ខណៈរបស់រូប ដែល ( មានប្រភេទ ) ផ្សេងគ្នា ដោយច្រើន ដូច្នោះ ។

ពិតហើយ ភាពជាវត្ថុមានវិស័យដែលគប្បីឃើញបាន ( ដោយចក្ខុ ) ឈ្មោះថា ជាលក្ខណៈរបស់រូបាយតនៈ ( សូម្បីមានប្រភេទ ) ដោយច្រើនប្រការនៃពណ៌ មានពណ៌ខៀវ និងពណ៌លឿងជាដើម ព្រោះរូបាយតនៈ សូម្បីផ្សេងគ្នាដោយពណ៌ មានពណ៌ខៀវជាដើម ក៏មិនកន្លងផុតនូវភាពជាពណ៌ មានវិស័យដែលគប្បីឃើញ ( ដោយចក្ខុ ) ទៅបានយ៉ាងណា **សីលន** ដែលពោលទុកដោយការសង្រួមយ៉ាងល្អនូវកាយកម្មជាដើម និងជាទីតាំងទីអាស្រ័យនៃកុសលធម៌ផងដែរ ឈ្មោះថា លក្ខណៈនៃសីល សូម្បី ( មានប្រភេទ ) ដោយច្រើន ដែលផ្សេងដោយធម៌ មានចេតនាជាដើម ព្រោះសីល សូម្បី ( មានប្រភេទ ) ផ្សេងគ្នា ដោយច្រើន ដោយការផ្សេងគ្នានៃចេតនា

ជាដើម ក៏មិនកន្ទង់ផុតពីការដែលសង្រួមយ៉ាងល្អ និងជាទីតាំងទីអាស្រ័យទៅបាន ដូច្នេះ ។

## រស (កិច្ច)

កិរិយាដែលកម្ចាត់ភាពទ្រុស្តសីល ន័យម្យ៉ាងទៀត គុណ គឺការមិនមាន ទោស លោកពោលថា រស ព្រោះអត្ថថាជា កិច្ច និងជាសម្បត្តិរបស់សីលនោះ ដែលមានលក្ខណៈដូចពោលមកនេះឯង ។

ព្រោះដូច្នោះ ឈ្មោះថា សីលនេះ គប្បីជ្រាបថា មានការកម្ចាត់នូវភាពទ្រុស្តសីលជាកិច្ច, ដោយរស មានកិច្ចជាអត្ថ ( ម្យ៉ាង ) មានការមិនមានទោស ដោយរស ដែលមានសម្បត្តិជាអត្ថ ( ម្យ៉ាង ) សេចក្តីពិត កិច្ចនោះឯង, ឬ ( មិនដូច្នោះ ) សម្បត្តិ លោកហៅថា រស ( អត្ថន័យថា **រស** ក្នុងទីនេះមិនមែនជារសាយតនៈ ដែលជាគូគ្នាជាមួយជិវ្ហាយតនៈ ពាក្យថា **កិច្ច** មានន័យសង្ខេបថា **នាទី** សីលមាននាទីកម្ចាត់ភាពទ្រុស្តសីល ចំណែកពាក្យថា សម្បត្តិក្នុងទីនេះគួរសម្គាល់ថា **ល្អព្រម** គឺមិនធ្វេសប្រហែសឲ្យគេតិះដៀល អធិប្បាយថា បុគ្គលរក្សាសីលហើយតែងប្រាសចាកទោសផ្លូវកាយវាចា សូម្បីបណ្ឌិតពិចារណាហើយក៏រកកន្លែងតិះដៀលមិនបាន, ន័យម្យ៉ាងទៀតអធិប្បាយថា សីលនោះបុគ្គលាចារ្យមិនឲ្យមានទោសផ្លូវកាយ វាចា គឺមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស តែទោសផ្លូវចិត្តនៅមាន

គឺអាចរក្សាសីលដោយអំណាចតណ្ហា មានះ ទិដ្ឋិ ធ្វើឲ្យកើតសេចក្តីរាយមាយ អ្នកដ៏ទៃមិនសរសើរ ( មិនជា **ភុជិស្ស វិញ្ញុបសត្ថ អបរាមដ្ឋ សមាធិសំវត្តនិក** ) កាលរក្សាប្រកបដោយអង្គ ៨ នេះហើយ ទើបជា **អរិយកន្តសីល** ហៅថា **អនវជ្ជសីល** ក៏បាន ព្រោះមិនមានការតិះដៀល ) ក្នុងបទ ( បញ្ហាទាំង ៤ ) មានលក្ខណៈជាដើម ។

## បច្ចុប្បដ្ឋាន និងបទដ្ឋាន

សីលនេះអ្នកប្រាជ្ញពណ៌នាទុកថា មានភាពស្អាតជាបច្ចុប្បដ្ឋាន ហិរិ និងឱត្តប្បៈនោះឯង ជាបទដ្ឋាននៃសីលនោះ ។

ពិតហើយ សីលមានភាពស្អាតដែលត្រាស់ទុកថា ( ភាពស្អាត ៣ យ៉ាង គឺ ) ភាពស្អាតផ្លូវកាយ ភាពស្អាតផ្លូវវាចា ភាពស្អាតផ្លូវចិត្ត ដូច្នេះ ជាបច្ចុប្បដ្ឋាន សីលនោះតែងប្រាកដ គឺដល់នូវគុណដែលគួរកាន់យកដោយភាពជាធម្មជាតិស្អាត ចំណែកហិរិ និងឱត្តប្បៈ អ្នកប្រាជ្ញទាំងឡាយពណ៌នាថា ជាបទដ្ឋាន អធិប្បាយថា ជាអាសន្នហេតុ ( ហេតុជិត ) នៃសីលនោះ ព្រោះពេលហិរិ និងឱត្តប្បៈមានហើយ សីលទើបកើតឡើង និងតាំងនៅបាន កាលហិរិ និងឱត្តប្បៈមិនមាន សីលក៏កើតមិនបាន តាំងនៅមិនបាន ។

លក្ខណៈ រស បច្ចុប្បដ្ឋាន និងបទដ្ឋាននៃសីល សាធុជនគប្បីជ្រាបដោយ ប្រការដូចពណ៌នាមកដូច្នេះចុះ ។

# មហាដីកា

## កថាពណ៌នាសរុបរបស់សីល

បទថា ឯវំ ប្រែថា ដោយប្រការដូចពោលហើយ ។ ពាក្យថា ដែលរួបរួម គុណជាអនេកទុក មានន័យថា រួបរួមគុណជាច្រើននៃអធិសីលសិក្ខាជាដើម និងធម៌ទាំងឡាយដទៃ ។ ពាក្យថា ដោយមុខ គឺសីល សមាធិ បញ្ញា សេចក្តីថា សូម្បីទ្រង់សម្តែងដោយមុខ គឺសីល សមាធិ និងបញ្ញា ជាប្រធាន មិនសម្តែងដោយសង្ខេប ដោយមុខមានត្រឹមវិបស្សនាជាដើម ដូចក្នុងពាក្យជាដើមថា **សព្វេ សង្ខារា អនិច្ចា** សង្ខារទាំងពួងមិនទៀង សូម្បីទ្រង់សម្តែងធ្វើមុខ គឺសីល សមាធិ និងបញ្ញា ឲ្យជាប្រធានក្នុងបណ្តាពោធិបក្ខិយធម៌ទាំងឡាយនោះ ក៏ព្រោះពោធិបក្ខិយធម៌ទាំង ៣៧ ប្រជុំចុះក្នុងវិសុទ្ធិមគ្គនេះដែរ ។

ដោយពាក្យនេះ គប្បីជ្រាបថា ទ្រង់សម្តែងនូវពោធិបក្ខិយធម៌ដែលប្រជុំចុះ ដោយជាសភាវៈ និងជាឧបការៈក្នុងសីល សមាធិ បញ្ញា ។

ទ្រង់ត្រាស់ដោយសង្ខេបក្រៃលែងតែម្យ៉ាង ទើបមិនអាចជាក់ច្បាស់ដោយសភាវៈ និងដោយវិភាគជាដើម ។ ពាក្យថា មិនអាច មានន័យថា មិនទាន់ល្មម គឺមិនទាន់អាច ។ ពាក្យថា ដល់ជនទាំងពួង មាន

ន័យថា សូមឱ្យអ្នកពេញចិត្ត ដោយពិស្តារ និងដោយសង្ខេប ឬសូមឱ្យ ដល់វិបច្ចិតញ្ញូបុគ្គលនិងនេយ្យបុគ្គលទាំងឡាយ ។ការទេសនាដោយ សង្ខេបល្មម ក៏ដើម្បីជាឧបការៈដល់អ្នកដែលពេញចិត្តរឿងដែល សម្តែងដោយសង្ខេប និងដល់ឧគ្ឃដិតញ្ញូបុគ្គលទាំងឡាយ តែមិនជា ឧបការៈដល់បុគ្គលក្រៅពីនេះ ។

**អស្ស យោគ វិសុទ្ធិមគ្គស្ស** នៃវិសុទ្ធិមគ្គនោះ ។ ឈ្មោះថា បញ្ហា ព្រោះអត្ថថា សួរ, កិរិយា គឺការធ្វើ ឈ្មោះថា កម្ម, កម្ម គឺបញ្ហា ឈ្មោះថា បញ្ហាកម្ម បានដល់ ប្រយោគនៃការសួរ ។

ពាក្យថា អ្វីជាសីល ជាពាក្យសួរដោយឈ្មោះថា **សីល** ព្រោះ អត្ថថាដូចម្តេច មានន័យថា លោកពោលថា សីលព្រោះអត្ថថា ដូចម្តេច, អធិប្បាយថា បទថា សីល អាស្រ័យការតាំងឈ្មោះយ៉ាង ណាទៅ, ដើម្បីនឹងជៀសវាង ពាក្យសួរថា សីលនេះនោះ គប្បីជ្រាប បានយ៉ាងណា ដោយសភាវៈ ដោយកិច្ច ដោយអាការប្រាកដ និង ដោយហេតុជិត ទើបលោកអាចារ្យពោលថា អ្វីជាលក្ខណៈ រស បច្ចុប្បដ្ឋាន និងបទដ្ឋានរបស់សីល ។ ធម្មតាការបដិបត្តិ រមែងមាន ក្នុងពេល មានអានិសង្សបានឃើញហើយនោះឯង ដូច្នេះទើបលោក ពោលថា មានអានិសង្សយ៉ាងណា ។ ពាក្យថា សីលនោះមានប៉ុន្មាន យ៉ាង ជាពាក្យសួរចំពោះប្រភេទ ។

ពិតហើយ ការនាំធម៌ដែលមានវិភាគឲ្យជាក់ច្បាស់ដោយសភាវៈ រមែងមានបានដោយមុខ គឺការសម្ដែងវិភាគនោះឯង ។ សេចក្ដីផ្ទួនផង់ គឺសេចក្ដីបរិសុទ្ធិ, សេចក្ដីបរិសុទ្ធិនោះ គឺជាការផុតចាកមន្ទិល គឺសង្កិលេស ។ អ្នកដែលត្រូវការផុតចាកមន្ទិល គឺសង្កិលេសនោះ ក៏គួរនឹងត្រូវដឹងសង្កិលេស ដូចមនុស្សដែលត្រូវការភាពឆ្លាតក្នុងឧបាយ ត្រូវដឹងនូវភាពជាអ្នកឆ្លាតក្នុងវត្ថុមិនមែនជាឧបាយដូច្នោះ ទើបពោលថា សេចក្ដីសៅហ្មងរបស់សីលនោះ យ៉ាងណា ។ បទថា **តត្រ** មានន័យស្មើគ្នានឹង **តស្មឹ យោគ បញ្ហាកម្មេ** ប្រែថា ក្នុងបញ្ហាកម្មនោះ, ឬមានន័យស្មើនឹង **តស្ស យោគ បញ្ហាកម្មស្ស** ប្រែថា នូវបញ្ហាកម្មនោះ ។

ពាក្យថា **វិសជ្ជនំ** ប្រែថា ពាក្យអធិប្បាយ ។ ក៏ខ្លឹមសារដែលគេសួរហើយនៅកំបាំងដូចក្ដាប់ទុកក្នុងដៃ ព្រោះមិនទាន់ប្រាកដច្បាស់ ។

ពាក្យខែសេចក្ដីដែលសួរនោះ ឈ្មោះថា ជាពាក្យវិសជ្ជនា ព្រោះនឹងធ្វើឲ្យ ជាក់ច្បាស់ឡើង ។

ក្នុងពាក្យថា ចាកបាណាតិបាតជាដើមនេះ, សត្វ ឈ្មោះថា **បាណ** ដោយបញ្ញត្តិ, ដោយបរមត្ថ បានដល់ ជីវិតិន្ទ្រីយ៍ ។ ការញុំាងជីវិតិន្ទ្រីយ៍នោះ ដែលមានសភាវៈឲ្យធ្លាក់ចុះទៅ ដោយសភាពឲ្យធ្លាក់ចុះភ្លាមក្នុងរវាង ឈ្មោះថា **អតិបាត** (ការញុំាងជីវិតិន្ទ្រីយ៍ឲ្យធ្លាក់ចុះ),

មានន័យថា ឲ្យធ្លាក់ទៅភ្លាម មិនឲ្យរស់នៅបានយូរ, ន័យម្យ៉ាងទៀត ការឈានកន្លង គឺប្រើសស្ត្រាជាដើមប្រហារឲ្យធ្លាក់ចុះ ក៏ឈ្មោះថា អតិបាត គឺការសម្លាប់សត្វ ។

ដោយអាទិ-ស័ព្ទលោកអាចារ្យរួមដល់ទាំងអទិន្នាទានផងដែរ ។

វៀរចាកកម្ម គឺការទ្រុស្តសីលមានបាណាតិបាតជាដើមទាំងឡាយនោះ ។

ពាក្យថា របស់បុគ្គលអ្នកវៀរ បានដល់ របស់បុគ្គលដែលវៀរបានដល់របស់បុគ្គលដែលវៀរដោយអំណាចសមាទានវិរតិ និងសម្បត្តវិរតិ ។

ពាក្យថា **វត្តបដិបត្តិ** គឺការធ្វើវត្ត មានឧបជ្ឈាយវត្តជាដើម ។

លោកអាចារ្យពោលពាក្យថា សេចក្ដីនេះ សមដូចព្រះធម្ម-សេនាបតីសារីបុត្តពោលទុក ដូច្នេះជាដើម ដើម្បីនឹងសម្ដែងចែកខ្លឹមសារដែលលោកពោលទុកដោយសង្ខេបថា ធម៌ទាំងឡាយ មានចេតនាជាដើម ដោយអំណាចព្រះបាលី ។

ក្នុងបទទាំងឡាយនោះ ឈ្មោះថា ចេតនា ព្រោះអត្ថថា តាំងចិត្ត អធិប្បាយថា តាំងទុកចំពោះក្នុងអារម្មណ៍រួមនឹងធម៌ដែលសម្បយុត្តជាមួយខ្លួន ។

ពិតហើយធម៌ដែលសម្បយុត្តជាមួយចេតនានោះរមែងប្រព្រឹត្ត

ទៅក្នុងអារម្មណ៍បាន ក៏ដោយអំណាចអនុកូលរបស់ចេតនានោះឯង ។ ចេតនាជាសាធារណៈដល់ធម៌ដែលជាកុសលត្តិកៈដោយពិត សូម្បីយ៉ាងនោះ ក្នុងទីនេះគប្បីជ្រាបថា ជាកុសល ព្រោះធ្វើពាក្យអធិប្បាយថា លោកបំណងយកសីលចេតនា ។

ធម្មជាតិដែលប្រកបក្នុងចិត្ត អធិប្បាយថា ធម្មជាតិដែលប្រកបជាមួយចិត្ត ឈ្មោះថា ចេតសិក ។ សូម្បីក្នុងពេលចេតនាជាចេតសិកធម៌ ក៏គប្បីឃើញថា **ចេតសិកសីល** បានដល់ វិរតិ និងអនភិជ្ឈាជាដើមដទៃពីចេតនានោះឯង ទាំងនេះគឺជាគោពលិពទ្ទន័យ (សំដៅដល់ គោ-ស័ព្ទ និង ពលិពទ្ទ-ស័ព្ទ មកជាមួយ គោ-ស័ព្ទ រមែងសំដៅដល់គោដទៃ គឺ **ជរគ្គវ** គោចាស់, **ទម្ម** គោហ្វឹក, **វច្ឆ** កូនគោ, រៀរ **ពលិពទ្ទ** គោទាក់ទងដោយកម្លាំង គឺគោកំលោះចេញ ដូចជា **ទេវា**ន **សក្កោ គន្ធព្វោ** មកជាមួយគ្នា **ទេវា** បានដល់ ទេវតាដទៃ រៀរសក្កទេវរាជ និង **គន្ធព្វ** ដែលជាទេវតាផងគ្នា ជាសេចក្ដីប្រៀបធៀប ចេតនា-ស័ព្ទ ជាមួយនឹងចេតសិក-ស័ព្ទ, ចេតសិក រមែងសំដៅដល់ចេតសិកដទៃៗ ក្រៅពីចេតនានោះ មានវិរតិចេតសិក និងអនភិជ្ឈាចេតសិកជាដើម យ៉ាងនេះហៅថា គោពលិពទ្ទន័យ ) ព្រោះចេតនានោះលោកកាន់យកក្នុងផ្នែកមួយថា ចេតនាជាសីល ។ តាមវាំងឈ្មោះថា សំវរៈ បានដល់ ការបិទមិនឲ្យអកុសលកើតឡើងបាន ។

ចិត្តនិងចេតសិកប្រព្រឹត្តទៅដោយអំណាចការមិនឈានកន្លង ជាបដិបក្ខ ដល់ការឈានកន្លង ឈ្មោះថា **អវីតិក្កម:** ( ការមិនឈានកន្លងល្មើស ) ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា ឈ្មោះថាសីលជាដើម ជាពាក្យខៃបទនៃព្រះសូត្រតាមដែលនាំមកហើយ ។ លោកពោលដល់ចេតនាដែលជាប្រធានសម្បយុត្ត ដោយវិរតិ ដោយពាក្យថាចេតនារបស់បុគ្គលដែលវៀរ ។ដោយពាក្យថាចេតនារបស់បុគ្គលអ្នកបំពេញ គឺការប្រមូលវត្តបដិបត្តិមក ។ពាក្យថា ការវៀរចាករបស់បុគ្គលអ្នកវៀរ លោកពោលសំដៅយកដោយវិរតិជាប្រធាន ។

ក្នុងអធិការនេះ លោកពោលចំពោះចេតនាសីល ក្នុងន័យនេះថា ពេលណា ចេតនាវិសេសជាងការវៀរចាកបាណាតិបាតជាដើមនោះ ដែលជាបដិបក្ខដល់បាណាតិបាតជាដើម ដោយព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ កាយសញ្ចេតនា ៣ យ៉ាង កាយកម្មផ្នែកកុសលដូច្នេះជាដើម ដែលប្រព្រឹត្តទៅហើយដូច្នេះ រមែងឲ្យសម្រេចជាការវៀរចាកចំពោះបាណាតិបាតជាដើមដោយភាពជាប្រធាន, ពេលនោះវិរតិ និងអនភិជ្ឈាជាដើម ដែលសម្បយុត្តដោយចេតនានោះចាត់ចូលខាងផ្នែកចេតនា ឬជាអញ្ញោហារិក: ។

លោកពោលចេតសិកសីល ក្នុងន័យនេះថា តែពេលណា វិរតិ និងអនភិជ្ឈាជាដើម វិសេសជាងចេតនាដែលប្រព្រឹត្តទៅដោយអាការ

វៀរចាកបាណាតិបាតជាដើមនោះ របស់អ្នកដែលដល់នូវសេចក្តីវៀសចាកបាណាតិបាតជាដើមនោះ រមែងឲ្យសម្រេចកិច្ចដោយភាពជាប្រធានក្នុងសេចក្តីនោះៗ ពេលនោះចេតនា ដែលសម្បយុត្តដោយវិរតិ និងអនភិជ្ឈាជាដើម ចាត់ចូលក្នុងផ្នែករបស់វិរតិជាដើម ឬជាអព្យោហារិកៈ ។

ឥឡូវនេះពេលនឹងសម្តែងចែកចេតនាសីល និងចេតសិកសីល ដោយទាក់ទងជាមួយកុសលកម្មបទ ១០ តាមន័យដែលមានមកក្នុងព្រះសូត្រ ទើបពោលពាក្យមានជាអាទិ៍ថា **អបិច** ( ន័យម្យ៉ាងទៀត ) តទៅ ។ ពាក្យថា របស់បុគ្គលអ្នកលះ មានន័យថា របស់បុគ្គលអ្នកលះ ដោយមិនប្រព្រឹត្តកន្លង សម្បវត្ថុដែលបានជួប ដោយតាំងចិត្តថាចាប់តាំងពីពេលនេះទៅយើងនឹងមិនធ្វើ ដូច្នេះ ដោយអំណាចការសមាទាន ។ ពាក្យថា ចេតនាក្នុងកម្មបទ ៧ បានដល់ ចេតនា ក្នុងកុសលកម្មបទ ៧ តាមលំដាប់ ឲ្យសម្រេចការលះបាណាតិបាតជាដើម ។ សត្វធ្វើកម្មណា មានការសោហាយស្មន់ជាមួយភរិយារបស់អ្នកដទៃជាដើមដោយអំណាចអភិជ្ឈាជាដើម, អនភិជ្ឈាជាដើមដែលជាតួលះកម្មនោះ ឈ្មោះថា សីល ដូច្នេះទើបពោលថា ធម៌ គឺអនភិជ្ឈាអព្យាបាទ ។ល។ និងសម្មាទិដ្ឋិ ឈ្មោះថា ចេតសិកសីល ដូច្នេះ ។ ដូចជាបុគ្គលធ្វើមិច្ឆាចារ និងបាណាតិបាតជាដើម ដោយអំណាចអភិជ្ឈា និងព្យាបាទ យ៉ាងណា, មិច្ឆាចារនិងព្យាបាទជាដើមទាំងឡាយ

នោះគេធ្វើក៏ដើម្បីប្រយោជន៍មានការឃើញនូវមុខបុត្រជាដើមដោយអំណាចការយល់ខុសខ្លះ ដូច្នេះឯង ។ ក៏ធម៌មានអនភិជ្ឈាជាដើមជាតួលះបង់នូវធម៌ មានអភិជ្ឈាជាដើមទាំងឡាយនោះដូច្នេះ ។

ដែលឈ្មោះថា បាតិមោក្ខសំវរសីល គឺសិក្ខាបទដែលទាក់ទងនឹងព្រះវិន័យ ចែកចេញជាចារិតសីល និងវារិតសីល ។ សតិសំវរៈ បានដល់ ការរក្សាឥន្ទ្រីយ៍ទាំងឡាយ មានចិត្តជាទី ៦ គឺសតិដែលប្រព្រឹត្តទៅយ៉ាងនោះឯងក៏ការរក្សានោះគឺសតិដែលប្រព្រឹត្តទៅហើយដោយប្រការនោះៗឯង ។ ញាណសំវរៈ បានដល់ បញ្ញា ។ខន្តិសំវរៈ បានដល់ សេចក្តីអត់ធន់ ។ ការអត់ធន់ គឺចំពោះខន្ធទាំងឡាយដែលមានទោសៈជាប្រធានដែលប្រព្រឹត្តទៅដោយប្រការនោះៗឬអទោសៈនោះឯង ។ ដែលឈ្មោះថា វីរិយសំវរៈ បានដល់ ការព្យាយាមដែលទាក់ទងដល់ការបន្ទោបង់កាមវិតក្កៈជាដើម ។ពាក្យដែលគួរពោលនឹងពោលក្នុងបាតិមោក្ខសំវរៈ និងសតិសំវរៈជាដើមនោះ នឹងមានអធិប្បាយខាងមុខ ។

ពាក្យថា ក្រសែទាំងឡាយ បានដល់ក្រសែនៃកិលេសដ៏សេសហួរចាកតណ្ហា ទិដ្ឋិ អវិជ្ជា និងទុច្ចរិតទាំងឡាយ ។ ដោយការត្រាស់ថា តថាគតពោលនូវការឃាំងក្រសែទាំងឡាយ ហើយត្រាស់ថាក្រសែទាំងឡាយនេះ រមែងបិទបានដោយបញ្ញា ដូច្នេះរមែងជឹងបាន

ថា ការឃាំង ការបិទ ការកាត់បានជាសមុច្ឆេទនូវក្រសែទាំងឡាយ ថាជាញាណ ។

លោកធ្វើទុកក្នុងចិត្ត ចំពោះអាការដូចដែលបានពោលមកនេះ ឲ្យជាប្រយោជន៍ ហើយពិចារណាដោយឧបាយត្រូវទំនងដោយញាណ ណា ទើបសេពបច្ច័យទាំងឡាយ ។ សូម្បីការពិចារណាសេពចំពោះ បច្ច័យ គឺញាណនោះរមែងប្រជុំចុះ គឺសង្គ្រោះចូលក្នុងញាណសំវរៈ នេះតែម៉្យាង ព្រោះជាសភាវៈនៃញាណ ។ឈ្មោះថា អ្នកអត់ធន់ ព្រោះ អត្ថថា អត់ធន់ គឺសង្កត់ទុក ។ ពាក្យថា ដែលកើតឡើង គឺដែលកើត ហើយ គឺកើតឡើងក្នុងអារម្មណ៍នោះៗ ។ពាក្យថា កាមវិតក្ក គឺសេចក្តី ត្រិះរិះដែលចូលទៅប្រកបដោយកាម ។ ពាក្យថា មិនទទួល ទុក គឺ មិនលើកចិត្តឡើងឲ្យនៅក្នុងខាងក្នុង ។

ពាក្យថា សូម្បីអាជីវបារិសុទ្ធិ មានន័យថា សូម្បីអាជីវបារិសុទ្ធិ សីលដែលលះមិច្ឆាជីពដែលព្រះពុទ្ធជាម្ចាស់ទ្រង់តិះដៀល ហើយ សម្រេច ( ចិញ្ចឹមជីវិត ) ដោយការស្វែងរកបច្ច័យមិនមានទោស ក៏រួមចុះក្នុងវីរិយសំវរៈនេះឯង ព្រោះមានវីរិយៈឲ្យសម្រេច ។

ក្នុងអធិការនេះ គប្បីជ្រាបថា ញាណ ឈ្មោះថា សំវរៈ ដោយ អត្ថថា បិទទុក ព្រោះហាមការប្រព្រឹត្តិទៅនៃក្រសែ គឺតណ្ហាជាដើម, ឈ្មោះថា សីល ព្រោះអត្ថថា សង្រួមរាំង ព្រោះភាវៈជាទីទ្រទ្រង់ទុក

ជាដើមនូវគុណដែលនឹងប្រព្រឹត្តទៅខាងមុខយ៉ាងណា, ខន្តិ ក៏ដូច្នោះ, ឈ្មោះថា សំវរៈ ព្រោះឃាំងទុកដោយការគ្របសង្កត់នូវកិលេសដែលកើតឡើង ព្រោះមិនទទួលយក, ឈ្មោះថា សីល ព្រោះអត្ថថា សន្ទ្រើម ដោយភាវៈជាទីទ្រទ្រង់ជាដើមនូវគុណដែលកើតឡើង ព្រោះសេចក្តីអត់ធន់ជាហេតុ ។ វីរិយ ឈ្មោះថា សំវរៈ ព្រោះឃាំងទុកដោយការបណ្តេញបាបធម៌ទាំងឡាយ ដែលគប្បីបន្ទោបង់, ឈ្មោះថា សីល ដោយអត្ថថា សន្ទ្រើមជាប្រក្រតី ដោយភាពជាទីទ្រទ្រង់ជាដើមនូវគុណដែលកើតឡើង ចំពោះហេតុនៃការបន្ទោបង់ ។

តែព្រះបាតិមោក្ខសំវរសីលជាដើម ជាគ្រឿងឃាំង ជាគ្រឿងបិទមិនឲ្យបាបកម្មនោះៗ កើតឡើង, ឈ្មោះថា សំវរៈ ព្រោះអាស្រ័យការឃាំង ការបិទនោះយ៉ាងណា, សូម្បីការវៀរចាកវត្ថុដែលជួបរបស់អ្នកមិនបានសមាទានសីល ក៏ដូច្នោះ ។

ហេតុនោះ ទើបលោកពោលថា ការវៀរចាកវត្ថុដែលជួបនៃកុលបុត្តទាំងឡាយអ្នកខ្លាចបាបក្តី ទាំងអស់នេះ គប្បីជ្រាបថា ឈ្មោះថា សំវរសីល, ឈ្មោះថា ការមិនឈានកន្លង ព្រោះអត្ថថា ជាហេតុមិនឈានកន្លង គឺចិត្តុប្បាទ ជាកុសលដែលកើតឡើងដោយប្រការនោះ ។

អវសេសេសុ យោគ បញ្ចេសុ ប្រែថា ក្នុងបញ្ហាដ៏សេសទាំង

ទ្បាយ ។ **សមាធានំ** ប្រែថា ការតាំងទុកដោយល្អ ។ ពិតហើយ កាយកម្មជាដើម ដែលប្រព្រឹត្តហើយដោយអំណាចនៃភាពជាអ្នកទ្រុស្តសីល មានការនាំមកនូវវត្ថុមិនជាប្រយោជន៍ និងសេចក្តីទុក្ខមកឲ្យទាំងក្នុងបច្ចុប្បន្ន និងអនាគត, ឈ្មោះថា **មិនតម្កល់ទុកដោយល្អ** ព្រោះមិនតាំងទុកហើយដោយប្រពៃ ឈ្មោះថា **ជ្រៀតជ្រែករឿងអ្នកដទៃ** និងឈ្មោះថា **ហូរទៅហើយ**, ចំណែកកាយកម្មជាដើម ដែលប្រព្រឹត្តទៅហើយដោយការមានសីលល្អ ឈ្មោះថា **តម្កល់ទុកដោយល្អហើយ មិនជ្រៀតជ្រែករឿងអ្នកដទៃ** ។ ដោយបរិយាយខុសពីភាពដែលជាអ្នកមានសីលល្អ និងមិនហូរទៅហើយ ដូចភាពជាអ្នកដែលមានភ្នែកសម្លឹងចុះហើយ មានការមិនគ្រវីដៃជាដើមដូច្នោះ ព្រោះដូច្នោះ ទើបលោកពោលថា អធិប្បាយថា ជាអ្នកមានកាយកម្មជាដើម មិនជ្រៀតជ្រែកអ្នកដទៃ ដោយអំណាចភាពជាអ្នកមានសីល ។ ដោយពាក្យនេះ ទើបលោកធ្វើសេចក្តីឲ្យដាច់ចេញផ្សេងពីសមាធិ ។

ការតាំងមាំនៃសមាធិនោះ បានដល់ ជាហេតុនៃការមិនរាយមាយរបស់សម្បយុត្តធម៌ទាំងឡាយ ។ ១.នេះជាសេចក្តីតាំងមាំ គឺការសង្រួមកាយកម្មជាដើម ការតាំងមាំ គឺជាមូលហេតុ ឈ្មោះថា ការចូលទៅទ្រទ្រង់ទុក ។

ពិតហើយ សីលនោះលោកពោលថា ជាការប្រព្រឹត្តិខាងដើម ។

ព្រោះហេតុនោះ ការទ្រទ្រង់នោះ លោកធ្វើឲ្យផ្សេងពីកិច្ចនៃបឋវីធាតុ ។ ពិតហើយ បឋវីធាតុនោះ តែងជាទីទ្រទ្រង់នូវរូបធម៌ដែលកើតរួមគ្នា ។ ចំណែកការទ្រទ្រង់នេះ រមែងប្រព្រឹត្តទៅដោយភាវៈជាមូល និងជាទីតាំងនៃធម៌មិនមានទោស ។ ព្រោះដូច្នោះ ទើបលោកពោលថា នៃកុសលធម៌ទាំងឡាយជាដើម ។

ក្នុងពាក្យថា នៃកុសលធម៌ទាំងឡាយជាដើមនោះ ដែលឈ្មោះថា **កុសលធម៌** បានដល់ មហគ្គតធម៌ និងលោកុត្តរធម៌ ព្រមទាំងធម៌ដែលជាបុព្វភាគ ។ **អញ្ញេ បន យោគ អាចរិយា** ប្រែថា អាចារ្យទាំងឡាយពួកដទៃ ។ បទថា **សិរដ្ឋោ** អធិប្បាយថា ពេលក្បាលត្រូវកាត់ហើយ អត្តភាពទាំងពួង រមែងវិនាសទៅ យ៉ាងណា, សីល ក៏ដូច្នោះ ពេលបែកធ្លាយហើយ វិនាសហើយ រាងកាយ គឺគុណទាំងពួងក៏វិនាសទៅ ។ ព្រោះដូច្នោះ សីលនោះ ទើបមានអត្ថថា អវយវៈប្រសើរបំផុត ឈ្មោះថា **សីសដ្ឋោ** ឬពេលនឹងគួរពោលថា **សិរោ សីលំ** លោកពោលថា **សីលំ** ដោយនិរុត្តិន័យ។ អត្ថថា ស្ងប់សេចក្ដីក្ដៅក្រហាយឈ្មោះថា **សីតលដ្ឋោ** ។ ដោយពាក្យនោះលោកសម្ដែងថា លុប ត អក្សរ ហើយពោលថា **សីលំ** ដោយនិរុត្តិន័យដូចគ្នា ។

ពិតហើយ សីលនេះ ដែលឲ្យសម្រេចហើយដោយសេចក្ដីព្យាយាម ក៏នឹងធ្វើឲ្យរំងាប់សេចក្ដីក្ដៅក្រហាយ គឺកិលេសទាំងពួង ។

ដោយ អាទិ-ស័ព្ទថា **ឯវមាទិនា** គប្បីឃើញថា លោកសង្គ្រោះពាក្យមានជាអាទិ៍យ៉ាងនេះថា ពេលសីលនោះមាននៅកុសលធម៌ទាំងឡាយក៏ប្រជុំចុះ គឺមិនទៅប្រាស ដូច្នេះទើបឈ្មោះថា **សីល**, ឬ ឈ្មោះថា **សីល** ព្រោះទុច្ចរិតទាំងមូលត្រូវកុសលធម៌នោះ មានឧស្សាហ៍កម្ចាត់ហើយ បិទហើយ, ឬឈ្មោះថា សីល ព្រោះអត្ថថា ជាសាលា ( ទីសម្រាក ) ដែលកុសលធម៌ទាំងអស់គួរចូលទៅដូច្នោះ ។

អត្ថ គឺភាវៈនោះឯង លោកប្រកាសទុកដោយលើកអត្ថនៃស័ព្ទឡើងក្នុងពេលដើមថា ឈ្មោះថា សីលដោយអត្ថថា សង្រួម ព្រោះដូច្នោះ ទើបលោកពោលថា ការសង្រួមរវាំងជាលក្ខណៈរបស់សីលដូច្នេះ ។ លោកអាចារ្យធ្វើទុកក្នុងចិត្តនូវការឆ្លើយតបសំណួរថា ព្រោះសីលដែលផ្សេងដោយប្រភេទមានចេតនាសីលជាដើមនោះ និងមានការសម្គាល់ដែលគប្បីពោលបានថា លក្ខណៈដទៃក្រៅពីការសម្គាល់ថា ការសង្រួមរវាំងនោះ ដែលរួបរួមបានមិនមានសល់នោះក៏ទេ ។ លក្ខណៈដែលរួបរួមធម៌មានច្រើនប្រភេទ ដែលឈ្មោះថាជាលក្ខណៈដូចគ្នា មិនមែនជាលក្ខណៈផ្សេងគ្នានោះទេមែនឬ? ទើបលោកពោលថា ភាពជាធម្មជាតិដែលចក្ខុវិញ្ញាណគប្បីឃើញបាន ជាលក្ខណៈរបស់រូបាយតនៈដែលមានច្រើនប្រភេទផ្សេងគ្នា ដូច្នេះ ។

ដូចជារូបាយតនៈ មានប្រភេទផ្សេងៗ ជាច្រើន មានពណ៌ខៀវ

ជាដើម មានភាវៈប្រព្រឹត្តទៅដែលចក្ខុវិញ្ញាណ គប្បីឃើញបានជាលក្ខណវិសេស ព្រោះមិនទូទៅដល់ធម៌ដទៃក្រៅពីរូបាយតនៈនោះ ។ មិនដូចសាមញ្ញលក្ខណៈ ដូចជារបស់មិនទៀងជាដើម ឬដូចជាការប្រែប្រួលជាលក្ខណៈពិសេសនោះទេ សេចក្តីនេះ យ៉ាងណា សូម្បីក្នុងសីលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

ភាវៈដែលចក្ខុគប្បីឃើញបាននេះគឺអ្វី ? គឺភាវៈដែលចក្ខុគប្បីឃើញ បានដល់ ភាពជាអារម្មណ៍របស់ចក្ខុវិញ្ញាណ ។ កាលបើជាអារម្មណ៍របស់ចក្ខុវិញ្ញាណនោះ មិនមានអ្វីក្រៅពីរូបាយតនៈ លោកអាចារ្យមានបំណងនឹងធ្វើរូបាយតនៈឲ្យផ្សេងពីធម៌ពួកដទៃ ទើបពោលថា ធម្មជាតិដែលចក្ខុគប្បីឃើញ ឈ្មោះថា **សនិទស្សនំ** ប្រែថា ប្រព្រឹត្តទៅក្នុងភាពដែលចក្ខុគប្បីឃើញ ព្រោះធ្វើឲ្យស្រដៀងធម៌ដទៃ ។

ក៏សភាវៈដែលធ្វើសេចក្តីផ្សេងគ្នា យ៉ាងណា ក្នុងធម៌ទាំងឡាយដែលដូចគ្នា ដោយភាពស្មើគ្នាក្នុងសភាវៈនៃធម៌ សភាវៈនោះគួរពោលអែបៗ បាន ព្រោះស្រដៀងនឹងធម៌ដទៃ ។ ព្រោះហេតុនេះ ការចូលចិត្តនូវភាពផ្សេងគ្នានៃខ្លឹមសារ រមែងមានបាន ។

ន័យម្យ៉ាងទៀត សហ-ស័ព្ទ ក្នុងពាក្យថា **សហ និទស្សនេន** នេះមាន **តព្ភាវ** ជាអត្ថ ដូចជាពាក្យថា **នន្ទិរាគសហគតា** ប្រែថា សេចក្តីរីករាយ និងសេចក្តីស្រឡាញ់ ដូច្នេះ ។ ពាក្យថា មានការកម្មាត់ភាព

ជាអ្នកទ្រុស្តសីលជារស មានន័យថា មាននាទីកម្ចាត់ភាពទ្រុស្តសីលផ្សេងៗមានការមិនសង្រួមផ្លូវកាយជាដើម ។ពាក្យថា មានគុណគឺការមិនមានទោសជារស មានន័យថា មានគុណដែលនរណាៗ តិះដៀលមិនបានជាសម្បត្តិ គឺដល់ព្រមដោយភាពជាអ្នកដែលអ្នកណាៗ មិនតិះដៀល, ឬដល់ព្រមដោយចំណែកមិនមានទោស ។ ពាក្យថា ក្នុងបណ្ដាលក្ខណៈជាដើម មានន័យថា ក្នុងបណ្ដាលក្ខណៈ និងរសជាដើម ដែលកំពុងពោលមកនេះ កិច្ចនោះឯង ឬសម្បត្តិ លោកហៅថា **រស** អធិប្បាយថា មិនមែនអាយតនៈ មានរសាយតនៈជាដើមឈ្មោះថា **រស** នោះទេ ។ ចំណែកអាចារ្យពួកខ្លះពោលថា **អវធារណ** ក្នុងពាក្យថា **កិច្ចមេវ** ដើម្បីសម្ដែងថា **រស** នោះមានកម្លាំងជាង **រស** ក្រៅពីនេះ, ពាក្យនោះ ត្រឹមតែជាមតិរបស់អាចារ្យពួកនោះ ព្រោះលោកសំដៅយកសេចក្ដីនេះថា ជាកិច្ចនោះឯង ឬសម្បត្តិ ឈ្មោះថា រស ។ ពាក្យថា មានភាពស្អាតជាបច្ចុប្បដ្ឋាន មានន័យថា សីល រមែងប្រាកដដោយភាពជាធម្មជាតិស្អាតតាមកាយទ្វារជាដើម ។បទថា**គហណភាវំ** ប្រែថាភាពជាគុណដែលគប្បីកាន់យកដោយពាក្យនោះលោកពោលនូវបច្ចុប្បដ្ឋាន ដោយអត្ថថា អាការដែលប្រាកដ តែដោយអត្ថថា ផលលោកថា បច្ចុប្បដ្ឋាន មានការមិនក្ដៅក្រហាយជាខាងក្រោយជាដើម ឬបច្ចុប្បដ្ឋាន គឺសមាធិប្រាកដ ។ ពិតហើយ សីលញុំាងការមិនក្ដៅ

ក្រហាយឲ្យប្រាកដក្នុងបច្ចុប្បន្ន, ញ៉ាំងសមាធិឲ្យប្រាកដតាមលំដាប់ ។ ចំណែកផល គឺអានិសង្សនោះ លោកអាចារ្យនឹងពោលដូចតទៅ ក្នុងកថាសម្តែងដោយអានិសង្ស ដូច្នេះគប្បីឃើញថា លោកមិនបានកាន់យកក្នុងទីនេះ ។ តែអាចារ្យពួកខ្លះពោលថា លោកមិនកាន់យកក្នុងទីនេះ ព្រោះលោកមិនត្រូវការផល, សេចក្តីនោះមិនត្រូវ ព្រោះផលមានច្រើនយ៉ាង សូម្បីសីលមានលោកិយសីលជាដើម លោកមិនទាន់បែងចែក ។ ពិតយ៉ាងនោះហើយ លោកអាចារ្យនឹងពោលតទៅថា ដោយអំណាចនៃនិស្សិតសីល អនិស្សិតសីល ដូច្នេះជាដើម ។

លោកអាចារ្យកាលនឹងសម្តែងថា បឋវីធាតុ មានកម្មជាដើមជាហេតុឆ្ងាយ មានភូតរូប ៣ ដែលសល់ជាហេតុជិត យ៉ាងណា, ម្យ៉ាងទៀត សំពត់ មានជាងតម្បាញ ត្រល់ត្បាញ ធ្មេញឈើ និងចម្រៀកធ្មេញឈើជាដើម ជាហេតុឆ្ងាយ មានសរសៃអំបោះជាហេតុជិត យ៉ាងណា, **សីល** មានការស្តាប់ធម៌ជាដើមជាហេតុឆ្ងាយ **សីល** នោះមានហិរិ និងឱត្តប្បៈ ជាហេតុជិត ដូច្នោះ ទើបលោកពោលថា ឯ **ហិរិ ឱត្តប្បៈ** ដូច្នេះជាដើម ។ ពាក្យថា ពិតហើយ ពេលហិរិ ឱត្តប្បៈ ដូច្នេះជាដើម ជាពាក្យញ៉ាំងភាពជាហេតុជិតរបស់សីលនោះឲ្យសម្រេច ។ ក្នុងពាក្យនោះ គប្បីជ្រាបថា សីល កើតឡើងដោយអំណាចការសមាទាន តាំងនៅដោយការមិនឈានកន្លង ។

( ចប់ មហាដីកា )

.............................

# អានិសង្សរបស់សីល

សេចក្តីថា សីលមានអានិសង្សយ៉ាងណា ? ឆ្លើយថា មានការបានទទួលគុណជាអនេកមានការមិនក្តៅក្រហាយជាដើមជាអានិសង្ស សមដូចជាពាក្យរបស់ព្រះសាស្តាត្រាស់ទុកថា ម្នាលអានន្ទ សីលជាកុសលមានការមិនក្តៅក្រហាយចិត្តជាផល មានការមិនក្តៅក្រហាយចិត្តជាអានិសង្ស ដូច្នេះ, ត្រាស់ទុកផ្សេងទៀតក៏មាន ម្នាលគហបតីទាំងឡាយ អានិសង្សនៃសីលសម្បត្តិរបស់អ្នកមានសីលមាន ៥ ប្រការ, ៥ ប្រការនោះ ដូចម្តេចខ្លះ ? ម្នាលគហបតីទាំងឡាយ បុគ្គលណាក្នុងលោកនេះជាអ្នកមានសីល ដល់ព្រមដោយសីល រមែងបាននូវភោគៈច្រើន មានសេចក្តីមិនប្រមាទជាហេតុ នេះជាអានិសង្សទី ១ នៃសីលសម្បត្តិរបស់អ្នកមានសីល, ម្នាលគហបតីទាំងឡាយ សេចក្តីដទៃនៅមានទៀត កិត្តិស័ព្ទដ៏ល្អរបស់អ្នកមានសីល អ្នកដល់ព្រមដោយសីល រមែងផ្សាយទៅ នេះជាអានិសង្សទី ២ នៃសីលសម្បត្តិរបស់អ្នកមានសីល, ម្នាលគហបតីទាំងឡាយ សេចក្តីដទៃនៅមានទៀត អ្នកមានសីល ដល់ព្រមដោយសីល នឹងចូលទៅកាន់បរិស័ទណាៗ ជាខត្តិយបរិស័ទក៏ដោយ ព្រាហ្មណបរិស័ទក៏ដោយ គហបតីបរិស័ទក៏ដោយ សមណបរិស័ទក៏ដោយ រមែងជាអ្នកក្លាហាន ចូលទៅមិនអៀនប្រៀន នេះជាអានិសង្សទី ៣ នៃសីលសម្បត្តិរបស់អ្នក

មានសីល, ម្នាលគហបតីសេចក្ដីដទៃទៅមានទៀត អ្នកមានសីល ដល់ព្រមដោយសីល ជាអ្នកមិនវង្វេងទៅពេលជិតស្លាប់ នេះជាអានិសង្សទី ៤ នៃសីលសម្បត្តិរបស់អ្នកមានសីល, ម្នាលគហបតីទាំងឡាយ សេចក្ដីដទៃទៅមានទៀត អ្នកមានសីល ដល់ព្រមដោយសីល បន្ទាប់ពីស្លាប់ទៅព្រោះកាយបែកធ្លាយ តែងចូលទៅកាន់សុគតិ នេះ ជាអានិសង្សទី ៥ នៃសីលសម្បត្តិរបស់អ្នកដែលមានសីល ។

អានិសង្សរបស់សីលជាអនេកដទៃទៀតមានភាពជាទីស្រឡាញ់ ជាទីពេញចិត្តជាខាងដើម មានការអស់អាសវៈជាទីបំផុត ព្រះសាស្ដាត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុសង្ឃឹមថា យើងគប្បីជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីលើកសរសើររបស់មិត្តសព្រហ្មចារីទាំងឡាយ ភិក្ខុនោះ គប្បីជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយចុះ ដូច្នេះជាដើម ។

សីលមានគុណជាអនេក មានការមិនក្ដៅក្រហាយចិត្តជាដើម ជាអានិសង្ស មានប្រការដូចដែលបានពោលមកដូច្នេះ ។

ន័យម្យ៉ាងទៀត វៀរសីលណាចេញហើយ ដែលទីងពឹង ( វត្ថុដទៃ ) របស់កុលបុត្តក្នុងសាសនាមិនមាន, នរណានឹងគប្បីពោលកំណត់នូវអានិសង្សរបស់សីលនោះបាន ទឹក គឺសីល រមែងជម្រះមន្ទិលរបស់សត្វមានជីវិតនេះបាន សូម្បីទឹកធំទាំងឡាយ គឺទន្លេគង្គា

ក្ដី យមុនាក្ដី សរភូក្ដី សរស្វតីក្ដី សូម្បីទន្លេអចិរវតីក្ដី មហីក្ដី មិនអាចជម្រះមន្ទិលនោះបានឡើយ សីលដែលបុគ្គលរក្សាល្អហើយ ជាអរិយសីល មានភាពត្រជាក់ក្រៃលែង រមែងរម្ងាប់នូវសេចក្ដីក្ដៅក្រហាយរបស់សត្វទាំងឡាយក្នុងលោកនេះបាន ខ្យល់លាយភ្លៀងក៏មិនអាចរម្ងាប់សេចក្ដីក្ដៅក្រហាយនេះបាន និងសូម្បីច័ន្ទក្រហមក៏រម្ងាប់មិនបាន ខ្សែកម្រងមុក្ដាក៏មិនបាន កែវមណីក៏មិនបាន រស្មីត្រជាក់នៃព្រះច័ន្ទក៏មិនបាន, ក្លិនដែលស្មើដោយក្លិនសីល ដែលផ្សាយទៅបានទាំងតាមបណ្ដោយខ្យល់ និងទាំងបញ្ច្រាសខ្យល់នឹងមានមកពីណា វត្ថុដទៃដែលជាជណ្ដើរឡើងទៅកាន់ស្ថានសួគ៌ និងជាទ្វារដែលញ៉ាំងសត្វទាំងឡាយឲ្យចូលទៅកាន់នគរព្រះនិព្វាននឹងស្មើដោយសីល មានមកពីទីណា ព្រះរាជាទ្រង់ប្រដាប់ដោយមុក្ដា និងមណី ក៏មិនស្អាតដូចអ្នកមានសីល ដែលប្រដាប់ដោយគ្រឿងប្រដាប់ គឺសីលទើបស្អាត សីលរមែងកម្ចាត់នូវភ័យ មានអត្តានុវាទភ័យជាដើមបាន ដោយប្រការទាំងពួង សីលរមែងញ៉ាំងឈ្មោះបោះសំឡេង និងសេចក្ដីរីករាយឲ្យដល់អ្នកមានសីលគ្រប់ពេលវេលា កថាមុខសម្ដែងពីអានិសង្សរបស់សីល ដែលជាមូលនៃគុណទាំងឡាយ មានប្រក្រតីទម្លាយកម្លាំងនៃទោសទាំងពួង សាធុជន គប្បីជ្រាបដោយប្រការដូច្នេះចុះ ។

..........................

# មហាដីកា

## ពណ៌នាអានិសង្សរបស់សីល

ក្នុងពាក្យថា មានការមិនក្តៅក្រហាយជាដើម នេះមានសេចក្តីអធិប្បាយ ដូច្នេះ ចិត្តុប្បាទដែលជាកុសល ជាបដិបក្ខដល់សេចក្តីក្តៅក្រហាយ ឈ្មោះថា ការមិនក្តៅក្រហាយ ។ ការមិនក្តៅក្រហាយនោះ ពិសេសគប្បីជ្រាបថា ប្រព្រឹត្តទៅដោយអំណាចការពិចារណាចំពោះសីលរបស់ខ្លួនថា ជាលាភរបស់យើងហ្ន៎ ! យើងបានសីលហើយហ្ន៎ ! សីលរបស់យើងបរិសុទ្ធល្អ ដូច្នេះ ។

ដោយ អាទិ-ស័ព្ទ លោកអាចារ្យសំដៅយកបាមោជ្ជ ភោគសម្បត្តិ និងការមានឈ្មោះបោះសំឡេងល្អជាដើម ។

បទថា មានការមិនក្តៅក្រហាយចិត្តជាផល គឺមានការមិនត្រូវក្តៅក្រហាយចិត្តជាប្រយោជន៍ ។ ពាក្យថា ជាកុសល គឺរកទោសមិនបាន ។ ពាក្យថា មានការមិនក្តៅក្រហាយចិត្តជាអានិសង្ស គឺមានការមិនក្តៅក្រហាយចិត្ត ជាកម្រៃ ។ ពាក្យនេះ លោកសម្តែងថា ត្រឹមតែសីលកើតឡើងឈ្មោះថា មិនក្តៅក្រហាយ ប្រៀបដូចជាផ្លែនិងផ្កាឈើដែលរីកធំហើយ ។ ចំណែកគុណជាដើមថា សមាធិដែលឲ្យសម្រេចបានដោយសីលនេះ នោះមួយ៉ាងដទៃទៀត ។

ពាក្យថា នៃសីលសម្បត្តិរបស់អ្នកមានសីល មានន័យថា នៃសីលសម្បត្តិនោះៗ ឯង នៃអ្នកដែលឈ្មោះថា មានសីល ព្រោះញ៉ាំងសីលឲ្យដល់ព្រមដោយការធ្វើឲ្យបរិសុទ្ធ និងឲ្យបរិបូរ ។

បទថា **អប្បមាទាធិករណំ** ប្រែថា ព្រោះមានសេចក្ដីមិនប្រមាទ ជាហេតុ ។ បទថា **ភោគក្ខន្ធំ** ប្រែថា គំនរនៃភោគៈ ។ ពាក្យថា កិត្តិសព្ទល្អ រមែងផ្សាយទៅ មានន័យថា ការប្រកាសនូវការលើកសរសើរដ៏ល្អ រមែងតាំងឡើង គឺផ្សាយទៅទូទាំងលោកថា អ្នកនេះមានសីលសូម្បី ព្រោះហេតុនេះ អ្នកនេះមានធម៌ល្អ សូម្បីព្រោះហេតុនេះ ដូច្នេះ ។

ពាក្យថា ជាអ្នកក្លាហាន មានន័យថា កាលបើមិនឃើញខ្. ដែលគប្បីតិះដៀលយ៉ាងណាៗ ក្នុងខ្លួន ទើបប្រាសចាកការញញើត មិនមានការភ័យខ្លាច ។ បទថា **អមង្កុភូតោ** ប្រែថា មិនអៀនប្រៀន ។ ពាក្យថា ជាអ្នកមិនវង្វេង មានន័យថា មិនជាអ្នកវង្វេង គឺមានចិត្តផូរផង់ តែម្យ៉ាងធ្វើកាលកិរិយា ព្រោះមិនមានការក្ដៅក្រហាយចិត្ត ដោយន័យជាអាទិ៍ថា ឱ ! យើងមិនបានធ្វើសេចក្ដីល្អទុក និងព្រោះកុសលកម្មជាដើមនោះឯងមកប្រាកដក្នុងខណៈនោះ ។

ពាក្យថា ព្រោះកាយបែកធ្លាយ មានន័យថា ព្រោះលះឧបាទិន្នក្ខន្ធ គឺព្រោះដាច់ជីវិតិន្ទ្រិយ៍ ។ ពាក្យថា បន្ទាប់ពីស្លាប់ មានន័យថា

បន្ទាប់ពីចុតិ ។ ពាក្យថា **សុគតិ** ប្រែថា គតិដែលល្អ ។ សូម្បីមនុស្សគតិ ក៏រាប់ចូលក្នុងបទថាសុគតិនោះដែរ ។ ពាក្យថា សគ្គំ បានដល់ទេវគតិ ។ ទេវគតិនោះ លោកហៅថា សគ្គំ ព្រោះអត្ថថា ប្រសើរយ៉ាងក្រៃលែងដោយអារម្មណ៍ទាំងឡាយមានរូបជាដើម,និងហៅថា **លោក** ព្រោះអត្ថថា ជាកន្លែងឃើញនូវផលបុណ្យដ៏រុងរឿង ។

បទថា **អាកង្ខេយ្យ ចេ** ប្រែថា បើគប្បីប្រាថ្នា ។ ពាក្យថា យើងគប្បីជាទីស្រឡាញ់ មានន័យថា ដែលគេគប្បីប្រព្រឹត្តស្រឡាញ់រាក់ទាក់ គឺគប្បីមើលដោយចក្ខុដែលជាទីស្រឡាញ់ គឺគប្បីជាអ្នកគួរស្រឡាញ់ ។

ពាក្យថា ជាទីពេញចិត្ត មានន័យថា ជាគ្រឿងចម្រើនចិត្តរបស់មិត្តសព្រហ្មចារីទាំងឡាយ,ឬមានន័យថាដែលចិត្តរបស់សព្រហ្មចារីទាំងឡាយនោះ គប្បីដល់អធិប្បាយថា ដែលចិត្តប្រកបដោយមេត្តាគប្បីផ្សាយទៅ ។

ពាក្យថា ជាទីគោរព មានន័យថា ជាអ្នកនៅក្នុងឋានៈដែលរឹងប៉ឹង ដូចជាឆត្រថ្ម ។ ពាក្យថា **ជាទីលើកសរសើរ** មានន័យថា គប្បីជាទីលើកសរសើរថា អ្នកនេះដឹងវត្ថុគួរដឹង ឃើញវត្ថុដែលគួរឃើញយ៉ាងពិតប្រាកដ ។ ពាក្យថា គប្បីជាអ្នកធ្វើឲ្យបរិបូរក្នុងសីលទាំងឡាយចុះ មានន័យថា ជាអ្នកធ្វើឲ្យបរិបូរ ក្នុងចតុប្បារិសុទ្ធិសីល

តែម្យ៉ាង គឺមិនធ្វើតិចតួច គប្បីជាអ្នកប្រកបហើយដោយអាការដែលបរិបូណ៌ ។

ពាក្យថា ដោយន័យជាដើមថា នេះលោករួបរួមយកអានិសង្សសីល ១៧ ប្រការដែលមានមកក្នុងសូត្រ ដែលលើកសរសើរសីល មានពាក្យជាដើមយ៉ាងនេះថា តែងប្រកបនូវការស្ងប់រម្ងាប់ចិត្តខាងក្នុងមិនធ្វើឈានឲ្យកម្រើក ប្រកបដោយវិបស្សនា បន្ថែមឡើងនូវសុញ្ញាគារ ។

ឥឡូវនេះ លោកអាចារ្យផ្ដើមពាក្យជាដើមថា ន័យម្យ៉ាងទៀតដូច្នេះក៏ដើម្បីនឹងសម្ដែងនូវអានិសង្សសីលទាំងឡាយនោះថា មិនមែនថា មានអានិសង្ស គឺសេចក្ដីមិនក្ដៅក្រហាយចិត្តជាដើមនេះ ម្យ៉ាងប៉ុណ្ណោះទេ សេចក្ដីពិត នៅមានអានិសង្សសីលដទៃទៀតជាច្រើន ។

ក្នុងបណ្ដាពាក្យទាំងឡាយនោះ ពាក្យថា ក្នុងព្រះសាសនា មានន័យថា ក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា គឺព្រះពុទ្ធសាសនាដែលនឹងនាំមកនូវគុណជាលោកិយ និងលោកុត្តរ ។

អធិប្បាយសេចក្ដីថា ទីពឹង គឺទីអាស្រ័យរបស់កុលបុត្តដែលមានអាចារទាំងឡាយ វៀរសីលចេញហើយ រមែងមិនមាន, នរណានឹងគប្បីពោល គឺនរណាអាចនឹងប្រាប់នូវការកំណត់ គឺបរិមាណនៃអានិសង្សរបស់សីលនោះដែល មានអានុភាពច្រើនយ៉ាងនេះបាន ។

ដោយពាក្យនេះ លោកអាចារ្យសម្តែងថា សីលប៉ុណ្ណោះ ជាឫសគល់នៃគុណទាំងឡាយដែលជាលោកិយនិងលោកុត្តរទាំងអស់តែម្យ៉ាង ដូច្នេះបន្ទាប់ពីនោះ កាលនឹងសម្តែងថា មិនមានគុណយ៉ាងដទៃ ដែលនឹងនាំប្រយោជន៍សុខមកឲ្យសត្វទាំងឡាយស្មើដោយសីល ក្នុងការជម្រះមន្ទិលដោយរម្ងាប់ការក្តៅក្រហាយ ដោយការខ្វះខ្វាយទៅនៃក្លិនក្រអូបបញ្ច្រាស់, ដោយភាវៈជាឧបាយឲ្យដល់សួគ៌ និងនិព្វាន, ក្នុងការឲ្យសម្រេចដោយគ្រឿងប្រដាប់អលង្ការ ដែលល្អឥតខ្ចោះបោសកម្ចាត់នូវភ័យនិងឲ្យកើតសេចក្តីរុងរឿងព្រមទាំងបាមោជ្ជ ដូច្នេះ ទើបបានភាសិត គាថាទាំងឡាយមានជាអាទិ៍ថា **ន គង្គា** ដូច្នេះ ប្រែសេចក្តីថា សូម្បីទន្លេគង្គា ក៏មិនអាចជម្រះមន្ទិលរបស់សត្វក្នុងលោកនេះបាន ។

ក្នុងបណ្តាពាក្យទាំងឡាយនោះ ពាក្យថា ***សរភូ*** គឺខ្សែទឹកមួយដែលអាចារ្យទាំងឡាយនាំគ្នាហៅក្នុងលោកថា សរភូ ។

ពាក្យថា **និន្នគា វា ចិរវតី** គឺទន្លេដែលមានឈ្មោះយ៉ាងនេះថា **អចិរវតី** ស័ព្ទថា ***វា*** មានន័យថា *វា*-ស័ព្ទ គ្រប់កន្លែងមានខ្លឹមសារជាអនិយម ( មិនពិតប្រាកដ ) ។ *វា*-ស័ព្ទនោះ លោករួមទាំងទន្លេគោធាវរី និងទន្លេច័ន្ទភាគាជាដើម ដែលមិនទាន់បានពោលទុក ។គប្បីយក ន អក្សរ ក្នុងគាថាដើមមកភ្ជាប់គ្នាដូច្នេះថា **បាណានវឌ្ឍន** ។បេ។

**ន សក្កុណន្តិ គង្គាទយោ នទិយោ** ទឹក គឺសីល រមែងជម្រះមន្ទិលណា របស់សត្វ ឈ្មោះថា មានបាណ ព្រោះអត្ថថា នៅជកជង្ហើមនៅឡើយ សូម្បីទន្លេគង្គាជាដើម ក៏មិនអាចជម្រះមន្ទិលនោះបាន ។

បទថា **ហារា** បានដល់ កែវមុក្តាហារ ។ បទថា **មណយោ** បានដល់ កែវមណី មានកែវពិទូរ្យជាដើម ។ ពាក្យថា **អរិយ** មានន័យថា បរិសុទ្ធ ។ ក្លិន គឺកិត្តិស័ព្ទដែលមានសីលជាសមុដ្ឋាន លោកហៅថា **សីលគន្ធោ** ( ក្លិនសីល ) ព្រោះភាវៈដែលផ្សេមចិត្ត និងផ្សាយទៅក្នុងទិសទាំងពួងបាន ក៏ក្លិនសីលនោះ រមែងផ្សាយទៅបញ្ច្រាស់ខ្យល់ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **ក្លិនរបស់សប្បុរស រមែងផ្សាយទៅបញ្ច្រាស់ខ្យល់បាន** ។ គប្បីជ្រាបថា ការល្មើសវត្ថុ ឈ្មោះថា កម្លាំងនៃទោស, **សីល** កាលបើមិនឲ្យធ្វើការល្មើសវត្ថុនោះ នៃទោសទាំងឡាយនោះ ឈ្មោះថា មានប្រក្រតីកម្ចាត់កម្លាំងរបស់ទោសទាំងឡាយ ។

( ចប់ មហាដីកា )

# ប្រភេទរបស់សីល

បន្ទាប់ពីនេះ ជាពាក្យវិសជ្ជនាក្នុងបញ្ហាដែលខ្ញុំម្ចាស់ពោលទុកថា សីលនោះ មានប៉ុន្មានប្រភេទ ?

សីលទាំងអស់ ដោយលក្ខណៈជាឫសគល់របស់ខ្លួន ត្រឹមតែមួយយ៉ាងប៉ុណ្ណោះ, ជា ២ យ៉ាង គឺជាចារិតសីល និងវារិតសីល, មួយវិញទៀត ជាអភិសមាចារិកសីល និងអាទិព្រហ្មចរិយកសីល, ជាវិរតិសីល និងអវិរតិសីល, ជានិស្សិតសីល និងអនិស្សិតសីល, ជាកាលបរិយន្តសីល និងអាបាណកោដិកសីល, ជាសបរិយន្តសីល និងអបរិយន្តសីល, ជាលោកិយសីល និងលោកុត្តរសីល ។

ជា ៣ យ៉ាង ដោយ ហីនសីល មជ្ឈិមសីល បណីតសីល និងជា ៣ យ៉ាងទៀត ដោយអត្តាធិបតេយ្យសីល លោកាធិបតេយ្យសីល និងធម្មាធិបតេយ្យសីល, ជាបរាមដ្ឋសីល អបរាមដ្ឋសីល និងបដិ-បស្សទ្ធិសីល, ជាវិសុទ្ធិសីល អវិសុទ្ធិសីល និងវេមតិកសីល និងជាសេក្ខសីល អសេក្ខសីល និងនេវសេក្ខានាសេក្ខសីល ។

ជា ៤ យ៉ាង គឺហានភាគិយសីល ឋិតិភាគិយសីល វិសេសភាគិយសីល និងជានិព្វេធភាគិយសីល, ជា ៤ យ៉ាងទៀត គឺភិក្ខុសីល ភិក្ខុនីសីល អនុបសម្បន្នសីល និងគហដ្ឋសីល, ជាបកតិសីល អាចារ

សីល ធម្មតាសីល និងបុព្វហេតុកសីល និងជាបាតិមោក្ខសំវរសីល ឥន្ទ្រិយសំវរសីល អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល ។

ជា ៥ យ៉ាង គឺ **បារិសុទ្ធិសីល** មានបរិយន្តបារិសុទ្ធិសីលជាដើម ឯសេចក្តីនេះ ព្រះសារីបុត្តក៏បានពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គ ថា សីល ៥ ប្រការ គឺបរិយន្តបារិសុទ្ធិសីល អបរិយន្តបារិសុទ្ធិសីល បរិបុណ្ណបារិសុទ្ធិសីល អបរាមដ្ឋបារិសុទ្ធិសីល បដិបស្សទ្ធិបារិសុទ្ធិសីល ដូច្នេះ, មយ៉ាងទៀតជា ៥ យ៉ាងទៀត គឺបហានសីល វេរមណីសីល ចេតនាសីល សំវរសីល និងអវីតិក្កមសីល ។

បណ្តាសីលទាំងឡាយនោះ ក្នុងចំណែកសីលតែមយ៉ាង គប្បីជ្រាបខ្លឹមសារតាម ន័យដូចដែលបានពោលហើយនោះចុះ... ។

## ទុកៈទី ១ ( សីលពួក ២ )

វិនិច្ឆ័យក្នុងចំណែកសីល ២ យ៉ាង ដូចតទៅនេះ :

ការបំពេញសិក្ខាបទ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តទុកថា នេះគួរធ្វើយ៉ាងណា ការបំពេញនោះឈ្មោះថា ចារិតសីល ការមិនធ្វើ ១.ដែលទ្រង់ហាមទុកថា នេះមិនគួរធ្វើយ៉ាងណា ការមិនធ្វើនោះឈ្មោះ ថា វារិតសីល ( តទៅ ) នេះជាការអធិប្បាយពាក្យក្នុងបទទាំងពីរនោះ បុគ្គលទាំងឡាយ រមែងប្រព្រឹត្តក្នុងសីលនោះ គឺដំណើរ ( កាយ

វាចា ) ទៅដោយភាពជាអ្នកធ្វើឲ្យបរិបូរក្នុងសីលទាំងឡាយ ព្រោះហេតុនោះ សីលនោះ ទើបឈ្មោះថា ចារិត ( ជាការប្រព្រឹត្ត ), បុគ្គលទាំងឡាយរមែងការពារ គឺរមែងរក្សានូវដែលទ្រង់ហាម ដោយសីលនោះ ព្រោះហេតុនោះ សីលនោះទើបឈ្មោះថា វារិត ( ជាគ្រឿងរក្សានូវដែលទ្រង់ហាម ) ក្នុងពីរយ៉ាងនោះ ចារិតសីលសម្រេចដោយសទ្ធា និងវីរិយៈ, វារិតសីល សម្រេចដោយសទ្ធា ( តែម្យ៉ាង ) ដូច្នេះ, សីល ២ ប្រភេទ គឺចារិតសីល និងវារិតសីល ដូច្នេះឯង ។

## ទុកៈទី ២

វិនិច្ឆ័យក្នុងទុកៈទី ២ មារយាទល្អក្រៃលែង ឈ្មោះថា អភិសមាចារ អភិសមាចារនោះឯង ហៅថា **អភិសមាចារិក**, ន័យម្យ៉ាងទៀត សិក្ខាបទដែលទ្រង់បញ្ញត្តប្រារព្ធចំពោះអភិសមាចារនោះ ឈ្មោះថា **អភិសមាចារិក**, ពាក្យថា **អភិសមាចារិក** នោះឯងជាពាក្យហៅចំពោះសីល ក្រៅពីអាជីវដ្ឋមកសីល ។

**សីល** ឈ្មោះថា **អាទិព្រហ្មចរិយក** ព្រោះជាភាវៈខាងដើមនៃមគ្គព្រហ្មចរិយ។

ពាក្យថា អាទិព្រហ្មចរិយក នេះជាឈ្មោះនៃអាជីវដ្ឋមកសីល ក៏អាជីវដ្ឋមកសីលនោះ ឈ្មោះថា ជាភាវៈខាងដើមនៃមគ្គ ព្រោះជា

គុណដែលបុគ្គលគួរធ្វើឲ្យហ្មត់ចត់ក្នុងចំណែកខាងដើមនោះឯង ព្រោះហេតុនោះ ព្រះសាស្ដា ទើបត្រាស់ថា ក៏ឯកាយកម្ម វចីកម្ម អាជីវៈរបស់ភិក្ខុនោះ រមែងហ្មត់ចត់ល្អហើយ ក្នុងចំណែកខាងដើម ដូច្នេះ, ន័យម្យ៉ាងទៀត សិក្ខាបទទាំងឡាយណាដែលទ្រង់ត្រាស់ថា ជាសិក្ខាបទតូច នេះក៏ជាអភិសមាចារិកសីល ដ៏សេសក៏ជាអាទិព្រហ្មចរិយកសីល, ន័យម្យ៉ាងទៀត សីលដែលទាក់ទងក្នុងឧភតោវិភង្គ ជាអាទិព្រហ្មចរិយកសីលដែលទាក់ទងក្នុងខន្ធកវត្ត ជាអភិសមាចារិកសីល អាទិព្រហ្មចរិយកសីលរមែងដល់ព្រម ព្រោះការដល់ព្រមនៃអភិសមាចារិកសីលនោះ ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីដែលភិក្ខុនោះឯងមិនធ្វើធម៌ដែលជាអភិសមាចារិកៈឲ្យបរិបូណ៌មុន ហើយនឹងញ៉ាំងធម៌ ដែលជាអាទិព្រហ្មចរិយកៈឲ្យបរិបូណ៌ដូច្នេះ នេះមិនមែនជាឋានៈដែលនឹងអាចកើតបានសីល ២ យ៉ាង ដោយជាអភិសមាចារិកសីល និងអាទិព្រហ្មចរិយកសីលដូច្នេះ ។

## ទុកៈទី ៣

វិនិច្ឆ័យក្នុងទុកៈទី ៣ គុណ គឺការវៀរចាកទោស មានបាណាតិបាតជាដើម យ៉ាងណាមួយ ជាវិរតិសីល គុណដ៏សេសមានចេតនា

ជាដើម ជាអវិរតិសីល គប្បីជ្រាបនូវសីលជា ២ យ៉ាង គឺជាវិរតិសីល និងអវិរតិសីល ដោយប្រការដូច្នេះ ។

## ទុកៈទី ៤

វិនិច្ឆ័យក្នុងទុកៈទី ៤, ពាក្យថា **និស្សយ** បានដល់ និស្ស័យ ២ យ៉ាង គឺតណ្ហានិស្ស័យ ១ ទិដ្ឋិនិស្ស័យ ១ ក្នុងពីរយ៉ាងនោះ សីលណា ដែលបុគ្គលប្រាថ្នាភពសម្បត្តិថា យើងនឹងបានជាស្តេចទេវតា ឬទេវតា ណាមួយដោយសីលនេះ ដូច្នេះ ប្រព្រឹត្តទៅសីលនេះជាតណ្ហានិស្សិត សីល សីលណាដែលបុគ្គលប្រព្រឹត្តទៅ ដោយសុទ្ធិទិដ្ឋិថា សេចក្តី បរិសុទ្ធិ (នឹងមានបាន) ដោយសីលនេះ ដូច្នេះ សីលនេះជាទិដ្ឋិនិស្សិត សីល ចំណែកសីលណាដែលជាលោកុត្តរក្តី ជាលោកិយតែជាគ្រឿង ទំនុកបម្រុងលោកុត្តរសីលនោះ នេះជាអនិស្សិតសីល ដូច្នេះឯង នេះ គឺសីល ២ យ៉ាង ដែលជានិស្សិតសីល និងអនិស្សិតសីល ដូច្នេះឯង។

## ទុកៈទី ៥

ក្នុងទុកៈទី ៥ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ សីលដែលបុគ្គលធ្វើការ កំណត់កាលសមាទាន ឈ្មោះថា **កាលបរិយន្តសីល** សីលដែល បុគ្គលសមាទានអស់មួយជីវិត ហើយប្រព្រឹត្តទៅអស់មួយជីវិតដូចគ្នា ឈ្មោះថា **អាបាណកោដិកសីល** គប្បីជ្រាបសីលជា ២ យ៉ាង គឺជា

កាលបរិយន្តសីល និងអាបាណកោដិកសីល ដោយប្រការដូច្នេះ ។

## ទុកៈទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុងទុកៈទី ៦ តទៅ :

សីលដែលមានការឃើញដោយអំណាចលាភ យស ញាតិ អវយវៈ និងជីវិត ជាទីបំផុត ឈ្មោះថា សបរិយន្តសីល ដែលផ្ទុយគ្នា ឈ្មោះថា អបរិយន្តសីល ពិតហើយ សូម្បីព្រះធម្មសេនាបតីសារីបុត្ត ក៏ពោលពាក្យនេះ ក្នុងគម្ពីរបដិសម្ភិទាមគ្គទុកថា សួរថា សីលមានទីបំផុតនោះដូចម្តេច ? ឆ្លើយថា សីលមានលាភជាទីបំផុតក៏មាន សីលមានយសជាទីបំផុតក៏មាន សីលមានញាតិជាទីបំផុតក៏មាន សីលមានអវយវៈជាទីបំផុតក៏មាន សីលមានជីវិតជាទីបំផុតក៏មាន ( សួរថា ) សីល មានលាភជាទីបំផុតនោះដូចម្តេច ? ( ឆ្លើយថា ) បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងកន្លងសិក្ខាបទដែលខ្លួនសមាទានហើយ ព្រោះលាភជាហេតុ ព្រោះលាភជាបច្ច័យ ព្រោះលាភជាហេតុ សីលនោះ ឈ្មោះថា មានលាភជាទីបំផុត សីលក្រៅពីនេះគប្បីធ្វើឲ្យពិស្តារដោយឧបាយនេះឯង សូម្បីការវិសជ្ជនាអបរិយន្តសីល លោកក៏ពោលទុកថា ( សួរថា ) សីលមិនមែនមានលាភជាទីបំផុតដូចម្តេច ? ( ឆ្លើយថា ) បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនធ្វើសូម្បីតែការគិតល្មើសសិក្ខា

បទតាមដែលសមាទានហើយ ព្រោះលាភជាហេតុ ព្រោះលាភជាបច្ច័យ ព្រោះលាភជាប្រធានឲ្យកើតឡើង ធ្វើម្តេចគេនឹងល្មើស (ដោយកាយវាចា) ទៅនេះ សីលនោះ ឈ្មោះថា មិនមែនមានលាភជាទីបំផុត សូម្បីសីលក្រៅពីនេះ ក៏គប្បីធ្វើឲ្យពិស្តារដោយឧបាយនេះដូចគ្នា គប្បីជ្រាបសីលជា ២ យ៉ាង គឺជាសបរិយន្តសីល និងអបរិយន្តសីល ដោយប្រការដូច្នេះឯង ។

## ទុកៈទី ៧

ក្នុងទុកៈទី ៧ គប្បីជ្រាបវិនិច្ឆ័យថា សីលមានអាសវៈទាំងអស់ជាលោកិយសីល ដែលមិនមានអាសវៈជាលោកុត្តរសីល ក្នុងសីល ២ យ៉ាងនោះ លោកិយសីល រមែងជាគុណនាំភពពិសេសមកឲ្យ និងជាគ្រឿងទំនុកបម្រុងការចេញចាកភពផងដែរ ដូចព្រះមានព្រះភាគត្រាស់ទុកថា វិន័យ (រមែងមាន) ដើម្បីប្រយោជន៍ដល់សំវរៈ សំវរៈដើម្បីប្រយោជន៍ដល់អវិប្បដិសារៈ អវិប្បដិសារៈដើម្បីប្រយោជន៍ដល់បាមោជ្ជ បាមោជ្ជដើម្បីប្រយោជន៍ដល់បីតិ បីតិដើម្បីប្រយោជន៍ដល់បស្សទ្ធិ បស្សទ្ធិដើម្បីប្រយោជន៍ដល់សុខ សុខដើម្បីប្រយោជន៍ដល់សមាធិ សមាធិដើម្បីប្រយោជន៍ដល់យថាភូតញ្ញាណទស្សនៈ យថាភូតញ្ញាណទស្សនៈដើម្បីប្រយោជន៍ដល់និព្វិទា និព្វិទាដើម្បី

ប្រយោជន៍ដល់វិរាគៈ វិរាគៈដើម្បីប្រយោជន៍ដល់វិមុត្តិ វិមុត្តិដើម្បីប្រយោជន៍ដល់វិមុត្តិញ្ញាណទស្សនៈ វិមុត្តិញ្ញាណទស្សនៈដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាន, កថា (ការនិយាយគ្នា) ការប្រឹក្សាគ្នា ការចូលអន្តុយជិតគ្នា ការផ្ទៀងសោតៈ (បង្អោនស្តាប់) គ្រប់យ៉ាងនោះជាប្រយោជន៍ នោះ គឺអ្វី នោះ គឺការរួចផុតនៃចិត្ត ព្រោះមិនប្រកាន់មាំ ដូច្នេះ ចំណែកលោកុត្តរសីល រមែងជាគុណនាំមកនូវការរលាស់ចេញចាកភព និងជាភូមិនៃបច្ចវេក្ខណញ្ញាណ បណ្ឌិតគប្បីជ្រាបសីលជា ២ យ៉ាង គឺលោកិយសីល និងលោកុត្តរសីល ដោយប្រការដូច្នេះ ។

## តិកៈទី ១ (សីលពួក៣)

ក្នុងតិកៈទាំងឡាយ គប្បីជ្រាបវិនិច្ឆ័យក្នុងតិកៈទី ១ ដូច្នេះ សីលដែលបុគ្គលប្រព្រឹត្តដោយឆន្ទៈ ចិត្ត វីរិយៈ វិមំសា យ៉ាងទាប ឈ្មោះថា **ហីនសីល** ដែលប្រព្រឹត្តដោយឆន្ទៈជាដើមកណ្តាល ឈ្មោះថា **មជ្ឈិមសីល** ដែលប្រព្រឹត្តដោយឆន្ទៈជាដើមប្រណីត ឈ្មោះថា **បណីតសីល** ។

ន័យម្យ៉ាងទៀតសីលដែលសមាទានដើម្បីប្រាថ្នាយស ឈ្មោះថា **ហីនសីល** ដែលសមាទានដោយត្រូវការផលបុណ្យ ឈ្មោះថា

មជ្ឈិមសីល ដែលសមាទាន ដើម្បីអរិយភាវៈ ដោយគិតថា វត្តនេះគួរធ្វើពិត ឈ្មោះថា **បណីតសីល** ។ ម្យ៉ាងវិញទៀត សីលដែលសៅហ្មងដោយទោស មានការលើកតម្កើងខ្លួន បន្ទាប់អ្នកដទៃយ៉ាងនេះថា យើងជាអ្នកដល់ព្រមដោយសីល ចំណែកភិក្ខុដទៃជាអ្នកទ្រុស្តសីលមានធម៌លាមកដូច្នេះជាដើមជាហីនសីល លោកិយសីលដែលមិនសៅហ្មងយ៉ាងនេះ ជា **មជ្ឈិមសីល លោកុត្តរសីល** ជា **បណីតសីល** ។

ន័យម្យ៉ាងទៀត សីលដែលប្រព្រឹត្តទៅដើម្បីត្រូវការភព និងភោគៈដោយអំណាចតណ្ហា ជាហីនសីល សីលប្រព្រឹត្តទៅដើម្បីត្រូវការ ការរួចផុតចំពោះខ្លួនឯង ជាមជ្ឈិមសីល សីលបារមីប្រព្រឹត្តទៅដើម្បីត្រូវការសេចក្ដីរួចផុតនៃសព្វសត្វ ជាបណីតសីល បណ្ឌិតគប្បីជ្រាបនូវសីល ៣ យ៉ាង គឺជាហីនសីល មជ្ឈិមសីល និងបណីតសីល ដោយប្រការដូច្នេះ ។

## តិកៈទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុងតិកៈទី ២ តទៅ ៖

សីលដែលបុគ្គលអ្នកធ្ងន់ក្នុងខ្លួន ប្រាថ្នានឹងលះកម្មដែលមិនគួរដល់ខ្លួន ប្រព្រឹត្តដោយសេចក្ដីគោរពក្នុងខ្លួន ឈ្មោះថា អត្តាធិបតេយ្យ

សីល ( សីលមានខ្លួនជាធំ ) ។ សីលដែលបុគ្គលធ្ងន់ក្នុងលោកប្រាថ្នានឹងគេចពីពាក្យតិះដៀលរបស់លោក ប្រព្រឹត្តដោយសេចក្តីគោរពក្នុងលោក ឈ្មោះថា **លោកាធិបតេយ្យសីល** ( សីលមានលោកជាធំ ) ។ សីលដែលបុគ្គលធ្ងន់ក្នុងធម៌ ប្រាថ្នានឹងបូជាភាពជាធំចំពោះធម៌ ប្រព្រឹត្តដោយសេចក្តីគោរពក្នុងធម៌ ឈ្មោះថា **ធម្មាធិបតេយ្យសីល** ( សីលមានធម៌ជាធំ ) គប្បីជ្រាបសីល ៣ យ៉ាង ដែលមានអត្តាធិបតេយ្យសីលជាដើម ដូច្នេះឯង។

## តិកៈទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុងតិកៈទី ៣ តទៅ

សីលណាដែលហៅថា និស្សិតសីលក្នុងសីលពួក ២ សីលនោះឈ្មោះថា បរាមដ្ឋសីល ព្រោះត្រូវតណ្ហា និងទិដ្ឋិចាប់យក, សីលជាសម្ភារៈនៃមគ្គរបស់កល្យាណបុថុជ្ជន និងដែលសម្បយុត្តដោយមគ្គរបស់ព្រះសេក្ខទាំងឡាយ ឈ្មោះថា អបរាមដ្ឋសីល ( សីលដែលមិនត្រូវតណ្ហា និងទិដ្ឋិចាប់យក ) ចំណែកសីល ដែលសម្បយុត្តដោយផលទាំងឡាយរបស់ព្រះសេក្ខ និងរបស់ព្រះអរហន្ត ឈ្មោះថា បដិបស្សទ្ធិសីល ( សីលដែលស្ងប់រម្ងាប់ហើយ ) គប្បីជ្រាបសីល ៣ យ៉ាង ដែលជាបរាមដ្ឋសីលជាដើមដូច្នេះ ។

## តិកៈទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុងតិកៈទី ៤ តទៅ

សីលដែលភិក្ខុអ្នកមិនត្រូវអាបត្តិ ធ្វើឲ្យបរិបូរក្តី ដែលត្រូវហើយសម្តែងចេញក្តី ឈ្មោះថា វិសុទ្ធិសីល សីលដែលភិក្ខុត្រូវអាបត្តិហើយមិនសម្តែង ឈ្មោះថា **អវិសុទ្ធិសីល** សីលរបស់ភិក្ខុអ្នកសង្ស័យក្នុងវត្ថុក្តី ក្នុងអាបត្តិក្តី ក្នុងអជ្ឈាចារក្តី ឈ្មោះថា វេមតិកសីល, ក្នុងសីលទាំងឡាយនោះ **អវិសុទ្ធិសីល** ព្រះយោគាវចរគួរធ្វើឲ្យបរិសុទ្ធ, ក្នុងវេមតិកសីលកុំធ្វើការកន្ទងល្មើសវត្ថុ គប្បីបន្ទោបង់សេចក្តីសង្ស័យចេញឲ្យបានយ៉ាងនេះ សេចក្តីសុខនឹងមានដល់អ្នក គប្បីជ្រាបសីល ៣ យ៉ាង ដែលជាវិសុទ្ធិសីលជាដើម ដោយប្រការដូច្នេះឯង ។

## តិកៈទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុងតិកៈទី ៥ ដូចតទៅ

សីលដែលសម្បយុត្តដោយអរិយមគ្គ ៤ និងសាមញ្ញផល ៣ ជាសេក្ខសីល ដែលសម្បយុត្តដោយអរហត្តផល ជាអសេក្ខសីលដ៏សេសជានេវសេក្ខានាសេក្ខសីល គប្បីជ្រាបសីល ៣ យ៉ាង ដែលជាសេក្ខសីលជាដើម ដោយប្រការដូច្នេះ តែក្នុងគម្ពីរបដិសម្ភិទាមគ្គព្រះធម្មសេនាបតីសារីបុត្តពោលទុកថា ព្រោះហេតុថា សូម្បីប្រក្រតី

របស់សត្វនោះៗ ក្នុងលោកក៏ហៅថា សីលដែលគេនាំគ្នាពោលថា **អយំ សុខសីលោ** បុគ្គលនេះមានប្រក្រតីជាសុខ **អយំ ទុក្ខសីលោ** បុគ្គល នេះមានប្រក្រតីជាទុក្ខ, **អយំ កលហសីលោ** បុគ្គលនេះមាន ប្រក្រតីឈ្លោះប្រកែក, **អយំ មណ្ឌនសីលោ** បុគ្គលនេះមានប្រក្រតី តែងខ្លួនដូច្នេះ, ដោយបរិយាយនេះ ទើបសីលមាន ៣ យ៉ាង គឺកុសល សីល អកុសលសីល អព្យាកតសីល, សីល ៣ យ៉ាង ដែលជាកុសល សីលជាដើមដូច្នេះឯង ក្នុងសីល ៣ យ៉ាងនោះ អកុសលសីល រមែង មិនសមជាមួយអាការស្មូម្បីតែ ១ នៅក្នុងអាការទាំងពួង មានលក្ខណៈ ជាដើម នៃសីលដែលសំដៅយកក្នុងអត្ថនេះ ព្រោះហេតុនោះ ទើប មិនរាប់ចូលក្នុងសីលនិទ្ទេសនេះព្រោះដូច្នោះគប្បីជ្រាបសេចក្តីដែល សីលនោះមាន ៣ យ៉ាង ក្នុងន័យដូចដែលបានពោលហើយនោះចុះ ។

## ចតុក្កៈទី ១ (សីលពួក៤)

ក្នុងចតុក្កៈទាំងឡាយ គប្បីជ្រាបវិនិច្ឆ័យក្នុងចតុក្កៈទី ១ ដូចតទៅ

ភិក្ខុណាក្នុងសាសនានេះ សេពគប់តែបុគ្គលទ្រុស្តសីល មិន សេពគប់បុគ្គលមានសីល ជាបុគ្គលល្ងង់ មិនឃើញទោសក្នុងការ ល្មើសវត្ថុ ជាអ្នកច្រើនទៅដោយការគិតខុស មិនរក្សាឥន្ទ្រីយ៍ទាំង ឡាយ សីលរបស់ភិក្ខុរូបនោះឯងចាត់ជាហានភាគិយសីល ( សីល

តាំងនៅក្នុងចំណែកនៃសេចក្ដីវិនាស ) ចំណែកភិក្ខុណា ក្នុងព្រះសាសនានេះ ជាអ្នកមានចិត្តរីករាយតែក្នុងសីលសម្បត្តិ មិនញុំាងនូវសេចក្ដីពេញចិត្តក្នុងការប្រកបកម្មដ្ឋានរឿយៗ ឲ្យកើតឡើង សីលនោះរបស់ភិក្ខុដែលពេញចិត្តនៅដោយគុណត្រឹមសីល មិនព្យាយាមជាប់តគ្នាឲ្យក្រៃលែងឡើងទៅនោះជាឋិតិភាគិយសីល(សីលតាំងនៅក្នុងចំណែកទ្រទ្រង់ខ្លួន ) ឯភិក្ខុណាជាអ្នកមានសីលដល់ព្រមហើយព្យាយាមជាប់តគ្នាឲ្យបានសមាធិ សីលរបស់ភិក្ខុនោះជាវិសេសភាគិយសីល(សីលដែលតាំងនៅក្នុងចំណែកវិសេសឡើង)ភិក្ខុណាមិនល្មមចិត្ត ដោយគុណត្រឹមសីលប្រកបដោយនិព្វិទារឿយៗ ជានិច្ចសីលរបស់ភិក្ខុនោះជានិព្វេធភាគិយសីល ( សីលតាំងនៅក្នុងចំណែកទម្លាយកិលេស ) ដូច្នេះឯង គប្បីជ្រាបសីល ៤ យ៉ាង ដែលជាហានភាគិយសីលជាដើម ដោយប្រការដូច្នេះ ។

## ចតុក្កៈទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុងចតុក្កៈទី ២ តទៅ

សិក្ខាបទដែលទ្រង់បញ្ញត្តប្រារព្ធចំពោះភិក្ខុទាំងឡាយនិងសិក្ខាបទទាំងឡាយ ដែលភិក្ខុទាំងឡាយនោះចាំបាច់ត្រូវរក្សា ព្រោះជាពុទ្ធប្បញ្ញត្តិសម្រាប់ភិក្ខុនេះ ឈ្មោះថា ភិក្ខុសីល, សិក្ខាបទដែលទ្រង់

បញ្ញត្តប្រារព្ធភិក្ខុនីទាំងឡាយ និងសិក្ខាបទដែលភិក្ខុនីទាំងឡាយនោះចាំបាច់ត្រូវរក្សា ព្រោះជាពុទ្ធប្បញ្ញត្តិសម្រាប់ភិក្ខុនី នេះឈ្មោះថាភិក្ខុនីសីល, សីល ១០ របស់សាមណេរ និងសាមណេរីទាំងឡាយឈ្មោះថា **អនុបសម្បន្នសីល** សិក្ខាបទ ៥ របស់ឧបាសកឧបាសិកាជានិច្ចសីល ឬពេលមានឧស្សាហ៍ សិក្ខាបទ ១០ ( ឬ ) សិក្ខាបទ ៨ ដែលជាអង្គឧបោសថ នេះឈ្មោះថា **គហដ្ឋសីល**, គប្បីជ្រាបសីល ៤ យ៉ាង ដែលជាភិក្ខុសីលជាដើម ដោយប្រការដូច្នេះ ។

## ចតុក្កៈទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុងចតុក្កៈទី ៣ ដូចតទៅ

ការមិនល្មើសសីល ៥ របស់មនុស្សឧត្តរកុរុទ្វីប ឈ្មោះថាបកតិសីល, **មារយាទ** និងចរិតរបស់ខ្លួនៗ ចំពោះត្រកូលនៃទេសៈ និងនៃបាសណ្ឌៈ ( លទ្ធិ ) ឈ្មោះថា **អាចារសីល**, សីលរបស់ព្រះមាតានៃព្រះបរមពោធិសត្វ ដែលមានព្រះពុទ្ធតម្រាស់ទុកយ៉ាងនេះថា ម្នាលអានន្ទ សេចក្តីនេះជាធម្មតា ក្នុងកាលព្រះពោធិសត្វចុះកាន់ផ្ទៃរបស់ព្រះមាតាហើយ ការពេញចិត្តទាក់ទងដោយកាម ក្នុងបុរសទាំងឡាយ រមែងមិនកើតឡើងចំពោះព្រះមាតារបស់ព្រះពោធិសត្វដូច្នេះ នេះឈ្មោះថា ធម្មតាសីល ចំណែកក្នុងជាតិនោះៗ របស់សត្វ

ដែលមានសន្តានបរិសុទ្ធទាំងឡាយ មានព្រះមហាកស្សបៈជាអាទិ៍ និងរបស់ព្រះពោធិសត្វ ឈ្មោះថា បុព្វហេតុសីល ( សីលមានហេតុដែលសម្រេចមកតាំងពីក្នុងជាតិមុនៗ ) ។

គប្បីជ្រាបសីល ៤ យ៉ាង គឺជាបកតិសីលជាដើម ដោយប្រការដូច្នេះ ។

# មហាដីកា

## កថាពោលអំពីប្រភេទរបស់សីល

វិធ-ស័ព្ទ ក្នុងបទថា **កតិវិធំ** នេះជាបរិយាយនៃកោដ្ឋាស (ចំណែក) ដូចជាក្នុងពាក្យជាដើមថា **ឯកវិធេន រូបសង្គហោ** (រូបសង្គ្រោះដោយចំណែកម្យ៉ាង) ឬមានអត្ថថា ប្រការ មានន័យថា មានប៉ុន្មានប្រការ អធិប្បាយថា ប្រភេទនៃសីលមានប៉ុន្មានប្រការ ? បទថា **សីលនលក្ខណេន** មានន័យថា ដោយសភាវៈ ពោល គឺការសង្រួម ។

សីល ឈ្មោះថា **ចរិត** ព្រោះអត្ថថា ជាហេតុប្រព្រឹត្ត គឺចូលដល់ភាពជាអ្នកធ្វើឲ្យបរិបូរក្នុងសីលទាំងឡាយ, ចរិតនោះឯង ជា **ចារិតសីល** ។

ឈ្មោះថា **វារិត** ព្រោះអត្ថថា ជាហេតុទប់ខ្លួន គឺរក្សាខ្លួនទុកពីខ្ទង់ដែលទ្រង់ហាម, សមាចារដ៏ក្រៃលែង ឈ្មោះថា **អភិសមាចារ**, **សីល** ប្រកបហើយក្នុងអភិសមាចារនោះ ឬអភិសមាចារនោះ ជាប្រយោជន៍ដល់សីលនេះ ហេតុនោះ សីលនេះ ទើបឈ្មោះថា អភិសមាចារិក ប្រែថា ប្រកបក្នុងអភិសមាចារ ឬមានអភិសមាចារជាប្រយោជន៍ ។

សីល ឈ្មោះថា **អាទិព្រហ្មចរិយ** ព្រោះអត្ថថា ជាខាងដើមនៃព្រហ្មចារ្យ, អាទិព្រហ្មចរិយ នោះឯងជា **អាទិព្រហ្មចរិយកំ** ។

សីលឈ្មោះថាវិរតិព្រោះអត្ថថាជាគ្រឿងវៀរ,មយ៉ាងវិញទៀតឈ្មោះថា វិរតិ ព្រោះអត្ថថា វៀរផ្ទាល់ ។

ន័យមយ៉ាងទៀត ការវៀរ ឈ្មោះថា **វិរតិ**, ឈ្មោះថា **អវិរតិ** ព្រោះអត្ថថា មិនវៀរ ។

ឈ្មោះថា **និស្សិតសីល** ព្រោះអត្ថថា អាស្រ័យហើយ, ឈ្មោះថា **អនិស្សិតសីល** ព្រោះអត្ថថា មិនអាស្រ័យហើយ ។

សីល ឈ្មោះថា បរិយន្ត ព្រោះអត្ថថា មានទីបំផុត, សីលមានទីបំផុត ដោយកាល ឈ្មោះថា កាលបរិយន្ត, មយ៉ាងទៀត សីលឈ្មោះថា **កាលបរិយន្តំ** ព្រោះអត្ថថា សីលនោះ មានកាលតាមដែលកំណត់ទុកក្នុងទីបំផុត ។ ឈ្មោះថា **អាបាណកោដិកំ** ព្រោះអត្ថថា មានដកបស្មើនឹងខ្យល់ដង្ហើម គឺការរស់នៅជាទីបំផុតជាកំណត់ ។

សីល ឈ្មោះថា លោកិយ ព្រោះអត្ថថា ប្រកបហើយក្នុងលោកដោយ បច្ច័យទាំងឡាយរបស់ខ្លួន ឬប្រាកដហើយក្នុងលោកនោះ ។

សីល ឈ្មោះថា **លោកុត្តរ** ព្រោះអត្ថថា ឆ្លងចាកលោក ។

ឈ្មោះថា **ហីន** ( ថោក ) ព្រោះអត្ថថា ថោកជាងមជ្ឈិមសីលនិងបណីតសីល ដោយបច្ច័យ និងដោយផល ឬប្រាសចាកគុណ

ទាំងឡាយនៃសីលទាំង នោះ ។

ឈ្មោះថា **បណីត** ព្រោះអត្ថថា នាំទៅកាន់ភាពជាប្រធាន ដោយបច្ច័យទាំងឡាយរបស់ខ្លួន ។សីលតាំងនៅជាកណ្តាលនៃសីល ទាំងពីរនោះឯង ឈ្មោះថា មជ្ឈិម ។

ការមានខ្លួនជាធំក្រៃលែង ឈ្មោះថា **អត្តាធិបតេយ្យ** ។ សូម្បី ក្នុងពួក ២ នៃបទដ៏សេស ក៏មានន័យដូចគ្នា ។

សីល ឈ្មោះថា **បរាមដ្ឋ** ព្រោះអត្ថថា ដែលតណ្ហា ឬទិដ្ឋិ ស្ទាបអង្អែលហើយ កម្ចាត់ហើយ ។ ដោយន័យផ្ទុយគ្នា ជាមួយ បរាមដ្ឋសីលនោះ សីល ឈ្មោះថា អបរាមដ្ឋសីល ។

សីល មានកិលេសស្ងប់ហើយ ឈ្មោះថា បដិបស្សទ្ធិ ។សីល ឈ្មោះថា សេក្ខ ព្រោះអត្ថថា កើតក្នុងសិក្ខា ឬជាសីលរបស់ព្រះ សេក្ខ ។ ដែលទាក់ទងក្នុងអសេក្ខធម៌ ព្រោះមានកិច្ចនៃសិក្ខាចប់ ហើយ ឈ្មោះថា អសេក្ខ ។ ឈ្មោះថា **នេវសេក្ខានាសេក្ខ** ។ ផ្ទុយគ្នា ពីសីលទាំងពីរនោះ ។

សីល ឈ្មោះថា ហានភាគិយ ព្រោះអត្ថថា សេពសេចក្តីវិនាស ឬមានចំណែកនៃសេចក្តីវិនាស ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យ ដូចគ្នា ។

សីល មានទីបំផុត ព្រោះមិនមានប្រមាណ និងមានសេចក្តី

បរិសុទ្ធិ ឈ្មោះថា **បរិយន្តប្បារិសុទ្ធិសីល** ។

សីល មិនមានទីបំផុត ព្រោះមិនមានប្រមាណ និងមានសេចក្តីបរិសុទ្ធិ ឈ្មោះថា **អបរិយន្តប្បារិសុទ្ធិសីល** ។

**សីល** ដែលបរិបូណ៌ដោយប្រការទាំងពួង និងមានសេចក្តីបរិសុទ្ធិ ឈ្មោះថា **បរិបុណ្ណប្បារិសុទ្ធិសីល** ។

ពាក្យថា តាមន័យដូចដែលបានពោលហើយ មានន័យថា តាមន័យដែលបានពោលហើយខាងដើមថា **សីលនដ្ឋេន សីលំ** ឈ្មោះថា សីល ដោយអត្ថថា សង្រួមរវាំងទុកដូច្នេះជាដើម ។ ពាក្យថា ការបំពេញសិក្ខាបទដែលទ្រង់បញ្ញត្តទុកថា វត្ថុនេះគួរធ្វើមានន័យថា ការបំពេញសីល គឺសិក្ខាបទ ដែលទ្រង់បញ្ញត្តទុកយ៉ាងនេះថា អភិសមាចារិកសីលនេះ គួរធ្វើ គួរបដិបត្តិ ដូច្នេះ ។ អ្នកបំពេញសីល គឺសិក្ខាបទ ឈ្មោះថា បំពេញ គឺរក្សានូវសិក្ខាបទ ។ មួយ៉ាងវិញទៀតសិក្ខានោះឯង ឈ្មោះថា សិក្ខាបទ ព្រោះត្រូវសិក្សា និងត្រូវបដិបត្តិ ។

គប្បីប្រកបពាក្យថា **តស្ស បូរណំ** ( បំពេញសិក្ខាបទនោះ ) ចូលផងដែរ ។

ពាក្យថា ការមិនធ្វើ ។ ដែលទ្រង់ហាមថា វត្ថុនេះមិនគួរធ្វើ មានន័យថា ការមិនធ្វើ គឺការវៀរ ។ ដែលព្រះមានព្រះភាគទ្រង់ហាមទុកថា នេះជាទុច្ចរិត មិនគួរធ្វើដូច្នេះ ។

ដោយបទថា **ចរន្តិ តស្មឹ** លោកអាចារ្យពោល និងអធិប្បាយសេចក្តីដែលសីលជាអធិករណៈថា បុគ្គលដែលមានសេចក្តីព្រមព្រៀងដោយសីលទាំងឡាយនោះ រមែងប្រព្រឹត្តនៅក្នុងសីលនោះ ទើបសម្តែងភាពនៃសីលជាឋានដែលប្រព្រឹត្តទៅរបស់បុគ្គលអ្នកមានការព្រមព្រៀងដោយសីលនោះ ដោយបទថា រមែងប្រព្រឹត្តនៅក្នុងសីលនោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា រមែងប្រព្រឹត្តទៅដោយភាពជាអ្នកធ្វើឲ្យបរិបូរក្នុងសីលទាំងឡាយ ។

ពាក្យថា ១.ដែលទ្រង់ហាម មានន័យថា ហាមទុកថា នេះមិនគួរធ្វើជាអកប្បិយៈ ។ពាក្យថា រមែងការពារ មានន័យថា រមែងការពារទុកដោយការមិនធ្វើនោះឯង ។ ពាក្យថា ដោយសីលនោះ លោកអាចារ្យពោលថា **វារិតសីល** ។

ឈ្មោះថា **វារិតសីល** ព្រោះអត្ថថា ជាទីហាម ឬជាគ្រឿងហាមរបស់ព្រះសាស្តា បានដល់ សិក្ខាបទ ។

ឈ្មោះថា **វារិតសីល** ព្រោះអត្ថថា ជាហេតុការពារទុករបស់អ្នកមិនញ៉ាំងសិក្ខាបទឲ្យកម្រើក ។

ពាក្យថា សម្រេចដោយសទ្ធា និងវីរិយៈ មានន័យថា គប្បីឲ្យសម្រេចដោយសទ្ធា និងដោយវីរិយៈ គឺសេចក្តីឧស្សាហ៍ព្យាយាម ។

បុគ្គលមិនមានសទ្ធា និងបុគ្គលខ្ជិលច្រអូសនឹងធ្វើវត្តបដិបត្តិ

ឲ្យបរិបូរមិនបានឡើយ, អ្នកមានសទ្ធាប៉ុណ្ណោះ មានប្រក្រតីឃើញភ័យក្នុងទោស សូម្បីមានប្រមាណតិចតួចដែលព្រះសាស្តាទ្រង់ហាមទុករមែងសមាទានសិក្សានូវសិក្ខាបទទាំងឡាយ ដូច្នេះ ទើបលោកពោលថា **វារិតសីល** សម្រេចដោយសទ្ធាដូច្នេះ ។

ការប្រព្រឹត្តិដោយសេចក្តីកោតក្រែងដ៏វិសេសក្រៃលែង ព្រោះទាក់ទងក្នុងអធិសីលសិក្ខា ឈ្មោះថា **អភិសមាចារ** ដូច្នេះ ទើបលោកពោលថា **ឧត្តមសមាចារោ** ប្រែថា ការប្រព្រឹត្តិកោតក្រែងដោយល្អយ៉ាងខ្ពង់ខ្ពស់ អធិប្បាយថា អភិសមាចារោនោះឯងជា **អភិសមាចារិកំ** ដូចជា **វេនយិកោ** ( ដើមជា **វេនយ** អ្នករៀនព្រះវិន័យជា **វេនយិកោ** ) ។

**អភិសមាចារ** ដោយនិទ្ទេសយ៉ាងឧក្រិដ្ឋ បានដល់ សីលក្នុងមគ្គនិងក្នុងផល, សីលដែលទ្រង់បញ្ញត្តប្រារព្ធចំពោះអភិសមាចារនោះ មានអភិសមាចារនោះជាផល មានអភិសមាចារនោះជាប្រយោជន៍ ឈ្មោះថា **អភិសមាចារិកសីល** ។ សីលនេះ គឺកាយកម្ម ៣ ដែលបរិសុទ្ធល្អ វចីកម្ម ៤ ដែលបរិសុទ្ធល្អ, អាជីវៈដែលបរិសុទ្ធល្អ ឈ្មោះថា **អាជីវដ្ឋមកសីល** ( សីលមានអាជីវៈជាគម្រប់ ៨ ) ។ ក្នុងអាជីវដ្ឋមកសីលនោះ ការវៀរចាកទុច្ចរិត ៧ ប្រការ ដែលមានអាជីពជាហេតុ ឈ្មោះថា សម្មាអាជីវៈ ព្រោះដូច្នោះ សូម្បីសម្មាអាជីវៈនោះក៏មាន ៧ ដោយពិត, សូម្បីយ៉ាងនោះ ព្រះមានព្រះភាគក៏ត្រាស់

ធ្វើអាជីវៈនោះឲ្យតែម្យ៉ាង ដោយភាពជាសម្មាអាជីវៈដូចគ្នា ។

ម្យ៉ាងវិញទៀត ទ្រង់ត្រាស់រួមការវៀរចាកមិច្ឆាជីព ដែលមិច្ឆាជីពមានកុហនៈវត្ថុ ៣ ប្រការ ជាទីអាស្រ័យជាមួយគ្នាថា អាជីវៈបរិសុទ្ធល្អ ដូច្នេះ ។ មគ្គនោះឯងឈ្មោះថា **ព្រហ្មចារ្យ** ព្រោះជាការប្រព្រឹត្តិដ៏ប្រសើរ ដូច្នោះទើបឈ្មោះថា **មគ្គព្រហ្មចរិយៈ** នៃមគ្គព្រហ្មចារ្យនោះ ។

បទថា **អាទិភាវភូតំ** មានន័យថា ដល់ហើយ គឺសម្រេចហើយនូវភាពជាធម៌គួរបម្រើន គឺគប្បីឲ្យសម្រេចក្នុងខាងដើម ឈ្មោះថា អាទិភាវភូតំ ។ សូម្បីសម្មាទិដ្ឋិក៏ជាខាងដើម តាមលំដាប់នៃទេសនាក៏ពិត សូម្បីយ៉ាងនោះ **អាជីវដ្ឋមកសីល** ក៏ជាខាងដើមតាមលំដាប់នៃការបដិបត្តិ ដូច្នេះឯង ។

បទថា **តស្ស សម្បត្តិយា** មានន័យថា អាទិព្រហ្មចរិយកសីលនឹងដល់ព្រម ក៏ព្រោះអភិសមាចារិកសីលដល់ព្រម គឺបរិបូណ៌ ។

អ្នកណាវៀរសិក្ខាបទ ដែលស្រាលមានទោសតិចតួចបាន អ្នកនោះនឹងវៀរសិក្ខាបទដែលមានទោសធ្ងន់មានទោសច្រើន មានកំហុសច្រើនបាន ព្រោះដូច្នោះ ទើបមិនមានពាក្យដែលត្រូវនិយាយតែម្យ៉ាងដូច្នេះ ។

ព្រះសូត្ររមែងធ្វើសេចក្តីនេះឲ្យជាក់ច្បាស់ដោយន័យផ្ទុយគ្នា ។

ក្នុងបណ្តាពាក្យទាំងឡាយនោះ ពាក្យថា ធម៌ បានដល់ សីល ។

សីលនោះលោកហៅថា ធម៌ ព្រោះអត្ថថា ទ្រទ្រង់ទុកនូវគុណវិសេសក្រៃលែងឡើងទៅ... ។

ដើម្បីនឹងសម្តែងថា វិរតិសីលមិនលាយគ្នាជាមួយនឹងសីលក្រៅពីនេះទាំងពេលមានការសម្បយោគជាដើម (សម្បយោគ គឺការប្រកបរួមគ្នា) ទើបលោកពោលថា គុណត្រឹមតែការវៀរ ដូច្នេះ ។

ក្នុងពាក្យថា ដោយអំណាចនិស្សិតសីល និងអនិស្សិតសីលនេះ លោកអាចារ្យបំណងនឹងសម្តែង **និស្ស័យ** ( ទីអាស្រ័យ ) ជាមុនទើបពោលពាក្យថា និស្ស័យជាដើម ។ ក្នុងពាក្យនេះ តណ្ហាតែម្យ៉ាងឈ្មោះថា **តណ្ហានិស្ស័យ** ព្រោះបុគ្គលដែលមានតណ្ហាចរិត គប្បីអាស្រ័យ ។ ទិដ្ឋិនិស្ស័យក៏ដូចគ្នា ។ ពិតហើយ បុគ្គលដែលមានទិដ្ឋិចរិត សូម្បីពេលទិដ្ឋិមិនមាន ព្រោះវៀរចាកតណ្ហា ក៏ជាអ្នកអាស្រ័យទិដ្ឋិ តែម្យ៉ាង កើតខាងក្នុង ។

លោកអាចារ្យពោលដល់ទេវតាដែលប្រាកដ មានមហារាជទាំង ៤ មានសក្ក មហារាជ និងសុយាមជាដើម ថា ទេវតា ។

ពោលដល់ទេវតាមិនប្រាកដថា ទេវតាអង្គណាមួយ ។ សីលអាស្រ័យតណ្ហាម្យ៉ាង ហេតុនោះឈ្មោះថា **តណ្ហានិស្សិតសីល** ។

អាចារ្យពួកខ្លះពោលថា សីលដែលតណ្ហាអាស្រ័យហើយ

ដូច្នេះ ។

ពាក្យរបស់អាចារ្យពួកខ្លះនោះរមែងខុស ដោយពាក្យថា និស្ស័យ ( ទីអាស្រ័យ ) មាន ២ យ៉ាង ដូច្នេះជាដើម ។ ពាក្យថា ដោយសុទ្ធទិដ្ឋិ មានន័យថា ដោយទិដ្ឋិដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា បរិសុទ្ធចាកសង្ស័យ នឹងមានដោយប្រការដូច្នេះ អធិប្បាយថា លោ-កុត្តរសីល ។

បទថា **តស្សេវ** មានន័យថា សីលជាអង្គគឺជាហេតុនៃលោកុត្តរនោះឯង សំដៅន័យថា ជាឧបនិស្ស័យនៃវិវដ្ដៈ ។

ពាក្យថា ធ្វើការកំណត់កាល មានន័យថា ធ្វើការកំណត់ដោយអំណាចកាល ដូចពាក្យថា អស់ ១ យប់ និង ១ ថ្ងៃជាដើម ។ ដើម្បីសម្ដែងថា សីលដែលបុគ្គល សូម្បីមិនធ្វើការកំណត់កាលសមាទានហើយជាប់ក្នុងវាង សូម្បីសីលដែលបុគ្គលប្រព្រឹត្តហើយអស់មួយជីវិត ដោយអំណាចសម្បត្តិវិរតិមិនមែន ជាសីលមានអាបាណ-កោដិកសីល ( អស់មួយជីវិត ) ដូច្នេះ ទើបពោលថា សីលដែលបុគ្គលសមាទានហើយអស់មួយជីវិត ហើយប្រព្រឹត្តទៅអស់មួយជីវិត ដូចគ្នា ។

ពាក្យថា ដោយអំណាចលាភ យស ញាតិ អវយវៈ និងជីវិត មានន័យថា ដោយអំណាចធ្វើលាភ និងយសដែលមិនទាន់កើត

ឡើង ឲ្យកើតឡើង ដោយអំណាចការរក្សា និងដោយអំណាចការធ្វើឲ្យចម្រើននូវលាភ និងយសដែលកើតឡើងហើយ ដោយអំណាចការធ្វើញាតិ អវយវៈ និងជីវិតមិនឲ្យវិនាសទៅ ។ ពាក្យថា អ្នកនោះនឹងកន្លងបានដូចម្ដេច មានន័យថា ១.ដែលថាអ្នកណាមិនធ្វើ សូម្បីចិត្តឲ្យកើតឡើងដើម្បីសេចក្ដីល្មើស, អ្នកនោះនឹងល្មើសតាមផ្លូវកាយវាចា នេះនឹងមានបានដូចម្ដេច, អធិប្បាយថា ១.នេះមិនមាន ។ ឯ កឹ សព្ទ នេះចុះ ក្នុងអត្ថបដិសេធ ។

សីលណាបង្ករអាសវៈមានកាមាសវៈជាដើម ចេញមកដោយភាពជាអារម្មណ៍ដូចដំបៅបង្ករខ្ទុះ ចេញមកដូច្នោះ ហេតុនោះ សីលនោះ ឈ្មោះថា **សាសវ** ព្រោះអត្ថថា ប្រព្រឹត្តទៅជាមួយអាសវៈទាំងឡាយ សូម្បីពេលមាន និងមិនមានការប្រកបគ្នាក៏ដោយ ។ លោកអាចារ្យពោលថា សីលមានអាសវៈ ឈ្មោះថា លោកិយសីលដូច្នេះ ព្រោះជាធម្មជាតិប្រព្រឹត្តទៅក្នុងភូមិ ៣ ហេតុនោះ ទើបសីលនោះទាក់ទងក្នុងភូមិ ៣ នោះ ។ ភពវិសេសទាំងឡាយ បានដល់សម្បត្តិភព ។

ពាក្យថា **វិនយ** បានដល់ **វិនយបរិយត្តិ** ឬសិក្ខាបទដែលមានក្នុងវិនយបរិយត្តិនោះ ។ សេចក្ដីបាមោជ្ជ បានដល់ បីតិបន្តិចបន្តួច ។ យថាភូតញ្ញាណទស្សន បានដល់ ការឃើញនាមរូប ព្រមទាំងបច្ច័យ,

ឬវិបស្សនាទន់ខ្សោយដែលមានការឃើញនាមរូប ព្រមទាំងបច្ច័យ នោះជាទីតាំង ។

បទថា **និព្វិទា** បានដល់ **និព្វិទាញាណ** ។ ដោយពាក្យនោះ លោកអាចារ្យពោលដល់វិបស្សនាដែលមានកម្លាំង ។

វិរាគ បានដល់មគ្គ ។ វិមុត្តិ បានដល់អរហត្តផល ។ **វិមុត្តិញ្ញាណ-ទស្សន** បានដល់ **បច្ចវេក្ខណញ្ញាណ** ។ ពាក្យថា **កថា** បានដល់ កថាពោលដោយវិន័យ ។

ពាក្យថា ការប្រឹក្សា បានដល់ ការពិចារណាព្រះវិន័យ ។ ពាក្យថា ការអាស្រ័យគ្នាយ៉ាងក្រៃលែង (ការចូលទៅអង្គុយជិត) បានដល់ ឧបនិស្សយប្បច្ច័យ ពោល គឺការតគ្នានៃហេតុតាមដែលពោលមក ។ លោកុត្តរសីល បានដល់ សីលដែលមានអាជីវៈជាទី ៨ ដែលប្រកបដោយមគ្គចិត្ត និងផលចិត្ត ។ ក្នុងលោកុត្តរសីលនោះ សីលក្នុងមគ្គជាគ្រឿងនាំចេញចាកភព និងជាភូមិរបស់បច្ចវេក្ខណញ្ញាណ ចំណែកសីលក្នុងផលជាភូមិរបស់បច្ចវេក្ខណញ្ញាណតែម្យ៉ាង ។

គប្បីឃើញថា ការដែលអធិបតីមានឆន្ទៈជាដើមជាធម៌ថោកទាប ក៏ដោយអំណាចអធិមុត្តិថោកទាប ។ ជាធម៌ប្រណីតក៏ដោយអំណាចអធិមុត្តិប្រណីត ។ ជាធម៌កណ្តាលៗ ក៏ដោយអំណាចនៅកណ្តាលធម៌ថោកទាប និងធម៌ប្រណីតទាំង ២ នោះ ។ ដូចជាកម្ម លោកបែង

ចែកដោយប្រភេទ មានកម្មថោកទាបជាដើម ដោយអំណាចការប្រមូលមកយ៉ាងណា, សូម្បីអធិបតីមានឆន្ទៈជាដើម ក៏ដូច្នោះ លោកបែងចែកតាមអំណាចការប្រព្រឹត្ត និងអាការដែលកើតឡើងរបស់អធិបតី មានឆន្ទៈជាដើមនោះ ក៏មានដោយប្រភេទនៃអធិមុត្តិ ។

ពាក្យថា ដោយសេចក្តីប្រាថ្នាយស មានន័យថា ដោយការរីករាយយ៉ាងក្រៃលែងក្នុងកិត្តិយស និងការសរសើរ ឬដោយការប្រាថ្នាបរិវារ ។

ឈ្មោះថា អាស្រ័យអរិយៈ ព្រោះស្អប់ខ្ពើមអំពើអាក្រក់ដោយគិតថា មនុស្សដូចយើង គប្បីធ្វើកម្មដូច្នេះបានយ៉ាងណា ។

ពាក្យថា ដែលមិនសៅហ្មង ដោយការលើកតម្កើងខ្លួនបន្អាប់គេ និងដែលមិនសៅហ្មងដោយឧបក្កិលេសទាំងឡាយដទៃ ។

ពាក្យថា ដើម្បីត្រូវការភព និងភោគៈ មានន័យថា ដើម្បីត្រូវការសម្បត្តិក្នុងភព និងដើម្បីត្រូវការសម្បត្តិ គឺភោគៈ ។

ពាក្យថា សីលដែលប្រព្រឹត្តទៅដើម្បីត្រូវការការរួចផុតចំពោះខ្លួន លោកពោលដល់សីលរបស់ព្រះសាវកពោធិសត្វ និងព្រះបច្ចេកពោធិសត្វ ។ ពាក្យថា ដើម្បីត្រូវការការរួចផុតចំពោះសព្វសត្វ មានន័យថា ដើម្បីរំដោះសព្វសត្វទាំងឡាយពីគ្រឿងចង គឺសង្សារវដ្ត ។ សីលដែលជាថ្នាក់បារមី បានដល់ សីលរបស់ព្រះមហាពោធិសត្វ ។

សភាពជាសីលបារមី មានការកំណត់ដោយសេចក្ដីករុណា និង ឧបាយកោសល្យប្រារព្ធមហាពោធិញ្ញាណប្រព្រឹត្តទៅ មានភាពស្អាត និងដុសខាត់រហូតដល់ថ្នាក់ឧក្រិដ្ឋយ៉ាងក្រៃលែង វៀរចាកការកំណត់ទេស: កាល និងសត្វជាដើម ។

បទថា **អននុរូបំ** ប្រែថា មិនសមគួរ ។ មនុស្សនោះឯងជាទីគោរព និងជាអធិបតីរបស់ខ្លួននោះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **អត្តគរុ** ប្រែថា មានខ្លួនជាទីគោរព គឺអ្នកដែលក្រៃលែងដោយការខ្មាស សីលរបស់បុគ្គលនោះ អ្នកមានខ្លួនជាអធិបតី ឈ្មោះថា អត្តាធិបតេយ្យសីល, លោកជាអធិបតី គឺជាទីគោរពរបស់បុគ្គលនោះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **លោកាធិបតី** ប្រែថា មានលោកជាអធិបតី គឺអ្នកដែលក្រៃលែងដោយឱត្តប្ប: ។ ធម្មតាថា ធម៌នេះមានអានុភាពច្រើន ជានិយ្យានិកធម៌តែម្យ៉ាង និងធម៌នេះបុគ្គលគប្បីបូជាដោយការបដិបត្តិនោះឯង ។ ព្រោះហេតុនោះ បុគ្គលដែលប្រាថ្នាបូជាភាពជាធំចំពោះធម៌ ក៏ដោយការគិតយ៉ាងនេះថា យើងនឹងបូជាធម៌នោះដោយការដល់ព្រមនៃសីល ។

បទថា **បរាមដ្ឋា** មានន័យថា ដែលតណ្ហា និងទិដ្ឋិស្ទាបអង្អែលហើយ ដោយការធ្វើឲ្យវិនាស ។ ពិតហើយ តណ្ហា និងទិដ្ឋិទាំងឡាយស្ទាបអង្អែលនូវសីលរបស់បុគ្គល ដែលប្រព្រឹត្តទៅហើយដោយគិត

ថា ដោយសីលនេះយើងនឹងជាទេព ឬជាទេវតាអង្គណាមួយ, សេចក្តីបរិសុទ្ធិចាកសង្ស័យ នឹងមានដោយសីលរបស់យើងនេះ ធ្វើបុគ្គលនោះឲ្យដល់នូវភាពអន់ថយ ព្រោះការធ្វើមិនឲ្យជាឧបនិស្សយប្បច្ច័យដល់មគ្គ ។

ពាក្យថា របស់កល្យាណបុថុជ្ជន មានន័យថា នៃបុគ្គលដែលជាបុគ្គលល្អ ក្នុងបុថុជ្ជនទាំងឡាយ ។ បុគ្គលដែលជាបុគ្គលល្អនោះ សូម្បីជាបុថុជ្ជនក៏ប្រកបដោយសីលជាដើម ដែលមានសេចក្តីល្អ ។ ឈ្មោះថា **អបរាមដ្ឋសីល** ព្រោះអត្ថថា ដែលកិលេសជាគ្រឿងស្ទាបអង្អែលទាំងឡាយនោះ មិនស្ទាបអង្អែល ព្រោះគ្របសង្កត់ និងព្រោះកាត់ផ្តាច់នូវកិលេសជាគ្រឿងស្ទាបអង្អែលទាំងឡាយបាន ។

ឈ្មោះថា **បដិបស្សទ្ធិសីល** ព្រោះរម្ងាប់ គឺស្ងប់ការរសាប់រសល់ គឺកិលេសនោះៗ ។

ពាក្យថា ដែលសម្តែងចេញ មានន័យថា សម្តែងវត្ថុដែលធ្វើហើយតាមធម៌ ដោយវុដ្ឋានវិធី និងទេសនាវិធី ។

ដោយអាការដូចបានពោលមកនេះ សីលនោះ ទើបតាំងនៅដូចប្រក្រតីវិញ ។ ព្រោះដូច្នោះ ទើបលោកពោលថា សីលនោះឈ្មោះថា វិសុទ្ធិសីល ។

ម្យ៉ាងវិញទៀត ដោយពាក្យថា ដែលសម្តែងហើយ នេះគប្បី

ឃើញថា លោករូបបួរមសូម្បីការតាំងចិត្តថា **ន បុនេវំ ករិស្សំ** យើងនឹងមិនធ្វើយ៉ាងនេះទៀតដូច្នេះផងដែរ ។ អ្នកមានសេចក្តីសង្ស័យ គឺសេចក្តីសង្ស័យក្នុងវត្ថុ ក្នុងន័យជាដើមថា សាច់ខ្លាឃ្មុំ ឬសាច់ជ្រូកដូច្នេះក្តី, ក្នុងអាបត្តិ ដោយន័យជាដើមថា ជាបាចិត្តិយ ឬហ្ន៎ !, ជាទុក្កដ ឬហ្ន៎ ! ដូច្នេះក្តី ឬក្នុងអជ្ឈាចារ ដោយន័យជាដើមថា យើងប្រព្រឹត្តកន្លងវត្ថុនោះឬទេហ្ន៎ ! ដូច្នេះក្តី ក៏គប្បីជម្រះចេញដោយការសម្តែងតាមធម៌ ។

**វិមតិ** ( សេចក្តីសង្ស័យ ) នោះឯងជា **វេមតិក** ពេលសេចក្តីសង្ស័យនោះ មានហើយ មានន័យថា ពេលកើតសេចក្តីសង្ស័យឡើង ។

ពាក្យថា គប្បីបន្ទោបង់សេចក្តីសង្ស័យ មានន័យថា គួរពិចារណាវត្ថុនោះឯង ឬសួរព្រះវិនយធរ ហើយបន្ទោបង់សេចក្តីសង្ស័យចេញ ភិក្ខុដែលមិនមានសេចក្តីសង្ស័យ ប្រសិនបើជាកប្បិយៈ ក៏គប្បីធ្វើ, បើជាអកប្បិយៈ ក៏គប្បីវៀរចាក ។

ព្រោះដូច្នោះ ទើបលោកពោលថា យ៉ាងនេះ សេចក្តីសុខនឹងមានដល់អ្នក ។

ពាក្យមានជាអាទិ៍ថា ដោយអរិយមគ្គ ៤ លោកពោលនូវសីលដែលទាក់ទងក្នុងមគ្គផលថា សម្បយុត្តដោយមគ្គផល ។ វោហារ

ដែលប្រព្រឹត្តទៅក្នុងសេចក្ដីរួមទាំងឡាយ ក៏ប្រព្រឹត្តទៅក្នុងចំណែកផ្សេងៗ ផងដែរ ។

ពាក្យថា សីលដ៏សេស បានដល់ លោកិយសីលទាំងអស់ ។

ពាក្យថា សូម្បីប្រក្រតី បានដល់ សូម្បីសភាវៈ ។ មានប្រក្រតីជាសុខ មានការនៅរួមជាសុខ ។ ពាក្យថា ដោយបរិយាយនោះ គឺដោយអត្ថដែលប្រាប់ដល់សេចក្ដីថា ប្រក្រតី ។អព្យាកតសីលប្រភេទ ខ្វះ នៅរួមជាមួយគ្នានឹងសីល ដែលបំណងយកក្នុងទីនេះបាន ដូច្នេះ ដើម្បីសម្ដែងថា អកុសលសីលប៉ុណ្ណោះ លោកមិនប្រកបទុក ក៏ពោលពាក្យមានជាអាទិ៍ថា ក្នុងសីល ៣ យ៉ាងនោះ អកុសលសីលអធិប្បាយថា ពិតយ៉ាងនោះ **សេក្ខតិក** លោកកាន់យកក្នុងទីនេះ, តែក្នុងទីនេះមិននាំយកកុសលត្តិកៈចូលទុកទេ ។ ពាក្យថា ក្នុងន័យដូចដែលបានពោលទុកហើយនោះ មានន័យថា ក្នុងន័យដូចដែលបានពោលទុកហើយនោះឯង គប្បីជ្រាបថា សីលនោះមាន ៣ប្រភេទ ដោយអំណាចតិកៈ ៥ មានហីនតិកៈជាដើម មិនរួមយកកុសលត្តិកៈទេ ។

ពាក្យថា **យោធ** កាត់បទជា **យោ+ឥធ** ។ ពាក្យថា ក្នុងការល្មើសវត្ថុ មានន័យថា ក្នុងការល្មើស គឺប្រព្រឹត្តកន្លងវត្ថុនៃអាបត្តិ ។ មហាវិតក្កៈ ៩ មានកាមសង្កប្បវិតក្កៈជាដើម ឈ្មោះថា មិច្ឆាសង្កប្បៈ ។

ពាក្យថា បែបនេះ ប្រែថា អ្នកដូច្នេះ ។ ពេលភិក្ខុនោះមិនចូល

ទៅរកភិក្ខុអ្នកមានសីល សេពគប់តែភិក្ខុទ្រុស្តសីល បន្ទាប់ពីនោះឯង ក៏នឹងមិនឃើញទោសនៃការល្មើសបញ្ញត្តិ ព្រោះកាន់យកគម្រូរបស់ភិក្ខុដែលទ្រុស្តសីលទាំងឡាយនោះ មិនរក្សាឥន្ទ្រិយ៍ដែលមានចិត្តជាទី ៦ ព្រោះច្រើនទៅដោយមិច្ឆាសង្កប្បៈ, សីលនឹងជាហានភាគិយសីល តែម្យ៉ាងប៉ុណ្ណោះ មិនជាឋិតិភាគិយសីល, មានភាពជាវិសេសភាគិយសីលជាដើមមកពីទីណា ។

បទថា ដោយសីលសម្បត្តិ បានដល់ ដោយការបរិបូរណ៍នៃសីល គឺដោយចតុប្បារិសុទ្ធិសីល ។ ពាក្យថា មិនព្យាយាមជាប់តគ្នាឲ្យក្រៃលែងឡើងទៅ មានន័យថា មិនព្យាយាមដើម្បីសម្រេចគុណវិសេស ឲ្យក្រៃលែងឡើងទៅ ។ សីលនោះចាត់ជា ឋិតិភាគិយសីល ព្រោះមិនប្រព្រឹត្តទៅព្រមដើម្បីសមាធិ ដែលនឹងសម្រេចបានថា សីលប្រព្រឹត្តទៅព្រមដើម្បីសមាធិ គឺក្នុងពេលសមាធិសម្រេចហើយ ។

ពាក្យថា ដើម្បីប្រយោជន៍ដល់សមាធិ មានន័យថា ដើម្បីជាប្រយោជន៍ដល់ការតាំងចិត្តមាំដោយអំណាចសមថៈ ។ពាក្យថា ចំពោះ **និព្វិទំ** គឺចំពោះវិបស្សនា ។ស័ព្ទថា **និព្វិទា** ក៏ដើម្បីសម្តែងដល់វិបស្សនាមានកម្លាំង ព្រោះសីល នឹងសម្រេចភាពជានិព្វេធភាគិយសីលបានសូម្បីដោយហេតុត្រឹមតែប៉ុណ្ណោះ ។

ភ្ជាប់សេចក្តីថា **យានិ ច សិក្ខាបទានិ នេសំ រក្ខិតព្វានិ** ( សិក្ខា

បទទាំងឡាយណាដែលភិក្ខុទាំងឡាយនោះគប្បីរក្សា) សិក្ខាបទទាំងឡាយនោះ បានដល់ សិក្ខាបទខ្លះៗដទៃខ្ទះក្រៅពីអសាធារណប្បញ្ញត្តិ ។

ពាក្យថា **នេសំ** គឺភិក្ខុទាំងឡាយនោះជាឆដ្ឋីវិភត្តិ ចុះក្នុងកត្តុ ព្រោះសំដៅដល់បទថា **រក្ខិតព្វានិ** ( ត្រូវរក្សា ) ប្រែថា ដែលភិក្ខុទាំងឡាយនោះគប្បីរក្សា ។

ពាក្យថា ឬពេលមានឧស្សាហ៍ គឺពេលមានឧស្សាហ៍ ដើម្បីខ្វល់ខ្វាយរក្សាសីលទាំងឡាយ ។ ពាក្យថា ១០ លោកពោលដល់សីល ដែលសាមណេរទាំងឡាយ គប្បីរក្សាដូចសីលរបស់យដិកាព្រាហ្មណ៍ជាដើម ។ ពាក្យថា ៨ គឺសីល ៨ ខ្លះៗដែលវៀរចាកខ្លះៗខាងក្រោយរបស់សីលទាំងអស់ ដោយរួមខ្លះៗវៀរចាកការរាំរែកជាដើម ជាមួយនឹងខ្លះៗវៀរចាកការសៀតផ្កាឈើជាដើម ចូលក្នុងសេចក្ដីតែមួយដូចគ្នា ។

ពាក្យថា ការមិនល្មើស គឺការមិនល្មើសសីលទាំង ៥ ។ ពាក្យថា បកតិសីល គឺសីលតាមសភាវៈ ។ ពួកជនអ្នកឧត្តរកុរុទ្វីបមានសីលដែលកំណត់ដោយការកើតក្នុងទីនោះ ។ ពាក្យថា ចរិតដែលជាមារយាទ មានន័យថា ចរិតដែលបុព្វបុរសក្នុងត្រកូលជាដើមនោះៗតាំងទុក, ដែលជាព្រំដែនខាងក្នុង មិនធ្វើវត្តដែលមានទោសនោះៗ ។

ក៏ធម៌ប្រចាំត្រកូល ឬធម៌ប្រចាំតំបន់ និងលទ្ធិបាសណ្ឌៈ លោក

សំដៅយកថា អាចារសីល ក្នុង ១.នោះ ការដែលពួកព្រាហ្មណ៍ជាដើម មិនផឹកទឹកស្រវឹងជាដើម ឈ្មោះថា ធម៌ប្រចាំត្រកូល ការដែលអ្នកជនបទក្នុងខ្លះ មិនបៀតបៀនគ្នាជាដើម ឈ្មោះថា ធម៌ប្រចាំតំបន់, ធម៌ គឺលទ្ធិបាសណ្ឌៈ បានដល់ ១.បដិបត្តិ មានយម និងនិយមជាដើមរបស់ពួកតិរ្ថិយ ។ ពិតហើយ លទ្ធិរបស់ពួកតិរ្ថិយ រមែងទៅ គឺប្រព្រឹត្តទៅដោយអន្ទាក់ គឺទិដ្ឋិ និងអន្ទាក់ គឺតណ្ហា ហេតុនោះ ទើបលោកពោលថា **បាសណ្ឌៈ** ប្រែថា ទៅដោយអន្ទាក់, ម្យ៉ាងវិញទៀត លោកពោលថា **បាសណ្ឌ** ព្រោះអត្ថថា បោះទៅនូវអន្ទាក់ គឺការបៀតបៀនវិន័យរបស់ព្រះអរិយៈ ។

សីល គឺសិក្ខាបទ ៥ របស់ព្រះមាតាព្រះបរមពោធិសត្វ ចាត់ជាសីលដែលបរិបូណ៌ ព្រោះព្រះបាលីថា តាមប្រក្រតីព្រះមាតារបស់ព្រះពោធិសត្វ ជាអ្នកមានសីល សីលរបស់ព្រះមាតានៃព្រះពោធិសត្វនោះ ជាលំដាប់ខ្ពង់ខ្ពស់មិនសៅហ្មង សូម្បីត្រឹមតែកើតការគិតឡើងចំពោះព្រះបិតារបស់ព្រះបរមពោធិសត្វ ទើបលោកពោលថា ធម្មតាសីល ។

ពាក្យថា ទាក់ទងដោយកាមគុណ មានន័យថា ចូលទៅប្រកបព្រមហើយ នូវសេចក្ដីរីករាយ គឺប្រាថ្នាហើយដោយសេចក្ដីរីករាយក្នុងកាម និងក្នុងចំណែកនៃកាមទាំងឡាយ ។ ពាក្យថា ធម្មតាសីល គឺ

សីលដែលមានហើយតាមធម្មតា គឺតាមនិយាមនៃហេតុ ។ ពិតហើយ សីលនៃមាតារបស់ព្រះពោធិសត្វជាធម្មជាតិ ដល់នូវការដុសខាត់យ៉ាងប្រសើរ តាមសភាវៈតែម្យ៉ាង ដោយតេជៈនៃសីល ដោយអានុភាពនៃគុណរបស់ព្រះមហាពោធិសត្វ ដែលបំពេញសីលបារមីឲ្យដល់ថ្នាក់ខ្ពង់ខ្ពស់បំផុតនៅក្នុងព្រះគភ៌ ។ ដោយ អាទិ-ស័ព្ទថា **មហាកស្សបាទីនំ** លោកអាចារ្យ រមែងរួបរួមយកបុគ្គលទាំងឡាយមាននាងភទ្ទាជាដើមទុកផងដែរ ។

បានឮថា នាងទាំងឡាយនោះឯង ជាអ្នកមានសីលបរិសុទ្ធល្អតែម្យ៉ាង អស់កាលយូរមកហើយ ព្រោះដូច្នេះ ទើបលោកពោលថា របស់សត្វដែលបរិសុទ្ធទាំងឡាយ ។

ពាក្យថា ក្នុងជាតិនោះៗ មានន័យថា ក្នុងជាតិ មានជាតិដែលជាព្រះសីលវាជា និងមហិង្សរាជាជាដើម ។ ឈ្មោះថា បុព្វហេតុកសីល ព្រោះអត្ថថា មានហេតុឲ្យសម្រេចមកពីមុន គឺក្នុងជាតិមុន ។

ក៏សីលមានបកតិសីលជាដើមនេះ វៀរចាកការសមាទាន ក៏មានលក្ខណៈមិនល្មើស គប្បីឃើញថា លោកសង្គ្រោះចូលក្នុងសម្បត្តវិរតិ ។

សម្ពន្ធសេចក្ដីថា ***យំ ភគវតា ឯវំ វុត្តំ សីលំ*** ( សីលណាដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះ ) ។ បទថា ឥធ ជាពាក្យសម្ដែង

ដល់សាសនាដែលជាទីអាស្រ័យរបស់បុគ្គលអ្នកបំពេញសីល ដែលកំពុងពោលដល់ និងបដិសេធនូវសេចក្ដីជាយ៉ាងនោះនៃសាសនាដទៃ ។

សមដូចដែលទ្រង់ត្រាស់ទុកថា **ឥធេវ ភិក្ខវេ សមណោ ។បេ។ សុញ្ញា បរប្បវាទា សមណេហិ អញ្ញេហិ** ។ ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ មានតែក្នុងព្រះសាសនានេះប៉ុណ្ណោះ សមណៈទី ២ និងសមណៈទី ៣ សមណៈទី ៤ មានតែក្នុងព្រះសាសនានេះប៉ុណ្ណោះ លទ្ធិសាសនាដទៃ សូន្យទទេចាកសមណៈ អ្នកដឹងទូទៅ ។

( ចប់មហាដីកា )

..........................

# ចតុក្កៈទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុងចតុក្កៈទី ៤ ដូចតទៅ

## បាតិមោក្ខសំវរសីល

សីលណាដែលព្រះមានព្រះភាគត្រាស់ទុកថា ភិក្ខុក្នុងសាសនានេះ ជាអ្នកសង្រួមដោយបាតិមោក្ខសំវរជានិច្ច ដល់ព្រមដោយអាចារៈនិងគោចរ មានប្រក្រតីឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទានសិក្សានៅក្នុងសិក្ខាបទទាំងឡាយ ដូច្នេះ សីលនោះ ឈ្មោះថា បាតិមោក្ខសំវរសីល ។

# មហាដីកា

## បាតិមោក្ខសំវរសីល

ពាក្យថា ភិក្ខុជាពាក្យសម្ដែងដល់បុគ្គលអ្នកបំពេញសីលនោះ ។

ពាក្យថា អ្នកសង្រួមដោយបាតិមោក្ខសំវរ នេះជាពាក្យសម្ដែងថា ភិក្ខុនោះតាំងនៅក្នុងបាតិមោក្ខសំវរសីល ។ ពាក្យថា ជានិច្ច នេះជាពាក្យសម្ដែងថា ភិក្ខុនោះមានការព្រមព្រៀងដោយការនៅសមគួរដល់សីលនោះ ។ បទថា ដល់ព្រមដោយអាចារ និងគោចរ នេះជាពាក្យសម្ដែងដល់ធម៌ដែលជាឧបការចំពោះបាតិមោក្ខសំវរសីលនិងគុណដែលគប្បីសម្រេចខ្ពស់ៗឡើងទៅ។ពាក្យថាមានប្រក្រតីឃើញភ័យក្នុងទោសសូម្បីតិចតួច នេះជាពាក្យសម្ដែងថា មិនឃ្លាតចាកបាតិមោក្ខសំវរសីល ។ ពាក្យថា សមាទាន ជាពាក្យសម្ដែងដល់ការកាន់យកសិក្ខាបទទាំងឡាយដោយមិនមានចំណែកសល់ ។ ពាក្យថា សិក្សា ជាពាក្យសម្ដែងដល់ភាពជាអ្នកមានការព្រមព្រៀងក្នុងសិក្ខាបទ ។ ពាក្យថា ក្នុងសិក្ខាបទទាំងឡាយ ជាពាក្យសម្ដែងដល់ធម៌ដែលគប្បីសិក្សា ។ ពាក្យណាដែលគួរពោលក្នុងអធិការនេះ ពាក្យនោះនឹងមានច្បាស់ខាងមុខ ។

## អធិប្បាយអត្ថនៃបទផ្សេងៗ

( តទៅ ) នេះជាពាក្យវិនិច្ឆ័យដោយពណ៌នាសេចក្ដីនៃបទតាមលំដាប់ ចាប់ពីខាងដើមនៃសីលទាំងឡាយនោះ

បទថា **ឥធ** គឺក្នុងសាសនានេះ ។

បទថា **ភិក្ខុ** បានដល់ កុលបុត្តដែលបួសដោយសទ្ធា, ដែលបានវោហារ ( ពាក្យហៅ ) យ៉ាងនោះ ព្រោះភាវៈ គឺការឃើញភ័យក្នុងសង្សារ ឬន័យម្យ៉ាងទៀត ព្រោះជាអ្នកប្រើសំពត់ដែលហែកដាច់ហើយ ជាបន្ទុះជាដើម ។

ក្នុងបទថា សង្រួមដោយបាតិមោក្ខសំវរនេះ មានសេចក្ដីថា ពាក្យថា **បាតិមោក្ខ** សំដៅយកសីលដែលជាសិក្ខាបទ ព្រោះថា អ្នកណាចាំរវាំងមើលគឺរក្សាសីលនោះសីលនោះរមែងញ៉ាំងបុគ្គលនោះឲ្យរួចផុត គឺឲ្យផុតចាកទុក្ខទាំងឡាយ មានទុក្ខក្នុងអបាយជាដើម ព្រោះហេតុនោះ សីលនោះទើបលោកហៅថា បាតិមោក្ខ ។

ការបិទបាំង ឈ្មោះថា សំវរ, ពាក្យថា **សំវរ** នេះជាឈ្មោះនៃការមិនល្មើស ផ្លូវកាយ និងផ្លូវវាចា, សំវរ គឺបាតិមោក្ខ ឈ្មោះថា បាតិមោក្ខសំវរភិក្ខុសង្រួមហើយគឺចូលដល់ប្រកបព្រមហើយដោយសំវរ គឺបាតិមោក្ខនោះ ឈ្មោះថា អ្នកសង្រួមដោយបាតិមោក្ខសំវរ ។

បទថា **វិហរតិ** គឺ ផ្លាស់ប្តូរឥរិយាបថជានិច្ច ។

# មហាដីកា

## ពណ៌នាបាតិមោក្ខសំវរសីល

បទថា **តត្រ** មានន័យស្មើនឹង **តេសុ យោគបាតិមោក្ខសំវរាទីសុ** ប្រែថា ក្នុងបណ្ដាបាតិមោក្ខសំវរសីលទាំងឡាយនោះ ។ ពាក្យថា **អាទិតោ បដ្ឋាយ** មានន័យថា ចាប់តាំងពីដើមនៃទេសនាដែលមកហើយ ដោយពាក្យថា **ឥធ ភិក្ខុ** ដូច្នេះ ។ បទថា **វិនិច្ឆយកថា** មានន័យថា កថាដែលនាំមកនូវការវិនិច្ឆ័យដើម្បីកម្ចាត់នូវសេចក្ដីសង្ស័យក្នុងសីលទាំងឡាយនោះ ។ លោកអាចារ្យ កាលនឹងសម្ដែងបរិយាយដែលជាផ្នែកមួយរបស់បព្វជិតដែលមិនទូទៅ ព្រោះសេចក្ដីខាងដើមទូទៅចំពោះបុគ្គលគ្រប់ជំពូក ទើបពោលថា **ភិន្នបដន្ធរាទិតាយ វា** ឬ ន័យម្យ៉ាងទៀត ព្រោះជាអ្នកប្រើសំពត់ដែលហែកដាច់ហើយជាដើម ដូច្នេះ ។ និងដោយប្រការដូច្នេះ រមែងសម្ដែងថា ភិក្ខុនោះ ជាអ្នកគួរដល់បាតិមោក្ខសំវរដែលបរិបូណ៌ហើយ ។ ធម្មតាភាវៈនៃអ្នកទ្រទ្រង់សំពត់ដែលហែកដាច់ហើយជាដើម រមែងមានចំពោះមនុស្សអត្តខាត់ដែលមិនមានផ្ទូវទៅដូច្នោះ ដើម្បីនឹងឲ្យផ្សេងពីមនុស្សអត្តខាត់នោះ ទើបពោលថា អ្នកបួសដោយសទ្ធា ដូច្នេះហើយ ទើបពោលថា កុលបុត្ត ដើម្បីសម្ដែងភាវៈនៃភាពជាអ្នកប្រកបការបដិបត្តិ ។ ពិត

ហើយ កុលបុត្តដែលមានអាចារ ឬកុលបុត្តពីកំណើត ក៏អាចបដិបត្តិបាន ។ ពាក្យថា សីល គឺសិក្ខាបទ បានដល់ សីលដែលទ្រង់បញ្ញត្តទុកដោយអំណាចសិក្ខាបទ ដែលផ្សេងដោយចារិតសីល និងវារិតសីល ។ បទថា **យោ** ជាពាក្យសម្តែងមិនច្បាស់លាស់ គឺបុគ្គលណាមួយ ។ បទថា **នំ យោគ វិនយបរិយាបន្នំ សីលំ** ប្រែថា បានដល់សីលដែលទាក់ទងក្នុងវិន័យនោះ ។

បទថា **តំ យោគ បុគ្គលំ** ប្រែថា បុគ្គលនោះ ។ រមែងធ្វើបុគ្គលនោះឲ្យរួចផុត ព្រោះភាពជាហេតុនៃការរួបរួមគ្នា ។ ភពទាំងឡាយក្នុងអបាយ ហេតុនោះ ឈ្មោះថា **អបាយិកានិ** ( ភពក្នុងអបាយ ) ។

ដោយ អាទិ-ស័ព្ទ លោករួមទាំងទុក្ខក្នុងសង្សារទាំងអស់ ក្រៅពីភពក្នុងអបាយនោះ ។ ការបិទកាយទ្វារនិងវចីទ្វារ ឈ្មោះថា ការសង្រួម ។ ទ្វារទាំងឡាយនោះរមែងឃាំងហើយ បិទហើយដោយការបិទណាការបិទនោះឈ្មោះថា **សំវរ** ។

ព្រោះសំវរនោះ គឺការមិនឈានកន្លងអាបត្តិទាំង ៧ កង ព្រោះធ្វើអធិប្បាយថា ជាបដិបក្ខដល់ការឈានកន្លង ដូច្នោះទើបលោកពោលថា ពាក្យថា សំវរនេះជាឈ្មោះនៃការមិនឈានកន្លង ( អាបត្តិ ) ដែលកើតតាមផ្លូវកាយ និងវាចា ។

ពាក្យថា សង្រួមហើយដោយសំវរ គឺបាតិមោក្ខ មានន័យថា មានកាយទ្វារ និងវចីទ្វារបិទហើយដោយបាតិមោក្ខសំវរសីល ។ ព្រោះ

បុគ្គលយ៉ាងនោះ រមែងឈ្មោះថា ចូលដល់ហើយនូវបាតិមោក្ខសំវរសីលនោះ និងឈ្មោះថា មានការព្រមព្រៀងដោយបាតិមោក្ខសំវរសីលនោះ ហេតុនោះ ទើបលោកពោលថា អធិប្បាយថា ចូលដល់ហើយ ប្រកបហើយ ដូច្នេះ ។

ន័យម្យ៉ាងទៀត បុថុជ្ជនឈ្មោះថា **បាតី** ( អ្នកមានការធ្លាក់ទៅជាប្រក្រតី ) ព្រោះអត្ថថា មានប្រក្រតីធ្លាក់ទៅក្នុងអបាយទាំងឡាយច្រើនគ្រា ព្រោះកិលេសទាំងឡាយមានកម្លាំង ១, ព្រោះការធ្វើបាបបានងាយ ១, ព្រោះការធ្វើបុណ្យធ្វើបានដោយកម្រ ១ ។ ឬឈ្មោះថា **បាតី** ( អ្នកមានការធ្លាក់ចុះទៅជាប្រក្រតី ) ព្រោះអត្ថថា ជាអ្នកដែលកម្លាំងនៃកម្មបន្សាត់ទៅហើយក្នុងភពជាដើម ព្រោះការមិនទៀងមានប្រក្រតីទៅ ព្រោះវិលទៅជុំវិញ មិនតាំងមាំ ដូចជាគ្រឿងយន្តសម្រាប់ស្ទូនថ្នាំង,ន័យម្យ៉ាងទៀតសន្តាននៃសត្វឬចិត្តនោះឯងឈ្មោះថា **បាតី** (អ្នកធ្វើឲ្យធ្លាក់ចុះទៅជាប្រក្រតី) ព្រោះអត្ថថា មានប្រក្រតីញុំាងអត្តភាពឲ្យធ្លាក់ទៅក្នុងសត្តនិកាយនោះៗ តាមអំណាចនៃការស្លាប់ ។ ឈ្មោះថា បាតិមោក្ខ ព្រោះអត្ថថា ញុំាងបាតីនោះឲ្យផុតចាកពីសង្សារទុក្ខ ។ សត្វលោកហៅថា **វិមុត្តោ** ( អ្នករួចផុត ) ព្រោះអត្ថថារួចផុតនៃចិត្ត ។ សមពិតដូចទ្រង់ត្រាស់ទុកថា **ចិត្តវោទានា វិសុជ្ឈន្តិ** ( សត្វទាំងឡាយរមែងបរិសុទ្ធ ព្រោះការផូរផង់នៃចិត្ត ) និងថា

**អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តំ** ចិត្តរួចផុតចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដូច្នេះ ។ ម្យ៉ាងទៀត ឈ្មោះថា **បាតី** ( អ្នកធ្លាក់ទៅ) ព្រោះអត្ថថា ធ្លាក់ទៅ គឺប្រព្រឹត្តទៅក្នុងសង្សារ ព្រោះហេតុ មានអវិជ្ជាជាដើម ។ សមដូចទ្រង់ត្រាស់ទុកថា សត្វមានគ្រឿងរាំង គឺអវិជ្ជា មានសំយោជនៈ គឺតណ្ហា ស្ទុះទៅជានិច្ច វិលវល់ជានិច្ច ដូច្នេះ ។

សីល ឈ្មោះថា បាតិមោក្ខ ព្រោះអត្ថថា ជាហេតុឲ្យសត្វឈ្មោះថា **បាតី** នោះផុតចាកសង្កិលេសទាំង ៣ មានតណ្ហាជាដើម ។

គប្បីជ្រាបថា ពាក្យថា **បាតិមោក្ខ** នោះ សម្រេចដោយការសមាស ដូចស័ព្ទទាំងឡាយ មានស័ព្ទថា **កណ្ឋេកាឡោ** ជាដើម ។

ម្យ៉ាងទៀត **ចិត្ត** ឈ្មោះថា **បាតី** ព្រោះអត្ថថា ធ្វើឲ្យធ្លាក់ទៅ គឺឲ្យធ្លាក់ វិនាសទៅក្នុងទុក្ខ ។ សមពិតដូចដែលទ្រង់ត្រាស់ទុកថា **ចិត្តេន នីយតិ លោកោ ចិត្តេន បរិកិស្សតិ** លោកដែលចិត្តរមែងនាំទៅ ចិត្តរមែងប្រានទៅ ។ សីល ឈ្មោះថា បាតិមោក្ខ ព្រោះអត្ថថា ជាហេតុឲ្យ **ចិត្ត** ឈ្មោះថា **បាតី** នោះផុតទៅ ។

ម្យ៉ាងទៀត **សង្កិលេស** មានតណ្ហាជាដើម ឈ្មោះថា **បាតី** ព្រោះអត្ថថា ជាហេតុឲ្យធ្លាក់ទៅក្នុងអបាយទុក្ខ និងសង្សារទុក្ខ ។ សមដូចដែលទ្រង់ត្រាស់ថា **តណ្ហា ជនេតិ បុរិសំ** ( តណ្ហារមែងញុំាងបុរសឲ្យកើត ) និងថា **តណ្ហាទុតិយោ បុរិសោ** ( បុរសមានតណ្ហាជាមិត្ត

គម្រប់ ២ ) ដូច្នេះជាដើម ។ ឈ្មោះថា បាតិមោក្ខ ព្រោះអត្ថថា ផុតចាកពីបាតីនោះ ។ម្យ៉ាងទៀត អាយតនៈខាងក្នុង ៦ និងខាងក្រៅ ៦ ឈ្មោះថា **បាតី** ព្រោះអត្ថថា ជាទីធ្លាក់ទៅ ។ សមដូចដែលទ្រង់ត្រាស់ទុកថា **ឆសុ លោកោ សមុប្បន្នោ ឆសុ កុព្វតិ សន្ថវំ** លោកកើតឡើងព្រមព្រោះអាយតនៈ ៦ រមែងធ្វើសេចក្ដីពេញចិត្តក្នុងអាយតនៈ ៦។

សីល ឈ្មោះថា **បាតិមោក្ខ** ព្រោះអត្ថថាផុតចាកពី **បាតិ** ពោលគឺអាយតនៈ ខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ នោះ ។ម្យ៉ាងទៀត សង្សារ ឈ្មោះថា បាតី ព្រោះអត្ថថា អ្នកដែលមានការធ្លាក់ទៅ គឺធ្លាក់វិនាសទៅ ។ សីល ឈ្មោះថា បាតិមោក្ខ ព្រោះអត្ថថា ផុតចាកសង្សារនោះ, ម្យ៉ាងទៀត ព្រះមានព្រះភាគជាធំក្នុងធម៌ ដែលសព្វលោកា ហៅថា **បតិ** ព្រោះភាពជាអធិបតីនៃលោកទាំងពួង ។

ឈ្មោះថា **មោក្ខ** ព្រោះអត្ថថា ជាហេតុរួចផុត, សីល ឈ្មោះថា បាតិមោក្ខ ព្រោះអត្ថថា ជាគ្រឿងរួចផុត, ចំពោះព្រះមានព្រះភាគ ឈ្មោះថា **បតិ** ព្រោះ **បាតិ** នោះ  ព្រះមានព្រះភាគទ្រង់បញ្ញត្តហើយ, **បាតិមោក្ខោ** នោះឯងជា **បាតិមោក្ខំ** ។ ម្យ៉ាងទៀត **សីល** ជា **បតិ** ព្រោះអត្ថថា ខ្ពង់ខ្ពស់ដោយភាពជាឫសគល់នៃសព្វគុណទាំងឡាយនោះផង ជា **មោក្ខ** ព្រោះអត្ថតាមដែលពោលហើយផង ហេតុនោះទើបឈ្មោះថា បតិមោក្ខ, **បតិមោក្ខ** នោះឯងជា **បាតិមោក្ខ** ។ ពិត

ដូចដែលលោកពោលទុកថា **បាតិមោក្ខន្តិ មុខមេតំ បមុខមេតំ** មានន័យថា បាតិមោក្ខនេះ សេចក្ដីថា សីលជាមុខ សីលនេះជាប្រមុខ ដូច្នេះគប្បីអធិប្បាយតទៅ... ។

ម្យ៉ាងទៀត ស័ព្ទថា **ប** ជានិបាតប្រើចុះក្នុងអត្ថថា **បការ**, ស័ព្ទថា **អតិ** ជានិបាតចុះក្នុងអត្ថថា **អច្ចន្ត** ( ភាពល្មើស ) ព្រោះដូច្នោះ សីលណា ឈ្មោះថា បាតិមោក ញុំាងសត្វឲ្យរួចផុតអំពីភាពល្មើស ហេតុនោះ សីលនោះ ឈ្មោះថា បាតិមោក្ខ ។

សីលនេះ ខ្លួនឯង រមែងញុំាងសត្វឲ្យរួចផុត គឺធ្វើឲ្យស្រោលស្តើងដោយអំណាចតទង្គប្បហានផង, ដែលប្រកបដោយសមាធិនិងប្រកបដោយបញ្ញា រមែងញុំាងសត្វឲ្យរួចផុត គឺធ្វើឲ្យស្រោលស្តើងដោយអំណាចវិក្ខម្ភនប្បហាននិងដោយសមុច្ឆេទប្បហាន ព្រោះហេតុនោះ ទើបសីលនោះ ឈ្មោះថា បាតិមោក្ខ, ម្យ៉ាងទៀត សីល ឈ្មោះថា បតិមោក្ខ ព្រោះអត្ថថា ជាការរួចផុតចំពោះៗ អធិប្បាយថា ជាការរួចផុតដោយចំពោះចាកទោស គឺសេចក្ដីល្មើសនោះៗ, បតិមោក្ខនោះឯងជា **បាតិមោក្ខ** ។ ម្យ៉ាងទៀត ពាក្យថា មោក្ខ បានដល់ និព្វាន, សីល ឈ្មោះថាបតិមោក្ខព្រោះអត្ថថាជារូបប្រៀបត្រង់ចំពោះនិព្វានដែលឈ្មោះថា **មោក្ខ** នោះ ។ មែនពិត **សីលសំវរ** ជាការឧទ័យ គឺរះឡើងនៃព្រះនិព្វាន ដូចជាការរះឡើងនៃអរុណរបស់ដួងព្រះអាទិត្យ

ដូច្នេះ ទើបដូចគ្នា ក្នុងការប្រៀបធៀបនៃព្រះនិព្វាននោះ ព្រោះជាការរំលត់កិលេសបានតាមសមគួរ, **បតិមោក្ខ** នោះឯងជា **បាតិមោក្ខ** ។

ម្យ៉ាងទៀត **សីល** ឈ្មោះថា **បតិមោក្ខ** ព្រោះអត្ថថា ប្រព្រឹត្តទៅចំពោះ មោក្ខ ( គឺព្រះនិព្វាន ) ឬចំពោះអត្ថថា មានមុខឆ្ពោះទៅរកមោក្ខ ( គឺព្រះនិព្វាន ), បតិមោក្ខ នោះឯងជា បាតិមោក្ខ បណ្ឌិតគប្បីជ្រាបខ្លឹមសារនៃ បាតិមោក្ខ-ស័ព្ទ ក្នុងអធិការនេះ ដោយប្រការដូចដែលពោលមកនេះចុះ ។

ពាក្យថា **ឥរិយតិ** ប្រែថា រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ។

លោកសម្តែងការសម្រាកនៃឥរិយាបថ ( ឥរិយាបថវិហារ ) របស់ភិក្ខុដែលតាំងនៅក្នុងសីល គឺ **បាតិមោក្ខសំវរ** ដោយពាក្យថា **វិហរតិ** នេះ ។

( ចប់ មហាដីកា )

.............................

## អាចារ-អនាចារ

ខ្លឹមសារនៃពាក្យថា ដល់ព្រមដោយអាចារ និងគោចរជាដើម គប្បីជ្រាបតាមន័យដែលពោលមកហើយ ក្នុងព្រះបាលីនោះឯង ពិតហើយ ព្រះធម្មសង្គាហកាចារ្យពោលពាក្យនេះទុកថា ពាក្យថា ដល់ព្រមដោយអាចារ និងគោចរ មាននិទ្ទេសថា អាចារក៏មាន អនាចារក៏មាន ក្នុង ២ យ៉ាងនោះ អនាចារ តើដូចម្តេច ? សេចក្តីល្មើសផ្លូវកាយ សេចក្តីល្មើសផ្លូវវាចា សេចក្តីល្មើសទាំងផ្លូវកាយ ទាំងផ្លូវវាចា នេះលោកហៅថា អនាចារ ភាពជាអ្នកទ្រុស្តសីល សូម្បីទាំងអស់ក៏ឈ្មោះថា អនាចារ ភិក្ខុរបខ្លះក្នុងធម្មវិន័យនេះ រមែងចិញ្ចឹមជីវិតដោយការឲ្យដើមឫស្សីខ្លះ, ដោយការឲ្យស្លឹកឈើខ្លះ ដោយការឲ្យផ្កាឈើខ្លះ ផ្លែឈើ គ្រឿងងូតទឹក និងឈើស្ទន់ ដោយការបន្ទាបខ្លួន ( ដើម្បីឲ្យគេស្រឡាញ់ខ្លះ ) ដោយនិយាយ ( លេងបន្ទំមែនខ្លះ ) ដូចជាសណ្តែកស្ងោរខ្លះ ( លោកពោលថា សណ្តែកស្ងោរនោះ នឹងមានសណ្តែកដែលមិនឆ្អិន,តិចតួចណាស់ ដែលឆ្អិន ស្មើគ្នាយ៉ាងណា បុគ្គលលេងបន្ទំមែន ពាក្យគេពិតតិចណាស់ ) ដោយធ្វើខ្លួនឲ្យជាអ្នកចិញ្ចឹមទារកខ្លះ ដោយការទទួលដំណឹងគេខ្លះ ឬដោយមិច្ឆាជីវៈផ្សេងៗ ដែលព្រះសាស្តា ទ្រង់តិះដៀល នេះឈ្មោះថា **អនាចារ** ។

មិនល្មើសផ្លូវវាចា ការមិនល្មើសទាំងផ្លូវកាយ និងផ្លូវវាចា នេះលោកហៅថា អាចារ សីលសំវរទាំងអស់ក៏ឈ្មោះថា អាចារ ភិក្ខុរូបខ្លះក្នុងសាសនានេះ មិនចិញ្ចឹមជីវិតដោយការឲ្យដើមឫស្សីក្តី មិនចិញ្ចឹមជីវិតដោយការឲ្យស្លឹកឈើក្តី មិនចិញ្ចឹមជីវិតដោយការឲ្យផ្កាឈើ ផ្លែឈើ គ្រឿងផ្សំ និងឈើស្ទន់ក្តី មិនចិញ្ចឹម ជីវិតដោយការបន្ទាបខ្លួន ( ដើម្បីឲ្យគេស្រឡាញ់ ) ក្តី មិនចិញ្ចឹមជីវិតដោយការនិយាយ ( លេងបន្ទំមែន ) ដូចជាសណ្តែកស្ងោរក្តី មិនចិញ្ចឹមជីវិតដោយការធ្វើខ្លួន ជាអ្នកចិញ្ចឹមទារកក្តី មិនចិញ្ចឹមជីវិតដោយការទទួលដំណឹងឲ្យគេក្តី មិនចិញ្ចឹមជីវិតដោយមិច្ឆាជីវៈផ្សេងៗ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់តិះដៀល នេះហៅថា អាចារ ។

## គោចរ-អគោចរ

ពាក្យថា គោចរ មាននិទ្ទេសថា គោចរក៏មាន អគោចរក៏មានក្នុង ២ យ៉ាងនោះ, អគោចរដូចម្តេច ? ភិក្ខុរូបខ្លះក្នុងសាសនានេះជាអ្នកមានស្រីពេស្យាជា គោចរ ឬស្រីមេម៉ាយ ស្រីសៅកែ ខ្ទើយភិក្ខុនី និងតៀមសុរាជាគោចរ ជាអ្នកស្និទ្ធស្នាលជាមួយនឹងព្រះរាជាជាមួយអមាត្យជាមួយនឹងតិរ្ថិយដោយការសំណេះសំណាលជាមួយគ្រហស្ថ របៀបមិនសមគួរ ឬថា រមែងសេព រមែងគប់រក រមែងចូល

ទៅអន្តុយជិតនូវត្រកូលទាំងឡាយ ដែលមិនមានសទ្ធា មិនជ្រះថ្លា ដែលបន្ទោសជាសុំ ដែលប្រាថ្នាឲ្យវត្ថុមិនមែនជាប្រយោជន៍ វត្ថុដែលមិនទំនុកបម្រុង ប្រាថ្នាសេចក្តីមិនជាសុខ ប្រាថ្នាសេចក្តីមិនក្សេមចាកយោគៈ ( ឲ្យ ) ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា នេះហៅថា អគោចរ ។

ក្នុង ២ យ៉ាងនោះ គោចរដូចម្តេច ? ភិក្ខុរូបខ្លះក្នុងសាសនានេះ ជាអ្នកមិនមានស្រីពេស្យាជាគោចរ ។ល។ មិនជាអ្នកមានតៀមសុរាជាគោចរ មិនស្និទ្ធស្នាលជាមួយព្រះរាជា ។ល។ ជាមួយសាវ័ករបស់ពួកតិរ្ថិយ ដោយការសំណេះសំណាលជាមួយគ្រហស្ថដែលមិនសមគួរ ឬថា រមែងសេព រមែងគប់រក រមែងចូលទៅអន្តុយជិតត្រកូលទាំងឡាយ ដែលមានសទ្ធាជ្រះថ្លា ( ដូច ) ជាអណ្តូងទឹក រុងរឿងដោយសំពត់កាសាវពស្ត្រ មានក្លិនឥសីចេញចូល ប្រាថ្នាប្រយោជន៍ឲ្យ ។ល។ ប្រាថ្នាធម៌ក្សេមចាកយោគៈ ។ល។ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា នេះហៅថា គោចរ, ភិក្ខុដែលចូលទៅរបួតដល់ជាអ្នកចូលមករបួតដល់ ជាអ្នកបដិបត្តិរបួតដល់ ជាអ្នកប្រកបព្រមដោយអាចារនេះផង ដោយគោចរនេះផង ដោយន័យដែលពោលមកហើយ ព្រោះ

ហេតុនោះ ទើបលោកពោលថា អាចារ-គោចរសម្បន្នោ អ្នកដល់ព្រមដោយអាចារ និងគោចរ ។

## អនាចារ ២ យ៉ាង

ក្នុងសេចក្ដីនេះ បណ្ឌិតគប្បីជ្រាប អាចារ និងគោចរ ដូចតទៅ

ន័យម្យ៉ាងទៀត អនាចារមាន ២ យ៉ាង គឺអនាចារផ្លូវកាយ ១ អនាចារផ្លូវវាចា ១ ក្នុង ២ យ៉ាងនោះ, អនាចារ ផ្លូវកាយដូចម្ដេច ? ភិក្ខុរបខ្លះក្នុងព្រះពុទ្ធសាសនានេះ សូម្បីនៅក្នុងជំនុំសង្ឃ ក៏មិនធ្វើការកោតក្រែងឈរអែបខាងអង្គុយអែបខាងចំពោះភិក្ខុទាំងឡាយជាថេរៈ ឈរមុខ ( លោក ) ខ្លះ អង្គុយមុខ ( លោក ) ខ្លះ អង្គុយអាសនៈខ្ពស់ ( ជាងលោក ) ខ្លះ អង្គុយក្រសោបសីសៈខ្លះ ឈរនិយាយខ្លះ លើកដៃខ្វាត់ខ្វែងនិយាយខ្លះ កាលភិក្ខុជាថេរៈមិនពាក់ស្បែកជើងចង្ក្រម ខ្លួនពាក់ស្បែកជើងចង្ក្រមខ្លះ កាលលោកចង្ក្រមក្នុងទីចង្ក្រមទាបខ្លួន ចង្ក្រមក្នុងទីចង្ក្រមខ្ពស់ខ្លះ កាលលោកចង្ក្រមនៅលើដី ខ្លួនចង្ក្រមនៅលើទីចង្ក្រមខ្លះ ឈរជ្រៀតខ្លះ អង្គុយជ្រៀតខ្លះ ចំពោះភិក្ខុជាថេរៈហាមភិក្ខុថ្មីដោយអាសនៈខ្លះ(គឺមិនអង្គុយតាមកន្លែងសមគួរចំពោះខ្លួន អង្គុយខាងក្រោយ ឬអង្គុយទាប ជាហេតុឲ្យភិក្ខុថ្មីរកកន្លែងអង្គុយមិនបាន ព្រោះកន្លែងសមគួរចំពោះខ្លួនលោកអង្គុយហើយ ទៅ

អង្គុយមុខក៏មិនបាន ) មិនទាន់សុំឱកាសភិក្ខុជាថេរៈផង សូម្បីនៅក្នុងរោងភ្លើងក៏ជញ្ជូនឧសដុតទៅបិទទ្វារ សូម្បីនៅកំពង់ទឹកដើរបៀសព្រះថេរៈចុះទៅខ្លះ ចុះមុនខ្លះ ងូតទឹកជ្រៀតខ្លះ ងូតទឹកមុនខ្លះ ជ្រៀតឡើងខ្លះ ឡើងមុនខ្លះ សូម្បីចូលទៅកាន់លំនៅផ្ទះ ក៏ដើរជ្រៀតភិក្ខុជាថេរៈទៅខ្លះ ទៅមុនលោកខ្លះ ក្រោកឡើងមុនព្រះថេរៈទៅខ្លះ,ម្យ៉ាងទៀត បន្ទប់រៀនរបស់ត្រកូលទាំងឡាយ ដែលជាបន្ទប់សម្ងាត់ និងគេបិទទុកជាកន្លែងកុលស្ត្រី កុលកុមារីអង្គុយប្រជុំគ្នា ក៏ស្ទុះចូលទៅក្នុងបន្ទប់នោះខ្លះ ស្ទាបអង្អែលសីសៈក្មេងប្រុសខ្លះ នេះហៅថា អនាចារផ្លូវកាយ ។

ក្នុង ២ យ៉ាងនោះ អនាចារផ្លូវវាចាតើដូចម្តេច ? ភិក្ខុរូបខ្លះក្នុងព្រះសាសនានេះ សូម្បីនៅក្នុងជំនុំសង្ឃក៏មិនធ្វើសេចក្តីកោតក្រែង មិនទាន់បានសុំឱកាសពីព្រះថេរៈផង ក៏ពោលធម៌ទៅ ឆ្លើយបញ្ហាទៅ សូត្របាតិមោក្ខទៅ ឈរនិយាយខ្លះ លើកដៃទាត់ខ្វែងនិយាយខ្លះ សូម្បីចូលទៅកាន់លំនៅផ្ទះ ពោលនឹងស្ត្រី ឬក្មេងស្រីយ៉ាងនេះថា នែអ្នកមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ បបរមិនទាន់អស់ទេឬ ? បាយមិនទាន់អស់ទេឬ ? របស់ទំពាមិនទាន់អស់ទេឬ ? និយាយច្រើនថា អាត្មានឹងផឹកអ្វី នឹងទំពាអ្វី នឹងឆាន់អ្វី ឬថា អ្នកទាំងឡាយ នឹងឲ្យអ្វីដល់អាត្មា ដូច្នេះ នេះហៅថា អនាចារផ្លូវវាចា ចំណែកអាចារ គប្បី

ជ្រាបដោយន័យផ្ទុយគ្នាចំពោះអនាចារនោះចុះ ។

ន័យម្យ៉ាងទៀត ភិក្ខុដែលមានការគោរព មានការកោតក្រែង ដល់ព្រមដោយហិរិឪត្តប្បៈ គ្រងរៀបរយ ឃ្លុំរៀបរយ មានកិរិយាឈានទៅ ថយក្រោយ ក្រឡេកមើល ឆាកមើល បត់ដៃចូល លាតដៃចេញ គួរជ្រះថ្លា ចក្ខុសំយុងចុះ ដល់ព្រមដោយឥរិយាបថ រក្សាទ្វារក្នុងឥន្ទ្រីយ៍ទាំងឡាយ ដឹងប្រមាណក្នុងភោជន ប្រកបរឿយៗ នូវជាគរិយធម៌ ប្រកបដោយសតិសម្បជញ្ញៈ ប្រាថ្នាតិច សន្តោស មិនស្និទ្ធស្នាលដោយពួកគណៈ ប្រារព្ធសេចក្តីព្យាយាម ធ្វើដោយគោរពក្នុងអភិសមាចារិកសិក្ខាបទទាំងឡាយ ច្រើនទៅដោយសេចក្តីគោរពនិងកោតក្រែងជានិច្ច ភាពជាអ្នកមានសេចក្តីគោរពជាអាទិ៍នេះ ហៅថាអាចារ គប្បីជ្រាបអាចារ ដូច្នេះឯង ។

## គោចរ ៣

## ឧបនិស្សយគោចរ

គោចរមាន ៣ យ៉ាង គឺឧបនិស្សយគោចរ អារក្ខគោចរ ឧបនិពន្ធគោចរ បណ្តាគោចរ ៣ យ៉ាងនោះ ឧបនិស្សយគោចរដូចម្តេច ?

កល្យាណមិត្តដែលប្រកបដោយគុណជាកថាវត្ថុ ១០ ដែលជាកន្លែងបុគ្គលបានអាស្រ័យហើយ រមែងបានស្តាប់វត្ថុដែលមិនធ្លាប់

បានស្តាប់ ធ្វើវត្ថុដែលធ្លាប់បានស្តាប់ហើយឲ្យកាន់តែជាក់ច្បាស់ឡើង ធ្វើនូវសេចក្តីសង្ស័យបាន ធ្វើការយល់ឲ្យត្រង់ ធ្វើចិត្តគំនិតឲ្យថ្លៃផង់បាន ឬថា បុគ្គលសិក្សាតាមកល្យាណមិត្តណាហើយ រមែងចម្រើនដោយសទ្ធា រមែងចម្រើនដោយសីល សុតៈ ចាគៈ បញ្ញា កល្យាណមិត្តនោះ ហៅថា ឧបនិស្សយគោចរ ។

## អារក្ខគោចរ

អារក្ខគោចរដូចម្តេច ? ភិក្ខុក្នុងព្រះសាសនានេះ ចូលទៅកាន់លំនៅផ្ទះ ដើរទៅតាមថ្នល់ មានចក្ខុសំយុងចុះ សម្លឹងមើលមួយជួរនឹម សង្រួមហើយ មិនក្រឡេកមើលពលដំរី មិនក្រឡេកមើលពលសេះ មិនក្រឡេកមើលពលរថ មិនក្រឡេកមើលពលថ្មើរជើង មិនក្រឡេកមើលស្ត្រីមិនមើលបុរសមិនងើយមុខមើលមិនឱនខ្លួនមើល មិនបែរមើលឡេះឡោះដើរទៅ នេះហៅថា អារក្ខគោចរ ។

## ឧបនិពន្ធគោចរ

ឧបនិពន្ធគោចរដូចម្តេច?ឧបនិពន្ធគោចរបានដល់សតិប្បដ្ឋាន ៤ ដែលជាទីនាំចិត្តចូលទៅចងទុក សមដូចភាសិតព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អ្វីជាគោចររបស់ភិក្ខុ ? ធម៌ជាវិស័យនៃបិតារបស់ខ្លួន ធម៌នេះគឺអ្វី គឺសតិប្បដ្ឋាន ៤ នេះហៅថា

ឧបនិពន្ធគោចរ ។

ភិក្ខុជាអ្នកចូលដល់ ជាអ្នកប្រកបព្រមដោយអាចារនេះផង ដោយគោចរនេះផង ដូចដែលពោលហើយ សូម្បីព្រោះហេតុនោះ ទើបហៅថា អាចារគោចរសម្បន្នោ (អ្នកដល់ព្រមហើយដោយអាចារ និងគោចរ ) ។

សេចក្តីថា មានប្រក្រតីឃើញភ័យក្នុងទោសសូម្បីតិចតួច មានន័យថា ជាអ្នកមានប្រក្រតីឃើញភ័យក្នុងទោសទាំងឡាយសូម្បីមានប្រមាណតូច ដែលផ្សេងដោយទោសជាដើមថា សេក្ខិយវត្តដែលមិនតាំងចិត្តកន្ទុង និងចិត្តុប្បាទ ដែលជាអកុសល ។ ពាក្យថា រមែងសមាទានសិក្សានៅក្នុងសិក្ខាបទទាំងឡាយ មានន័យថា សីលយ៉ាងណាមួយដែលត្រូវសិក្សានៅក្នុងសិក្ខាបទទាំងឡាយ គឺកាន់សីលទាំងពួងនោះដោយល្អ សិក្សាជានិច្ច ក្នុងអធិការនៃបាតិមោក្ខសំវរសីលនេះ គប្បីជ្រាបថា បាតិមោក្ខសំវរសីល ព្រះមានព្រះភាគទ្រង់សម្តែងដោយបុគ្គលាធិដ្ឋាន ទេសនាដោយបទថា **បាតិមោក្ខសំវរសំវុតោ** ត្រឹមតែមួយបទនេះ ចំណែកពាក្យថា អាចារគោចរសម្បន្នោជាដើម ព្រះមានព្រះភាគត្រាស់ដើម្បីទ្រង់សម្តែង១.បដិបត្តិ ដែលជាផ្លូវដល់ព្រមនៃសីលទាំងអស់ នោះចំពោះអ្នកបដិបត្តិ ។

# មហាដីកា

## អាចារ-អនាចារ

ពាក្យថា ក្នុងព្រះបាលី គឺក្នុងព្រះបាលីឈានវិភង្គ ។ ក្នុងព្រះបាលីលោកពោលទុកថា **អាចារគោចរសម្បន្នោ** ដូច្នេះក៏ដើម្បីសម្តែងអាចារសមណៈ និងគោចររបស់សមណៈពិតមែន តែសូម្បីយ៉ាងនោះ ដូចជាបុគ្គលកាលនឹងប្រាប់ផ្លូវដែលគួរកាន់យក តែងប្រាប់ផ្លូវគួរវៀរចាកមុន ហើយទើបប្រាប់ផ្លូវគួរ កាន់យកជាក្រោយថា អ្នកចូរលះផ្លូវខាងឆ្វេងចេញ ចូរកាន់យកផ្លូវខាងស្តាំចុះ ដូច្នេះយ៉ាងណា ឬថា បុគ្គលដែលបានជម្រះមន្ទិល គឺញើស ឬរបស់មិនស្អាត ដោយការងូតទឹកជម្រះរាងកាយ ព្រមទាំងសីសៈហើយ ទើបសមគួររៀបចំតែងខ្លួនដោយផ្កាឈើ គ្រឿងក្រអូបនិងគ្រឿងលាបជាដើមយ៉ាងណា, បុគ្គលដែលលះបង់បាបធម៌ហើយ ទើបសមគួរប្រកបដោយកល្យាណធម៌ក៏ដូច្នោះដែរ ព្រោះហេតុនោះ កាលដែលព្រះមានព្រះភាគទ្រង់លើកធម៌ ២ ប្រការ ឡើងសម្តែងថា អាចារមានហើយ អនាចារមានហើយ ដូច្នេះហើយ ទ្រង់មានបំណងនឹងចែកអនាចារមុន ទើបត្រាស់ថា ក្នុងអាចារ និងអនាចារនោះ អនាចារ តើដូចម្តេច ? ដូច្នេះជាដើម ។

ក្នុងបណ្តាពាក្យទាំងឡាយនោះ ពាក្យថា សេចក្តីល្មើសផ្លូវកាយ

បានដល់ កាយទុច្ចរិត ៣ យ៉ាង ។ ពាក្យថា សេចក្ដីល្មើសផ្លូវវាចា បានដល់ វចីទុច្ចរិត ៤ យ៉ាង ។ ពាក្យថា សេចក្ដីល្មើសទាំងផ្លូវកាយ និងផ្លូវវាចា បានដល់ ទុច្ចរិតទាំង ២, ទាំងផ្លូវកាយ និងផ្លូវវាចានោះ។

ព្រះមានជោគទ្រង់បានសម្ដែងការទ្រុស្ដសីលដែលមានអាជីវៈជាទី ៨ ដោយប្រការ ដូច្នេះហើយ ។ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងអនាចារផ្លូវចិត្ត ទើបពោលថា ភាពជាអ្នកទ្រុស្ដសីលទាំងអស់ ឈ្មោះថា អនាចារ កាលដែលទ្រង់សម្ដែងអនាចារជាចំណែកផ្សេងៗ ក្នុងបណ្ដាអនាចារទាំងឡាយនោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា ភិក្ខុរូបខ្លះ ក្នុងព្រះសាសនានេះ សម្រេចការចិញ្ចឹមជីវិតដោយការឲ្យដើមឫស្សី ដូច្នេះ ។ ក្នុងបណ្ដាពាក្យទាំងឡាយនោះ ពាក្យថា ដោយការឲ្យដើមឫស្សី មានន័យថា ឲ្យដើមឫស្សីដើម្បីត្រូវការបានបច្ច័យ ។

សូម្បីក្នុងពាក្យមានពាក្យថា ឲ្យស្លឹកឈើជាដើម ក៏មានន័យដូចគ្នា ។

ពាក្យថា ដើមឫស្សី បានដល់ គួដើមឫស្សីយ៉ាងណាមួយនាំមកដើម្បីជាប្រយោជន៍ដល់មនុស្សទាំងឡាយ ។ ស្លឹកឈើ បានដល់ ស្លឹកឈើសម្រាប់រុំឲ្យ ក្រអូបនូវរបស់ដែលមានក្លិនក្រអូបជាដើម ឬស្លឹកត្នោត និងស្លឹកដូងជាដើម ។ ផ្កាឈើ បានដល់ ផ្កាឈើដែលប្រើដើម្បីជាប្រយោជន៍ដល់មនុស្សទាំងឡាយយ៉ាងណាមួយ ។ ផ្លែឈើ

ក៏ដូចគ្នា ។ គ្រឿងសម្រាប់ផ្លូត បានដល់ គ្រឿងលម្អិតសម្រាប់ផ្លូត មានលម្អិតដើមសំបូរជាដើម ។ សុម្បីជីស្អិត ក៏សង្គ្រោះចូលក្នុងគ្រឿងផ្លូតនេះបានផងដែរ ។ ឈើស្ទន់ ជាឈើដុសធ្មេញដែលប្រើជម្រះមាត់ប្រភេទណាមួយ ។ ភាពជាបុគ្គលផ្គាប់ផ្គុន គឺដាក់ខ្លួនទុកក្នុងឋានៈទាបដូចជាទាសៈ ហើយទទួលពាក្យខុសរបស់អ្នកដទៃ ពោលពាក្យសរសើរដើម្បីឲ្យគេស្រឡាញ់ ។ ពាក្យថា ភាពជាអ្នកមានសម្តីដូចជាសត្វសេក មានន័យថា ភាពជាអ្នកធ្វើដូចសណ្តែកស្ងោរ គឺស្វែងរកការចិញ្ចឹមជីវិតដោយពាក្យពិត និងពាក្យ **ធបោក** ។

ដូចជាកាលស្ងោរសណ្តែកឆ្អិនហើយ សណ្តែកជាច្រើនរលួយ មិនរលួយ មានតិចតួចយ៉ាងណា, ក្នុងការចិញ្ចឹមជីវិតដែលទាក់ទងដោយពាក្យសម្តីពិត និងពាក្យធបោក ក៏ដូចគ្នា ដែលមិនពិតច្រើនៗ ដែលពិតតិចតួច ។ ឈ្មោះថា **បរិភត្តិ** ព្រោះអត្ថថា អ្នកចិញ្ចឹម គឺអ្នកមើលចិញ្ចឹមទារករបស់មនុស្សដទៃ ឈ្មោះថា **បារិភត្យំ**, **បារិភត្យំ** នោះឯងជា **បារិភត្យតា**, ពាក្យនេះជាឈ្មោះនៃការមើល ចិញ្ចឹមទារករបស់ត្រកូល ដោយកិច្ចមានការតែងខ្លួនឲ្យជាដើម ។

ការនាំដំណឹង និងសារតបទៅក្នុងស្រុកដទៃ តំបន់ដទៃជាដើមរបស់គ្រហស្ថនោះៗ ឈ្មោះថា **ជង្ឃបេសនិកំ** ( ការបញ្ជូនសារដោយស្មងដើរទៅ ប្រៃសណីយ៍ ) ។ បទថា ដោយមិច្ឆាជីវៈយ៉ាង

ដទៃៗ មានន័យថា ដោយមិច្ឆាជីវៈ គឺដោយការរកចិញ្ចឹមជីវិតយ៉ាង
ណាមួយបណ្ដាការរកស៊ីមានការឲ្យដើមឫស្សីជាដើមទាំងឡាយនេះ
ឬបណ្ដាការរកស៊ីជាពេទ្យ ជានាយឃ្លាំង ការបួរផ្លាស់របស់របរ និង
ការចាត់រកប្រាក់ចំណូលចំពោះសង្ឃ និងប្រាក់ចំណូល ចំពោះចេតិយ
ជាដើម ។

ពាក្យថា ដែលព្រះពុទ្ធជាម្ចាស់ទ្រង់តិះដៀល មានន័យថា លោក
អ្នកប្រាជ្ញទាំងឡាយតិះដៀលហើយ គឺទ្រង់ហាមហើយ ។ ពាក្យថា
ដោយមិច្ឆាជីវៈ គឺមិនមែនជាសម្មាអាជីវៈ ។ ពាក្យថា នេះហៅថា
អនាចារ មានន័យថា ទាំងអស់ នេះលោកថា ជាអនាចារ ។

**អាចារនិទ្ទេស** គប្បីជ្រាបដោយន័យផ្ទុយគ្នា ដូចដែលពោល
ហើយ ។

សូម្បីក្នុងគោចរនិទ្ទេសគប្បីជ្រាបហេតុក្នុងការពោលអគោចរ
មុន តាមន័យ ដែលនឹងពោលក្នុងពេលក្រោយនោះឯង ។ ពាក្យថា
គោចរ បានដល់ ស្ថានទី ដែលគួរចូលទៅដើម្បីបិណ្ឌបាតជាដើម ។
ស្ថានទីដែលមិនសមគួរ ( ចូលទៅដើម្បីបិណ្ឌបាតជាដើម ) ឈ្មោះ
ថា អគោចរ ។ ស្ត្រីពេស្យាជាគោចររបស់ភិក្ខុនោះ ហេតុនោះ ភិក្ខុ
នោះ ឈ្មោះថា មានស្ត្រីពេស្យាជាគោចរ, អធិប្បាយថា ស្ថានទីដែល
ភិក្ខុ គប្បីចូលទៅដោយអំណាចមិត្តជិតស្និទ្ធ ។ ដែលឈ្មោះថា ស្ត្រី

ពេស្យា បានដល់ ពួកស្រីដែលអាស្រ័យរូបចិញ្ចឹមជីវិត ពួកស្រីពេស្យាទាំងឡាយនោះ ដែលភិក្ខុមិនគប្បីចូលទៅរកដោយអំណាចមិត្តជិតស្និទ្ធនឹងគ្នា ព្រោះនឹងធ្វើសេចក្ដីអន្តរាយដល់ភាពជាសមណៈ សូម្បីអ្នកមានចិត្តបរិសុទ្ធ ក៏ជាហេតុឲ្យតិះដៀលបាន, ព្រោះហេតុនោះ ក្នុងការទាក់ទងជាមួយនឹងការថ្វាយទាន ភិក្ខុត្រូវតាំងសតិជាមុនហើយទើបគួរចូលទៅ ។

ស្ត្រីដែលប្ដីស្លាប់ ឬស្ត្រីដែលលែងប្ដី ហៅថា ស្ត្រីមេម៉ាយ ។ ពាក្យថា ស្ត្រីសៅកែ បានដល់ ស្ត្រីក្រមុំដែលមិនបានរៀបការ នៅរហូតដល់ចាស់ ។ ពាក្យថា **បណ្ឌក** បានដល់ ខ្ទើយ ។ ពួកខ្ទើយទាំងឡាយនោះ មានកិលេសក្រាស់ មានការក្ដៅក្រហាយ ( ជានិច្ច ) មិនស្ងប់ច្រើនទៅដោយការជជែកគ្នាដែលអាស្រ័យលោកាមិស ព្រោះហេតុនោះ ភិក្ខុមិនគប្បីចូលទៅជិត ។ ដែលឈ្មោះថា ភិក្ខុនី បានដល់ ស្ត្រីដែលប្រព្រឹត្តព្រហ្មចារ្យលំដាប់ខ្ពស់ ។ សូម្បីភិក្ខុក៏ដូចគ្នា ។ អន្តរាយនៃព្រហ្មចារ្យ គប្បីមានបានក្នុងពេលមិនយូរប៉ុណ្ណោះ ព្រោះតែការចូលទៅរកគ្នា ដោយការធ្លាប់ស្គាល់គ្នា ព្រោះភិក្ខុ និងភិក្ខុនីទាំងនោះជាវិសភាគវត្ថុនៃគ្នានឹងគ្នា, ដូច្នេះ ទើបមិនគួរចូលទៅរកគ្នា ។ ក្នុងពេលចូលទៅរកគ្នា ទាក់ទងអំពីការសួរជំងឺជាដើម ក៏គួរធ្វើសតិទុក ។

បទថា **បានាគារំ** បានដល់ **រោងសុរា** (តៀមសម្រាប់ផឹកស្រា) ។ រោង

សុរានោះ មិនទទេចាកអ្នកលេងសុរា ។ ភិក្ខុមិនគួរចូលទៅក្នុងរោងសុរានោះ ដោយអំណាចភាពជាអ្នកលេងជាដើម ជាមួយអ្នកលេងសុរាទាំងឡាយនោះ ព្រោះធ្វើអន្តរាយដល់ព្រហ្មចារ្យបាន ។

ក្នុងពាក្យជាដើមថា ជាអ្នកស្និទ្ធស្នាលជាមួយព្រះរាជា មានន័យថា ដែលឈ្មោះថា ព្រះរាជា គឺជាអ្នកដែលគ្រប់គ្រងរាជសម្បត្តិ ។ ឈ្មោះថា មហាអមាត្យ នៃព្រះរាជា គឺជាអ្នកដែលប្រកបដោយគុណរាស់ដោយឥស្សរិយយស ដូចជាឥស្សរិយយសរបស់ព្រះរាជា ។

ពាក្យថា ពួកតិរ្ថិយ គឺពួកអ្នកបួសក្រៅព្រះពុទ្ធសាសនាដែលមានការឃើញវិបរិត ។ ពាក្យថា ពួកសាវកតិរ្ថិយ គឺអ្នកដែលសេពគប់ពេញទំហឹង ជាអ្នកឲ្យបច្ច័យពួកតិរ្ថិយទាំងឡាយនោះ ។ ពាក្យថា ដោយភាពស្និទ្ធស្នាលមិនសមគួរ គឺអ្នកស្និទ្ធស្នាលនៅដោយភាពដែលមិនសមគួរ គឺជាសត្រូវដល់សិក្ខាទាំង ៣ ដែលជាហេតុនាំឲ្យអន្តរាយដល់ព្រហ្មចារ្យ ឬសេចក្តីវិនាសដល់ធម៌ជាគ្រឿងដុសខាត់ ។

ឥឡូវនេះកាលនឹងសម្តែងគោចរដោយបរិយាយដទៃទៀត ទើបលោកពោលពាក្យជាដើមថា **យានិ វា បន តានិ** ដូច្នេះ ។

ក្នុងបណ្តាពាក្យទាំងឡាយនោះ ពាក្យថា មិនមានសទ្ធា មានន័យថា វៀរចាកសទ្ធាក្នុងព្រះពុទ្ធជាម្ចាស់ជាដើម ។ ព្រោះហេតុនោះឯងទើបឈ្មោះថា មិនជ្រះថ្លា,ម្យ៉ាងទៀត ព្រោះមិនជឿកម្ម និងផលរបស់

កម្ម ទើបឈ្មោះថា អ្នកមិនមានសទ្ធា ។ ព្រោះមិនមានសេចក្ដីជ្រះថ្លា ក្នុងព្រះរតនត្រ័យ ទើបឈ្មោះថា អ្នកមិនជ្រះថ្លា ។

ពាក្យថា អ្នកចូលចិត្តជេរ ចូលចិត្តបរិភាស មានន័យថា អ្នកជេរដោយអក្កោសវត្ថុ និងគំរាមកំហែងដោយការសម្ដែងឲ្យភ័យ ។

ឈ្មោះថា អ្នកប្រាថ្នាសេចក្ដីវិនាស ព្រោះអត្ថថា មិនប្រាថ្នាប្រយោជន៍ ប្រាថ្នាតែសេចក្ដីវិនាសតែប៉ុណ្ណោះ ។ ឈ្មោះថា អ្នកប្រាថ្នាការមិនទំនុកបម្រុង ព្រោះអត្ថថា មិនប្រាថ្នាការទំនុកបម្រុង ប្រាថ្នាការមិនទំនុកបម្រុងតែម្យ៉ាង ។ ឈ្មោះថា អ្នកប្រាថ្នាសេចក្ដីមិនជាសុខ ព្រោះអត្ថថា មិនប្រាថ្នាសេចក្ដីជាសុខ ប្រាថ្នាតែសេចក្ដីទុក្ខតែម្យ៉ាង ។

ឈ្មោះថា អ្នកប្រាថ្នាភាពមិនក្សេមចាកយោគៈ ព្រោះអត្ថថា មិនប្រាថ្នាភាពក្សេមចាកយោគៈ គឺការមិនមានភ័យ ប្រាថ្នាតែភាពមិនក្សេមចាកយោគៈ តែម្យ៉ាង ។ ក្នុងពាក្យថា ដល់ភិក្ខុទាំងឡាយនេះរួមយកទាំងសាមណេរផង ។ ក្នុងពាក្យថា ដល់ភិក្ខុនីទាំងឡាយនេះរួមយកទាំងសិក្ខមានា និងសាមណេរីផង ។ ពាក្យនេះសម្ដែងដល់ភាពជាអ្នកប្រាថ្នាសេចក្ដីវិនាសសម្រាប់អ្នកកាន់សាសនាគ្រប់ជំពូក ។ ពាក្យថា ត្រកូលបែបនោះ គឺត្រកូលមានខត្តិយត្រកូលជាដើមដូច្នេះ ។ ពាក្យថា រមែងសេព គឺថា អាស្រ័យចិញ្ចឹមជីវិត ។ ពាក្យថា រមែងគប់រក គឺចូលទៅរក ។ ពាក្យថា រមែងចូលទៅអង្គុយជិត គឺចូលទៅ

រករឿយៗ ។ ពាក្យថា នេះហៅថា មានន័យថា នេះគឺស្ត្រីពេស្យាជាដើម ១, ព្រះរាជាជាដើម ១, ត្រកូលដែលមិនមានសទ្ធាជាដើម ១ ។ ឈ្មោះថា អគោចរ ព្រោះអត្ថថា ជាគោចរដែលមិនសមគួរ ទាំង ៣ ប្រការ សម្រាប់ភិក្ខុដែលសេពនូវគោចរនោះ ៗ ។

ក្នុងបណ្ដាអគោចរទាំងឡាយនេះ ស្ត្រីពេស្យាជាដើម ឈ្មោះថា អគោចរ ព្រោះជាទីអាស្រ័យនៃកាមគុណ ៥ ។ ដូចដែលទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយអ្វីជាអគោចរ ជាវិស័យដទៃរបស់ភិក្ខុនោះ គឺកាមគុណ ៥ ដូច្នេះ ។ ព្រះរាជាជាដើមជាអគោចរ ព្រោះមិនជាឧបនិស្ស័យនៃសមណធម៌ និងព្រោះជាហេតុនៃទិដ្ឋិវិបត្តិ ព្រោះត្រូវផ្ដេកបន្ទោរបំបែក គឺលាភ និងសក្ការៈ ។ ត្រកូលដែលមិនមានសទ្ធាជាដើម ឈ្មោះថា អគោចរ ព្រោះនាំមកនូវសេចក្ដីសន្ដោសនៃចិត្តជាហេតុឲ្យវិនាសសទ្ធា ។

ក្នុងនិទ្ទេសនៃគោចរ គប្បីជ្រាបពាក្យ មានពាក្យថា មិនមានស្ត្រីពេស្យាក្នុងគោចរជាដើមដោយអំណាចពាក្យផ្ទុយគ្នាជាមួយពាក្យដែលបានពោល នោះ ។

ពាក្យថា អណ្ដូងទឹក បានដល់ ដូចស្ពានទីល្ហមទីងចុះបានតាមសប្បាយ ដូចជាស្រះបោក្ខរណីដែលគេជីកទុកសម្រាប់ភិក្ខុសង្ឃ និងភិក្ខុនីសង្ឃក្នុងផ្លូវបំបែកទាំង ៤ ។ ពាក្យថា រុងរឿងដោយសំពត់

កាសាវពស្ត្រ មានន័យថា មានពន្ទឺតែមួយដូចគ្នា ដោយពន្ទឺនៃសំពត់កាសាវពស្ត្រដែលភិក្ខុ និងភិក្ខុនីដណ្តប់នោះឯង ។ពាក្យថា មានខ្យល់នៃឥសីផាត់ទៅមក មានន័យថា មានខ្យល់កើតពីចីវរ មានខ្យល់កើតពីសរីរៈនៃឥរិយាបថ មានការបត់ចូល និងលាតចេញជាដើម ធ្វើឲ្យកើតរបស់ពួកឥសី ពោល គឺភិក្ខុ និងភិក្ខុនីដែលចូលទៅកាន់ផ្ទះ និងចេញទៅ ផាត់ទៅមក គឺបក់តិចៗ ឬកម្ចាត់សេចក្តីអាក្រក់ចេញទៅ ។

ឥឡូវនេះ ដើម្បីសម្តែងនូវអាចារគោចរក្នុងន័យដែលបានពោលមកហើយក្នុងនិទ្ទេស ទើបផ្តើមពាក្យថា **អបិច** ជាដើម ។ បទថា **ឯត្ថ** មានន័យស្មើនឹង **ឯតស្មឹ យោគ បាតិមោក្ខសីលនិទ្ទេសេ** ប្រែថា ក្នុងបាតិមោក្ខសីលនិទ្ទេសនេះ ។ ពាក្យថា ដោយន័យនេះ មានន័យថា តាមវិធីដែលកំពុងពោលក្នុងខណៈនេះ ។ បទថា **សង្ឃគតោ** ប្រែថា ទៅកាន់ទីប្រជុំសង្ឃ ។ **បទថា អចិត្តីការកតោ** ប្រែថា មិនធ្វើសេចក្តីកោតក្រែង អធិប្បាយថា មិនធ្វើសេចក្តីគោរព ។ ពាក្យថា ជ្រៀត មានន័យថា ជ្រៀតដោយរាងកាយ ឬដោយចីវរ ។ គប្បីភ្ជាប់សេចក្តីថា សូម្បីឈរនៅខាងមុខ ក៏មិនធ្វើសេចក្តីកោតក្រែង ។ពាក្យថា ឈរនិយាយខ្វះមានន័យថា ឈរនិយាយនៅក្នុងទីជិត ដូចជាឈរនិយាយខ្ពស់ជាងលោក ។ បទថា **ពាហា វិក្ខេបកោ** គឺគ្រវីដៃទៅមក ។ បទថា **អនុបាហនានំ** ជាឆដ្ឋីវិភត្តិ ចុះក្នុង **អនាទរ** ។ បទថា **សឧបាហនោ**

ប្រែថា ពាក់ស្បែកជើង ។ ពាក្យថា ជ្រៀតភិក្ខុដែលជាថេរៈ មានន័យថា ចូលទៅកាន់កន្លែងដែលភិក្ខុជាថេរៈកំពុងឈរ គឺចូលទៅជិតភិក្ខុជាថេរៈទាំងឡាយយ៉ាងកៀក ។ដាក់អុសចូលទៅក្នុងក្អមភ្លើង ។រមែងដាក់ឧសចូលទៅក្នុងចង្ក្រានភ្លើង ។ពាក្យថា ចៀស មានន័យថា ឈានចេញទៅម្ខាងផ្លូវ ។បន្ទប់តូច ជាបន្ទប់សម្ងាត់ ដោយសភាពគេបិទទុក គឺបាំងទុកដោយរាំងនទ និងជញ្ជាំងជាដើម ។

បទថា **អនាបុច្ឆា** ប្រែថា មិនជម្រាបលា ។

បទថា **អស្ស ឃោគ អនាចារស្ស** ( នៃអនាចារនោះ ) ។

ពាក្យថា ន័យម្យ៉ាងទៀត ភិក្ខុជាដើម ជាពាក្យក្នុងអដ្ឋកថាដែលប្រព្រឹត្តទៅហើយ ព្រោះទាក់ទងនឹងការសម្តែងអាចាររបស់ភិក្ខុក្នុងទីទាំងពួងតែម្យ៉ាង មិនមែនព្រះបាលីក្នុងគម្ពីរនិទ្ទេស ។ គរុភាព ឬការធ្វើឲ្យធ្ងន់ ឈ្មោះថា សេចក្តីគោរព ជាហេតុនៃគុណមានសទ្ធា សីល សុតៈ និងចាគៈជាដើម, ឈ្មោះថា អ្នកមានសេចក្តីគោរព ព្រោះអត្ថថា ប្រព្រឹត្តទៅជាមួយដោយសេចក្តីគោរពនិងសេចក្តីកោតក្រែងជាដើមក្នុងគរុដ្ឋានិយបុគ្គលទាំងឡាយ ឈ្មោះថា សេចក្តីកោតក្រែង បានដល់ការបដិបត្តិរបស់អ្នកដែលមានសេចក្តីកោតក្រែង ។ ឈ្មោះថា អ្នកមានសេចក្តីកោតក្រែង ព្រោះអត្ថថា ប្រព្រឹត្តទៅជាមួយសេចក្តីកោតក្រែង ។ ឈ្មោះថា ដល់ព្រមដោយហិរិ និងឱត្តប្បៈ ព្រោះមានចិត្ត

ខ្លាស និងព្រោះមាន សេចក្ដីខ្លាចក្រែងយ៉ាងវិសេស ។ ឈ្មោះថា គ្រងរៀបរយ ឃុំរៀបរយ ដោយអំណាចនៃសេក្ខិយធម៌ ។

បទថា **បាសាទិកេន** ប្រែថា នាំមកនូវសេចក្ដីជ្រះថ្លា ។ ឯបទនេះ ជា តតិយាវិភត្តិចុះក្នុង **ឥត្ថម្ភូតលក្ខណៈ** ។ សូម្បីក្នុងបទ ៦ បទ បន្ទាប់ពីបទនេះ ក៏មានន័យដូចគ្នា ។

បទថា **អភិក្កន្តេន** ប្រែថា មានការឈានទៅ ។

បទថា **ឥរិយាបថសម្បន្នោ** ប្រែថា ដល់ព្រមដោយឥរិយាបថ ។

ដោយបទនោះលោកពោលថា សូម្បីឥរិយាបថដ៏សេសក៏គួរជ្រះថ្លា ។ ពាក្យថា រក្សាទ្វារក្នុងឥន្ទ្រីយ៍ទាំងឡាយ មានន័យថា មានការរក្សាចាត់ចែងទុកល្អ ហើយក្នុងទ្វារទាំង ៦ មានចក្ខុន្ទ្រីយ៍ជាដើម ។

ពាក្យថា ដឹងប្រមាណក្នុងភោជន មានន័យថា ដឹងប្រមាណដោយប្រការទាំងពួង ទាក់ទងដោយការស្វែងរក ការទទួល និងការបរិភោគជាដើម នូវបច្ច័យទាំង ៤ យ៉ាង ដែលដឹងថា ភោជន ព្រោះជារបស់សម្រាប់បរិភោគ ។

បទថា ប្រកបរឿយៗ នូវជាគរិយធម៌ មានន័យថា ប្រកបហើយរឿយៗគឺប្រកបហើយប្រកបទូទៅហើយនូវជាគរិយធម៌ការមនសិការភាវនាក្នុងខាងដើមនៃរាត្រី និងខាងចុងនៃរាត្រី គឺប្រកបហើយ ខ្វល់ខ្វាយហើយក្នុងជាគរិយធម៌ នោះ ។

បទថា ប្រកបដោយសតិសម្បជញ្ញៈជាដើម ជាពាក្យសម្ដែង ចំពោះអង្គនៃអាចារតាមដែលបានពោលហើយ ។ ក្នុងបទទាំងឡាយនោះ ពាក្យថា ប្រាថ្នាតិច គឺមិនមានសេចក្ដីប្រាថ្នា ។ ពាក្យថា សន្ដោស គឺរីករាយហើយតាមរបស់ដែលមាន ព្រោះជាសន្ដោស មានយថាលាភសន្ដោសជាដើម ។ ពាក្យថា ធ្វើដោយគោរព មានន័យថា មានប្រក្រតីធ្វើដោយការយកចិត្តទុកដាក់ ។ ពាក្យថា ច្រើនទៅដោយការគោរព និងកោតក្រែង មានន័យថា ច្រើនទៅដោយការធ្វើសេចក្ដីគោរពក្នុងគរុដ្ឋានិយបុគ្គលទាំងឡាយ ។ ពាក្យថា នេះហៅថាអាចារ មានន័យថា នេះ គឺភាពជាអ្នកមានសេចក្ដីគោរពជាដើមហៅថា អាចារ ព្រោះបុគ្គលដែលប្រាថ្នានូវប្រយោជន៍ទាំងឡាយ គប្បីប្រព្រឹត្តដោយយកចិត្តទុកដាក់ ។ គោចរដែលជាទីចូលទៅអាស្រ័យនៃគុណទាំងឡាយមានសីលជាដើម ឈ្មោះថា **ឧបនិស្សយគោចរ** ។ គោចរដែលជាគ្រឿងរក្សាចិត្ត ពោល គឺសតិនោះឯង ឈ្មោះថា **អារក្ខគោចរ** ។ គោចរដែលជាគ្រឿងចូលទៅចងចិត្តទុក ពោល គឺកម្មដ្ឋាន ឈ្មោះថា ឧបនិពន្ធគោចរ ។ កល្យាណមិត្តដែលប្រកបដោយគុណ ដែលជាវត្ថុនៃកថា ដែលអាស្រ័យវិវដ្ដៈ ១០ មានភាពជាអ្នកប្រាថ្នាតិចជាដើម ឈ្មោះថា អ្នកប្រកបដោយគុណ គឺកថាវត្ថុ ១០ ។ ព្រោះប្រកបដោយកថាវត្ថុ ១០ នោះឯងបុគ្គលទើបឈ្មោះថា កល្យាណមិត្ត ព្រោះអត្ថថា

ជាមិត្តមានគុណ ដែលបណ្ឌិតគប្បីរាប់រក គឺជាមនុស្សល្អ ។ លក្ខណៈរបស់កល្យាណមិត្តនោះនឹងមានមកខាងមុខ ។

វត្ថុដែលមិនធ្លាប់បានស្តាប់ បានដល់ **នវង្គសត្ថុសាសន៍** មានសុត្តៈ និងគេយ្យៈជាដើម ។ បទថា រមែងបានស្តាប់ មានន័យថា រមែងញ៉ាំងសុតមយញ្ញាណឲ្យកើតឡើង ។ ពាក្យថា ធ្វើវត្ថុដែលធ្លាប់បានស្តាប់ហើយឲ្យប្រាកដច្បាស់ មានន័យថា រមែងញ៉ាំងសុតមយញ្ញាណនោះៗ តាមដែលបានស្តាប់ហើយ នៅមិនទាន់ជាក់ច្បាស់ ព្រោះមិនទាន់លះបង់ឲ្យហ្មត់ចត់ គឺធ្វើមិនឲ្យខ្វល់ខ្វាយ មិនឲ្យស្រពេចស្រពិលដោយវិធីការពិនិត្យខុសត្រូវជាដើមរឿយៗ ម្យ៉ាងទៀត ក្នុងធម៌ទាំងឡាយនោះ ធម៌ទាំងឡាយណានៅជាទីតាំងនៃសេចក្តីសង្ស័យ ក៏កាត់សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយនោះចេញបាន ទើបឈ្មោះថា ធ្វងសេចក្តីសង្ស័យបាន ។ រមែងធ្វើទិដ្ឋិឲ្យត្រង់ដោយការធ្វើសេចក្តីយល់ត្រូវក្នុងកម្ម និងផលរបស់កម្ម និងក្នុងព្រះរតនត្រ័យឲ្យត្រង់ ។ ហើយបន្ទាប់ពីនោះឯង រមែងញ៉ាំងចិត្តឲ្យជ្រះថ្លាដោយសទ្ធាសម្បទាទាំង ២ យ៉ាង ។

ន័យម្យ៉ាងទៀត កាលញ៉ាំងធម៌តាមដែលបានស្តាប់ហើយ ឲ្យជាក់ច្បាស់ កំណត់រូបធម៌ និងអរូបធម៌ ដែលមកហើយតាមធម៌ដែលបានស្តាប់ហើយនោះ កំណត់នាម និងរូប ព្រមទាំងបច្ច័យបាន

ក៏ឈ្មោះថា ធ្វើការឃើញត្រង់ ព្រោះកម្ចាត់ការវៀចវេរនៃទិដ្ឋិថា ជាសត្វ ចេញបាន ។ ព្រោះឃើញអាការត្រឹមតែថា ធម៌ទាំងឡាយជាបច្ច័យ និងកើតពីបច្ច័យ ឈ្មោះថា ឆ្លងសេចក្តីសង្ស័យ ក្នុងអទ្ធាទាំង ៣ ចេញបាន ។

ហើយខាងមុខបន្ទាប់ពីនោះចម្រើនវិបស្សនាដោយឧទយព្វយ-ញ្ញាណជាដើម ចុះកាន់អរិយភូមិ ទើបឈ្មោះថា ញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះរតនត្រ័យដោយសេចក្តីជ្រះថ្លាមិនកម្រើក ។ បុគ្គលជាយ៉ាង នោះឯង រមែងមិនវិនាសចាកគុណទាំងឡាយមានសទ្ធាជាដើម ដោយ ការសិក្សាតាមកល្យាណមិត្តនោះឯង នឹងចម្រើនឡើងទៅតែម្យ៉ាងជា ប្រាកដ ។ ព្រោះហេតុនោះ ទើបលោកពោលថា សិក្សាតាមកល្យាណ មិត្តនោះ ដូច្នេះជាដើម ។

ពាក្យថា លង្វែកផ្ទះ មានន័យថា ចូលទៅកាន់គោចរគ្រាម តាមដែលមាន ឈ្មោះថា លង្វែកផ្ទះ ព្រោះអត្ថថា មានផ្ទះជាចន្លោះៗ ឬគោចរគ្រាមនេះមានក្នុងរវាងផ្ទះនោះ ( តាមលំដាប់ផ្ទះ ) ។ ភិក្ខុដើរ ទៅតាមថ្នល់ដើម្បីស្វែងរកភិក្ខាតែ ១ ផ្ទះៗ ក្នុងគោចរគ្រាមនោះ ។

ពាក្យថា មានចក្ខុសំយុងចុះ គឺសម្លឹងភ្នែកចុះក្រោម ។ លោក ពោលថា សម្លឹងមើលមួយជួរនឹម ក៏ដើម្បីជៀសវាងពាក្យសួរថា ដោយ អាការមានត្រឹមណា ទើបឈ្មោះថា មានចក្ខុសំយុងចុះ ។

ពាក្យថា សង្រួម គឺរវាំង ។ ក្នុងទីនេះដោយអាការយ៉ាងណា ទើបឈ្មោះថា ជាអ្នកសង្រួមហើយ, ដើម្បីសម្ដែងអាការនោះ ទើបលោកពោលថា មិនសម្លឹងមើលពលដីរ ដូច្នេះជាដើម ។

បទថា **យត្ថ** មានន័យស្មើនឹង **យេសុ យោគ សតិប្បដ្ឋានេសុ** ប្រែថា ក្នុងសតិប្បដ្ឋានពួកណា ។ ចិត្ត គឺភាវនាចិត្ត ។ បទថា **ឧប-និពន្ធតិ** ប្រែថា នាំចូលទៅចងទុក ។

ដូចពាក្យបុរាណាចារ្យពោលទុកថា នរជនក្នុងលោកនេះ ពេលហ្វឹកហាត់កូនគោ គប្បីចងទុកនឹងបង្គោលយ៉ាងណា ភិក្ខុក៏ដូចគ្នា គប្បីចងចិត្តរបស់ខ្លួនទុក ឲ្យមាំក្នុងអារម្មណ៍ដោយសតិ ។

ដើម្បីសម្ដែងភាពនៃសតិប្បដ្ឋានដែលជាឧបនិពន្ធគោចរដោយព្រះសូត្រ ទើបលោកអាចារ្យពោលថា សមដូចពាក្យដែលព្រះសាស្ដាពោលទុក ដូច្នេះជាដើម ។

ក្នុងបណ្ដាពាក្យទាំងឡាយនោះ ត្រើនពាក្យថា ធម៌ដែលជាវិស័យនៃបិតារបស់ខ្លួន មានន័យថា ធម៌ដែលជាវិស័យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលជាបិតារបស់ខ្លួន, ដែលព្រះអង្គទ្រង់ឃើញហើយទ្រង់សម្ដែងហើយ ។ពាក្យថាមានប្រមាណតិចគឺមានប្រមាណតិចយ៉ាងក្រៃលែង ។ បទថា **អសព្ពិច្ច អាបន្នសេក្ខិយអកុសលចិត្ត-ប្បាទាទិភេទេសុ** បណ្ឌិតគប្បីឃើញសព្ទ **អសព្ពិច្ច** ជាវិសេសនៈ

របស់ **សេក្ខិយ** យ៉ាងនេះថា **អសញ្ចិច្ច អាបន្នសេក្ខិយេសុ អកុ-សលចិត្តុប្បាទាទិភេទេសុ** ។ ក្នុងទីនេះ ដោយស័ព្ទថា សេក្ខិយ លោកកាន់យកសុប្បវត្តជាដើមថា វត្តដែលមានមកក្នុងវត្តខន្ធកជាដើម ។

ព្រោះវត្តទាំងឡាយនោះ លោកក៏ប្រាថ្នាថាជា **សេក្ខិយ** ដោយអត្ថថា គួរសិក្សា ។ ពិតយ៉ាងនោះ ក្នុងមាតិកា ព្រះមានព្រះភាគទ្រង់មិនបានធ្វើការកំណត់សេក្ខិយវត្តទុកដូចជាបារាជិកជាដើម ។

ក៏ព្រោះធ្វើអធិប្បាយយ៉ាងនេះ សព្ទថា **អសញ្ចិច្ច** ថា **អសញ្ចិច្ច-អាបន្នសេក្ខិយា** (សេក្ខិយវត្តដែលមិនតាំងចិត្តកន្លង) រមែងសម្រេច ។

ក្នុងសេក្ខិយវត្ត ៧៥ ដែលមកក្នុងមាតិកា ឈ្មោះថា **នោសញ្ញាវិមោក្ខ** មិនអាចរកបាន, ក្នុងអធិការនេះ ដោយ អសញ្ចិច្ច-ស័ព្ទនោះឯងលោកសង្គ្រោះយកការមិនមានសតិ និងការមិនដឹងទុក្ខផងដែរ ។

តែអាចារ្យពួកខ្លះពោលទុកក្នុងរឿងនេះថា ដោយស័ព្ទថា មិនតាំងចិត្តកន្លង លោកកាន់យកអាបត្តិដែលជា **អចិត្តកៈ**, ពាក្យនោះត្រឹមតែជាមតិអាចារ្យពួកនោះ ព្រោះក្នុងបណ្ដាគរុកាបត្តិ អាបត្តិខ្លះជាអចិត្តកៈក៏មាន, ព្រោះក្នុងទីនេះ ទ្រង់សំដៅយកទោសស្រាលជាងទោសទាំងអស់ដែលនឹងត្រូវសម្ដែងឡើង ដោយការអធិដ្ឋាន គឺតាំងចិត្តសង្រួមតទៅ ឬសម្ដែងដោយការសម្ដែងអាបត្តិចេញ ។ ព្រោះដូច្នោះទើបលោកពោលថា **យានិ តានិ វជ្ជានិ អប្បមត្តកានិ ឱរមត្តកានិ**

លហុកានិ លហុសម្មតានិ ជាដើម ។ ( ទោសទាំងឡាយនោះណា មានប្រមាណតូច មានប្រមាណស្រាល ដឹងថាស្រាល ) ។ ដោយ អាទិ-ស័ព្ទ គប្បីឃើញការសង្គ្រោះទោសដែលមិនដល់ភាពជាអាបត្តិ ដែលមិនគប្បីឈានកន្លង ដើម្បីភាពបរិសុទ្ធិនៃបាតិមោក្ខសំវរសីល ។ ពាក្យថា មានប្រក្រតីឃើញភ័យ មានន័យថា មានសភាពឃើញទោស ដែលមានប្រមាណតូចយ៉ាងក្រៃលែង ហាក់ដូចប៉ុនភ្នំសិនេរុ ដែល មានកម្ពស់ ៦.៨០០.០០០ យោជន៍ ឬមានសភាព ឃើញអាបត្តិ ត្រឹមទុក្កដសិត ដែលមានទោសស្រាលជាងអាបត្តិទាំងពួង ធ្វើឲ្យដូច អាបត្តិបារាជិក ។

ពាក្យថា សីលយ៉ាងណាមួយ គឺសីលដែលនឹងគប្បីសិក្សា ដែល គប្បីបដិបត្តិ ដែលគប្បីបំពេញខ.ណាមួយដែលចែកជាមូលប្បញ្ញត្តិ អនុប្បញ្ញត្តិ សព្វត្ថប្បញ្ញត្តិ បទេសប្បញ្ញត្តិជាដើម ។ ពាក្យថា កាន់ យកដោយល្អ បានដល់ កាន់យកហើយ ដោយល្អនោះឯង គឺដោយ គោរព និងដោយប្រការទាំងពួង ។

សួរថា ការដល់ព្រមដោយអាចារគោចរនេះ ទាក់ទងក្នុងបាតិ-មោក្ខសំវរ សីល ឬមិនទាក់ទង ?

ឆ្លើយថា ទាក់ទង ។

បើយ៉ាងនោះ ហេតុអ្វីទើបត្រូវពោលថា ដល់ព្រមដោយអាចារ

និងគោចរទុកទៀត លោកអាចារ្យពោលពាក្យថា ក្នុងអធិការនៃ
បាតិមោក្ខសំវរនេះជាដើម សំដៅយកពាក្យក្រើនរំលឹកទុកទៀត ។

( ចប់មហាដីកា )

( ចប់ បាតិមោក្ខសំវរសីល )

.....................................

# ឥន្ទ្រិយសំវរសីល

ចំណែកសីលណា ដែលទ្រង់ត្រាស់ទុកថា ភិក្ខុនោះឃើញរូបដោយចក្ខុហើយ ជាអ្នកមិនកាន់យកនិមិត្ត មិនកាន់យកអនុព្យញ្ជនៈ អភិជ្ឈា ទោមនស្សទាំងឡាយ ធម៌ទាំងឡាយដែលជាបាប ជាអកុសល នឹងគប្បីហូរទៅតាមភិក្ខុ ដែលមិនសង្រួមចក្ខុន្ទ្រីយ៍ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រីយ៍ណា រមែងបដិបត្តិដើម្បីបិទនូវចក្ខុន្ទ្រីយ៍នោះ រក្សាចក្ខុន្ទ្រីយ៍នោះ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រីយ៍, អ្នកស្តាប់សំឡេងដោយសោតៈហើយ ។ល។ ធុំក្លិនដោយឃានៈហើយ ។ល។ លិទ្ធរសដោយជិវ្ហាហើយ ។ល។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយហើយ ។ល។ ដឹងធម្មារម្មណ៍ដោយមនៈហើយ មិនកាន់យកនិមិត្ត មិនកាន់យកអនុព្យញ្ជនៈ ដល់នូវការសង្រួមក្នុងមនិន្ទ្រីយ៍ ដូច្នោះ សីលនេះ ឈ្មោះថា **ឥន្ទ្រិយសំវរសីល** ។

ចំណែកឥន្ទ្រិយសំវរសីលណា ដែលព្រះមានជោគទ្រង់សម្តែងទុកដោយន័យថា ភិក្ខុនោះឃើញរូបដោយចក្ខុដូច្នេះជាដើម ក្នុងលំដាប់នៃបាតិមោក្ខសំវរសីល គប្បីជ្រាបវិនិច្ឆ័យក្នុងឥន្ទ្រិយសំវរសីលនោះដូចតទៅនេះ :

បទថា ភិក្ខុនោះ បានដល់ ភិក្ខុដែលតាំងនៅក្នុងបាតិមោក្ខសំវរ

សីលនោះ ។

ពាក្យថា ឃើញរូបដោយចក្ខុ មានន័យថា ឃើញរូបដោយចក្ខុវិញ្ញាណ ។ ដែលអាចក្នុងការឃើញរូប បានវោហារថា ចក្ខុដោយអំណាចភាពជាហេតុពិតហើយ បុរាណាចារ្យទាំងឡាយពោលទុកថា ចក្ខុរមែងមិនឃើញរូប ព្រោះចក្ខុមិនមានចិត្តសូម្បីចិត្តក៏មិនឃើញរូប ព្រោះចិត្តមិនមានចក្ខុ តែពេលដែលទ្វារជាមួយអារម្មណ៍ខ្ទប់គ្នា បុគ្គលរមែងឃើញរូបដោយចិត្ត មានចក្ខុបសាទជាទីតាំង ពាក្យនិយាយដូច្នេះ ឈ្មោះថា សសម្ភារកថា ដូចកថាក្នុងពាក្យថា បាញ់ដោយធ្នូជាដើម ( សសម្ភារកថា ប្រែថា ពាក្យនិយាយមានសម្ភារៈ គឺមានអង្គប្រកប ទើបមានន័យគ្រប់គ្រាន់ ដូចពាក្យថា បាញ់ដោយធ្នូ សម្ភារៈរបស់ពាក្យនេះ គឺកូនសរ ព្រោះបើមិនមានកូនសរ ក៏បាញ់មិនបាន តែពេលដែលបាញ់កូនសរចេញទៅពីធ្នូហើយ ក៏និយាយថា បាញ់ដោយធ្នូ ជាការស្តាប់គ្នាបានយ៉ាងណា ពាក្យថា ឃើញរូបដោយចក្ខុ មានសម្ភារៈ គឺចក្ខុវិញ្ញាណ ) ព្រោះហេតុនោះ សេចក្តីថា ឃើញរូបដោយចក្ខុវិញ្ញាណនេះ នោះឯងជាការសម្គាល់ក្នុងពាក្យថា ឃើញរូបដោយចក្ខុនោះ ។ បទថា **ន និមិត្តគ្គាហី** មានន័យថា រមែងមិនកាន់យកនិមិត្តថា ស្ត្រី ឬបុរស ឬនិមិត្តដែលជាទីតាំងរបស់កិលេសមានសុភនិមិត្តជាដើមគិតហើយ ក្នុងអាការត្រឹមតែឃើញប៉ុណ្ណោះ ។

បទថា **នានុព្យញ្ជនគ្គាហី** មានន័យថា រមែងមិនកាន់យកអាការផ្សេងៗ មានដៃ ជើង ក្បាល ការសើច ការចរចា ការនិយាយម្រិកម្រ៉ក់ និងការក្រឡេកមើលជាដើម ដែលបានវោហារថា អនុព្យញ្ជនៈ ឈ្មោះថា អនុព្យញ្ជនៈ ព្រោះជាគ្រឿងធ្វើកិលេសទាំងឡាយឲ្យប្រាកដ វត្ថុណាលេចធ្លោក្នុងសរីរៈនោះ ក៏កាន់យកវត្ថុនោះ ( ជាអារម្មណ៍ ) ដូចព្រះមហាតិស្សត្ថេរនៅចេតិយបព៌តដូច្នោះ ។

## រឿងព្រះមហាតិស្សត្ថេរ

មានដំណាលមកថា ស្ត្រីកូនប្រសារត្រកូលមួយឈ្លោះគ្នាជាមួយស្វាមី ក៏តុបតែង និងប្រដាប់កាយស្អាតហើយ ដូចជាទេពកញ្ញាចេញពីអនុរាធបុរៈតាំងពីព្រលឹមដើរទៅកាន់ផ្ទះរបស់ញាតិ ក្នុងរវាងផ្លូវ បានជួបព្រះមហាតិស្សត្ថេរ ដែលនិមន្តចេញពីចេតិយមហាបព៌តមកកាន់អនុរាធបុរៈ ដើម្បីបិណ្ឌបាត ក៏កើតមានចិត្តវិបល្លាសសើចខ្លាំងឡើង ចំណែកព្រះថេរៈក្រឡេកមើលគិតថា នេះជាអ្វី ? ក៏ត្រឡប់បានអសុភសញ្ញាក្នុងធ្មេញរបស់ស្ត្រីនោះ ហើយបានសម្រេចព្រះអរហត្ត ។

ព្រោះហេតុនោះ ព្រះបុរាណាចារ្យទើបពោលទុក ( ជាគាថា ) ថា ព្រះថេរៈឃើញធ្មេញរបស់ស្ត្រីនោះហើយ ត្រឡប់រលឹកដល់

សញ្ញាចាស់ លោកឈរនៅក្នុងទីនោះឯង បានសម្រេចព្រះអរហត្ត ។

ចំណែកស្វាមីរបស់នាងដើរតាមមកជួបព្រះថេរៈ ចូលទៅសួរថា លោកដ៏ចម្រើន លោកមានឃើញស្ត្រីខ្លះឬទេ ? ព្រះថេរៈពោលនឹងគេថា អាត្មាមិនឃើញថាស្ត្រី ឬបុរសដើរទៅអំពីទីនេះទេ តែថាគ្រោងឆ្អឹងនោះកំពុងដើរទៅកាន់ផ្លូវធំ ។

ក្នុងពាក្យថា **យត្វាធិករណមេនំ** ជាដើម មានវិនិច្ឆ័យថា ធម៌ទាំងឡាយ មានអភិជ្ឈាជាដើមទាំងឡាយនោះ គប្បីហូរទៅតាម គឺគប្បីជាប់តាមបុគ្គលនោះ ដែលមិនសង្រួមចក្ខុន្ទ្រីយ៍ គឺជាអ្នកដែលមិនបិទចក្ខុទ្វារ ដោយបន្ទះទ្វារ គឺសតិ ដោយហេតុណា គឺព្រោះហេតុនៃការមិនសង្រួមចក្ខុន្ទ្រីយ៍ណា សេចក្ដីថា រមែងបដិបត្តិដើម្បីឃាំងនូវចក្ខុន្ទ្រីយ៍នោះ មានន័យថា រមែងបដិបត្តិដើម្បីបិទចក្ខុន្ទ្រីយ៍នោះដោយបន្ទះទ្វារ គឺសតិ, ភិក្ខុបដិបត្តិយ៉ាងនោះ លោកពោលថា រមែងរក្សាចក្ខុន្ទ្រីយ៍ខ្លះ រមែងដល់ព្រមដោយការសង្រួមក្នុងចក្ខុន្ទ្រីយ៍ខ្លះ ។

ពាក្យថា ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រីយ៍នោះ គប្បីជ្រាបថាតាមពិត ការសង្រួម ឬមិនសង្រួមក៏ដោយ ក្នុងចក្ខុន្ទ្រីយ៍ក៏ទេ ព្រោះសតិក្ដី ការវង្វេងភ្លេចសតិក្ដី មិនបានអាស្រ័យចក្ខុបសាទកើតឡើងនោះទេ ម្យ៉ាងទៀត ក្នុងពេលដែលរូបារម្មណ៍មកកាន់គន្លងចក្ខុ ពេលភវង្គចិត្តកើតរលត់ ២ ខណៈហើយ **មនោធាតុ** ដែលជាកិរិយាឲ្យ

សម្រេចអាវជ្ជនកិច្ច ( កិច្ច គឺការនឹកពាវរកអារម្មណ៍ ) កើតឡើងហើយរលត់ទៅ បន្ទាប់ពីនោះ ចក្ខុវិញ្ញាណឲ្យសម្រេចទស្សនកិច្ច ( គឺកិច្ចឃើញ ) កើតឡើងហើយរលត់ទៅ បន្ទាប់ពីនោះមនោធាតុជាវិបាកឲ្យសម្រេចសម្បដិច្ឆន្នកិច្ច ( កិច្ច គឺការទទួលអារម្មណ៍ ) កើតឡើងហើយរលត់ទៅ បន្ទាប់ពីនោះ មនោវិញ្ញាណធាតុដែលជាអហេតុកវិបាកឲ្យសម្រេចសន្តីរណកិច្ច ( កិច្ច គឺការពិចារណា ) កើតឡើងហើយរលត់ទៅបន្ទាប់មកមនោវិញ្ញាណធាតុដែលជាអហេតុកកិរិយាឲ្យសម្រេចវោដ្ឋព្វនកិច្ច ( គឺការកំណត់យក ) កើតឡើងហើយ រលត់ទៅ, ក្នុងលំដាប់នោះជវនចិត្តទើបស្ទុះទៅ ការសង្រួម ឬមិនសង្រួមក៏ដោយ ក្នុងសម័យទាំងឡាយនោះ គឺក្នុងភវង្គសម័យក៏មិនមាន ក្នុងបណ្តាសម័យនៃវិថីចិត្ត មានអាវជ្ជនៈជាដើម សម័យណាមួយក៏មិនមានឡើយ តែថា ក្នុងខណៈនៃជវនចិត្ត បើការទ្រុស្តសីលក្តី ការវង្វេងភ្លេចសតិក្តី ការមិនដឹងក្តី ការមិនអត់ធន់ក្តី ការខ្ជិលច្រអូសក្តី កើតឡើង ការមិនសង្រួមក៏មានឡើង ការមិនសង្រួម ដែលមានឡើងយ៉ាងនេះនោះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា

ការមិនសង្រួមក្នុងចក្ខុន្ទ្រិយ៍ ព្រោះហេតុអ្វី ? ព្រោះហេតុថាពេលការមិនសង្រួមនោះមានហើយ សូម្បីទ្វារក៏មិនបានឃុំគ្រង សូម្បីភវង្គចិត្ត សូម្បីវិថីចិត្ត មានអាវជ្ជនៈជាដើម ក៏មិនបានឃុំគ្រង ( ទៅ

តាមគ្នា ) ប្រៀបដូចអ្វី ? ប្រៀបដូចទ្វារព្រះនគរទាំង ៤ ទិស ដែលបុគ្គលមិនបានរាំងហើយ សូម្បីខាងក្នុងផ្ទះ ស៊ុមទ្វារ និងបន្ទប់ជាដើម ដែលបុគ្គលរាំងល្អហើយក៏ដោយ វត្ថុរបស់របរទាំងអស់ក្នុងព្រះនគរ ក៏ឈ្មោះថា មិនបានរក្សា មិនបានឃុំគ្រងផងដែរ ព្រោះពួកចោរ នឹងចូលទៅតាមទ្វារព្រះនគរ ហើយកាន់យកវត្ថុដែលខ្លួនត្រូវការបាន យ៉ាងណាពេលការទ្រុស្តសីលជាដើមកើតឡើងក្នុងជវនចិត្តក៏ដូច្នោះ ដូចគ្នា ពេលការមិនសង្រួមនោះមានហើយ សូម្បីទ្វារក៏ឈ្មោះថា មិនបានឃុំគ្រង សូម្បីភវង្គចិត្ត សូម្បីវិថីចិត្តមានអាវជ្ជនៈជាដើមក៏ឈ្មោះថា មិនបានឃុំគ្រង តែពេលសំវរ មានសីលសំវរជាដើម កើតឡើងក្នុងជវនចិត្តនោះហើយ សូម្បីទ្វារក៏បានឃុំគ្រង សូម្បីភវង្គចិត្ត សូម្បីវិថីចិត្តមានអាវជ្ជនៈជាដើមក៏បានឃុំគ្រងហើយ ប្រៀបដូចអ្វី ?ប្រៀបដូចទ្វារព្រះនគរដែលបុគ្គលរាំងល្អហើយ សូម្បីក្នុងផ្ទះជាដើម គេមិនបានរាំងក៏ដោយ វត្ថុរបស់របរទាំងអស់ក្នុងព្រះនគរ ក៏ឈ្មោះថា បានឃុំគ្រងល្អហើយទាំងអស់ ព្រោះកាលបើទ្វារព្រះនគរបិទហើយ ពួកចោរក៏មិនមានប្រកចូលបានយ៉ាងណាពេលសំវរមានសីលសំវរ ជាដើម កើតឡើងក្នុងជវនចិត្ត ក៏ដូច្នោះ ដូចគ្នា សូម្បីទ្វារក៏បានឃុំគ្រង ហើយ សូម្បីភវង្គចិត្ត សូម្បីវិថីចិត្តមានអាវជ្ជនៈជាដើម ក៏បានឃុំគ្រង ហើយ ព្រោះដូច្នោះ ការសង្រួមពេលកើតឡើងនៅក្នុងខណៈនៃជវន

ទើបព្រះមានព្រះភាគត្រាស់ថា ការសង្រួមក្នុងចក្ខុន្ទ្រីយ៍ សូម្បីក្នុងន័យថា ស្តាប់សំឡេងដោយត្រចៀកជាដើម ក៏មានន័យដូចគ្នា សីលដែលបរិយាយមកយ៉ាងនេះបណ្ឌិតគប្បីជ្រាបដោយសង្ខេបថា ឈ្មោះថា ឥន្ទ្រិយសំវរសីល ដែលមានការវៀរចាកការកាន់យកនិមិត្ត ដែលកិលេសជាប់តាមជាអាទិ៍ ក្នុងរូបជាដើម ជាលក្ខណៈ ។

# មហាដីកា

# ឥន្ទ្រិយសំវរសីល

*បទថា សោ យោគ បាតិមោក្ខសំវរសីលេ បតិដ្ឋិតភិក្ខុ ប្រែថា ភិក្ខុដែល តាំងនៅក្នុងបាតិមោក្ខសំវរសីលនោះ ។*

*ដោយបទថា សោ នោះ ព្រះមានព្រះភាគទ្រង់សម្ដែងដល់ ប្រភេទភិក្ខុ ដែលគប្បីប្រាថ្នានូវឥន្ទ្រិយសំវរសីលនោះ ។ ពាក្យថា ដោយចក្ខុ ទ្រង់សម្ដែងដល់ចក្ខុ ជាដែននៃសំវរ ។*

*ពាក្យថា រូប ទ្រង់សម្ដែងដល់រូបដែលជាទីតាំងនៃសំវរ ។*

*ពាក្យថា ឃើញហើយជាអ្នកមិនកាន់យកនិមិត្ត មិនកាន់យក អនុព្យញ្ជនៈ ទ្រង់សម្ដែងដល់ឧបាយនៃសំវរ ។*

*ពាក្យថា អភិជ្ឈាទោមនស្សទាំងឡាយ ធម៌ទាំងឡាយដែល ជាបាបអកុសលនឹងហូរទៅតាមភិក្ខុដែលមិនសង្រួមចក្ខុន្ទ្រីយ៍ ព្រោះ ហេតុមិនសង្រួមចក្ខុន្ទ្រីយ៍ណា ទ្រង់សម្ដែងធម៌ដែលជាបដិបក្ខដល់ សំវរ និងទោសក្នុងធម៌ដែលជាបដិបក្ខដល់សំវរនោះ ។ ពាក្យថា រមែងបដិបត្តិដើម្បីសំវរ ទ្រង់សម្ដែងដល់សតិជាធម៌ ដែលគប្បីចូល ទៅតាំងទុកតែម្យ៉ាង ។ ពាក្យថា រមែងរក្សាចក្ខុន្ទ្រីយ៍ ទ្រង់សម្ដែងថា ការឃាំងចក្ខុន្ទ្រីយ៍គឺការញ៉ាំងសតិឲ្យចូលទៅតាំងទុកនោះឯង ។ ពាក្យ*

ថា រមែងដល់ការសង្រួមក្នុងចក្ខុន្ទ្រីយ៍ ទ្រង់សម្តែងថា សតិនោះឯង ជាយ៉ាងនោះ ជាសំវរក្នុងចក្ខុន្ទ្រីយ៍នោះ ។

## ពណ៌នាឥន្ទ្រិយសំវរសីល

*ឥន្ទ្រិយសំវរសីល* ជាអង្គនៃបាតិមោក្ខសំវរសីល ពេលមានឥន្ទ្រិយសំវរសីលនោះហើយ ទើបគួរប្រាថ្នាក្នុងបាតិមោក្ខសំវរសីលនោះ ដូច្នោះ ទើបលោកពោលទុកថាពាក្យថា ភិក្ខុនោះ បានដល់ ភិក្ខុតាំងនៅក្នុងបាតិមោក្ខសំវរសីលនោះ កាលបើឥន្ទ្រិយសំវរសីលនេះ ភិក្ខុធ្វើឲ្យដល់ព្រមហើយ បាតិមោក្ខសំវរសីល រមែងឃុំគ្រងល្អហើយ រក្សាល្អហើយតែម្យ៉ាង ដូចស្រូវសំណាបដែលគេ ការពារទុកល្អ ហើយដោយរបងបន្ទា ។

បទថា **ការណាវសេន** មានន័យថា ដោយអំណាចនៃហេតុដែលមិនទូទៅ ។

ផល បុគ្គលរមែងអាងបានដោយអំណាចហេតុដែលមិនទូទៅ, ដូចជាពន្ទក ស្រូវដំណើប សំឡេងស្គរ ដូច្នោះឯង ។

ម្យ៉ាងទៀត ពាក្យនេះប្រាប់ដល់វត្ថុដែលអាស្រ័យដោយនិស្សយវោហារ ដូចជាគ្រែហៅ (ធម្មតាគ្រែមិនហៅ មនុស្សនៅលើគ្រែហៅ គ្រែជាទីអាស្រ័យ មនុស្សជាអ្នកអាស្រ័យ) ដូច្នោះ ។ រូប បានដល់

រូបាយតនៈ ។ ពាក្យថា **ឃើញរូបដោយចក្ខុ** នេះ បើចក្ខុឃើញរូបបានមែន, សូម្បីបុគ្គលដែលព្រមព្រៀងដោយវិញ្ញាណដទៃក៏នឹងឃើញរូបបាន, តែមិនមែនមានដូច្នោះ, ព្រោះហេតុអ្វី ? ព្រោះចក្ខុមិនមានចិត្ត ។ ហេតុនោះ ទើបលោកពោលថា ចក្ខុមិនឃើញរូប ព្រោះមិនមានចិត្ត បើវិញ្ញាណអាចឃើញរូបបានមែន ក៏នឹងឃើញរូបនោះ ដែលនៅខាងក្រៅ ជញ្ជាំងជាដើមបាន ព្រោះមិនមានអ្វីបិទបាំង, សេចក្តីនេះក៏មិនមាន ព្រោះវិញ្ញាណគ្រប់ជួងមិនមានការឃើញ, ព្រោះហេតុនោះទើបលោកពោលថា ចិត្តរមែងមិនឃើញរូបព្រោះមិនមានចក្ខុ ។ ក្នុងពាក្យថា ឃើញរូបដោយចក្ខុនោះ មានន័យថា វិញ្ញាណដែលអាស្រ័យចក្ខុរមែងឃើញបាន វិញ្ញាណដទៃៗ ឃើញមិនបាន ។ ហើយវិញ្ញាណនោះរមែងមិនកើតក្នុង កន្លែងដែលត្រូវវត្ថុមានជញ្ជាំងជាដើម យ៉ាងណាមួយ យាំងទុកដែលជាកន្លែងបាំងពន្លឺ ។ តែក្នុងទីណាដែលមិនបាំងពន្លឺដូចជាស្ថានទីដែលមានដំបូល បន្ទប់ធ្វើដោយកែវផលិកជាដើមក្នុងទីនោះ សូម្បីត្រូវវត្ថុបាំងវិញ្ញាណក៏នៅកើតឡើងបានដែរ សេចក្តីនេះយ៉ាងណា, ចក្ខុដែលវិញ្ញាណអាស្រ័យរមែងឃើញបាន, ចក្ខុ តែឯកឯង មិនឃើញដោយប្រការនោះ ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា ឃើញរូបដោយចក្ខុដូច្នេះទ្រង់សំដៅយកចក្ខុដែលវិញ្ញាណអាស្រ័យ ។ ពាក្យថា ពេលទ្វារជាមួយអារម្មណ៍ប៉ះគ្នា មានន័យថា

ពេលទ្វារប៉ះជាមួយអារម្មណ៍មានហើយ អធិប្បាយថា ពេលរូបារម្មណ៍មកកាន់គន្លងចក្ខុ ។

ពាក្យថា ដោយចិត្តមានចក្ខុបសាទជាទីតាំង មានន័យថា ដោយវិញ្ញាណ ដែលមានចក្ខុបសាទជាទីតាំង គឺអាស្រ័យចក្ខុបសាទនោះប្រព្រឹត្តទៅហើយ, ហៅថា ចក្ខុវិញ្ញាណ ។

ពាក្យថា រមែងឃើញ គឺរមែងមើលឃើញ ។ ពេលវិញ្ញាណមានចក្ខុបសាទជាទីអាស្រ័យនៃការចាំងចុះនឹងរូបារម្មណ៍ ដែលពន្លឺឧបត្ថម្ភហើយ ដោយគុណដែលជាទីអាស្រ័យរបស់ខ្លួន បុគ្គលដែលព្រមព្រៀងដោយវិញ្ញាណនោះ ទើបលោកពោលថា ឃើញរូបដូច្នោះ ។

ការចាំងចុះក្នុងទីនេះ គឺការធ្វើអារម្មណ៍ឲ្យជាក់ច្បាស់តាមសភាវៈ ដែលហៅថា កាន់យកដោយប្រចក្ស ។ ពេលការឃើញរូបដោយចក្ខុវិញ្ញាណសម្រេច, បុគ្គលទើបឈ្មោះថា ឃើញរូបដោយចក្ខុដូចជាពេលការបាញ់រន្ធដោយកូនសរសម្រេចក៏មានពាក្យនិយាយថា បុគ្គលបាញ់ដោយធ្នូ ជាអង្គប្រកបរបស់កូនសរនោះ ព្រោះហេតុនោះ ពាក្យដូច្នេះនេះ ទើបឈ្មោះថា **សសម្ភារកថា** ។ ពាក្យមានអង្គប្រកប ឈ្មោះថា សសម្ភារកថា អធិប្បាយថា ប្រកបដោយហេតុនៃការឃើញ ។ ម្យ៉ាងទៀត ការនិយាយចំពោះការឃើញដែលមាន

អង្គប្រកប ក៏ឈ្មោះថា សសម្ភារកថា ។ ពាក្យថា ព្រោះហេតុនោះ មានន័យថា ព្រោះការឃើញរូបដោយចក្ខុសុទ្ធៗ ឬដោយវិញ្ញាណសុទ្ធៗ មិនមាន ព្រោះហេតុណា គឺព្រោះហេតុនោះ ។

ក្នុងពាក្យថា និមិត្តថាស្ត្រី ឬបុរស មានន័យថា រូបរាងសណ្ឋានដែលបុគ្គលប្រកាន់យកសំដៅចំពោះរូបក្តី ភាពមានសាច់ដោះកំពុងក្តី ភាពដែលមាត់ មិនមានពុកមាត់ក្តី ការចងសក់ និងការប្រើសំពត់ក្តី ឥរិយាបថ មានការឈរ ការដើរមិនអង់អាចជាដើមក្តី ទាំងអស់ អាស្រ័យសន្តានរបស់ស្ត្រី ។ ឈ្មោះថា និមិត្ត ថាស្ត្រី ព្រោះជាហេតុនៃការដឹងច្បាស់ថា ស្ត្រី ។និមិត្តថាជាបុរសគប្បីជ្រាបដោយបរិយាយផ្ទុយគ្នាពីពាក្យដែលពោលហើយ ។គប្បីជ្រាបគ្រឿងសម្គាល់ថា ក្នុងពាក្យថា ឬនិមិត្តមានសុភនិមិត្តជាដើមនេះអាការដែលគួរប្រាថ្នាដែលជាហេតុឲ្យកើតរាគៈ ឈ្មោះថា សុភនិមិត្ត ។ ដោយបទ អាទិ-ស័ព្ទ រួមទាំងបដិឃនិមិត្តជាដើមផង ។ បដិឃនិមិត្តនោះ គប្បីជ្រាបថា ជាអាការដែលមិនគួរប្រាថ្នាជាដើម គឺជាហេតុឲ្យកើតទោសៈជាដើម ។

ក្នុងអធិការនេះ អភិជ្ឈា និងទោមនស្សប៉ុណ្ណោះ ដែលមកក្នុងព្រះបាលីតាមសភាពពិត, សូម្បីយ៉ាងនោះ ក៏ត្រូវរួមយកទាំងឧបេក្ខានិមិត្តទុកផងដែរ ព្រោះសូម្បីមោហៈដែលកើតឡើងដោយការសម្លឹងមិនជានិច្ចកាល ក៏ជាការមិនសង្រួមបាន ។ ពិតហើយ លោកអាចារ្យ

ពោលថា ការវង្វេងសតិក្តី ការមិនដឹងក្តី ដូច្នេះ ។ ម្យ៉ាងទៀត ក្នុងពាក្យថា ឧបេក្ខានិមិត្តនេះបានដល់អារម្មណ៍ដែលជាទីតាំងនៃអញ្ញាណុបេក្ខា ( ការព្រងើយ គឺការមិនដឹង ) ១, សញ្ញាណុបេក្ខានោះ គប្បីជ្រាប ព្រោះការសម្លឹងអារម្មណ៍នោះមិនជានិច្ចកាល ។ លោកអាចារ្យពោលចំពោះហេតុនៃរាគៈ ទោសៈនិងមោហៈ ។ ដោយសភាពយ៉ាងនេះថា មានសុភនិមិត្តជាដើម ដូច្នេះ ។

ដោយហេតុនោះ ទើបលោកពោលថា និមិត្តជាទីតាំងរបស់កិលេស ។

ពាក្យថា **រមែងតាំងនៅក្នុងអាការត្រឹមតែឃើញប៉ុណ្ណោះ** មានន័យថា រមែងតាំងនៅក្នុងវណ្ណាយតនៈដែលត្រឹមតែចក្ខុវិញ្ញាណ និងវិថីចិត្តទាំងឡាយកាន់យកប៉ុណ្ណោះ តាមន័យដែលទ្រង់ត្រាស់ទុកក្នុងព្រះសូត្រថា ពេលឃើញក៏ត្រឹមតែឃើញ មិនកំណត់អាការ មានភាពស្អាតជាដើម យ៉ាងណាមួយដទៃពីនោះ ។

ពាក្យថា **ព្រោះធ្វើការប្រាកដ** មានន័យថា ព្រោះធ្វើឲ្យប្រាកដ គឺធ្វើឲ្យឃើញច្បាស់ ។ ព្រោះថា ពេលបុគ្គលកំណត់ដោយភាពស្អាតជាដើមនូវអវយវៈ មានដៃជាដើមនៃវិសភាគវត្ថុ កិលេសដែលកើតឡើងក្នុងអវយវៈទាំងឡាយនោះហើយៗ រឿយៗ ក៏នឹងប្រាកដច្បាស់ឡើង ព្រោះហេតុនោះ អវយវៈទាំងឡាយនោះ ទើបឈ្មោះថា អនុ-

ព្យញ្ជនៈ នៃកិលេសទាំងឡាយនោះ ។

តែព្រោះអវយវៈទាំងឡាយនោះ ជាអាការដែលភូតរូប និងឧបាទាយរូបដែលអាស្រ័យគ្នាហើយដោយប្រការនោះៗ អាស្រ័យគ្នាជានិច្ច ។ វៀរលែងអាការនោះចេញ មិនមានអាការណាៗ ឈ្មោះថាដៃជាដើមដោយបរមត្ថ, ព្រោះដូច្នោះ ទើបលោកពោលថា មិនកាន់យកអាការផ្សេងៗ មានដៃ ជើង ក្បាល ការសើច ការចរចា ការនិយាយម្រិកម្រ៉ក់ និងការក្រឡេកមើលជាដើម ។

លោកពោលថា ក្នុងសរីរៈនោះ វត្ថុណាមានពិត ក៏កាន់យកវត្ថុនោះ ដូច្នោះ ក៏ដើម្បីជៀសវាងពាក្យសួរថា នឹងកាន់យកយ៉ាងណា? ន័យម្យ៉ាងទៀត កាន់យកអាការត្រឹមតែថា ភូតរូប និងឧបាទាយរូបមានសក់ ក្រចកជាដើម ដែលមាននៅក្នុងសរីរៈនេះប៉ុណ្ណោះ តាមពិតលោកអាចារ្យកាល សម្ដែងតួយ៉ាងនៃការកាន់យកនូវអាការមិនស្អាតក្នុងសរីរៈនោះ ទើបនាំយករឿងរបស់ព្រះមហាតិស្សត្ថេរមកសម្ដែងដោយពាក្យមានជាអាទិ៍ថា ព្រះតិស្សត្ថេរ ដែលនៅក្នុងចេតិយបរពតជាដើម ។

ក្នុងពាក្យទាំងឡាយនោះ ពាក្យថា សុមណ្ឌិតបសាធិតា មានន័យថា តុបតែងហើយ ប្រដាប់ហើយដោយល្អ ។ អាចារ្យទាំងឡាយពោលថា ការប្រើវត្ថុមានគ្រឿងអាភរណៈជាដើម តែងខ្លួន ។ ឈ្មោះ

ថា **មណ្ឌន** ប្រែថា តុបតែង ។ ការតុបតែងរាងកាយដោយវិធី មានការខាត់ស្បែកជាដើម ឈ្មោះថា **បសាធន** ប្រែថា តុបតែង ឬប្រដាប់, ម្យ៉ាងទៀត ការប្រើគ្រឿងអាភរណៈទាំងឡាយ និងគ្រឿងតុបតែងមានគ្រឿងអលង្ការ គឺសំពត់ជាដើម តែងខ្លួន ឈ្មោះថា **បសាធន** ។

ការតុបតែងឲ្យគ្រប់គ្រឿង ឈ្មោះថា **មណ្ឌន** ។

ពាក្យថា មានចិត្តវិបល្លាស គឺមានចិត្តវិបរិតទៅដោយអំណាចរាគៈ ។

ពាក្យថា ក្រឡេកមើល មានន័យថា ព្រះថេរៈមានការធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាននោះឯង និមន្តទៅក្រឡេកមើលដោយគិតថា នេះគឺអ្វី តាមសំឡេងសើច ព្រោះការមនសិការដែលជាបុព្វភាគ មានសំឡេងជាសត្រូវ ។

ពាក្យថា **អសុភសញ្ញា** បានដល់ អដ្ឋិកសញ្ញា ។

ពិតហើយ ខណៈនោះព្រះថេរៈកំពុងបរិហារអដ្ឋិកកម្មដ្ឋាន ។

ពាក្យថា សម្រេចអរហត្ត មានន័យថា បានឮថា ព្រះថេរៈបានបដិភាគនិមិត្តនិងឧបចារឈានដ៏ប្រសើរ ព្រោះបុព្វភាគភាវនា លោកបានចម្រើនល្អហើយ ដោយការឃើញឆ្អឹងធ្មេញរបស់ស្ត្រីនោះ ដែលសើចនៅទីនោះឯង កំពុងឈរនៅតាមប្រក្រតី ក៏សម្រេចបឋមជ្ឈាននៅទីនោះ ធ្វើឈាននោះឲ្យជាបាទ ចម្រើនវិបស្សនា សម្រេចអាស-

វគ្គយៈ តាមលំដាប់មគ្គ ។

ពាក្យថា ត្រឡប់រលឹកដល់សញ្ញាចាស់ មានន័យថា រលឹកដល់រឿយៗ គឺប្រមូលមកនូវអដ្ឋិកកម្មដ្ឋានចាស់ តាមដែលសន្សំហើយ គឺដែលតាមប្រកបគ្រប់ពេល ។ ពាក្យថា **អនុមគ្គំ** ប្រែថា តាមផ្លូវ គឺតាមដានជើងរបស់ស្ត្រី បានឮថា សរីរៈទាំងអស់របស់ស្ត្រីនោះ ប្រាកដដោយភាពជាគ្រោងឆ្អឹង ដោយការឃើញឆ្អឹងធ្មេញនោះឯង ព្រោះព្រះថេរៈមានការជំនាញក្នុងភាវនា ។ ព្រះថេរៈមិនសម្គាល់ថា គ្រោងឆ្អឹងនោះជាស្ត្រី ឬបុរស ។ ព្រោះដូច្នោះ ទើបលោកពោលថា អាត្មាភាពមិនដឹងថា ស្ត្រី ឬបុរសដើរទៅពីទីនេះ តែថា គ្រោងឆ្អឹងនោះកំពុងដើរទៅកាន់ផ្លូវធំ ដូច្នេះ ។

លោកអាចារ្យពោលថា ព្រោះហេតុ មិនសង្រួមចក្ខុន្ទ្រីយ៍ណាហើយពោលទៀតថា ដើម្បីត្រូវការបិទនូវចក្ខុន្ទ្រីយ៍នោះ ដោយសន្ទះទ្វារ គឺសតិ មិនបានពោលថា (ព្រោះហេតុ) នៃការមិនសង្រួមដូច្នេះ។ ពាក្យនេះ លោកអធិប្បាយទុកថា ព្រះមានព្រះភាគទ្រង់សម្តែងអំពីការហូរទៅនៃអភិជ្ឈាជាដើម ព្រោះហេតុនៃការមិនសង្រួមចក្ខុន្ទ្រីយ៍ណា,ទ្រង់សម្តែងអំពីការហូរទៅនៃអភិជ្ឈានោះជាដើមថា ប្រព្រឹត្តទៅព្រោះហេតុនៃការមិនសង្រួមចក្ខុន្ទ្រីយ៍នោះឯង ។ ពិតហើយ ចក្ខុន្ទ្រីយ៍ជាហេតុនៃការហូរទៅនូវអភិជ្ឈាជាដើម តាមផ្លូវចក្ខុទ្វារ ដូចជាហេតុ

នៃវិញ្ញាណដែលប្រកបតាមទ្វារនោះៗ ។ ពេលការមិនសង្រួមចក្ខុន្ទ្រីយ៍មានហើយ អភិជ្ឈាជាដើមទាំងឡាយនោះ រមែងហូរទៅជានិច្ច ព្រោះដូច្នេះ ការមិនសង្រួមនោះ មានហេតុមកពីការមិនសង្រួមចក្ខុន្ទ្រីយ៍ ទើបលោកពោលទុកដូច្នេះឯង ។ ព្រោះពាក្យថា **យត្វាធិករណំ** មានន័យថា ព្រោះហេតុនៃចក្ខុន្ទ្រីយ៍ណា ។ សួរថា ព្រោះហេតុនៃចក្ខុន្ទ្រីយ៍ប្រភេទណា ? ឆ្លើយថា ព្រោះហេតុនៃចក្ខុន្ទ្រីយ៍ ដែលមិនសង្រួម ។ សួរថា មិនសង្រួមយ៉ាងណា ? ឆ្លើយថា ព្រោះហេតុ មិនសង្រួមចក្ខុន្ទ្រីយ៍ណា អភិជ្ឈាជាដើម ទើបហូរទៅតាម គឺប្រការដែលបុគ្គលចូលទៅកាំងការហូរទៅនៃអភិជ្ឈាជាដើមនោះ ដើម្បីសង្រួមនូវចក្ខុន្ទ្រីយ៍នោះ ពាក្យប្រកបសេចក្ដីក្នុងអធិការនេះ មានដូចពោលមកនេះឯង ។

ពាក្យមានជាអាទិ៍ថា តែក្នុងខណៈនៃជវនចិត្ត ។

ពាក្យថា ជាអ្នកទ្រុស្ដសីលក្ដី ដូច្នេះទាំងអស់លោកពោលទុកក្នុងចក្ខុទ្វារនេះប៉ុណ្ណោះ ដើម្បីមិនពោលទៀត ព្រោះហេតុនោះទ្វារទាំង ៦ គប្បីជ្រាបតាម ដែលកើតបានដោយប្រការដូច្នេះ ។ ព្រោះថា ការទ្រុស្ដសីល គឺកាយទុច្ចរិត និងវចីទុច្ចរិតមិនមានក្នុងទ្វារ ៥, ដូច្នេះ គប្បីប្រកបការមិនសង្រួម គឺការទ្រុស្ដសីល ទាក់ទងក្នុងមនោទ្វារ, អសំវរដ៏សេស ទើបប្រកបជាមួយទ្វារ ៦ ។ ពិតហើយ ភាពជាអ្នកវង្វេង

ភ្លេចសតិជាដើម អាចមានការកើតឡើងបានតាមទ្វារទាំង ៥ ព្រោះអកុសលជាបដិបក្ខចំពោះសតិជាដើម, ចំណែកភាពជាអ្នកទ្រុស្តសីលដែលជាការកន្ទង់ល្មើសផ្លូវកាយ និងវាចា មិនមានការកើតក្នុងទ្វារទាំង ៥ ទេ ។ ព្រោះជវ័ន ដែលប្រព្រឹត្តទៅតាមទ្វារទាំង ៥ មិនអាចញ៉ាំងវិញ្ញត្តិឲ្យកើតបានទេ ។ អសំវរទាំង ៥ មានការទ្រុស្តសីលជាដើម លោកពោលទុកជាបដិបក្ខចំពោះសំវរទាំង ៥ មានសីលសំវរជាដើមក្នុងទីនេះ ។ ពីរបទថា **តស្មឹ សតិ** ប្រែថា ពេលអសំវរនោះមានហើយ ។

ពាក្យថា **ប្រៀបដូចអ្វី** មានន័យថា អសំវរពេលកើតឡើងក្នុងជវ័ន លោកហៅថា ការមិនសង្រួមក្នុងចក្ខុន្ទ្រិយ៍ ដោយប្រការណា, តួយ៉ាងនៃប្រការនោះយ៉ាងណា ដោយពាក្យថា **ប្រៀបដូច** ជាដើម លោកអាចារ្យសម្តែងភាពស្មើគ្នាថា ពេលមិនសង្រួមយ៉ាងហ្នឹង ក៏ជាហេតុមិនសំវរយ៉ាងហ្នឹងទៅ គឺថា ពេលអសំវរមាននៅក្នុងជវ័នធម្មជាតិមានទ្វារជាដើម ដែលសម្ពន្ធជាមួយជវ័ននោះ ក៏មិនសង្រួមដូចជាពេលដែលមានការមិនរក្សាព្រះនគរ ទព្វសម្ភារៈមានផ្ទះជាដើមដែលសម្ពន្ធជាមួយនគរនោះ ក៏មិនរក្សាផងដែរ មិនមែនសម្តែងភាពស្មើគ្នានៃខាងដើមនិងខាងចុងឬភាពស្មើគ្នាទាំងខាងក្នុងនិងខាងក្រៅនោះទេ ។

ម្យ៉ាងទៀត ពេលទ្វារ និងភវង្គជាដើមមានហើយ ជវនដែលកើតឡើងនោះ លោកពោលថា ដូចជាទ្វារព្រះនគរ ព្រោះធ្វើឲ្យដូចជានៅខាងក្រៅ, ចំណែកក្រៅពីនេះ លោកពោលថា ដូចជាខាងក្នុងនគរ ។ ព្រោះថា ភវង្គដើម ដែលសម្រេច ហើយក្នុងកាលមុន ដោយភាពជាបច្ច័យ សូម្បីមិនមានក្នុងកាលនៃជវន ក៏ឈ្មោះថា **មាន** ព្រោះផលកើតឡើង ដូចជាចក្ខុជាដើម ។ ព្រោះថា លុះត្រាតែធម្មជាតិដែលទ្រទ្រង់មាន ទើបហៅថា មានក៏ទេ ។ ឯពាក្យថា ព្រោះធ្វើឲ្យដូចជាខាងក្រៅ ខ្ញុំម្ចាស់ពោលទុក ព្រោះធ្វើអធិប្បាយថា ពេលជវនជាខាងក្រៅ និងពេលធម្មជាតិក្រៅពីនេះ ជាខាងក្នុង សូម្បីមិនមានដោយបរមត្ថ ជវនដែលចរមក ដែលកើតឡើងក្នុងគ្រាខ្វះជាខាងក្រៅ និងធម្មជាតិក្រៅពីនេះ មានសភាពខុសគ្នាជាមួយជវននោះ ជាខាងក្នុងរមែងមិនបានដោយបរិយាយណាមួយ ព្រោះព្រះបាលីមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ ចិត្តនេះផូរផង់ ចិត្តនេះឯងត្រូវឧបក្កិលេសដែលចរមកធ្វើឲ្យសៅហ្មង ដូច្នេះឯង ។ ម្យ៉ាងទៀត ព្រោះពេលអសំវរកើតឡើងក្នុងជវនៈ បន្ទាប់ពីជវនៈនោះ ធម្មជាតិមានទ្វារ និងភវង្គជាដើម ក៏ដល់ភាពជាហេតុនៃអសំវរ ។ ធម្មជាតិមានទ្វារ និងភវង្គជាដើម ជាហេតុនៃអសំវរនោះ រមែងដឹងបានដោយការកើតឡើងនៃអសំវរ ព្រោះហេតុនោះ ការដែលចោរ គឺភាពជាអ្នកទ្រុស្តសីល

ជាដើម ចូលទៅតាមផ្លូវជវនដែលប្រៀបដូចជាទ្វារនគរ ប្ញទំនៅត្រង់ទ្វារ និងភវង្គជាដើម លោកពោលថា ជាការទម្លាយ ភណ្ឌៈ គឺកុសល ។ អសំវរកើតឡើងត្រង់ទ្វារណា អសំវរនោះ រមែងប្រព្រឹត្តទៅ ក្នុងទ្វារនោះចូលទៅកាត់ចេញនូវធម្មជាតិ មានទ្វារជាដើម ដែលជាឧបនិស្ស័យនៃសំវរដូច្នេះឯង ។ គប្បីឃើញការជាប់គ្នានៃធម្មជាតិ មានទ្វារនិងភវង្គជាដើមជាមួយជវនៈដោយការទាក់ទងនៅក្នុងសន្តតិតែមួយ ។

ក្នុងអធិការនេះ ពេលរូបារម្មណ៍ប្រាកដតាមផ្លូវចក្ខុទ្វារ ពេលកុសលជវន និងអកុសលជវនកើតឡើង ៧ ខណៈ ទាក់ទងដោយហេតុ មានធម្មជាតិដែលកំណត់ទុកជាដើម ហើយធ្លាក់ចុះកាន់ភវង្គពេលជវនតាមផ្លូវមនោទ្វារកើតឡើង ៧ ខណៈ ដូចគ្នាក្នុងអារម្មណ៍នោះៗ តាមសមគួរដល់ជវន តាមផ្លូវចក្ខុទ្វារនោះ ហើយចុះកាន់ភវង្គជវនអាស្រ័យអារម្មណ៍នោះឯង តាមទ្វារនោះឯងទៀត កំណត់ដោយន័យជាដើមថា ស្ត្រី បុរស ស្មុះទៅ ៧ ខណៈ ដោយអំណាចសេចក្តីជ្រះថ្លា ឬសេចក្តីស្រឡាញ់ជាដើម ។ លោកអាចារ្យសំដៅយកជវនដែលប្រព្រឹត្តទៅយ៉ាងនេះជានិច្ច ទើបពោលពាក្យមានជាអាទិ៍ថា ពេលការទ្រុស្តសីលជាដើម កើតឡើងក្នុងជវនចិត្ត កាលការមិនសង្រួមនោះ មានហើយ សូម្បីទ្វារ ក៏ឈ្មោះថា មិនបានរក្សា ដូច្នេះ ។

តស្មឹ យោគ ជវនេ ប្រែថា ក្នុងជវននោះ ។ ពាក្យថា ពេលសំវរ

មានសីលជាដើម មានន័យថា ពេលសីលសំវរ សតិសំវរ ញាណសំវរ ខន្តិសំវរ និងវីរិយសំវរ កើតឡើងហើយ ។ ដូចជាពេលបុគ្គលមិនចូលទៅតាំងធម៌សម្រាប់សង្រួម គឺសតិទុកជាមុន គប្បីជ្រាបថា ការទ្រុស្តសីលជាដើម កើតឡើងបានយ៉ាងណា, ពេលចូលទៅតាំងធម៌សម្រាប់សង្រួម គឺសតិទុកមុន គប្បីជ្រាបថា សីលជាដើម កើតឡើងបានដូច្នេះ ។ សូម្បីក្នុងអារម្មណ៍ មានសំឡេងជាដើម ក៏គប្បីជ្រាបថា និមិត្ត និងអនុព្យញ្ជនៈតាមសមគួរ ។

បុគ្គលស្តាប់សំឡេងដោយសោតវិញ្ញាណហើយ មិនកាន់យកនិមិត្តថា សំឡេងស្ត្រី សំឡេងបុរស ឬនិមិត្តដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ដែលជាទីតាំងនៃកិលេស រមែងត្រឹមតែឮក្នុងសំឡេងដែលខ្លួនបានស្តាប់ហើយប៉ុណ្ណោះ ។ ទាំងមិនកាន់យកអាការនៃសំឡេងចម្រៀងជាដើម ។ ដោយភាពផ្សេងពីគ្នា មានសំឡេងដែលកើតពីឋានទាំង ៦ ( សំឡេងសត្វក្ងោក ) ជាដើម ដែលកំណត់ជាសំឡេងស្រាលជាង ( គេ ) ជាដើម ដែលបានវោហារថា អនុព្យញ្ជនៈ ព្រោះញ៉ាំងនូវកិលេសឲ្យប្រាកដ ។ សូម្បីក្នុងអារម្មណ៍ មានក្លិនជាដើម ក៏គប្បីពោលតាមសមគួរយ៉ាងនេះ ។

ចំណែកផ្លូវមនោទ្វារភវង្គដែលមានអាវជ្ជនៈឈ្មោះថា មនោទ្វារ, បណ្ឌិត គប្បីប្រកបពាក្យដោយន័យមានជាអាទិ៍ថា ពេលធម្មារម្មណ៍

មកប្រាកដតាមទ្វារនោះហើយ ក៏ដឹង គឺជ្រាបអារម្មណ៍នោះ ដោយជវនចិត្តនោះ ដូច្នេះ ។ កិលេសទាំងឡាយដែលជាប់តាម មានហើយដោយសារការកាន់យកនិមិត្តជាដើមនេះ ហេតុនោះ ការកាន់យកនិមិត្តជាដើមនោះឯង ឈ្មោះថា **កិលេសានុពន្ធោ** ប្រែថា មានកិលេសជាប់តាម, ឥន្ទ្រិយសំវរសីល មានការវៀរចាកការកាន់យកនិមិត្តជាដើម ដែលមានកិលេសជាប់តាមនោះ ជាលក្ខណៈ ទើបឈ្មោះថា **កិលេ-សានុពន្ធនិមិត្តាទិគាហបរិវជ្ជនលក្ខណំ** ប្រែថា មានការវៀរចាកការកាន់យកនិមិត្តជាដើម ដែលមានកិលេសជាប់តាម ជាលក្ខណៈ ។

ដោយ **អាទិ**-ស័ព្ទ លោកអាចារ្យប្រមូលយកអនុព្យញ្ជនៈផងដែរ ។

( ចប់ មហាដីកា )

( ចប់ ឥន្ទ្រិយសំវរសីល )

.................................

# អាជីវបារិសុទ្ធិសីល

ចំណែកការវៀរចាកមិច្ឆាជីវៈ ដែលប្រព្រឹត្តទៅដោយអំណាចនៃការល្មើសសិក្ខាបទ ៦ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្ត ព្រោះអាជីពជាហេតុ ព្រោះអាជីព ជាប្រធាន និង ( ដោយអំណាច ) នៃបាបធម៌ទាំងឡាយយ៉ាងនេះ គឺ

១-កុហនា ការលលួង ។

២-លបនា ការបញ្ចោរ ។

៣-នេមិត្តិកតា ការធ្វើនិមិត្ត ។

៤-និប្បេសិកតា ការប្រើសំដីជាខ្នាសកោសយកលាភ ។

៥-លាភេន លាភំ និជិគីសនតា ការស្វែងរកលាភដោយលាភ

ដូច្នេះជាដើម សីលនេះ ឈ្មោះថា អាជីវបារិសុទ្ធិសីល ។

# មហាដីកា

ភ្ជាប់សេចក្ដីថា ដោយអំណាចការល្មើស ( ឈានកន្ទង ) ។

ពាក្យថា សិក្ខាបទ ៦ មានន័យថា សិក្ខាបទ ៦ ៗ គឺដែលសម្បយុត្តដោយបារាជិកាបត្តិជាដើម ដែលមកដោយព្រះបាលីថា **អាជីវហេតុ អាជីវការណា អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបតិ** ជាដើម ភិក្ខុរមែងពោលអួត ឧត្តរិមនុស្សធម៌ដែលមិនមាន ដែលមិនពិត ព្រោះអាជីវៈជាហេតុ ព្រោះអាជីវៈជាប្រធាន ។

ការបោកបញ្ឆោតដោយកុហនាវត្ថុ ៣ យ៉ាង មានការនិយាយបញ្ឆិតបញ្ឆៀងជាដើម ឈ្មោះថា កុហនា ( ការលលួង ) ។

ការពោលលើកសរសើរខ្លួនឯងឬទាយក ដើម្បីឲ្យគេឲ្យរបស់របរផ្សេងៗ ឈ្មោះថា លបនា ( ការពោករ ) ។

ឈ្មោះថា នេមិត្តិក ព្រោះអត្ថថា កាយកម្ម និងវចីកម្មដែលឲ្យកើតការសម្គាល់ថា នឹងឲ្យបច្ច័យ លោកហៅថា និមិត្ត ការប្រព្រឹត្តិដោយនិមិត្តនោះ លោកហៅថា និមិត្តិកតា ( ការធ្វើគរ ) ។

ភិក្ខុរមែងញាំញីដោយការបង្ខិតបង្ខំជាដើម ចំពោះបុគ្គលទាំងឡាយដទៃ ព្រោះលាភ ដូចកិនរបស់ក្រអូបជាដើម ដូច្នេះ ទើបឈ្មោះថា **និប្បេសោ** ។

**និប្បេសោ** នោះឯងជា **និប្បេសិកោ** ភាវៈនៃ និប្បេសិក នោះឈ្មោះថា និប្បេសិកតា ( ការកោស ) ។

ការស្វែងរកលាភរបស់បុគ្គលដទៃ ដោយលាភរបស់ខ្លួនដែលបានហើយ ព្រោះមានសេចក្ដីប្រាថ្នាច្រើន ឈ្មោះថា ការទាក់លាភដោយលាភ ។ លោកសង្គ្រោះយកភាពជាអ្នកនិយាយដោយពាក្យមិនជាទីស្រឡាញ់ និងភាពជាអ្នកបញ្ឆោរជាដើម ដោយ អាទិ-ស័ព្ទ ក្នុងពាក្យថា **ឯវមាទីនំ** ដូច្នេះ ។

( ចប់មហាដីកា )

## ពណ៌នាអាជីវបារិសុទ្ធិសីល

ឥឡូវនេះគប្បីជ្រាបវិនិច្ឆ័យក្នុងអាជីវបារិសុទ្ធិសីលដែលពោលទុកក្នុងលំដាប់នៃឥន្ទ្រិយសំវរសីលតទៅ ពាក្យថា សិក្ខាបទ ៦ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តទុក ព្រោះអាជីវៈជាហេតុ ព្រោះអាជីវៈជាប្រធាន មានន័យថា សិក្ខាបទ ៦ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តទុកយ៉ាងនេះគឺព្រោះអាជីវៈជាហេតុព្រោះអាជីវៈជាប្រធានភិក្ខុក៏មានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ និយាយអួតឧត្តរិមនុស្សធម្មដែលមិនមាន (ក្នុងខ្លួន) ត្រូវអាបត្តិបារាជិក ព្រោះអាជីវៈជាហេតុ ព្រោះអាជីវៈជាប្រធាន ភិក្ខុដល់នូវភាពជាអ្នកនាំដំណឹង ត្រូវអាបត្តិសង្ឃាទិសេស ព្រោះអាជីវៈជាហេតុ ព្រោះអាជីវៈជាប្រធាន ភិក្ខុនិយាយថា ភិក្ខុណានៅក្នុងវិហាររបស់ខ្លួន ភិក្ខុនោះជាព្រះអរហន្ត ដូច្នេះ កាលបើលោកប្តេជ្ញាហើយ ត្រូវអាបត្តិថុល្លច្ច័យ ព្រោះអាជីវៈជាហេតុ ព្រោះអាជីវៈជាប្រធាន, ភិក្ខុមិនមានជំងឺ សុំភោជនដែលប្រណីត ដើម្បីប្រយោជន៍ចំពោះខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ព្រោះអាជីវៈជាហេតុ ព្រោះអាជីវៈជាប្រធាន ភិក្ខុនីមិនមានជំងឺសុំភោជនដែលប្រណីត ដើម្បីប្រយោជន៍ដល់ខ្លួនឯង ត្រូវបាដិ-ទេសនិយ ព្រោះអាជីវៈជាហេតុ ព្រោះអាជីវៈជាប្រធាន, ភិក្ខុមិនមាន

ជំនីសុំសម្ល ឬបាយដើម្បីប្រយោជន៍ដល់ខ្លួនឆាន់ ត្រូវទុក្កដ ដូច្នេះ សេចក្តីទាំងឡាយនេះ យ៉ាងណា ( សំដៅយក ) សិក្ខាបទទាំង ៦ ទាំងឡាយនេះ ។

ក្នុងពាក្យទាំងឡាយ មានពាក្យថា លល្បួង ( កុហនា ) ជាដើម មានព្រះបាលី ដូចតទៅ

បណ្តាកិរិយាទាំងនោះ **ការលល្បួង** តើដូចម្តេច ? ការក្លែងធ្វើមុខចង់ចិញ្ចើម ក្លែងធ្វើឆាកមុខ ឆបោកគេឲ្យវង្វេងវង្វាន់ ដោយវិធីល្បួង ពោល គឺការក្លែងបដិសេធបច្ច័យក្តី ដោយការនិយាយបញ្ចិតបញ្ចៀងក្តី ការក្លែងរៀបឫកពា តាំងឫកពា រៀបឥរិយាបថឲ្យល្អក្តី របស់ភិក្ខុដែលឃើញចំពោះលាភសក្ការៈ និងសេចក្តីសរសើរ មានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា ការលល្បួង ( ក្នុងមហានិទ្ទេសពោលថា **កុហនាវត្ថុ** ( វិធីលល្បួង ) មាន ៣ យ៉ាង គឺ ១ ក្លែងបដិសេធបច្ច័យ, ២ និយាយបញ្ចិតបញ្ចៀង, ៣ ក្លែងធ្វើឥរិយាបថគួរឲ្យជ្រះថ្លា ) ។

បណ្តាកិរិយាទាំងឡាយ **ការបញ្ចោរ** តើដូចម្តេច ? ការនិយាយសាកសួរគេមុន និយាយអួត និយាយយកចិត្តគេ និយាយចង់សម្ពន្ធនឹងគេ និយាយបន្ទំគេ និយាយអែបអបគេ និយាយដាក់ខ្លួន និយាយ (លេងបន្ទំមែន) ដូចសណ្តែកស្ងោរ (និយាយខ្សឹបខ្សៀវដោយសេចក្តី

ស្រឡាញ់) ជាបងចិញ្ចឹមក្មេងយ៉ាងណា របស់ភិក្ខុដែលឃើញចំពោះលាភសក្ការៈ និងសេចក្តីសរសើរមាន សេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា **បញ្ឆោរ** ។

បណ្តាកិរិយាទាំងឡាយនោះ **ភាពជាអ្នកធ្វើនិមិត្ត** តើដូចម្តេច ? ការបួញមាត់ពោលបញ្ចិតបញ្ចៀង និយាយដៀងដង និយាយចាក់ធ្លុះ និយាយស្អាបស្អង់មតិ និយាយល្បួងលួងលោមចំពោះជនដទៃទាំងឡាយណា របស់ភិក្ខុដែលឃើញចំពោះលាភសក្ការៈ និងការសរសើរមានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា ភាពជាអ្នកធ្វើនិមិត្ត ។

បណ្តាកិរិយាទាំងឡាយនោះ **ការកោស** ( និប្បេសិកតា ) តើដូចម្តេច ? ការជេរគេ ការនិយាយរំលោភគេ ការនិយាយរិះគន់គេ ការនិយាយបណ្តេញគេ ការនិយាយដេញតាមគេ ការនិយាយចំអកដាក់គេ ការនិយាយសើចចំអកគេ និយាយពន្ទើសគេ និយាយមើលងាយគេ និយាយពោលទោសគេ ចំពោះមុខអ្នកដទៃ និយាយសំឡុតបន្តិតបន្ខំគេនៃភិក្ខុដែលឃើញចំពោះលាភសក្ការៈ និងសេចក្តីសរសើរមានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ នេះហៅថា ការកោស ( ការបន្តិតបន្ខំ ) ។

កិរិយាទាំងឡាយនោះ **ការស្វែងរកលាភដោយលាភ** ( បាបធម៌

៥ ប្រការ គឺ កុហនា, លបនា, នេមិត្តិកតា, និប្បេសិកតា, **លាភេន លាភំ និជិគីសនតា** មានសេចក្ដីប្រាថ្នាតែម្យ៉ាង គឺឲ្យបានបច្ច័យ តែដោយវិធីការផ្សេងៗ ) តើដូចម្ដេច ? ភិក្ខុឃើញចំពោះលាភសក្ការៈ និងសេចក្ដីសរសើរ មានសេចក្ដីប្រាថ្នាលាមក ត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ រមែងនាំអាមិសដែលខ្លួន បានពីផ្ទះនេះទៅផ្ទះនោះ ឬនាំអាមិសដែលខ្លួនបានពីផ្ទះនោះមកផ្ទះនេះការចូលចិត្តរក ការស៊ើបរក ការស្វែងរកអាមិសដោយអាមិសបែបនេះ នេះហៅថា ការស្វែងរកលាភដោយលាភ ។

សេចក្ដីអធិប្បាយនៃព្រះបាលីគប្បីជ្រាបដូចតទៅ

## កុហនានិទ្ទេស

## ការលលួងដោយឫក

គប្បីជ្រាបអធិប្បាយក្នុងកុហនានិទ្ទេសមុន, បទថា ឃើញចំពោះលាភ សក្ការៈ និងសេចក្ដីសរសើរ មានន័យថា ប៉ង គឺប្រាថ្នាលាភសក្ការៈផង ឈ្មោះបោះសំឡេងផង ។ បទថា មានសេចក្ដីប្រាថ្នាលាមក គឺមានសេចក្ដីត្រូវការសម្ដែងគុណដែលមិនមាន ( ក្នុងខ្លួន ) ព្រោះហេតុ កុហនវត្ថុ ៣ យ៉ាង មកក្នុងមហានិទ្ទេសដោយអំណាចការក្លែងបដិសេធបច្ច័យ ការនិយាយបញ្ឆិតបញ្ឆៀង និងអាស្រ័យ

ឥរិយាបថ ព្រោះហេតុនោះ ដើម្បីសម្ដែងកុហនវត្ថុទាំង ៣ យ៉ាង នោះតទៅនេះ លោកផ្ដើមពាក្យថា **បច្ចយបដិសេធនេន វា** ដូច្នេះ ជាអាទិ ។ ក្នុងកុហនវត្ថុទាំង ៣ យ៉ាងនោះ ការធ្វើឲ្យគេយល់ប្រឡំ នៅពេលដែលគេនិមន្ត ដោយបច្ច័យ មានចីវរជាដើម ( ខ្លួនឯង ) គឺ ជាអ្នកមានសេចក្ដីត្រូវការដោយបច្ច័យនោះពិតៗ តែអាស្រ័យសេចក្ដី ប្រាថ្នាលាមក ក៏ក្លែងធ្វើជាហាម ព្រោះដឹងថា គហបតី ( ទាយក ) ទាំងឡាយនោះមានសទ្ធាមាំទាំចំពោះខ្លួន ហើយដើម្បីឲ្យគេអង្វរថា លោកម្ចាស់ដាក់ធុរៈជាអ្នកប្រាថ្នាតិចពិត មិនត្រូវការទទួលអ្វីៗ ឡើយ, ពួកខ្ញុំម្ចាស់បានល្អឯកហើយ បើលោកម្ចាស់ទទួលអ្វីៗ សូម្បីតែបន្តិច បន្តួច ដូច្នេះហើយ នាំបច្ច័យមានចីវរជាដើមដែលប្រណីតៗ ចូលទៅ ( ថ្វាយ ) ដោយឧបាយវិធីផ្សេងៗ ទៀត, ( គេ ) ក្លែងធ្វើជាអ្នកប្រាថ្នា នឹងអនុគ្រោះអ្នកទាំងនោះ ហើយទទួលក្ដី ជាហេតុឲ្យបន្ទាប់ពីនោះទៅ ( គេ ) នាំចូលមកថ្វាយភ្វាម ទាំងរទេះគោៗ ( ដូច្នេះ ) គប្បីជ្រាបថា ( នេះជា ) កុហនវត្ថុដែលរាប់ថា ជាការក្លែងបដិសេធបច្ច័យ ។

## កុហនវត្ថុទាក់ទងដោយបច្ច័យ

ពិតហើយ សូម្បីក្នុងមហានិទ្ទេសលោកក៏បានពោលពាក្យនេះ ទុកថា

កុហនវត្ថុដែលរាប់ថា ជាការក្លែងបដិសេធបច្ច័យដូចម្តេច ? គហបតីទាំងឡាយនិមន្តភិក្ខុក្នុងព្រះសាសនានេះដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារទាំងឡាយ អ្នកមានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ជាអ្នកមានសេចក្តីត្រូវការពិត ក្លែងប្រាប់ត្រឡប់វិញនូវចីវរ ក្លែងប្រាប់ត្រឡប់វិញនូវបិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ព្រោះអាស្រ័យសេចក្តីប្រាថ្នាឲ្យបានចីវរ ។ល។ ភេសជ្ជបរិក្ខារច្រើនឡើង គេពោលយ៉ាងនេះថា ប្រយោជន៍អ្វី ចំពោះសមណៈ ដោយចីវរមានតម្លៃច្រើន សមណៈគប្បីរើសសំពត់ ដែលគេបោះចោលហើយអំពីព្រៃខ្លះ អំពីគំនរសម្រាមខ្លះ អំពីផ្សារខ្លះមកធ្វើជាសំពត់សង្ឃាដីគ្រងនោះ ទើបគួរ, ប្រយោជន៍អ្វីដល់សមណៈ ដោយបិណ្ឌបាតដែលមានតម្លៃខ្ពស់ សមណៈ គប្បីចិញ្ចឹមជីវិតដោយដុំបាយដែលបានមកដោយការព្យាយាម ទៅស្វែងរកបិណ្ឌបាតតាមមានតាមបាននោះទើបគួរ, ប្រយោជន៍អ្វីចំពោះសមណៈ ដោយសេនាសនៈមានតម្លៃច្រើន សមណៈគប្បីជាអ្នកនៅតាមគល់ឈើ ឬនៅក្នុងអព្ភោកាសនោះទើបគួរ, ប្រយោជន៍អ្វីចំពោះសមណៈដោយគិលានប្បច្ច័យភេសជ្ជបរិក្ខារ ដែលមានតម្លៃច្រើន សមណៈគប្បីធ្វើថ្នាំដោយទឹកមូត្រស្អុយ ឬដោយចំណិតសម៉ នោះទើបគួរ ព្រោះអាស្រ័យហេតុនោះ ទើបលោកក្លែងគ្រងចីវរគេខ្ទក់

ក្លែងធាន់បិណ្ឌបាតដែលអន់ ក្លែងសេពសេនាសនៈដែលចាស់ ក្លែងសេពគិលានប្បច្ចយភេសជ្ជបរិក្ខារដែលថោក គហបតីទាំងឡាយស្គាល់ថា សមណៈរូបនេះជាអ្នកប្រាថ្នាតិច សន្តោស ស្ងប់ មិនប្រឫកប្រេបល់ដោយពួកគណៈ ប្រារព្ធសេចក្តីព្យាយាម មានប្រក្រតីពោលនូវធម៌ផុសខាត់កិលេស ដូច្នេះ រមែងនិមន្តលោកដោយចីវរ ។ល។ ភេសជ្ជបរិក្ខារក្រៃលែងៗ ឡើង លោកក្លែងពោលយ៉ាងនេះថា ព្រោះការប្រជុំនៃវត្ថុ ៣ យ៉ាង កុលបុត្តអ្នកមានសទ្ធា រមែងបានបុណ្យច្រើន គឺព្រោះការដល់ព្រមនៃសទ្ធា កុលបុត្តអ្នកមានសទ្ធារមែងបានបុណ្យច្រើន ព្រោះការដល់ព្រមគ្នានៃទេយ្យធម៌ ។ល។ នៃទក្ខិណេយ្យ បុគ្គលទាំងឡាយ កុលបុត្តអ្នកមានសទ្ធា រមែងបានបុណ្យច្រើន សទ្ធារបស់អ្នកទាំងឡាយ មានហើយដោយពិត ទេយ្យធម៌ក៏មានព្រមហើយ បដិគ្គាហក គឺអាត្មាភាពក៏មានព្រមហើយ បើអាត្មាភាពមិនទទួលសោតដូច្នោះ អ្នកទាំងឡាយនឹងវិនាសចាកបុណ្យ អាត្មាភាពមិនមានសេចក្តីប្រាថ្នាត្រូវការដោយរបស់នេះឡើយ តែអាត្មាភាពទទួលដើម្បីអនុគ្រោះអ្នកទាំងឡាយប៉ុណ្ណោះ ដូច្នេះព្រោះអាស្រ័យហេតុនោះ លោកក៏ទទួលចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារច្រើនៗ, ការក្លែងធ្វើមុខចង់ចិញ្ចើមក្លែងផាកមុខចេញធបោកគេឲ្យវង្វេងវង្វាន់បែបនេះយ៉ាងណា នេះលោកហៅថា កុហនវត្ថុដែលរាប់ថា ក្លែង

បដិសេធបច្ច័យ ៤

## កុហនវត្ថុទាក់ទង
## ដោយការនិយាយបញ្ឆិតបញ្ឆៀង

ការនិយាយឲ្យគេភាន់ច្រឡំ ដោយប្រការនោះៗ ដោយវាចាសម្តែងអំពីការសម្រេចឧត្តរិមនុស្សធម្ម នៃភិក្ខុអ្នកមានសេចក្តីប្រាថ្នាលាមកនោះ គប្បីជ្រាបថា ជាកុហនវត្ថុដែលជាការរាប់ថា និយាយបញ្ឆិតបញ្ឆៀង ដូចលោកពោលទុកថា ក្នុងវត្ថុទាំងឡាយនោះ កុហនវត្ថុដែលជាការរាប់ថា ការនិយាយបញ្ឆិតបញ្ឆៀង តើដូចម្តេច ? ភិក្ខុរូបខ្លះក្នុងសាសនានេះ មានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ មានបំណងចង់ឲ្យគេលើកសរសើរ ក៏គិតថា ពួកជនទើងលើកសរសើរយើងដោយប្រការយ៉ាងនេះហើយពោលវាចាអាស្រ័យអរិយធម៌ គឺនិយាយថា ភិក្ខុណាគ្រងចីវរដូច្នេះ ភិក្ខុនោះជាសមណមហេសក្ខ ពោលថា ភិក្ខុណាប្រើបាត្រលោហៈ បំពង់ត្រងទឹក សំពត់តម្រងទឹក កូនសោ វត្ថពន្ធ ស្បែក ជើងដូច្នេះ ភិក្ខុនោះជាសមណមហេសក្ខ និយាយថា ព្រះឧបជ្ឈាយ៍ ព្រះអាចារ្យ ភិក្ខុរួមឧបជ្ឈាយ៍ ភិក្ខុរួមអាចារ្យ ភិក្ខុដែលជាមិត្ត ភិក្ខុជាក្មេ ភិក្ខុដែលពេញចិត្តគ្នា ភិក្ខុជាសំឡាញ់របស់ភិក្ខុណាជាយ៉ាងនេះៗ ភិក្ខុណានៅក្នុង

វិហារ រោងវែង ប្រាសាទ ផ្ទះត្រឡោល គុហាដែលស្ងាត់ ខ្ទម ផ្ទះកំពូល ប៉ម ផ្ទះមូល សាលាវែង រោងប្រជុំ មណ្ឌប គល់ឈើ យ៉ាងនេះៗ ភិក្ខុនោះជាសមណមហេសក្ខ មិនដូច្នោះ គេសម្តែងអាការដែលគួរខ្ពើម មិនចេះអៀនខ្មាសល្មងគេ និយាយល្ងង់ញយៗ ចេញមុខខ្លួនឯង ពោលនូវពាក្យលឺបល ប្រឫកប្របល់ លាក់សាច់រឿង ទាក់ទងជាមួយលោកុត្តរធម៌ និងសុញ្ញតា (ទាក់ទងនឹងខ្លួន) ដូចជាសមណៈនេះបានវិហារសមាបត្តិដ៏ល្អិតទាំងឡាយនេះ យ៉ាងនេះការក្លែងធ្វើមុខចង់ចិញ្ចើម ធ្វើជាងាកមុខចេញ បោកបញ្ឆោតឲ្យគេភាន់ច្រឡំ ដូច្នេះយ៉ាងណា នេះលោកហៅថា កុហនវត្ថុដែលជាការនិយាយបញ្ចិតបញ្ចៀង ។

## កុហនវត្ថុទាក់ទងដោយឥរិយាបថ

ចំណែកការបញ្ឆោតគេដោយឥរិយាបថ ដែលធ្វើបំណងឲ្យគេសរសើរ នៃភិក្ខុជាបុគ្គលមានសេចក្តីប្រាថ្នាលាមកនោះឯង គប្បីជ្រាបថា ជាកុហនវត្ថុអាស្រ័យឥរិយាបថ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា កុហនវត្ថុដែលរាប់ថា កំណាត់ឫកពាអាស្រ័យឥរិយាបថ ដូចម្តេច ? ភិក្ខុរូបខ្លះក្នុងព្រះសាសនានេះ មានសេចក្តីប្រាថ្នាលាមក ត្រូវការប្រាថ្នាគ្របសង្កត់ ហើយមានសេចក្តីបំណងឲ្យគេលើកសរសើរ

គិតថា ពួកជននឹងសរសើរយើង ដោយអាការយ៉ាងនេះហើយ ក្លែងធ្វើជា ដេក ដើរ ឈរ អង្គុយ ដោយផ្ចិតផ្ចង់ រៀបឫកពា ដេក ដើរ ឈរ អង្គុយ ធ្វើដូចជាដេកចូលសមាបត្តិ ដើរចូលសមាបត្តិ ឈរចូលសមាបត្តិ អង្គុយចូលសមាបត្តិ និងជាអ្នកប្រាជ្ញាក្លែងធ្វើជាចូលឈានឲ្យគេឃើញ ការរៀបឫកពា តាំងឫកពា តែងឫកពាឥរិយាបថ ការក្លែងធ្វើជាចងចិញ្ចើម ធ្វើជាងាកមុខចេញ បញ្ឆោតគេឲ្យភាន់ច្រឡំដូច្នេះ យ៉ាងណា នេះហៅថា កុហនវត្ថុដែលកំណត់ ឫកពាអាស្រ័យឥរិយាបថ ។

ក្នុងបាលីនៃកុហនានោះ បទថា **បច្ចយប្បដិសេធនសន្នាតេន** មានន័យ ( ដោយកុហនវត្ថុ ) ដែលបណ្ឌិតរួបរួមយ៉ាងនេះថា ការក្លែងបដិសេធបច្ច័យ ឬថា បណ្ឌិតពោលដោយការក្លែងបដិសេធបច្ច័យ ។ បទថា និយាយបញ្ចិតបញ្ចៀង បានដល់ និយាយប្រជ្រិះ ( វត្ថុដែលចង់បាន ) ។ បទថា ឥរិយាបថ គឺសំដៅយកឥរិយាបថទាំង ៤ ។ បទថា **អដ្ឋបនា** ប្រែថា ការតាំង ( ឫកពា ) ទុកជាមុន ឬការតាំង ( ឫកពា ) ដោយយកចិត្តទុកដាក់ ។ បទថា **ឋបនា** គឺអាការដែលតាំង (ឫកពា) ។

បទថា **សណ្ឋបនា** គឺការរៀបចំតាក់តែង អធិប្បាយថា ការធ្វើភាវៈដែលគួរជ្រះថ្លា ។ បទថា **ភាកុដិកា** គឺការធ្វើមុខចងចិញ្ចើម អធិប្បាយថា ធ្វើមុខជ្រួញ ដោយសម្តែងភាវៈរបស់អ្នកតាំងនៅក្នុងសេចក្តី

ព្យាយាមយ៉ាងតឹងរឹងបំផុត ការធ្វើមុខចងចិញ្ចើមជាប្រក្រតីនៃភិក្ខុនោះ ហេតុនោះ ភិក្ខុនោះឈ្មោះថា **ភាកុដិក** ( អ្នកមានការធ្វើមុខចងចិញ្ចើមជាប្រក្រតី ) ភាពនៃ ភាកុដិក ឈ្មោះថា **ភាកុដិយំ** ( ភាពជាអ្នកមានការធ្វើមុខចងចិញ្ចើមជាប្រក្រតី ) ។ បទថា **កុហនា** ប្រែថា ការធបោក, ការប្រព្រឹត្តិធបោកឈ្មោះថា **កុហាយនា** សេចក្តីថា ចំពោះបុគ្គលដែលធបោក ឈ្មោះថា **កុហិតត្តំ** ។

## លបនានិទ្ទេស

## ការនិយាយបញ្ចោរ

គប្បីជ្រាបអត្ថាធិប្បាយក្នុងលបនានិទ្ទេសដូចតទៅ

ការដែលភិក្ខុបានឃើញមនុស្សមកកាន់វិហារ ហើយនិយាយឡើងមុនថា អ្នកដ៏ចម្រើន អ្នកទាំងឡាយមកដើម្បីត្រូវការអ្វី នឹងនិមន្តភិក្ខុឬ បើយ៉ាងនោះ អញ្ជើញត្រឡប់ទៅវិញចុះ អាត្មាភាពនឹងនាំភិក្ខុទៅតាមក្រោយ ដូច្នេះ ឈ្មោះថា **អាលបនា** ( សាកសួរ ),ម្យ៉ាងទៀតកាលដែលភិក្ខុសុំខ្លួនចូលទៅនិយាយ របៀបអួសទាញគេឲ្យមករកខ្លួនថា អាត្មាភាពឈ្មោះ **តិស្សៈ** ព្រះរាជាទ្រង់ជ្រះថ្លា ចំពោះអាត្មា រាជមហាមាត្យនោះៗ ក៏ជ្រះថ្លាចំពោះអាត្មា យ៉ាងនេះ ក៏ឈ្មោះថា **អាលនបា** ( សុំខ្លួន ), ការដែលភិក្ខុត្រូវគេសួរហើយ ក៏និយាយដូច

ដែលបានពោលហើយនោះ ឈ្មោះថា **លបនា** ( អួត ), ការដែលភិក្ខុខ្វាចម្ចាស់ ផ្ទះស្អប់ហែងនិយាយរក ក៏និយាយឱនលំទោនព្រមឲ្យឱកាសគេ ឈ្មោះថា **សល្លបនា** ( និយាយយកចិត្ត ) ការនិយាយធ្វើឲ្យគេខ្ពស់ឡើង ( ជាងកំណើតដើម ដែលគេរស់នៅ ) ថា លោកកុដុម្ពីធំ លោកម្ចាស់ផ្ទះធំ លោកទានបតីធំ ដូច្នេះ ឈ្មោះថា **ឧល្លបនា** ( និយាយលើក ), ការនិយាយលើកកម្ពស់គេគ្រប់យ៉ាង ឈ្មោះថា **សមុល្លបនា** ( និយាយបញ្ជោរ ) ការចង គឺរុំគេដោយវាចាថា ម្នាលឧបាសកឧបាសិកាទាំងឡាយ កាលមុនក្នុងពេលដូច្នេះ ពួកអ្នករមែងឲ្យនូវទាន ( **នវទាន** ការឲ្យរបស់ដែលផលិតថ្មី ដូចជាស្រូវថ្មី ផ្លែឈើថ្មី ) ឥឡូវនេះមិនឲ្យផ្កាប្ញ ? រហូតពួកគេទទួលមាត់ថា លោកម្ចាស់ពួកខ្ញុំម្ចាស់ នឹងឲ្យ ( ដូចគ្នា ) តែឥឡូវនេះមិនទាន់មានឱកាស ដូច្នេះជាដើម ឈ្មោះថា **ឧន្នហនា** ( និយាយចង ), មយ៉ាងទៀត ភិក្ខុឃើញគេកាន់អំពៅហើយ សួរថា ឧបាសកបានអំពៅមកពីណា ? គេឆ្លើយថាពីចំការអំពៅ លោកម្ចាស់ ភិក្ខុសួរថា អំពៅក្នុងចំការនោះផ្អែមឬទេ ? គេឆ្លើយថា ទំពាមើលទើបដឹង លោកម្ចាស់ភិក្ខុទើបនិយាយថា ឧបាសកអ្នកចូរឲ្យអំពៅដល់ ( អាត្មា ) ដូច្នេះ មិនគួរ ដល់ភិក្ខុពាក្យសំដីចងរបស់ភិក្ខុ ( និយាយ ) ជ្រុលទៅដូច្នេះ យ៉ាងណា ពាក្យនោះក៏ឈ្មោះថា **ឧន្នហនា** ការនិយាយចងហើយរឿយៗ គ្រប់វិធី គ្រប់ផ្លូវ ឈ្មោះ

ថា **សមុន្ទហនា** ( និយាយចង ) ។ បទថា **ឧក្កាបនា** អធិប្បាយថា ការនិយាយ ការនិយាយសម្តែងវិធីឡើងថា ត្រកូលនេះដឹងអាត្មាតែម្នាក់ បើទេយ្យធម៌កើតឡើងក្នុងត្រកូលនេះ គេនឹងឲ្យដល់អាត្មាតែម្នាក់គត់ យ៉ាងនេះ ហៅថា **ឧក្កាបនា** ( ការនិយាយចង ) អធិប្បាយថា និយាយបង្អាប់ ក្នុងអធិការនេះ បណ្ឌិតគួរពោលរឿងនាងតេលកន្ទរិកា ( មកសាធកៈ ) ។

ការនិយាយចងគេគ្រប់យ៉ាងឈ្មោះថា **សមុក្កាបនា** ( ការនិយាយសង្កត់យក ), និយាយរឿយៗ ឲ្យគេស្រឡាញ់ មិនត្រូវសម្លឹងមើលថា គួរដល់សច្ចៈ ឬគួរដល់ធម្មៈ, ឈ្មោះថា អនុប្បិយភាណិតា (ភាពជាអ្នកនិយាយបញ្ចោរ ការប្រព្រឹត្តិដាក់ខ្លួន គឺការប្រព្រឹត្តិដាក់ខ្លួនទុកឲ្យទាបៗ ឈ្មោះថា **ចាដុកម្យតា** ( បន្ទាបខ្លួន ) ភាពជាអ្នកដូចជាសណ្តែកស្ងោរ ឈ្មោះថា **មុគ្គសូបតា** ដូចជាសណ្តែក កាលស្ងោរវាទៅ តែងតែមានសណ្តែកមួយចំនួនមិនរលួយ ក្រៅពីនោះរលួយយ៉ាងណា ក្នុងការនិយាយរបស់បុគ្គលណា ពាក្យពិតមានត្រឹមតែបន្តិចបន្តួច ក្រៅពីនោះ ជាពាក្យមិនពិតអេចអូច ( ទាំងអស់ ) ក៏ដូច្នោះ បុគ្គលនេះលោកហៅថា មុគ្គសូប ( បុគ្គលដូចសណ្តែកស្ងោរ ) ភាវៈនៃមនុស្ស **មុគ្គសូប** នោះឈ្មោះថា **មុគ្គសូបតា** ។ ភាពជាបងចិញ្ចឹម ឈ្មោះថា **បារិភដ្យតា** អធិប្បាយថា ភិក្ខុណាមើលចិញ្ចឹម គឺ

ថែរក្សាក្មេងក្នុងត្រកូល ត្រឹមបង្អែះខ្លះ ត្រឹមកខ្លះ ដូចជាស្ត្រីបងចិញ្ចឹម ចិញ្ចឹមក្មេង ការធ្វើរបស់ភិក្ខុ ចិញ្ចឹមក្មេងនោះ ឈ្មោះថា **បារិភដ្យ**, ការប្រព្រឹត្តិនៃ **បារិភដ្យ** ឈ្មោះថា **បារិភដ្យតា** ដូច្នេះ ។

## នេមិត្តិកតានិទ្ទេស

## ការប្រើឧបាយដោយកាយវាចា

គប្បីជ្រាបអត្ថាធិប្បាយក្នុងនេមិត្តិកតានិទ្ទេសតទៅ

កាយកម្ម និងវចីកម្ម យ៉ាងណាមួយ ដែលញ៉ាំងការសម្គាល់ ឲ្យដឹងជាបច្ច័យ ( ចំពោះខ្លួន ) ឲ្យកើតដល់អ្នកដទៃៗ ឈ្មោះថា **និមិត្តំ** (ការបូញមាត់មិននិយាយ) កាលដែលភិក្ខុឃើញគេកាន់យកខាទនីយៈ ដើរទៅ ក៏ធ្វើនិមិត្តដោយន័យថា អ្នកទាំងឡាយបានរបស់ទំពាអ្វីមក ដូច្នេះជាដើមឈ្មោះថា **និមិត្តកម្មំ** (ពោលបញ្ឆិតបញ្ឆៀង) ការនិយាយ ទាក់ទងដល់បច្ច័យ ឈ្មោះថា **ឱភាសោ** ( និយាយគោះ ) កាលដែល ភិក្ខុឃើញក្មេងមើលគោហើយសួរថា កូនគោទាំងឡាយ នេះជាកូន គោទៅបៅដោះ ឬជាកូនគោបេះរត់... ពេលគេឆ្លើយថា កូនគោនៅ បៅដោះ លោកម្ចាស់ ហើយធ្មៀតឱកាសនិយាយគោះដោយន័យថា មិនមែនជាកូនគោឈប់បៅដោះ បើជាកូនគោនៅបៅដោះ ពួកភិក្ខុគង់ បានទឹកដោះស្រស់ខ្លះ ដូច្នេះជាដើម ទាល់តែក្មេងទាំងនោះ ត្រូវទៅ

ប្រាប់មាតាបិតាឲ្យថ្វាយទឹកដោះស្រស់ ( ដល់លោក ) ជាអាទិ ឈ្មោះថា **ឱភាសកម្មំ** ( និយាយឲ្យន័យ ), ការនិយាយបញ្ឆិតនូវ ( វត្ថុដែលចង់បាន ) ឈ្មោះថា **សាមន្តជប្បា** ( និយាយបញ្ឆិតបញ្ឆៀង ) ក្នុងបទនេះគួរពោលរឿងភិក្ខុជីតុន ( មកសាធក )..ៗ

បានឮថា ភិក្ខុជីតុនប្រាថ្នានឹងឆាន់អាហារ ទើបចូលទៅកាន់ផ្ទះ ( របស់ឧបដ្ឋាយិកា ) ហើយអង្គុយចុះ ស្ត្រីមេផ្ទះឃើញភិក្ខុនោះហើយមិនប្រាថ្នានឹងឲ្យ ទើបនិយាយថា គ្មានអង្ករ ធ្វើជាទៅរកអង្ករ ទៅកាន់ផ្ទះរបស់បុគ្គលដែលធ្លាប់ស្គាល់គ្នា ភិក្ខុចូលទៅក្នុងបន្ទប់រកមើលប្រទះកំណាត់អំពៅនៅកន្លៀតទ្វារ ឃើញទឹកអំពៅពេញក្នុងភាជនៈ ឃើញត្រីងៀតក្នុងជាល ឃើញអង្ករក្នុងថ្នាំង ឃើញទឹកដោះក្នុងក្អម ហើយចេញមកអង្គុយ ស្ត្រីមេផ្ទះ ( ត្រឡប់ ) មកវិញ ក៏ក្លែងប្រាប់ថា មិនបានអង្ករ ភិក្ខុក៏និយាយឡើងថា ឧបាសិកាអាត្មាឃើញប្រផ្នូលមុនហើយ ដឹងថាថ្ងៃនេះភិក្ខាទឹងមិនសម្រេច ស្ត្រីមេផ្ទះសួរថា ប្រផ្នូលអ្វីលោកម្ចាស់ ភិក្ខុឆ្លើយថា អាត្មាឃើញពស់ស្រដៀងបាច់អំពៅដែលរក្សាទុកនៅកន្លៀតទ្វារ គិតនឹងវាយវា ក្រឡេកមើលទៅក៏ឃើញបើកពពារស្រដៀងត្រីងៀត ដែលរក្សាទុកក្នុងជាល អាពស់នោះត្រូវប្រហារដោយដុំថ្មនិងដុំដីស្រដៀងដុំស្ករអំពៅដែលរក្សាទុកក្នុងភាជនៈសម្តែងអាការឡើង ពេលនោះ វាក៏ខាំដុំដីនោះ ឃើញចង្កូមរបស់វាស្រដៀង

អន្តរក្នុងផ្ទាំង ពេលវាខឹង ( ក៏ឃើញ ) ទឹកមាត់លាយ ដោយពិស ចេញពីមាត់របស់វាស្រដៀងទឹកដោះដែលទុកក្នុងក្អម ស្ត្រីមេផ្ទះនោះ យល់ថា មិនអាចបញ្ឆោតបុគ្គលក្បាលត្រងោលបាន ទើបថ្វាយអំពៅ ហើយដាំបាយថ្វាយព្រមជាមួយទឹកដោះ ជុំស្ករអំពៅ និងត្រី ដូច្នេះឯង, ការនិយាយបញ្ចិត យ៉ាងនេះ គប្បីជ្រាបថា **សាមន្តជប្បា** ( និយាយបញ្ចិតបញ្ចៀង ) និយាយព័ទ្ធទៅព័ទ្ធមកដើម្បីបានបច្ច័យនោះ ឈ្មោះថា **បរិកថា** ( និយាយព័ទ្ធ ) ។

## និប្បេសិកតានិទ្ទេស

## ការប្រើសំដីជាខ្នាសកោសយកលាភ

គប្បីជ្រាបអត្ថាធិប្បាយក្នុងនិប្បេសិកតានិទ្ទេសតទៅ

បទថា **អក្កោសនា** បានដល់ ការជេរដោយវត្ថុសម្រាប់ជេរ ១០ យ៉ាង ។ បទថា **វម្ភនា** បានដល់ និយាយបន្តុំ ។ បទថា **គរហនា** បានដល់ និយាយបន្ទុច គេដោយន័យថា គេជាមនុស្សមិនមានសទ្ធា ជាមនុស្សមិនជ្រះថ្លាជាដើម ។ បទថា **ឧក្ខេបនា** គឺបណ្តញគេដោយវាចាថា លោកកុំនិយាយយ៉ាងនេះក្នុងទីនេះការបណ្តេញគេ អាងរឿង អាងហេតុគ្រប់យ៉ាង ឈ្មោះថា **សមុក្ខេបនា** ( ការនិយាយបណ្តេញគេ),ម្យ៉ាងវិញទៀតកាលដែលឃើញគេមិនឲ្យហើយក៏ក្លែងនិយាយ

សរសើរគេថា ឱ ! លោកទានបតី ដូច្នេះ ឈ្មោះថា **ឧក្ខេបនា** (បញ្ចោះ), សរសើរកាន់តែខ្លាំងឡើងថា ឱ ! លោក មហាទានបតី ដូច្នេះ ឈ្មោះថា **សមុក្ខេបនា** ។ បទថា **ខិបនា** គឺនិយាយចំអកដាក់យ៉ាងនេះថា ហេតុអ្វីជីវិតរបស់អ្នកបរិភោគបន្លែ បទថា **សង្ខិបនា** គឺនិយាយចំអកឲ្យពិសេសក្រៃលែងឡើងយ៉ាងនេះថា អ្នកទាំងឡាយនឹងហៅលោកអ្នកនេះដែលឲ្យពាក្យថា មិនមានដល់ជនទាំងពួងអស់កាលជានិច្ចថា មិនមែនជាទាយកបានយ៉ាងណា ។ បទថា **បាបនា** បានដល់ មើលងាយថាគេមិនមែនជាទាយក ឬបន្ទំឲ្យគេខូចខាត ការនិយាយមើលងាយគេគ្រប់បែបយ៉ាង ឈ្មោះថា **សម្បាបនា** (មើលងាយ) ។ បទថា **អវណ្ណហារិកា** មានន័យថា ការនាំសេចក្ដីវិនាសពីផ្ទះ (នេះ) ទៅកាន់ផ្ទះ (នោះ), ចេញពីស្រុកនេះទៅកាន់ស្រុកនោះ, ចេញពីជន បទនេះ ទៅកាន់ជនបទនោះ ដោយគិតថា គេនឹងឲ្យ (បច្ច័យ) ដល់យើងព្រោះខ្លាចសេចក្ដីវិនាសយ៉ាងនេះ ។ បទថា **បរបិដ្ឋិមំសិកតា** បានដល់ភាពជាអ្នកនិយាយ ពាក្យផ្អែមចំពោះមុខ និយាយនិន្ទាក្រោយខ្នង សេចក្ដីនោះ ប្រៀបដូចជាបុគ្គលមិនអាចតស៊ូចំពោះមុខគេ ក៏បន្ខូចគេជាខាងក្រោយ ព្រោះហេតុនោះ ទើបឈ្មោះថា **បរបិដ្ឋិមំសិកតា** ។

ពាក្យថា **អយំ វុច្ចតិ និប្បេសិកតា** មានន័យថា កិរិយា មានការពោលពាក្យអាក្រក់ជាដើម នេះនោះ លោកពោលថា ឈ្មោះថា

**និប្បេសិកតា** ព្រោះកម្ចាត់នូវសេចក្តីល្អរបស់អ្នកដទៃឲ្យវិនាសទៅ ហាក់ដូចជាបោសដោយអំបោសចម្រៀកឫស្សី, ម្យ៉ាងទៀត ព្រោះជាការជាន់ឈ្លីសេចក្តីល្អរបស់អ្នកដទៃដើម្បីរកលាភ ដូចជាកិនកម្ទេចគន្ធជាតិដើម្បីរកក្លិនក្រអូបដូច្នោះ ។

## លាភេន លាភំ និជិគីសនតានិទ្ទេស

## ការស្វែងរកលាភដោយលាភ

គប្បីជ្រាបអត្ថាធិប្បាយក្នុងនិទ្ទេសនៃ **លាភេន លាភំ និជិគីសនតា** ដូចតទៅ

ការស្វែងរកឈ្មោះថា **និជិគីសនតា** ។ ពាក្យថា **ឥតោ លទ្ធំ** គឺបានពីផ្ទះនេះ ។ បទថា **អមុត្រ** គឺកន្លែងផ្ទះនោះ ។ បទថា **ឯដ្ឋិ** បានដល់ការចូលចិត្តរក ។ បទថា **គវេដ្ឋិ** បានដល់ ការស្រាវជ្រាវរក ។ បទថា **បរិយេដ្ឋិ** បានដល់ ការស្វែងរក ។ ក៏ក្នុងនិទ្ទេសនេះ បណ្ឌិតគប្បីពោលរឿងរបស់ភិក្ខុ ឲ្យភិក្ខាដែលបានមក តាំងពីដំបូងដល់ទារកក្នុងត្រកូលនោះៗ ( ហើយបានបច្ច័យតបជំនួសមកវិញ ) ក្នុងទីបំផុតក៏បានទឹកដោះ ( ជានិទស្សនៈ ) ។ បទថា **ឯសនា** ជាដើម ជាវេវចនៈនៃពាក្យថា **ឯដ្ឋិ** ជាដើមនោះឯង ព្រោះហេតុនោះ គប្បីជ្រាបយោជនាក្នុងបទទាំងឡាយនេះថា បទថា **ឯដ្ឋិ** ក៏ គឺ **ឯសនា** ។ បទថា **គវេដ្ឋិ**

ក៏គឺ **គវេសនា** ។ បទថា **បរិយេដ្ឋិ** គឺ **បរិយេសនា** ដូច្នេះ ។

សេចក្ដីដែលពោលមកនេះ ជាការអធិប្បាយនៃបាបធម៌ទាំងឡាយ មាន **កុហនា** ជាដើម ។

ឥឡូវនេះគប្បីជ្រាបថា ក្នុងបទថា **ឯវមាទីនញ្ច បាបធម្មានំ** នោះ កាន់យកបាបធម៌ជាអនេកដែលព្រះអង្គត្រាស់ទុកក្នុងព្រហ្មជាលសូត្រ ដោយន័យថា ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ ដ៏ចម្រើនពួកមួយ បរិភោគភោជនដែលទាយកថ្វាយដោយសទ្ធាហើយ រមែងចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ដោយតិរច្ឆានវិជ្ជា ។

តិរច្ឆានវិជ្ជា គឺ អ្វីខ្លះ ? តិរច្ឆានវិជ្ជា គឺ

**១-អង្គំ** វិជ្ជានិយាយអំពីសរីរាវយវៈ ។

**២-និមិត្តំ** វិជ្ជាសម្រាប់ទាយនូវហេតុផ្សេង ៗ ។

**៣-ឧប្បាតំ** វិជ្ជានិយាយអំពីឧប្បត្តិហេតុ ។

**៤-សុបិនំ** វិជ្ជាសម្រាប់ទាយយល់សប្ដិ ។

**៥-លក្ខណំ** វិជ្ជាសម្រាប់ទាយលក្ខណៈ ។

**៦-មូសិកច្ឆិន្នំ** វិជ្ជាសម្រាប់ទាយនូវសំពត់ដែលកណ្ដុរកាត់ ។

**៧-អគ្គិហោមំ** វិធីបូជាភ្លើង ។

**៨-ទព្វិហោមំ** វិធីបូជាវែក ។ ដូច្នេះជាដើម ។

មិច្ឆាជីវៈ ដែលប្រព្រឹត្តទៅដោយអំណាចនៃការល្មើសសិក្ខាបទ

៦ ដែលទ្រង់បញ្ញត្ត ព្រោះអាជីពជាហេតុទាំងឡាយនេះក្តី ដោយអំណាចនៃបាបធម៌ មានជាអាទិយ៉ាងនេះ គឺការលលួង ការបញ្ចោរ ការគំរាមកំហែង និងការស្វែងរកលាភ ដោយលាភទាំងឡាយនេះក្តី យ៉ាងណា ការវៀរចាកមិច្ឆាជីវៈគ្រប់ប្រការ យ៉ាងណា នេះឈ្មោះថា **អាជីវបារិសុទ្ធិសីល** ដូច្នេះឯង ។

សេចក្តីនៃពាក្យក្នុងពាក្យថា **អាជីវបារិសុទ្ធិសីល**នោះមានន័យដូច្នេះ ជនទាំងឡាយរមែងអាស្រ័យវត្ថុនោះរស់នៅ ហេតុនោះ វត្ថុនោះ ទើបឈ្មោះថា **អាជីវ** វត្ថុនោះបានដល់អ្វី ? វត្ថុនោះបានដល់សេចក្តីព្យាយាមស្វែងរកបច្ច័យ ។ សេចក្តីហ្មត់ចត់ ឈ្មោះថា បារិសុទ្ធិ សេចក្តីហ្មត់ចត់នៃអាជីវៈ ឈ្មោះថា អាជីវបារិសុទ្ធិ ។

# មហាដីកា

## អំពីអាជីវបារិសុទ្ធិសីល

ពាក្យថា ដែលពោលទុក គឺដែលពោលទុកក្នុងខាងដើម ទាក់ទងដោយឧទ្ទេស ក្នុងអាជីវបារិសុទ្ធិសីលនេះឯង ។

ពិតហើយ លោកអាចារ្យបំណងនឹងអធិប្បាយបទថា នៃសិក្ខាបទ ៦ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្ត ព្រោះមានអាជីវៈជាហេតុ ដូច្នេះហើយ ក៏សម្ដែងបទទាំងឡាយនោះ ដោយជាព្រះបាលីនោះឯង ទើបផ្ដើមពាក្យថា **យានិ តានិ** ដូច្នេះជាដើម ។

ក្នុងបណ្ដាបទទាំងឡាយនោះភ្ជាប់សេចក្ដីថា សិក្ខាបទ ៦ ដែលព្រះមានព្រះភាគត្រាស់ទុកថា ទ្រង់បញ្ញត្តយ៉ាងនេះ ។ ពាក្យថា ព្រោះអាជីវៈជាហេតុ បានដល់ ព្រោះការចិញ្ចឹមជីវិតជាហេតុ បានដល់សេចក្ដីប្រាថ្នាថា ដោយអាការយ៉ាងនេះ យើងនឹងរកចិញ្ចឹមជីវិតមិនលំបាក ព្រោះបច្ច័យទាំងឡាយ ។

ពាក្យថា ព្រោះអាជីវៈជាប្រធាន ជាវេវចនៈនៃពាក្យថា ព្រោះអាជីវៈជាហេតុនោះឯង ។ ពាក្យថា មានសេចក្ដីប្រាថ្នាលាមក មានន័យថា ប្រកបដោយសេចក្ដីប្រាថ្នា ក្នុងការលើកសរសើរដោយគុណដែលមិនមានរបស់បុគ្គលលាមក ។

ពាក្យថា ដែលសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ មានន័យថា គឺជាអ្នកដែលសេចក្ដីប្រាថ្នា ញាំញីហើយ ប្រទូសរ៉ាយហើយ ឬគ្របសង្កត់ហើយ ។

បទថា **អសន្តំ** ប្រែថា មិនមាននៅ ។ បទថា **អភូតំ** ប្រែថា ដែលមិនទាន់កើតឡើង ។ ព្រោះសេចក្ដីដែលគុណនោះមិនកើតឡើង គុណនោះទើបមិនមាននៅ ហេតុនោះពាក្យក្រោយ ទើបជាពាក្យប្រាប់ហេតុនៃពាក្យដំបូង ។

ពាក្យថា **ឧត្តរិមនុស្សធម្ម** គឺធម៌របស់មនុស្សដ៏ប្រសើរ គឺបុរសដ៏ខ្ពង់ខ្ពស់ ឬធម៌ដ៏ប្រសើរក្រៃលែង គឺឧក្រិដ្ឋជាងធម៌របស់មនុស្ស ។

បទថា **ឧល្លបតិ** ស្មើគ្នានឹង **ឧគ្គតាយុកោ លបតិ** ប្រែថា ជាអ្នកផុតអាយុទៅហើយពោល ។ ព្រោះថា សីលជាអាយុរបស់ភិក្ខុ, សីលនោះឯង រមែងវិនាសព្រមគ្នាក្នុងពេលនិយាយយ៉ាងនោះ របស់ភិក្ខុនោះ ។ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **អាបត្តិបារាជិកស្ស** ។

ប្រែសេចក្ដីថា គប្បីជាអាបត្តិ ពោល គឺបារាជិក ឬប្រែសេចក្ដីថា ការអួត ជាហេតុឲ្យត្រូវ **វីតិក្កមៈ** ដែលមានឈ្មោះថា **បារាជិក** ។

ពីរបទថា **សញ្ចរិត្តំ សមាបជ្ជតិ** មានន័យថា រមែងដល់ភាពជាអ្នកនាំបុរស ស្ត្រីឲ្យស្រឡាញ់គ្នា, អធិប្បាយថា ប្រាប់សេចក្ដីបំណងរបស់ស្ត្រីដល់បុរស ។ ភ្ជាប់សេចក្ដីថា ដោយអំណាចការល្មើស

សិក្ខាបទ ៦ ទាំងឡាយនេះ ខ្ញុំម្ចាស់នឹងសម្តែងទុកនៅបទក្រោយ ។

បទថា **កុហនាតិអាទីសុ** ជាការលើកបទឡើងនៃព្រះបាលីដែលលើកឡើង សម្តែងហើយក្នុងបទក្រោយនោះឯង ។

ពាក្យថា មានព្រះបាលីដូចនេះ បានដល់ ព្រះបាលីនិទ្ទេសដែលមកហើយ ក្នុងវិភង្គដូចតទៅ

ឈ្មោះថា លាភ ព្រោះអត្ថថា បច្ច័យមានចីវរជាដើមដែលបានមក លាភទាំងឡាយនោះឯងដែលគេឲ្យដោយសេចក្តីគោរពគឺដោយហេតុជួយសង្គ្រោះ ឈ្មោះថា សក្ការៈ ។ ភាពជាអ្នកមានយសល្បីខ្ចរខ្ចាយទូទៅ ឈ្មោះថា កិត្តិ-ស័ព្ទ ។ លាភនោះផង សក្ការៈនោះផង កិត្តិស័ព្ទនោះផង, ក្នុងពាក្យថា អ្នកអាស្រ័យ នេះលោកសំដៅយកទីអាស្រ័យ គឺតណ្ហា ព្រោះដូច្នោះ ទើបលោកពោលថា ប្រាថ្នាហើយដូច្នេះ ។

ពាក្យថា ប្រាថ្នាគុណដែលមិនមាន មានន័យថា ជាអ្នកប្រាថ្នាដើម្បីឲ្យគេលើកសរសើរក្នុងពេលគុណមានសទ្ធាជាដើមមិនមាន គឺមិនប្រាកដនៅក្នុងខ្លួន ។

ពិតហើយ សេចក្តីប្រាថ្នាលាមក មានលក្ខណៈលើកសរសើរគុណដែលមិនមាន, និងមានលក្ខណៈមិនដឹងប្រមាណក្នុងការទទួល ។ ពីរពាក្យថា ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់មានន័យថា ឈ្មោះថា ដែល

សេចក្ដីប្រាថ្នាគ្របសង្កត់ព្រោះអត្ថថា ត្រូវសេចក្ដីប្រាថ្នាដ៏លាមកធ្វើឲ្យទៅប្រាសចាកសម្មាអាជីវៈ ។ លោកពោលថា អធិប្បាយថា ត្រូវសេចក្ដីប្រាថ្នាប្រទូសរ៉ាយហើយ ព្រោះអធិប្បាយថា បុគ្គលរបៀបនោះ ជាអ្នកត្រូវអន្តរាយ គឺអាជីពបៀតបៀនហើយ ។

ឈ្មោះថា កុហនវត្ថុ ព្រោះអត្ថថា ការកុហកបោកបញ្ឆោតនោះឯងជាវត្ថុ ដែលនាំឲ្យកើតឡើងនូវបច្ច័យ ( ជាទីតាំងឲ្យបច្ច័យកើតឡើង ) លោកអាចារ្យ កាលនឹងសម្ដែងកុហនវត្ថុទាំង ៣ យ៉ាងនោះដែលមកហើយក្នុងនិទ្ទេសនោះ ដោយព្រះបាលីនេះ ដែលជាទីអាស្រ័យនៃកុហនវត្ថុនោះ ដូច្នេះគប្បីឃើញសេចក្ដីតាមដែលពោលមកនេះយ៉ាងនេះ ។

បទថា **តទត្ថិកស្សេវ** មានន័យថា អ្នកមានសេចក្ដីត្រូវការចីវរជាដើម ទាំងឡាយនោះឯង ។

បទថា **បដិក្ខិបនេន** មានន័យថា ព្រោះហេតុ គឺការបដិសេធន៍បច្ច័យមានចីវរជាដើម ។ បទថា **អស្ស** សេចក្ដីប៉ុនគ្នានឹង **ភវេយ្យ** ( ប្រែថា គួរជា ) ។ ដោយ ច-ស័ព្ទថា **បដិគ្គហណេន ច** លោករួមដល់ការបដិសេធន៍ដែលពោលទុកព្ទដ៏ខាងដើមផងដែរ ។

បទថា **ភិយ្យោកម្យតំ** ប្រែថា ភាពជាអ្នកត្រូវការច្រើន ។ បទថា **យំ** ជាកិរិយាបរាមាស, ព្រោះដូច្នោះ ក្នុងពាក្យថា **ធារេយ្យ** នេះ

ប្រកបសេចក្តីថា ការធ្វើឲ្យជាសំពត់សង្ឃាដី ហើយទ្រទ្រង់ទុកនោះណា នេះសមគួរចំពោះសមណៈ ។

បទថា **បាបណិកានិ** មានន័យថា សំពត់ដែលគេបោះចោលពីហាង ។

បទថា **នន្តកានិ** មានន័យថា សំពត់បន្ទះតូចៗ ដែលមិនមានជាយ ។

បទថា **ឧច្ចិនិត្វា** បានដល់ ដែលជ្រើសរើសរួមទុក ដោយការស្វែងរក ។

ពាក្យថា ដោយការទៅស្វែងរក មានន័យថា ដោយអាហារដែលបានមក ដោយការទៅស្វែងរក ។ បរិក្ខារនៃជីវិត ពោល គឺភេសជ្ជៈដែលជាបច្ច័យរបស់អ្នកជំងឺ ឈ្មោះថា គិលានប្បច្ចយភេសជ្ជបរិក្ខារ។ ពាក្យថាមូត្រស្អុយ នេះជាឈ្មោះរបស់មូត្រគោគ្រប់ប្រភេទទាំងចាស់ទាំងថ្មី ។ ពាក្យថា មូត្រស្អុយ មានន័យថា មូត្រដែលគេបោះចោលទៅហើយ គឺដែលបុគ្គលដទៃលះបង់ចោលហើយ ព្រោះភាពជារបស់ស្អុយ ឬដោយមូត្រគោដែលស្អុយ ។ ពាក្យថា ជា **ធុតវាទ** មានន័យថា មានប្រក្រតីពោលនូវគុណជាគ្រឿងកម្ចាត់កិលេស ដល់បុគ្គលទាំងឡាយដទៃ ។ព្រោះការប្រជុំគ្នា មានន័យថា ព្រោះមាននៅចំពោះ

មុខ គឺថាព្រោះជាអ្នកបានហើយ ។

ការនិយាយដាក់ខ្លួនឲ្យជិតចំពោះការសម្រេចនូវឧត្តរិមនុស្សធម៌ ឈ្មោះថា ការនិយាយបញ្ចិតបញ្ចៀង ។

ពាក្យថា អ្នកមានសក្តិធំ គឺជាអ្នកមានអានុភាពច្រើន, អធិប្បាយថា ដោយការសម្រេចឧត្តរិមនុស្សធម៌ ។ លោកអាចារ្យពោលពាក្យថា មិត្ត នេះជាពាក្យស្មើគ្នា ហើយពោលពាក្យនោះឲ្យផ្សេងពីគ្នាទៅទៀតថា អ្នកជាក្មេងនឹងគ្នា អ្នកចូលចិត្តគ្នា ។

ពិតហើយ មិត្តដែលធ្លាប់ត្រឹមតែឃើញគ្នា ឈ្មោះថា ជាក្មេងដែលរាប់អានគ្នា យ៉ាងជិតស្និទ្ធ ឈ្មោះថា ជាអ្នកចូលចិត្តគ្នា មានន័យថា មិត្តភក្តិ ។ គឺអ្នកដែលដើរទៅជាមួយគ្នាតាំងពី ៧ ជំហានទៅ លោកហៅថា **មិត្តភក្តិ** ។

កន្លែងនៅទាំងអស់ដែលកំណត់ដោយកំផែង ឈ្មោះថា វិហារ ។ ប្រាសាទ វែងឈ្មោះថា រោងវែង ។ អាចារ្យខ្លះ ពោលថា ប្រាសាទមានសណ្ឋានដូចគ្រុឌ ។

ប្រាសាទ ៤ ជ្រុង ឈ្មោះថា ប្រាសាទ ។ ផ្ទះត្រងោល បានដល់ប្រាសាទដែលមានដំបូលត្រងោល ។ ផ្ទះកំពូល បានដល់ ប្រាសាទដែលគប្បីធ្វើដោយចុង កំពូល ២ ។ ប៉ម បានដល់ ទីអាស្រ័យពិសេស ៤-៥ ជាន់ ដែលប្រកបទុកដើម្បី ការពារអរិរាជសត្រូវ ។ ពាក្យថា

រោងមូល បានដល់ ទីអាស្រ័យពិសេសមានច្រើនមុំរួមទុកដោយកំពូលតែមួយ ។ អាចារ្យពួកខ្លះពោលថា សាលាវែងមិនមាន បន្ទប់មានទ្វារតែមួយ ឈ្មោះថា សាលាវែង ។ ចំណែកអាចារ្យមួយពួកទៀត ពោលថា ប្រាសាទមានមុខវែង ឈ្មោះថា វិហារ ។ រោងវែង បានដល់ សេនាសនៈដែលប្រក់ប៉ាំងទុកតែម្ខាង ។ បានឮមកថា ជញ្ជាំងរបស់សេនាសនៈនោះខ្ពស់ម្ខាង ម្ខាងទៀតទាប ព្រោះហេតុនោះ សេនាសនៈនោះ ទើបប្រក់ប៉ាំង តែម្ខាង ។

ប្រាសាទ បានដល់ ប្រាសាទ ៤ ជ្រុង ទូលាយ ។ ផ្ទះត្រងោល បានដល់ សេនាសនៈដែលប្រក់ត្រងោលប្រកបដោយកំពូលព្រះចន្ទ ។ គុហា បានដល់ ល្អាងភ្នំសុទ្ធៗ ។ កន្លែងសម្ងាត់ បានដល់ ទីដែលស្ងាត់ដែលបិទទ្វារទុក ។ ផ្ទះកំពូល បានដល់ ប្រាសាទដែលមានកំពូលយ៉ាងណាមួយ ។ ប៉ម បានដល់ ផ្ទះដែលមានកំផែងយ៉ាងមាំ ជាកន្លែងដែលមិនប្រើគន្លឹះ ដំបូលប្រក់ដោយឥដ្ឋទាំងឡាយយ៉ាងណា ១ ។ អាចារ្យខ្លះពោលថា ធ្វើដោយអាការដូចប៉មក៏មាន ។ រោងមូល បានដល់ សេនាសនៈដែលធ្វើដោយអាការមូល ។ ទីអាស្រ័យពិសេសប្រភេទណាមួយឈ្មោះថា សាលាវែង, ដែលលោកហៅថា សាលារក្សាខ្ទួន ។ រោងប្រជុំ បានដល់ ស្ថានទីប្រជុំ ។

ការសង្កត់សង្កិនសេចក្ដីសោប់សល់កាយ និងវាចាដែលមិន

មានប្រយោជន៍ ព្រោះភាពជាអ្នកប្រាថ្នាលាមក ដែលជាធូលីគួរខ្ពើម ឈ្មោះថា **កោរជ, កោរជ** នោះឯងមាននៅចំពោះភិក្ខុនេះ ហេតុនោះ ភិក្ខុនេះឈ្មោះថា **កោរជិក** ( អ្នកមានធូលីគួរខ្ពើម ) គឺមានអាការដែលសង្រួមដោយការបោកបញ្ឆោត ភិក្ខុដែលមានធូលីគួរខ្ពើមក្រៃលែង គឺពពាក់ពពូនៗ ឈ្មោះថា **កោរជិកកោរជិកោ** ( អ្នកមានអាការដែលគួរខ្ពើមក្រៃលែង ) ។ អាចារ្យខ្លះថា គួររង្កៀសក្រៃលែង ។ អ្នកធបោកគេយ៉ាងក្រៃលែង ឈ្មោះថា **កុហកុហោ** មានន័យថា អ្នកធ្វើឲ្យគេវង្វេងវង្វាន់យ៉ាងក្រៃលែង ។

ការនិយាយបញ្ចោរយកចិត្តគេយ៉ាងក្រៃលែងឈ្មោះថា **លបលបោ** ឈ្មោះថា អ្នកបញ្ចោរគេ ។

ពាក្យថា បេញមុខខ្លួនឯង បានដល់ ប្រើពាក្យនិយាយដែលប្រព្រឹត្តទៅដោយភាពជាអ្នកមានធូលីគួរខ្ពើមក្រៃលែងជាដើម ។ ធ្វើឲ្យបុគ្គលដទៃសរសើរដោយត្រឹមតែមុខរបស់ខ្លួន បានដល់ ភិក្ខុបែបនេះនោះ រមែងធ្វើខ្លួនដូចជាបុគ្គលដទៃ ដោយភាពជាអ្នកយ៉ាងនេះពោលថា សមណៈរូបនេះ ដូច្នេះជាដើម ។

ពាក្យថា ជ្រាលជ្រៅជាដើម លោកពោលហើយព្រោះសេចក្តីនៃពាក្យនោះ ទាក់ទងដោយឧត្តរិមនុស្សធម៌ ។

ពាក្យថា ធ្វើដោយបំណងឲ្យគេសរសើរ មានន័យថា ធ្វើដោយ

បំណងយ៉ាងនេះថា ជនគប្បីសរសើរយើងថា ជាអរិយៈ ឬអ្នកបាន គុណវិសេស បានយ៉ាងណាហ្ន៎ ។ ពាក្យថា រៀបឫកផ្ចិតផ្ចង់ដើរ មាន ន័យថា រៀបឫកការដើរ របស់ខ្លួនដោយគោរពដូចការដើររបស់អ្នក មានគុណវិសេស គឺធ្វើដូចជាអ្នកមានសតិសម្បជញ្ញៈក្នុងការដើរតែ ម្យ៉ាង ។ ពាក្យថា តាំងឫក មានន័យថា តាំងចិត្ត ឬប្រាថ្នាថា ជន ទាំងឡាយចូរដឹងថា យើងជាព្រះអរហន្ត ។ ពាក្យថា ធ្វើដូចជាចូល សមាធិ មានន័យថា ហាក់ដូចតាំងមាំឲ្យគេឃើញដោយឈានសមាធិ ពាក្យថា ក្លែងចូលឈាន មានន័យថា អង្គុយដូចចូលសមាធិក្នុងទី ដែលមនុស្សស្រញូរទៅមក ឈ្មោះថា ក្លែងចូលឈានក្នុងកន្លែងដែល ប្រាកដជនតាមផ្លូវ ។

បទថា **ឥរិយាបថសណ្ឋិតំ** ដែលជាការសង្រួមឥរិយាបថ ។

បទថា **បច្ចយបដិសេវនសណ្ឋាតេន** គឺដោយការសេពបច្ច័យ ដែលបណ្ឌិតពោលទុកយ៉ាងនេះថា ការសេពបច្ច័យដែលខ្លួនធ្វើឲ្យ កើតឡើងដោយឧបាយមិនល្អ, ឬដោយការសេពបច្ច័យដែលនឹងគប្បី ពោលទុកគប្បីប្រាប់នោះ ។ការពោលក្នុងទីជិតខ្លួនធ្វើដូចជាទីជទៃ ឈ្មោះថា ខ្សឹបក្នុងទីជិត ។ លោកពោលថា **អដ្ដបនា** ព្រោះ **វស្សៈ អា** អក្សរចេញ ។ ការធបោក ឈ្មោះថា **កុហ**, ការដល់ គឺការ ប្រព្រឹត្តិទៅនៃការធបោកនោះ ឈ្មោះថា **កុហាយនា**, ឬការទៅគតិ

ការធ្វើរបស់បុគ្គលដែល ( កុហក ) **ឆបោក** ឈ្មោះថា **កុហាយនា** ។ ឈ្មោះថា **កុហិតោ** គឺអ្នកកុហក ព្រោះអត្ថថា រមែងឆបោក ឬទៅហើយដោយការឆបោក ។ ពាក្យថា ភិក្ខុត្រូវគេសួរ បានដល់ ភិក្ខុដែលត្រូវគេសួរហើយថា នរណា គឺតិស្សៈ, នរណាដែលព្រះរាជាបូជាហើយ ។

ពាក្យថា ធ្វើឲ្យគេខ្ពង់ខ្ពស់ បានដល់ លើកឡើង គឺផ្គងទុកដោយអាការ មានភាពដល់ព្រមដោយសម្បត្តិជាដើម ។ ពាក្យថា និយាយចង មានន័យថា ការចង គឺសម្ពន្ធហើយរឿយៗ ។ បានឮថា ភិក្ខុ ២ អង្គចូលទៅកាន់ផ្ទះ មួយអង្គុយលើអាសនៈ ហើយក៏ហៅកុមារិកាម្នាក់មក, ពេលនោះកុមារិកានោះមកហើយ, ក្នុងបណ្តាភិក្ខុ ២ អង្គនោះ ភិក្ខុមួយអង្គ ផ្តើមសួរភិក្ខុមួយអង្គទៀតថា លោកដ៏ចម្រើននាងកុមារិកានេះជាធីតារបស់អ្នកណា ។ ភិក្ខុដែលត្រូវសួរ ទើបផ្តើមរឿងឡើងថា ជាធីតារបស់នាងតេលកន្ទរិកា ឧបដ្ឋាករបស់ខ្ញុំ, មាតារបស់នាងទារិកានេះ ពេលដែលខ្ញុំទៅផ្ទះ កាលឲ្យសប្បិ ( ទឹកដោះថ្លា ) ក៏ឲ្យទាំងថ្នាំងតែម្តង, សូម្បីទារិកានេះក៏ឲ្យទាំងថ្នាំងដូចគ្នានឹងមាតា (របស់គេ ) ។ ទើបពោលថា **តេលកន្ទរិកវត្ថុ បេត្ថ វត្តព្វំ** ( ក៏ក្នុងរឿងនេះបណ្ឌិតគប្បីពោលរឿងនាងតេលកន្ទរិកាមកសាធកៈ ) លោកសំដៅយករឿងនេះ ។

ពាក្យថា ឬគួរដល់ធម្ម មានន័យថា ឬសមគួរដល់ពាក្យល្មមប្រមាណ ។

ពិតហើយ ពាក្យល្មមប្រមាណ លោកហៅថា ធម៌ ដូចដែលលោកពោលទុកថា **សុភាសិតំ ឧត្តមមាហុ សន្តោ ធម្មំ ភណេ នាធម្មំ តំ ទុតិយន្តិ** (សប្បុរសទាំងឡាយពោលពាក្យជាសុភាសិតថាជាពាក្យដ៏ខ្ពង់ខ្ពស់ បុគ្គលគប្បីពោលពាក្យដែលជាធម៌ មិនគប្បីពោលពាក្យដែលមិនមែនជាធម៌ នោះជាគម្រប់ ២) ។ ព្រោះដូច្នោះ ទើបលោកពោលចំពោះការនិយាយច្រើនថា ជាការរអ៊ូរទាំរវើរវាយ, ម្យ៉ាងទៀត វាចាសុភាសិតដែលចេញពីពាក្យសត្យ គប្បីជ្រាបថា ឈ្មោះថា ធម៌ ។ បុគ្គលដែលមានការធ្វើដូចជាសណ្តែកស្ងោរ ឈ្មោះថា **មុគ្គសូប** អ្នកដូចជាសណ្តែកស្ងោរ ។ ព្រោះហេតុនោះ ទើបលោកពោលថា **អយំ បុគ្គលោ មុគ្គសុបោតិ វុច្ចតិ** បុគ្គលនេះឯងលោកហៅថា មុគ្គសូប (មនុស្សដូចសណ្តែកស្ងោរ) ។

ការងាររបស់បុគ្គលអ្នកទទួលចិញ្ចឹមក្មេង ឈ្មោះថា **បារិភដ្យំ**, **បារិភដ្យំ** នោះឯងជា **បារិភដ្យតា** ។

ភិក្ខុអ្នកប្រព្រឹត្តហើយដោយនិមិត្ត, ម្យ៉ាងទៀត អ្នកធ្វើការបួញមាត់មិននិយាយដើម្បីចិញ្ចឹមជីវិត ឈ្មោះថា **នេមិត្តិកោ** ភាវៈនៃបុគ្គលអ្នកធ្វើការបួញមាត់ ដើម្បីចិញ្ចឹមជីវិតនោះ ឈ្មោះថា **នេមិត្តិកតា** ។

ការប្រកាសនូវសេចក្តីត្រូវការរបស់ខ្លួនឈ្មោះថា ឱភាស ( និយាយឲ្យន័យ ) ។

សួរថា ឱភាស នោះគឺអ្វី ?

ឆ្លើយថា ពោលទាក់ទងដល់បច្ច័យ មានពាក្យថា ថ្ងៃនេះពួកភិក្ខុរកបច្ច័យ បានយ៉ាងលំបាក ដូច្នេះជាដើម ។ ការនិយាយបញ្ចិតបញ្ចៀងដល់វត្ថុដែលខ្លួនប្រាថ្នា ឈ្មោះថា **សាមន្តជប្បន** ( និយាយបញ្ចិតបញ្ចៀង ) ។

ការផ្តាសាដោយអក្កោសវត្ថុ ១០ ដោយគិតថា បុគ្គលនឹងគប្បីឲ្យ ព្រោះខ្លាចផ្តាសាក៏មាន ។ ពាក្យសម្តីមានការនិយាយបន្ទំជាដើមក៏ដូចគ្នា ។ ការនិយាយបន្ទំ បានដល់ ការនិយាយបើកចេញទៅខាងក្រៅចាកសេចក្តីចំពោះឧបាសកជាទាយកជាដើម ។

ការនិយាយចំអកចំអន់ ឈ្មោះថា **ខិបនា** ។ ពាក្យនិយាយចំអកចំអន់នោះ ជាពាក្យពោលសើចចំអន់ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ឧប្បណ្ឌនា** ដូច្នេះ ។

ការនិយាយថា គេមិនមែនជាទាយក ឬការនិយាយបន្ទំឲ្យខូចខាត ឈ្មោះថា **បាបនា** ។ អ្នកមានប្រក្រតីកាត់សាច់ស៊ីក្រោយខ្នងរបស់អ្នកដទៃ ឈ្មោះថា **បរបិដ្ឋិមំសិកោ** ( អ្នកនិន្ទាក្រោយខ្នង ), ភាវៈនៃ **បរបិដ្ឋិមំសិកោ** នោះឯង ឈ្មោះថា **បរបិដ្ឋិមំសិកតា** ។

បទថា **អត្តគ្គំ** ប្រែថា ទម្លាយ ( ការកាត់បន្ថយសេចក្តីល្អរបស់អ្នកដទៃ ) ។

ពាក្យថា ដូចជាកិនគន្ធជាតិរកក្លិនក្រអូប មានន័យថា បណ្ឌិតគប្បីឃើញថា ការបានបច្ច័យដែលមិនទាន់បានដោយការកិនកម្ទេច, ក្នុងពេលមិនទាន់បានកិនកម្ទេចនូវគុណ គឺសេចក្តីល្អរបស់អ្នកដទៃ ក៏ដូចជាការបាននូវក្លិនក្រអូបដែលនៅមិនទាន់បានដោយការកិន,ក្នុងពេលមិនទាន់បានក្លិនក្រអូប ( មានន័យថា ដើម្បីនឹងរកក្លិនក្រអូបត្រូវកិនបំបែករបស់ក្រអូប ទើបនឹងបានក្លិនក្រអូប,បច្ច័យក៏ទំនងដូចគ្នា ) ។

សេចក្តីត្រូវការដើម្បីនឹងកោង គឺដើម្បីយកលាភតូចបញ្ឆោតឲ្យបានលាភធំ ហើយកាន់យក នោះឈ្មោះថា **និជិគីសន** ភាវៈនៃ **និជិគីសន** នោះឈ្មោះថា **និជិគីសនតា** បានដល់ អាការនៃការប្រព្រឹត្តទៅនៃសេចក្តីប្រាថ្នានោះៗ ឯង ឬបានដល់ ការធ្វើការស្វែងរកដែលកើតរួមជាមួយអាការនោះ ។ពាក្យថា អង្គំ ការដឹងដែលប្រព្រឹត្តចំពោះអវយវៈមានដៃនិងជើងជាដើម ។បទថា **និមិត្តំ** បានដល់ **នេមិត្តសាស្ត្រ** ( វិជ្ជាទាយប្រផ្នូល ) ។ បទថា **ឧប្បាតំ** បានដល់ មាន **ឧក្កាបាត** ភ្លើងឆេះព្រៃគ្រប់ទិសនិងរញ្ជួយផែនដីជាដើម ។បទថា **សុបិនំ** គឺសាស្ត្រ ។ បទថា **លក្ខណំ** គឺវិជ្ជាមើលលក្ខណៈរបស់ស្ត្រី-បុរស ។ បទថា **មូសិកច្ឆិន្នំ** គឺ **វិជ្ជាទំនាយ** ថា នៅពេលកណ្តុរកាត់សំពត់ត្រង់កន្លែង

នោះនៃសំពត់ជាដើម ទឹងមានផលឈ្មោះនេះ ។ វិធីបូជាភ្លើង គឺការបូជាភ្លើងថា ពេលបូជា ភ្លើងឈ្មោះនេះក្នុងបណ្តាភ្លើង មានភ្លើងចំបើងជាដើម ទឹងមានផលឈ្មោះនេះ ឈ្មោះថា **អគ្គិហោម** (វិធីបូជាភ្លើង) ។ គប្បីជ្រាបថា វិធីបន្ទិលផ្សេងក៏មានន័យដូចគ្នា ។

ដោយ អាទិ-ស័ព្ទ គប្បីជ្រាបថា លោកសង្គ្រោះយកភ្លើងអង្គាមជាដើម ព្រមទាំងសង្គ្រោះមិច្ឆាជីពផ្សេងៗ ដែលមកក្នុងព្រះសូត្រ ។

ព្រោះអាជីវបារិសុទ្ធិសីល មានសេចក្តីព្យាយាមជាគ្រឿងធ្វើឲ្យសម្រេច ទើបលោកពោលថា សេចក្តីព្យាយាមក្នុងការស្វែងរកបច្ច័យ ដូច្នេះ ។

សេចក្តីបរិសុទ្ធិនៃអាជីវៈនោះ ជាសេចក្តីព្យាយាមរកទោសមិនបាន ដែលជាហេតុឲ្យមានការបានបច្ច័យដោយធម៌ជានិច្ច ។ ព្រោះបុគ្គលខ្ជិលច្រអូសមិនអាចស្វែងរកបច្ច័យដោយត្រឹមត្រូវបានឡើយ ។

( ចប់ មហាដីកា )

( ចប់ អាជីវបារិសុទ្ធិសីល )

................................

## បច្ចយសន្និស្សិតសីល

ការបរិភោគបច្ច័យ ៤ ដែលបរិសុទ្ធដោយការពិចារណាដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យថា ភិក្ខុពិចារណាដោយឧបាយនៃបញ្ញាហើយ សេពនូវចីវរថា ត្រឹមតែដើម្បីបំបាត់នូវភាពរងា ដូច្នេះជាដើម ។

នេះឈ្មោះថា បច្ចយសន្និស្សិតសីល ។

# មហាដីកា

សេចក្ដីបរិសុទ្ធិ គឺមិនសៅហ្មងដោយការពិចារណា គឺ **បច្ចវេក្ខ-ណៈ** ឈ្មោះថា **បដិសង្ខានបរិសុទ្ធិ** ( បរិសុទ្ធដោយការពិចារណា )។

សភាវៈឈ្មោះថា **ចតុប្បច្ចយបរិភោគោ** ព្រោះអត្ថថា ជាហេតុបរិភោគបច្ច័យ ៤ បានដល់ចេតនាដែលរកទោសមិនបាន ដែលប្រព្រឹត្តទៅហើយដោយប្រការនោះៗ ។

( ចប់ មហាដីកា )

## ពណ៌នាបច្ចយសន្និស្សិតសីល

ចំណែកបច្ចយសន្និស្សិតសីល ដែលពោលទុកក្នុងលំដាប់នៃអាជីវបារិសុទ្ធិសីលនោះគប្បីជ្រាបអត្ថាធិប្បាយក្នុងបច្ចយសន្និស្សិតសីលនោះដូចតទៅនេះ

### ចីវរ

ពាក្យថា ពិចារណាដោយឧបាយនៃបញ្ញា មានន័យថា ពិចារណា គឺដឹង សម្លឹងដោយឧបាយ គឺដោយ ( ត្រូវ ) ផ្លូវ, មែនពិត ការសម្លឹង ដែលពោលទុកដោយន័យថា ដើម្បីបំបាត់ភាពរងាជាដើមនោះឯង បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា ពិចារណាដោយឧបាយនៃបញ្ញា ក្នុងទីនេះ ។ ក្នុងបទទាំងនោះ បទថា **ចីវរ** បានដល់ បណ្ដាសំពត់មានអន្តរវាសកជាដើម ផ្លុំងណាមួយ ។ បទថា **សេព** ចំពោះ គឺប្រើប្រាស់ បានដល់ ស្លៀក ឬដណ្ដប់ ។ ពាក្យថា **យាវទេវ** ជាពាក្យនិយមកំណត់ដែននៃប្រយោជន៍ ពិតហើយ ប្រយោជន៍ក្នុងការប្រើចីវររបស់ព្រះយោគី ក៏មានប៉ុណ្ណោះឯង នោះគឺអ្វី ? គឺប្រយោជន៍ ដើម្បីបំបាត់ភាពរងាជាដើម មិនហួសពីនេះទេ ។

ពាក្យថា **ភាពរងា** បានដល់ ភាពរងាដែលកើតឡើងដោយអំណាចការកម្រើកនៃធាតុខាងក្នុងក្ដី ដោយអំណាចការប្រែប្រួល

នៃរដូវខាងក្រៅក្តី យ៉ាងណាមួយ ។

បទថា **បដិឃាតាយ** ប្រែថា ដើម្បីបំបាត់ គឺដើម្បីបន្ទោបង់នូវភាពរងានោះ ដែលធ្វើឲ្យវាមិនអាចញ៉ាំងអាពាធឲ្យកើតឡើងក្នុងសរីរៈបាន ព្រោះថា ពេលសរីរៈ ត្រូវរងាបៀតបៀនហើយ ភិក្ខុមានចិត្តរសាប់រសល់ មិនអាចតាំងសេចក្តីព្យាយាម ដោយប្រពៃបាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតថា គប្បីប្រើចីវរដើម្បីបំបាត់ភាពរងាបាន ន័យនេះ គប្បីជ្រាបប្រយោជន៍ដ៏សេសទាំងពួង ព្រោះក្នុងអធិការនេះបានពោលទុកអស់ជើងហើយ ។បទថា ភាពក្តៅ គឺភាពក្តៅនៃភ្លើង បណ្ឌិតគប្បីជ្រាបដែនកើតនៃភាពក្តៅនោះ ព្រោះភ្លើងព្រៃជាដើម ។

ចំណែកក្នុងប្រជុំបទថា **ឌំសមកសវាតាតបសិរីសបសម្ផស្សានំ** នោះគប្បី ជ្រាបអត្ថាធិប្បាយដូចតទៅនេះ

បទថា **ឌំសា** ប្រែថា សត្វរបោម អាចារ្យខ្លះថា សត្វរុយក្បាលខៀវក៏មាន ។

បទថា **មកសា** ប្រែថា សត្វមូសនោះឯង ។

បទថា **វាតា** បានដល់ ខ្យល់ទាំងឡាយ មានខ្យល់លាយភ្លៀងនិងខ្យល់មិនលាយភ្លៀងជាដើម ។ បទថា **អាតបោ** គឺកម្តៅថ្ងៃ ។សត្វដែលលូនទៅគ្រប់ប្រភេទ ឈ្មោះថា **សិរីសប** បានដល់ ជំពូកសត្វ

ដែលមានខ្លួនវែង មានពស់ជាដើម សម្ផស្សរបស់សត្វទាំងឡាយ នោះមាន ២ យ៉ាង គឺសម្ផស្សដោយការខាំ ១ សម្ផស្សដោយការពាល់ត្រូវ ១, សម្ផស្ស ២ យ៉ាងនោះ មិនអាចបៀតបៀន ភិក្ខុដែលអង្គុយហ៊ុំចីវរបានទេ ព្រោះហេតុនោះ ក្នុងទីដូច្នោះ ទើបភិក្ខុសេពចីវរ ដើម្បីជាប្រយោជន៍ដល់ការការពារសម្ផស្សទាំងឡាយ ការពោលពាក្យថា **យាវទេវ** នេះទៀត ក៏ដើម្បីសម្តែងនូវការកំណត់ដែននៃប្រយោជន៍ពិតហើយការបិទបាំងអវយវៈ ដែលញ៉ាំងសេចក្តីខ្មាសអៀនឲ្យកម្រើកជាប្រយោជន៍ប្រចាំ ប្រយោជន៍ក្រៅពីនេះ គឺមានម្តងម្កាលប៉ុណ្ណោះ ។

ពាក្យថា **ហិរិកោបិនំ** ក្នុងបទថា **ហិរិកោបិនប្បដិច្ឆាទនត្ថំ** នោះសំដៅយកទីចង្អៀតនោះៗ ពិតហើយ ពេលអវយវៈណាៗ ដែលបុគ្គលបើកចេញ ការអៀនខ្មាសរមែងកម្រើក គឺរមែងវិនាស អវយវៈនោះ លោកហៅថា **ហិរិកោបិន** ព្រោះជាហេតុញ៉ាំងការអៀនខ្មាសឲ្យកម្រើក សេចក្តីនៃបទនោះថា ដើម្បីបិទបាំងនូវអវយវៈ **ហិរិកោបិន** នោះឯង ព្រោះហេតុនោះ ( បាឋៈទើបគួរ ) **ហិរិកោបិនប្បដិច្ឆាទនត្ថំ** ( តែ ) បាឋៈថា **ហិរិកោបិន បដិច្ឆាទនត្ថំ** ក៏មាន ។

## បិណ្ឌបាត

បទថា **បិណ្ឌបាត** បានដល់ អាហារយ៉ាងណាមួយ ក៏អាហារ

យ៉ាងណាមួយ លោកហៅថា បិណ្ឌបាត ព្រោះអាហារនោះធ្លាក់ចុះក្នុងបាត្ររបស់ភិក្ខុដោយការភិក្ខាចារ, ម្យ៉ាងទៀត ការធ្លាក់ចុះនៃដុំបាយទាំងឡាយ អធិប្បាយថា ការប្រជុំការរួមគ្នានៃភិក្ខាទាំងឡាយដែលភិក្ខុបានហើយក្នុងទីនោះៗ ឈ្មោះថា បិណ្ឌបាត ។

បទថា **នេវ ទវាយ** គឺដើម្បី **ទវ** អធិប្បាយថា ប្រាថ្នានឹងលេងដូចជាទារកទាំងឡាយ មានគាមទារកជាដើមក៏ទេ ។ បទថា **ន មទាយ** គឺដើម្បី **មទ** អធិប្បាយថា ប្រាថ្នាការស្រវឹងក្នុងកម្លាំងកាយ និងប្រាថ្នាការស្រវឹងក្នុងភាពជាបុរស ដូចជាពួកអ្នកប្រដាល់ជាដើមក៏ទេ ។ បទថា **ន មណ្ឌនាយ** គឺដើម្បី **មណ្ឌន** អធិប្បាយថា ប្រាថ្នាភាវៈ គឺការធ្វើអវយវៈតូចធំ ឲ្យធំធាត់ ដូចជាស្រីស្នំ និងស្រ្តីពេស្យាជាដើមក៏ទេ ។

បទថា **ន វិភូសនាយ** គឺដើម្បី **វិភូសន** អធិប្បាយថា ប្រាថ្នាភាពមានពណ៌សម្បុរផូរផង់ ដូចជាតួល្ខោន និងអ្នករបាំជាដើមក៏ទេ ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា ក្នុង ៤ បទនោះ បទថា **នេវ ទវាយ** នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដើម្បីលះនូវឧបនិស្ស័យនៃមោហៈ ។

បទថា **ន មទាយ** នោះ ត្រាស់ដើម្បីលះនូវឧបនិស្ស័យនៃទោសៈ ។ ពីរបទថា **ន មណ្ឌនាយ ន វិភូសនាយ** នោះ ត្រាស់ដើម្បីលះបង់នូវឧបនិស្ស័យនៃរាគៈ ។

ម្យ៉ាងទៀត ពីរបទថា **នេវ ទវាយ ន មទាយ** នេះ ត្រាស់ដើម្បីការពារការ កើតឡើងនៃសំយោជនៈរបស់ខ្លួន ។ ពីរបទថា **ន មណ្ឌនាយ ន វិភូសនាយ** នេះ ត្រាស់ដើម្បីការពារ ការកើតឡើងនៃសំយោជនៈរបស់អ្នកដទៃផង ម្យ៉ាងទៀត ការលះអយោនិសោបដិបត្តិ និងកាមសុខល្លិកានុយោគោ ក៏ទ្រង់ត្រាស់ដោយបទទាំង ៤ នោះផងដែរ ។

បទថា **យាវទេវ** មានអធិប្បាយដូចពោលហើយនោះឯង ។ បទថា **ឥមស្ស កាយស្ស** គឺនៃរូបកាយដែលប្រកបដោយមហាភូតរូប ៤ នេះ ។ បទថា **ឋិតិយា** ដើម្បីការតាំងនៅតទៅ ។ បទថា **យាបនាយ** គឺដើម្បីការមិនដាច់ខ្សែនៃការប្រព្រឹត្តិ ឬដើម្បីការតាំងនៅអស់កាលយូរ ពិតហើយភិក្ខុនេះរមែងសេពបិណ្ឌបាតដើម្បីការតាំងនៅនៃកាយ និងដើម្បីការប្រព្រឹត្តិទៅបាន ដូចជាម្ចាស់នៃផ្ទះដែលចាស់ ទល់ផ្ទះ និងដូចជាឈ្នួញរទេះបន្តក់ ( ប្រេង ) ភ្លៅរទេះដូច្នោះ មិនមែនដើម្បីលេង, ដើម្បីស្រវឹង ដើម្បីតុបតែង និងដើម្បីចម្រើនសម្បុរក៏ទេ, ម្យ៉ាងទៀតគប្បីជ្រាបថា ពាក្យថា ឋិតិ នេះ ជាឈ្មោះរបស់ជីវិតិន្ទ្រិយ៍ ព្រោះហេតុនោះ ដោយពាក្យថា **ឥមស្ស កាយស្ស ឋិតិយា យាបនាយ** ត្រឹមប៉ុណ្ណោះ ទើបមានពាក្យអធិប្បាយថា ដើម្បីញ៉ាំងជីវិតិន្ទ្រិយ៍នៃកាយនេះ ឲ្យប្រព្រឹត្តទៅ ដូច្នេះក៏បាន ។ បទថា **វិហឹសុបរតិយា** មាន

វិនិច្ឆ័យថា ការស្រេកឃ្លាន ឈ្មោះថា **វិហឹសា** ព្រោះអត្ថថា ធ្វើឲ្យឈឺ, ពិតហើយ ភិក្ខុនេះសេព បិណ្ឌបាតដើម្បីរំងាប់ការស្រេកឃ្លាននោះ ដូចជាបុគ្គលលាបថ្នាំដំបៅ រក្សាដំបៅ និងមនុស្សឈឺ នៅពេលកើតអាការក្តៅ និងរងាជាដើម ក៏លេបថ្នាំព្យាបាលអាការនោះ ដូច្នោះ ។

បទថា **ព្រហ្មចរិយានុគ្គហាយ** គឺដើម្បីអនុគ្រោះសាសនព្រហ្មចរិយៈទាំងមូល (ដែលកើតមាន) ព្រោះការសេពបិណ្ឌបាតជាបច្ច័យ, បដិបត្តិដើម្បីឆ្លងផុតកន្តារ ដោយការប្រកបរឿយៗ ក្នុងសិក្ខា ៣ ឈ្មោះថា រមែងសេព (បិណ្ឌបាត) ដើម្បីអនុគ្រោះព្រហ្មចរិយៈ ដូចជា (គូរភរិយាស្វាមី) មានសេចក្តីត្រូវការឆ្លងផុតកន្តារ (បង្ខំចិត្ត) បរិភោគសាច់កូនឯង ដូចបុគ្គលត្រូវការឆ្លងទន្លេអាស្រ័យក្បូន និងដូចជាបុគ្គលត្រូវការឆ្លងសមុទ្រអាស្រ័យទូកដូច្នោះ ។ សេចក្តីថា **ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ** មានអធិប្បាយថា ភិក្ខុគិតថា ដោយប្រការនេះ គឺដោយការសេពបិណ្ឌបាតនេះ យើងនឹងកម្ចាត់វេទនា គឺការស្រេកឃ្លានចាស់ចេញផង និងមិនញ៉ាំងវេទនាថ្មីដែលមានការបរិភោគលើសប្រមាណជាបច្ច័យឲ្យកើតឡើងផង ដូចជាព្រាហ្មណ៍អាហរត្ថកៈ, ព្រាហ្មណ៍អលង្សាដកៈ, ព្រាហ្មណ៍តត្ថវដ្តកៈ, ព្រាហ្មណ៍កាកមាសកៈ, ព្រាហ្មណ៍ភុត្តវមិតកៈណាមួយដូច្នេះ ហើយសេព (បិណ្ឌបាត) ដូចជាបុគ្គលដែលឈឺ សេពភេសជ្ជៈដូច្នេះ នេះ

ន័យម្យ៉ាង ។ ន័យម្យ៉ាងទៀត គប្បីជ្រាបអត្ថាធិប្បាយក្នុងសេចក្ដីនេះថា វេទនាណាដែលលោកហៅថា វេទនាចាស់ ព្រោះអាស្រ័យការបរិភោគរបស់មិនជាសប្បាយ និងបរិភោគហួសប្រមាណក្នុងបច្ចុប្បន្នកើតឡើងដោយកម្មចាស់ជាបច្ច័យ យើងពេលដែលញ៉ាំងបច្ច័យនៃវេទនាចាស់ឲ្យស្ងប់ទៅហើយដោយការបរិភោគនូវរបស់ជាទីសប្បាយនិងបរិភោគល្មមប្រមាណ ឈ្មោះថា រមែងកម្ចាត់វេទនាចាស់នោះចេញបាន និងវេទនាដែលហៅថា វេទនាថ្មី ព្រោះអាស្រ័យកម្ម គឺការបរិភោគមិនប្រពៃដែលខ្លួនធ្វើក្នុងពេលឥឡូវនេះ ឲ្យកើតឡើងតទៅ យើងកាលបើមិនឲ្យមូលនៃវេទនាថ្មី នោះកើតឡើងដោយអំណាចនៃការបរិភោគល្អ ឈ្មោះថា នឹងមិនញ៉ាំងវេទនាថ្មី នោះឲ្យកើតឡើងផងដូច្នេះក៏បាន ។

ឯការកាន់យកនូវការបរិភោគល្អ ការលះអត្តកិលមថានុយោគនិងការមិនលះសេចក្ដីសុខដែលប្រកបដោយធម៌ (៣ ប្រការនេះ) គប្បីជ្រាបថា ទ្រង់សម្ដែងគ្រប់ហើយដោយបាឋៈត្រឹម ២ ប្រការនេះ ។

បទថា **យាត្រា ច មេ ភវិស្សតិ** មានន័យថា ភិក្ខុគិតថា ដោយការបរិភោគល្មមប្រមាណ ការប្រព្រឹត្តិទៅ ពោល គឺការធ្វើដំណើរទៅអស់កាលយូរ ព្រោះការមិនមានអន្តរាយដែលនឹងចូលមកកាត់ផ្ដាច់នូវជីវិតិន្ទ្រិយ៍ឬនឹងថយចុះនូវឥរិយាបថនឹងមានដល់យើង, ម្យ៉ាងទៀត

នឹងមានដល់រាងកាយរបស់យើង ដែលមានការប្រព្រឹត្តិទៅទាក់ទង ដល់បច្ច័យនេះផងដែរ ដូច្នេះហើយសេព (បិណ្ឌបាត) ដូចជាបុគ្គល មានរោគក៏រ៉ៃ ប្រើថ្នាំព្យាបាលរោគនោះដូច្នោះ ។

ពីរបទថា **អនវជ្ជតា ច ផាសុវិហារោ ច** មានន័យថា ភិក្ខុគិតថា ការរកទោសមិនបាន នឹងមានដល់យើងដោយវៀរចាកការស្វែងរក ការទទួល និងការបរិភោគដែលមិនល្អចេញនិងការនៅជាសុខនឹងមាន ដល់យើង ដោយការបរិភោគល្មមប្រមាណ ដូច្នេះ ។ ន័យម្យ៉ាងទៀត ថា ការរកទោសមិនបាន ព្រោះមិនមានទោសផ្សេងៗ ដូចជាការត្រេកអរ នឹងកាម ការខ្ជិលច្រអូស ការទម្រន់ ការដែលត្រូវអ្នកប្រាជ្ញតិះដៀល ជាដើម ព្រោះបរិភោគនូវរបស់មិនជាទីសប្បាយ និងបរិភោគហួស ប្រមាណជាបច្ច័យ នឹងមានដល់យើង ឯភាពជាសុខដែលមានរាង កាយមាំមួន ព្រោះបរិភោគអាហារជាសប្បាយ និងបរិភោគល្មម ប្រមាណជាបច្ច័យនឹងមានដល់យើង ដូច្នេះខ្លះ, ន័យម្យ៉ាងទៀត ការ មិនមានទោស ដោយការលះសុខក្នុងការដេក សុខក្នុងការពត់ខ្លួន សុខក្នុងការលក់ចេញបាន នឹងមានដល់យើង ដោយការវៀរចាកការ បរិភោគអាហារតាមដែលត្រូវការ រហូតពេញផ្ទៃ និងមានសេចក្តីសុខ ដោយឥរិយាបថ ៤ ដំណើរទៅសមប្រកបនឹងមានដល់យើងដោយ ការបរិភោគអាហារឲ្យខ្វះ ៤-៥ ដុំ ដូច្នេះ ហើយសេព ( បិណ្ឌបាត )

សមដូចពាក្យប្រព័ន្ធពោលទុកថា

យោគាវចរ ភិក្ខុគប្បីឈប់បរិភោគ ( មុនទឹងឆ្អែត ) ៤-៥ ដុំ ហើយផឹកទឹក ការបរិភោគត្រឹមប៉ុណ្ណោះ ក៏ល្មមហើយ ដើម្បីការនៅជាសុខនៃភិក្ខុដែលមានខ្លួន បញ្ជូនទៅហើយ ( គឺមិនអាល័យក្នុងរូបកាយ និងជីវិត ) ដូច្នេះ ។

ការកំណត់កាន់យកប្រយោជន៍និង៖.បដិបត្តិជាកណ្តាល គប្បីជ្រាបដោយទ្រង់សម្តែងហើយដោយបាឋ:ត្រឹម ៣ បទនេះ ( មានបទថា យាត្រា ជាអាទិ ) ។

## សេនាសនៈ

បទថា សេនាសន សំដៅយកទាំងទីដេក និងទីអង្គុយ ភិក្ខុដេកក្នុងទីណាៗនិងជាវិហារឬរោងផ្សេងៗមានរានហាលជាដើមក៏ដោយ ទីនោះៗ ឈ្មោះថា សេនាសនៈ ភិក្ខុរមែងអង្គុយសំរាកនៅក្នុងទីណាៗ ( ដូចពោលហើយ ) ទីនោះៗ ឈ្មោះថា អាសន រួមពីរពាក្យនោះចូលគ្នាហៅថា សេនាសនៈ ។

ពីរបទថា ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ អធិប្បាយថា រដូវនោះឯង ឈ្មោះ ឧតុបរិស្ស ( អន្តរាយ គឺរដូវ ) ព្រោះអត្ថថាបៀតបៀន សេចក្តីនៃពីរបទនោះថា ដើម្បីបន្ទោបង់ឧតុបរិស្សយផង

ដើម្បីរីករាយក្នុងការពួនសម្ងំ មានពាក្យពង្រីកសេចក្ដីថា វេទនាណា មិនជាសប្បាយ ធ្វើឲ្យសរីរៈមានអាពាធ និងការរសាប់រសល់នៃចិត្ត ជាវត្ថុដែលគប្បីបន្ទោបង់ចេញបាន ដោយការសេពនូវសេនាសនៈ ដើម្បីបន្ទោបង់វេទនានោះ និងដើម្បីឯកិយភាវសុខផង ពិតហើយ ការបន្ទោបង់នូវឧតុបរិស្សយ ក៏ទ្រង់បានត្រាស់ទុកហើយ ដោយបាលីខាងដើម មានពាក្យថា **សីតស្ស បដិឃាតាយ** ជាអាទិនោះ សូម្បីពិតដូច្នោះ គប្បីជ្រាបថា ទ្រង់ត្រាស់ពាក្យនេះទុកក្នុងពេលក្រោយទៀត, ( ដោយ ) ទ្រង់បំណង ( ឲ្យជ្រាបថា ) ការបន្ទោបង់ឧតុបរិស្សយ ជាប្រយោជន៍ប្រចាំ ដូចពាក្យពោលទុកហើយក្នុងពេលសេពចីវរ ថា ការបិទបាំងអវយវៈដែលញ៉ាំងសេចក្ដីខ្មាសអៀនឲ្យកម្រើក ជាប្រយោជន៍ប្រចាំ ប្រយោជន៍ក្រៅពីនេះរមែងមានម្ដងម្កាល ដូច្នេះ ។

ន័យម្យ៉ាងទៀត វេទនាមានប្រការដូចពោលមកនេះ គង់ជាឧតុ ( មួយចំណែក ) ចំណែកបរិស្សយ ( ជាចំណែកមួយទៀត ) មាន ២ យ៉ាង គឺ **បាកដបរិស្សយ** អន្តរាយបើកបង្ហាញ ១, **បដិច្ឆន្នបរិស្សយ** អន្តរាយបិទបាំង ១ ក្នុងអន្តរាយ ២ យ៉ាងនោះ

**អន្តរាយបើកបង្ហាញ** បានដល់ សត្វសាហាវទាំងឡាយ មានសីហៈ និងខ្លាជាដើម ។

**អន្តរាយបិទបាំង** បានដល់ កិលេសទាំងឡាយមានរាគៈ និង

ទោសៈជាដើម អន្តរាយទាំងឡាយនោះឯង រមែងធ្វើសេចក្តីអាពាធ ឲ្យហេតុ ព្រោះមិនមានកន្លែងការពារខ្លួនក្តី, ហេតុ (សម្លឹងមើលទៅ) ឃើញរូបដែលជាអសប្បាយជាដើមក្តីមិនបាន, ក្នុងសេនាសនៈណា ភិក្ខុកាលដឹងយ៉ាងនោះហើយ ពិចារណា សេពនូវសេនាសនៈនោះ គប្បីជ្រាបថា ឈ្មោះថា ពិចារណាដោយបញ្ញាហើយ សេពនូវសេនាសនៈ ។ល។ ដើម្បីបន្ទោបង់រដូវ និងអន្តរាយ ដូច្នេះ ។

## គិលានប្បច្ចយភេសជ្ជបរិក្ខារ

ក្នុងបទថា **គិលានប្បច្ចយភេសជ្ជបរិក្ខារំ** នេះ មានវិនិច្ឆ័យថា ភេសជ្ជៈ ឈ្មោះថា បច្ច័យ ព្រោះអត្ថថាជាគ្រឿងប្រឆាំងនឹងរោគ មានសេចក្តីថា ជាថ្នាំ ព្យាបាលរោគ ពាក្យថា **បច្ច័យនេះ** ជាឈ្មោះរបស់ភេសជ្ជៈដែលជាសប្បាយយ៉ាងណាមួយ ដែលឈ្មោះថា **ភេសជ្ជៈ** ព្រោះហេតុថា ជាវត្ថុដែលពេទ្យគប្បីធ្វើ (ត្រៀម) ព្រោះជាវត្ថុដែលពេទ្យផ្តល់ឲ្យភេសជ្ជៈ គឺជាបច្ច័យនៃអ្នកជំងឺ ឈ្មោះថា គិលានប្បច្ចយភេសជ្ជៈ សំដៅដល់វត្ថុដែលពេទ្យធ្វើជាសប្បាយចំពោះអ្នកជំងឺ យ៉ាងណាមួយ ដូចជាប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើម ។

**បរិវារ** (គ្រឿងចោមរោម) ព្រះមានព្រះភាគត្រាស់ថា **បរិក្ខារ**

ក្នុងបាលីថា ព្រះនគរជាស្ថានដែលគេព័ទ្ធល្អហើយ ដោយនគរបរិក្ខារ ៧ ជាដើម, អលង្ការ ( គ្រឿងប្រដាប់ ) ក៏ត្រាស់ថា បរិក្ខារ ក្នុងបាលីថា រថ មានសីលជាបរិក្ខារ មានឈានជាភ្លៅ មានសេចក្ដីព្យាយាមជាកង់ជាដើម, សម្ភារៈ ( គ្រឿងទ្រ ) ក៏ត្រាស់ថា បរិក្ខារ ក្នុងបាលីមានថា ជីវិតបរិក្ខារទាំងឡាយនេះ យ៉ាងណាមួយ បព្វជិតរកបានដោយប្រពៃជាដើម, ក្នុងបទថា គិលានប្បច្ចយភេសជ្ជបរិក្ខារ នេះ រមែងគួរទាំងសម្ភារៈទាំងបរិក្ខារ, ពិតហើយ គិលានប្បច្ចយភេសជ្ជៈនោះឈ្មោះថា ជាគ្រឿងការពារជីវិតក៏បាន ព្រោះជាគ្រឿងរក្សា ( ជីវិត ) មិនឲ្យចូលដល់អាពាធដែលនឹងធ្វើជីវិតឲ្យវិនាសកើតឡើងបាន ឈ្មោះថា ជាគ្រឿងគាំទ្រជីវិតក៏បាន ព្រោះជាគ្រឿងបណ្ដាលជីវិតឲ្យយឺនយូរ ព្រោះដូច្នោះ គិលានប្បច្ចយភេសជ្ជៈនោះ ទើបទ្រង់ត្រាស់ហៅថា បរិក្ខារ ។

ដូច្នេះ(បទនេះទើបធ្វើវិគ្រោះបានថា)**គិលានប្បច្ចយភេសជ្ជញ្ច តំ បរិក្ខារោ ចាតិ គិលានប្បច្ចយភេសជ្ជបរិក្ខារោ** (បរិក្ខារ គឺភេសជ្ជៈដែលជាថ្នាំព្យាបាលរោគនៃអ្នកជំងឺ ) សេចក្ដីនៃបាឋៈនោះថា... នូវគិលានប្បច្ចយភេសជ្ជបរិក្ខារនោះអធិប្បាយថា នូវគ្រឿងទំនុកបម្រុងនៃជីវិត មានប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើម ដែលពេទ្យផ្ដល់ឲ្យជាទីសប្បាយនៃអ្នកជំងឺ យ៉ាងណាមួយ ។

បទថា **ឧប្បន្នានំ** ប្រែថា កើតហើយ មានហើយ បង្កើតឡើងហើយ, ក្នុងបទថា **វេយ្យាពាធិកានំ** នេះ ការកម្រើកនៃធាតុ ឈ្មោះថា អាពាធ ចំណែករោគផ្សេងៗ មានរោគឃ្លង់ បូស និងដំបៅពងបែកជាដើម ដែលមានការកម្រើកនៃធាតុនោះជាសមុដ្ឋាន ឈ្មោះថា វេយ្យាពាធិក ព្រោះកើតពីអាពាធ ។

បទថា **វេទនា** បានដល់ ទុក្ខវេទនា គឺវេទនាដែលជាវិបាករបស់អកុសល គឺ ( ដើម្បីបំបាត់ចេញ ) នូវវេទនាទាក់ទងដោយរោគ ដែលកើតពីអាពាធទាំងឡាយនោះ ។ បទថា **អព្យាបជ្ឈបរមតាយ** មានន័យថា ដើម្បីសេចក្ដីមិនមានទុក្ខតែម្យ៉ាង អធិប្បាយថា ត្រឹមតែទុក្ខនោះវិនាសអស់ទៅ ។

សីល ដែលមានការពិចារណាដោយបញ្ញាជាមុន ហើយទើបបរិភោគបច្ច័យជាក្រោយ លក្ខណៈនេះ បណ្ឌិតគប្បីជ្រាបថា បច្ចយសន្និស្សិតសីល ដោយសង្ខេប ដោយប្រការដូច្នេះ, ចំណែកអត្ថនៃពាក្យ ក្នុងពាក្យថា បច្ចយសន្និស្សិតសីល នេះ គប្បីជ្រាបដូច្នេះ ក៏គ្រឿងអាស្រ័យមានចីវរជាដើម លោកហៅថា បច្ច័យ ព្រោះជាទីដែលសត្វទាំងឡាយអាស្រ័យ គឺប្រើបរិភោគ ទើបប្រព្រឹត្តទៅបាន គឺទើបរស់នៅបាន មានន័យថា ទើបប្រព្រឹត្តទៅបាន សីលនេះអាស្រ័យបច្ច័យទាំងឡាយនោះ ព្រោះហេតុនោះទើបឈ្មោះថា បច្ចយសន្និស្សិត ។

# មហាដីកា

## ពណ៌នាបច្ចយសន្និស្សិតសីល

សព្ទថា **បដិសង្ខា** នេះជានិទ្ទេសដោយលប់ **យ** អក្សរ ដូចក្នុងពាក្យជាដើមថា **សយំ អភិញ្ញា** ។ លោកអាចារ្យកាលនឹងសម្ដែងថា យោនិសោ-សព្ទ ក្នុងពាក្យថា **យោនិសោ** នេះ មានអត្ថថា ឧបាយ ទើបពោលថា ដោយឧបាយគឺដោយត្រូវផ្លូវ ។ លោកអាចារ្យពោលថា ពិចារណាហើយ គឺដឹងហើយ ដូច្នេះហើយ ទើបពោលថា សេចក្ដីថា ពិចារណាហើយ ដូច្នេះជាដើម ក៏ដើម្បីសម្ដែងថា ការពិចារណានេះនោះ បានដល់ **បច្ចវេក្ខណញ្ញាណ** ។

ដូចជាពាក្យថា **បច្ចវេក្ខិត្វា** មានន័យថា ឃើញចំពោះប្រយោជន៍នោះៗ មានការការពារភាពរងាជាដើម, អធិប្បាយថា ឃើញដោយញាណ យ៉ាងណា, ពាក្យថា **បដិសង្ខាយ** ក៏ដូច្នោះ មានន័យថា ពិចារណាចំពោះៗ ហើយនូវប្រយោជន៍នោះៗ ឯង, អធិប្បាយថា ដឹងហើយ ព្រោះ សង្ខា-សព្ទ ក្នុងទីនេះ ជាបរិយាយនៃញាណនោះឯង ។ តែក្នុងទីនេះ អាចារ្យមួយពួកទៀតពោលទុកថា ពាក្យថា **បដិសង្ខា យោនិសោ** ជាដើម លោកពោលដោយកាលដែលបរិភោគបច្ច័យដោយពិត សូម្បីដូច្នោះ បច្ចយសន្និស្សិតសីលនឹងបរិសុទ្ធបាន

ក៏ដោយការពិចារណាទាក់ទងដោយភាពជាធាតុ ឬទាក់ទងដោយភាព ជារបស់បដិកូល ។ អាចារ្យពួកខ្លះពោលថា បច្ចយសន្និស្សិតសីល រមែងបែកធ្លាយ ។ តែអាចារ្យមួយពួកទៀតពោលថា កំណត់ទុកមុន តែម្យ៉ាង, បណ្ឌិតគប្បីពិចារណាចុះ ។

លោកអាចារ្យពោលថា ក្នុងបណ្ដាសំពត់អន្តរវាសកៈ សំពត់ប្រភេទណាមួយ ដោយបំណងយកថា ចីវរ ជាឯកវចនៈ ប្រាប់ត្រឹមតែមួយ ។

ពាក្យថា **ចីវរំ** ក្នុងព្រះបាលីជាឯកវចនៈ ព្រោះពាក្យនោះ ជាស័ព្ទពោលដល់ជាតិ ( គឺប្រភេទ ) ដូច្នេះទើបអាចប្រាប់បានថា ព្រះយោគីគប្បីរក្សាចីវរដោយមានប្រមាណត្រឹមណា ទ្រង់កាន់យកចីវរមានប្រមាណប៉ុណ្ណោះ ទាំងអស់នោះ ទុកជាមួយគ្នា, ម្យ៉ាងវិញទៀត ពាក្យថា **ប្រភេទណាមួយ** នេះជាការកំណត់កាន់យកមិនមានចំណែកសល់, មិនមែនជាពាក្យអនិយម ។ ចំណែកការកំណត់ថា គ្រង ឬ ឃុំ ដូច្នេះ ជាការសម្ដែងដល់ការប្រើប្រាស់ដែលជាបរិយាយ នៃការសេពចំពោះ ( នូវចីវរ ) គប្បីឃើញថា ទ្រង់បញ្ញត្តដល់ការបរិភោគនោះដោយប្រការដូច្នេះ ហើយទើបសង្គ្រោះដល់ការប្រើប្រាស់ សូម្បីទាក់ទងជាមួយការធ្វើជាទីដេក ទីអង្គុយ និងការប្រក់បាំងដោយសំពត់ជាដើម ។

ដែននៃប្រយោជន៍ទាំងឡាយ ឈ្មោះថា **បយោជនាវធិ** ការនិយមទាក់ទង ដោយការកំណត់ដែននៃប្រយោជន៍នោះយ៉ាងណា, ការប្រាប់ដល់ការនិយមនោះ ឈ្មោះថា ជាពាក្យនិយមកំណត់ដែននៃប្រយោជន៍ ។

ឥឡូវនេះ ដើម្បីនឹងអធិប្បាយការកំណត់នោះឲ្យច្បាស់ ទើបពោលពាក្យជាដើមថា មានប៉ុណ្ណោះនោះឯង ដូច្នេះ ។

ដោយ អវធារណ-សព្ទ ក្នុងបទថា **ឯត្តកមេវ ហិ** ជាដើមនោះទ្រង់ហាមការប្រើប្រាស់សំពត់ទាក់ទងជាមួយនឹងការដើរសង្ហារជាគ្រឿងប្រដាប់ ជាការសំយុងជាយ និងជាគ្រឿងស្លៀកដណ្តប់ដូចតួល្ខោនជាដើម ។ ដោយហេតុនោះ ទើបលោកពោលថា មិនហួសពីនេះ ដូច្នេះ ។ ពិតហើយ សត្វទាំងឡាយពួកខ្លះស្លៀកដណ្តប់ និងសន្សំសំពត់ទុកជាការដើរសង្ហារ ដើររបុិលរប៉ូច ដូចជាពួកអ្នកក្រុងដែលនៅក្នុងវ័យកំលោះ ក្រមុំ ដូច្នោះ ។ បុគ្គលពួកខ្លះ ស្លៀកសំពត់សន្សំសំពត់ទុកជាគ្រឿងប្រដាប់, ដូចជាស្ត្រីដែលចិញ្ចឹមជីវិត ដោយអាស្រ័យរូបដូច្នោះ ។ ពួកអ្នកលេងល្ខោនស្លៀកពាក់សំពត់របៀបសំយុងជាយ ។ ពួកម្ចាស់ផ្ទះជាដើមស្លៀកពាក់សំពត់ និងសន្សំជាគ្រឿងស្លៀកពាក់ដូចតួល្ខោន ។

ការកើតរោគ មានរោគដែលកើតពីភាពរងាជាដើម ឈ្មោះថា

ជាតុខាងក្នុងកម្រើក ។ ពាក្យថា ដោយអំណាចការប្រែប្រួលនៃរដូវ មានន័យថា ដោយអំណាចការផ្លាស់រដូវ គឺដោយសមុដ្ឋាននៃឧតុមានភាពត្រជាក់ជាវិសភាគៈគ្នា ។ ដោយ វា-ស័ព្ទ គប្បីឃើញថា សង្គ្រោះការប្រព្រឹត្តិទៅទាក់ទងដោយការធ្លាក់ព្រិលជាដើម ក្នុងហេមន្តរដូវជាដើម, អធិប្បាយថា មិនញុំាងភាពរងាឲ្យកើតឡើង ការបន្ទោបង់នូវភាពត្រជាក់នោះដើម្បីប្រយោជន៍ណា ដើម្បីសម្តែងថាប្រយោជន៍នោះដល់ទីបំផុតហើយ ទើបពោលពាក្យជាដើមថា ត្រូវភាពរងាបៀតបៀនហើយ ដូច្នេះ ។

ពាក្យថា ទាំងពួង មានន័យថា ក្នុងប្រយោជន៍ដ៏សេសគ្រប់យ៉ាងជាដើមថា ដើម្បីបន្ទយភាពក្តៅ ដូច្នេះ ។ សូម្បីកម្តៅនៃព្រះអាទិត្យ ក៏ជាភាពក្តៅ តែម្យ៉ាងដោយពិត, សូម្បីយ៉ាងនោះលោកពោលថា ភាពក្តៅនៃភ្លើង ព្រោះកម្តៅនៃព្រះអាទិត្យនោះ លោកកាន់យកដោយស័ព្ទថា កម្តៅថ្ងៃ ។ ភាពក្តៅនៃភ្លើងព្រៃប្រភេទខ្លះអាចនឹងប្រើចីវរបិទបាំងកាយសម្រាលបាន ព្រោះហេតុនោះ ទើបលោកពោលថា គប្បីជ្រាបដែនកើតនៃកម្តៅនោះឯងព្រោះភ្លើងព្រៃជាដើម ។

បទថា **ឌំសា** បានដល់ សត្វរបោម ។ ព្រោះសត្វរបោមទាំងនោះមានប្រក្រតីខាំ ដូច្នេះទើបលោកពោលថា **ឌំសនមក្ខិកា** ។

ពាក្យថា មានពស់ជាដើម គឺសត្វទាំងឡាយមានពស់ ក្អែប

ពីងពាង តុកកែ និងខ្ជួយជាដើម ។ លោកពោលដោយពិសដែលកើត ពីការពាល់ត្រូវដោយពាក្យថា សម្ផស្សដោយការពាល់ត្រូវ ។ ពិត ហើយ ពស់មាន ៣ ជំពូក គឺពួក ដែលមានពិសដោយការខាំ ១, ពួក ដែលមានពិសដោយការពាល់ត្រូវ ១, ពួកដែលមានពិសដោយការ មើល ១, ក្នុងពស់ ៣ ជំពូកនោះ លោកសំដៅ ២ ជំពូកខាងដើម ។ រួមសត្វទាំងអស់នោះមានក្អែបជាដើមចូលផង ។ជាប្រយោជន៍ប្រចាំ គឺជាប្រយោជន៍តែម្យ៉ាង និងមានក្នុងកាលទាំងពួង ។ ការខ្មាសអៀន រមែងកម្រើក គឺការមិនខ្មាសអៀនរមែងតាំងស្ងប់ ។ ព្រោះដូច្នេះ ទើប លោកពោលថា រមែងវិនាសទៅ ។ម្យ៉ាងទៀត មានវិគ្រោះថា អវយវៈ ណា រមែងគួរដល់ការបិទបាំង គឺការបិទបាំង ហេតុនោះ អវយវៈនោះ ឈ្មោះថា **កោបិន** ( គួរបិទបាំង ) ។ អវយវៈ ឈ្មោះថា **កោបិន** នោះ ផង, ឈ្មោះថា ហិរិផង ព្រោះអត្ថថាគួរខ្មាស ព្រោះហេតុនោះ ទើប ឈ្មោះថា **ហិរិកោបិន** ( អវយវៈគួរបិទបាំង គួរខ្មាស ) ក៏គប្បីជ្រាប ខ្លឹមសារក្នុងបទថា **ហិរិកោបិន** នេះដោយប្រការដូចពោលមកនេះ ។ ច-សព្ទ ក្នុងបទថា **តស្ស ច** មានការប្រមូលមកនូវប្រយោជន៍ ដែល ពោលទុកមកហើយជាអត្ថ ។

ពាក្យថា អាហារយ៉ាងណាមួយ មានន័យថា វត្ថុដែលគប្បី លេបស៊ី យ៉ាងណាមួយ ដោយឡែកជារបស់ដែលបុគ្គលគប្បីទំពា

និងដែលបុគ្គលគប្បីបរិភោគជាដើម ។ ភិក្ខុឈ្មោះថា **បិណ្ឌោល** ព្រោះអត្ថថា ធ្វើដំណើរទៅដើម្បីដុំបាយ គឺដើម្បីភិក្ខា, កម្មរបស់ភិក្ខុឈ្មោះថា **បិណ្ឌោល** នោះ ឈ្មោះថា **បិណ្ឌោល្យំ** ។ ដោយការធ្វើដំណើរទៅដើម្បីដុំបាយ គឺដោយភិក្ខាចារនោះ ។

បទថា ព្រោះការដែលធ្លាក់ទៅ មានន័យថា ព្រោះការដែលបុគ្គលដាក់ចូលទៅ ។ ឈ្មោះថា បិណ្ឌបាត បានដល់ ភិក្ខាហារដែលគេដាក់ចូលទៅក្នុងបាត្រ ។

ពីរបទថា **បិណ្ឌានំ វា បាតោ** មានន័យថា ប្រជុំភិក្ខាដែលបានហើយពីផ្ទះមួយៗ ។ សូម្បីការធ្វើដោយរហ័ស លោកហៅថា **ទវ** ដូចជាក្នុងប្រយោគ មានជាអាទិថា **នត្ថិ ទវា** ( មិនមានភាពរហ័សរហួន) ដើម្បីឲ្យប្លែកពាក្យគ្នានោះ ទើបលោកពោលថា **ទវត្ថំ កីឡានិមិត្តនិវត្តំ ហោតិ** ( ដើម្បី **ទវ** អធិប្បាយថា ប្រាថ្នាទីងលេង ) ។ អ្នកកីឡា គឺពួកអ្នកដែលតស៊ូ ជាមួយគ្នានឹងគ្នាដោយកណ្តាប់ដៃ ។ បទថា ប្រាថ្នាភាពស្រវឹងក្នុងកម្លាំង គឺភាពស្រវឹងដែលអាស្រ័យកម្លាំង កើតឡើងជាការស្រវឹងក្នុងកម្លាំង ។ ប្រាថ្នាសេចក្តីស្រវឹងក្នុងកម្លាំងនោះ មានន័យថា ដើម្បីឲ្យកើតកម្លាំង ។ ពាក្យថា ប្រាថ្នាភាពស្រវឹងក្នុង ភាពជាបុរស មានន័យថា មានមានះថា ជាប្រុស ហៅថា ភាពស្រវឹងក្នុងភាពជាបុរស បានដល់ មានះដែលកើតឡើងថា យើងក៏ជាបុរស ។

អាចារ្យមួយពួកពោលថា មានះដែលប្រព្រឹត្តទៅអាស្រ័យភាពជាអ្នកមិនអាចក្នុងការសេពនូវអសទ្ធម្ម ឬរាគៈនោះឯង ជាភាពស្រវឹងក្នុងភាពជាបុរស ។ ប្រាថ្នានូវភាពស្រវឹងថា ជាបុរសនោះ ។ ស្ត្រីរាំង បានដល់ ស្រីស្នំរបស់ព្រះរាជា ។ ស្ត្រីពេស្យា បានដល់ ស្ត្រីដែលអាស្រ័យរូបចិញ្ចឹមជីវិត ព្រោះប្រកបការនៅរួមគ្នាបានគ្រប់មនុស្ស ។ ការធ្វើឲ្យអវយវៈពេញបរិបូណ៌ ឈ្មោះថាការតុបតែងក្នុងទីនេះដូច្នេះ ទើបលោកពោលថា ប្រាថ្នាភាវៈ គឺការធ្វើអវយវៈតូចធំឲ្យពេញលេញដូច្នេះ អធិប្បាយថា ព្រោះភាពរីកលូតលាស់នៃអវយវៈជាហេតុ ។ ដែលឈ្មោះថា តួល្ខោន បានដល់ អ្នកសម្តែងក្នុងរោងល្ខោន ។ តួរបាំ បានដល់ ពួកអ្នកលោតរាំជាដើម ។

ការប្រដាប់ បានដល់ ការធ្វើឲ្យស្អាតឡើង, ដូច្នោះ ទើបលោកពោលថា ប្រាថ្នាភាពមានពណ៌ស្រស់ថ្លា ។

**ឯតំ យោគ បទំ** ប្រែថា បទនេះ ។ បទថា **មោហូបនិស្សយ-ប្បហានត្ថំ** ប្រែថា ដើម្បីលះភាពជាឧបនិស្ស័យនៃមោហៈ ។ពិតហើយ ការលេងរមែងមានបានព្រោះមោហៈ ហើយរមែងធ្វើឲ្យមោហៈចម្រើនលូតលាស់ល្អ ដូច្នោះភាពមិនជាឧបនិស្ស័យនៃមោហៈ រមែងមានបានក៏ព្រោះវៀរចាកការលេងនោះចេញ ។

ពាក្យថា ដើម្បីលះភាពជាឧបនិស្ស័យនៃទោសៈ នេះលោក

ពោលទាក់ទង ដោយសេចក្តីស្រវឹងក្នុងកម្លាំងនិងការស្រវឹងក្នុងភាពជាបុរសជាហេតុនៃទោសៈ តែដោយអំណាចពាក្យក្រៅពីនេះគួរពោលថា ដើម្បីលះភាពជាឧបនិស្ស័យនៃរាគៈ ។ ការបដិសេធការតុបតែងនិងការប្រដាប់គប្បីមាន ក៏ដោយការលះឧបនិស្ស័យនៃមោហៈចេញបានតែជាបដិបក្ខដោយត្រង់ចំពោះភាពជាឧបនិស្ស័យនៃរាគៈដូច្នោះ ទើបលោកពោលថា ដើម្បីលះភាពជាឧបនិស្ស័យនៃរាគៈ ដូច្នេះ ។ បុគ្គលដទៃប្រារព្ធនូវភាពមួរម៉ៅក្នុងការលេងរបស់បុគ្គលខ្លះ រមែងកើតសំយោជនៈទាំងឡាយ មានបដិឃសំយោជនៈជាដើមតែម្យ៉ាង ដូចពួកទេវតាមាន ទេវតាក្នុងមនោបទោសិកៈជាដើម,តាមពិត សូម្បីយ៉ាងនោះ បុគ្គលទាំងឡាយណា ប្រារព្ធនូវភាពមួរម៉ៅក្នុងការលេងរបស់ខ្លួន ក៏រមែងកើតបាបទាំងឡាយមានរាគៈ មោហៈ និងមានៈជាដើមបានយ៉ាងពិសេស ។ ទើបលោកអាចារ្យសំដៅដល់បុគ្គលទាំងឡាយនោះទើបលោកពោលថាដើម្បីហាមការកើតឡើងនៃសំយោជនៈចំពោះខ្លួន ហើយពោលថា ដើម្បីហាមការកើតឡើងនៃសំយោជនៈសម្រាប់អ្នកដទៃ ព្រោះបាបធម៌មានរាគៈនិងមោហៈជាដើម រមែងកើតឡើងដល់បុគ្គលដទៃបានយ៉ាងមានប្រសិទ្ធភាព ព្រោះអាស្រ័យការប្រដាប់តុបតែង ។ ក្នុងពាក្យថា **អយោនិសោបដិបត្តិ** នេះ គឺការបដិបត្តិខុសទាំងអស់ វៀរតែកាមសុខល្លិកានុយោគៈ ឈ្មោះថា

អយោនិសោបដិបត្តិ ។

អាចារ្យទាំងឡាយពោលថា ដោយពីរបទដំបូង ទ្រង់ត្រាស់ដល់ការលះបង់អយោនិសោបដិបត្តិ, ដោយពីរបទក្រោយ ត្រាស់ដល់ការលះបង់កាមសុខល្លិកានុយោគៈ ។ តែព្រោះពាក្យថា ដោយបទទាំង ៤ គប្បីជ្រាបថា ដោយបទទាំងពួង ត្រាស់ដល់ការលះធម៌ទាំង ២ យ៉ាង ។ សូម្បីកាមកីឡា ក៏ចាត់ចូលក្នុងការលេងនោះដែរ, សូម្បីការស្រវឹងក្នុងភាពជាបុរសក៏ជាហេតុនៃកាមសុខល្លិកានុយោគៈនោះដែរ ។

ពាក្យថា ដែលប្រកបដោយមហាភូតរូប ៤ គឺដែលអាស្រ័យមហាភូតរូប ៤ ។ ពាក្យថា នៃរូបកាយ មានន័យថា នៃប្រជុំសន្តតិរូប ៤ ។ បទថា **ឋិតិយា** ប្រែថា ដើម្បីការតាំងនៅ ។ ការតាំងនៅនៃកាយនោះៗ លោកសំដៅយក ហើយដោយអំណាចការបន្តគ្នាទៅ ព្រោះដូច្នោះ ទើបលោកពោលថា ដើម្បីតាំងនៅបន្តគ្នាទៅ ។

បទថា **យាបនាយ** មានន័យថា ដើម្បីការប្រព្រឹត្តិទៅនៃជីវិតិន្ទ្រិយ៍ពិតហើយ ជីវិតិន្ទ្រិយ៍ ទ្រង់សម្តែងអធិប្បាយហើយថា **យាបនា វត្តនា** ដូច្នេះ ។ ការមិនដាច់ក្រសែនៃជីវិតិន្ទ្រិយ៍នោះ មានបានដោយមានអាហារចូលទៅបម្រុងផង ។ លោកអាចារ្យកាលនឹងសម្តែងថា ការដែលកាយនឹងតាំងនៅបានយូរ រហូតអស់អាយុកប្ប ឈ្មោះថា យាបនា ការញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដូច្នេះទើបលោកពោលទុកថា ដើម្បី

តាំងនៅអស់កាលយូរ ។

ឥឡូវនេះ កាលនឹងធ្វើនូវខ្លឹមសារដែលពេញហើយនោះឯងឲ្យជាក់ច្បាស់ក្រៃលែងឡើងទៅ ទើបពោលពាក្យមានជាអាទិថា ដូចទ្រផ្ទះទុក ។ ក្នុងពាក្យនោះ មានពាក្យប្រកបសេចក្ដីដូចតទៅនេះ ដូចជាម្ចាស់នៃផ្ទះដែលទ្រុឌទ្រោម ត្រូវការធ្វើការទល់ផ្ទះដើម្បីមិនឲ្យផ្ទះនោះរលំ,ម្យ៉ាងទៀត ដូចជារទេះនាយពាណិជ្ជត្រូវការបន្តក់ប្រេងភ្លៅដើម្បីឲ្យរទេះនោះ ប្រើការបានយ៉ាងណា, យោគីនេះក៏ដូច្នោះ ដើម្បីឲ្យកាយតាំងនៅបាន និងដើម្បីញុំាងជីវិតិន្ទ្រីយ៍ឲ្យប្រព្រឹត្តទៅ រមែងសេពចំពោះ រមែងបរិភោគបិណ្ឌបាត ។ ដោយការសម្ដែងឧបមានេះ តែងសម្ដែងថា ការមិនធ្លាក់ចុះ ការញុំាងជីវិតិន្ទ្រីយ៍ឲ្យប្រព្រឹត្តទៅ ការរស់នៅ ឈ្មោះថា ការតាំងនៅ ។ ពាក្យថា មិនមែនដើម្បីលេង ដើម្បីស្រវឹង ដើម្បីតាក់តែង និងដើម្បីចម្រើនពណ៌សម្បុរ នេះជាពាក្យសម្ដែងអត្ថបដិសេធ ដោយអវធារណៈថា **យាវទេវ** (ត្រឹមដើម្បី... ប៉ុណ្ណោះ)។ ឈ្មោះថា ឋិតិ ព្រោះអត្ថថា ជាហេតុតាំងនៅនៃឧបាទិន្នធម៌ បានដល់អាយុ, ព្រោះដូច្នោះ ទើបលោកពោលថា ពាក្យថា ឋិតិ នេះជាឈ្មោះរបស់ជីវិតិន្ទ្រីយ៍ ដូច្នេះ ។

ពិតហើយ អាយុនោះលោកសម្ដែងអធិប្បាយថា ឈ្មោះថា ឋិតិ ពាក្យថា **ឋិតិយា យាបនាយ** មានន័យថា ដើម្បីឲ្យជីវិតិន្ទ្រីយ៍

បានវោហារថា ឋិតិ ព្រោះជាហេតុតាំងនៅនៃកាយឲ្យប្រព្រឹត្តទៅ ។

ព្រោះហេតុនោះ ទើបលោកពោលថា ដើម្បីញុំាងជីវិតិន្ទ្រីយ៍ឲ្យប្រព្រឹត្តទៅ ។ បទថា **អាពាធនវដ្ឋន** មានន័យថា ព្រោះអត្ថថាបៀតបៀន ឬព្រោះអត្ថថា ចាក់ដោត ។ ពិតហើយ ការស្រេកឃ្លានជារោគដ៏ក្រៃលែង ។ បទថា **ឧបរមត្ថំ** មានន័យថា ដើម្បីរម្ងាប់ ។ ដូចជាបុគ្គលមានដំបៅ ត្រូវលាបថ្នាំរក្សាដំបៅ ។ ភ្ជាប់សេចក្ដីថា ដូចជាអ្នកឈឺ ពេលដែលភាពក្ដៅ និងភាពរងាជាដើម គ្របសង្កត់ក៏សេពចំពោះនូវថ្នាំត្រជាក់ និងថ្នាំក្ដៅ ដែលជាគ្រឿងបំបាត់ភាពក្ដៅនិងភាពរងានោះ ។

អនុសាសនីដ៏បរិសុទ្ធ ជាពាក្យប្រៀនប្រដៅដែលសង្គ្រោះដោយសិក្ខា ៣ លើកលែងមគ្គព្រហ្មចារ្យ ដូច្នោះទើបលោកពោលថា ដើម្បីអនុគ្រោះដល់សាសនព្រហ្មចរិយៈទាំងមូល និងមគ្គព្រហ្មចរិយៈផងដូច្នេះ ។

បទថា **អនុគ្គហត្ថំ** ប្រែថា ដើម្បីអនុគ្រោះ ដើម្បីឲ្យដល់ព្រម ។ ពាក្យថា អាស្រ័យកម្លាំងកាយ មានន័យថា អាស្រ័យកម្លាំងកាយជាហេតុឲ្យគុណវិសេស បរិបូណ៌តាមដែលប្រារព្ធទុក ។ ព្រោះដូច្នោះទើបលោកពោលថា ដោយអំណាចនៃការប្រកបរឿយៗ ក្នុងសិក្ខា ៣ ជាដើម ។ មានសេចក្ដីប្រៀបធៀបដោយឧបមាថា ភរិយា និង

ស្វាមីត្រូវការឆ្លងនូវផ្លូវកន្ដារ និងបុគ្គលត្រូវការឆ្លងទន្លេ និងសមុទ្រ តម្រង់ទៅដល់ការសម្រេចប្រយោជន៍នោះៗ តែម្យ៉ាងប៉ុណ្ណោះ ជាអ្នកមិនមានការរីករាយពេញចិត្តបរិភោគនូវសាច់កូនជាដើម ( បង្ខំចិត្តបរិភោគ ) ក៏ព្រោះ ( បើ ) វៀរចាកសាច់បុត្រជាដើមនោះ ក៏នឹងមិនសម្រេច ( ការឆ្លងផ្លូវកន្ដារបាន ) សេចក្ដីនេះយ៉ាងណា សូម្បីយោគីនេះត្រូវការឆ្លងផ្លូវកន្ដារគឺភព តែម្យ៉ាងក៏ដូច្នោះ ជាអ្នកមិនមានសេចក្ដីប្រាថ្នា មិនមានការពេញចិត្ត ក៏ចាំបាច់ត្រូវសេពចំពោះនូវបិណ្ឌបាត ព្រោះវៀរចាកបិណ្ឌបាតនោះ ការឆ្លងផ្លូវកន្ដារ គឺភព ក៏នឹងមិនអាចសម្រេចបាន ។

បទថា **ឥតិ** ជាបទនិបាតក្នុងអត្ថថា ប្រការ ។ ដោយ ឥតិ-ស័ព្ទនោះ លោកកាន់យកអាការ គឺការសេពបិណ្ឌបាតដែលភិក្ខុសេពជានិច្ច ដូច្នោះ ទើបលោកពោលថា ដោយប្រការដូច្នេះ គឺដោយការសេពបិណ្ឌបាតនេះ ដូច្នេះ ។ បទថា **បុរាណំ** មានន័យថា ឈ្មោះថាចាស់ ព្រោះការបរិភោគមានតាំងពីកាលមុន ។ បទថា **បដិហង្ខាមិ** ប្រែថា នឹងកម្ចាត់ ។ ប្រកបសេចក្ដីថា រមែងសេព ចំពោះដោយគិតថា នឹងមិនឲ្យវេទនាថ្មីកើតឡើង ។ លោកពោលថា ដូចជាព្រាហ្មណ៍អាហរហត្ថកៈ ព្រាហ្មណ៍អលង្សាដកៈ ព្រាហ្មណ៍តត្ថវដ្ដកៈ ព្រាហ្មណ៍កាកមាសកៈ ព្រាហ្មណ៍ភុត្តវមិតកៈ បុគ្គលណាមួយ ដែលមានការ

បរិភោគហួស ប្រមាណជាបច្ច័យ ដូច្នេះ ដើម្បីចៀសវាងពាក្យសួរថា នឹងសេពយ៉ាងណា និងរបៀបណាទៅ ។ ការបរិភោគរកប្រមាណមិនបាន គឺមិនមានប្រមាណ ជាបច្ច័យ ដល់វេទនានោះ ហេតុនោះ វេទនានោះ ឈ្មោះថា មានការបរិភោគហួសប្រមាណជាបច្ច័យ, ការបរិភោគរកប្រមាណមិនបានជាបច្ច័យនោះ អធិប្បាយថា ជាហេតុនៃការបរិភោគ ដែលមានប្រមាណហួសពីប្រមាណនៃភ្លើងធាតុរបស់ខ្លួន អាចនឹងរំលាយបាន ព្រាហ្មណ៍បរិភោគច្រើនកាលមិនអាចក្រោកឡើងតាមធម្មតានៃខ្លួនត្រូវនិយាយថា ចូរជួយទាញដៃដូច្នេះ ដូច្នេះ ព្រាហ្មណ៍នេះ ឈ្មោះថា **អាហរហត្ថក:** ( ជួយទាញដៃ ) ។ ព្រាហ្មណ៍បរិភោគហើយ សូម្បីក្រោកឡើងបាន តែមិនអាចស្លៀកសំពត់បាន ព្រោះមានពោះប៉ោងឡើងខ្លាំង ព្រាហ្មណ៍នោះ ឈ្មោះថា **អលង្សាដក:** ( ហាមសំពត់ ) ។ ព្រាហ្មណ៍បរិភោគ ហើយមិនអាចក្រោកឡើងបាន រំកិលទៅមក ក្នុងទីនោះនុ៎ះឯង ព្រាហ្មណ៍នេះ ឈ្មោះថា **តត្ថវដ្តក:** ( រំកិលនៅទីនោះកន្លែង ) ។ ព្រាហ្មណ៍ណាបរិភោគអាហារ រហូតហៀរតាមទ្វារមាត់ ដែលសត្វក្អែកអាចចឹកស៊ីបាន ព្រាហ្មណ៍នោះ ឈ្មោះថា **កាកមាសក:** ( បរិភោគរហូតដល់ក្អែកចឹកមាត់ ) ។ ព្រាហ្មណ៍ណាបរិភោគហើយ មិនអាចបៀមទុកក្នុងមាត់បាន ក៏ត្រូវក្អួតចេញមកក្នុងទីនោះៗ ឯង, ព្រាហ្មណ៍នោះ ឈ្មោះថា **ភុត្តវមិតក:** ( ក្អួតបាយ ) ។

ដូចព្រាហ្មណ៍ទាំងនេះណាមួយ ។

ម្យ៉ាងទៀត វេទនាដែលកើតឡើង ព្រោះមិនបានបរិភោគជាបច្ច័យ ឈ្មោះថា វេទនាចាស់, រមែងសេពនូវបិណ្ឌបាតនោះ ដោយគិតថា នឹងកម្ចាត់នូវវេទនានោះ ។ វេទនាណាដែលកើតឡើងព្រោះការបរិភោគហួសប្រមាណ ឈ្មោះថា វេទនាថ្មី, រមែងសេពនូវបិណ្ឌបាតនោះដោយគិតថា នឹងមិនញុំាងវេទនាថ្មីឲ្យកើតឡើង ។

ម្យ៉ាងទៀត វេទនាកើតឡើង ព្រោះមិនបានបរិភោគជាបច្ច័យ ឈ្មោះថា វេទនាថ្មី រមែងសេពដើម្បីមិនឲ្យវេទនាថ្មីនោះ ដែលមិនទាន់កើតឡើង កុំឲ្យកើតឡើង ។

ម្យ៉ាងទៀតពាក្យថាវេទនាដែលកើតឡើងព្រោះមិនបានបរិភោគជាបច្ច័យ នេះជាពាក្យអធិប្បាយនៃការស្រេកឃ្លាន ។ ដើម្បីសម្តែងដល់ការស្រេកឃ្លាន ដែលនឹងមិនឲ្យកើតឡើង នឹងគប្បីធ្វើបានដោយការបរិភោគនោះ ។ ក្នុងបណ្តាវេទនាដែលកើតឡើង ព្រោះមិនបានបរិភោគជាបច្ច័យក្តី ព្រោះបានបរិភោគជាបច្ច័យក្តី វេទនាមានការស្រេកឃ្លានជាហេតុ តាមដែលប្រព្រឹត្តទៅជាវេទនាដំបូង ព្រោះវេទនានោះរមែងកើតឡើង ហើយកាន់តែចម្រើនខ្លាំងឡើងៗ ដល់អ្នកដែលមិនបានបរិភោគ ។ វេទនា មានវេទនាដែលដុតអវយវៈ ហើយដូចជាលំពែងចាក់ទម្លុះជាដើម ដែលមានការស្រេកឃ្លានជាហេតុ សូម្បី

មានក្នុងពេលក្រោយ ក៏មិនកើត ។ ព្រោះវេទនានោះ មិនទាន់កើតឡើងក្នុងកាលមុន ក៏នឹងមិនកើតឡើង ព្រោះហេតុតែបានបរិភោគហើយ ដូច្នេះ វេទនាទាំងឡាយនេះ មានភាពផ្សេងគ្នាដូចពោលមកនេះឯង ។

ការដែលវេទនាទាំងឡាយនេះមានការបៀតបៀនជាហេតុ ជាការផ្សេងគ្នា ព្រោះការបៀតបៀន ។

**យា យោគ វេទនា** ប្រែថា វេទនាណា ។ បទថា **អធុនា** ប្រែថា ក្នុងពេល ឥឡូវនេះ ។ ពាក្យថា ព្រោះអាស្រ័យការបរិភោគរបស់មិនជាសប្បាយ និងបរិភោគហួសប្រមាណ មានន័យថា កើតឡើងព្រោះអាស្រ័យប្រយោគ គឺការបរិភោគអាហារដែលមិនជាសប្បាយនិងដែលហួសប្រមាណ ។ ពាក្យថា ដោយអំណាចកម្មចាស់ជាបច្ច័យមានន័យថា ដោយអំណាចនៃកម្មចាស់ជាបច្ច័យ ព្រោះខ្លួនធ្វើទុកក្នុងកាលមុន គឺក្នុងជាតិមុន ។ វេទនាណាដែលគួរនឹងកើតឡើង ព្រោះអាស្រ័យប្រយោគវិបត្តិការវៀរចាកវេទនានោះហើយញ៉ាំងប្រយោគសម្បត្តិឲ្យតាំងឡើង ជាការទម្លាយបច្ច័យនៃទុក្ខវេទនា និងជាការកម្ចាត់ផងដែរ ដូច្នោះទើបលោកពោលថា តថាគត កាលញ៉ាំងបច្ច័យនៃវេទនាចាស់នោះឲ្យវិនាសទៅ ឈ្មោះថា រមែងកម្ចាត់វេទនានោះផង ដូច្នេះ ។

ការបរិភោគមិនប្រពៃ បានដល់ ការមិនពិចារណានូវបច្ច័យទាំងឡាយ ហើយចាំបរិភោគ ។ ការបរិភោគដែលមិនប្រពៃនោះឯង ជាការបន្តកម្ម ព្រោះភាពជាអ្នកមានកម្មដែលខ្លួនធ្វើហើយ និងបន្តហើយ ។ ប្រកបសេចក្តីថា វេទនាណា ដែលលោកហៅថា វេទនាថ្មី ព្រោះអាស្រ័យ គឺការសន្សំកម្មនោះ កើតឡើងក្នុងកាលតទៅ គឺក្នុងអនាគត ។ ពាក្យថា ដោយអំណាចនៃការបរិភោគប្រពៃ មានន័យថា ដោយអំណាចនៃការបានពិចារណាហើយបរិភោគបច្ច័យទាំងឡាយ, មិនញុំាងកម្ម គឺការបរិភោគមិនប្រពៃដែលជាមូលហេតុឲ្យ វេទនាថ្មីនោះកើតឡើង គឺមិនឲ្យកើតឡើងគ្រប់ៗ ប្រការ ។

បទថា **ឯត្តាវតា** មានន័យថា ដោយបទទាំង ២ ដែលត្រាស់ទុកមានពាក្យថា **ឥតិ បុរាណំ** ដូច្នេះជាដើម ។

ម្យ៉ាងទៀត ដោយបទទាំង ៤ មានពាក្យថា **វិហឹសុបរតិយា** ដូច្នេះជាដើម ។ ទ្រង់រមែងសម្តែងការសង្គ្រោះការបរិភោគប្រពៃ ព្រោះទ្រង់ត្រាស់ដល់ការបរិភោគបច្ច័យ ដែលសមគួរដល់បព្វជិតទាំងឡាយ ។

ឯទ្រង់សម្តែងដល់ការលះអត្តកិលមថានុយោគ ព្រោះត្រាស់ដល់ការកម្ចាត់ទុក្ខ មានទុក្ខ គឺការស្រេកឃ្លានជាដើម ហើយទ្រង់តែងតែសម្តែងនូវការយកចិត្តទុកដាក់ចំពោះសេចក្តីសុខ ដែលប្រកប

ដោយធម៌ ព្រោះមិនលះបង់នូវសេចក្តីសុខផ្លូវកាយដែលជាបច្ច័យ ដល់សេចក្តីសុខដែលកើតពីឈានជាដើម ។

អន្តរាយដែលចូលមកកាត់ផ្តាច់ជីវិតិន្ទ្រីយ៍ ឬធ្វើឲ្យទន់ឥរិយាបថគប្បីមានបាន ព្រោះតែប្រកបដោយការបរិភោគអាហារដែលមិនជាសប្បាយ និងការបរិភោគហួសប្រមាណ, តែការអន្តរាយនោះនឹងមិនមាន ក៏ព្រោះប្រកបដោយការបរិភោគអាហារដែលជាសប្បាយ និងការបរិភោគល្មមប្រមាណ ។ លោកអាចារ្យកាលនឹងសម្តែងខ្លឹមសារនេះថា ព្រោះហេតុដូច្នោះ ការដំណើរទៅ គឺការប្រព្រឹត្តិទៅនៃសរីរៈពោល គឺការរស់នៅបានអស់កាលយូរ នឹងមានបាន ទើបពោលថា ដោយការបរិភោគល្មមប្រមាណ ការប្រព្រឹត្តិទៅ ពោល គឺរស់នៅអស់កាលយូរ ព្រោះមិនមានអន្តរាយ ដែលនឹងចូលមកកាត់ផ្តាច់ជីវិតិន្ទ្រីយ៍ ឬធ្វើឲ្យទន់ឥរិយាបថដល់យើង ដូច្នេះ ។

រោគណា ដែលជារោគព្យាបាលមិនជា និងជារោគកែខៃលែងបាន, រោគនោះ ឈ្មោះថា រោគពុំរំរ៉ៃ រោគនោះមានដល់បុគ្គលនោះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា អ្នកមានរោគពុំរំរ៉ៃ ។

បុគ្គលមានរោគពុំរំរ៉ៃនោះឯង រមែងប្រើថ្នាំរក្សាអស់កាលជានិច្ច សូម្បីភិក្ខុនេះក៏ត្រូវសេពដូច្នោះដែរ ។

សួរថា បើដំណើរទៅ គឺញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅសោត,

ពាក្យដែលលោកពោលទុកក្នុងបទមុន ដើម្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្តី ក្នុងរឿងនេះ មានសេចក្តីផ្សេងគ្នាយ៉ាងណា ?

ឆ្លើយថា ការញ៉ាំងជីវិតិន្ទ្រិយ៍ឲ្យប្រព្រឹត្តទៅ ទ្រង់សង្គ្រោះយកថា **យាបនា** ដើម្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបទមុន តែក្នុងបទនេះ ទ្រង់សង្គ្រោះយកការប្រព្រឹត្តិទៅ គឺដំណើរទៅ ពោល គឺការមិនដាច់ខ្សែនៃឥរិយាបថទាំង ៤ ដូច្នេះ ក្នុងរឿងនេះ មានសេចក្តីផ្សេងគ្នាដូចពោលមកនេះឯង ។

ការស្វែងរកបច្ច័យដោយមិច្ឆាជីវៈ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់តិះដៀលហើយ ឈ្មោះថា ការស្វែងរកដែលមិនប្រពៃ ។ ការមិនដឹងប្រមាណនូវទេយ្យធម៌របស់ទាយក និងរបស់ខ្លួនហើយទទួល ឬការទទួលដើម្បីញ៉ាំងសទ្ធាទេយ្យឲ្យធ្លាក់ចុះ ឈ្មោះថា ការទទួលមិនប្រពៃ, ឬបានដល់ ការទទួលដែលជាហេតុឲ្យត្រូវអាបត្តិ ។ការមិនពិចារណាហើយបរិភោគ ឈ្មោះថា ការបរិភោគមិនប្រពៃ ។

ការវៀរចាកការស្វែងរក ការទទួល និងការបរិភោគដែលមិនប្រពៃទាំងឡាយនោះ គប្បីជ្រាបដោយអំណាចនៃការធ្វើបច្ច័យឲ្យកើតឡើងជាដើម ដោយធម៌ ដោយស្មើ ។ ពិតហើយ ការស្វែងរកបច្ច័យដោយធម៌ ទទួលមកដោយធម៌ ពិចារណាហើយទើបបរិភោគ ឈ្មោះថា ភាពជាអ្នកមិនមានទោស ។

បទថា **អរតិ** ប្រែថា ការត្រេកត្រអាលក្នុងកាម បានដល់ ការមិនរីករាយ ក្នុងសេនាសនៈដែលស្ងាត់ និងក្នុងអធិកុសលធម៌ទាំងឡាយ ។

បទថា **តន្ទិ** មានន័យថា ការងោកងក់ គឺភាពដេកលក់ ។ បទថា **វិជម្ភិកា** មានន័យថា ការពត់កាយ ព្រោះត្រូវបីនមិទ្ធៈគ្របសង្កត់ ។ កិរិយាដែលអ្នកប្រាជ្ញទាំងឡាយតិះដៀល ឈ្មោះថា **វិញ្ញុគរហា** ។ ពិតហើយ ភិក្ខុរបស់ៈធ្វើវត្ថុ ដែលមិនមានទោសឲ្យជាវត្ថុមានទោស, គិតថា របស់នេះយើងបានមកហើយ ក៏បរិភោគហួសប្រមាណ កាលបើអាហារនោះមិនអាចរលាយបាន រមែងលំបាក ព្រោះក្អួត និងចុកពោះជាដើម, ភិក្ខុទាំងឡាយពេញវត្តត្រូវខ្វល់ខ្វាយស្វែងរកភេសជ្ជៈមកបីបាច់ថែរក្សាសរីរៈភិក្ខុនោះ ។

ភិក្ខុទាំងឡាយដទៃទឹងសួរភិក្ខុពួកនោះថា តើមានអ្វីកើតឡើង កាលបានស្តាប់ថា ភិក្ខុនោះចុកពោះ ក៏តិះដៀលថា លោកអង្គនេះមានប្រក្រតីយ៉ាងនេះជានិច្ចអស់កាលយូរហើយ មិនដឹងប្រមាណពោះរបស់ខ្លួន យ៉ាងនេះ គឺធ្វើវត្ថុដែលគ្មានទោសឲ្យជាវត្ថុមានទោស ។

ភិក្ខុមិនធ្វើយ៉ាងនោះ រមែងសេពដោយគិតថា នឹងមិនឲ្យមានទោស ភិក្ខុដឹងកម្លាំងនៃភ្លើង ( ធាតុ ) តាមប្រក្រតីរបស់ខ្លួន សេព ( បច្ច័យ ) តែល្មមប្រមាណប៉ុណ្ណោះ ដោយគិតថា ព្រោះមិនគួរមាន

ការត្រេកត្រអាលក្នុងកាមជាដើម យ៉ាងនេះហើយ ទើបមានសេចក្ដីសុខផ្លូវកាយដែលគ្មានទរណាៗ តិះដៀលបាន ដូច្នេះ ។

សេចក្ដីត្រូវការដោយការបរិភោគ មានប្រមាណត្រឹមណា ការបរិភោគនោះ ឈ្មោះថា តាមត្រូវការដោយការញ៉ាំងសេចក្ដីត្រូវការនោះឲ្យសម្រេច ឈ្មោះថា ឲ្យពេញផ្ទៃ, ដោយការញ៉ាំងផ្ទៃឲ្យពេញ ឈ្មោះថាការបរិភោគអាហារតាមដែលត្រូវការរហូតពេញផ្ទៃ,ដោយការវៀរចាកការបរិភោគអាហារតាមដែលត្រូវការ រហូតពេញផ្ទៃនោះ។

សុខដែលទឹងគប្បីបានដោយការដេក ឈ្មោះថា សុខដោយការដេក សុខដែលកើតឡើងដល់បុគ្គលដែលដេកត្រឡប់ទៅមកទាំងពីរខាង ឈ្មោះថា សុខដោយការប្រែខ្លួន, សុខដែលកើតឡើងដោយការដេកលក់ គឺអាការលក់ ឈ្មោះថា សុខដោយការលក់, ការធ្វើឲ្យឥរិយាបថ ៤ ដំណើរការទៅសមប្រកបដោយលះសេចក្ដីសុខក្នុងការដេក សេចក្ដីសុខដោយការប្រែខ្លួន និងសេចក្ដីសុខដោយ ការដេកលក់ចេញ ឈ្មោះថា ការនៅជាសុខ ។ លោកអាចារ្យបំណាងនឹងធ្វើឲ្យលក្ខណៈនៃការនៅជាសុខ ដែលលោកពោលទុកក្នុងវិកប្បក្រោយ ឬក្នុងវិកប្បទាំងអស់ឲ្យច្បាស់ឡើងក្នុងស្ថានដែលមក ( អាគម ) ទើបពោលពាក្យថា សមដូចពាក្យប្រព័ន្ធដែលពោលទុកជាដើម ។ ក្នុងវិកប្បទាំង ៣ ត្រាស់ដល់ការនៅជាសុខ ដោយការបរិភោគអាហារ

ឲ្យល្មមៗ នោះឯង ។

ពាក្យថា ដោយលំដាប់ពាក្យត្រឹមប៉ុណ្ណោះ មានន័យថា ដោយបទទាំង ៣ ដែលពោលទុកតាមន័យ មានជាអាទិថា យាត្រា ដូច្នេះ ។

ពាក្យថា ការប្រព្រឹត្តិទៅនឹងមានដល់យើង ជាពាក្យសម្តែងដល់ការកំណត់ប្រយោជន៍ ។ ពិតហើយ ការត្រាច់ទៅរមែងញុំាងភិក្ខុនោះឲ្យប្រកបការប្រើប្រាស់អាហារបាន ។ ការនៅជាសុខ ជាហេតុមិនលះបង់សេចក្តីសុខដែលប្រកបដោយធម៌ ។ ឈ្មោះថា ជាមជ្ឈិមាបដិបទា ព្រោះវៀរចាកទីបំផុតទាំង ២ចេញ ។

ប៉ុន្តែក្នុងទីនេះ គប្បីប្រមូលអង្គ ៨ មក ដូចតទៅនេះ

ពាក្យថា មិនមែនដើម្បីលេងជាអង្គ ១ ។

ពាក្យថា មិនមែនដើម្បីស្រវឹងជាអង្គ ១ ។

ពាក្យថា មិនមែនដើម្បីតុបតែងជាអង្គ ១ ។

ពាក្យថា មិនមែនដើម្បីប្រដាប់ជាអង្គ ១ ។

ពាក្យថា ត្រឹមតែដើម្បីឲ្យកាយនេះតាំងនៅ ប្រព្រឹត្តទៅជាអង្គ ១

ពាក្យថា ដើម្បីរំងាប់ការបៀតបៀន ដើម្បីអនុគ្រោះព្រហ្មចរិយៈជាអង្គ ១ ។

ពាក្យថា ដោយប្រការដូច្នេះ នឹងបន្ទោបង់វេទនាចាស់ និងមិនញុំាងវេទនាថ្មីឲ្យកើតឡើង ជាអង្គ ១ ។

ពាក្យថា ការញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន នឹងមានដល់យើង ជាអង្គ ១ ។

សេចក្តីថា ភាពជាអ្នកមិនមានទោស ១ ការនៅជាសុខ ១ ដូចពោលមកនេះជាអានិសង្សនៃការបរិភោគក្នុងទីនេះ ។ តែព្រះមហាសិវត្ថេរពោលថា ៤ អង្គខាងដើម ឈ្មោះថា ជាខ.ហាមឃាត់, តែគប្បីកាន់យកអង្គ ៨ ខាងមុខ ដូច្នេះ ។

ក្នុងបណ្តាអង្គ ៨ ទាំងឡាយនោះ

ពាក្យថា ត្រឹមតែដើម្បីញុំាងជីវិតិន្ទ្រិយ៍នៃកាយនេះ ឲ្យតាំងនៅ ជាអង្គ ១ ។

ពាក្យថា ដើម្បីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅជាអង្គ ១ ។

ពាក្យថា ដើម្បីរំងាប់ការបៀតបៀន ជាអង្គ ១ ។

ពាក្យថា ដើម្បីអនុគ្រោះព្រហ្មចរិយៈជាអង្គ ១ ។

ពាក្យថា ដោយប្រការនេះនឹងបន្ទោបង់វេទនាចាស់ចេញ ជាអង្គ ១ ។

ពាក្យថា នឹងមិនញុំាងវេទនាថ្មីឲ្យកើតឡើងជាអង្គ ១ ។

ពាក្យថា ការប្រព្រឹត្តិទៅនឹងមានដល់យើងជាអង្គ ១ ។

ពាក្យថា ភាពជាអ្នកមិនមានទោសជាអង្គ ១ ។

តែការនៅជាសុខជាអានិសង្សនៃការបរិភោគដូច្នេះឯង ។ ភិក្ខុ

កាលលេបអាហារប្រកបដោយអង្គ ៨ យ៉ាងនេះ ឈ្មោះថា ពិចារណាសេពបិណ្ឌបាតដោយឧបាយត្រូវទំនង ។

លោកអាចារ្យពោលថា សេន-ស័ព្ទ ប្រព្រឹត្តទៅក្នុងអត្ថនៃអធិករណៈ ដោយ និទ្ទេសជាសត្តមីវិភត្តិថា **យត្ថ យត្ថ** ។ អាសនស័ព្ទក៏ដូចគ្នា ។ លោកសង្គ្រោះប្រាសាទជាដើមនិងគ្រែជាដើម ដោយអាទិ-ស័ព្ទថា **អឌ្ឍយោគាទិម្ហិ** ។ គប្បីនាំវិហារ និងអឌ្ឍយោគៈជាដើម ( វិហារ និងផ្ទះដំបូលមួយចំហៀង ) មកភ្ជាប់ បញ្ចូលដូច្នេះថា អង្គុយក្នុងវិហារ ឬក្នុងកន្លែងដែលប្រក់ដំបូលមួយចំហៀងជាដើម ។ ដោយ អាទិ-ស័ព្ទ ក្នុងពាក្យថា **អឌ្ឍយោគាទិកេ** នេះគប្បីជ្រាបថា រួមយកគ្រែ និងសន្ថតជាដើមផងដែរ ។

ពាក្យថា **បរិសហនត្ថំ** មានន័យថា ព្រោះអត្ថថា គ្របសង្កត់, អធិប្បាយថា ព្រោះអត្ថថា បៀតបៀន ។

ពាក្យថា **ឧតុយេវ ឧតុបរិស្សយោ** មានន័យថា រដូវមានក្តៅ និងត្រជាក់ជាដើមនោះឯង មិនជាសប្បាយ ឈ្មោះថា មានរដូវជាអន្តរាយតាមន័យដូចដែលបានពោលហើយ, អធិប្បាយថា ដើម្បីបន្ទោបង់នូវអន្តរាយ គឺរដូវនោះ, ដើម្បីមិនឲ្យអន្តរាយ គឺរដូវដែលមិនទាន់កើតឡើង មិនឲ្យកើតឡើង និងដើម្បីរម្ងាប់ អន្តរាយ គឺរដូវដែលកើតឡើងហើយ ។ ការដែលចិត្តថយត្រឡប់ចាកពីអារម្មណ៍ផ្សេងៗ គេច គឺ

គេចចេញដោយល្អ ឋិតនៅក្នុងអារម្មណ៍តែមួយប៉ុណ្ណោះ ដែលជាកម្មដ្ឋាន ។ ការមករីករាយ គឺសេចក្ដីរីករាយដ៏ក្រៃលែងក្នុងការគេចចេញនោះ ឈ្មោះថា **បដិសល្លានារាមោ** ( មានការគេចចេញជាទីរីករាយ ) ដើម្បី ប្រយោជន៍ដល់ការគេចចេញជាទីរីករាយនោះ ។

ពិតហើយ សេនាសនៈដែលស្ងាត់ សមគួរដល់ការចម្រើនភាវនារបស់យោគី ព្រោះជាសុញ្ញាគារ ( ផ្ទះទំនេរ ) ។ ដើម្បីប្រកាសប្រយោជន៍ទាំង ២ នេះនោះ ទើបពោលពាក្យថា **យោ សរីរពាធ ចិត្ត វិក្ខេបករោ** ប្រែថា រដូវណាធ្វើឲ្យមានអាពាធចំពោះសរីរៈ និងការរាយមាយចិត្តដូច្នេះជាដើម ។

ក្នុងពាក្យទាំងឡាយនោះ បទថា **ឯកីភាវសុខត្ថំ** មានន័យថា សេចក្ដីសុខ ដែលមានការនៅម្នាក់ឯងជាហេតុ ឈ្មោះថា សេចក្ដីសុខដែលកើតឡើងពីការនៅម្នាក់ឯង, ដើម្បីសេចក្ដីសុខដែលកើតពីការនៅម្នាក់ឯងនោះ ។ គឺសេចក្ដីសុខ ដែលកើតដោយមិនមានការប្របូកប្របល់ដោយពួកគណៈ និងការជំពាក់ចិត្ត ដោយកិលេស ។

លោកអាចារ្យសំដៅយកពាក្យក្រើនរំលឹកថា ប្រសិនបើឧតុនោះឯង ឈ្មោះថា **ឧតុបរិស្សយ** ( អន្តរាយ គឺឧតុ ), លោកពោលនូវការការពារភាពរងា និងភាពក្ដៅទុកថា **ឧតុ ច សីតុណ្ហំ** ជាដើម ហើយព្រោះហេតុអ្វី ទើបពោលចំពោះតែការបន្ទោបង់ **ឧតុបរិស្សយ**

( អន្តរាយ គឺឧតុ ) ទៀត, ដូច្នេះ ទើបពោលថា **ភាមញ្ច** ដូច្នេះ ជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ដោយពាក្យថា ការបន្ទោបង់អន្តរាយ គឺឧតុ ដែលប្រកបប្រយោជន៍ជាប្រចាំនេះ លោកអាចារ្យសម្តែងថា ក្នុងពាក្យថា ដើម្បីការពារភាពរងា ដើម្បីការពារភាពក្តៅ ទ្រង់ត្រាស់សំដៅយកភាពរងា និងភាពក្តៅដែលមិនប្រាកដប្រជា គឺកើតឡើងម្តងម្កាល, ចំណែកអន្តរាយ គឺឧតុ សំដៅយកអន្តរាយដែលមានគ្រប់កាលទាំងពួងជាប្រក្រតី ។

ពាក្យថា ( ឧត ) មានប្រការដូចពោលមកហើយ គឺ ( ឧតុ ) មានប្រការ ដូចដែលពោលហើយយ៉ាងនេះថា ឧតុ មានភាពរងាជាដើម, និងថា ឧតុមិនជាទីសប្បាយ ។ អន្តរាយប្រាកដ គឺធ្វើការបៀតបៀនដល់កាយនិងចិត្តដល់ភិក្ខុ ដែលអង្គុយនៅទីវាល និងគល់ឈើជាដើមយ៉ាងណា ព្រោះមិនមានការបិទបាំង គឺព្រោះជាស្ថានទីដែលមិនមានទ្វារបិទការពារជាដើម ។ អន្តរាយកំបាំង គឺធ្វើការបៀតបៀនដល់កាយ និងចិត្តរបស់ភិក្ខុ ព្រោះការឃើញរូបមិនជាទីសប្បាយជាដើម ។ ក្នុងសេនាសនៈដែលបានបិទបាំងទុក រមែងធ្វើការបៀតបៀនមិនបាន ។

ពាក្យថា ជ្រាបយ៉ាងនេះហើយ ភ្ជាប់សេចក្តីថា ភិក្ខុកាលជ្រាបថា ជាសេនាសនៈដែលប្រាសចាកអន្តរាយទាំង ២ យ៉ាង យ៉ាងនេះ

ហើយ ទើបសេព គប្បីជ្រាបថា ( ឈ្មោះថា រមែងពិចារណាត្រូវឧបាយហើយ ទើបសេពសេនាសនៈនោះ ។ល។ ) ដូច្នេះ ។

ភាពជាបដិបក្ខដល់រោគ ដែលមានការកម្រើកនៃធាតុជាលក្ខណៈ ឬថា មានទុក្ខវេទនាដែលមានការកម្រើកនៃធាតុនោះជាហេតុជាលក្ខណៈ ឈ្មោះថា មានសេចក្ដីថា ជាហេតុប្រឆាំង ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា សេចក្ដីថា មានន័យថា ដោយភាពជាសត្រូវចំពោះរោគ ដូច្នេះ មានអធិប្បាយថា ដោយសេចក្ដីថា រំងាប់រោគបាន ។

ពាក្យថា (វត្ថុដែលជាសប្បាយ) យ៉ាងណាមួយ បានដល់ ( វត្ថុដែលជាសប្បាយ ) យ៉ាងណាមួយ ក្នុងបណ្ដាវត្ថុ មានទឹកដោះខាប់ជាដើម ។ ពិតហើយ មានអធិប្បាយថា វត្ថុជាសប្បាយ ព្រោះវត្ថុនោះធ្វើឲ្យស្ងប់ភាពវិការបាន ។ ឈ្មោះថា ជាវត្ថុដែលពេទ្យធ្វើ ព្រោះជាវត្ថុដែលពេទ្យនោះគប្បីចាត់ចែង ។ ព្រោះហេតុនោះ ទើបលោកពោលថា ព្រោះភាពដែលពេទ្យនោះអនុញ្ញាត ដូច្នេះ ។

ពាក្យថា ដោយបរិក្ខារនៃនគរ ដោយវត្ថុព័ទ្ធជុំវិញរក្សានូវនគរ ។ អាចារ្យជាច្រើនពោលដល់វត្ថុ ៧ យ៉ាង គឺ

១. កន្លែងដែលលើកឡើងជាផ្ទាំងថ្មបោទព័ទ្ធជុំវិញ ។

២. ភ្លើងបំភ្លឺទីក្រុង ។

៣. ជើងកំផែង ។

៤. កំផែង ។

៥. បង្គោលរបង ។

៦. រនុកទ្វារ ។

៧. ប៉មចាំយាមកំផែង ។

ថាជា **បរិក្ខារប្រចាំនគរ** ដូច្នេះក៏មាន ។

ពាក្យថា មានសីលជាបរិក្ខារ គឺមានសីលដែលបរិសុទ្ធល្អជាគ្រឿងប្រដាប់ ។ ក្នុងសូត្រនេះ អរិយមគ្គទ្រង់សំគ្រោះថា **រថ** ។ ហើយត្រាស់ដល់ធម៌ទាំងឡាយ មានសម្មាវាចាជាដើមថាជា **បរិក្ខារ** ដោយសេចក្ដីថា ជាគ្រឿងប្រដាប់នៃអរិយមគ្គនោះ ។

ពាក្យថា បរិក្ខារនៃជីវិត បានដល់ ហេតុនៃការប្រព្រឹត្តិទៅនៃជីវិត ។ បទថា **សមុទានេតព្វា** (គប្បីនាំមកដោយល្អ) គឺគប្បីនាំមកបានដល់គប្បីស្វែងរកតៗ ទៅដោយប្រពៃ ។ភេសជ្ជៈ ដែលជាបច្ច័យសម្រាប់អ្នកជំងឺ រមែងមានទាំងបរិក្ខារ (នៃជីវិត) ព្រោះការពារនូវអន្តរាយទាំងឡាយបានដោយជុំវិញ ។ ព្រោះហេតុនោះ ទើបលោកពោលថា ព្រោះរក្សាទុក ។ល។ ដែលធ្វើជីវិតឲ្យវិនាស ដូច្នេះ ។

ក្នុងពាក្យទាំងឡាយនោះ បទថា **អន្តរំ** ប្រែថា ចន្លោះ មានន័យថា ឱកាស ។

សេចក្តីថា ព្រោះរក្សាទុក ហាក់បីដូចជាពួកអ្នកយាមដែលឈរព័ទ្ធជុំវិញ រក្សាចៅហ្វាយនាយរបស់ខ្លួន មិនឲ្យឱកាសដល់ពួកសត្រូវ ។

បទថា **អស្ស យោគ្គ ជីវិតស្ស** ប្រែថា នៃជីវិតនោះ ។ ពាក្យថា ព្រោះភាពជាហេតុ គឺព្រោះជាហេតុនៃការប្រព្រឹត្តិទៅអស់កាលយូរ ។

ពិតហើយ ភេសជ្ជៈដែលជាវសាយតនៈ គឺដែលមានក្នុងអាហារ រមែងញ៉ាំងជីវិតឲ្យរស់នៅអស់កាលជាយូរ ។ ភិក្ខុរមែងកម្ចាត់ទុក្ខ-វេទនា ដែលមិនទាន់កើតឡើងដោយការបរិភោគភេសជ្ជៈ មិនមែនកម្ចាត់វេទនាដែលកើតឡើងហើយនោះទេ ព្រោះទុក្ខវេទនាដែលកើតឡើងហើយទាំងឡាយនោះ មានការបែកធ្លាយទៅ តាមសភាវៈរបស់ខ្លួននោះឯង, ពិតហើយ សូម្បីដូច្នេះ លោកក៏ហៅទុក្ខវេទនា ដែលមិនទាន់កើតឡើងដូចជាវេទនាដែលកើតឡើងហើយថា កើតឡើងហើយ ។ ព្រោះដូច្នេះ វោហារថា កើតឡើងហើយនោះ រមែងមានបានក្នុងធម៌ទាំងឡាយ ដែលដូចគ្នានឹងធម៌ដែលកើតឡើងហើយនោះ, ដូចជាពាក្យថា **សា ឯវ តិត្តិរិ** ប្រែថា សត្វទទានោះឯង, **តានិយេវ ឱសធានិ** ឱសថនោះឯង ( គឺជាពូជសត្វទទាដូចគ្នា, ជាថ្នាំត្រូវគ្នា ) ដូច្នេះឯង ។ ព្រោះដូច្នេះ ទើបលោកពោលថា បទថា **ឧប្បន្នានំ** ប្រែថា កើតឡើងហើយ គឺមានហើយ បង្កើតហើយ ដូច្នេះ ។ ការកម្រើក

នៃធាតុនោះ ចាប់តាំងពីការបង្កខ្ជួន ក៏ជាសមុដ្ឋាននៃរោគទាំងឡាយ នេះ ព្រោះហេតុនោះ រោគទាំងឡាយនេះ ឈ្មោះថា មានការកម្រើក នៃធាតុនោះជាសមុដ្ឋាន ។

លោកអាចារ្យពោលទុកថា **ទុក្ខវេទនា** ដូច្នេះហើយពោលថា ទុក្ខវេទនាដែលជាអកុសលវិបាក ដើម្បីធ្វើឲ្យផ្សេងពីទុក្ខវេទនានោះ ព្រោះទុក្ខវេទនានោះ សូម្បីមានសភាពជាអកុសល ក៏មានដែរ ។

ការកម្រើកនៃធាតុឈ្មោះថា **ព្យាពាធ** ព្រោះអត្ថថា ធ្វើឲ្យលំបាកផ្សេងៗ, **ព្យាពាធ** នោះឯងជា **ព្យាបជ្ឈ** ប្រែថា ធ្វើឲ្យលំបាកផ្សេងៗ មានសេចក្ដីថា ជាទុក្ខ ។ ឈ្មោះថា **អព្យាបជ្ឈ** ព្រោះអត្ថថា ជាទីដែលមិនមាន **ព្យាបជ្ឈ** បានដល់ ការមិនមានទុក្ខ ។ ព្រោះហេតុនោះ ទើបលោកពោលថា បទថា **អព្យាបជ្ឈបរមតាយ** ប្រែថា ដើម្បីការមិនមានទុក្ខដ៏ក្រៃលែងដូច្នេះ ។ ពាក្យថា ទុក្ខនោះ បានដល់ ទុក្ខដែលមានរោគជាហេតុ ។

លោកអាចារ្យបំណងនឹងសម្ដែងថា ការអាស្រ័យបច្ច័យទាំងឡាយ មានចីវរជាដើម ឈ្មោះថា ការប្រើប្រាស់នោះឯង ដូច្នេះ ទើបពោលថា **តេ បដិច្ច និស្សាយ** ក៏បច្ច័យទាំងឡាយមានចីវរជាដើមទាំងឡាយនោះ ព្រោះហេតុដែលសត្វទាំងឡាយអាស្រ័យ ដូច្នេះហើយ ក៏នៅពោលថា **បរិភុញ្ជមានា** ប្រើប្រាស់ដូច្នេះ ។ បទថា **បវត្តន្តិ**

( ប្រព្រឹត្តទៅបាន ) កែជា **ជីវន្តិ** ( រស់នៅបាន ) ។

ការរស់នៅ ឈ្មោះថា ការប្រព្រឹត្តិទៅដែលជាហេតុពោលដល់ជីវិតិន្ទ្រីយ៍ថា មានការប្រព្រឹត្តិទៅជារស ដូច្នេះ ។

( ចប់ មហាដីកា )

( បច្ចយសន្និស្សិតសីល ចប់ )

## សាធនៈ

## ហេតុឱ្យសីលសម្រេចដល់ព្រម

គប្បីជ្រាបថា **សាធន** ( ហេតុឲ្យសម្រេច ) ក្នុងសីល ៥ យ៉ាងនេះ ដូច្នេះ **បាតិមោក្ខសំវរ** ភិក្ខុគប្បីឲ្យដល់ព្រមដោយសទ្ធា ព្រោះបាតិមោក្ខសំវរសីលនោះ ជាសទ្ធាសាធនៈ ( មានសទ្ធាជាហេតុឲ្យសម្រេច ) ព្រោះហេតុនៃការបញ្ញត្តិសិក្ខាបទជាការកន្លងវិស័យរបស់សាវ័ក ពិតហើយ ការត្រាស់ហាមនូវការទូលសុំ ឲ្យទ្រង់បញ្ញត្តសិក្ខាបទជានិទស្សនៈក្នុងសេចក្តីនេះបាន ព្រោះដូច្នោះបាតិមោក្ខសំវរសីលនោះភិក្ខុសមាទានសិក្ខាបទតាមដែលទ្រង់បញ្ញត្តទុកឲ្យហ្មត់ចត់ ដោយសទ្ធា ហើយមិនធ្វើសេចក្តីអាល័យសូម្បីក្នុងជីវិត និងគប្បីឲ្យដល់ព្រមបានយ៉ាងល្អ ដូចពាក្យដែលទ្រង់ត្រាស់ទុកថា

ភិក្ខុទាំងឡាយដែលជាអ្នកតាមរក្សាសីល ចូរជាអ្នកមានសីលជាទីស្រឡាញ់ ដោយល្អ មានការគោរព ( ក្នុងសីល ) គ្រប់ៗ ពេល ដូចសត្វត្រដៀវរិចរក្សាពង ចាមរីរក្សារោមកន្ទុយ មាតារក្សាបុត្រជាទីស្រឡាញ់តែមួយ បុគ្គលរក្សាភ្នែក ( ដែលនៅសល់ ) តែម្ខាង ដូច្នោះ ។

ហើយទ្រង់ត្រាស់ទុក ( ក្នុងទី ) ដទៃទៀតថា

មហាសមុទ្រមានការនៅយឺនយូរជាធម្មតា ក៏មិនហៀរច្រាំង យ៉ាងណា ម្នាលមហារាជ: សាវករបស់តថាគតក៏ដូច្នោះដូចគ្នា រមែង មិនកន្លងសិក្ខាបទ ដែលតថាគតបញ្ញត្តហើយដល់សាវកទាំងឡាយ សូម្បីព្រោះហេតុនៃជីវិត ។

ក្នុងសេចក្ដីនេះ គប្បីជ្រាបនូវរឿងព្រះថេរៈទាំងឡាយដែលត្រូវ ចោរចងទុកក្នុងព្រៃក្រាស់ ( ជានិទស្សនៈ ) :

បានឮថា ចោរទាំងឡាយចងព្រះថេរៈ(មួយអង្គ) ដោយវល្លិ៍ ម្យ៉ាង ( ទុកចោល ) ក្នុងព្រៃក្រាស់មហាវត្ត ព្រះថេរៈសឹងយ៉ាងនោះ ឯងចម្រើនវិបស្សនាអស់រយៈពេល ៧ថ្ងៃ បានសម្រេចអនាគាមិផល ហើយ បានមរណៈក្នុងទីនោះឯង ទៅកាន់ព្រហ្មលោក ។

( រឿងមួយទៀត ) ពួកចោរចងព្រះថេរៈមួយអង្គទៀតដោយ វល្លិផោម ( ទុកចោល ) ឲ្យសឹងនៅក្នុងតម្ពបណ្ណិទ្វីប ព្រះថេរៈនោះ កាលភ្លើងឆេះព្រៃរាលដាលមក ក៏មិនផ្ដាច់វល្លិ៍ ផ្ដើមតាំងវិបស្សនា រហូតបានសម្រេចជាព្រះអរហន្តសមសីសីបរិនិព្វានទៅ, ព្រះអភយៈ អ្នកជាទីឃភាណកៈ ( ពោលនូវគម្ពីរទីឃនិកាយ ) និមន្តទៅតាមផ្លូវ ជាមួយនឹងភិក្ខុ ៥០០ អង្គ, បានជួបលោក ក៏ឲ្យធ្វើឈាបនកិច្ចសរីរៈ របស់ព្រះថេរៈ ហើយក៏ឲ្យសាងព្រះចេតិយ ( បញ្ចុះអដ្ឋិ ) ទុក ។

ព្រោះហេតុនោះ កុលបុត្រដែលមានសទ្ធាដទៃ កាលបើញុំាង

បាតិមោក្ខឲ្យហ្មត់ចត់ សូម្បីលះបង់ជីវិតក៏មិនគប្បីទម្លាយសីលសំវរៈ ដែលព្រះលោកនាថជាម្ចាស់ទ្រង់បញ្ញត្តទុក ។

ដូចជា **បាតិមោក្ខសំវរសីល** ភិក្ខុគប្បីឲ្យដល់ព្រមដោយសទ្ធា យ៉ាងណា **ឥន្ទ្រិយសំវរសីល** ក៏គប្បីឲ្យដល់ព្រមដោយសតិដូច្នោះ ព្រោះថា **ឥន្ទ្រិយសំវរសីល** នោះ ជាសតិសាធនៈ ( មានសតិជាហេតុឲ្យសម្រេច) ហេតុដែលឥន្ទ្រិយ៍ទាំងឡាយតាំងមាំហើយមិនឲ្យបន្ទោះ ដែលទោសទាំងឡាយ មានអភិជ្ឈាជាដើម នឹងគប្បីហូរចូលមកបាន ព្រោះហេតុនោះ ឥន្ទ្រិយសំវរនោះ កាលព្រះយោគីរលឹកដល់ ( ព្រះធម៌ទេសនា ) **អាទិត្តបរិយាយសូត្រ** ដោយន័យថា ម្នាលភិក្ខុទាំងឡាយចក្ខុន្ទ្រិយ៍ ដែលចាក់ទម្លាយដោយដែកដុតក្រហមឆ្អៅប្រសើរជាងក្នុងការកាន់យកនូវអនុព្យញ្ជនៈ កាន់យកនូវនិមិត្តក្នុងរូបទាំងឡាយ ដែលគប្បីដឹងបានដោយចក្ខុមិនប្រសើរឡើយ ដូច្នេះជាដើម ហើយពេលវិញ្ញាណប្រព្រឹត្តទៅតាមទ្វារ មានចក្ខុទ្វារជាដើម ក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ហាមការប្រកាន់ មានការកាន់យកដោយនិមិត្តជាដើម ដែលជាផ្លូវនៃទោសទាំងឡាយ មានអភិជ្ឈាជាដើម ដែលគប្បីនឹងហូរចូលមកបាន ដោយការមិនវង្វេងសតិ (នោះឯង ) គប្បីធ្វើឲ្យដល់ព្រមយ៉ាងល្អ ។

កាលបើឥន្ទ្រិយសំវរសីលនោះភិក្ខុមិនធ្វើឲ្យដល់ព្រមយ៉ាងនេះ

ហើយសម្បីសីលបាតិមោក្ខ ក៏មិនអាចតាំងនៅបានយូរ ប្រៀបដូចជាស្រូវសំណាបដែលមិនបានធ្វើរបងជុំវិញ ក៏មិនតាំងនៅបានយូរ ។

ម្យ៉ាងទៀតភិក្ខុដែលមិនធ្វើឥន្ទ្រិយសំវរឲ្យដល់ព្រម រមែងត្រូវចោរ គឺកិលេសទាំងឡាយប្រទូសរ៉ាយបាន ដូចជាផ្ទះដែលបើកទ្វារទុក ក៏ត្រូវចោរចូលយកបានដូច្នោះ ប្រការមួយទៀត រាគៈរមែងហូរស្រោចចិត្តរបស់អ្នកបាន ដូចភ្លៀងហូរចូលផ្ទះដែលប្រក់មិនបានជិតល្អដូច្នោះ សមដូចព្រះពុទ្ធភាសិតត្រាស់ទុកថា ភិក្ខុគប្បីរក្សាឥន្ទ្រិយ៍ខាងក្នុង ព្រោះរូប សំឡេង ក្លិន រស និងផស្សៈទាំងឡាយ ព្រោះទ្វារទាំងឡាយដែលបើកទុកមិនរក្សា រមែងប្រទូសរ៉ាយ ( អ្នកមិនរក្សា ) ដូចចោរចូលផ្ទះដែល ( បើកទ្វារទុក ) ដូច្នោះ ភ្លៀងរមែងហូរស្រោចផ្ទះដែលប្រក់មិនជិតល្អបានយ៉ាងណា រាគៈក៏រមែងហូរស្រោចចិត្តដែលមិនបានអប់រំ ក៏ដូច្នោះដែរ ។

តែកាលឥន្ទ្រិយសំវរនោះ ដែលភិក្ខុធ្វើឲ្យដល់ព្រមហើយ សម្បីសីលបាតិមោក្ខ ក៏រមែងតាំងនៅយឺនយូរ ដូចស្រូវសំណាបដែលមានរបងព័ទ្ធជុំវិញដោយល្អ រមែងតាំងនៅយឺនយូរបានដូច្នោះ ។ ម្យ៉ាងទៀតភិក្ខុធ្វើឥន្ទ្រិយសំវរសីលឲ្យដល់ព្រមចោរគឺកិលេសទាំងឡាយ រមែងប្រទូសរ៉ាយមិនបាន ដូចផ្ទះដែលបិទទ្វារល្អហើយ ពួកចោរទម្លាយមិនបានដូច្នោះ, ប្រការមួយទៀត រាគៈក៏ហូរស្រោចចិត្តរបស់

អ្នកមិនបាន ដូចភ្លៀងហូរស្រោចចូលផ្ទះដែលប្រក់ជិតល្អហើយ មិនបានដូច្នោះ ។ សមដូចព្រះពុទ្ធវចនៈត្រាស់ថា ភិក្ខុគប្បីរក្សាឥន្ទ្រិយ៍ខាងក្នុង ព្រោះរូប សំឡេង ក្លិន រស និងផស្សៈទាំងឡាយ ព្រោះថាទ្វារទាំងឡាយ ដែលបិទរក្សាហើយដោយល្អនោះ រមែងមិនប្រទុស-រ៉ាយដល់ ( អ្នករក្សា ) ទេ ដូចពួកចោរទម្លាយផ្ទះដែលបិទល្អហើយមិនបាន ដូច្នោះ ។

ភ្លៀងរមែងហូរស្រោចផ្ទះដែលប្រក់ល្អហើយមិនបាន យ៉ាងណា រាគៈរមែងហូរស្រោចចិត្តដែលបានអប់រំហើយ មិនបានក៏យ៉ាងនោះ ទេសនានេះ ជាទេសនាដ៏ឧក្រិដ្ឋក្រៃលែង ។ ចិត្តជាធម្មជាតិលឿនរហ័ស ព្រោះដូច្នោះ ឥន្ទ្រិយសំវរៈ ( នោះ ) ភិក្ខុចាំបាច់ត្រូវបន្ទោបង់នូវរាគៈដែលកើតឡើង ដោយមនសិការនូវអសុភកម្មដ្ឋាន ហើយទើបធ្វើឲ្យដល់ព្រមបាន ដូចព្រះវង្គីសត្ថេរដែលបួសថ្មីដូច្នោះ ។

## រឿងព្រះវង្គីសត្ថេរ

បានឮថា ពេលព្រះថេរៈបានបួសហើយថ្មីៗ ( តាមព្រះអានន្ទៈ ) ទៅបិណ្ឌបាត រាគៈកើតឡើងព្រោះឃើញស្ត្រីម្នាក់ ទើបប្រាប់ព្រះអានន្ទថា បពិត្រអ្នកគោតមគោត្រ ខ្ញុំម្ចាស់ត្រូវកាមរាគៈដុតរោលចិត្តរបស់ខ្ញុំម្ចាស់ឲ្យអន្ទះអន្ទែង សូមលោកម្ចាស់ករុណាប្រាប់នូវឧបាយ

រំលត់ភាពក្តៅក្រហាយផងចុះ ។

ទើបព្រះថេរៈប្រាប់ថា ចិត្តរបស់លោកក្តៅក្រហាយ ព្រោះធ្វើការសម្គាល់ខុស លោកចូរវៀរចាកសុភនិមិត្ត ដែលជាផ្លូវកើតរាគៈចេញ ចូរអប់រំចិត្តឲ្យតាំង មាំដោយអសុភសញ្ញាចូរ ( ពិចារណា ) ឃើញសង្ខារទាំងឡាយជារបស់ដទៃ (មិនឋិតថេរ) ដោយភាពជាទុក្ខនិងដោយជាសភាពមិនមែនខ្លួន ញុំាងរាគៈធំឲ្យរលត់ទៅ ចូរកុំក្តៅក្រហាយតទៅទៀតឡើយ ។ ព្រះវង្គីសត្ថេរ បន្ទោបង់នូវរាគៈបានហើយ ទើបនិមន្តទៅបិណ្ឌបាតតទៅ ។ ម្យ៉ាងទៀត ភិក្ខុអ្នកបំពេញនូវឥន្ទ្រិយសំវរៈ គប្បីដូចជាព្រះចិត្តគុត្តត្ថេរអ្នកនៅក្នុងរូងភ្នំធំឈ្មោះកុរណ្ឌកៈនិងព្រះមហាមិត្តត្ថេរ នៅក្នុងមហាវិហារ ឈ្មោះ ចោរកៈ ។

## រឿងព្រះចិត្តគុត្តត្ថេរ

បានឮថា ក្នុងរូងភ្នំកុរណ្ឌកៈមានចិត្តកម្មអំពីរឿងអភិនេស្រ្កមណ៍នៃព្រះពុទ្ធជាម្ចាស់ ៧ ព្រះអង្គ ជាទីកក់ក្តៅចិត្ត ភិក្ខុជាច្រើនអង្គនិមន្តទៅរកមើលសេនាសនៈ ឃើញចិត្តកម្មនោះ ក៏ពោល ( សរសើរព្រះថេរៈ ) ថា ចិត្តកម្មនេះគួរឲ្យរីករាយ ចិត្ត ព្រះថេរៈពោលថា អាវុសោទាំងឡាយ យើងនៅក្នុងរូងភ្នំជាង ៦០ ឆ្នាំហើយ យើងមិនដឹងថាមានចិត្តកម្ម ឬមិនមានឡើយ ថ្ងៃនេះអាស្រ័យអ្នកទាំងឡាយដែលប្រើ

ភ្នែកទើបដឹង មានន័យថា ព្រះថេរៈនៅមកយូរប៉ុណ្ណោះ មិនធ្លាប់បាន ក្រឡេកមើលជញ្ជាំងល្អាងភ្នំឡើយ ។

ម្យ៉ាងទៀតនៅជិតមាត់រូងភ្នំរបស់លោកមានដើមខ្វឹងមួយដើមផងដែរ សូម្បីដើមឈើនោះ ព្រះថេរៈក៏មិនធ្លាប់ងើយមើលលើផងដែរ ពេលបានឃើញកេសរផ្កាជ្រុះមកលើផែនដី តាមរដូវនៃឆ្នាំ ទើបដឹងថា វាមានផ្កា, ព្រះរាជា ទ្រង់បានស្តាប់គុណសម្បត្តិរបស់ព្រះថេរៈ ក៏មានបំណងចង់ថ្វាយបង្គំ ទ្រង់បញ្ជូន ( រាជបុរសទៅនិមន្ត ) ដល់ទៅ ៣ ដង កាលបើព្រះថេរៈមិនមក ទើបត្រាស់ឲ្យចងរឹតដោះរបស់ស្ត្រីកូនខ្ចី ក្នុងស្រុកភូមិនោះ ហើយឲ្យប្រថាប់ព្រះរាជត្រា ( លើសំពត់រឹតទឹកដោះនោះ ) មានព្រះរាជឱង្ការទុកថា ពួកទារកមិនបាន ( ផឹកទឹកដោះទេ ) បើសិនថា ព្រះថេរៈមិនមក ទើបព្រះថេរៈព្រមទៅកាន់មហាគ្រាម ព្រោះការអាណិតពួកទារក, ព្រះរាជាទ្រង់ស្តាប់ ( ដំណឹងនោះ ) ហើយ ត្រាស់ ( ដល់រាជបុរស ) ថា នែ ! នាយ អ្នកទាំងឡាយ ចូរទៅនិមន្តព្រះថេរៈចូលមក យើងនឹងទទួលសីល ហើយប្រទានឲ្យនាំចូលទៅក្នុងរាជវាំង ទ្រង់នមស្ការព្រះថេរៈហើយ ទ្រង់អង្គាសព្រះថេរៈហើយ មានព្រះរាជឱង្ការថា លោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះមិនទាន់មានឱកាស ស្អែកនេះខ្ញុំម្ចាស់នឹងទទួលសីល ដូច្នេះ ទ្រង់ទទួលយកបាត្ររបស់ព្រះថេរៈ ស្តេចជូនដំណើរបន្តិចជាមួយព្រះទេវី ទ្រង់

ថ្វាយបង្គំហើយ ក៏ស្ដេចត្រឡប់មកវិញ, ព្រះរាជា ឬព្រះទេវីថ្វាយបង្គំ ពេលណាក៏ដោយ ព្រះថេរៈក៏ពោលថ្វាយព្រះពរ ( ដោយពាក្យតែមួយ ) ថា **សុខី ហោតុ មហារាជា** សូមមហារាជ ចូរទ្រង់មានសេចក្ដីសុខ ៧ ថ្ងៃកន្លងទៅ ដោយអាការយ៉ាងនោះ ភិក្ខុទាំងឡាយបានសួរលោកថា លោកម្ចាស់ដ៏ចម្រើន ហេតុអ្វីពេលព្រះរាជា ទ្រង់ថ្វាយបង្គំក្ដី ព្រះទេវីទ្រង់ថ្វាយបង្គំក្ដី លោកថ្វាយព្រះពរ ( ដូចគ្នា ) យ៉ាងនេះ ថា **សុខី ហោតុ មហារាជា** ព្រះថេរៈឆ្លើយថា អាវុសោទាំងឡាយ យើងមិនបានធ្វើការសម្គាល់ថា ជាព្រះរាជា ឬព្រះទេវីទេ លុះកន្លងទៅ ៧ ថ្ងៃ ទ្រង់បានដោះលែង ដោយទ្រង់ឃើញថា ការនៅក្នុងទីនេះរបស់ព្រះថេរៈ ជាការលំបាក ដូច្នេះទើបត្រឡប់ទៅរួងភ្នំកុរណ្ឌកៈវិញ ហើយឡើងទៅកាន់ទីចង្រ្កម ក្នុងពេលកណ្ដាលយប់ ទេវតាអាស្រ័យនៅនឹងដើមខ្នុងឈរកាន់ប្រទីប ( បំភ្លឺឲ្យ ) គ្រានោះ កម្មដ្ឋានរបស់លោក បានប្រាកដបរិសុទ្ធក្រៃលែង ព្រះថេរៈសប្បាយចិត្តថា ហេតុអ្វីហ្ន៎ ! ថ្ងៃនេះកម្មដ្ឋានរបស់យើងត្រចះត្រចង់ក្រៃលែង បណ្ដាលឲ្យភ្នំ ( កូនភ្នំនោះលាន់សំឡេង ) ទាំងផ្ទៃឈើក៏លាន់សំឡេង ក៏បានសម្រេចព្រះអរហត្តក្នុងវេលាមជ្ឈិមយាម ព្រោះហេតុនោះ សូម្បីកុលបុត្តដទៃប្រាថ្នានូវប្រយោជន៍ មិនគប្បីមានភ្នែករវើរវាយ ដូចស្វាក្នុងព្រៃ ដូចជាសត្វផ្អើលក្នុងព្រៃ និងដូចជាទារកភ័យខ្លាច គប្បីដាក់ចក្ខុសំយុង

ចុះ សម្លឹងមើលត្រឹមតែមួយជួរនឹម កុំគប្បីទៅតាមអំណាចរបស់ចិត្ត ដែលរសាប់រសល់ដូចស្វាព្រៃ ។

# រឿងព្រះមហាមិត្តត្ថេរ

ពេលមួយ រោគបួសមានពិស បានកើតឡើងដល់ញោមស្រី របស់ព្រះមហាមិត្តត្ថេរ សូម្បីធីតារបស់នាងក៏បួសក្នុងសម្នាក់ភិក្ខុនី ទើបនាងពោលនឹងធីតាភិក្ខុនីនោះថា ទៅចុះកូនម្តាយ កូនចូរទៅកាន់សម្នាក់បងប្រុស ប្រាប់សេចក្តីដែលញោមមិនសប្បាយ ហើយយកថ្នាំមកចុះ ភិក្ខុនីនោះទៅប្រាប់ហើយ ព្រះថេរៈពោលថា អាត្មាមិនដឹងនឹងរកថ្នាំផ្សេងៗ មានថ្នាំឫសឈើជាដើម មកដាំស្ងោរឲ្យបានទេ តែនឹងប្រាប់ថ្នាំដល់ប្អូន ( ដូច្នេះ **អហំ យតោ បព្វជិ ។បេ។ មាតុយា មេ ផាសុ ហោតុ** ) អាត្មាចាប់តាំងពីកាលបួសហើយ មិនធ្លាប់មានចិត្តដែលសហគតដោយលោភៈ ហើយទម្លាយឥន្ទ្រីយ៍ទាំងឡាយ ក្រឡេកមើលរូបដែលជាវិសភាគៈឡើយ ដោយពាក្យសច្ចៈនេះសូមសេចក្តីសុខចូរមានដល់ញោមអាត្មាចុះ ប្អូនស្រីត្រឡប់ទៅវិញចុះ ចូរពោលពាក្យ ( **អហំ យតោ** ។បេ។...) ដែលអាត្មាពោលហើយនេះ ហើយអង្អែលសរីរៈរបស់មាតាចុះ ភិក្ខុនីនោះ ( ត្រឡប់ ) ទៅ ពោលខ្លឹមសារនោះហើយ បានធ្វើតាមការប្រាប់ទាន់ពេលនោះឯង បួសរបស់

ឧបាសិកាក៏ថ្វាយទៅ ដូចពពុះទឹកដែលបែកដូច្នោះ នាងក្រោកឡើង ហើយបន្ទឹ វាចាសម្ដែងសេចក្ដីសប្បាយរីករាយចេញមកថា ប្រសិនបើព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះជន្មនៅពិត ព្រះអង្គប្រាកដជាអង្អែលសីសៈរបស់ភិក្ខុដែលដូចជាបុត្តរបស់យើងដោយព្រះហស្ត ដែលមានក្បាច់ដ៏វិចិត្រមិនខាន ដូច្នេះ ហេតុនោះសូម្បីបុគ្គលដទៃដែលមានការសម្គាល់ថា ខ្លួនជាកូនរបស់ត្រកូល បានបួសក្នុងព្រះសាសនាហើយ គប្បីតាំងនៅក្នុងឥន្ទ្រិយសំវរៈដ៏ប្រសើរ ដូចព្រះមិត្តត្ថេរហោង ។

**ឥន្ទ្រិយសំវរៈ** ភិក្ខុគប្បីឲ្យដល់ព្រមដោយសតិយ៉ាងណា អាជីវ-បារិសុទ្ធិសីល ភិក្ខុគប្បីឲ្យដល់ព្រមដោយសេចក្ដីព្យាយាមដូច្នោះដែរ ព្រោះអាជីវបារិសុទ្ធិនោះ ជាវីរិយសាធនៈ ( មានវីរិយៈជាហេតុឲ្យសម្រេច ) ព្រោះថា ការព្យាយាមដែលប្រារព្ធ ហើយដោយល្អជាហេតុឲ្យមានការលះមិច្ឆាជីវៈ ហេតុនោះ **អាជីវបារិសុទ្ធិសីល** នេះ ភិក្ខុលះបង់អនេសនា ការស្វែងរកមិនសមគួរចេញ ហើយសេពតែបច្ច័យដែលកើតឡើងដោយបរិសុទ្ធ វៀរបច្ច័យដែលកើតឡើងមិនបរិសុទ្ធដែលដូចជាអសិរពិសចេញ គប្បីធ្វើឲ្យដល់ព្រមបាន ដោយការស្វែងរកដោយល្អ មានការនិមន្តទៅបិណ្ឌបាតជាដើម ដោយសេចក្ដីព្យាយាម ។

ក្នុងបច្ច័យ ២ យ៉ាង ( គឺបរិសុទ្ធុប្បាទប្បច្ចយនិងអបរិសុទ្ធុប្បាទ-

ប្បច្ចយ ) នោះ សម្រាប់ភិក្ខុអ្នកមិនបានកាន់ធុតង្គ បច្ច័យដែលកើតពីសង្ឃ ឬពីគណៈក្តី ពីសម្នាក់គ្រហស្ថអ្នកជ្រះថ្លាដោយគុណទាំងឡាយរបស់អ្នកដែលមានការសម្តែងធម៌ជាដើមក្តី ឈ្មោះថា បច្ច័យកើតឡើងដោយបរិសុទ្ធ ចំណែកបច្ច័យដែលកើតឡើងដោយវត្ត មានការនិមន្តទៅបិណ្ឌបាតជាដើម ឈ្មោះថា កើតឡើងដោយបរិសុទ្ធយ៉ាងក្រៃលែង សម្រាប់ភិក្ខុអ្នកកាន់ធុតង្គ បច្ច័យដែលកើតឡើងដោយវត្តមានការនិមន្តទៅបិណ្ឌបាតជាដើម និងកើតឡើងពីសម្នាក់គ្រហស្ថដែលជ្រះថ្លាក្នុងធុតង្គគុណរបស់លោក ដោយអនុលោមដល់ធុតង្គនិយម ឈ្មោះថា បច្ច័យដែលកើតឡើងដោយបរិសុទ្ធ ។ ម្យ៉ាងទៀត ការសមាទានធុតង្គរបស់អ្នកបរិភោគថ្នាំដែលត្រាំអំពីសម៉ ( ត្រាំទឹកនោម ) ស្អុយ និងមធុរភេសជ្ជៈ៤ កើតឡើង ( បានមក ) ដើម្បីប្រើរំងាប់ព្យាធិ ម្យ៉ាងគិតថា មិត្តសព្រហ្មចារីដទៃៗ នឹងត្រូវឆាន់ចតុមធុរភេសជ្ជៈ ( ជាប្រាកដ ) ដូច្នេះហើយ ( ខ្លួនឯង ) ឆាន់តែសម៉ប៉ុណ្ណោះជាការប្រពៃ ភិក្ខុដូច្នោះ លោកហៅថា **អរិយវំសិកភិក្ខុ** ( ភិក្ខុនៅក្នុងអរិយវង្ស ) ថ្នាក់ឧត្តម ។

ឯបច្ច័យទាំងឡាយ មានចីវរប្បច្ច័យនោះ បណ្តាបច្ច័យទាំងឡាយនោះ ក្នុងចីវរនិងបិណ្ឌបាត, និមិត្ត ( ការធ្វើនិមិត្ត ), ឱភាស ( និយាយឲ្យន័យ ), **បរិកថា** ( និយាយពន្ធ ), **វិញ្ញត្តិ** ( សុំត្រង់ៗ )

រមែងមិនសមគួរដល់ភិក្ខុគ្រប់រូប ដែលនឹងធ្វើអាជីវៈឲ្យបរិសុទ្ធ តែក្នុងសេនាសនៈ និមិត្ត ឱភាស និងបរិកថា គួរសម្រាប់ភិក្ខុអ្នកមិនបានកាន់ធុតង្គ ។

ក្នុងអាការទាំងឡាយនោះ ពេលភិក្ខុធ្វើកិច្ច មានបរិកម្មទីរាបស្មើជាដើម ដើម្បីក្រាលសេនាសនៈ កាលបើគ្រហស្ថទាំងឡាយសួរថា លោកដ៏ចម្រើនធ្វើអ្វី នរណាឲ្យធ្វើ ក៏ពោលតបថា មិនមាននរណាឲ្យធ្វើទេ ដូច្នេះ ឬថា និមិត្តកម្ម ( ការធ្វើដូចគ ) រូបនោះយ៉ាងដទៃទៀត ឈ្មោះថា និមិត្ត ( ធ្វើគ ) ពេលដែលភិក្ខុសួរថា ឧបាសក ឧបាសិកាទាំងឡាយ អ្នកទាំងឡាយនៅផ្ទះអ្វី កាលគេតបថា នៅប្រាសាទលោកម្ចាស់ ក៏និយាយថា ឧបាសកឧបាសិកាទាំងឡាយ ប្រាសាទមិនសមគួរដល់ភិក្ខុទាំងឡាយទេ ដូច្នេះ, ឬឱភាសកម្ម ( ការនិយាយឲ្យន័យ ) រូបនោះយ៉ាងដទៃទៀត ឈ្មោះថា ឱភាស ( ឲ្យន័យ ), ការដែលភិក្ខុនិយាយថា សេនាសនៈរបស់ភិក្ខុសង្ឃតូចចង្អៀត ដូច្នេះ ឬថា និយាយអមទៅរូបដទៃទៀត ឈ្មោះថា **បរិកថា** ( និយាយព័ទ្ធ ) ។

ក្នុងភេសជ្ជៈ អាការទាំងអស់រមែងគួរ តែភេសជ្ជៈដែលកើតឡើង (ដោយអាការមាននិមិត្តជាដើម ) យ៉ាងនេះ ភិក្ខុឆាន់ពេលដែលរោគជាហើយ មិនគួរក្នុងរឿងភេសជ្ជៈ ( ដែលកើតឡើងយ៉ាងនោះ ) នោះ ព្រះវិន័យធរទាំងឡាយ ពោលថា ឱកាស ( ដែលអាចឆាន់ថ្នាំ

បាន ) ព្រះមានព្រះភាគទ្រង់ប្រទានទុកហើយ ព្រោះហេតុនោះ ទើបគួរ ចំណែកអាចារ្យផ្អែកខាងព្រះសូត្រពោលទុកថា មិនជាអាបត្តិ ក៏ពិតហើយ សូម្បីយ៉ាងនោះ ក៏ធ្វើអាជីវៈឲ្យកម្រើក ហេតុនោះ ទើបមិនគួរ ភិក្ខុណាមិនធ្វើនិមិត្ត ឱភាស បរិកថា និងវិញ្ញត្តិ សូម្បីព្រះមានព្រះភាគទ្រង់អនុញ្ញាតអាស្រ័យគុណ មានសេចក្តីប្រាថ្នាតិចជាដើមនោះឯង ។

សូម្បីទីងត្រូវអស់ជីវិតប្រាកដឡើងចំពោះមុខ ក៏នៅតែសេពចំពោះបច្ច័យដែលកើតឡើង វៀរចាកកម្មដែលជាហេតុធ្វើឲ្យអាជីវៈកម្រើក មានឱភាសជាដើម ភិក្ខុនេះលោកហៅថា អ្នកមានការប្រព្រឹត្តជាបរមសល្លេខ ដូចព្រះសារីបុត្តត្ថេរ ដូច្នោះ ។

## រឿងព្រះសារីបុត្តអាពាធ

បានឮថា ក្នុងសម័យមួយព្រះសារីបុត្តបានចម្រើននូវបវិវេក ( ការស្ងាត់ចាកកាម និងអកុសលធម៌ ) ទើបនិមន្តទៅកាន់ព្រៃមួយកន្លែងជាមួយព្រះមហាមោគ្គល្លានត្ថេរ ។ ថ្ងៃមួយអាពាធព្រោះខ្យល់ក្នុងផ្ទៃកើតឡើង ញ៉ាំងទុក្ខដ៏ខ្លាំងក្លាឲ្យកើតឡើងដល់លោក ព្រះមហាមោគ្គល្លានទៅកាន់ទីឧបដ្ឋាកលោកក្នុងពេលល្ងាច ឃើញព្រះថេរៈសឹងក៏សួរ ( ជ្រាប ) សេចក្តីនោះហើយសួរថា ( អាវុសោកាលមុន

សេចក្ដីសុខកើតដល់លោកដោយវត្ថុអ្វី ព្រះថេរៈពោលថា អាវុសោ កាលនៅជាគ្រហស្ថ ញោមស្រីរបស់ខ្ញុំម្ចាស់ បានឲ្យបាយបាយាស ជាំជាមួយទឹកដោះសុទ្ធៗ ផ្សំជាមួយទឹកដោះថ្លា ទឹកឃ្មុំ និងស្ករអំពៅ សេចក្ដីសុខមានដល់ខ្ញុំម្ចាស់ ដោយបាយបាយាសនោះ ចំណែកលោកព្រះមហាមោគ្គល្លាន ពោលថា អាវុសោ ណ្ហើយចុះ! បើបុណ្យរបស់ខ្ញុំម្ចាស់ ឬរបស់លោកម្ចាស់មាន ទោះយ៉ាងណា ស្អែកនេះយើងក៏គង់នឹងបានពោលដល់ទេវតាដែលអាស្រ័យនៅដើមផ្ចុំ ខាងក្រោយទីចង្ក្រម បានឮពាក្យសន្ទនានេះរបស់លោកទាំងពីរ ទើបគិតថា យើងនឹងជួយឲ្យបាយបាយាសកើតដល់ព្រះគុណម្ចាស់ក្នុងថ្ងៃស្អែកនេះ ទើបចូលទៅកាន់ត្រកូលឧបដ្ឋាករបស់ព្រះថេរៈក្នុងពេលនោះឯង គេចូលក្នុងកាយរបស់កូន ច្បងក្មេងបណ្ដាលអាការជាឈឺឲ្យកើតឡើង រួចហើយទេវតានោះទើបបន្លឺសំឡេង និយាយជាមួយញាតិដែលមកជួបជុំគ្នារក្សាអ្នកជំងឺនោះ ប្រសិនបើអ្នកចាត់ចែងធ្វើនូវបាយបាយាស ឈ្មោះយ៉ាងនេះ ថ្វាយព្រះថេរៈក្នុងថ្ងៃស្អែកនេះបាន ទើបខ្ញុំដោះលែង ញាតិទាំងឡាយនោះពោលថា សូម្បីលោកមិនប្រាប់ ក៏ពួកខ្ញុំម្ចាស់ ថ្វាយភិក្ខាដល់លោកម្ចាស់ជាប្រចាំហើយ ដូច្នេះ ក្នុងថ្ងៃស្អែកឡើង ក៏បានជួយគ្នាចាត់ចែងធ្វើបាយាសយ៉ាងនោះត្រៀមទុក ព្រះមហាមោគ្គល្លានត្រេនិមន្តមក (កន្លែងព្រះសារីបុត្តពីព្រលឹម) ពោល

ថា អាវុសោ ! លោកចូរនៅក្នុងទីនេះ រហូតដល់ពេលខ្ញុំម្ចាស់ទៅបិណ្ឌបាតហើយត្រឡប់មកវិញ ហើយក៏ចូលទៅកាន់ភូមិមនុស្សទាំងឡាយនោះចេញទៅទទួលលោក ទទួលបាត្រព្រះថេរៈមកដាក់នូវបាយាសប្រភេទដូចពោលហើយនោះ យ៉ាងពេញហើយថ្វាយ, ព្រះថេរៈសម្តែងអាកា ( ត្រឡប់ទៅវិញ ), លោកដ៏ចម្រើននិមន្តឆាន់ចុះខ្ញុំម្ចាស់ទាំងឡាយនឹងថ្វាយ ( មួយបាត្រទៀត ) ញុំាងព្រះថេរៈឲ្យឆាន់រួចហើយ បានថ្វាយពេញបាត្រទៀត ព្រះថេរៈមកដល់ហើយបង្អោនចូលទៅថ្វាយ ពោលថា អាវុសោ សារីបុត្ត និមន្តឆាន់ចុះ ចំណែកព្រះថេរៈឃើញបាយាសនោះហើយគិតថា បាយាសគួរ ពេញចិត្តក្រៃលែង ( នេះ ) កើតឡើងដោយរបៀបណា ក៏បានដឹងហេតុដែលកើតឡើងនៃបាយាសនោះ ទើបពោលថា នាំចេញទៅចុះ អាវុសោមោគ្គល្លានបិណ្ឌបាតនេះមិនគួរបរិភោគទេចំណែកព្រះមហាមោគ្គល្លាននោះ មិនញុំាងចិត្តសូម្បីតែ ( គិតទោមនស្ស ) ឲ្យកើតឡើងថា គេមិនឆាន់បិណ្ឌបាត ដែលបុគ្គលដូចជាយើងនាំមកឲ្យហើយ ដោយពាក្យ ( ប្រាប់របស់ព្រះសារីបុត្ត ) តែម្តងប៉ុណ្ណោះ ក៏យកបាត្រ ( ចេញទៅ ) ផ្កាប់បាត្រចាក់ចោលក្នុងកន្លែងមួយ ព្រមគ្នានឹងបាយាស ( ធ្លាក់ចុះ ) ដល់ផែនដី អាពាធរបស់ព្រះថេរៈក៏ជាសះស្បើយ ចាប់តាំងពីពេលនោះមកអស់រយៈ ៤៥ ឆ្នាំ អាពាធដូច្នេះ មិនដែលកើតឡើងទៀត

ឡើយ, លំដាប់នោះ ព្រះសារីបុត្តបានពោលនឹងព្រះមហាមោគ្គល្លាន ថា អាវុសោ បាយបាយាសដែលកើតឡើងអាស្រ័យវចីវិញ្ញត្តិ ជារបស់មិនគួរបរិភោគ សូម្បី ( ឃ្លាន ) រហូតដល់ពោះវៀនចេញក្រៅ ( រករបស់ស៊ី ) នៅតាមផែនដី ( ក៏ដោយ ) ហើយបានបន្លឺឧទាននេះថា បើយើងជាអ្នកបរិភោគនូវមធុបាយាសដែលកើតឡើង ព្រោះបន្ទីវាចា ជាវចីវិញ្ញត្តិនោះ អាជីវៈរបស់យើងនឹងត្រូវតិះដៀល សូម្បីចង្វាយពោះវៀនរបស់យើងនឹងចេញមកខាងក្រៅ យើងក៏មិនគប្បីទម្លាយអាជីវៈជាដាច់ខាត សូម្បីត្រូវលះបង់ជីវិត ( ក៏ដោយ ) យើងគ្រប់គ្រងចិត្តរបស់ខ្លួនបាន យើងវៀរចាកការស្វែងរកមិនសមគួរ មិនធ្វើអនេសនាដែលព្រះពុទ្ធជាម្ចាស់ខ្ពើមឡើយ ដូច្នេះ ។

ម្យ៉ាងទៀត សូម្បីរឿងរបស់ព្រះមហាតិស្សត្ថេរ ដែលឆាន់ផ្លែស្វាយ ដែលអាស្រ័យនៅក្នុងចីវរគុម្ពវិហារ ក៏គួរពោលទុកក្នុងទីនេះ អ្នកនៅក្នុងព្រៃដែលបួសដោយសទ្ធា មានបញ្ញាពិចារណាឃើញផលដោយប្រចក្ស មិនឲ្យសូម្បីតែការគិត ក្នុងការស្វែងរកមិនសមគួរដោយប្រការទាំងពួងកើតឡើងឡើយ គប្បីធ្វើអាជីវៈឲ្យបរិសុទ្ធបានដោយប្រការដូច្នេះ ។

ដូចជា **អាជីវបារិសុទ្ធសីល** ដែលភិក្ខុឲ្យដល់ព្រមដោយការព្យាយាម យ៉ាងណា **បច្ចយសន្និស្សិតសីល** ភិក្ខុគប្បីឲ្យដល់ព្រម

ដោយបញ្ញាដូច្នោះព្រោះបច្ចយសន្និស្សិតសីលនោះជាបញ្ញាសាធនៈ ( មានបញ្ញាជាហេតុឲ្យសម្រេច ) ព្រោះថា បុគ្គលមានបញ្ញា ជាអ្នកអាចឃើញទោស និងអានិសង្សក្នុងការបរិភោគបច្ច័យទាំងឡាយ ព្រោះហេតុនោះ បច្ចយសន្និស្សិតសីលនោះ ភិក្ខុដែលលះការពេញចិត្តក្នុងបច្ច័យហើយ ពិចារណាដោយបញ្ញា ដោយវិធីតាមដែលពោលហើយ ទើបបរិភោគបច្ច័យដែលកើតឡើង ដោយធម៌តាមសមគួរ ( នោះឯង ) គប្បីធ្វើឲ្យដល់ ព្រមបាន ។

ក្នុងបច្ចយសន្និស្សិតសីលនោះ ការពិចារណាមានពីរយ៉ាង គឺ

១- ពិចារណាក្នុងពេលបានបច្ច័យទាំងឡាយ ។

២- ពិចារណាក្នុងពេលបរិភោគបច្ច័យទាំងឡាយ ។

តាមពិតការពិចារណារបស់ភិក្ខុ អ្នកបរិភោគបច្ច័យទាំងឡាយមានចីវរជាដើម ដែលពិចារណាថា ជាធាតុ ឬជារបស់បដិកូល សូម្បីក្នុងពេលបានមកហើយរក្សាទុកបន្ទាប់ពីពេលបាននោះទៅក៏មិនមានទោសឡើយ សូម្បីក្នុងពេលបរិភោគ ។

តទៅនេះ ជាការវិនិច្ឆ័យដែលធ្វើការព្រមព្រៀង ( មិនមានការសង្ស័យ ) ក្នុងការពិចារណានាពេលបរិភោគបច្ច័យនោះ ។

## ការបរិភោគមាន ៤ យ៉ាង

-ថេយ្យបរិភោគ ( បរិភោគដូចជាចោរ ) ។

-ឥណបរិភោគ ( បរិភោគដូចជាអ្នកជាប់បំណុល ) ។

-ទាយជ្ជបរិភោគ ( បរិភោគដូចជាអ្នកទទួលមរតក ) ។

-សាមីបរិភោគ ( បរិភោគដូចជាម្ចាស់របស់ ) ។

ក្នុងបរិភោគ ៤ យ៉ាងនោះ ការបរិភោគរបស់ភិក្ខុទ្រុស្តសីល អង្គុយនៅក្នុង កណ្តាលសង្ឃ ក៏ឈ្មោះថា **ថេយ្យបរិភោគ** ។

ការបរិភោគបច្ច័យ ដែលខ្លួនមិនបានពិចារណារបស់ភិក្ខុអ្នកមានសីល ឈ្មោះថា **ឥណបរិភោគ** ។

ព្រោះហេតុនោះ ចីវរ ភិក្ខុគប្បីពិចារណាគ្រប់ៗ ពេលដែលបរិភោគ, បិណ្ឌបាតគប្បីពិចារណាគ្រប់ៗ ពេលដែលទំពាលេប, បើមិនអាចយ៉ាងនោះគប្បីពិចារណាក្នុងពេលមុនឆាន់ ក្នុងពេលក្រោយឆាន់ ក្នុងយាមខាងដើម ក្នុងយាមកណ្តាល យាមចុងក្រោយ ( ពេលណាមួយ ) បើភិក្ខុនោះមិនបានពិចារណា រហូតដល់អរុណរះឡើង លោករមែងតាំងនៅក្នុងឋានៈ **ឥណបរិភោគ** សូម្បីសេនាសនៈ គប្បីពិចារណាគ្រប់ៗ ពេលដែលប្រើប្រាស់ ការមានសតិសម្រួម ទាំងក្នុងពេលទទួលទាំងពេលបរិភោគភេសជ្ជៈរមែងគួរ សូម្បីដូច្នេះ ពេលភិក្ខុ

ពិចារណាក្នុងពេលទទួល ហើយមិនបានពិចារណាក្នុងពេលបរិភោគ ប៉ុណ្ណោះជាអាបត្តិ តែបើមិនបានពិចារណាក្នុងពេលទទួល ពិចារណាក្នុងពេលបរិភោគ មិនជាអាបត្តិ ...។

## សុទ្ធិមាន ៤ យ៉ាង

-**ទេសនាសុទ្ធិ** ( បរិសុទ្ធដោយការសម្តែង ) ។

-**សំវរសុទ្ធិ** ( បរិសុទ្ធដោយការសង្រួម ) ។

-**បរិយេដ្ឋិសុទ្ធិ** ( បរិសុទ្ធដោយការស្វែងរក ) ។

-**បច្ចវេក្ខណសុទ្ធិ** ( បរិសុទ្ធដោយការពិចារណា ) ។

ក្នុងសុទ្ធិ ៤ យ៉ាងនោះ **បាដិមោក្ខសំវរសីល** ឈ្មោះថា **ទេសនាសុទ្ធិ** ហេតុ ដែលបាដិមោក្ខសំវរសីលនោះ លោកហៅថា **ទេសនាសុទ្ធិ** ព្រោះបរិសុទ្ធដោយការសម្តែង ។

**ឥន្ទ្រិយសំវរសីល** ឈ្មោះថា **សំវរសុទ្ធិ** ហេតុដែលឥន្ទ្រិយសំវរសីលនោះ លោកហៅថា **សំវរសុទ្ធិ** ព្រោះបរិសុទ្ធដោយការសង្រួម គឺការតាំងចិត្តថា យើងនឹងមិនធ្វើយ៉ាងនេះទៀត ។

**អាជីវបារិសុទ្ធិសីល** ឈ្មោះថា **បរិយេដ្ឋិសុទ្ធិ** ហេតុដែលអាជីវបារិសុទ្ធសីលនោះ លោកហៅថា **បរិយេដ្ឋិសុទ្ធិ** ព្រោះបរិសុទ្ធដោយការស្វែងរករបស់ភិក្ខុអ្នកលះបង់អនេសនា ញុំាងបច្ច័យឲ្យកើតឡើង

ដោយធម៌ដ៏ប្រពៃ ។

បច្ចយបរិភោគសន្និស្សិតសីល ឈ្មោះថា **បច្ចវេក្ខណសុទ្ធិ** ហេតុដែលបច្ចយបរិភោគសន្និស្សិតសីលនោះ លោកហៅថា បច្ចវេក្ខណសុទ្ធិ ព្រោះបរិសុទ្ធ ដោយការពិចារណា ដូចដែលពោលមកហើយ ហេតុនោះ ខ្ញុំម្ចាស់ទើបពោលថា មិនបានពិចារណាក្នុងពេលទទួល តែពិចារណាក្នុងពេលបរិភោគមិនជាអាបត្តិ ដូច្នេះ ។

ការបរិភោគបច្ច័យរបស់ព្រះសេក្ខៈ ៧ ពួក ឈ្មោះថា **ទាយជ្ជបរិភោគ** ព្រោះថា ព្រះសេក្ខៈ ៧ ពួកនោះ ជាបុត្តរបស់ព្រះសាស្តា ហេតុនោះទើបលោកជាទាយាទនៃបច្ច័យទាំងឡាយ ដែលជាសម្បត្តិរបស់ព្រះបិតា, ការបរិភោគបច្ច័យទាំងឡាយនោះ សួរថា លោកទាំងឡាយនោះ បរិភោគបច្ច័យរបស់ព្រះមានព្រះភាគ ឬបរិភោគបច្ច័យរបស់គ្រហស្ថ ឆ្លើយថា បច្ច័យទាំងឡាយសូម្បីគ្រហស្ថថ្វាយ តែក៏រាប់ថា ជារបស់ព្រះមានព្រះភាគបាន ព្រោះជារបស់ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាត្ត ហេតុនោះ ព្រះសេក្ខៈទាំងឡាយ បណ្ឌិតគប្បីជ្រាបថា លោកបរិភោគបច្ច័យរបស់ព្រះមានព្រះភាគ ពិតហើយ ធម្មទាយាទសូត្រជាគ្រឿងសាធកៈក្នុងសេចក្តីនេះ, ការបរិភោគរបស់ព្រះខីណាស្រពទាំងឡាយ ឈ្មោះថា **សាមីបរិភោគ** ហេតុដែលព្រះខីណាស្រពទាំងឡាយឈ្មោះថា **សាមីបរិភោគ** ព្រោះកន្លងភាពជា

ទាសៈនៃតណ្ហាបានហើយ ។

ក្នុងបរិភោគទាំងឡាយនោះ **សាមីបរិភោគ** ១ **ទាយជ្ជបរិភោគ** ១ រមែងគួរដល់បព្វជិតគ្រប់ចំពូក ចំណែក **ឥណបរិភោគ** រមែងមិនគួរ ( ដល់បព្វជិតទាំងពួង ) ក្នុងថេយ្យបរិភោគមិនចាំបាច់ពោលដល់ឡើយ, ឯការបរិភោគបច្ច័យ ដែលខ្លួនពិចារណាហើយរបស់ភិក្ខុអ្នកមានសីល ការបរិភោគនោះ ឈ្មោះថា ការបរិភោគមិនមានបំណុល ព្រោះជាសត្រូវដល់ឥណបរិភោគក៏បាន ឬសង្គ្រោះចូលក្នុងទាយជ្ជ-បរិភោគក៏បានដូចគ្នា ព្រោះបុគ្គលដែលមានសីលក៏អាចហៅថា សេក្ខៈបានព្រោះប្រកបព្រមដោយសិក្ខា (គឺសីល) ឯក្នុងបរិភោគទាំងឡាយនេះ ព្រោះហេតុដែលសាមីបរិភោគក្រៃលែងជាងគេ ហេតុនោះបច្ចយសន្និស្សិតសីល កាលភិក្ខុប្រាថ្នាសាមីបរិភោគនោះ ពិចារណាដោយបច្ចវេក្ខណៈ ដូចដែលបានពោលហើយ ហើយបរិភោគ ( នោះឯង ) គប្បីធ្វើឲ្យដល់ព្រមបាន ។

ភិក្ខុដែលធ្វើយ៉ាងនេះ រមែងឈ្មោះថាជា **កិច្ចការី** ពិតហើយ ពាក្យនេះលោកពោលទុកថា

សាវ័កដែលមានបញ្ញាប្រពៃ បានស្តាប់ធម៌ដែលព្រះមានជោគទ្រង់សម្តែងហើយ គប្បីពិចារណាជាមុនហើយ ទើបសេពនូវដុំបាយទីនៅ ទីអង្គុយ ទីដេក ទឹកសម្រាប់បោកសម្អាតធូលីដែលជាប់សំពត់

សង្ឃាដី ព្រោះហេតុនោះឯង ភិក្ខុទើបជាអ្នកមិនជាប់នៅក្នុងវត្ថុទាំងឡាយនេះ គឺក្នុងដុំបាយ ក្នុងទីដេក ទីអង្គុយ និងក្នុងទឹកសម្រាប់ប៉ោកសម្អាតធូលីដែលជាប់សំពត់សង្ឃាដី ដូចជាដំណក់ទឹកជាប់នៅលើស្លឹកឈូកដូច្នោះ, អ្នកបានអាហារដោយការអនុគ្រោះចំពោះជនដទៃតាមកាលហើយ គប្បីតាំង ( សតិ ) ឲ្យមាំទាំជានិច្ច ដឹងប្រមាណក្នុងរបស់ទំពា ក្នុងរបស់ឆាន់ និងក្នុងរបស់គ្រេបជញ្ជក់ទាំងឡាយដូច ( បុគ្គលកើតដំបៅ ) ដឹងប្រមាណក្នុងការដាក់ថ្នាំរក្សាដំបៅ ដូច្នោះភិក្ខុគប្បីជាអ្នកមិនឱនឆាន់អាហារ ល្មមតែញ៉ាំងរូបកាយឲ្យប្រព្រឹត្តទៅបានប៉ុណ្ណោះ ដូច ( ស្វាមីភរិយា ) ស៊ីសាច់កូន ឯងក្នុងផ្លូវកន្ទារ (ដើម្បីឲ្យរួចពីស្លាប់ឆ្លងផ្លូវកន្តារទៅបានប៉ុណ្ណោះ) ដូចជា (អ្នកជំនួញតាមរទេះ ) បន្តក់ប្រេងភ្លៅរទេះ ដើម្បីឲ្យរទេះទៅដល់គោលដៅប៉ុណ្ណោះ ។

ក្នុងភាពជាអ្នកធ្វើ **បច្ចយសន្និស្សិតសីល** នេះឲ្យបរិបូណ៌ គួរពោលរឿងសង្ឃរក្ខិតសាមណេរ (ជាឧទាហរណ៍) ព្រោះសាមណេរនោះពិចារណាដោយល្អហើយ ទើបបរិភោគ ដូចលោកពោលប្រវត្តិខ្លួនឯងទុកថា ព្រះឧបជ្ឈាយ៍ពោលនឹងខ្ញុំម្ចាស់ ដែលកំពុងបរិភោគបាយស្រូវសាលីយ៉ាងត្រជាក់ថា នែ ! សាមណេរ អ្នកកុំជាអ្នកមិនសង្រួម កុំដុតអណ្ដាត (ខ្លួនឯង) ឡើយ ខ្ញុំម្ចាស់ស្ដាប់ពាក្យរបស់ព្រះ

ឧបជ្ឈាយ៍ហើយ បាននូវសេចក្ដីសង្វេគ ក្នុងកាលនោះ ខ្ញុំម្ចាស់អង្គុយនៅក្នុងអាសនៈនោះឯង ក៏បានសម្រេចព្រះអរហត្ត ខ្ញុំម្ចាស់នោះ មានការពិចារណា ពេញបរិបូណ៌ហើយ ដូចជាព្រះចន្ទក្នុងថ្ងៃ ១៥ កើត ដូច្នោះ ជាអ្នកអស់ហើយនូវអាសវៈទាំងឡាយ ឥឡូវនេះភពថ្មីមិនមានទៀតទេ ដូច្នេះ ហេតុនោះ សូម្បីកុលបុត្តដទៃ កាលបើប្រាថ្នានូវការអស់ទុក្ខ គប្បីពិចារណាដោយល្អហើយសឹម សេពនូវបច្ច័យទាំងឡាយចុះ ។

សីល ៤ យ៉ាងដែលចាត់ជាបារិសុទ្ធិសីល មានបាតិមោក្ខសំវរសីលជាដើម គប្បីជ្រាបដូចដែលបានពោលហើយមកដូច្នេះឯង ។

# មហាដីកា

## ពណ៌នាហេតុដែលធ្វើឱ្យសីលសម្រេចដល់ព្រម

លោកអាចារ្យបំណងនឹងសម្ដែងនូវសីល ដែលបានសម្ដែងអធិប្បាយទុក ដោយសេចក្ដីផ្សេងគ្នានៃសីល មានបាដិមោក្ខសំវរសីលជាដើម តាមប្រការដូចដែលពោលមកហើយ ដោយការចែកហេតុ ដែលនាំឲ្យសីលសម្រេច ទើបផ្ដើមពាក្យថា **ឯវមេតស្មឹ** ដូច្នេះជាដើម ។

ក្នុងបទទាំងឡាយនោះ ពាក្យថា **សាធន** ព្រោះអត្ថថា ជាហេតុសម្រេច គឺឲ្យដល់ព្រម, **បាដិមោក្ខសំវរសីល** ឈ្មោះថា **សទ្ធាសាធន** ព្រោះអត្ថថា មានសទ្ធាជាហេតុឲ្យសម្រេច ។ តែថា សូម្បីវៀរចាកវិរិយៈ សតិ និងបញ្ញាចេញ បាដិមោក្ខសំវរសីលក៏សម្រេចមិនបានមែនឬ ? លោកអាចារ្យកាលនឹងសម្ដែងថា ពិតហើយ សម្រេចមិនបាន,តែដែលពោលយ៉ាងនេះសំដៅយកភារៈនៃសទ្ធាជាហេតុពិសេសទើបពោលថា ព្រោះការដែលទ្រង់បញ្ញត្តសិក្ខាបទកន្លងវិស័យរបស់សាវក ដូច្នេះ ។

លោកអាចារ្យកាលសម្ដែងថា ឈ្មោះថា ការដែលទ្រង់បញ្ញត្តសិក្ខាបទ គឺសមគួរទៅតាមកំហុសនោះៗ ក្នុងវត្ថុដែលជាក់ចុះ (ដែល

កន្លងល្មើស ) ដែលមានប្រភេទជាទោសធ្ងន់ ទោសស្រាលជាដើម មិនមែនវិស័យរបស់សាវកទាំងឡាយ,ជាវិស័យរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយប៉ុណ្ណោះ ។ លើកការបញ្ញត្តិសិក្ខាបទទុកសិនចុះ ។ ឈ្មោះថា សូម្បីតែកាលនៃការបញ្ញត្តិសិក្ខាបទទាំងនោះក៏មិនមែន ជាវិស័យរបស់សាវកទាំងឡាយដែរ, ជាវិស័យរបស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ដូច្នេះទើបពោលថា ការត្រាស់ហាមចំពោះការទូលសុំឲ្យទ្រង់បញ្ញត្តសិក្ខាបទ ជានិទស្សនៈក្នុងរឿងនេះ ដូច្នេះ ។

ពិតហើយ ព្រះមានជោគត្រាស់ទុកថា **អាគមេហិ ត្វំ សារិបុត្ត អាគមេហិ ត្វំ សារិបុត្ត តថាគតោវ តត្ថ កាលំ ជានិស្សតិ** ម្នាលសារីបុត្ត អ្នកកុំឡើយ, ម្នាលសារីបុត្ត អ្នកកុំឡើយ តថាគតប៉ុណ្ណោះដែលដឹងកាលក្នុងការបញ្ញត្តិសិក្ខាបទនោះដូច្នេះ ។

ច-ស័ព្ទ ក្នុងបទថា **ចេត្ថ** នោះមានអត្ថថា រួមចូលទុក ។ ដោយ ច-ស័ព្ទនោះ គប្បីជ្រាបដល់ការរួមយកពាក្យពោលមានយ៉ាងនេះថា **អបញ្ញត្តំ ន បញ្ញាបេម បញ្ញត្តំ ន សមុច្ឆិន្ទាម យថាបញ្ញត្តេសុ សិក្ខាបទេសុ សមាទាយ វត្តាម** ពួកយើងនឹងមិនបញ្ញត្តសិក្ខាបទដែលទ្រង់មិនបានបញ្ញត្តទុក, ពួកយើងនឹងមិនដកសិក្ខាបទដែលទ្រង់បញ្ញត្តទុកហើយ, ពួកយើងនឹងសមាទានប្រព្រឹត្តក្នុងសិក្ខាបទទាំងឡាយតាមដែលទ្រង់បញ្ញត្តទុកដូច្នេះជាដើម ។

ពាក្យថា ដោយសទ្ធា គឺដោយការកាន់យកដោយសទ្ធា បានដល់ដោយការ ធ្វើឲ្យតាំងឡើងចំពោះដោយសទ្ធាក្នុងព្រះសាស្តា និងក្នុងព្រះធម៌, អធិប្បាយថា សូម្បីក្នុងជីវិត ( ក៏មិនធ្វើសេចក្តីអាល័យ ) ចាំបាច់ពោលថ្វីដល់បរិក្ខារនៃជីវិត ។

ពាក្យថា ដូចសត្វត្រដៀវរិចរក្សាពង មានន័យថា ដូចសត្វឈ្មោះត្រដៀវ រិចរក្សាពងរបស់ខ្លួន ។ បានឮមកថា សត្វត្រដៀវរិច រមែងលះបង់ជីវិតដើម្បីរក្សាពងប៉ុណ្ណោះ ។ ពាក្យថា ដូចចាមរីរក្សារោមកន្ទុយ បានដល់ ដូចសត្វ ឈ្មោះចាមរីរក្សានូវរោមកន្ទុយរបស់ខ្លួន ។ បានឮមកថា សត្វចាមរីដែលត្រូវព្រានព្រៃធ្វើឲ្យរអិលដួល រមែងលះបង់ជីវិតដើម្បីរក្សារោមកន្ទុយរបស់ខ្លួន ដែលជាប់នៅក្នុងបន្ទាជាដើមនោះឯង ។ គប្បីនាំ បីបទថា **បិយំវ បុត្តំ ឯកំ** មកសម្ពន្ធគ្នា ។ ជាពាក្យឧបមា ដែលលោកអាចារ្យពោលទុក ទាក់ទងនឹងការខ្វាយខ្វល់រក្សា ដូចជាកុដុម្ពីមានបុត្តតែមួយ រមែងរក្សាបុត្តតែមួយយ៉ាងល្អ, មួយ៉ាងទៀត បុគ្គលមានភ្នែកតែម្ខាង រមែងរក្សាភ្នែកតែម្ខាងនោះទុកយ៉ាងល្អ យ៉ាងណា ។ ភិក្ខុចាំរក្សាសីល ក៏យ៉ាងនោះដូចគ្នា ដូច្នេះ ។ បទថា **សុបេសលា** ប្រែថា មានសីលជាទីស្រឡាញ់ដោយល្អ ។ ក្នុងកាលគ្រប់ពេល គឺក្នុងកាលជាភិក្ខុកំលោះ ជាភិក្ខុវ័យកណ្តាល និងជាព្រះថេរៈគ្រប់កាលទាំងពួង ។ ភិក្ខុឈ្មោះថា មានការគោរព ក៏ព្រោះ

ទាក់ទងដោយគារវធម៌ទាំង ៦ មានន័យថា ជាអ្នកមានការធ្វើឲ្យប្រាកដច្បាស់ ។ ពាក្យថា ដូច្នោះដូចគ្នា មានន័យថា មហាសមុទ្រមានការតាំងនៅយឺនយូរជាធម្មតាមិនហៀរប្រាំងយ៉ាងណា សាវកទាំងឡាយរបស់តថាគត ក៏ដូច្នោះដូចគ្នា ។ ពាក្យថា សាវកទាំងឡាយរបស់តថាគត ត្រាស់សំដៅដល់ព្រះអរិយសាវកទាំងឡាយ ។ ព្រោះថា មានតែព្រះអរិយសាវកប៉ុណ្ណោះ ជាអ្នកមានសីលមាំទាំ ។ ពាក្យថា ក្នុងសេចក្ដីនេះ គឺក្នុងរឿងដែលមិនកន្លងសីល សូម្បីព្រោះហេតុនៃជីវិត ។ ឈ្មោះថា ព្រៃក្រាស់មហាវត្ត បានដល់ ព្រៃក្រាស់មួយកន្លែង ។ អាចារ្យខ្លះថា ព្រៃក្រាស់ដែលនៅជិតព្រៃហិមពាន្ត ។ ពាក្យថា ព្រះថេរៈ បានដល់ ព្រះថេរៈមួយអង្គមិនប្រាកដឈ្មោះនិងគោត្រ ។ ចោរចងព្រះថេរៈឲ្យសឹង, បញ្ជាថា ( យើង ) ទៅហើយកុំប្រាប់ដល់នរណាៗ ដូច្នេះ ។

បទថា **បូតិលតាយ** ប្រែថា ប្រើវល្លិផោម ។ ពាក្យថា **សមសីសី** បានដល់ ជីវិតសមសីសី ។ អរហត្តមគ្គរបស់ព្រះអរិយបុគ្គលណា ធ្វើអវិជ្ជាដែលជាក្បាលរបស់កិលេសឲ្យដាច់ទៅតាមលំដាប់មគ្គ, បន្ទាប់ពីនោះទៅ កាលមិនមានការ តាំងមាំក្នុងបច្ចវេក្ខណញាណទី ១៩ ហើយធ្លាក់ចុះកាន់ភវង្គ ចុតិចិត្ត ក៏ធ្វើជីវិតិន្ទ្រិយ៍ដែលជាសីសៈរបស់ខន្ធកំពុងរស់នៅឲ្យអស់ទៅ, ព្រះអរិយបុគ្គលនោះ លោកហៅ

ថា **ជីវិតសមសីសី** ព្រោះមានវារៈព្រមគ្នានោះឯង ។ ព្រះថេរៈនោះ បរិនិព្វានហើយដោយអាការនោះ ។ ព្រោះហេតុនោះ ទើបលោកពោល ថា ជាសមសីសីបរិនិព្វានទៅ ដូច្នេះ ។ អាចារ្យជាច្រើនលោកពោល ថា បានឮមកថា ព្រះអភ័យត្ថេរ លោកមានអភិញ្ញាច្រើន ។ ព្រោះ ដូច្នោះ ទើបលោកឲ្យសាងចេតិយទុកដូច្នេះ ។

ពាក្យថា **អប្បេវ** មានន័យថា ទោះយ៉ាងណា សូម្បីជីវិតរបស់ ខ្លួនក៏លះបង់បាន ។ បទថា **ន ភិន្ទេ** ប្រែថា មិនគប្បីទម្លាយ គឺមិន គប្បីឈានកន្លង ។

ពាក្យថា ( ឥន្ទ្រិយ៍ទាំងឡាយ ) ដែលសតិតាំងមាំហើយ គឺ ឥន្ទ្រិយ៍ទាំងឡាយដែលសតិចូលទៅតាំងទុកមាំហើយ តាំងមាំហើយ ដោយទាក់ទងនឹងការរក្សាទុក ។ ពាក្យថា ព្រោះធម៌ទាំងឡាយមាន អភិជ្ឈាជាដើមនឹងហូរទៅតាមមិនបាន មានន័យថា ព្រោះធម៌ទាំង ឡាយ មានអភិជ្ឈាជាដើម មិនគប្បីជាប់តាមដោយភាពជាទ្វារ ។ បទ ថា **វរំ** ប្រែថា ប្រសើរ ។ បទថា **តត្តាយ** ប្រែថា ដុត ។ បទថា **អាទិត្តាយ** បានដល់ ក្តៅមកតាំងពីដើម ។ បទថា **សម្បជ្ជលិតាយ** បានដល់ឆេះរន្ទាលដោយជុំវិញ ។ពាក្យថា កើតមានពន្លឺប្រាលរន្ទាល គឺកើតអណ្តាតភ្លើង ។ បទថា **សម្បលិមជ្ជំ** ( ត្រូវសង្កត់ចុះ ) គឺត្រូវ អត់ទ្រាំដោយអាការទាំងពួង មានន័យថា ត្រូវធ្វើឲ្យវិនាស ។ គប្បី

នាំពាក្យចូលមកភ្ជាប់គ្នាថា **ន តេវ វរំ** ។ ពាក្យថា ក្នុងរូបទាំងឡាយ គឺក្នុងរូបារម្មណ៍ទាំងឡាយ ។ ពាក្យថា ការកាន់យកនូវនិមិត្តដោយអនុព្យញ្ជនៈ គឺការកាន់យកនូវនិមិត្ត មានសុភនិមិត្តជាដើម ដោយអំណាចការធ្វើកិលេសទាំងឡាយ ឲ្យជាក់ច្បាស់រឿយៗ គឺដោយអំណាចការធ្វើឲ្យប្រាកដ ដោយការធ្វើឲ្យកើតឡើង ។ ម្យ៉ាងទៀត ពាក្យថា ដោយអនុព្យញ្ជនៈ បានដល់ ការកាន់យកនូវនិមិត្ត មានឥត្ថីនិមិត្ត បុរិសនិមិត្ត និងសុភនិមិត្តជាដើម ។

ពាក្យថា **ចក្ខុទ្វារបវិប្បវត្តស្ស** ប្រែថា ប្រព្រឹត្តទៅតាមចក្ខុទ្វារជាដើម ។

ពាក្យថា ពេលវិញ្ញាណ គឺពេលជវនវិញ្ញាណ ។ ភ្ជាប់សេចក្តីថា ភិក្ខុដែលហាមការកាន់យកនូវនិមិត្ត គប្បីញ៉ាំងឥន្ទ្រិយសំវរឲ្យដល់ព្រមបាន ។

បទថា **អសំវិហិតសាខាបរិវារំ** ប្រែថា ដែលមិនមានការព័ទ្ធរបងការពារដោយល្អ ។ ពាក្យថា ពួកចោរដែលមានការប្លន់អ្នកដទៃជាប្រក្រតី បានដល ពួកចោរដែលប្លន់វត្ថុរបស់អ្នកដទៃជាប្រក្រតី ។ ពាក្យថា រមែងហូរស្រោច គឺរមែងធ្លាយចូលទៅដោយប្រការទាំងពួង ។

ពាក្យថា ព្រោះរូប គឺព្រោះហេតុនៃរូប បានដល់ ព្រោះរូបជាហេតុ ។

ភ្ជាប់សេចក្តីថា គប្បីរក្សាឥន្ទ្រីយ៍ ឲ្យឆ្ងាយពីសេចក្តីវិនាស ដែលកើតឡើង ( ព្រោះរូប ) ។ ក្នុងអារម្មណ៍ដ៏សេស ក៏យ៉ាងនេះ ។

ពាក្យថា ព្រោះថាទ្វារទាំងឡាយនេះ បានដល់ ទ្វារទាំងឡាយមានចក្ខុទ្វារជាដើម ។ ជាការត្រាស់អធិប្បាយទុកដោយពាក្យពោលជាការណូបចារន័យ ( ពោលទាក់ទងដល់ហេតុ ) ថា ទ្វារឈ្មោះថាបើកទុក ព្រោះមិនបានបិទការពារទុកដោយ សន្ទះទ្វារ គឺសតិ ព្រោះហេតុនោះឯង ទើបឈ្មោះថា មិនរក្សាទុក ។ រមែងបៀតបៀនភិក្ខុដែលព្រមព្រៀងដោយទ្វារនោះ ដោយភាពជាហេតុឲ្យកើតឡើងនៃកិលេសដូច្នេះ ។ន័យម្យ៉ាងទៀត ជាការត្រាស់អធិប្បាយទុកដោយពាក្យនិយាយ ជាការណូបចារន័យនោះឯងថា ធម៌ទាំងឡាយមានរូបជាដើមទាំងឡាយនោះ ជាអារម្មណ៍របស់កិលេស, ជាទ្វារ បានដល់ជាទ្វាររបស់ចក្ខុជាដើម ។ ដូចដែលបើកទុកមិនរក្សាទុកទាំងឡាយនោះ នេះរមែងបៀតបៀនបុគ្គលដែលព្រមព្រៀង ដោយធម៌មានរូបជាដើមនិងទ្វារមានចក្ខុទ្វារជាដើមនោះព្រោះហេតុនៃចក្ខុជាដើមដែលមិនបានសង្រួម ។ បទថា **អគារំ** ប្រែថា ផ្ទះ ។ ពាក្យថា ដែលប្រក់មិនល្អ គឺមិនប្រក់ការពារដោយត្រឹមត្រូវ ។ ពាក្យថា ដែលមិនបានអប់រំ គឺដែលវៀរចាកលោកុត្តរភាវនា ។

ខ្លឹមសាររបស់ពាក្យថា ដែលជាចំណែកបរិសុទ្ធ ដែលថា ពេល

ធ្វើឲ្យដល់ព្រម បានហើយជាដើម គប្បីជ្រាបដោយបរិយាយផ្ទុយគ្នា ដូចដែលពោលហើយចុះ ។ ការមិនធ្វើកិលេសឲ្យកើតឡើងដោយប្រការទាំងពួងនេះ ចាត់ជាទេសនាដ៏ឧក្រិដ្ឋក្រៃលែង ព្រោះដូចជាការមកហើយដោយមគ្គ ។

ពាក្យថា នឹងគប្បីធ្វើ ( ឥន្ទ្រិយសំវរ ) ឲ្យដល់ព្រមបាន គឺនឹងគប្បីធ្វើឲ្យដល់ព្រមបានដោយសេចក្តីហ្មត់ចត់ ព្រោះការតាំងចិត្តទុកថា យើងនឹងមិនធ្វើយ៉ាងនេះទៀត ដូច្នេះ ។

ពីរបទថា **អធុនា បព្វជិតេន** ប្រែថា អ្នកបួសមិនទាន់បានយូរ មានន័យថា បួសបានថ្មីៗ ។ ពាក្យថា ខ្ញុំម្ចាស់ត្រូវកាមរាគៈដុតពោល គឺខ្ញុំម្ចាស់ត្រូវភ្លើង គឺកាមរាគៈដុតពោល ។ ព្រះវង្គីសត្ថេរ កាលនឹងសម្តែងថា សេចក្តីក្តៅក្រហាយនោះ កើតឡើងក្នុងចិត្ត នៅក្នុងវេលានេះ ដូច្នេះទើបពោលថា **ចិត្តរបស់ខ្ញុំម្ចាស់** អន្ទះអន្ទែង ដូច្នេះ ។ ពាក្យថា សាធុ ជាពាក្យស្នើសុំ ។ ពាក្យថា **ឧបាយ រំលត់** គឺឧបាយរំលត់នូវសេចក្តីអន្ទះអន្ទែងនោះ ។

ព្រះវង្គីសត្ថេរហៅព្រះអានន្ទត្ថេរដោយគោត្រថា បពិត្រលោកគោតមគោត្រ ។

ពាក្យថា ព្រោះការបន្តទៅខុសនៃសញ្ញា គឺព្រោះហេតុនៃការបន្តទៅខុសនៃសញ្ញាដែលកើតឡើងថា ស្អាតក្នុងវត្ថុដែលមិនស្អាត

គឺព្រោះសញ្ញាវិបរិត ជាហេតុ ។ សួរថា សូមលោកចូរវៀរនូវសុភ-និមិត្ត ដូចម្ដេច ? ឆ្លើយថា ចូរវៀរ គឺចូរកុំធ្វើទុកក្នុងចិត្តនូវសុភនិមិត្ត ដែលប្រកបដោយរាគៈ គឺដែលជាហេតុឲ្យកើតឡើងនៃរាគៈ ។ មិនមែនត្រឹមតែជាអ្នកមិនធ្វើទុកក្នុងចិត្តនូវសុភនិមិត្ត តែម្យ៉ាងប៉ុណ្ណោះទេ តែថា ចូរអប់រំចិត្តរបស់ខ្លួនដោយអសុភភាវនាផង ។

សួរថា អប់រំយ៉ាងណា ? ឆ្លើយថា ចូរអប់រំឲ្យមានអារម្មណ៍តែមួយតាំងមាំល្អ គឺចូរអប់រំនូវចិត្តនោះឲ្យមានអារម្មណ៍តែមួយ ព្រោះមិនមានសេចក្ដីរាយមាយ និងជាធម្មជាតិតាំងមាំល្អ ព្រោះមានការតាំងមាំ យ៉ាងល្អ ក្នុងអារម្មណ៍ដែលមិនស្អាត ដូច្នោះចុះ ។

ព្រះអានន្ទត្ថេរ កាលសម្ដែងនូវការគ្របសង្កត់នូវកាមរាគៈដោយសមថភាវនា យ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងសម្ដែងនូវវិធីកាត់ផ្ដាច់ ទើបពោលថា សង្ខារេ ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា ចូរពិចារណាឲ្យឃើញនូវសង្ខារទាំងឡាយ ដោយភាពជារបស់ដទៃ បានដល់ ចូរពិចារណាឲ្យឃើញនូវសង្ខារទាំងឡាយ សូម្បីទាំងអស់ថា ជារបស់ដទៃ ព្រោះអត្ថថាមិនស្ដាប់បង្គាប់ ។

ដោយភាពជាទុក្ខ ព្រោះត្រូវការកើតឡើង និងការរលត់ទៅបៀតបៀន ព្រោះហេតុជារបស់មិនទៀង និងចូរពិចារណាដោយភាព

មិនមែនជាខ្លួន ព្រោះមិនមែនជាតួខ្លួន ជាសភាវៈ និងព្រោះវៀរចាកតួខ្លួន ។

ពេលលោកលើកសង្ខារទាំងឡាយឡើងកាន់ត្រៃលក្ខណ៍ចម្រើនវិបស្សនា យ៉ាងនេះ ក៏ញ៉ាំងរាគៈឲ្យអស់ទៅ ដោយប្រការទាំងពួងដោយមគ្គទី ៤ តាមលំដាប់មគ្គ គឺនឹងចូលទៅស្ងប់រាគៈ ព្រោះមានអារម្មណ៍ច្រើនទៅដោយការ គ្របសង្កត់នូវធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ បាន ។ ព្រះអានន្ទត្ថេរបានជាស់តឿន ព្រះវង្គីសត្ថេរឲ្យប្រកបក្នុងការបន្ទោបង់កាមរាគៈឲ្យធ្ងន់ជាងនោះទៀតថា កុំជាអ្នកក្តៅក្រហាយរឿយៗ ឡើយ ដូចក្នុងបទនេះឯងជាដើម ។

លោកអាចារ្យកាលនឹងសម្តែងវិធីដែលធ្វើឥន្ទ្រិយសំវរសីលឲ្យដល់ព្រម យ៉ាងនេះហើយ បំណងសម្តែងសេចក្តីថា ឥន្ទ្រិយសំវរសីលនោះនឹងធ្វើឲ្យដល់ព្រមបានល្អ ក៏ដោយអាការយ៉ាងនេះ ដូច្នេះទើបសម្តែងដល់ព្រះថេរៈទាំងឡាយ ដែលជាអ្នកធ្វើឲ្យបរិបូរក្នុងឥន្ទ្រិយសំវរសីលនោះទុក ដោយពាក្យថា **អបិច** ដូច្នេះជាដើម ។

ក្នុងពាក្យទាំងឡាយនោះ ពាក្យថា មិនធ្លាប់ក្រឡេកមើលជញ្ជាំងល្ហាងភ្នំនេះលោកពោលទុក ព្រោះព្រះថេរៈជាអ្នកក្រឡេកមើលមួយជួរនឹមក្នុងទីទាំងពួង ។ សួរថា ព្រះថេរៈ មិនសម្លាតសេនាសនៈទេឬ? ព្រោះថា មានពាក្យត្រាស់ទុកថា **ឧល្លោកា បឋមំ ឱហារេ តព្វំ** ក្នុង

វិហារគប្បីក្រឡេកមើលលើបើមានសរសៃពីងពាង គប្បីសម្អាតចេញ ) ជាដើម ។ ឆ្លើយថា បានឮថា ពួកអន្តេវាសិក ជាដើមនោះឯង ជម្រះសេនាសនៈរបស់លោកឲ្យស្អាត ។ បទថា **អស្ស យោគនាគរុក្ខស្ស** ប្រែថា ដើមខ្ទឹងនោះ ។

ពាក្យថា ក្នុងលផ្ទៃកផ្ទះគឺក្នុងលផ្ទៃកផ្ទះធំ ៗស្ត្រីទាំងឡាយណាមានបុត្ត និងធីតា ជាក្មេងតូចនៅបៅដោះ ស្ត្រីទាំងឡាយនោះឈ្មោះថា **តរុណបុត្តោ** ស្ត្រីកូនខ្ចី បានដល់ ( ឲ្យរុំដោះ ) ស្ត្រីកូនខ្ចីទាំងឡាយនោះ ។

ពាក្យថា ឲ្យប្រថាប់ត្រា គឺឲ្យរុំដោះដោយសំពត់សម្រាប់រុំ ហើយប្រើរាជត្រាប្រថាប់ទុក ។ ព្រះរាជាកាលទ្រង់ធ្វើការពន្យាពេល ដើម្បីទ្រង់ឃើញព្រះថេរៈបានយូរ ទើបពោលថា ស្អែកនេះខ្ញុំម្ចាស់នឹងទទួលសីល ដូច្នេះ ។ ព្រះថេរៈ ក្នុងពេលព្រះរាជាថ្វាយបង្គំក្តី ព្រះទេវីថ្វាយបង្គំក្តី រមែងកាន់យកត្រឹមតែជាអាការនៃដៃ តែមិនបានធ្វើការបែងចែកឲ្យផ្សេងគ្នាថា បុរស ឬស្ត្រី ។

ព្រោះហេតុនោះទើបលោកពោលថា ខ្ញុំមិនបានធ្វើការកំណត់ដូច្នេះ ។ ទេវតាសរសើរថា ឱ ! ព្រះគុណម្ចាស់អង្គនេះ មានសីលបរិសុទ្ធល្អ ហ្ន៎ ! ដូច្នេះទើបកាន់ប្រទីបមានដងពីរថ្វាយ ។

ពាក្យថា ( កម្មដ្ឋានរបស់ព្រះថេរៈ ) ជាធម្មជាតិត្រចះត្រចង់

បរិសុទ្ធក្រៃលែង គឺកម្មដ្ឋានជាធម្មជាតិត្រចះត្រចង់ បរិសុទ្ធហួសពីការប្រៀបបាន ព្រោះបាននូវសប្បាយៈ ។ ពាក្យថា ញ៉ាំងភ្នំទូទៅឲ្យកម្រើកបានដល់ ធ្វើភ្នំទាំងអស់ ឲ្យលាន់ឮព្រមគ្នា ព្រោះការញ័រនៃផែនដី អាចារ្យខ្លះពោលថា ព្រោះពួកទេវតានៅទីនោះឲ្យសព្ទសាធុការដូច្នេះ ពាក្យថា ភ្ញាក់ គឺរអើលដោយខ្លាច ។ បទថា **ពាលោ** បានដល់ ក្មេងខ្ចី ។ ពាក្យថា ភ័យខ្លាច គឺភ័យខ្លាចព្រោះការប្រាសចាកពួកញាតិ ។

ពាក្យថា **រោគបួសមានពិស** លោកពោលដល់រោគដំណួចពិសនៅលើដោះ ។ អាចារ្យពួកខ្លះពោលថា សូម្បីរោគ មានរោគមាសៈ ( រោគដំណួចពិសដូចគ្រាប់ដោះ ) ជាដើម ក៏ឈ្មោះថា រោគបួសមានពិសដូច្នេះ ។ ឈ្មោះថា អាត្មាបួស ហើយតាំងពីពេលណា, ចាប់តាំងពីពេលនោះ មានន័យថា ចាប់តាំងពីពេល អាត្មាបួស ។ ពាក្យថា ទម្លាយឥន្ទ្រីយ៍ទាំងឡាយ គឺទម្លាយឥន្ទ្រិយសំវរសីល ។ ពិតហើយ ពេលឥន្ទ្រិយសំវរសីលទាំងឡាយនោះបែកធ្លាយហើយ សូម្បីឥន្ទ្រីយ៍ទាំងឡាយ ក៏ពោលបានថា បែកធ្លាយហើយ ព្រោះគ្មានការរក្សាទុក, ម្យ៉ាងទៀត ឥន្ទ្រីយ៍ទាំងឡាយជាទ្វារនៃការប្រកាន់នូវនិមិត្ត និងអនុព្យញ្ជនៈនោះឯង ឈ្មោះថា ជាការបែកធ្លាយ ព្រោះជាហេតុឲ្យកើតសេចក្ដីវិនាសដល់បុគ្គលអ្នក ព្រមព្រៀងដោយឥន្ទ្រីយ៍នោះ, គប្បីជ្រាបថា មិនបែកធ្លាយដោយបរិយាយផ្ទុយគ្នា ។ អាចារ្យមួយពួក

ទៀតពោលថា ម្យ៉ាងទៀត ការបង្អោនឥន្ទ្រីយ៍ទាំងឡាយ ចូលទៅ (កាន់អារម្មណ៍) ដោយមិនត្រូវឧបាយ ឈ្មោះថា ជាការធ្វើឲ្យបែកធ្លាយ, ការបង្អោនចូលទៅដោយត្រូវឧបាយ ឈ្មោះថា ជាការមិនធ្វើឲ្យបែកធ្លាយដូច្នេះ ។

បទថា **មិត្តត្ថេរោវ** ប្រែថា ដូចជាព្រះមហាមិត្តត្ថេរ ។ បទថា **វរេ** ប្រែថា ដ៏ប្រសើរ ។ បទថា **តថា វីរិយេន** (ដោយវីរិយៈដូច្នេះ) មានន័យថា លោកធ្វើវីរិយៈឲ្យបែកដោយ តថា-ស័ព្ទ ។ សតិ ដែលមានលក្ខណៈមិនមានទោសនោះឯង ជាហេតុឲ្យសម្រេចនូវឥន្ទ្រិយសំវរសីលយ៉ាងណា, វីរិយៈដែលមិនមានទោសក៏ជាហេតុឲ្យសម្រេចនូវអាជីវបារិសុទ្ធិសីលដូច្នោះ ដូចគ្នា ។ គប្បីឃើញការសម្ដែងដល់វីរិយៈនោះឯងថា ជាការដែលលោកធ្វើឲ្យប្លែកគ្នា ។ ព្រោះហេតុនោះឯង ទើបលោកពោលថា សេចក្ដីព្យាយាម ដែលភិក្ខុប្រារព្ធហើយដោយល្អ ដូច្នេះ ។ ការស្វែងរកដែលមិនប្រពៃ ឈ្មោះថា **អនេសនា** សង្គ្រោះយកមិច្ឆាជីវៈ តាមដែលពោលហើយ ។ **អនេសនា** នោះឯង ឈ្មោះថា **អប្បដិរូបា** ព្រោះអត្ថថា មិនសមគួរចំពោះពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា បានដល់ (លះ) ការស្វែងរកដែលមិនត្រឹមត្រូវ មិនសមគួរនោះឯង ។

ន័យម្យ៉ាងទៀត ការស្វែងរកដែលជាសត្រូវដល់ភាពសមគួរ

ឈ្មោះថា ការស្វែងរកមិនសមគួរ សម្រាប់ភិក្ខុដែលកាន់យកធុតង្គ បានដល់ ការស្វែងរកខុសពីការកំណត់របស់ធុតង្គ ជាការបដិបត្តិ របស់ភិក្ខុអង្គណាមួយដែលញ៉ាំងសល្លេខធម៌ (ធម៌ជាគ្រឿងជុសខាត់ កិលេស ) ឲ្យកម្រើក ។ ច-ស័ព្ទ ក្នុងចំណែកនេះ លោកសម្តែង អធិប្បាយថា ត្រូវលប់ចេញ មានន័យថា លះបង់ការស្វែងរកដែល មិនត្រឹមត្រូវ និងការស្វែងរកដែលមិនសមគួរ ។ ភ្ជាប់សេចក្តីថា **បដិសេវនានេន បរិវជ្ជយតា សម្បាទេតព្វា** ប្រែថា ( អាជីវបារិសុទ្ធិ នេះ) ភិក្ខុដែលសេពហើយ វៀរហើយ គប្បីឲ្យដល់ព្រមបាន ។ដោយ ពាក្យថា ( ដែលមានការកើតឡើងដ៏បរិសុទ្ធ ) នេះឯង ដែលលោក អាចារ្យសម្តែងភាវៈនៃគុណទាំងឡាយ មានធម្មទេសនាជាដើម មាន អធ្យាស្រ័យដ៏បរិសុទ្ធជាសមុដ្ឋាន ព្រោះហេតុនោះ ទើបលោកពោល ថា របស់ពួកគ្រហស្ថដែលជាអ្នកជ្រះថ្លាក្នុងគុណទាំងឡាយ មានធម្ម-ទេសនាជាដើមរបស់លោក ដូច្នេះ ។ ដោយ អាទិ-ស័ព ( ប្រែថា ជាដើម ) គប្បីជ្រាបដល់ការកាន់យកនូវគុណទាំងឡាយ មានភាព ជាអ្នកបានស្តាប់ច្រើន ការបរិបូរណ៍នៃវត្ត ការដល់ព្រមនៃឥរិយាបថ ជាដើម ។សូម្បីក្នុងពាក្យនេះថា អ្នកជ្រះថ្លាក្នុងធុតង្គគុណរបស់លោក ក៏ក្នុងន័យនេះឯង ។

ដោយ អាទិ-ស័ព្ទ ( ដែលប្រែថា ជាដើម ) ថា **បិណ្ឌបាតចរិ-**

**យាទីហិ** ប្រែថា ដោយវត្តមានការនិមន្តទៅបិណ្ឌបាតជាដើម គប្បីឃើញថា សង្គ្រោះយកការប្រព្រឹត្តិមានការសេពគប់មិត្តល្អ សំឡាញ់ល្អ និងការទ្រទ្រង់សំពត់បង្សុកូលជាដើម ។

ពាក្យថា ដោយអនុលោមតាមការកំណត់របស់ធុតង្គ គឺដោយទាក់ទងជាមួយនឹង១.បដិបត្តិដែលកំណត់ទុកក្នុងធុតង្គនោះឯងៗ មានន័យថា ទាក់ទងនឹងការមិនធ្វើឲ្យកម្រើក ។ បុគ្គលប្រាថ្នាច្រើនប៉ុណ្ណោះដែលមានការចិញ្ចឹមជីវិត ដោយមិច្ឆាជីវៈ បុគ្គលប្រាថ្នាតិចមិនដូច្នោះ ។ លោកអាចារ្យពោលថា ដើម្បីជាប្រយោជន៍ដល់ការរម្ងាប់ការឈឺចាប់នោះម្យ៉ាង ដូច្នេះជាដើម ដើម្បីសម្តែងថា មិច្ឆាជីវៈមិនអាចកើតឡើងបានឡើយ កាលបើសេចក្តីប្រាថ្នាតិចនោះ ដល់កម្រិត ។

ក្នុងបទទាំងឡាយនោះ បទថា **បូតិហរីដកី** បានដល់ សម៉ដែលត្រាំដោយទឹកមូត្រស្អុយ ឬដែលគេបោះចោលហើយ ដោយភាពជារបស់ស្អុយ ។ ភិក្ខុឈ្មោះថា **អរិយវំសិក** ព្រោះអត្ថថា មានអរិយវង្សឬប្រកបក្នុងអរិយវង្ស ភិក្ខុឈ្មោះថា ជាអ្នកខ្ពង់ខ្ពស់ ព្រោះលះបង់នូវសេចក្តីប្រាថ្នាក្នុងបច្ច័យ ឲ្យនៅក្នុងទីឆ្ងាយបានហើយផង ភិក្ខុនោះឯងជា **អរិយវំសិក** ផង ព្រោះហេតុនោះ ទើបឈ្មោះថា **ឧត្តមអរិយ-វំសិក** ។

ពាក្យថា ( រមែងមិនគួរ ) ដល់ភិក្ខុរូបណាមួយ គឺដល់ភិក្ខុអង្គ

ណាមួយ ក្នុងបណ្ដាភិក្ខុដែលកាន់ធុតង្គ និងមិនបានកាន់ធុតង្គ ។

ការសំដៅចំពោះបច្ច័យទាំងឡាយ ហើយធ្វើនិមិត្តដែលធ្វើឲ្យអ្នកដទៃអាចដឹងនូវបំណងបាន ឈ្មោះថា និមិត្ត ។ ការមិនពោលត្រង់ៗ តែម្ដង ពោលបញ្ចិតបញ្ចៀងចំពោះបំណង ( របស់ខ្លួន ) ក៏ប្រាកដច្បាស់ដល់ ( អ្នកដទៃ ) បាន ឈ្មោះថា ឱភាស ។ ការពោលដោយមានបរិយាយ ( ពោលអែបៗ ) ឈ្មោះថា **បរិកថា** ។ ពាក្យថា ( ភេសជ្ជៈ ) **ដែលកើតឡើងដោយអាការនោះ** គឺកើតឡើង ហើយដោយទាក់ទងអាការ មាននិមិត្តជាដើម ។

បទថា ប្រទានឱកាសទុកឲ្យហើយ គឺប្រទានឱកាស ចំពោះការបរិភោគទុកឲ្យហើយ ព្រោះរោគជាសំខាន់ ។ ព្រោះដូចនោះ ទើបគួរបរិភោគបាន សូម្បីក្នុងពេលដែលមិនមានរោគ គឺថា មិនជាអាបត្តិ ។

ព្រោះហេតុនោះទើបអាចារ្យអ្នកទ្រទ្រង់ព្រះសូត្រពោលថា មិនជាអាបត្តិក៏ពិត ដូច្នេះជាដើម ។ ពាក្យថា ទើបមិនគួរ គឺមិនគួរដល់ភិក្ខុអ្នកតាំងនៅក្នុង **សល្លេខបដិបត្តិ** អធិប្បាយថា នឹងធ្វើសល្លេខធម៌ឲ្យកម្រើកទៅ ។ ដោយពាក្យថា តែនឹងធ្វើអាជីវៈឲ្យកម្រើកបាននោះឯង អាចារ្យទ្រទ្រង់ព្រះសូត្រទាំងឡាយ ពោល ( អធិប្បាយ ) ថា អាការទាំងឡាយ មាននិមិត្តជាដើម មិនគួរដល់ភិក្ខុដែលទ្រទ្រង់ធុតង្គក្នុង ខ.ដែលទាក់ទងនឹងសេនាសនៈ ( មិនមែនចំពោះតែរឿងភេសជ្ជៈ

ប៉ុណ្ណោះទេ ) ។ អាចារ្យមួយពួកទៀតពោលថា រមែងមិនគួរទាល់តែសោះ សូម្បីចំពោះភិក្ខុដែលទ្រង់ទ្រង់ធុតង្គដទៃៗ ក្រៅពី១.ដែលទាក់ទងនឹងសេនាសនៈនោះ ។

ពាក្យថា កាលមិនធ្វើ គឺកាលមិនធ្វើអាការទាំងឡាយ មាននិមិត្តជាដើម សូម្បីជាវិស័យដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកចំពោះខ្លួន តែមួយអង្គក៏ដោយ ។

បទថា **អញ្ញត្រ** ប្រែថា វៀរប៉ុណ្ណោះ ។

លោកអាចារ្យពោលដល់ព្រះមហាថេរៈ ដែលលះបង់ការនៅដោយគណៈ ហើយនៅដោយអរហត្តផលសមាបត្តិដែលជាកំពូលនៃបដិបស្សទ្ធិវិវេកនៅក្នុងព្រៃថា កាលនឹងចម្រើនវិវេក ដូច្នេះ ។ អាពាធព្រោះខ្យល់ដែលអាស្រ័យផ្ទៃ ឈ្មោះថា អាពាធព្រោះខ្យល់ក្នុងផ្ទៃ ។

**បាយ** ឈ្មោះថា មានទឹកដោះសុទ្ធ ព្រោះអត្ថថា មានទឹកដោះដែលមិនមាន វត្ថុដទៃលាយបាយនោះឯងជាបាយាស ព្រោះហេតុនោះ ទើបលោកពោលថា បាយាសលាយទឹកដោះសុទ្ធ មានន័យថា បាយាស ដែលដាំដោយទឹកដោះមិនលាយជាមួយទឹក ។ បទថា **តស្ស យោគ បាយាសស្ស** ប្រែថា នៃបាយាសនោះ ។

ពាក្យថា មូលនៃការកើតឡើង បានដល់ ហេតុនៃការកើតឡើង

ពោល គឺការបន្លឺនូវវាចារបស់ខ្លួនថា ក្នុងកាលដែលនៅជាគ្រហស្ថ មាតារបស់ខ្ញុំបានឲ្យបាយាសទឹកដោះសុទ្ធ ផ្សំជាមួយទឹកដោះថ្លា ទឹកឃ្មុំ និងស្ករអំពៅ ខ្ញុំមានសេចក្ដីសុខបាន ដោយហេតុនោះ ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះសារីបុត្តពោលថា ជាបិណ្ឌបាតដែលមិនគួរបរិភោគដូច្នេះព្រះថេរៈមិនគិតនឹងធ្វើឱភាស(ការសម្ដែងអាការឲ្យដឹង ) ឲ្យកើតឡើងឡើយ ពិតមែនឬ ? ឆ្លើយថា មិនមានក៏ពិត តែថា ព្រះថេរៈគិតថា បុថុជ្ជនពួកខ្លះដែលមិនដឹងអធ្យាស្រ័យនឹងសម្គាល់យ៉ាងនោះបាន ( គឺគប្បីសម្គាល់ថា យើងធ្វើឱភាសជាដើម ) និងក្នុងអនាគត ភិក្ខុដែលប្រព្រឹត្តព្រហ្មចារ្យរួមគ្នាទាំងឡាយនឹងដល់នូវទិដ្ឋានុគតិ ( យកគំរូ ) តាមយើងយ៉ាងនេះបាន ដូច្នេះ ទើបហាមបាយបាយាសនោះចេញ ។ ម្យ៉ាងទៀត ជាសល្លេខបដិបត្តិដ៏ខ្ពង់ខ្ពស់ក្រៃលែងរបស់ព្រះមហាថេរៈ ។ ពិតហើយ អាស្រ័យពាក្យពោលរបស់ភិក្ខុកំលោះថា របស់បរិភោគសំបូរណ៍ នរណាទៅមិនពេញចិត្ត ដូច្នេះ, លោកក៏មិនព្រមបរិភោគរបស់ដែលគេថ្វាយតាមក្រោយទៀត រហូតដល់បរិនិព្វាន ។

ពាក្យថា ព្រោះការផ្សាយទៅនៃវចីវិញ្ញត្តិ មានន័យថា ព្រោះហេតុ គឺពាក្យបន្លឺឡើង ។ ពិតហើយ សំឡេងដែលកំពុងកើតឡើងដែលទាក់ទងនឹងការធ្វើឲ្យគេដឹងនូវសេចក្ដីប្រាថ្នា សូម្បីនៅមិនទាន់

មានការដឹងនូវសេចក្តីប្រាថ្នា ក៏ប្រព្រឹត្តទៅដោយអំណាចនៃវចីវិញ្ញត្តិនោះឯង ក្នុងពេលវចីវិញ្ញត្តិជាបច្ច័យ ដោយបច្ច័យប្រភេទខ្លះ ចំពោះសំឡេងនោះ ព្រោះហេតុនោះ ទើបលោកហៅថា ការផ្សាយទៅនៃវចីវិញ្ញត្តិ ។ បទថា **ភុត្តោ** មានន័យថា ប្រសិនបើយើងជាអ្នកបរិភោគ ។ បទថា **ស** មានន័យស្មើនឹង **អស្ស,** ព្រោះថា ជាពាក្យសម្តែង អធិប្បាយដោយលប់អក្សរ **អ** ដូចក្នុងប្រយោគថា **ឯវំស តេ** ជាដើម ។ បទថា **អន្តគុណំ** បានដល់ ពោះវៀន ។ ពាក្យថា គប្បីចេញទៅខាងក្រៅ គឺបើចេញមកពីទីអាស្រ័យ ហើយទៅខាងក្រៅ ដោយទាក់ទងទៅនឹងទីកន្លែងរកស៊ី ។ លោកពោលទុកទៅតាមវោហាររបស់អ្នកស្រុកនោះឯង ដើម្បីសម្តែងនូវការប្រាថ្នាតិចយ៉ាងក្រៃលែង ។ពិតហើយ ក្នុងផ្លូវលោកជនទាំងឡាយ កាលទឹងតិះដៀលភោជនដែលមិនសមគួរបរិភោគចូលក្នុងពោះ រមែងពោលយ៉ាងនេះថា ពោះវៀនរបស់គេ គប្បីចេញទៅខាងក្រៅ ដូច្នេះ ។ ពាក្យថា យើងនឹងបង្អាប់ គឺយើងនឹងបង្អាប់តាំងពីដើម មានន័យថា យើងនឹងធ្វើឲ្យប្រព្រឹត្តទៅក្នុងអំណាច ។

មានរឿងពោលមកថា ព្រះមហាតិស្សត្ថេរ កាលធ្វើដំណើរទៅតាមផ្លូវ ក៏កើតទុរ្ភិក្សភ័យ មានកាយលំបាក អស់កម្លាំង ព្រោះដាច់អាហារ និងព្រោះការនឿយ ហត់ក្នុងការដើរផ្លូវ ទើបសម្រាកនៅក្បែរ

គល់ស្វាយ ដែលមានផ្លែមួយដើម, និងមានផ្លែជាច្រើនធ្លាក់នៅក្រោមដើមស្វាយនោះ នៅទីនោះ មានឧបាសកវ័យចំណាស់ម្នាក់ ទៅដល់កន្លែងសម្រាករបស់ព្រះថេរៈ ជ្រាបដល់ការលំបាក ទើបធ្វើទឹកអម្ពបានៈ (ទឹកផ្លែស្វាយ) ឲ្យឆាន់ លើកលោកដាក់លើខ្នងរបស់ខ្លួន ហើយនាំទៅកាន់ទីសម្រាក ។ព្រះថេរៈទូន្មានខ្លួនឯងថា ឧបាសកនេះមិនមែនបិតា ទាំងមិនមែនជាមាតារបស់យើង មិនមែនញាតិទាំងមិនមែនជាផៅពង្ស តែធ្វើកិច្ចបែបនេះបាន គឺព្រោះហេតុដែលយើងជាអ្នកមានសីល ។

ដូច្នេះហើយ ក៏ផ្ដើមពិចារណា ចម្រើនវិបស្សនានៅលើខ្នងរបស់ឧបាសកនោះឯង ក៏បានធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តតាមលំដាប់មគ្គ ។ លោកអាចារ្យសំដៅយក **តិស្សត្ថេរអង្គនេះ** ទើបពោលថា ម្យ៉ាងទៀត ក្នុងសេចក្ដីនេះ បណ្ឌិតគួរពោលនូវរឿងព្រះតិស្សត្ថេរអ្នកឆាន់ទឹកផ្លែស្វាយផងដែរ ដូច្នេះ ។

ពាក្យថា **សូម្បីដោយប្រការទាំងពួង** គឺសូម្បីដោយអំណាចការកើតឡើង នូវការគិតដែលទាក់ទងដោយការស្វែងរកដែលមិនសមគួរក៏មិនធ្វើឲ្យកើតឡើង ដោយប្រការទាំងពួង, អធិប្បាយថា នឹងចាំបាច់ពោលថ្វីចំពោះការស្វែងរក ដោយអំណាចកាយ និងវាចា ដែលកម្រើកព្រោះហេតុនោះ ទើបលោកពោលថា **អនេសនាយ** ដូច្នេះជាដើម ។

ការឃើញទោសគឺអាបត្តិ ព្រោះការបរិភោគដោយជាប់បំណុល ក្នុងការបរិភោគបច្ច័យដែលមិនបានពិចារណា ហើយអានិសង្ស ក្នុងការបរិភោគបច្ច័យ ដែលបានពិចារណា ដោយបរិយាយផ្ទុយគ្នាជាមួយនឹងការបរិភោគបច្ច័យដែលមិនបានពិចារណានោះឈ្មោះថាការឃើញទោស និងអានិសង្ស ។ ព្រោះការឃើញទោស និងអានិសង្សនោះ មានបច្ច័យជាអធិការ ( អ្នកចាត់ចែង ) ទើបលោកពោលថា **ព្រោះបច្ច័យទាំងឡាយ** ដូច្នេះ ។ ពិតហើយ ធម្មជាតិទាំងដែលជាហេតុនិងមិនមែនជាហេតុបុគ្គលរមែងពោលដល់ដោយភាពជាហេតុបាន ដូចដែលពោលថាភត្តសម្រេចហើយព្រោះស្មៅទាំងឡាយដូច្នេះជាដើម ។ ដើម្បីសម្តែងថា ឈ្មោះថា ការបរិភោគបច្ច័យដែលមិនបានពិចារណា គប្បីមានដល់ភិក្ខុបានដោយប្រការ គឺហេតុណា កាលវៀរប្រការ គឺហេតុនោះចេញ បច្ចយសន្និស្សិតសីលរមែងសម្រេច និងបរិសុទ្ធបាន ដូច្នេះ ទើបលោកអាចារ្យពោលថា ព្រោះដូច្នោះ ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា ការប្រាថ្នាក្នុងបច្ច័យ មានន័យថាដោយសព្ទថា ការប្រាថ្នានោះឯង គប្បីឃើញថា ជាការកាន់យក **សម្មោហៈ** ( ការវង្វេង ) ផង ព្រោះប្រព្រឹត្តទៅជាមួយការប្រាថ្នានោះ និងព្រោះជាឧបនិស្សយប្បច្ច័យដល់សេចក្តីប្រាថ្នានោះ ។

ពាក្យថា ដែលកើតឡើងត្រឹមត្រូវតាមធម៌ នេះជាពាក្យសម្តែងនូវសេចក្តីបរិសុទ្ធិនៃផ្លូវមករបស់បច្ច័យទាំងឡាយ, មិនមែនជាពាក្យសម្តែងនូវសេចក្តីបរិសុទ្ធិនៃបច្ចយសន្និស្សិតសីលទេ ។ ព្រោះថាការពិចារណាដល់បច្ច័យទាំងឡាយ មានវត្ថុនេះជាប្រយោជន៍ ហើយទើបបរិភោគ ទើបជាបច្ចយសន្និស្សិតសីល ។

តែព្រោះហេតុនៃបច្ច័យទាំងឡាយនោះ ដែលបានមកដោយត្រឹមត្រូវប៉ុណ្ណោះ ដែលភិក្ខុគប្បីបរិភោគបាន ព្រោះដូច្នោះ ទើបលោកពោលថា បច្ច័យដែលកើតឡើងត្រឹមត្រូវតាមធម៌ ដូច្នេះ ។ ពាក្យថា ដោយវិធីតាមដែលពោលហើយ គឺដោយវិធីដែលបានពោលហើយថា ដើម្បីការពារនូវភាពរងា ដូច្នេះជាដើម ។

ពាក្យថា ទាក់ទងជាធាតុក្តី បានដល់ ទាក់ទងជាមួយធាតុមនសិការថា ជាធាតុយ៉ាងនេះថា បច្ច័យមានចីវរជាដើម និងបុគ្គលអ្នកប្រើប្រាស់បច្ច័យមានចីវរជាដើមណា នោះត្រឹមតែជាធាតុ ប្រព្រឹត្តទៅតាមបច្ច័យប៉ុណ្ណោះ ដូច្នេះក្តី ។

ពាក្យថា ទាក់ទងថាជារបស់បដិកូលក្តីបានដល់ទាក់ទងជាមួយនឹងការសម្គាល់ថា ជាបដិកូលក្នុងបិណ្ឌបាត គឺក្នុងអាហារប៉ុណ្ណោះ, ន័យម្យ៉ាងទៀត ទាក់ទងនឹងមនសិការថា ជាបដិកូលយ៉ាងនេះ បច្ច័យមានចីវរជាដើមទាំងអស់នេះ ដែលមិនទាន់គួរខ្ពើម តែកាលបើពាល់

ត្រូវកាយនេះហើយក៏ជារបស់គួរខ្ពើមរកប្រៀបមិនបានដូច្នេះ ។ ពាក្យថា ក្នុងពេលបន្ទាប់ពីពេលដែលរកបាននោះ គឺក្នុងកាលតទៅបន្ទាប់ពីកាលដែលបានមក ។

ឈ្មោះថា ការបរិភោគដែលមិនមានទោស ព្រោះភិក្ខុធ្វើឲ្យបរិសុទ្ធហើយ ដោយបញ្ញាមកតាំងពីដើម ដូចជាការប្រើប្រាស់បាត្រនិងចីវរដែលបានអធិដ្ឋាន ហើយរក្សាទុកដូច្នោះ ។ សេចក្ដីដែលមានមកនេះជាសេចក្ដីមួយដែលសម្ដែងនូវការបរិសុទ្ធិក្នុងខាងដើម ព្រោះការពិចារណា, មិនមែនជាការដែលបដិសេធការពិចារណាក្នុងវេលាដែលបរិភោគ ព្រោះហេតុនោះ ទើបលោកពោលថា សូម្បីក្នុងពេលដែលបរិភោគជាដើម ។ ( គឺក្នុងវេលាដែលបរិភោគ សូម្បីភ្លេចពិចារណាក៏មិនជាទោស បើបានពិចារណាថា ជាធាតុជាដើម តាំងពីពេលដែលបានទទួលមក ) ។ បទថា **តត្រ** ប្រែថា ក្នុងការពិចារណាក្នុងពេលដែលបរិភោគនោះ ។ ពាក្យថា ដែលធ្វើការព្រមព្រៀងគ្នា គឺមិនធ្វើការសង្ស័យ បានដល់ មានភាពតែមួយ ។

ការបរិភោគរបស់បុគ្គលដែលមិនសមគួរបរិភោគ ឈ្មោះថា **ថេយ្យបរិភោគ** ( បរិភោគដូចជាចោរ ), អធិប្បាយថា ព្រះមានជោគទ្រង់អនុញ្ញាតបច្ច័យទាំងឡាយទុកសម្រាប់ភិក្ខុអ្នកមានសីល ក្នុងសាសនារបស់ព្រះអង្គ, មិនមែនសម្រាប់ភិក្ខុទ្រុស្តសីល ។ ទាំងពួក

ទាយក មានការបរិច្ចាគយ៉ាងនេះក៏សម្រាប់ភិក្ខុអ្នកមានសីលមិនមែនសម្រាប់ភិក្ខុអ្នកទ្រុស្តសីល ។ព្រោះគេសង្ឃឹមការតបមកវិញដល់ភាវៈដែលការធ្វើរបស់ខ្លួនមានផលច្រើន ។ ព្រោះព្រះមានជោគទ្រង់មិនអនុញ្ញាតនិងព្រោះពួកទាយកមិនបានបរិច្ចាគឲ្យដូចបានពោលហើយនេះ ការបរិភោគរបស់ភិក្ខុអ្នកទ្រុស្តសីល ទើបជាការបរិភោគដូចជាចោរ ឈ្មោះថា **ថេយ្យបរិភោគ** ។

ការបរិភោគដោយទាក់ទងដូចជាអ្នកជាប់បំណុល មានន័យថា ដូចជាអ្នកទទួលបំណុល ហើយបរិភោគ ព្រោះមិនមានទក្ខិណាវិសុទ្ធិពីបដិគ្គាហកៈ ឈ្មោះថា **ឥណបរិភោគ** ។

ពាក្យថា ព្រោះហេតុនោះ លោកសំដៅយកខ្លឹមសារដែលបានពោលហើយ ដោយពាក្យថា **សីលវតោ** ជាដើមនោះឯង ដោយភាពជាហេតុ ។ ភ្ជាប់សេចក្ដីថា ភិក្ខុដោះចីវរចេញពីកាយហើយ គប្បីពិចារណាក្នុងពេលដែលប្រើប្រាស់គ្រប់ពេល ក្នុងពេលមុនភត្ត ។ល។ ក្នុងយាមក្រោយភត្តដូច្នេះ ។ ពេលមិនអាចជាយ៉ាងនោះ គឺដែលទាក់ទងជាមួយនឹងពេលផ្សេងគ្នាតាមដែលពោលហើយ ក៏គប្បីពិចារណាក្នុង ១ ថ្ងៃ ៤ ដងខ្លះ ៣ ដងខ្លះ ២ ដងខ្លះ ១ ដងខ្លះ ។ ប្រសិនបើថា ( កាលបើមិនបានពិចារណារហូតដល់ ) អរុណរះឡើង រមែងតាំងនៅក្នុងឋានៈនៃ **ឥណបរិភោគ** ។

អាចារ្យជាច្រើនពោលថា ប្រសិនបើធ្វើការពិចារណាទៅក្នុងអតីត ដោយន័យថា ចីវរដែលយើងប្រើប្រាស់ហើយពីម្សិលមិញនេះណា,ចីវរនោះយើងបានប្រើប្រាស់ត្រឹមតែដើម្បីការពារភាពរងា ។ល។ ដើម្បីបិទបាំងអវយវៈដែលញ៉ាំងការអៀនខ្មាសឲ្យកម្រើកប៉ុណ្ណោះ ។ បិណ្ឌបាត ដែលយើងបានបរិភោគហើយពីម្សិលមិញណា, មិនមែនដើម្បីលេងដូច្នេះជាដើម ។ ពាក្យដែលអាចារ្យជាច្រើនពោលមកនោះ បណ្ឌិតគប្បីពិចារណាចុះ ។

ពាក្យថា សូម្បីសេនាសនៈ ក៏គប្បីពិចារណាក្នុងពេលដែលប្រើប្រាស់គ្រប់ពេល គឺគប្បីពិចារណាក្នុងពេលដែលចូលទៅគ្រប់ៗពេល ។

បទថា **សតិប្បច្ចយតា** ប្រែថា មានសតិជាបច្ច័យគួរដល់ការទទួល និងការមានសតិគួរដល់ការពិចារណា ជាបច្ច័យគួរដល់ការបរិភោគ មានន័យថា គប្បីពិចារណាឲ្យហើយ ទើបទទួល និងបរិ-ភោគ ។ ព្រោះហេតុនោះ ទើបលោកពោលថា ( ពេលភិក្ខុ ) ធ្វើសតិដូច្នេះជាដើម ។ ពាក្យថា សូម្បីដូច្នេះ មានន័យថា ប្រសិនបើការពិចារណាក្នុងកាលទាំងពីរ ( គឺក្នុងពេលទទួល និងពេលបរិភោគ ) គឺជាការត្រឹមត្រូវ, សូម្បីពោលដូច្នោះ ។ អាចារ្យមួយពួកទៀតបានពោលថា **សតិប្បច្ចយតា** គឺពេលដែលការបរិភោគភេសជ្ជៈមានហើយ

មានន័យថា ពេលបច្ច័យមានហើយ ។ បទថា **ឯវំ សន្តេបិ** គឺពេលបច្ច័យមានហើយ ដូច្នេះ ។ ពាក្យនោះ ត្រឹមតែជាមតិរបស់អាចារ្យទាំងនោះ ។

ពិតហើយ **បច្ចយសន្និស្សិតសីល** រមែងបរិសុទ្ធបានព្រោះការពិចារណា មិនមែនបរិសុទ្ធបានព្រោះបច្ច័យនោះទេ ។

លោកអាចារ្យ កាលសម្តែងសេចក្តីបរិសុទ្ធិនៃបច្ចយសន្និស្សិតសីលយ៉ាងនេះហើយ កាលសម្តែងសេចក្តីបរិសុទ្ធិ សូម្បីទាំងអស់ដោយបំណងនោះឯង ទើបពោលថា ក៏សុទ្ធិ (សេចក្តីបរិសុទ្ធិ) មាន ៤ យ៉ាង ដូច្នេះជាដើម ។

ក្នុងពាក្យទាំងឡាយនោះ ធម្មជាតិឈ្មោះថា សុទ្ធិ ព្រោះអត្ថថា ជាសេចក្តីបរិសុទ្ធិ, សុទ្ធិ គឺការសម្តែងភាពសមគួរចំពោះធម៌ ឈ្មោះថា **ទេសនាសុទ្ធិ** ។

ក្នុងអធិការនេះ គប្បីឃើញថា សូម្បីការចេញពីអាបត្តិ ដោយការនៅបរិវាសកម្ម ក៏មានការសង្គ្រោះចូលក្នុងទេសនានោះដែរ ។ ឯសម្រាប់ភិក្ខុទាំងឡាយ ដែលមានមូលអាបត្តិ (បារាជិក ៤) ត្រូវហើយ ការប្រកាសថា ខ្លួនមិនមានភាពជាភិក្ខុនោះឯងជាទេសនា ។

សុទ្ធិ គឺសំវរៈដែលពិសេស គឺការតាំងចិត្ត (ថានឹងមិនធ្វើយ៉ាងនេះទៀត) ឈ្មោះថា **សំវរសុទ្ធិ** ។

សុទ្ធិ គឺការស្វែងរកបច្ច័យទាំងឡាយត្រឹមត្រូវទៅតាមធម៌នោះ ឈ្មោះថា **បរិយេដ្ឋិសុទ្ធិ** ។

សុទ្ធិ គឺការពិចារណាតាមវិធីដែលពោលហើយនោះឯង ក្នុងបច្ច័យទាំង ៤ ឈ្មោះថា **បច្ចវេក្ខណសុទ្ធិ** ។

**វចនត្ថ** នេះ ជាន័យនៃពាក្យសមាសក្នុងសុទ្ធិទាំងឡាយ ។ ចំណែកវចនត្ថៈក្នុងសីល មានសុទ្ធិទាំងឡាយ ដូចជាបាតិមោក្ខសំវរសីល ឈ្មោះថា **ទេសនាសុទ្ធិ** ព្រោះអត្ថថា មានការស្វែងរកជាគ្រឿងបរិសុទ្ធ សូម្បីក្នុងសីលដ៏សេស ក៏មានន័យដូចគ្នា ។ ចំណែកសព្ទថា សុទ្ធិ គឺមានន័យដូចខ្ញុំម្ចាស់បានពោលហើយមកនោះឯង ។ ពាក្យថា ( នឹងមិនធ្វើ ) យ៉ាងនេះ លោកអាចារ្យពោលសំដៅយកប្រភេទនៃសំវរៈ ។

ពាក្យថា លះ គឺវៀរ មានន័យថា មិនធ្វើ ។

បច្ច័យ ៤ ឈ្មោះថា ទាយ ( មរតក ) ព្រោះអត្ថថា ដែលបុគ្គលគប្បីឲ្យ, ទាយនោះដែលបុគ្គលគប្បីបាន រមែងកាន់យក ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **ទាយាទ** ។ បច្ច័យទាំងឡាយដែលភិក្ខុគប្បីបរិភោគ ឈ្មោះថា ជារបស់ព្រះមានព្រះភាគ ព្រោះកាលបើទ្រង់មិនអនុញ្ញាតទុក ក៏គ្មានការបរិភោគបាន ឡើយដោយប្រការទាំងពួង ព្រោះកាលបើទ្រង់អនុញ្ញាតទុកនោះឯង ទើបមានការបរិភោគបាន ។

ក៏ធម្មទាយាទសូត្រ ដែលមានយ៉ាងនេះថា **ធម្មទាយាទា មេ ភិក្ខវេ ភវថ ។បេ។ នោ អាមិសទាយាទា** ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរជាធម្មទាយាទរបស់តថាគត ចូរកុំជាអាមិសទាយាទឡើយ ។ តថាគតតែងពិចារណាចំពោះអ្នកទាំងឡាយថា ធ្វើយ៉ាងណាហ្ន៎ ! ទើបសាវករបស់តថាគត គប្បីជាធម្មទាយាទ កុំគប្បីជាអាមិសទាយាទ ដូច្នេះជាសាធកៈក្នុងរឿងនេះ គឺក្នុងសេចក្តីនេះ ។

សម្រាប់បុគ្គលដែលមិនទាន់ប្រាសចាករាគៈទាំងឡាយ រមែងមិនមានភាពជាម្ចាស់របស់ក្នុងការបរិភោគបច្ច័យ ព្រោះភាពជាទាសៈរបស់តណ្ហា,សម្រាប់អ្នកដែលប្រាសចាករាគៈហើយទាំងឡាយឈ្មោះថា មានភាពជាម្ចាស់របស់ទាំងឡាយ ក្នុងការបរិភោគបច្ច័យទាំងឡាយនោះ ព្រោះមានការបរិភោគបានតាមការពេញចិត្ត ដោយគ្មានភាពជាទាសៈរបស់តណ្ហានោះ ។ ពិតហើយ លោកទាំងនោះតែងបរិភោគបច្ច័យទាំងឡាយ ដោយអាការធ្វើវត្ថុបដិកូលឲ្យជាវត្ថុមិនបដិកូលក៏បាន, ដោយអាការធ្វើវត្ថុមិនបដិកូលឲ្យជាបដិកូលក៏បាន, ដោយអាការព្រងើយ វៀរចាកអាការទាំងពីរនោះចេញក៏បាន, ទាំងអាចធ្វើមនោរថរបស់ទាយកទាំងឡាយ ឲ្យបរិបូរបានផងដែរ ។ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ពិតហើយ ព្រះខីណាស្រពទាំងឡាយនោះ ចាត់ជាសាមីបរិភោគ ព្រោះលោកទាំងឡាយនោះ

ឈានកន្លងពីភាពជាទាសៈរបស់តណ្ហាបានហើយ ដូច្នេះ ។

ពាក្យថា ( គួរ ) ដល់ភិក្ខុទាំងពួង គឺចំពោះភិក្ខុទាំងឡាយដែលជាព្រះអរិយបុគ្គល និងបុថុជ្ជន ។ សួរថា **សាមីបរិភោគ** និងទាយជ្ជបរិភោគទាំងឡាយនេះ មានដល់បុថុជ្ជនបានយ៉ាងណា ? ឆ្លើយថា មានបានដោយទាក់ទងដល់ការប្រៀបធៀប ។ ការបរិភោគដោយចិត្តដែលមិនជាប់ជំពាក់ក្នុងបច្ច័យនោះៗ ព្រោះលះបង់នូវសេចក្ដីប្រាថ្នាក្នុងបច្ច័យចំពោះភិក្ខុ សូម្បីជាបុថុជ្ជនអ្នកតាំងនៅក្នុងសល្លេខបដិបត្តិយ៉ាងណា, ការបរិភោគនោះរមែងដូចជាសាមីបរិភោគ ។ ចំណែកការបរិភោគបច្ច័យដែលបានពិចារណាហើយ ចំពោះភិក្ខុអ្នកមានសីលរមែងដូចជាទាយជ្ជបរិភោគ ព្រោះការមិនធ្វើមនោរថរបស់ទាយកទាំងឡាយឲ្យវិនាសទៅ ។ សេចក្ដីនេះ សមដូចពាក្យដែលលោកអាចារ្យពោលទុកថា ដល់ការសង្គ្រោះចូលក្នុងទាយជ្ជបរិភោគនោះឯងក៏បាន ដូច្នេះ ។ ក្នុងការបរិភោគរបស់ភិក្ខុ ជាកល្យាណបុថុជ្ជនមិនមានពាក្យដែលត្រូវពោលដល់ឡើយ ព្រោះកល្យាណបុថុជ្ជនទាំងឡាយនោះមានការសង្គ្រោះចូលក្នុងព្រះសេក្ខៈបាន ។សេក្ខសូត្រជាសាធកៈក្នុងសេចក្ដីនេះបាន ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះថា សូម្បីលោកអ្នកមានសីល ដូច្នេះជាដើម ។

ពាក្យថា ព្រោះភាពជាសត្រូវ មានន័យថា ប្រៀបដូចជាបុគ្គល

ជំពាក់បំណុល រមែងមិនបានទៅកាន់តំបន់ដែលប្រាថ្នា តាមការពេញចិត្តរបស់ខ្លួនយ៉ាងណា, ភិក្ខុដែលប្រកបដោយការបរិភោគ ដូចជាអ្នកជំពាក់បំណុលគេ រមែងមិនបានចេញចាកលោកដូច្នោះ ដូចគ្នា ។

ការបរិភោគបច្ច័យដែលបានពិចារណាហើយ ចំពោះភិក្ខុអ្នកមានសីល ឈ្មោះថា ការបរិភោគដោយមិនជាប់បំណុល ព្រោះជាបដិបក្ខដល់ការបរិភោគដែលជាប់បំណុល ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ចាត់ជាការបរិភោគ មិនជាប់បំណុលក៏បាន ដូច្នេះ ។

ដោយពាក្យនេះលោកអាចារ្យសម្តែងថា ការបរិភោគដែលមិនជាប់បំណុល ជាការបរិភោគម្យ៉ាងដទៃទៀត ផុតពីការបរិភោគ ៤ យ៉ាង ដោយបរិយាយ ។ ពាក្យថា ដោយសិក្ខានេះ គឺដោយសិក្ខាពោល គឺសីល ។ ពាក្យថា **កិច្ចការី** បានដល់ ជាអ្នកមានប្រក្រតីធ្វើឲ្យដល់ព្រមនូវភាពត្រឹមត្រូវ ដោយការបដិបត្តិសមគួរដល់ការបព្វជ្ជា ។

ឥឡូវនេះ លោកអាចារ្យមានបំណងបើកបង្ហាញនូវភាពជាកិច្ចការីនោះឯង ដោយបទព្រះសូត្រ ទើបពោលថា ពិតហើយ ព្រះមានព្រះភាគត្រាស់ពាក្យនេះទុក ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា វិហារ បានដល់ ទីស្នាក់អាស្រ័យ ។ ពាក្យថា ទីដេក ទីអង្គុយ បានដល់ គ្រែជាដើម ។ ដោយពាក្យទាំងពីរនោះ លោកពោលដល់សេនាសនៈនោះឯង ។ បទថា **អាបំ** ប្រែថា ទឹក ។ ពាក្យ

ថា ទឹកជម្រះធូលីដែលជាប់លើសំពត់សង្ឃាដី បានដល់ ទឹកជម្រះមន្ទិល គឺធូលីជាដើម ដែលជាធូលីជាប់នឹងសំពត់សង្ឃាដី ។

ពាក្យថា ស្តាប់ធម៌ដែលព្រះសុគតទ្រង់សម្តែងទុក បានដល់ស្តាប់ធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងទុកក្នុងបច្ច័យ ៤ មានចីវរជាដើម ដោយន័យថា ភិក្ខុពិចារណាចីវរដោយឧបាយត្រូវទំនងហើយទើបសេពត្រឹមតែដើម្បីការពារនូវភាពរងា ដូច្នេះជាដើម ។

ពាក្យថា ព្រះសាវករបស់ព្រះមានព្រះភាគ ជាអ្នកមានបញ្ញាដ៏ប្រសើរ គប្បីពិចារណាហើយ ទើបសេព មានន័យថា សាវករបស់ព្រះសាស្តាជាអ្នកមានបញ្ញាខ្ពង់ខ្ពស់ ជាព្រះសេក្ខៈក៏ដោយ ជាបុថុជ្ជនក៏ដោយ គប្បីពិចារណាហើយ ទើបសេព គឺអាចសេពនូវបច្ច័យ ៤ យ៉ាង ។ បិណ្ឌបាតទ្រង់ត្រាស់ហៅថា ដុំបាយ, សេនាសនៈទ្រង់ត្រាស់ហៅថា **វិហារ** ជាដើម, **គិលានប្បច្ច័យ** ( ថ្នាំជាបច្ច័យសម្រាប់អ្នកឈឺ ) ដែលទ្រង់សម្តែងទុកដោយទឹកជាសំខាន់ ព្រោះអត្ថថា សូម្បីទឹកផឹកក៏ឈ្មោះថា គិលានប្បច្ច័យបាន ព្រោះជាគ្រឿងរម្ងាប់នូវការឈឺចាប់ គឺការស្រេកឃ្លានបាន ( ៦ ) ចីវរមានសំពត់សង្ឃាដីជាដើម គឺពិចារណាដោយន័យថា ត្រឹមតែដើម្បីការតាំងនៅនៃកាយនេះប៉ុណ្ណោះ ដូច្នេះជាដើម ។

ក៏ព្រោះហេតុដែលសាវករបស់ព្រះមានជោគជាអ្នកមានបញ្ញា

ដ៏ប្រសើរ ជាអ្នកមានប្រក្រតីពិចារណាហើយទើបសេព, ព្រោះហេតុនោះឯង ទើបជាភិក្ខុអ្នកមិនជាប់ក្នុងធម៌ទាំងឡាយនោះ គឺក្នុងដុំបាយ ។ល។ ដូចជាដំណក់ទឹកមិនជាប់លើស្លឹកឈូកដូច្នេះ ។

ពាក្យថា តាមកាល គឺក្នុងពេលបរិភោគរបស់ព្រះអរិយបុគ្គលទាំងឡាយ ។

បទថា **លទ្ធា** ប្រែថា បានហើយ ។ បទថា **បរតោ** ប្រែថា ពីអ្នកដទៃ បានដល់ ពីទាយក ។ ពាក្យថា ដោយការអនុគ្រោះ គឺដោយការជួយសង្គ្រោះ មានន័យថា ភិក្ខុនោះគប្បីដឹងច្បាស់ គឺគប្បីដឹងប្រមាណក្នុងបច្ច័យដែលអ្នកដទៃនាំចូលទៅ ( ថ្វាយ ) សូម្បីច្រើន ក៏ជាអ្នកតាំងមាំ គឺជាអ្នកមានសតិតាំងមាំជានិច្ច គឺអស់កាលទាំងពួង ។

ពាក្យថា ដូចជាការដឹងប្រមាណក្នុងការរុំថ្នាំរក្សាដំបៅដូច្នោះ ប្រកបសេចក្តីថា គប្បីដឹងប្រមាណ ដូចជាការដឹងប្រមាណក្នុងការរុំថ្នាំលាបដំបៅ ដូច្នោះ ។ បទថា **អាហរិ** ប្រែថា ទំពាលេប ។

ម្យ៉ាងទៀត បាឋៈថា **អាហរេយ្យាហារំ** ដូច្នេះក៏បាន ។ ពាក្យថា ដើម្បីការប្រព្រឹត្តិទៅបាន គឺដើម្បីការប្រព្រឹត្តិទៅបាននៃរាងកាយ ។ ពាក្យថា ជាអ្នកមិនឱន គឺជាអ្នកមិនឱនដោយការឱន គឺតណ្ហា បានដល់ ជាអ្នកមិនមានសេចក្តីប្រាថ្នា គឺតណ្ហា ។

សាមណេរឈ្មោះថា **ភាគិនេយ្យសង្ឃរក្ខិតសាមណេរ**(សង្ឃ-

រក្ខិតសាមណេរជាក្មួយ ) ព្រោះលោកកាន់យកឈ្មោះរបស់ព្រះសង្ឃរក្ខិតត្ថេរ ដែលជាឪពុកមារបស់ខ្លួននោះឯង ។ បទថា **សាលិក្ខុរំ** ប្រែថា បាយស្រូវសាលី ។ បទថា **សុនិព្វុតំ** ប្រែថា ដែលត្រជាក់ល្អហើយ ។ ពាក្យថា អ្នកមិនសង្រួម លោកពោលសំដៅយកការមិនពិចារណា ។ បទថា **សព្វាសវបរិក្ខីណោ** ប្រែថា ជាអ្នកមានអាសវៈទាំងពួងអស់ហើយ ។

( ចប់ មហាដីកា )

# បញ្ចកសីល ( សីលពួក៥ )

## ទី ១

អត្ថាធិប្បាយក្នុងបញ្ចកសីលទី ១ នៃសីលចែកជា ៥ យ៉ាង បណ្ឌិតគប្បីជ្រាបដោយសីលរបស់អនុបសម្បន្នជាដើម... ។

ពិតហើយ ពាក្យតទៅនេះ ព្រះធម្មសេនាបតីសារីបុត្ត ពោលទុកក្នុង **គម្ពីរបដិសម្ភិទា** ថា

១-បរិយន្តប្បារិសុទ្ធិសីលដូចម្តេច ? សីលរបស់អនុបសម្បន្នទាំងឡាយដែលមានសិក្ខាបទមានទីបំផុតនេះឈ្មោះថា បរិយន្តប្បា-រិសុទ្ធិសីល ។

២- អបរិយន្តប្បារិសុទ្ធិសីលដូចម្តេច ? សីលរបស់ឧបសម្បន្នទាំងឡាយដែលមានសិក្ខាបទមិនមានទីបំផុត នេះឈ្មោះថា អបរិយន្ត-ប្បារិសុទ្ធិសីល ។

៣- បរិបុណ្ណប្បារិសុទ្ធិសីលដូចម្តេច ? សីលរបស់កល្យាណបុថុជ្ជនដែលប្រកបក្នុងកុសលធម៌ ធ្វើឲ្យបរិបូណ៌រហូតដល់ដែនព្រះសេក្ខៈ មិនអាល័យក្នុងរាងកាយ និងជីវិត រមែងលះបង់ជីវិតបាន នេះឈ្មោះថា បរិបុណ្ណប្បារិសុទ្ធិសីល ។

៤- អបរាមដ្ឋប្បារិសុទ្ធិសីលដូចម្តេច ? សីលរបស់ព្រះសេក្ខៈ

៧ ចំពូក នេះឈ្មោះថា **អបរាមដ្ឋប្បារិសុទ្ធិសីល** ។

**៥-** បដិបស្សទ្ធិប្បារិសុទ្ធិសីល ដូចម្តេច ? សីលរបស់ព្រះខីណាស្រពទាំងឡាយជាសាវ័ករបស់ព្រះតថាគត សីលរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ សីលរបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធទាំងឡាយនេះឈ្មោះថា បដិបស្សទ្ធិប្បារិសុទ្ធិសីល (សីលដែលមានភាពបរិសុទ្ធិព្រោះការស្ងប់រំងាប់ទៅនៃកិលេស ) ។

ក្នុងសីលទាំងឡាយនោះ សីលរបស់អនុបសម្បន្ន គប្បីជ្រាបថា ជាបរិយន្តប្បារិសុទ្ធិសីល ព្រោះមានទីបំផុត ( នៃចំនួន ) ដោយអំណាចនៃការរាប់សីលរបស់ឧបសម្បន្នទាំងឡាយ សូម្បីជាសីលមានទីបំផុតដោយអំណាចការរាប់ ( ដូចលោកពោលគាថាទុក ) ថា

សិក្ខាបទទាំងឡាយដែលជាគ្រឿងសង្រួម និងជាវិន័យទាំងឡាយ (ចំនួន) ៩០០០ កោដិ សិក្ខាបទ, ៨០០ កោដិ សិក្ខាបទ, ៥០ សែនសិក្ខាបទ និង ៣៦ សិក្ខាបទ ( រួមជាមួយម៉ឺនប្រាំពីរពាន់កោដិប្រាំលាន សាមសិបប្រាំមួយសិក្ខាបទ ) ដែលព្រះសម្ពុទ្ធទ្រង់ប្រកាសហើយ, ក្នុងគម្ពីរវិន័យលោកនិទ្ទេស ទុកដោយមុខ ។ល។ ដូច្នេះក្តី

( តែ ) បណ្ឌិតគប្បីជ្រាបថា ជាអបរិយន្តប្បារិសុទ្ធិសីល ព្រោះសំដៅយកភាវៈ គឺការសមាទានដោយជាអនវសេសសីល ( សីលមិនមានចំណែកសល់ និងជាសីលដែលមិនមានការឃើញចំពោះលាភយស

ញាតិ អវយវៈ និងជីវិតជាទីបំផុត ដូចជាសីលរបស់ព្រះមហាតិស្សៈ អ្នកឆាន់ផ្លែស្វាយដែលស្នាក់អាស្រ័យនៅនឹងចីវរគុម្ពវិហារដូច្នោះ ។

ពិតហើយលោកមានអាយុនោះមិនលះបង់នូវសប្បុរិសានុស្សតិ ( ការតាមរលឹកចំពោះសប្បុរស ) នេះថា

**នរជនគប្បីលះបង់ទ្រព្យ ព្រោះហេតុនៃអវយវៈដ៏ប្រសើរ កាលនឹងរក្សាជីវិត គប្បីលះបង់អវយវៈចេញ កាលរលឹកដល់ធម៌ គប្បីលះបង់អវយវៈ ទ្រព្យ និងសូម្បីលះបង់ជីវិត ។**

ដូច្នេះ សូម្បីមានការសង្ស័យក្នុងជីវិតមានហើយ ក៏មិនកន្លងសិក្ខាបទ អាស្រ័យអបរិយន្តបារិសុទ្ធិសីលនោះឯង នៅលើខ្នងរបស់ឧបាសកនោះឯង បានសម្រេចព្រះអរហត្ត ដូចលោកពោលនូវប្រវត្តិទុកថា ព្រះថេរៈទូន្មានខ្លួនឯងថា ឧបាសកនេះមិនមែនបិតា ទាំងមិនមែនមាតា មិនមែនញាតិ ទាំងមិនមែនផៅពង្សរបស់យើង គេធ្វើកិច្ចដូច្នេះឲ្យ ក៏ព្រោះហេតុនៃយើងជាអ្នកមានសីល ដូច្នេះហើយ ញុំាងសេចក្តីសង្វេគឲ្យកើតឡើងពិចារណា ( សន្ធារ ) ដោយបញ្ញាទាំងដែលនៅលើខ្នងរបស់ឧបាសកនោះ បានសម្រេចព្រះអរហត្តហើយដូច្នេះ ។

សីលរបស់កល្យាណបុថុជ្ជនទាំងឡាយដែលវៀរចាកមន្ទិល សូម្បីតែកើតចិត្តគិតកន្លង ក៏មិនមាន ព្រោះជាសីលដែលបរិសុទ្ធ

ក្រៃលែង ដូចកែវមណីដែលជាងច្នៃល្អហើយ និងដូចជាមាសដែលជាងធ្វើបរិកម្មល្អហើយ តាំងពីឧបសម្បទាមក រមែងជាបទដ្ឋាននៃព្រះអរហត្តដោយពិត ព្រោះហេតុនោះ ទើបលោកពោលថា បរិបុណ្ណប្បារិសុទ្ធិសីល ដូចជាសីលរបស់ព្រះមហាសង្ឃរក្ខិតត្ថេរ និងព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរដូច្នេះ ។

## រឿងព្រះមហាសង្ឃរក្ខិតៈ

បានឮថា ព្រះភិក្ខុសង្ឃសួរដល់ការសម្រេចលោកុត្តរធម៌ នឹងព្រះមហាសង្ឃរក្ខិតត្ថេរដែលមានវស្សា ៦០ កន្លងហើយ ដេកនៅលើគ្រែដែលជាកន្លែងសម្រាប់ស្លាប់ ព្រះថេរៈប្រាប់ថា យើងមិនមានលោកុត្តរធម៌ទេ គ្រានោះភិក្ខុកំលោះ ដែលជាឧបដ្ឋាករបស់លោករំលឹកថា លោកដ៏ចម្រើន មនុស្សទាំងឡាយដែលនៅ ជុំវិញទីនេះប្រមាណ ១២ យោជន៍ ប្រជុំគ្នាដោយគិតថា ព្រះគុណម្ចាស់ បរិនិព្វានដូច្នេះ, មហាជននឹងមានសេចក្តីក្តៅក្រហាយជាខាងក្រោយព្រោះការមរណភាពរបស់បុថុជ្ជននៃលោកម្ចាស់ អាវុសោ យើងមិនផ្តើមតាំងវិបស្សនា ព្រោះប្រាថ្នាថា នឹងរង់ចាំជួបព្រះមានព្រះភាគមេត្តេយ្យសិនបើដូច្នេះ អ្នកចូរជួយយើងឲ្យអង្គុយ ហើយទុកឱកាសដល់យើង ភិក្ខុកំលោះនោះជួយព្រះថេរៈឲ្យអង្គុយហើយ ចេញទៅខាងម្ខាង ព្រះថេរៈ

បានសម្រេចព្រះអរហត្តព្រមគ្នានឹងភិក្ខុកំលោះចេញទៅក្រៅនោះឯង ទើបឲ្យសញ្ញាដោយការផ្ទាត់ក្រចកដៃ ព្រះសង្ឃមកប្រជុំគ្នាហើយ ក៏ប្រាប់ថា លោកដ៏ចម្រើន ព្រះថេរៈញ៉ាំងលោកុត្តរធម៌ ឲ្យកើតឡើងក្នុងពេលទៀបមរណភាពបែបនេះ ឈ្មោះថា បានធ្វើនូវកិច្ចដែលគេធ្វើបានដោយកម្រ ព្រះថេរៈពោលថា នេះមិនមែនជាកិច្ចដែលធ្វើបានដោយកម្រទេ យើងនឹងប្រាប់កិច្ចដែលធ្វើបានដោយកម្រដល់អ្នកទាំងឡាយ, អាវុសោទាំងឡាយយើងរលឹកដល់កម្មដែលបានធ្វើផង ការមិនដឹងព្រោះមិនមានសតិ តាំងពីកាលដែលយើងបួសហើយមិនឃើញឡើយ ។ សូម្បីចៅរបស់លោក ក៏បានសម្រេចព្រះអរហត្តតាមទំនងដូចគ្នា ក្នុងពេលដែលមានវស្សាបាន ៥០ ។

បុគ្គលណា បើជាអ្នកស្តាប់តិច ទាំងមិនមាំទាំនៅក្នុងសីលទាំងឡាយបណ្ឌិតទាំងឡាយរមែងរិះគន់បុគ្គលនោះទាំង២ផ្លូវគឺទាំងសីលនិងទាំងសុតៈ, បុគ្គលណាជាអ្នកស្តាប់តិច តែជាអ្នកមាំទាំក្នុងសីលទាំងឡាយ បណ្ឌិតទាំងឡាយរមែងសរសើរបុគ្គលនោះចំពោះសីល (តែ) សុតៈរបស់គេប្រើការមិនបាន, បុគ្គលណាជាអ្នកស្តាប់ច្រើន តែមិនមាំទាំក្នុងសីលទាំងឡាយ បណ្ឌិតទាំងឡាយរមែងតិះដៀលបុគ្គលនោះខាងសីល សុតៈរបស់គេប្រើការបាន, បុគ្គលណាបើជាអ្នកស្តាប់ច្រើន ទាំងមាំទាំក្នុងសីលទាំងឡាយ បណ្ឌិតទាំងឡាយ រមែង

សរសើរបុគ្គលនោះទាំង ២ ផ្លូវ គឺទាំងសីល និងសុតៈ ។

អ្នកណាហ្ន៎ ! គួរតិះដៀលអ្នកជាពុទ្ធសាវក បានស្ដាប់ច្រើន ទ្រទ្រង់ធម៌ មានបញ្ញាប្រៀបដូចជាមាសជម្ពូនុទនោះ សូម្បីទេវតាទាំងឡាយក៏សរសើរ ព្រហ្មក៏សរសើរដែរ ។

ចំណែកសីលរបស់ព្រះសេក្ខៈទាំងឡាយ បណ្ឌិតគប្បីជ្រាបថា ជា **អបរាមដ្ឋប្បារិសុទ្ធិសីល** ព្រោះជាសីលដែលមិនត្រូវប៉ះពាល់ដោយអំណាចទិដ្ឋិ ម្យ៉ាងទៀត ជាសីលដែលមិនត្រូវប៉ះពាល់ដោយអំណាចរាគៈ សីលរបស់បុថុជ្ជនទាំងឡាយ គប្បីជ្រាបថាជាបរាមដ្ឋប្បារិសុទ្ធិសីល ដូចជាសីលរបស់ព្រះតិស្សត្ថេរ ជាបុត្ររបស់កុដុម្ពី ដូច្នោះ លោកអង្គនោះ បំណងនឹងអាស្រ័យសីលបែបនោះ ហើយតាំងនៅក្នុងព្រះអរហត្ត ទើបពោលនឹងសត្រូវទាំងឡាយថា

យើងទម្លាយស្មងទាំងសងខាង ផ្ញើសញ្ញាដល់អ្នកទាំងឡាយ យើងអៀន ខ្មាសចំពោះការស្លាប់ក្នុងភាពជាបុគ្គល ដែលមានរាគៈ យើងគិតយ៉ាងនេះហើយ ទើបពិចារណា ( សន្ធារ ) ដោយបញ្ញា ក៏បានសម្រេចព្រះអរហត្ត ពេលអរុណរះឡើង ។

## រឿងរបស់ព្រះថេរៈ ១ អង្គ

ព្រះថេរៈ ១ អង្គទៀត អាពាធធ្ងន់រហូតមិនអាចបរិភោគអាហារ

ដោយដៃរបស់ខ្លួនបាន ដេកនៅលើនៅក្នុងមូត្រ និងលាមករបស់ខ្លួនឯង ភិក្ខុកំលោះទាំងឡាយរូបណាក៏ដោយ ពេលឃើញលោកហើយក៏ពោលថា ឱ ! ជីវិត សង្ខារទាំងឡាយជាទុក្ខ ព្រះមហាថេរៈពោលនឹងអ្នកទាំងនោះថា អាវុសោ យើងស្លាប់ក្នុងពេលឥឡូវនេះនឹងបានសួគ៌សម្បត្តិសេចក្តីសង្ស័យក្នុងរឿងនេះមិនមានដល់យើងទេតែត្រូវទម្លាយសីលនេះហើយទើបបានសម្បត្តិក៏ដូចគ្នាដែរ ភាពជាគ្រហស្ថគប្បីបានមក កាលបើភិក្ខុទម្លាយសិក្ខាបទហើយដូច្នេះ ដូច្នេះ ហើយគិតថា យើងត្រូវស្លាប់ទៅជាមួយសីលឲ្យបាន ដេកនៅដូច្នេះឯងពិចារណារោគនោះ ( ជាអារម្មណ៍ ) សម្រេចព្រះអរហត្ត ហើយព្យាករណ៍ ( ព្រះអរហត្ត ) ដល់ភិក្ខុសង្ឃដោយគាថាទាំងឡាយនេះថា

កាយយើងត្រូវព្យាធិយ៉ាងណាមួយពាល់ត្រូវ ហើយរោគក្តៅធ្វើឲ្យលំបាក អាការធ្ងន់ធ្ងរាងកាយដែលជារបស់ស្អុយនេះ ហួតហែងយ៉ាងរហ័សដូចផ្កាឈើ ដែលគេបោះចោលនៅលើធូលីកណ្តាលថ្ងៃ ហួតហែងទៅយ៉ាងឆាប់រហ័សដូច្នោះ សាកសពនេះមិនគួរឲ្យពេញចិត្តទេ, បុគ្គលពាលត្រឡប់ជារាប់អានថា ជារបស់គួរពេញចិត្ត កាយស្អុយនេះមិនស្អាត បុគ្គលពាលត្រឡប់ជារាប់អានថា ជារបស់ស្អាត, កាយពេញទៅដោយសាកសពផ្សេងៗ តែ (ត្រឡប់) ជារូបគួរពេញ

ចិត្តសម្រាប់បុគ្គលដែលមិនឃើញ (តាមសេចក្តីពិត) សូមតិះដៀល កាយ ដែលទុក្ខសោក ក្ដិនស្អុយកខ្វក់ មានជំងឺជានិច្ច ដែលពួកសត្វ ជាអ្នកប្រមាទវង្វេងហើយ ធ្វើផ្លូវនៃដំណើរទៅកាន់សុគតិឲ្យវិនាស ហើយ ដូច្នេះ ។

ចំណែកសីលរបស់លោកអ្នកអស់កិលេស មានព្រះអរហន្ត ជាដើម គប្បីជ្រាបថា ជាបដិបស្សទ្ធិប្បារិសុទ្ធិសីល ព្រោះជាសីល បរិសុទ្ធដោយភាពរំងាប់នូវកិលេស ដែលជាគ្រឿងក្តៅក្រហាយទាំង ពួង សីល ៥ យ៉ាង ដែលចាត់ជាបារិសុទ្ធិសីល មានបរិយន្តប្បារិសុទ្ធិ សីលជាដើម សាធុជន គប្បីជ្រាបដោយប្រការ ដូចដែលពោលមក នេះចុះ ។

# មហាដីកា

## ពណ៌នាសីលព្វក ៥ ទី ១

សិក្ខាបទទាំងឡាយ ឈ្មោះថា **បរិយន្ត** ព្រោះអត្ថថា មានទីបំផុត ។

អនុបសម្បន្នទាំងឡាយណា មានសិក្ខាបទដែលមានទីបំផុត អនុបសម្បន្នទាំងឡាយនោះ ឈ្មោះថា **អ្នកមានសិក្ខាបទមានទីបំផុត** បានដល់ របស់អនុបសម្បន្ន អ្នកមានសិក្ខាបទដែលមានទីបំផុតទាំងឡាយនោះ ។ ពាក្យថា **របស់ឧបសម្បន្ន** គឺលើកលែងកល្យាណបុថុជ្ជន ព្រះសេក្ខៈ និងព្រះអសេក្ខៈទាំងឡាយចេញ ក៏បានដល់របស់ឧបសម្បន្នទាំងឡាយដទៃ ក្រៅពីកល្យាណបុថុជ្ជនជាដើមទាំងឡាយនោះ ។ ព្រោះថា **សាមញ្ញជោទនា** រមែងតាំងនៅក្នុងភាពផ្សេងគ្នា ។ ពាក្យថា **អ្នកប្រកបក្នុងកុសលធម៌** បានដល់ អ្នកប្រកបក្នុងវិបស្សនាចារៈ ។ ធម៌ ឈ្មោះថា **សេក្ខបរិយន្ត** ព្រោះអត្ថថា មានសេក្ខធម៌ទាំងឡាយជាទីបំផុត គឺជាដែនយ៉ាងប្រាកដ ។ ម្យ៉ាងទៀត ការជាប់ទាក់ទងគ្នានៃកុសលធម៌ដែលប្រព្រឹត្តទៅ ចាប់តាំងពីការកំណត់នាមរូប ឬការសមាទាននូវកុសលធម៌រហូតដល់គោត្រភូ តាំងនៅក្នុងសេក្ខធម៌ទាំងឡាយ ឈ្មោះថា **សេក្ខបរិយន្ត** ។ ម្យ៉ាងទៀត សិក្ខា ៣ ដែលជា

លោកិយ ជាការសិក្សាក្នុងចំណែកខាងដើម នៃសេក្ខធម៌ទាំងឡាយ ឈ្មោះថា **សេក្ខបរិយន្ត** បានដល់ ក្នុងសេក្ខបរិយន្តៈនោះ ។

ពាក្យថា អ្នកធ្វើឲ្យបរិបូណ៌ គឺអ្នកធ្វើឲ្យពេញ មិនធ្វើសិក្ខាណាមួយឲ្យវិនាសទៅ ។ ឈ្មោះថា មិនអាល័យក្នុងរាងកាយ និងជីវិត ក៏ដើម្បីសម្រេចនូវគុណវិសេសក្រៃលែងឡើងទៅ ។ ព្រោះតែមិនអាល័យក្នុងកាយ និងជីវិតនោះឯង ទើបជាអ្នកមានជីវិតលះបង់បានហើយ ដើម្បីប្រយោជន៍ដល់ភាពបរិបូរណ៍នៃសីល ។

សីល ឈ្មោះថា **អបរាមដ្ឋប្បារិសុទ្ធិសីល** ព្រោះសង្កិលេស គឺទិដ្ឋិមិនអាចប្រកាន់បាន ។ សីលដែលមានភាពបរិសុទ្ធិព្រោះកិលេសទាំងឡាយស្ងប់រំងាប់ទៅ ដោយប្រការទាំងពួង ឈ្មោះថា បដិបស្សទ្ធិប្បារិសុទ្ធិសីល ។

សីលរបស់ព្រះអសេក្ខៈព្រះសេក្ខៈនិងកល្យាណបុថុជ្ជនដែលជាអនុបសម្បន្ន ចាត់ជាអបរិយន្តសីលបានដោយអានុភាពតែមួយព្រោះមានអានុភាពច្រើន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះជាសីលមានទីបំផុតដោយជុំវិញ ដោយអំណាចនៃការរាប់ ( មិនមែនដោយអានុភាព ) ដូច្នេះ ។

សិក្ខាបទទាំងឡាយឈ្មោះថា **សំវរវិនយ** ព្រោះជាគ្រឿងការពារ និងព្រោះជាគ្រឿងហ្វឹកហាត់កាយវាចា ។ ពាក្យថា ទ្រង់សម្តែង

ទុកដោយមុខ គឺវគ្គ បានដល់ ព្រះសាស្តាទ្រង់សម្តែងទុកដោយការរាប់តាមដែលពោលហើយដោយវិត្ថារន័យ ដែលទ្រង់ទេសនាទុកក្នុងទីកន្លែងនោះៗ ។ ពាក្យថា សិក្ខា បានដល់ សិក្ខា ពោល គឺសីល ។

បទថា **វិនយសំវរេ** បានដល់ ក្នុងវិនយបិដក ។ គប្បីនាំយកពាក្យដែលលោកពោលទុកក្នុងខាងក្រោយចូលមកភ្ជាប់គ្នា, សីលរបស់ឧបសម្បន្ន សូម្បីថា មានទីបំផុត ក៏ដោយអំណាចនៃការរាប់ដូច្នេះចុះ ។

ឈ្មោះថា សីល ដែលឧបសម្បន្ន គប្បីសិក្សាក្នុងប្រការណាមួយ ចាត់ជាអបរិយន្តបារិសុទ្ធិសីល ព្រោះសំដៅយកភាវៈដែលសមាទានក្នុងសីលទាំងឡាយនោះ មិនមានសល់ ព្រោះសូម្បីក្នុងខ.ណាមួយ ក៏មិនសល់ ។

ពាក្យថា ភាវៈដែលសមាទាន គឺភាវៈមាននៃការសមាទាន ។ ឈ្មោះថា គឺភាវៈដែលមិនប្រាកដទីបំផុតអាស្រ័យដោយលាភ ។ល។ បានដល់ ការមិនកន្លងសីល ព្រោះហេតុនៃលាភជាដើម ។

អ្នកដែលត្រូវចោរប្ងន់ស្កាត់ប្ងន់តាមផ្លូវ ធ្វើឲ្យអន្តរាយ សុខចិត្តលះបង់ទ្រព្យ ព្រោះហេតុនៃអវយវៈប្រសើរជាង ។ ក្នុងពេលដែលត្រូវពស់ខាំជាដើម កាលនឹងរក្សាជីវិត គប្បីលះបង់អវយវៈ ។ កាលតាមរឭកដល់ធម៌គប្បីលះអវយវៈទ្រព្យ និងសូម្បីជីវិតបានទាំងអស់

ដូចសប្បុរសទាំងឡាយ មានព្រះសុត្តសោមមហាពោធិសត្វជាដើម ។ ព្រោះហេតុនោះ ទើបលោកពោលថា កាលមិនលះបង់អនុស្សតិរបស់សប្បុរស ១.នោះ ដូច្នោះ ។ ឈ្មោះថា កាលមានការសង្ស័យចំពោះជីវិត ក៏ព្រោះមានអន្តរាយ គឺសេចក្តីស្រេកឃ្លាន ។

ពាក្យថា មិនល្មើសសិក្ខាបទ មានន័យថា កាលផ្លែស្វាយទាំងឡាយមិនមានម្ចាស់ជ្រុះនៅលើផែនដី សូម្បីមាននៅជិតៗ នោះហើយ ក៏មិនព្រមបរិភោគ ព្រោះគ្មានអ្នកប្រគេន ឈ្មោះថា មិនល្មើសបដិគ្គហណសិក្ខាបទ ( សិក្ខាបទដែលទាក់ទងនឹងការទទួលប្រគេន ) ។

បទថា **សីលវន្តស្ស** មានន័យថា នៅធ្វើកិច្ចដូច្នេះ មានការបែកទៅតាមព្រៃជាដើមបាន ព្រោះហេតុនៃភាពជាអ្នកមានសីល ឬព្រោះហេតុនៃខ្លួនជាអ្នកមានសីល អធិប្បាយថា ព្រោះហេតុនៃសីល ។

ពាក្យថា ដូចជាកែវមណីដែលថ្លៃល្អហើយ គឺដូចជាកែវមណីដែលជាងថ្នៃ ទុកដោយប្រពៃ ដាក់លើជុំថ្ម ៤ ជុំ ហើយនោះឯង ។

ពាក្យថា ដូចជាសីលរបស់ព្រះមហាសង្ឃរក្ខិតត្ថេរ និងព្រះសង្ឃរក្ខិតត្ថេរ ត្រូវជាក្មួយ គឺដូចជាសីលរបស់ព្រះមហាសង្ឃរក្ខិតត្ថេរ និងដូចជាសីលរបស់ព្រះសង្ឃរក្ខិតត្ថេរ ជាក្មួយរបស់ព្រះមហាសង្ឃរក្ខិតត្ថេរនោះឯង, មានអធិប្បាយថា សេចក្តីក្តៅក្រហាយចិត្តនឹងមានដល់មហាជន ពួកយើងមកក្នុងទីនេះដើម្បីប្រយោជន៍អ្វីទៅ ដូច្នេះ ។

បទថា **អច្ឆរិកាយ** បានដល់ ដោយការផ្ទាត់ក្រចកដៃ ។

ពាក្យថា ព្រោះមិនមានសតិ គឺព្រោះការលត់ទៅនៃសតិ ។

ពាក្យថា ដែលធ្វើព្រោះមិនដឹង គឺការធ្វើភ្លាំងភ្លាត់ព្រោះមិនដឹង មានន័យថា ដែលមិនដឹងហើយធ្វើ ។ ពាក្យថា បើថាបុគ្គលជាអ្នកស្តាប់តិច មានន័យថា ប្រសិនបើបុគ្គលជាអ្នកវៀរចាកនូវធម៌ដែលបានស្តាប់មានសុតៈ គេយ្យៈជាដើម។

ពាក្យថា មិនតាំងមាំក្នុងសីលទាំងឡាយដោយល្អ គឺបើជាអ្នកមិនតាំងមាំដោយល្អ សូម្បីក្នុងសីលទាំងឡាយ មានបាតិមោក្ខសំវរសីលជាដើម ។

ពាក្យថា **សុតៈរបស់គេមិនឈ្មោះថាដល់ព្រម** មានន័យថា សុតៈរបស់បុគ្គលដែលវៀរចាកសីលនោះ មិនជាហេតុនាំមកនូវភវសម្បត្តិដល់ខ្លួននិងដល់អ្នកដទៃ ។ពិតហើយ បុគ្គលដែលជាអ្នករៀនជាមួយដឹងថា ជាអ្នកទ្រុស្តសីល ដូច្នេះហើយ រមែងមិនចូលទៅកាន់សំណាក់របស់គេទៀត ។ ក្នុងពាក្យថា **ពហុស្សុតោបិ ចេ** នេះ ស័ព្ទថា **ចេ** ត្រឹមតែជាស័ព្ទនិបាត ។ ពាក្យថា ( ទាំងទេវតាទាំងព្រហ្ម ) ក៏សរសើរ ) គឺឈ្មោះថា ជាអ្នកដែលគេសរសើរនោះឯង ។ ដោយស័ព្ទថា ដែលមិនត្រូវប្រកាន់មាំដោយអំណាចរាគៈ លោកពោលដល់ការមិនមាននៃតណ្ហាបរាមាស ( កិលេសប្រកាន់មាំ គឺតណ្ហា ) ។

ពាក្យថា សីលដែលដូចគ្នា គឺសីលដែលមិនត្រូវប្រកាន់មាំដោយអំណាចរាគៈ ។ ពាក្យថា ទម្លាយ គឺកម្ចាត់ ។ ពាក្យថា នឹងឲ្យសញ្ញា គឺនឹងធ្វើសញ្ញា, បំណងថា ដើម្បីឲ្យឱកាសយើងដែលជាអ្នកមានពេលតិច ។ បទថា **អដ្ឋិយាមិ** ប្រែថា រង្កៀស ។ បទថា **ហរាយាមិ** ប្រែថា ខ្មាសអៀន ។ បទថា **បលិបន្នោ** ប្រែថា លិចនៅ ឬប្រែថា មិនស្អាតស្អំ ។ ពាក្យថា យើងនឹងស្លាប់ទៅព្រមជាមួយសីលនោះឯង មានអធិប្បាយថា យើងកាលមិនបានធ្វើសីលឲ្យវិនាសទៅ ក៏នឹងស្លាប់ទៅជាមួយសីលនោះឯង តទៅនេះយើងនឹងមិនលះសីលនោះសូម្បីក្នុងកាលណាក៏ដោយ ។ ព្រោះថា ការព្រាត់ប្រាសចាកសីលនឹងមានក្នុងការកាន់យកនូវភព,យើងនឹងមិនកាន់យកភពទៀតឡើយដូច្នេះ ។ ពាក្យថា ពិចារណាវេគ មានន័យថា កំណត់វេទនាដែលកើតពីរោគ នាមធម៌ដ៏សេសដោយមានវេទនាជាប្រធាន និងរូបធម៌ទាំងឡាយ ហើយឃើញច្បាស់ ។

ពាក្យថា ( កាលយើង ) វិនាសទៅ គឺ ( កាលយើង ) មានរាងកាយត្រូវរោគធ្វើឲ្យដល់នូវភាពវិការ ។ បទថា **បរិសុស្សតិ** ប្រែថា ស្ងួតស្រពោន ។ ដូចជាអ្វី ? ដូចផ្កាឈើដែលគេបោះចោលលើគំនរធូលី កណ្ដាលថ្ងៃដូច្នោះ មានន័យថា ដូចផ្កាឈើមានផ្កាដើមច័ន្ទរី ( ដើមអំពិលបារាំង ) ជាដើម ដែលគេទុក លើគំនរធូលីដែលក្ដៅ

ព្រោះកម្តៅព្រះអាទិត្យដូច្នោះ ។ បទថា **អជញ្ញំ** ប្រែថា មិនគួរពេញចិត្ត គឺគួរខ្ពើស ។ ពាក្យថា គួរពេញចិត្ត គឺដែលពួកមនុស្សពាលសរសើរយ៉ាងនេះថា គួរពេញចិត្ត ។ ពាក្យថា ជារូបគួរពេញចិត្តសម្រាប់អ្នកមិនឃើញ មានន័យថា ជារូបដែលអ្នកមិនឃើញ គឺមិនដឹងតាមសេចក្តីពិត សរសើរហើយថា គួរពេញចិត្ត ។

បទថា **ធិរត្ថុមំ** កាត់បទជា **ធិរត្ថុ ឥមំ** ព្រោះប្រកបដោយ ធិ ស័ព្ទ ទើបជា **ទុតិយាវិភត្តិ** ក្នុងបទទាំងពួងមានខ្លឹមសារថា ការខាកស្តោះចំពោះកាយស្អុយនេះ មានដូច្នេះ ។

បទថា **ទុគ្គន្ធិយំ** មានន័យស្មើនឹង **ទុគ្គន្ធិកំ** ប្រែថា មានក្លិនស្អុយ ។

បទថា **យត្ថ** មានន័យថា កាយស្អុយតាមដែលពោលហើយដែលពួកប្រជាប្រមាទ គឺដល់នូវការប្រមាទហើយ ព្រោះហេតុនៃរាគៈ។

ពាក្យថា **ប្រជា** បានដល់ សត្វ ។ ពាក្យថា **ធ្វើផ្លូវដើម្បីចូលទៅកាន់សុគតិឲ្យវិនាសទៅ** មានអធិប្បាយថា សូម្បីតែសីលដែលជាផ្លូវដើម្បីការចូលទៅកាន់សុគតិ ក៏ធ្វើឲ្យវិនាសទៅ, នឹងចាំបាច់ពោលថ្វីដល់គុណវិសេសជាន់លើ មានឈានជាដើម ។ លោកអ្នកអស់អាសវៈដែលជាសាវ័កទាំងឡាយគួរនឹងហៅថា ព្រះអរហន្តតែម្យ៉ាង, ចំណែកលោកអ្នកអស់អាសវៈក្រៅពីនេះ ព្រោះប្រព្រឹត្តទៅជាមួយនឹងភាពពិសេស ទើបគួរនឹងហៅថា ព្រះបច្ចេកពុទ្ធ ព្រះសម្មាសម្ពុទ្ធ

ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ( ចំណែកសីលរបស់លោកអ្នកអស់អាសវៈទាំងឡាយ ) មានព្រះអរហន្តជាដើម ដូច្នេះ ។

ពាក្យថា ដោយការស្ងប់រម្ងាប់នូវសេចក្តីខ្វល់ខ្វាយទាំងពួងចេញបានដល់ ដោយការស្ងប់រំងាប់សេចក្តីខ្វល់ខ្វាយ គឺកិលេសទាំងពួងចេញបាន ។

( ចប់ មហាដីកា )

# បញ្ចកសីល "សីលពួក ៥"

## ទី ២

ក្នុងបញ្ចកសីលទី ២ បណ្ឌិតគប្បីជ្រាបខ្លឹមសារដោយអំណាចគុណ មានការលះជាដើមនូវទោសទាំងឡាយ មានបាណាតិបាតជាដើម, ពិតហើយ ព្រះធម្មសេនាបតីសារីបុត្ត ពោលទុកក្នុង **គម្ពីរបដិសម្ភិទាមគ្គ** ថា សីល ៥ គឺការលះបង់បាណាតិបាត ជាសីល, ការវៀរចាក (បាណាតិបាត) ក៏ជាសីល, ចេតនាវៀរចាក (បាណាតិបាត) ក៏ជាសីល, ការសង្រួម (វៀរចាកបាណាតិបាត) ក៏ជាសីល, ការមិនល្មើស ( បាណាតិបាត ) ក៏ជាសីល, ការលះការវៀរចាកចេតនា ការសង្រួម ការមិនល្មើសអទិន្នាទាន កាមេសុមិច្ឆាចារៈ មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាបៈ អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ( នីមួយៗ ) ជាសីល ។

ការលះកាមច្ឆន្ទៈដោយនេក្ខម្មៈ លះព្យាបាទដោយអព្យាបាទ ( គឺមេត្តា ) លះថីនមិទ្ធៈដោយអាលោកសញ្ញា លះឧទ្ធច្ចៈដោយការមិនរាយមាយ (ឯកគ្គតា) លះវិចិកិច្ឆាដោយធម្មវវត្ថាន (ការដាក់ចិត្តក្នុងធម៌) លះអវិជ្ជាដោយញាណ លះអរតិដោយបាមោជ្ជ លះនីវរណៈដោយបឋមជ្ឈាន លះវិតក្កវិចារដោយទុតិយជ្ឈាន លះបីតិដោយ

តតិយជ្ឈាន លះបង់សុខ និងទុក្ខដោយចតុត្ថជ្ឈាន និងរូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញាដោយអាកាសានញ្ចាយតនសមាបត្តិ លះអាកាសានញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ លះវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ លះអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ លះនិច្ចសញ្ញាដោយអនិច្ចានុបស្សនា លះសុខសញ្ញាដោយទុក្ខានុ-បស្សនា លះអត្តសញ្ញាដោយអនត្តានុបស្សនា លះនន្ទិដោយនិព្វិទា-នុបស្សនា ( អនុបស្សនាដែលប្រព្រឹត្តទៅដោយអាការនឿយណាយក្នុងសង្ខារ ) លះរាគៈដោយវិរាគានុបស្សនា ( អនុបស្សនាដែលប្រព្រឹត្តទៅដោយការលះបង់រាគៈ ) លះសមុទយៈដោយនិរោធានុបស្សនា ( សម្លឹងសង្ខារដែលរលត់ ) លះការប្រាថ្នាហួសកំណត់ដោយមុញ្ចិតុ-កម្មយតានុបស្សនា លះសេចក្ដីប្រកាន់ទុកដោយបដិនិស្សគ្គានុបស្សនា (អនុបស្សនាដែលប្រព្រឹត្តទៅដោយអាការលះសង្ខារ) លះឃនសញ្ញា ( ការសម្គាល់ថាដុំ ) ដោយខយានុបស្សនា ( សម្លឹងមើលសង្ខារសូន្យទៅ ) លះការប្រមូលយកទុក ដោយវយានុបស្សនា ( សម្លឹងមើលសង្ខារដែលវិនាស ) លះធុវសញ្ញា ( ការសម្គាល់ថា ឋឹងឋេរ ) ដោយវិបរិណាមានុបស្សនា ( សម្លឹងមើលសង្ខារដោយភាពប្រែប្រួល ) លះកិលេសដែលជានិមិត្តដោយអនិមិត្តានុបស្សនា លះកិលេសដែលជា

ទីតាំងដោយអប្បណិហិតានុបស្សនា លះអភិនិវេស ( អត្តានុទិដ្ឋិ ) ដោយសុញ្ញតានុបស្សនា លះការចុះចិត្តមាំដែលថាជាសារៈ ( ក្នុងវត្ថុដែលមិនមែនជាសារៈ ) ដោយអធិប្បញ្ញាធម្មវិបស្សនា ( ការឃើញច្បាស់នូវធម៌ដោយអធិប្បញ្ញា ) លះការចុះចិត្តមាំដោយអំណាចភាពល្ងង់ដោយយថាភូតញ្ញាណទស្សនៈ លះការចុះចិត្តមាំដោយអំណាចអាល័យដោយអាទីនវានុបស្សនា លះការមិនពិចារណា ( រកផ្លូវរួចផុត ) ដោយបដិសង្ខានុបស្សនា លះសេចក្តីចុះចិត្តមាំដោយអំណាចសំយោគដោយវិវដ្តានុបស្សនា លះកិលេសទាំងឡាយដែលមានទីតាំងរួមជាមួយទិដ្ឋិដោយសោតាបត្តិមគ្គ លះកិលេសយ៉ាងគ្រោតគ្រាតដោយសកទាគាមិមគ្គ លះកិលេសយ៉ាងល្អិតដោយអនាគាមិមគ្គ លះសព្វកិលេសដោយអរហត្តមគ្គ ( ទីមួយៗ ) ជាសីល, ការវៀរចាកចេតនា ការសង្រួម ការមិនល្មើស ( ចំពោះទោសនិងគុណទាំងឡាយនោះនីមួយៗ ) ជាសីល, សីលបែបនេះឯងប្រព្រឹត្តទៅដើម្បីការមិនក្តៅក្រហាយនៃចិត្តប្រព្រឹត្តទៅដើម្បីបាមោជ្ជ ដើម្បីបីតិ ដើម្បីបស្សទ្ធិ ដើម្បីសោមនស្ស ដើម្បីការរីកចម្រើន ( នូវសមាធិ ) ដើម្បីធ្វើសមាធិឲ្យចម្រើន ដើម្បីធ្វើឲ្យចម្រើន (នូវសមាធិ) ដើម្បីធម៌ជាគ្រឿងប្រដាប់ (នៃសមាធិ) ដើម្បីធម៌ដែលឧបត្ថម្ភ ( សមាធិ ) ដើម្បីធម៌ជាបរិវារ ( នៃសមាធិ ) ដើម្បីភាពពេញលេញ ( នៃសមាធិ ) ដើម្បីសេចក្តី

នឿយណាយណាយតែម្យ៉ាង ដើម្បីធ្វើឲ្យស្រោលស្ដើងនូវរាគៈ ដើម្បីសេចក្ដីរំលត់ ដើម្បីសេចក្ដីស្ងប់រំងាប់ ដើម្បីការដឹងវិសេស ដើម្បីការដឹងព្រម ដើម្បីនិព្វានដូច្នេះ ។

ក្នុងធម៌ ៥ ប្រការ មានបហានៈជាដើមនេះ ឈ្មោះថា ធម៌ណាៗ ដែលទ្រឹងហៅថា **បហានៈ** រមែងមិនមាន វៀរតែធម៌ គឺការមិនកើតឡើងនៃទោសមានបាណាតិបាតជាដើម ដូចដែលបានពោលហើយតែម្យ៉ាង តែព្រោះថា ការលះនោះៗ ពោលបានថា ជាការចូលទៅទ្រទ្រង់ទុក ព្រោះអត្ថថា ជាទីតាំងអាស្រ័យនៃកុសលធម៌នោះៗ និងជាការរួមយកទុក ព្រោះមិនធ្វើឲ្យខ្ចាត់ខ្ចាយ ( នៃកុសលធម៌នោះៗ ) ព្រោះហេតុនោះ ទើបលោកហៅថា សីល ព្រោះអត្ថថា ជាមូលដ្ឋាន ពោលគឺជាការចូលទៅទ្រទ្រង់ទុក និងរួបរួមទុក ដូចដែលបានពោលហើយខាងដើមនោះឯងធម៌៤យ៉ាងក្រៅពីនេះលោកសំដៅយកការប្រព្រឹត្តិទៅនៃចិត្តដោយវៀរចាកទោសនោះៗដោយការសង្រួមចំពោះទោសនោះៗ ផង ដោយចេតនាសម្បយុត្តក្នុងការវៀរចាក និងការសង្រួមទាំងពីរនោះផង ដោយការមិនល្មើសរបស់បុគ្គលដែលមិនកន្លងទោសនោះៗ ផង, ចំណែកអត្ថថា ធម៌ ៤ យ៉ាងនោះ ជាសីល ខ្ញុំម្ចាស់អធិប្បាយទុកខាងដើមហើយ ។ សីល ៥ យ៉ាង ជាបញ្ចសីល មានបហានសីលជាដើម គប្បីជ្រាបដោយប្រការដូច្នេះ ។

ឯការឆ្លើយបញ្ហាទាំងឡាយនេះ គឺអ្វីជាសីល ដែលហៅថាសីល ព្រោះអត្ថថា ដូចម្តេច អ្វីជាលក្ខណៈ ជារស ជាគ្រឿងប្រាកដ និងជាបទដ្ឋានរបស់សីលនោះ សីលមានអានិសង្សយ៉ាងណា និងសីលនោះមានប៉ុន្មានយ៉ាង ចប់ត្រឹមប៉ុណ្ណេះ ។

# មហាដីកា

## ពណ៌នាសីលពួក ៥ ទី ២

ដោយ **អាទិ**-ស័ព្ទ ( ប្រែថា ជាដើម ), ក្នុងពាក្យថា **បាណាតិ-បាតាទីនំ** ( នូវបាណាតិបាតជាដើម ) គប្បីជ្រាបថា រួមយកអទិន្នាទានជាដើមផង កិលេសដែលមគ្គថ្នាក់កំពូល ( អរហត្តមគ្គ ) គប្បីសម្លាប់ជាទីបំផុត ។ ដោយ អាទិ-ស័ព្ទ ក្នុងពាក្យថា **បហានាទិ** ( សីលមានការលះជាដើម ) គប្បីឃើញថា រួមយកសីល ៤ យ៉ាង មានវេរមណី ( ការវៀរចាក ) ជាដើម ។ ក្នុងគម្ពីរខ្លះចារទុកថា **បហានវសេន** ដោយអំណាចនៃការលះ, នោះជាការចារទុកឃ្លៀងឃ្លាត ។

ពាក្យថា ការលះបាណាតិបាតក៏ជាសីល មានន័យថា បាណាតិ-បាត ត្រូវលះទៅដោយកុសលចិត្តុប្បាទដែលមានហិរិឱត្តប្បៈ ករុណា អលោភៈជាដើម ជាប្រធានយ៉ាងណា នោះឈ្មោះថា **បហានៈ** ការលះបង់ ( ឬគ្រឿងលះបង់ ) បាណាតិបាតជាសីល ដោយអត្ថថា សង្រួម ។

ក្នុងន័យនេះដែរ ការវៀរចាកបាណាតិបាត ឈ្មោះថា **វេរមណីសីល** ។ ចេតនាជាបដិបក្ខចំពោះបាណាតិបាត ឈ្មោះថា ចេតនាសីល ។ ការសង្រួម គឺការការពារទ្វារដែលចូលទៅនៃបាណាតិបាត ឈ្មោះថា

សំវរសីល ។ ការមិនឈានកន្លងបាណាតិបាត ឈ្មោះថា អវីតិក្កម-សីល ។

សូម្បីក្នុងពាក្យថា **អទិន្នាទានស្ស** ជាដើម ក៏មានន័យដូចគ្នា ។

ចំណែកការលះ (បហានៈ) ធម៌ទាំងឡាយមានអភិជ្ឈា ជាដើម គប្បីជ្រាបថា ដោយអំណាចធម៌ មានអភិជ្ឈាជាដើម ។ វេរមណីចេតនា ដែលសម្បយុត្តជាមួយអនភិជ្ឈាជាដើម សំវរ និងអវីតិក្កម បានដល់ ធម៌ទាំងឡាយ (ដ៏សេស) មានអនភិជ្ឈានោះជាដើម ដែលជាប្រធាន ។

លោកអាចារ្យ កាលសម្ដែងបហានសីលជាដើម ដោយទាក់ទងជាមួយកុសលកម្មបទ ១០ យ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងសម្ដែងនូវបហានសីលជាដើមទាំងឡាយនោះ ដោយទាក់ទងជាមួយនឹងសមាបត្តិ ៨ ព្រមទាំងឧបាយដោយទាក់ទងជាមួយមហាវិបស្សនា ១៨និងទាក់ទងជាមួយអរិយមគ្គទាំងឡាយ ទើបផ្ដើមពាក្យថា នេក្ខម្មេន ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះពាក្យថា ដោយនេក្ខម្មៈ គឺ ដោយកុសលចិត្តុប្បាទ ដែលមានអលោភៈជាប្រធាន ។ ពិតហើយ កុសលធម៌ទាំងឡាយ ជាបដិបក្ខចំពោះកាម ព្រះសារីបុត្តត្រេរបំណង ពោលថា នេក្ខម្មៈ ក្នុងទីនេះ ព្រោះហេតុនោះ ទើបលោកពោលថា ការលះ កាមច្ឆន្ទៈ (ដោយនេក្ខម្មៈ) ក៏ជាសីល ដូច្នេះជាដើម ។ ក្នុង

ពាក្យទាំងឡាយនោះ គប្បីជ្រាបនូវសីល ៥ យ៉ាង មានបហានសីល ជាដើម តាមន័យដែលខ្ញុំម្ចាស់នឹងពោលក្នុងពេលក្រោយចុះ ។ ខ្ញុំម្ចាស់ សម្ដែងនូវសេចក្ដីប្លែកៗ ប៉ុណ្ណោះ ។

ពាក្យថា ដោយការមិនព្យាបាទ គឺដោយមេត្តា ។

ពាក្យថា ដោយអាលោកសញ្ញា គឺដោយការសម្គាល់ក្នុងពន្លឺ ដែលប្រាកដធ្វើឲ្យជាក់ច្បាស់ហើយ ធ្វើទុកក្នុងចិត្ត ។ ពាក្យថា ដោយ **អវិក្ខេប** គឺដោយសមាធិ ។ ពាក្យថា ដោយការកំណត់ធម៌ គឺដោយ ការវិនិច្ឆ័យតាមសេចក្ដីពិត នូវធម៌ទាំងឡាយមានកុសលជាដើម ។ អាចារ្យជាច្រើនពោលថា បានដល់ ការកំណត់នាមរូបព្រមទាំងបច្ច័យ ដូច្នេះក៏មាន ។

លោកអាចារ្យកាលសម្ដែងនូវសីលទាំងឡាយ មានបហាន សីលជាដើម ដោយអំណាចនៃបដិបទាដែលជាចំណែកខាងដើម ដែល ជាឧបាយឲ្យសម្រេចនូវគុណវិសេស មានបឋមជ្ឈានជាដើម ដែល ទ្រង់បានត្រាស់ទុកដោយពាក្យថា **អភិជ្ឈំ លោកេ បហាយ** លះអភិជ្ឈា ក្នុងលោក ដោយការលះនីវរណៈ មានកាមច្ឆន្ទៈជាដើមចេញបាន យ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងសម្ដែងទុកដោយអំណាចនៃ គុណវិសេស មានសមាបត្តិ ៨ ជាដើម ព្រមទាំងឧបាយ ទើបពោល ពាក្យថា **ញាណេន** ដូច្នេះជាដើម ។ ពិតហើយ អនិច្ចសញ្ញាជាដើម

តែងសម្រេចដល់ព្រះយោគីដែលតាំងនៅក្នុងញាតបរិញ្ញាបានក៏ដោយការធ្វើមោហៈ ដែលជាគ្រឿងបិទបាំងក្នុងការកំណត់នាមរូប និងការធ្វងសេចក្ដីសង្ស័យឲ្យនៅក្នុងទីឆ្ងាយ ។

ម្យ៉ាងទៀត ព្រះយោគីវចរ រមែងលះអរតិ ( ការមិនរីករាយ ) បានដោយបាមោជ្ជដែលជាហេតុនៃការរីករាយដ៏ក្រៃលែង ( អភិរតិ ) ក្នុងឈានសមាបត្តិទាំងឡាយ ។ កាលការមិនរីករាយក្នុងឈានសមា-បត្តិទាំងឡាយនោះត្រូវបន្ទោបង់ចេញហើយ ក៏មានការសម្រេចឈានជាដើមបាន ព្រោះហេតុនោះ សមាបត្តិ និងវិបស្សនា មានការបន្ទោបង់អរតិ និងការទម្លាយអវិជ្ជាជាដើមជាឧបាយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ការលះអវិជ្ជាដោយញាណ ការលះអរតិដោយបាមោជ្ជ** ដូច្នេះ ។ តែគប្បីឃើញថា លោកធ្វើពាក្យនិទ្ទេសធ្វងលំដាប់គ្នា ដើម្បីសម្ដែងនូវការសង្គ្រោះយកអវិជ្ជាដែលមានសភាពជានីវរណៈ ទុកក្នុងពួកនីវរណៈ នឹងសម្ដែងក្នុងពេលក្រោយ ។ ( បើធ្វើពាក្យនិទ្ទេសទុកតាមលំដាប់គ្នា ក៏នឹងឃើញថា ការលះអរតិដោយបាមោជ្ជ ការលះអវិជ្ជាដោយញាណ ) ។

ពាក្យថា **ការលះនីវរណៈទាំងឡាយដោយបឋមជ្ឈាន** ជាដើម សួរថា ឈានទាំងឡាយនឹងថាជាសីល បានដូចម្ដេច ? ឬថា ក្នុងឈានទាំងឡាយនោះ មានការកើតវិរតិ ( ធម្មជាតិដែលវៀរចាក ) បានយ៉ាង

ណា ? ព្រោះថា ឈានទាំងឡាយនេះ រមែងប្រព្រឹត្តទៅដោយអំណាចការតាំងមាំនៃចិត្តរបស់បុគ្គលដែលមានកាយកម្មជាដើម បរិសុទ្ធល្អហើយ មិនមែនប្រព្រឹត្តទៅដោយទាក់ទងជាមួយ ការជម្រះកាយកម្មជាដើម ឲ្យបរិសុទ្ធដូចកាមាវចរកុសលនោះទេ ទាំងមិនបានប្រព្រឹត្តទៅដោយទាក់ទងដល់ការកាត់ផ្តាច់ និងការស្ងប់រំងាប់ទុច្ចរិត ព្រមទាំងមិច្ឆាជីវៈដូចជាមគ្គធម៌ និងផលធម៌ទាំងឡាយនោះដែរ ? ឆ្លើយថា ការដែលពោលមកនេះត្រូវ, ក្នុងមហគ្គតធម៌ទាំងឡាយមិនមានសភាវៈដែលជាសីលនៈ ( សង្រួម គឺសភាវៈដែលចូលទៅទ្រទ្រង់ទុកសភាវៈដែលតាំងទុកដោយល្អ ) ដោយនិបរិយាយនោះទេ នឹងមានសភាវៈដែលត្រូវវៀរចាកពីត្រឹមណាទៅ តែគប្បីឃើញថា ពាក្យថា **ការលះនីវរណធម៌ទាំងឡាយដោយបឋមជ្ឈាន** ជាដើមនេះ លោកពោលទុកដោយបរិយាយ ។

ក៏បរិយាយនោះ គឺអ្វី គឺថា ពេលមហគ្គតកុសលទាំងឡាយលះធម៌ដែលជាបដិបក្ខ ហើយពេលនោះក៏ឈ្មោះថា វៀរចាកធម៌ដែលជាបដិបក្ខទាំងឡាយនោះ និងឈ្មោះថា សង្រួម ( ការពារបិទបាំង ) ទុក ដោយប្រការដែលធម៌ជាបដិបក្ខទាំងឡាយនោះឡើងកាន់ចិត្តមិនបាន ។ ឈ្មោះថា **អវីតិក្កម** ព្រោះអត្ថថា មិនមានការឈានកន្លងផ្លូវមនោទ្វារ ពោល គឺកិលេសរុំព័ទ្ធ, ចំណែកចេតនាក៏បាន ដល់ចេតនា

ដែលសម្បយុត្តជាមួយមហគ្គតធម៌ទាំងឡាយនោះឯង ។ អត្ថាធិប្បាយនេះនោះ នឹងមកដល់ខាងមុខ ។ សូម្បីពាក្យថា ការលះវិតក្កជាដើមក៏ជាការប្រើបាន ព្រោះធ្វើអធិប្បាយយ៉ាងនេះ ។ ព្រោះថា ដោយនិប្បរិយាយ សីលជាអ្នកលះកុសលធម៌ទាំងឡាយមិនត្រឹមត្រូវទេ, ឯក្នុងអធិការនេះ លោកក៏មិនបាន បំណងយកធម៌មានវិតក្កជាដើមដែលជាអកុសល ។

ការលះទុក្ខ រមែងមានបានក្នុងឧបចារៈនៃបឋមជ្ឈាននោះឯង និងការលះសុខរមែងមានបានក្នុងឧបចារៈនៃចតុត្ថជ្ឈានក៏ពិត, សូម្បីយ៉ាងនោះ លោកសំដៅយកការលះយ៉ាងពិតប្រាកដ ទើបពោលថា ការលះសុខ និងទុក្ខដោយចតុត្ថជ្ឈាន ដូច្នេះ ។ ក្នុងពាក្យថា **ការលះរូបសញ្ញា ។បេ។ ដោយអាកាសានញ្ចាយតនសមាបត្តិ** ជាដើម មានពាក្យដែលគួរអធិប្បាយយ៉ាងណា ពាក្យនោះនឹងមកក្នុងកថាពោលដោយអរូបកម្មដ្ឋាន ។

ការតាមពិចារណាឃើញនូវវត្ថុដែលមិនទៀង ឬតាមពិចារណាឃើញថា មិនទៀងឈ្មោះថា **អនិច្ចានុបស្សនា** ។ ពាក្យថា **អនិច្ចានុ-បស្សនា** នេះ ជាឈ្មោះរបស់វិបស្សនាដែលប្រព្រឹត្តទៅកាន់យកភាពជារបស់មិនទៀងនៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

ពាក្យថា **ការលះនិច្ចសញ្ញា** គឺការលះបង់ការសម្គាល់ខុស

ដែលប្រព្រឹត្តទៅយ៉ាងនេះថា សង្ខារធម៌ទាំងឡាយ ទៀង យឺនយូរ ដូច្នេះ ។

គប្បីឃើញថា កាន់យកទាំងទិដ្ឋិ និងចិត្ត ដោយស័ព្ទថា សញ្ញា នោះឯង ។

សូម្បីក្នុងពាក្យនិយាយក្រៅពីនេះ ក៏មានន័យដូចនេះ ។ ពាក្យថា ដោយនិព្វិទានុបស្សនា គឺដោយអនុបស្សនាដែលប្រព្រឹត្តទៅដោយអាការនឿយណាយ ក្នុងសង្ខារទាំងឡាយ ។ ពាក្យថា ( ការលះ ) នន្ទិ គឺ ( ការលះ ) តណ្ហាដែលប្រកបដោយបីតិ ។

ពាក្យថា ដោយវិរាគានុបស្សនា គឺដោយអនុបស្សនាដែលប្រព្រឹត្តទៅ ដោយការលះបង់រាគៈ ។ ពាក្យថា ( ការលះ ) រាគៈ គឺ ( ការលះ ) សេចក្តីស្រឡាញ់ក្នុងសង្ខារទាំងឡាយ ។

ពាក្យថា ដោយនិរោធានុបស្សនា គឺដោយការតាមពិចារណាឃើញនូវការរលត់ទៅនៃសង្ខារទាំងឡាយ ។ម្យ៉ាងទៀត ការតាមពិចារណាឃើញសង្ខារទាំងឡាយ រមែងរលត់ទៅតែម្យ៉ាង រមែងមិនកើតឡើងដោយអំណាចនៃភពថ្មីតទៅទៀត ឈ្មោះថា និរោធានុបស្សនា ។

ព្រោះហេតុនោះ ទើបព្រះសារីបុត្តត្ថេរ ពោលទុកថា **និរោធានុបស្សនាយ និរោធេតិ នោ សមុទេតិ** រមែងធ្វើឲ្យរលត់ទៅ មិនមែន

ធ្វើឲ្យកើតឡើងដោយនិរោធានុបស្សនាដូច្នេះ ។ និរោធានុបស្សនានេះ ដល់នូវភាពមានកម្លាំង ដោយមុញ្ចិតុកម្យតាញាណ ( ក្នុង **គម្ពីរបរមត្ថទីបនី** ( ច្បាប់ថៃ ) ពោលថា គម្ពីរវិសុទ្ធិមគ្គច្បាប់ថៃ ប្រើពាក្យថា **មុញ្ចិតុកម្យតាញាណ** ខុសគោលភាសា ត្រូវប្រើពាក្យ **មុញ្ចិតុ-កម្យតាញាណ** វិញ ។ ពាក្យថា **មុញ្ចិចិតុ** មកពី **មុញ្ចិតុំ** ប្រែថា បណ្តោត, ពាក្យថា **មច្ចិតុ** មកពី **មុច្ចិតុំ** ប្រែថា រួចផុត ។ សេចក្តីអធិប្បាយមានក្នុង **គម្ពីរបរមត្ថទីបនី** បណ្ឌិតគប្បីពិចារណាចុះ ) ។ អនុបស្សនា ដែលប្រព្រឹត្តទៅដោយការលះនូវសង្ខារទាំងឡាយនោះ ឯងឈ្មោះថា **បដិនិស្សគ្គានុបស្សនា** ។

ឯបដិនិស្សគ្គានុបស្សនានេះ បានដល់ បញ្ញាដែលពិចារណា ហើយព្រងើយកន្តើយ ។

ពាក្យថា ( ការលះ ) សេចក្តីប្រកាន់ ( អាទាន ) បានដល់ ( ការលះ ) សេចក្តីប្រកាន់ដែលទាក់ទងថា ជារបស់ទៀងជាដើម ។ ការប្រកាន់ដោយសភាពជារបស់តែមួយដោយអំណាចនៃការបន្តគ្នា ការរួមគ្នា កិច្ច និងអារម្មណ៍ ឈ្មោះថា **ឃនសញ្ញា** បានដល់ ( ការលះ ) ឃនសញ្ញានោះ ។

ពាក្យថា ( ការលះ ) សេចក្តីខ្វល់ខ្វាយ ( អាយូហន ) បានដល់ ( ការលះ ) ការតាក់តែង ។ ការដែលសង្ខារទាំងឡាយដល់នូវអាការ

ប្រែប្រួលទៅ មានអាការដែលឋិតថេរមិនបាន ឈ្មោះថា **វិបរិណាម** ។

ពាក្យថា ( ការលះ ) ការសម្គាល់ថាមាំទាំ ( ធុវសញ្ញា ) បានដល់ ( ការលះ ) សេចក្ដីប្រកាន់ថា ជារបស់មាំទាំ ។ ពាក្យថា ( ការលះ ) និមិត្ត បានដល់ ការលះសេចក្ដីប្រកាន់ខុសនូវសង្ខារទាំងឡាយ ដែលទាក់ទងនឹង ឃន ( ភាពជាដុំ ) មានសមូហឃនៈជាដើម និងដោយការកំណត់តាមកិច្ចរបស់ខ្លួន ។

ពាក្យថា ( ការលះ ) **បណិធិ** បានដល់ ( ការលះ ) **បណិធិ** មានរាគៈជាដើម មានន័យថា ( ការលះ ) ភាវៈដែលមានចិត្តបង្អោនទៅកាន់សង្ខារទាំងឡាយ ដោយអំណាចតណ្ហា ។ ពាក្យថា ( ការលះ ) ការប្រកាន់មាំ ( អភិនិវេស ) បានដល់ ( ការលះ ) អត្តានុទិដ្ឋិ ។ ការពិចារណាធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ដោយជារបស់មិនទៀង ជាទុក្ខជាដើម ឈ្មោះថា អធិប្បញ្ញាធម្មវិបស្សនា ។

ពាក្យថា ( ការលះ ) សេចក្ដីប្រកាន់មាំដោយការប្រកាន់ថាជាសារៈ បានដល់ លះបង់សេចក្ដីឃើញខុសដោយការប្រកាន់ថា ជាសារៈក្នុងសង្ខារទាំងឡាយ ដែលមិនមានសារៈ ។ ឈ្មោះថា **យថាភូតញ្ញាណទស្សន** បានដល់ អនុបស្សនា មានអនិច្ចានុបស្សនាជាដើម ដែលដល់នូវភាពមាំទាំហើយនោះឯង ។ អាចារ្យពួកខ្លះពោលថា បានដល់ **ឧទយព្វយញ្ញាណ** ។ អាចារ្យមួយពួកទៀតពោលថា បានដល់

ញាណទី ៦ ឃើញនាមរូបព្រមទាំងបច្ច័យ ។ សេចក្តីប្រកាន់មាំថា លោកកើតឡើងព្រមហើយ ដោយអំណាចនៃព្រះឥស្វរៈសាងឡើង ជាដើម ឈ្មោះថា ការប្រកាន់មាំដោយសេចក្តីវង្វេង ( សម្មោហាភិនិ- វេស ) ។ អាចារ្យពួកខ្លះពោលថា បានដល់ការប្រកាន់មាំថាដាច់សូន្យ ថាទៀង ។ អាចារ្យមួយពួកទៀតពោលថា ការដល់នូវការសង្ស័យ ដែលប្រព្រឹត្តទៅក្នុងន័យថា **អហោសឹ នុ ខោ អហំ អតីតមទ្ធានំ** ក្នុង កាលជាអតីតយើងបានកើតហើយ ឬហ្ន៎ ! ដូច្នេះជាដើម ឈ្មោះថា ការប្រកាន់ដោយអំណាចនៃការវង្វេង ។ការប្រកាន់ដោយការប្រយុទ្ធ តទល់ដ៏ក្តៅក្នុងសង្ខារទាំងឡាយ ឈ្មោះថា ការប្រកាន់ដោយសេចក្តី អាល័យ ( អាលយាភិនិវេស ) ។ តណ្ហា ឈ្មោះថា អាល័យ ព្រោះ មានពាក្យនិយាយថា **អាលយរតា អាលយសម្មុទិតា** ជាប់ជំពាក់ ហើយ ព្រោះអាល័យរីករាយ ហើយព្រោះអាល័យដូច្នេះ ។ អាចារ្យ មួយពួកទៀតពោលថា តណ្ហានោះឯង ឈ្មោះថា **អាលយាភិនិវេស** ព្រោះប្រព្រឹត្តទៅដោយអំណាចសេចក្តីប្រកាន់ក្នុងទ្វារទាំងឡាយ មាន ចក្ខុទ្វារជាដើម និងក្នុងអារម្មណ៍ទាំងឡាយមានរូបជាដើម ដូច្នេះ ។

ញាណដែលបានដឹងថាសង្ខារដែលតាំងនៅយ៉ាងនេះនោះរមែង ត្រូវលះបង់ទៅ ឈ្មោះថា **បដិសង្ខានុបស្សនា** ។

ឈ្មោះថា ការមិនពិចារណា បានដល់ អកុសលធម៌ទាំងឡាយ

ដែលមានមោហៈជាបទដ្ឋានជាបដិបក្ខដល់ការពិចារណា ។ព្រះនិព្វាន ឈ្មោះថា វិវដ្ដៈ ព្រោះទៅប្រាសចាកវដ្ដៈ ការប្រព្រឹត្តិទៅដោយការតាមពិចារណាឃើញ ពោល គឺភាពជាអ្នកមានចិត្តបង្អោនទៅក្នុងវិវដ្ដៈនោះ ឈ្មោះថា វិវដ្ដានុបស្សនា បានដល់ សង្ខារុបេក្ខាញាណ និងអនុ-លោមញ្ញាណ ។ឈ្មោះថា សេចក្ដីប្រកាន់មាំដោយសំយោគ បានដល់ការប្រកាន់មាំក្នុងសង្ខារទាំងឡាយដោយអំណាចនៃការប្រកប ។

ពាក្យថា ដែលមានទីតាំងតែមួយជាមួយទិដ្ឋិ គឺដែលមានទីតាំងជាមួយគ្នាកើតព្រមគ្នាជាមួយទិដ្ឋិ និងមានទីតាំងតែមួយជាមួយគ្នាដោយការលះបង់ ( ព្រមជាមួយទិដ្ឋិ ) ។ ពាក្យថា ( កិលេសទាំងឡាយ ) ដែលគ្រោតគ្រាត លោកពោលប្រៀបធៀបជាមួយកិលេសទាំងឡាយដែលត្រូវសម្លាប់ដោយមគ្គជាន់លើ ។ បើកាន់យកដោយប្រការដទៃ កិលេសទាំងឡាយដែលទស្សនៈ ( សោតាបត្តិមគ្គ ) គប្បីលះបង់ ក៏ឈ្មោះថា គ្រោតគ្រាតជាងកិលេសដែលមគ្គទី ២ ( សកទា-គាមិមគ្គ ) គប្បីលះ ។ បទថា **អណុសហគតានំ** ប្រែថា យ៉ាងល្អិត ពាក្យនេះ លោកពោលប្រៀបធៀបជាមួយកិលេសដែលត្រូវសម្លាប់ដោយមគ្គជាន់ក្រោម ។

ពាក្យថា កិលេសទាំងឡាយទាំងពួង បានដល់ កិលេសទាំងឡាយដែលនៅសល់ ។ព្រោះថាកិលេសទាំងឡាយដែលមគ្គ ៣ មាន

បឋមមគ្គជាដើម លះបង់បានហើយ អរហត្តមគ្គមិនត្រូវលះទៀតទេ ។

ពាក្យថា រមែងប្រព្រឹត្តទៅព្រមដើម្បីការមិនក្តៅក្រហាយនៃចិត្ត ជាដើម មានន័យថា សីល រមែងមានដើម្បីជាប្រយោជន៍ដល់ការមិន ក្តៅក្រហាយនៃចិត្ត ព្រោះមានពាក្យនិយាយថា **សំវរោ អវិប្បដិសា-រត្ថាយ** សំវររមែងមានដើម្បីប្រយោជន៍ដល់ការមិនក្តៅក្រហាយចិត្ត និងថា **អវិប្បដិសារត្ថានិ ខោ អានន្ទ កុសលានិ សីលានិ** ម្នាលអានន្ទ កុសលសីលទាំងឡាយ មានការមិនក្តៅក្រហាយចិត្តជាប្រយោជន៍ ដូច្នេះ ។

ឈ្មោះថា រមែងប្រព្រឹត្តទៅព្រមដើម្បីបាមោជ្ជ ព្រោះមានពាក្យ ថា **អវិប្បដិសារោ បាមុជ្ជត្ថាយ ។ យោនិសោ មនសិការោតោ បាមុជ្ជំ ជាយតិ** ការមិនក្តៅក្រហាយចិត្ត រមែងប្រព្រឹត្តទៅព្រមដើម្បីប្រយោជន៍ ដល់បាមោជ្ជ ។ កាលមនសិការដោយឧបាយត្រូវទំនងបាមោជ្ជ រមែង កើតឡើងដូច្នេះ ។ ឈ្មោះថា រមែងប្រព្រឹត្តទៅព្រមដើម្បីបីតិ ព្រោះ មានពាក្យសម្តែងថា **បាមុជ្ជំ បីតិយា ។ បមុទិតស្ស បីតិ ជាយតិ** បាមោជ្ជប្រព្រឹត្តទៅដើម្បីបីតិ ។ បុគ្គលអ្នកមានចិត្តត្រជាក់រមែងកើត បីតិដូច្នេះ ។ ឈ្មោះថា រមែងប្រព្រឹត្តទៅព្រម ដើម្បីបស្សទ្ធិ ព្រោះមាន ពាក្យសម្តែងថា **បីតិ បស្សទ្ធាយ ។ បីតិមនស្ស កាយោ បស្សម្ភតិ** បីតិរមែងប្រព្រឹត្តទៅ ព្រមដើម្បីបស្សទ្ធិ, កាយរបស់បុគ្គលមានចិត្ត

ប្រកបដោយបីតិ រមែងស្ងប់រំងាប់ដូច្នេះ ។ ឈ្មោះថា រមែងប្រព្រឹត្តទៅព្រមដើម្បីសោមនស្ស ព្រោះមានពាក្យសម្ដែងថា **បស្សទ្ធិ សុខត្ថាយ ។ បស្សទ្ធកាយោ សុខំ វេទយតិ** បស្សទ្ធិរមែងប្រព្រឹត្តទៅព្រម ដើម្បីប្រយោជន៍សុខ បុគ្គលដែលមានកាយស្ងប់រំងាប់ហើយ រមែងសោយសុខដូច្នេះឯង ។

ក្នុងពាក្យថា ដើម្បីប្រយោជន៍ដល់សុខ រមែងសោយសុខ ដូច្នេះនេះ ទ្រង់ត្រាស់ចំពោះសោមនស្សថា សុខ ។ ពាក្យថា ដើម្បីអាសេវន គឺដើម្បីអាសេវនៈនៃសមាធិ ។ សេចក្ដីថា ពិតហើយកាលសុខដែលមិនមានអាមិសសម្រេចហើយ សមាធិក៏សម្រេចដូចគ្នា ព្រោះមានពាក្យសម្ដែងថា **សុខិនោ ចិត្តំ សមាធិយតិ** ចិត្តរបស់អ្នកមានសុខរមែងតាំងមាំដូច្នេះ ។ ព្រោះដូច្នោះ ទើបមានការសម្គាល់ថា សីលប្រព្រឹត្តទៅព្រម ដើម្បីអាសេវនៈ គឺដើម្បីភាពរហ័ស រហួន និងមានកម្លាំងនៃសមាធិ ។ ពាក្យថា **ដើម្បីភាវនា** គឺដើម្បីសេចក្ដីចម្រើននៃសមាធិនោះឯង ។

ពាក្យថា ដើម្បីការធ្វើឲ្យច្រើនគឺដើម្បីការធ្វើរឿយៗ ។ពាក្យ ថា ដើម្បីធម៌ដែលជាគ្រឿងប្រដាប់ គឺរមែងប្រព្រឹត្តទៅព្រម គឺដើម្បីធម៌ដែលជាគ្រឿងតាក់តែង ដោយការបង្កើតឡើងនូវគុណ មានសទ្ធិន្ទ្រិយ៍ជាដើម ដែលជាគ្រឿងប្រដាប់របស់សមាធិនោះឯង ។

ពាក្យថា ដើម្បីបរិក្ខារ គឺរមែងប្រព្រឹត្តទៅព្រម ដើម្បីជាបរិក្ខារនៃសមាធិនោះឯង ដោយការសម្រេចនៃធម៌ដែលជាសម្ភារៈ ( អង្គប្រកប ) របស់សមាធិ មានអវិប្បដិសារៈ ( ការមិនក្ដៅក្រហាយចិត្ត ) ជាដើម ។

ព្រោះថា ស័ព្ទថា បរិក្ខារ ក្នុងទីនេះ មានសេចក្ដីសម្គាល់ថា សម្ភារៈ ។ ឯបច្ច័យ គប្បីជ្រាបថា ឈ្មោះថា សម្ភារៈ ដូចក្នុងប្រយោគថា **យេ ចេ ឥមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា** បរិក្ខារ ( គឺសម្ភារៈ បានដល់ បច្ច័យ ) នៃជីវិត ដែលបព្វជិតគប្បីស្វែងរកមក ដូច្នេះជាដើម ។

ស័ព្ទថា បរិក្ខារ លោកពោលថា មានអត្ថថា ជាគ្រឿងប្រដាប់ ដូចក្នុងប្រយោគថា **រថោ សីលបរិក្ខារោ** រថ មានសីលជាបរិក្ខារជាដើមក៏បាន, មានអត្ថថា **បរិវារ** ( គ្រឿងចោមរោម ) ដូចក្នុងប្រយោគថា **សត្តហិ នគរបរិក្ខារេហិ សុបរិក្ខិត្តំ ហោតិ** នគរដែលហុំព័ទ្ធល្អ ហើយដោយបរិក្ខារនគរ ៧ យ៉ាង ដូច្នេះជាដើមក៏បាន ។ តែក្នុងទីនេះដែលពោលបានថា មានអត្ថថា សម្ភារៈ ( គឺបច្ច័យ ) ព្រោះជាគ្រឿងប្រដាប់ និងបរិវារ លោកកាន់យកម្យ៉ាងៗ ផ្សេងៗ គ្នា ។ ពាក្យថា ដើម្បីបរិវារ គឺរមែងប្រព្រឹត្តទៅដើម្បីបរិវារសម្បត្តិ ដោយឲ្យសម្រេចធម៌វិសេសមានសតិ វីរិយៈជាដើម ដែលជាបរិវាររបស់សមាធិ ព្រោះ

ជាមូលហេតុនោះឯង ។ ពាក្យថា ដើម្បីភាពបរិបូរណ៍ គឺរមែងប្រព្រឹត្តទៅព្រម ដើម្បីភាពបរិបូរណ៍នៃសមាធិ ដោយឲ្យសម្រេចភាពបរិបូរណ៍ គឺការឲ្យសម្រេចវសីភាព និងឲ្យដល់នូវភាពជាបទដ្ឋាននៃវិបស្សនា ។

លោកអាចារ្យ កាលសម្តែងសមាធិដែលមានភាពបរិសុទ្ធិល្អ ជាមូលដែលមានភាពបរិបូរណ៍ដោយអាការទាំងពួងយ៉ាងនេះហើយ ឥឡូវនេះបំណងនឹងសម្តែងនូវប្រយោជន៍ទាំងឡាយដែលមានសីល ជាមូលមានសមាធិជាបទដ្ឋាន ដោយព្រះបាលីថា **សមាហិតោ បជានាតិ បស្សតិ ។បេ។ វិរតា វិមុច្ចតិ** បុគ្គលដែលមានចិត្តតាំងមាំរមែងដឹង រមែងឃើញ កាលដឹង កាលឃើញ តាមសេចក្តីពិត ក៏រមែងនឿយណាយ កាលនឿយណាយរមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តក៏រួចផុត ទើបពោលថា **ដើម្បីសេចក្តីនឿយណាយតែម្យ៉ាង** ដូច្នេះជាដើម ។

ពិតហើយ កាលលោកបានសម្តែងនូវ **និព្វិទា** ( ការនឿយណាយ ) ហើយ **យថាភូតញ្ញាណទស្សន** ( ការឃើញ គឺការដឹងតាមសេចក្តីពិត) ដែលជាបទដ្ឋាននៃនិព្វិទាញាណនោះក៏លោកបានសម្តែងហើយ ព្រោះកាលបើយថាភូតញ្ញាណទស្សនៈនោះ មិនមាននិព្វិទាក៏សម្រេចមិនបាន ។ លោកអាចារ្យចែកធម៌ទាំងឡាយ មាននិព្វិទាជាដើម ដោយសភាវៈតែម្យ៉ាង ។ ពាក្យថា **យថាភូតញ្ញាណទស្សន**

ក្នុងទីនេះសំដៅយកការឃើញនាមរូបព្រមទាំងបច្ច័យ ។ គប្បីជ្រាប ថា ក្នុងអធិការនេះ លោកអាចារ្យសម្ដែងនូវប្រយោជន៍របស់សីល ដែលមានអមតមហានិព្វានជាទីបំផុត ទុកដូចដែលបានពោលមកនេះ។

ឥឡូវនេះ លោកអាចារ្យសម្ដែងសភាវៈដែលជាសីល ក្នុងធម៌ ទាំងឡាយ មានបហានៈជាដើម ទើបផ្ដើមពាក្យថា **ឯត្ថ ច** ដូច្នេះ ជាដើម ។ ក្នុងធម៌ទាំងឡាយនោះ ការលះ បានដល់ ការរលត់ គឺ មិនកើតឡើង ឈ្មោះថា បហានៈ, ព្រោះហេតុនោះ លោកសំដៅយក ភាពជាភាវសាធនៈនៃបហានៈនោះ ( គឺឲ្យប្រែថា ការលះ ) ទើប ពោលថា ឈ្មោះថា ធម៌ណាៗ ហៅថា **បហានៈ** មិនមាន ដូច្នេះ ។ ម្យ៉ាងទៀត បហានៈនោះមានការឃើញធម៌ ក៏ដោយប្រការនៃពាក្យ របស់ខ្ញុំម្ចាស់បានសំវណ្ណនានៅពេលក្រោយនោះឯង ។

ពិតហើយ ការលះនោះជាសីល រមែងសមគួរល្អ ដូចដែលបាន ពោលហើយ ។

ពាក្យថា ការលះនោះៗ បានដល់ ការលះដែលបានពោលទុក យ៉ាងនេះថា ការលះបាណាតិបាត ការលះអទិន្នាទានជាដើមនោះៗ ។ ពាក្យថា នៃកុសលធម៌នោះៗ គឺនៃកុសលធម៌នោះៗ យ៉ាងនេះ គឺការ លះបាណាតិបាត ជាការចូលទៅទ្រទ្រង់ទុកដោយអត្ថថា ជាទីតាំង នៃកុសលធម៌ មានមេត្តាជាដើម, ការលះអទិន្នាទាន ជាការចូលទៅ

ទ្រទ្រង់ទុក ដោយអត្ថថា ជាទីតាំងនៃកុសលធម៌មានចាគៈជាដើម ។ ពាក្យថា ដោយអត្ថថាជាទីតាំងគឺដោយភាពជាទីតាំង ។លោកអាចារ្យ ធ្វើទុកក្នុងចិត្តថា ពិតហើយ កុសលធម៌នោះមានការលះ ទើបមាន បាន កាលកុសលធម៌នោះមិនមាន ការលះក៏មិនមាន ការលះនោះ ទើបបាននូវភាវៈដែលគួរនឹងពោលបានថា ជាទីតាំងនៃកុសលធម៌នោះ ដូច្នេះ ហើយទើបពោលដល់ការលះបាណាតិបាតជាដើមនោះថា ជាការតាំងទុកដោយល្អ ដោយមិនធ្វើឲ្យញាប់ញ័រ ( ក្នុងវិសុទ្ធិមគ្គ ដោយមិនធ្វើសេចក្ដីឲ្យខ្វាត់ខ្វាយ ) ព្រោះអត្ថថា ធម៌ទាំងឡាយ មាន បាណាតិបាតជាដើម មានក្នុងសន្តានណា ក៏ជាហេតុឲ្យញាប់ញ័រនៃ សន្តាននោះ ។ សូម្បីក្នុងការលះធម៌ដ៏សេស ក៏មានពាក្យដែលគួរ ពោលយ៉ាងនេះ ។ ឈ្មោះថា ការតាំងចិត្តទុកដោយល្អ បានដល់ ការ តាំងចិត្តទុកដោយប្រពៃ ឬបានដល់ ការសន្រ្ទួម ។

ពាក្យថា ធម៌ ៤ យ៉ាងក្រៅពីនេះ អធិប្បាយថា ធម៌ ៤ យ៉ាង មានវេរមណី ( ការវៀរចាក ) ជាដើម ។ មិនមែនត្រឹមតែបញ្ញត្តិ ដូច ជា **បហានៈ** ( ការលះ ) ទេ ។

ពាក្យថា ចាកទោសនោះៗ គឺចាកទោស មានបាណាតិបាតជា ដើមនោះ ។

ពាក្យថា (ដោយអំណាចនៃការសន្រ្ទួម) ទោសនោះៗ គឺដោយ

អំណាចនៃការការពារទោស មានបាណាតិបាតជាដើម ឬដោយ
អំណាចនៃការសម្រួមនោះៗ ។ ពាក្យថា ដោយអំណាចចេតនាដែល
សម្បយុត្តដោយការវៀរចាក និងការសម្រួមទាំង ២ នោះ គឺដោយ
អំណាចនៃចេតនាដែលសម្បយុត្តជាមួយការវៀរចាកទាំងឡាយ ព្រម
ទាំងសំវរធម៌ទាំងឡាយ ។

ពាក្យថា នៃបុគ្គលដែលមិនឈានកន្លងទោសនោះៗ មានន័យ
ថា ធម៌ ៤ យ៉ាងក្រៅពីនេះ ឈ្មោះថា លោកពោលសំដៅយកភាវៈ
ដែលមាននៅនៃការប្រព្រឹត្តិទៅរបស់ចិត្តដោយអំណាចនៃបុគ្គលអ្នក
មិនឈានកន្លងទោស មានបាណាតិបាតជាដើមនោះៗ ឬនៃប្រជុំធម៌
ព្រោះដូច្នោះ ទើបមានអធិប្បាយថា រមែងរកបាន សូម្បីក្នុងខណៈ
តែមួយជាមួយគ្នា ។

( ចប់ មហាដីកា )

## ភាពសៅហ្មង និងភាពផូរផង់នៃសីល

ចំណែកបញ្ហាកម្មដែលថា អ្វីជាភាពសៅហ្មង និងអ្វីជាភាពផូរផង់របស់សីលនោះ ខ្ញុំម្ចាស់នឹងពោលដល់បញ្ហាកម្មនោះដូចតទៅ ការដាច់សីលជាដើម ជាភាពសៅហ្មងរបស់សីល សីលមិនដាច់ជាដើម ជាភាពផូរផង់របស់សីល ។

## ភាពសៅហ្មងនៃសីល

ឯការដាច់សីលជាដើមនោះ លោកសង្គ្រោះយកការបែកធ្លាយ (នៃសីល) ដែលមានលាភ និងយសជាដើម ជាហេតុម្យ៉ាង ១ ដោយមេថុនសំយោគ ៧ ប្រការ ជាហេតុម្យ៉ាង ១ ។

ពិតហើយ សិក្ខាបទក្នុងចំណែកខាងដើម ឬក្នុងចំណែកខាងចុងក្នុងអាបត្តិ ទាំង ៧ កង របស់ភិក្ខុណាទម្លាយហើយ សីលរបស់ភិក្ខុនោះ ឈ្មោះថា ជាសីលដាច់ ដូចសំពត់ដាច់ជាយដូច្នោះ, ចំណែកសិក្ខាបទរបស់ភិក្ខុណាទម្លាយក្នុងចំណែកកណ្តាល សីលរបស់ភិក្ខុនោះឈ្មោះថា សីលធ្លុះ ដូចជាសំពត់ដែលធ្លុះនៅត្រង់កណ្តាលដូច្នោះ, សិក្ខាបទរបស់ភិក្ខុណាធ្លាយ ២-៣ សិក្ខាបទ ទៅតាមលំដាប់ សីលរបស់ភិក្ខុនោះ ឈ្មោះថា ជាសីលពពាល ដូចមេគោដែលខ្លួន មាន

ពណ៌ក្រហម ឬខ្មៅយ៉ាងណាមួយ មានពណ៌ចំរុះគ្នាខាងមុខ ខាងក្រោយ និងនៅត្រង់ពោះខ្វះដូច្នោះ, សីលរបស់ភិក្ខុណាធ្លាយខ្ទេចខ្ទីសីលរបស់ភិក្ខុនោះ ឈ្មោះថា សីលពព្រុស ដូចជាមេគោដែលមានខ្នងលាយទៅដោយពណ៌ចំរុះដូច្នោះសីលដាច់ជាដើមដោយការបែកធ្លាយ(នៃសីល)ដែលមានលាភជាដើមហេតុរមែងមានដោយប្រការដូច្នេះឯង ។

## មេថុនសំយោគ ៧

( ចំណែកសីលដាច់ជាដើម ) ដោយអំណាចមេថុនសំយោគ ៧ គប្បីជ្រាបដូចតទៅនេះ

ពិតហើយ ព្រះមានព្រះភាគត្រាស់ទុក ( ក្នុងមេថុនសំយោគ-សូត្រនោះ ) ថា

១-ម្នាលព្រាហ្មណ៍ សមណៈក្តី ព្រាហ្មណ៍ក្តី បុគ្គលណាមួយក្នុងលោកនេះប្តេជ្ញា ( ខ្លួនថា ) ជាព្រហ្មចារីពិតៗ បានដោយការប្រកបកិរិយាដែលបុគ្គលនៅពីរនាក់ ហើយគប្បីនៅជាមួយមាតុគ្រាម មិនមែនជាឋានៈទេ, ព្រោះនៅរីករាយដោយការថ្នាក់ថ្នម ការខាត់ពណ៌ ការឲ្យងូតទឹក ការគក់ប្រេបាច់នៃមាតុគ្រាមដែលគេរីករាយស្រឡាញ់ និងដល់នូវការសប្បាយចិត្តដោយការបម្រើ មានការថ្នាក់ថ្នមជាដើម

នោះ ម្នាលព្រាហ្មណ៍ សូម្បីការរីករាយ ការបម្រើនៃមាតុគ្រាមនោះ រាប់ថាជាការដាច់ក៏បាន ធ្លុះក៏បាន ពពាលក៏បាន ពព្រុសក៏បាននៃព្រហ្មចរិយៈរបស់សមណព្រាហ្មណ៍នោះ ម្នាលព្រាហ្មណ៍ សមណព្រាហ្មណ៍នោះ តថាគតហៅថា គេប្រព្រឹត្តព្រហ្មចរិយៈមិនបរិសុទ្ធ ប្រកបដោយមេថុនសំយោគ រមែងមិនរួចផុតចាកជាតិ ជរា មរណៈ ។ល។ តថាគតពោលបានថា គេមិនអាចរួចផុតចាកទុក្ខបានឡើយ ។

២-ម្នាលព្រាហ្មណ៍ សេចក្ដីដទៃនៅមានទៀត សមណៈក្ដី ព្រាហ្មណ៍ក្ដី បុគ្គលណាមួយក្នុងលោកនេះក្ដី ដែលប្ដេជ្ញា (ខ្លួនថា) ជាព្រហ្មចារីពិតៗបានដោយការប្រកបកិរិយាដែលបុគ្គលនៅពីរនាក់ ហើយគប្បីនៅជាមួយមាតុគ្រាម មិនមែនជាឋានៈទេ, ទាំងសូម្បី (មិនដល់) នូវការរីករាយថ្នាក់ថ្នម ។ល។ នៃមាតុគ្រាម តែថា នៅសើចចំអកលេងកំប្លែងលេងជាមួយមាតុគ្រាម គេរីករាយ ដោយការសើចចំអកជាដើមនោះ ។ល។ តថាគតហៅថា គេរមែងមិនរួចផុតចាកទុក្ខបានឡើយ ។

៣-ម្នាលព្រាហ្មណ៍ សេចក្ដីដទៃនៅមានទៀត សមណៈក្ដី ព្រាហ្មណ៍ក្ដី បុគ្គលណាមួយក្នុងលោកនេះក្ដី ប្ដេជ្ញា (ខ្លួនថា) ជាព្រហ្មចារីពិតៗ បានដោយការប្រកបកិរិយា ដែលបុគ្គលនៅពីរនាក់ ហើយគប្បីនៅជាមួយមាតុគ្រាម មិនមែនជាឋានៈទេ, ទាំងមិនដល់

នូវការរីករាយថ្នាក់ថ្នម ។ល។ នៃមាតុគ្រាមទាំងមិន ( ដល់នូវ ) ការសើចចំអក សើចលេងកំប្លែងជាមួយមាតុគ្រាម តែថានៅសម្លឹង នៅមើលមាតុគ្រាមនោះដោយភ្នែក ( របស់ខ្លួន ) គេរីករាយដោយការមើលនោះ ។ល។ តថាគតពោលថា គេរមែងមិនរួចផុតចាកទុក្ខបានឡើយ ។

៤-ម្នាលព្រាហ្មណ៍សេចក្ដីដទៃនៅមានទៀត សមណៈក្ដី ព្រាហ្មណ៍ក្ដី បុគ្គលណាមួយក្នុងលោកនេះក្ដី ប្ដេជ្ញា ( ខ្លួនថា ) ជាព្រហ្មចារីពិតៗ បានដោយការប្រកបកិរិយាដែលបុគ្គលនៅពីរនាក់ ហើយគប្បីនៅជាមួយមាតុគ្រាម មិនមែនជាឋានៈទេ សូម្បីទាំងមិនដល់នូវការរីករាយថ្នាក់ថ្នម ។ល។ នៃមាតុគ្រាម ទាំងមិនដល់នូវការសើចចំអក ។ល។ ជាមួយមាតុគ្រាម ទាំងមិនដល់នូវការមើល មាតុគ្រាម ។ល។ តែថា ស្ដាប់សំឡេងមាតុគ្រាមសើចក្ដី និយាយក្ដី ច្រៀងក្ដី ស្រែកយំក្ដី ខាងក្រៅជញ្ជាំង ឬខាងក្រៅកំផែងក្ដី គេរីករាយដោយសំឡេងនោះ ។ល។ តថាគតពោលថា គេរមែងមិនរួចផុតចាកទុក្ខបានឡើយ ។

៥-ម្នាលព្រាហ្មណ៍ សេចក្ដីដទៃនៅមានទៀត សមណៈក្ដី ព្រាហ្មណ៍ក្ដី បុគ្គលណាមួយក្នុងលោកនេះក្ដី ប្ដេជ្ញា ( ខ្លួនថា ) ជាព្រហ្មចារីពិតៗ បានដោយការប្រកបកិរិយាដែលបុគ្គលនៅរួមគ្នាពីរនាក់ ហើយគប្បីនៅជាមួយមាតុគ្រាម មិនមែនជាឋានៈទេ សូម្បីមិនរីករាយក្នុង

ការថ្នាក់ថ្នម ។ល។ របស់មាតុគ្រាម សូម្បីមិនសើចចំអកលេង ។ល។ ជាមួយមាតុគ្រាម សូម្បីមិនដល់នូវការក្រឡេកមើលមាតុគ្រាម ។ល។ សូម្បីមិនដល់នូវការស្តាប់សំឡេងរបស់មាតុគ្រាមច្រៀងក្តី ។ល។ តែនៅតាមនឹកដល់ការធ្លាប់សើច ការនិយាយលេងជាមួយមាតុគ្រាម ក្នុងកាលមុន គេរីករាយក្នុងរឿងចាស់នោះ ។ល។ តថាគតពោលថា គេរមែងមិនរួចផុតចាកទុក្ខបានឡើយ ។

៦-ម្នាលព្រាហ្មណ៍ សេចក្តីដទៃនៅមានទៀត សមណៈក្តី ព្រាហ្មណ៍ក្តី បុគ្គលណាមួយក្នុងលោកនេះក្តី ប្តេជ្ញា ( ខ្លួនថា ) ជាព្រហ្មចារីពិតៗបានដោយការប្រកបកិរិយាដែលបុគ្គលនៅរួមគ្នាពីរនាក់ហើយ គប្បីនៅជាមួយមាតុគ្រាម មិនមែនជាឋានៈទេ ។ល។ សូម្បីមិនតាមនឹកដល់ការដែលធ្លាប់សើច និងការនិយាយលេងជាមួយមាតុគ្រាម ក្នុងកាលមុន តែគេឃើញគហបតី បុត្តរបស់គហបតីដែលជាអ្នកបរិបូណ៌ដោយកាមគុណ ៥ បម្រើខ្លួនជានិច្ច គេរីករាយក្នុងការបម្រើរបស់គហបតី ឬបុត្តរបស់គហបតីនោះ ។ល។ តថាគតពោលថា គេរមែងមិនរួចផុតចាកទុក្ខបានឡើយ ។

៧-ម្នាលព្រាហ្មណ៍ សេចក្តីដទៃនៅមានទៀត សមណៈក្តី ព្រាហ្មណ៍ក្តី បុគ្គលណាមួយក្នុងលោកនេះក្តី ដែលប្តេជ្ញា ( ខ្លួនថា ) ជាព្រហ្មចារីពិតៗ បាន ដោយការប្រកបកិរិយាដែលបុគ្គលនៅរួមគ្នាពីរ

នាក់ ហើយគប្បីនៅជាមួយមាតុគ្រាមមិនមែនជាឋានៈទេ សូម្បីមិន ឃើញគហបតី ឬបុត្តរបស់គហបតី ។ល។ បម្រើខ្លួន ។ល។ តែថា ប្រព្រឹត្តព្រហ្មចរិយៈប្រាថ្នាទេវនិកាយណាមួយ ដោយសន្សំមថា យើង នឹងបានជាម្ចាស់ទេព ឬជាទេពអន្តណាមួយ ដោយសីលនេះដោយ តបៈនេះឬដោយព្រហ្មចរិយៈនេះគេរីករាយសប្បាយចិត្ត ដល់នូវការ សប្បាយចិត្ត ដោយភាពជាទេវតានោះ ម្នាលព្រាហ្មណ៍ សូម្បីដោយ ការរីករាយក្នុងភាពជាទេវតានោះ គឺជាការដាច់សីលក៏បាន ធ្លុះក៏បាន ពពាលក៏បាន ពព្រុសក៏បាននៃព្រហ្មចរិយៈ ដូច្នេះ ។

ភាពនៃសីលដែលជាសីលដាច់ជាដើម គប្បីជ្រាបថា លោក សង្គ្រោះដោយការបែកធ្លាយ ( នៃសិក្ខាបទ ) ដែលមានលាភជាដើម ជាហេតុ ១ ដោយមេថុនសំយោគ ៧ ប្រការ ១ ដូចពោលមកនេះឯង ។

## ភាពផូរផង់នៃសីល

ចំណែកសីល ដែលជាសីលមិនដាច់ជាដើម លោកសង្គ្រោះ ដោយការមិនបែកធ្លាយនៃសិក្ខាបទទាំងឡាយ ដោយប្រការទាំងពួង ប្រការ ១ ដោយការសម្តែងនូវសិក្ខាបទទាំងឡាយដែលគប្បីសម្តែង ចំពោះសិក្ខាបទ ដែលបានបែកធ្លាយហើយ ដោយប្រការ ១ ដោយ ការមិនមានមេថុនសំយោគ ៧ ប្រការ ១ ដោយសេចក្តីល្អដទៃទៀត

គឺដោយការមិនកើតឡើងនូវបាបធម៌ទាំងឡាយដូចជា **កោធ ឧបនាហ មក្ខ បលាស ឥស្សា មច្ឆរិយ មយា សាឋេយ្យ ថម្ភ សារម្ភ មាន អតិមាន មទ បមាទ** ជាដើមប្រការ ១, ដោយការកើតឡើងនូវគុណទាំងឡាយមាន **អប្បិច្ឆតា សន្តុដ្ឋិតា** និងសល្លេខតាជាដើមប្រការ ១ ។

ពិតហើយ សីលទាំងឡាយណា មិនបែកធ្លាយព្រោះលាភជាដើមក្តី សូម្បីបែកធ្លាយដោយទោស គឺសេចក្តីប្រមាទ តែសម្តែងហើយក្តី ដែលមេថុនសំយោគ ឬបាបធម៌មាន **កោធ** និង **ឧបនាហ** ជាដើម មិនចូលមកទម្លាយចេញក្តី សីលទាំងឡាយនោះ លោកហៅថា **ខណ្ឌ** ( មិនដាច ), **មច្ឆិទ្ទ** ( មិនធ្លុះ ), **អសពល** ( មិនពពាល ), **អកម្មាស** (មិនពព្រុស ) ដោយប្រការទាំងពួង និងសីលទាំងឡាយនោះឯង ឈ្មោះថា **ភុជិស្ស** ព្រោះធ្វើភាពជាឯករាជ្យ, ឈ្មោះថា **វិញ្ញុបសត្ថ** ព្រោះភាពជាសីលដែលវិញ្ញូជនសរសើរ, ឈ្មោះថា **អបរាមដ្ឋ** ព្រោះជាសីល ដែលតណ្ហាមិនស្ទាបអង្អែល និងជា **សមាធិសំវត្តនិក** ព្រោះញុំាងឧបចារសមាធិ និងអប្បនាសមាធិឲ្យប្រព្រឹត្តទៅដោយងាយៗ ព្រោះហេតុនោះភាពជាសីលមិនដាច់ជាដើមនេះគប្បីជ្រាបថា ជាការផូរផង់នៃសីលទាំងឡាយនោះ ឯការផូរផង់នេះនោះ រមែងសម្រេចដោយអាការ ២ គឺដោយការឃើញទោសនៃសីលវិបត្តិ ១ ដោយការឃើញអានិសង្សនៃសីលសម្បត្តិ ១ ។

# ទោសនៃសីលវិបត្តិ

ក្នុងអាការ ២ យ៉ាងនោះ ទោសនៃសីលវិបត្តិ គប្បីឃើញតាមន័យនៃព្រះសូត្រដែលមានពាក្យផ្ដើមថា ម្នាលភិក្ខុទាំងឡាយទោសនៃសីលវិបត្តិរបស់ភិក្ខុ អ្នកទ្រុស្ដសីលមាន ៥ យ៉ាង នេះម្យ៉ាង, ម្យ៉ាងទៀត បុគ្គលអ្នកទ្រុស្ដសីល ព្រោះការទ្រុស្ដសីលជាដើមហេតុរមែងមិនជាទីពេញចិត្តរបស់ទេវតា និងមនុស្សទាំងឡាយ ជាអ្នកដែលមិត្តព្រហ្មចារីទាំងឡាយមិនគប្បីពោលបង្រៀន ត្រូវលំបាកចិត្ត ព្រោះការតិះដៀលនូវការទ្រុស្ដសីល ( របស់ខ្លួន ) ត្រូវក្ដៅចិត្តព្រោះការពោលសរសើរ ( អ្នកដទៃ ) ដែលមានសីលទាំងឡាយ ព្រោះភាពជាអ្នកទ្រុស្ដសីលនោះគេតែងតែជាអ្នកមានពណ៌សម្បុរសៅហ្មងម្យ៉ាងទៀត ចាត់ថាជាអ្នកមានសម្ផស្សគ្រោតគ្រាត ព្រោះនាំអបាយទុក្ខមកឲ្យដល់មនុស្សទាំងឡាយដែលយកគំរូ តាមគេអស់កាលយូរ គឺជាអ្នកមានរាគៈពាល់ត្រូវ ព្រោះដែលខ្លួនបានទទួលទេយ្យធម៌របស់គេមកធ្វើឲ្យទាយកទាំងឡាយមិនមានផលច្រើន ដូចជាសំពត់សំបកឈ្មើជាសំពត់ដែលមានសម្បុរអន់សម្ផស្សគ្រោតគ្រាត ហើយរាគៈពាល់ត្រូវ ដូច្នេះ ជាបុគ្គលជម្រះ ( ឲ្យបរិសុទ្ធ ) បានដោយលំបាក ដូចរណ្ដៅលាមក ដែលប្រឡាក់មកជាយូរ ( លំបាកនឹងលៀងឲ្យបានស្អាត )

ដូច្នោះ ។ ជាអ្នកឃ្លាតចាកប្រយោជន៍ទាំងពីរ ដូចជាកំណាត់ឈើដុតសាកសព ( ដែលឆេះទាំងសងខាង ត្រង់កណ្តាល ជារបស់លាមក រកប្រយោជន៍មិនបានទាំងក្នុងព្រៃ ទាំងក្នុងស្រុក) ដូច្នោះសូម្បីប្រកាសភាពជាភិក្ខុ ក៏មិនមែនជាភិក្ខុ ដូចសត្វលាដើរតាមហ្វូងគោ (សូម្បីស្រែកដូចគោក៏មិនមែនជាគោ ) ដូច្នេះ ជាអ្នកបារម្ភជានិច្ច ដូចបុគ្គលមានពៀរជាមួយបុគ្គលទូទៅ ជាបុគ្គលមិនគួរនៅរួមគ្នា ដូចសាកសព សូម្បីប្រកបដោយគុណមានសុតៈជាដើម ក៏មិនគួរដល់ការបូជារបស់មិត្តព្រហ្មចារីទាំងឡាយ ដូចភ្លើងក្នុងព្រៃខ្មោច មិនគួរដល់ការបូជារបស់ពួកព្រាហ្មណ៍ ជាបុគ្គលអភ័ព្វក្នុងការសម្រេចនូវគុណវិសេស ដូចបុគ្គលភ្នែកខ្វាក់អភ័ព្វក្នុងការឃើញរូប ជាអ្នកគ្មានសេចក្តីសង្ឃឹមក្នុងព្រះសទ្ធម្ម ដូចក្មេងចណ្ឌាលគ្មានសង្ឃឹមក្នុងរាជសម្បត្តិ សូម្បីសម្គាល់ថាខ្លួនមានសុខ ក៏ឈ្មោះថា ជាមនុស្សមានទុក្ខដែរ ព្រោះភាពជាអ្នកមានចំណែកនៃទុក្ខ ដែលទ្រង់ត្រាស់ទុកក្នុងអគ្គិក្ខន្ធបរិយាយ ។

ពិតហើយ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ឃើញកម្ម និងវិបាកច្បាស់លាស់ ដោយអាការទាំងពួង កាលទ្រង់សម្តែងនូវទុក្ខដែលក្តៅរោលរាល មានការរីករាយក្នុងសុខ ដូចបានពោលហើយជាបច្ច័យដោយហេតុត្រឹមតែនឹកដល់អាចញុាំង ភាពក្តៅឆេះរោលរាលហឫទ័យឲ្យកើតឡើង ហើយញុាំងការក្អួតលោហិតក្តៅៗ ឲ្យប្រព្រឹត្តទៅដល់បុគ្គល

ទ្រុស្តសីលទាំងឡាយ ជាអ្នកមានចិត្តត្រេកត្រអាលដោយតម្រេកសុខ ក្នុងការបរិភោគបញ្ចកាមគុណ និងក្នុងសាមីចិកម្ម (ដែលអ្នកដទៃធ្វើ) មានការថ្វាយបង្គំ ការសម្តែងនូវការរាប់អានជាដើម ទើបទ្រង់ត្រាស់ ( អគ្គិក្ខន្ធបរិយាយសូត្រ ) ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញឬទេ នូវគំនរភ្លើងធំដែលឆេះចេញជាអណ្តាតសន្ធោសន្ធៅឡើង នៅទីនោះ ភិក្ខុទាំងឡាយ ក្រាបទូលថា ព្រះករុណា ព្រះអង្គឃើញ ទ្រង់ត្រាស់ថាម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយសម្គាល់សេចក្តីនោះ ដូចម្តេចបុគ្គលគប្បីចូលទៅអង្គុយឱបឬចូលទៅដេកឱបនូវគំនរភ្លើង ធំនោះ ដែលឆេះជាអណ្តាតសន្ធោសន្ធៅនៅទីនោះក្តី និងបុគ្គលចូល ទៅអង្គុយបបោសអង្អែលឬចូលទៅដេកអង្អែលនូវនាងក្សត្រិយ៍នាង ព្រាហ្មណី ឬនាងគហបតី ដែលមានបាតដៃ បាតជើងទន់ដូចសំឡីក្តី ទាំងពីរនេះមួយណាប្រសើរជាងភិក្ខុទាំងឡាយក្រាបទូលថា បពិត្រ ព្រះអង្គដ៏ចម្រើន សេចក្តីនោះ បុគ្គលគប្បីចូលទៅអង្គុយអង្អែល ឬ ដេកអង្អែលនាងក្សត្រិយ៍នាងព្រាហ្មណីនិងនាងគហបតីនោះប្រសើរ ជាង កាលដែលបុគ្គលចូលទៅ អង្គុយឱបភ្លើង ដេកឱបភ្លើង ។ល។ នោះជាទុក្ខព្រះអង្គ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រាប់អ្នកទាំងឡាយឲ្យបានដឹងបុគ្គលគប្បីចូលទៅអង្គុយ ឱប ឬដេកឱបគំនរភ្លើង ។ល។ នោះប្រសើរជាង សម្រាប់ភិក្ខុទ្រុស្ត

សីល មានធម៌លាមក មានសមាចារមិនស្អាត កាលនឹកដល់ដោយការរង្កៀស មានការលាក់បាំង មិនមែនសមណៈតែប្តេជ្ញាខ្លួនថា ជាសមណៈមិនមែន ព្រហ្មចារីតែប្តេជ្ញាថាជាព្រហ្មចារី ជាបុគ្គលស្អុយក្នុងទទឹកជោក ( ដោយកិលេស ) សេចក្តីនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុនោះ គប្បីស្លាប់ ឬទុក្ខ ស្មើរតែស្លាប់ ព្រោះហេតុដែលគេចូលទៅអង្គុយឱប ឬចូលទៅដេកឱបគំនរភ្លើងធំនោះ ( ក៏ពិត ) តែព្រោះកាយបែកធ្លាយទៅ នឹងគប្បីដល់អបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនោះ ជាបច្ច័យក៏ទេ, ម្នាលភិក្ខុទាំងឡាយ ចំណែកភិក្ខុដែលជាអ្នកទ្រុស្តសីល មានធម៌លាមក មានសមាចារមិនស្អាត កាលនឹកដល់ដោយការរង្កៀស មានការលាក់បាំង មិនមែនសមណៈ តែប្តេជ្ញាថាជាសមណៈ មិនមែនព្រហ្មចារី តែប្តេជ្ញាថា ជាព្រហ្មចារី ជាបុគ្គលស្អុយក្នុង ទទឹកជោក ( ដោយកិលេស ) នោះចូលទៅអង្គុយអង្អែល ដេកអង្អែល នាងក្សត្រិយ៍ ។ល។ ម្នាលភិក្ខុទាំងឡាយសេចក្តីនោះប្រព្រឹត្តទៅមិនដើម្បីជាប្រយោជន៍ដើម្បីសេចក្តីទុក្ខដល់គេ អស់កាលយូរអង្វែង ព្រោះកាយបែកធ្លាយទៅ គេរមែងចូលដល់ អបាយ ទុគ្គតិ វិនិបាត នរក ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងនូវទុក្ខ មានការបរិភោគកាមគុណ ៥ ដែលទាក់ទងដោយស្ត្រីជាបច្ច័យ ដែលឧបមាដោយ

គំនរភ្លើង យ៉ាងនេះហើយ ទើបទ្រង់សម្តែងនូវទុក្ខដែលមានការអភិវាទ ការធ្វើអញ្ជលី ការបរិភោគចីវរ បិណ្ឌបាត គ្រែ តាំង និងវិហារ ជាបច្ច័យ ដែលឧបមាដោយខ្សែរវេញដោយរោមកន្ទុយសត្វ លំពែងដ៏មុត បន្ទះដែក ដុំដែក គ្រែដែក ឬកៅអីដែក និងថ្នាំងដែកទាំងឡាយនេះ ដោយទំនងដូចគ្នានេះថា

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនឹងសម្គាល់សេចក្តីនោះដូចម្តេច កាលដែលបុរសមានកម្លាំង យកខ្សែដែលវេញដោយកន្ទុយសត្វយ៉ាងតឹង ចងស្មងជើង ទាំងពីរ ហើយអូសកន្ត្រាក់ទៅមក ខ្សែនោះក៏កាត់សម្បុរស្បែកកាលកាត់សម្បុរស្បែកហើយក៏កាត់នូវស្បែក កាលកាត់ស្បែក ហើយក៏កាត់នូវសាច់ កាលកាត់សាច់ហើយក៏កាត់នូវសរសៃ កាលកាត់សរសៃហើយក៏កាត់នូវឆ្អឹង កាលកាត់ឆ្អឹង ហើយក៏ទម្លាយក្រពេញរំអិលក្នុងឆ្អឹង(ជាមួយ)នឹងការដែលភិក្ខុទ្រុស្តសីលរីករាយក្នុងការអភិវាទរបស់ក្សត្រិយមហាសាល ព្រាហ្មណមហា-សាល ឬគហបតីមហាសាលណាមួយប្រសើរជាង ។ល។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនឹងសម្គាល់សេចក្តីនោះដូចម្តេច កាលបុរសមានកម្លាំងប្រហារចំកណ្តាលដើមទ្រូង ដោយលំពែងដ៏មុតដែលសំលៀងដោយប្រេង(ជាមួយ)នឹងភិក្ខុទ្រុស្តសីលដែលគ្រេកអរក្នុងការធ្វើអញ្ជលីរបស់ក្សត្រិយមហាសាល ព្រាហ្មណ

មហាសាល គហបតីមហាសាល មួយណាប្រសើរជាង ។ល។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្ដីនោះ ដូចម្ដេច ការដែលបុរសមានកម្លាំងយកបន្ទះដែកដែលដុតក្រហមឆ្អៅមករុំកាយ ( ជាមួយ ) នឹងភិក្ខុទ្រុស្ដសីល គប្បីប្រើប្រាស់ចីវរ ដែលគេថ្វាយដោយសទ្ធារបស់ក្សត្រិយមហាសាល ។ល។ ណាមួយប្រសើរជាង ?... ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្ដីនោះ ដូចម្ដេច កាលដែលបុរសមានកម្លាំង យកដង្កាប់ដែកដែលក្រហមឆ្អៅគាស់មាត់ប្រកដុំដែក ដែលដុតក្ដៅចូលទៅក្នុងមាត់ ដុំលោហៈក្ដៅនោះ ឆេះទាំងបបូរមាត់ ឆេះមាត់ ឆេះអណ្ដាត ឆេះបំពង់ក ឆោះពោះនាំយកទាំងសរសៃធំ ទាំងសរសៃតូចចេញ ទៅតាមទ្វារក្រោម ( ជាមួយ)នឹងភិក្ខុដែលទ្រុស្ដសីលបរិភោគបិណ្ឌបាតដែលគេថ្វាយដោយសទ្ធារបស់ក្សត្រិយមហាសាល ។ល។ មួយណាប្រសើរជាង ?...

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្ដីនោះ ដូចម្ដេច ការដែលបុរសមានកម្លាំងចាប់សីសៈក្ដី ចាប់កក្ដី ( សង្កត់) ឲ្យអង្គុយចុះក្ដី ឲ្យដេកចុះក្ដី នៅលើកៅអីដែក ឬគ្រែដែកដែលក្ដៅក្រហមឆ្អៅ ( ជាមួយ ) នឹងភិក្ខុទ្រុស្ដសីលប្រើប្រាស់គ្រែ ឬកៅអីដែលគេថ្វាយដោយសទ្ធារបស់ក្សត្រិយមហាសាល ។ល។ មួយណាប្រសើរ

ជាង... ?

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះ ដូចម្តេច កាលដែលបុរសមានកម្លាំងចាប់ជើងឡើងលើសំយុងក្បាលចុះ ហើយដាក់ចុះទៅក្នុងឆ្នាំងលោហៈ ដែលកំពុងពុះក្តៅចេញជាអណ្តាតភ្លើង គេត្រូវស្ងោរពុះវក់វី ធ្លាក់ចុះក្រោម អណ្តែតឡើងលើ ជួនកាលអណ្តែតទៅទាំងទទឹង នៅក្នុងឆ្នាំងលោហៈនោះ ( ជាមួយ ) នឹងភិក្ខុទ្រុស្តសីល ប្រើប្រាស់វិហារដែលគេថ្វាយដោយសទ្ធារបស់ក្សត្រិយមហាសាល ។ល។ មួយណាប្រសើរជាង ។ល។ គេរមែងចូលដល់ ។ល។ ដូច្នេះ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបការឃើញទោស ព្រោះសីលវិបត្តិ ដោយការពិចារណាក្នុងន័យជាអាទិយ៉ាងនេះថា

សេចក្តីសុខរបស់បុគ្គលអ្នកមានសីលទម្លាយហើយ មិនលះកាមសុខដែលមានផលជាទុក្ខ ក្តៅជាងទុក្ខព្រោះឱបគំនរភ្លើង នឹងមានមកពីណា... ។

សុខក្នុងការរីករាយ ដោយការថ្វាយបង្គំនឹងមានដល់បុគ្គលមានសីលវិបត្តិជាអ្នកដែលត្រូវទទួលទុក្ខដ៏ក្រៃលែង ជាងទុក្ខដែលកើតពីការរួសដោយខ្សែក្រនុយសត្វដ៏ស្អិតទៅទៀត... ។

សុខក្នុងការរីករាយ ចំពោះការផ្គងអញ្ជលីកម្មរបស់បុគ្គលអ្នកមានសទ្ធាទាំងឡាយដែលជាហេតុនៃទុក្ខ ដែលមានប្រមាណក្រៃលែង

ជាផទុក្ខដែលកើតពីការប្រហារដោយលំពែងនឹងមានដល់បុគ្គលអ្នកមិនមានសីល ដូចម្ដេចបាន...។

សេចក្ដីសុខក្នុងការប្រើប្រាស់ចីវររបស់បុគ្គល ( ទ្រុស្ដសីល ) អ្នកមិនសង្រួម នឹងត្រូវសោយសម្ផស្សនៃបន្ទះដែកដុតក្ដៅក្នុងនរកអស់កាលដ៏យូរ នឹងមានដូចម្ដេចបាន... ។

បិណ្ឌបាត សូម្បីមានរសឆ្ងាញ់ ក៏ប្រៀបដូចជាថ្នាំពិសដ៏ខ្លាំងក្លាសម្រាប់បុគ្គល មិនមានសីលនឹងត្រូវទំពាដុំដែកដ៏ក្ដៅ អស់រាត្រីដ៏យូរ... ។

ការប្រើប្រាស់គ្រែនិងកៅអី សូម្បីគេសន្មតគ្នាថា ជាសុខ តែក៏ជាទុក្ខសម្រាប់អ្នកមិនមានសីលដែលត្រូវទទួលនូវទុក្ខដែល (កើតពីការប្រើប្រាស់ ) គ្រែ និងកៅអី ដែកដែលក្ដៅបៀតបៀនអស់កាលជានិច្ច ។

ការរីករាយក្នុងការស្នាក់អាស្រ័យក្នុងវិហារដែលគេថ្វាយដោយសទ្ធានឹងមានដល់បុគ្គលទ្រុស្ដសីល ជាអ្នកដែលត្រូវធ្លាក់ទៅកណ្ដាលឆ្នាំងលោហៈដ៏ក្ដៅ បានដូចម្ដេចទៅ ?...។

ព្រះមានព្រះភាគ ជាគ្រូរបស់លោក កាលទ្រង់តិះដៀលនូវបុគ្គលទ្រុស្ដសីល បានត្រាស់ថា បុគ្គលមានសមាចារដែលគួររលឹកដល់ ដោយការរង្កៀសថា ជាបុគ្គលសេមរសាម ( ដោយសំរាម

គឺកិលេស ) ជាបុគ្គលជោកជាំ ( ដោយទឹក គឺកិលេស ) ជាបុគ្គលលាមក និងជាបុគ្គលស្អុយក្នុង ដូច្នេះ គួរតិះដៀលជីវិតរបស់បុគ្គលទ្រុស្តសីលនោះ ជាបុគ្គលមិនមានបញ្ញា ទ្រទ្រង់ភេទជាសមណៈ តែមិនមែនជាសមណៈ គាស់រំលើងឫសគល់របស់ខ្លួន សប្បុរសទាំងឡាយដែលជាអ្នកមានសីលក្នុងលោកនេះ រមែងគេចចេញពីបុគ្គលទ្រុស្តសីលណា ប្រៀបដូចជាអ្នកស្រឡាញ់ភាពស្អាតទាំងឡាយគេចចេញពីលាមក គេចចេញពីសាកសព ជីវិតរបស់បុគ្គលទ្រុស្តសីលនោះ ( នឹងមានប្រយោជន៍អ្វី ) ។

បុគ្គលទ្រុស្តសីលនោះ នឹងជាអ្នកមិនរួចផុតចាកភ័យទាំងពួង តែជាអ្នកផុត ចាកអធិគមសុខ ( សុខដែលកើតពីមគ្គផល ) ទាំងអស់ គេបិទទ្វារសួគ៌យ៉ាងជិត ឡើងកាន់ផ្លូវអបាយទៅ...។

បុគ្គលណាទៅ នឹងជាវត្ថុនៃសង្វាររបស់ជនអ្នកប្រាថ្នាសង្វារឲ្យស្មើដោយបុគ្គលទ្រុស្តសីលនេះ ទោសនៃការទ្រុស្តសីលមានច្រើនដូចពោលមកនេះឯង ។

ឯការឃើញអានិសង្សនៃសីលសម្បត្តិ គប្បីជ្រាបដោយន័យផ្ទុយគ្នាពីប្រការ ដូចបានពោលហើយនោះចុះ ។ន័យម្យ៉ាងទៀត សីលរបស់ភិក្ខុណាអស់មន្ទិលល្អ ភារៈទ្រទ្រង់បាត្រនិងចីវររបស់ភិក្ខុនោះ រមែងគួរជាទីជ្រះថ្លា បព្វជ្ជារបស់លោកក៏មានផល ហទយៈរបស់ភិក្ខុ

អ្នកមានសីលបរិសុទ្ធ រមែងមិនធ្លាក់ចុះកាន់ភ័យមានការតិះដៀលខ្លួនឯងជាដើម ដូចព្រះអាទិត្យមិនចុះកាន់ភាពងងឹតដូច្នោះ ។ ភិក្ខុកាលស្អាតក្នុងតបោវន រមែងស្អាតដោយភាពដល់ព្រមនៃសីល ដូចព្រះច័ន្ទកាលស្អាតក្នុងផ្ទៃមេឃ រមែងស្អាតដោយភាពដល់ព្រមនៃរស្មីដូច្នោះ, សូម្បីក្លិនកាយរបស់ភិក្ខុអ្នកមានសីល រមែងញ៉ាំងភាពសប្បាយរីករាយដល់ទេវតាទាំងឡាយចាំបាច់ពោលថ្វីដល់ក្លិនសីល ក្លិននៃសីលរមែងគ្របសម្បត្តិនៃគន្ធជាតិទាំងឡាយ ផ្សាយទៅកាន់ទិសទាំង ១០ មិនមានទើសទាក់, សក្ការៈបន្តិចបន្តួចដែលទាយក ធ្វើហើយចំពោះអ្នកមានសីល រមែងនាំឲ្យមានផលច្រើន ព្រោះដូច្នោះ អ្នកមានសីលទើបដូចជាភាជនៈ ( សម្រាប់ទទួល ) គ្រឿងបូជា និងសក្ការៈ ...។

សម្បត្តិណាក្នុងមនុស្ស និងសម្បត្តិណាក្នុងទេវលោក សម្បត្តិទាំងពីរនោះ កាលអ្នកមានសីលដល់ព្រមប្រាថ្នាហើយ មិនមែនជាវត្ថុដែលបានដោយលំបាកឡើយ ម្យ៉ាងទៀត ចិត្តរបស់អ្នកមានសីលដល់ព្រម រមែងស្ទុះទៅកាន់ព្រះនិព្វាន សម្បត្តិដែលជាសម្បត្តិដ៏ស្ងប់ជាទីបំផុត ។

បណ្ឌិតគប្បីសម្ដែងអានិសង្សដែលមានអាការផ្សេងៗ ជាច្រើនក្នុងសីលដែលជាមូលនៃសម្បត្តិទាំងពួងដោយប្រការដូច្នេះឯង ។ព្រោះកាលសម្ដែងហើយ យ៉ាងនេះ ចិត្តគំនិតរមែងភ័យ គេចពីសីលវិបត្តិ

ហើយបង្អោនទៅកាន់សីលសម្បត្តិ ព្រោះដូច្នោះ ភិក្ខុឃើញទោសនៃសីលវិបត្តិនេះ និងអានិសង្សនៃសីលសម្បត្តិនេះ ដូចពោលហើយ គប្បីញុំាងសីលឲ្យផូរផង់ ដោយការយកចិត្តទុកដាក់គ្រប់ប្រការចុះ ។

ក៏ឯសីលក្នុងវិសុទ្ធិមគ្គដែលទ្រង់សម្តែងដោយ **សីល សមាធិ បញ្ញា** ដែលបានសម្តែងហើយដោយព្រះគាថា ( បាទដើម ) នេះថា **សីលេ បតិដ្ឋាយ នរោ សបញ្ញោ** ត្រឹមប៉ុណ្ណោះចុះ ជាលំដាប់ដំបូង ។

# មហាដីកា

## ពណ៌នាភាពសៅហ្មង និងភាពផូរផង់នៃសីល

ឈ្មោះថា **សង្កិលេស** ព្រោះអត្ថថា ជាហេតុឲ្យសៅហ្មង ។

អ្វីទៅជាហេតុឲ្យសៅហ្មងនោះ លោកអាចារ្យពោលថា ភាវៈដែលសីលដាច់ជាដើម គឺជាហេតុឲ្យសៅហ្មងរបស់សីល ដូច្នេះ ។

ឈ្មោះថា **វោទាន** ព្រោះអត្ថថា ជាហេតុឲ្យផូរផង់ គឺបរិសុទ្ធបានដល់ ភាវៈដែលសីលមិនដាច់ជាដើម ។ បទថា **លាភយសាទិ** ( ដែលមានលាភ និងយសជាដើម ) ដោយ អាទិ-សព្ទ ( ប្រែថា ជាដើម ) មានការសង្គ្រោះយកញាតិ អវយវៈ ជីវិតជាដើម ។ ពាក្យថា ក្នុងបណ្ដាអាបត្តិទាំង ៧ កង សិក្ខាបទរបស់ភិក្ខុរូបណាដែលទម្លាយហើយក្នុងខាងដើមក្ដី ក្នុងទីបំផុតក្ដី ត្រង់កណ្ដាលក្ដី នេះលោកពោលទុកដោយអំណាចព្រះបាលី ដែលជាឧទ្ទេសខាងដើមនៃអាបត្តិទាំងឡាយនោះ ព្រោះថា មិនមានអ្វីដទៃពីលំដាប់នៃកងអាបត្តិទាំងឡាយ ។

ពាក្យថា ដាច បានដល់ សីលដែលមានការដាច់ ឬដែលដាច់ហើយ ។ សូម្បីក្នុងពាក្យថា ធ្លុះ ក៏ក្នុងន័យនេះដូចគ្នា ។ ពាក្យថា ដូចជាសំពត់សាដក ដែលដាច់ជាយ ដូច្នោះ គឺដូចជាសំពត់ដែលដាច់ជាយ ឬដាច់ចុងជាយនៃសំពត់ដូច្នោះ ។

ពាក្យថា ដោយប្រការដូច្នេះ គឺដោយអាការដែលកំពុងពោលដល់ក្នុងពេលឥឡូវនេះ ។ ពាក្យថា ដោយអំណាចមេថុនសំយោគ មានន័យថា ឈ្មោះថា មេថុន ព្រោះអត្ថថា វត្ថុនេះជារបស់មនុស្សពីរនាក់ ព្រោះការដល់នូវភាពស្រដៀងគ្នា ព្រោះការថោមរោមនៃរាគៈ បានដល់ ការរួមដំណេក ។

ការប្រកបរួមគ្នាដោយអំណាចនៃមេថុន ឈ្មោះថា មេថុនសំ-យោគ តែក្នុងទីនេះប្រព្រឹត្តដូចមេថុនសំយោគ ទើបឈ្មោះថា មេថុនសំយោគ បានដល់ ដោយអំណាចមេថុនសំយោគនោះ ។ បទថា **ឥធ** ប្រែថា ក្នុងលោកនេះ ។ បទថា **ឯកច្ចោ** បានដល់ បុគ្គលខ្លះ ។ ពាក្យថា សមណៈក្តី ព្រាហ្មណ៍ក្តី គឺអ្នកជាសមណៈ ព្រោះថា បាន បួសក្តី អ្នកជាព្រាហ្មណ៍ដោយជាតិ ( កំណើត ) ក្តី ។

ពាក្យថា នូវការប្រសព្វរួមគ្នាពីរៗ គឺវត្ថុដែលបុគ្គលពីរៗ នាក់ គប្បីដល់រួមគ្នា មានន័យថា បានដល់ មេថុន ។ ភ្ជាប់សេចក្តីថា **នហេវ ខោ សមាបជ្ជតិ** ។ ឈ្មោះថា **ឧច្ឆាទនំ** បានដល់ ការខាត់ពណ៌ ។ ឈ្មោះថា **សម្ពាហនំ** បានដល ការគក់ប្រេបាច់ ។ បទថា **សាទិយតិ** បានដល់ ព្រមទទួល ។ ពាក្យថា រីករាយ ដោយការធ្វើនោះ គឺ សប្បាយក្នុងការខាត់ពណ៌ជាដើម ។ បទថា **និកាមេតិ** ( ប្រាថ្នា ) បានដល់ **ឥច្ឆតិ** ( ត្រូវការ ) ។ ពាក្យថា សេចក្តីត្រេកអរ បានដល់

ការរីករាយ ។ ក្នុងពាក្យថា សូម្បីខនេះឯង នេះទ្រង់ត្រាស់រួមយកការ ព្រមទទួលជាដើម (ព្រមទទួល រីករាយ ប្រាថ្នា ដល់នូវភាពត្រេកអរ) តាមដែលទ្រង់បានត្រាស់ថា ខនេះឲ្យកើតដូចគ្នា ដោយទាក់ទងជាមួយ នឹងការដាច់ជាដើម ។

បិ-ស័ព្ទ (ប្រែថា សូម្បី) មានអត្ថថា រួបរួមប្រកាន់យកពាក្យ ដែលកំពុងពោលដល់ ។ ខោ-ស័ព្ទ (ប្រែថា ឯ) មានអត្ថថា បញ្ជាក់ សេចក្តី ។ ខនេះមានការពោលអធិប្បាយទុកថា កាលសមណៈ ឬ ព្រាហ្មណ៍ជាអ្នកប្រកាសថា ជាព្រហ្មចារី មិនមានការប្រសព្វរួមគ្នា ពីរៗ ការព្រមទទួលជាដើមនូវមាតុគ្រាមឲ្យ ខាត់ស្បែកឲ្យ ងូតទឹកឲ្យ គក់ប្របាច់ឲ្យ យ៉ាងណា សេចក្តីនេះ ចាត់ជាការដាច់ក៏បាន ធ្លុះក៏បាន ពព្រុសក៏បាន ពពាលក៏បាន ព្រោះជាការធ្វើឲ្យព្រហ្មចរិយៈនោះ ដល់ នូវការដាច់ជាដើម យ៉ាងពិតប្រាដកដូច្នេះឯង ។ ក៏ព្រះសាស្តាកាល ទ្រង់សម្តែងថា ព្រោះការដល់នូវការដាច់ជាដើមយ៉ាងនេះ សមណៈ ឬព្រាហ្មណ៍នោះ ឈ្មោះថា រមែងប្រព្រឹត្តព្រហ្មចារ្យមិនបរិសុទ្ធ, មិន បរិសុទ្ធ ជាអ្នកប្រកបដោយមេថុនសំយោគ មិនមែនមិនប្រកបនោះ ទេ ។ ព្រោះហេតុនោះ ទើបគេរួចផុតចាកទុក្ខមានជាតិជាដើម មិន បាន ដូច្នេះ ទើបទ្រង់ត្រាស់ថា **អយំ វុច្ចតិ** (អ្នកនេះហៅថា) ដូច្នេះ ជាដើម ។

ពាក្យថា សើចលេង គឺសើចមានសំឡេងខ្លាំងដោយអំណាចកិលេស ។

ពាក្យថា លេង គឺលេងដោយទាក់ទងការស្និទ្ធស្នាលគ្នាដោយកាយ ។

ពាក្យថា សើចកំប្លែង គឺសើចលេងជាមួយមាតុគ្រាមគ្រប់យ៉ាង ។

ពាក្យថា ប្រើភ្នែក គឺប្រើភ្នែករបស់ខ្លួន ។ ពាក្យថា ( សម្លឹងទល់ ) ភ្នែក គឺសម្លឹងទល់ភ្នែករបស់មាតុគ្រាម ។ ពាក្យថា សម្លឹង គឺចូលទៅសម្លឹង គឺមើល ។

ពាក្យថា ខាងក្រៅជញ្ជាំង គឺផ្នែកម្ខាងទៀតនៃជញ្ជាំង ។ ឈ្មោះថា ផ្នែកខាងក្រៅកំផែង គឺដោយន័យដូចគ្នានោះ ។ អាចារ្យច្រើនទាក់ពោលថា ជញ្ជាំង ដែលធ្វើដោយដី ឈ្មោះថា ជញ្ជាំង ធ្វើដោយឥដ្ឋឈ្មោះថា កំផែង ។

ន័យម្យ៉ាងទៀត **អស្ស យោគ ព្រហ្មចារិបដិញ្ញស្ស** ប្រែថា អ្នកប្តេជ្ញាខ្លួនថា ជាព្រហ្មចារីនោះ ។ ពាក្យថា ក្នុងកាលមុន គឺក្នុងកាលមុនបន្ទាប់ពីការសមាទានវត្ត ។ ពាក្យថា ដោយកាមគុណ គឺដោយអំណាចនៃកាមទាំងឡាយ ។ បទថា **សមប្បិតំ** បានដល់ ពេញលេញគឺដល់ព្រមដោយល្អ ។ ពាក្យថា ព្រមព្រៀង គឺប្រកបព្រម ។ បទថា

**បរិចារិយមានំ** ប្រែថា ដែលលេងហើយ ឬត្រូវបម្រុងបម្រើហើយ ។

បទថា **បណិធាយ** ប្រែថា ប្រាថ្នា ។ ក្នុងពាក្យថា ដោយសីលជាដើម មានវិនិច្ឆ័យថា ឈ្មោះថា **សីល** ក៏ដោយទំនាក់ទំនងជាមួយការសមាទានយមសីល និងនិយមសីលជាដើម ។ ឈ្មោះថា វត្ត ក៏ដោយទំនាក់ទំនងជាមួយនឹងការមិនឈានកន្លង ។ ន័យម្យ៉ាងទៀត សូម្បីទាំងពីរយ៉ាង ក៏ឈ្មោះថា សីល ។ ការដែលធ្វើឲ្យប្រព្រឹត្តទាក់ទងជាមួយនឹងការធ្វើឲ្យលំបាក ឈ្មោះថា វត្ត ។ ម្យ៉ាងទៀត ធម្មជាតិដែលមានលក្ខណៈប្រាសចាកការប្រព្រឹត្តិដែលរាប់ថាជាកិច្ចមិនសមគួរនោះៗ ឈ្មោះថា សីល ។ ឧបដិបត្តិវិសេសដោយការធ្វើកិច្ច គឺការតុបតែងឲ្យស្អាត និងការបរិភោគជាដើម របស់អ្នកមានការសមាទានវត្ត និងសីលនោះៗ ឈ្មោះថា វត្ត ។ ការប្រព្រឹត្តិដែលធ្វើឲ្យលំបាកសូម្បីដោយប្រការទាំងពួង ឈ្មោះថា តប, ការវៀរចាកមេថុន ឈ្មោះថា **ព្រហ្មចរិយ** ។ ពាក្យថា ដោយប្រការទាំងពួង គឺដោយមិនមានសល់ ឬថា ទាំងអស់ ។ ពាក្យថា ដោយការមិនបែកធ្លាយ គឺដោយការមិនឈានកន្លង ។ ប្រកបសេចក្តីបានថា សង្គ្រោះដោយអាការយ៉ាងដទៃ គឺការមិនកើតឡើងនៃបាបធម៌ទាំងឡាយ ១ ការកើតឡើងនៃគុណទាំងឡាយ ១ ។ ក្នុងបាបធម៌ទាំងឡាយនោះ កោធៈ ( សេចក្តីក្រោធ ) មានការអន់ចិត្តជាលក្ខណៈ ។ ឧបនាហៈ ( ការចងសេចក្តី

ក្រោធ ) មានការចងគំនុំមាំ ជាលក្ខណៈ ។ មក្ខៈ ( ការរមិលគុណ ) មានការលប់គុណអ្នកដទៃជាលក្ខណៈ ។ បលាសៈ ( ការវាយឫកស្មើ ) មានការប្រកាន់ប្រៀបធៀបជាលក្ខណៈ ។ ឥស្សា ( សេចក្ដីឫស្យា ) មានការប្រណែនក្នុងសម្បត្តិអ្នកដទៃជាលក្ខណៈ ។ មច្ឆរិយៈ ( សេចក្ដីកំណាញ់ ) មានការលាក់សម្បត្តិរបស់ខ្លួនជាលក្ខណៈ ។ មាយា ( ការលាក់ពុត ) មានការបិទបាំងទោសដែលមានជាលក្ខណៈ ។ សាថេយ្យៈ ( ការអួតអាង ) មានការលើកសរសើរគុណដែលមិនមានជាលក្ខណៈ ។ ថម្ភៈ ( ការរឹងត្អឹង ) មានការរឹងត្អឹងនៃចិត្ត ជាលក្ខណៈ ។ សារម្ភៈ ( ការប្រណាំងវាសនា ) មានការធ្វើឲ្យខ្ពស់ឡើងជាលក្ខណៈ ។ អតិមានះ ( ការក្រអើតក្រអោង ) មានការប្រកាន់ខ្លួនខ្លាំងជាលក្ខណៈ ។ មទៈ ( ការស្រវឹង ) មានការស្រវឹងជាលក្ខណៈ ។ បមាទៈ ( សេចក្ដីប្រមាទ ) មានការបណ្ដែតបណ្ដោយចិត្តជាលក្ខណៈ ។ ដោយ អាទិ-ស័ព្ទ ( ប្រែថា ជាដើម ) មានការសង្គ្រោះយកបាបធម៌ទាំងឡាយមានលោភៈ មោហៈមនសិការដែលវិបរិតជាដើម ។ ឥឡូវនេះលោកបំណងនឹងធ្វើខ្លឹមសារ ដែលពោលទុកដោយពាក្យថា ចំណែកភាវៈដែលសីលមិនដាច់ជាដើមដូច្នេះជាដើមនោះឯងឲ្យជាក់ច្បាស់ក្រៃលែងឡើង ទើបពោលថា **យានិ ហិ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា ដែល ( បាបធម៌ទាំងឡាយ ) ចូលទៅ

ទម្លាយមិនបាន គឺដែល (បាបធម៌ទាំងឡាយ) ចូលទៅធ្វើឲ្យអន្តរាយមិនបាន ។ ឈ្មោះថា ការធ្វើភាពជាឥស្សរៈ ព្រោះរួចផុតពីភាពជាទាសៈរបស់តណ្ហា ដោយភាពជាឧបនិស្ស័យនៃវិវដ្ដៈ ។

លោកអាចារ្យពោលថា ព្រោះជាសីលដែលអ្នកប្រាជ្ញទាំងឡាយបានសរសើរ ដូច្នេះ ព្រោះបុគ្គលពាលទាំងឡាយមិនសំខាន់ ។

សីល ឈ្មោះថា **សមាធិសំវត្តនិក** ព្រោះអត្ថថា មានការប្រព្រឹត្តិទៅព្រម ដើម្បីសមាធិជាប្រយោជន៍ ឬប្រកបក្នុងការប្រព្រឹត្តិទៅព្រមដើម្បីសមាធិ ។

**សីលសម្បទា** រមែងមានបានព្រោះការប្រាសចាកទៅនៃធម៌ដែលជាបដិបក្ខ ដូចការដល់ព្រមនៃស្រូវសំណាប រមែងមានបានព្រោះមិនមានរុក្ខជាតិធ្វើឲ្យអន្តរាយដូច្នោះ, ក៏សីលសម្បទានោះ រមែងសម្រេចបាន កាលមានការឃើញទោសនៃសីលវិបត្តិនោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ដោយការឃើញទោសនៃសីលវិបត្តិ ដូច្នេះ ។ **សម្មាបដិបត្តិ** រមែងមានបាន ព្រោះការឃើញគុណហើយប៉ុណ្ណោះ ព្រោះបុគ្គលដែលមានប្រក្រតីពិចារណាមុនហើយទើបធ្វើជាអ្នកជូន់ក្នុងប្រយោជន៍ ព្រោះហេតុនោះ ទើបលោកពោលថា ដោយការឃើញអានិសង្សក្នុងសីលសម្បត្តិ ដូច្នេះ ។

ក្នុងអាការទាំងឡាយនោះ គប្បីជ្រាបដល់ទោសក្នុងសីលវិបត្តិ

ដោយពាក្យនិយាយក្នុងផ្នែកផ្សេងគ្នាជាមួយអានិសង្ស ក្នុងសីល-សម្បទា ដែលលោកសម្តែងទុកក្នុងពេលក្រោយចុះ សេចក្តីនោះគប្បីដឹងបានយ៉ាងងាយ ព្រោះហេតុនោះ លោកអាចារ្យបំណងនឹងសម្តែងដោយហេតុយ៉ាងដទៃមិនធ្វើឲ្យពិស្តារ ទើបផ្តើមពាក្យថា **អបិច** (ម្យ៉ាងទៀត) ជាដើម ។ ក្នុងពាក្យទាំងឡាយនោះ សីលសម្បទាជាគ្រឿងសាងនូវការពេញចិត្តដល់សត្វទាំងឡាយយ៉ាងណា សីលវិបត្តិក៏ជាគ្រឿងសាងនូវការមិនពេញចិត្តដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលថា បុគ្គលអ្នកទ្រុស្តសីល ។ល។ របស់ទេវតា និងមនុស្សទាំងឡាយដូច្នេះ ។

ឈ្មោះថា **ជាអ្នកដែល** (សព្រហ្មចារី) **មិនគប្បីប្រៀនប្រដៅ** គឺជាអ្នកដែលសព្រហ្មចារីគួរវៀរស ។

ពាក្យថា ជាទុក្ខ គឺមានទុក្ខកើតឡើងព្រម ។ ពាក្យថា មានការក្តៅក្រហាយចិត្ត បានដល់ ជាអ្នកមានការក្តៅក្រហាយជាខាងក្រោយរឿយៗ ក្នុងន័យថា យើងមិនបានធ្វើកម្មល្អទុក ហ្ន៎ ! ដូច្នេះជាដើម ។

ពាក្យថា ជាអ្នកមានសម្បុរអាក្រក់ បានដល់ ជាអ្នកវៀរចាកវណ្ណៈ គឺគុណធម៌ និងចាកវណ្ណៈ គឺ (សម្បុរនៃកាយ) ។ បទថា **អស្ស យោគ ទុស្សីលស្ស** ប្រែថា របស់បុគ្គលអ្នកទ្រុស្តសីលនោះ ។ ឈ្មោះថា មានសម្ផស្សជាទុក្ខ ព្រោះអត្ថថា មានសម្ផស្សដែលជាទុក្ខ

គឺជាហេតុនាំមកនូវសេចក្តីទុក្ខដល់បុគ្គលដែលត្រូវប៉ះពាល់ ។ ឈ្មោះថា ជាអ្នកមានតម្លៃតិច ព្រោះអត្ថថា មានតម្លៃតិច ព្រោះមិនមានគុណានុភាព ។

ពាក្យថា ដូចរណ្តៅលាមកប្រឡាក់មកជាយូរ គឺដូចជាអណ្តូងដែលគេសន្សំលាមក មានការប្រមូលទុកជាច្រើនឆ្នាំ ។ ឈ្មោះថា ជាអ្នកដែលនរណាៗ ជម្រះបានដោយលំបាក គឺជាអ្នកដែលនរណាៗ មិនគប្បីអាចជម្រះបាន ។

ឈ្មោះថា ដូចសំពត់រុំសាកសព គឺដូចសំពត់ដែលភ្លើងឆេះព្រោះការដុតសព ។ ឈ្មោះថា ជាអ្នកឃ្លាតចាកប្រយោជន៍ទាំង ២ គឺជាអ្នកឃ្លាតចាកប្រយោជន៍ ជាសមណៈ និងចាកភោគៈរបស់គ្រហស្ថ ។

បុរស ឈ្មោះថា **សព្វវេរី** ព្រោះអត្ថថា មានពៀរចំពោះបុគ្គលទាំងពួង ឬថា មានបុគ្គលទាំងពួងជាអ្នកមានពៀរនឹងគ្នា, **សព្វវេរី** នោះឯងជា **សព្វវេរិកោ** ។ ឈ្មោះថា **អសំវាសារហោ** ព្រោះអត្ថថា មិនគួរដល់នូវការនៅរួមគ្នា ។ ពាក្យថា ក្នុងព្រះសទ្ធម្ម បានដល់ ក្នុងព្រះបដិបត្តិសទ្ធម្ម និង បដិវេធសទ្ធម្ម ។

លោកអាចារ្យបំណងសម្តែងដោយពិស្តារ នូវខ្លឹមសារដែលបានពោលទុកដោយសង្ខេបថា ព្រោះភាពជាអ្នកមានចំណែកនៃទុក្ខដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងអគ្គិក្ខន្ធបរិយាយសូត្រ ដូច្នេះ

ទើបផ្ដើមពាក្យថា **ទុស្សីលានញ្ចិ** ដូច្នេះជាដើម ។ ភិក្ខុដែលមានចិត្ត ត្រេកអរដោយការរីករាយក្នុងសេចក្ដីសុខដែលកើតពីការបរិភោគ កាមគុណ ៥ និងក្នុងសេចក្ដីសុខ ដែលកើតពីការថ្វាយបង្គំជាដើម ដែលអ្នកដទៃធ្វើហើយ ឈ្មោះថា អ្នកមានចិត្តត្រេកអរ ។ល។ ក្នុង កាមគុណ ៥, បានដល់ ភិក្ខុទាំងឡាយនោះ ។ ឈ្មោះថា **តប្បច្ចយំ** ព្រោះអត្ថថា មានការរីករាយក្នុងសេចក្ដីសុខតាមដែលពោលហើយ មកនោះជាបច្ច័យ ។

ភ្ជាប់សេចក្ដីថា ទុក្ខំ ( ជា **តប្បច្ចយំ ទុក្ខំ** ) ។

បទថា **បស្សថ នោ** ប្រែថា អ្នកទាំងឡាយឃើញឬទេ ពួកអ្នក ឃើញខ្លះទេ ។

បទថា **មហន្តំ** ប្រែថា ធំ ។ បទថា **អគ្គិក្ខន្ធំ** ប្រែថា គំនរភ្លើង ។ បទថា **អាទិត្តំ** ប្រែថា ក្ដៅ ។ បទថា **សម្បជ្ជលិតំ** ប្រែថា ឆេះសន្ធោ សន្ធៅដោយជុំវិញ បង្ហួយជាបំណែកភ្លើង ។ បទថា **សជោតិភូតំ** គឺ មានពន្លឺ បានដល់ ពន្លឺដែលកើតឡើងជាមួយគ្នា ដោយអណ្ដាតភ្លើង ដែលឆេះឡើងដោយជុំវិញ ។ ពាក្យថា **អ្នកទាំងឡាយសម្គាល់សេចក្ដី នោះដូចម្ដេច** មានន័យថា ទ្រង់ត្រាស់សួរដើម្បីឲ្យមានការកាន់យក ការឃើញតាមថា អ្នកទាំងឡាយនឹងសម្គាល់ឃើញនូវសេចក្ដីដែល តថាគតកំពុងពោលដល់ក្នុងពេលឥឡូវនេះ នោះយ៉ាងណា ?

បទថា **អាលិង្គិត្វា** ប្រែថា ឱប ។ ពាក្យថា គប្បីចូលទៅអង្គុយ គឺគប្បីចូលទៅអង្គុយដោយកិរិយាឱបនោះៗ ឯង ។ ក្នុងព្រះសូត្រនេះ ព្រះសាស្តាទ្រង់នាំ មកហើយនូវខ្លឹមសារ គឺការឱបគំនរភ្លើង និងការឱបនាងក្រមុំតូចយ៉ាងណា ទ្រង់បំណងធ្វើឲ្យខ្លឹមសារនោះប្រាកដច្បាស់ ទើបត្រាស់ថា តថាគតនឹងប្រាប់ដូច្នេះជាដើម ។ ក្នុងបទទាំងឡាយនោះ បទថា **អារោចយាមិ** ប្រែថា តថាគតនឹងប្រាប់ ។

បទថា **វោ** ប្រែថា ដល់ពួកអ្នក។ បទថា **បដិវេទយាមិ** ប្រែថា នឹងឲ្យជ្រាប ។

ពាក្យថា សម្រាប់ភិក្ខុដែលទ្រុស្តសីល គឺសម្រាប់ភិក្ខុដែលមិនមានសីល បានដល់ វៀរចាកសីល ។

ពាក្យថា មានធម៌លាមក គឺមានសភាពអាក្រក់ ព្រោះភាពជាអ្នកមានអធ្យាស្រ័យថោកទាប ព្រោះហេតុជាបុគ្គលទ្រុស្តសីល នោះឯង ។

ពាក្យថា មានការប្រព្រឹត្តិមិនស្អាតដែលគប្បីនឹកដល់ដោយការសង្ស័យ គឺមានការប្រព្រឹត្តិជារបស់មិនស្អាត ដែលគេនឹកដល់ដោយការសង្ស័យ ព្រោះមានការប្រព្រឹត្តិតាមផ្លូវកាយជាដើម មិនបរិសុទ្ធ។ ពិតហើយបុគ្គលអ្នកទ្រុស្តសីលរមែងជាមនុស្សដែលអ្នកដទៃគួរសង្ស័យបាន តែម្យ៉ាងថា នេះជាវត្ថុដែលអ្នកនោះបានធ្វើទុក ដូច្នេះ

ព្រោះឃើញការធ្វើ ដែលមិនសមគួរខ្លះប៉ុណ្ណោះ,ម្យ៉ាងទៀត កាល ឃើញភិក្ខុទាំងឡាយកំពុងសន្ទនាគ្នា ដោយកិច្ចណាមួយប៉ុណ្ណោះ ក៏គិតថា ភិក្ខុទាំងឡាយនោះជ្រាបកម្មដែលយើងបានធ្វើទុក ហើយ ប្រឹក្សាគ្នាឬហ្ន៎ ! ដូច្នេះ ទើបឈ្មោះថា មានការប្រព្រឹត្តិដែលខ្លួនឯង នោះឯង នឹកដល់ដោយការសង្ស័យដូច្នេះឯង ។

ពាក្យថា មានការបិទបាំង គឺមានការងារដែលគប្បីបិទបាំង ព្រោះ ជាការងារដែលត្រូវខ្មាសអៀន ។ បទថា **អស្សមណស្ស** ប្រែថា មិនមែនសមណៈ ។

ឈ្មោះថា ប្តេជ្ញាថា ជាសមណៈក្នុងកិច្ចទាំងឡាយមានការចាប់ ស្លាកជាដើម ដោយមិច្ឆាប្តេជ្ញាថា សូម្បីយើងក៏ជាសមណៈ ដូច្នេះ ។ ឈ្មោះថា មិនមែនព្រហ្មចារី ក៏ព្រោះមិនមែនជាអ្នកដែលប្រព្រឹត្ត ប្រសើរ ។ ឈ្មោះថា ប្តេជ្ញាថាជាព្រហ្មចារី ក្នុងកិច្ចទាំងឡាយ មាន ឧបោសថកម្មជាដើម ដោយមិច្ឆាប្តេជ្ញាថា សូម្បីយើងក៏ជាព្រហ្មចារី ដូច្នេះ ។ ឈ្មោះថា ជាបុគ្គលស្អុយក្នុង ព្រោះត្រូវកម្មស្អុយ គឺសីល វិបត្តិតាមចូលទៅខាងក្នុង ។ ឈ្មោះថា **ជោកជាំ** គឺជោកជាំ ព្រោះការ ហូរជ្រាបនៃកិលេស មានរាគៈជាដើម តាមទ្វារទាំង ៦ ។ ឈ្មោះថា មានជាតិរសេមរសាម ព្រោះមានសំរាមគឺរាគៈជាដើមកើតឡើងព្រម ហើយ និងត្រូវលោកអ្នកមានសីលទាំងឡាយគប្បីបោះបង់ចោល ។

ពាក្យថា ដោយការឧបមា ជាមួយគំនរភ្លើង មានន័យថា ដោយមានឧបមាជាមួយនឹងវត្ថុអន់ថយ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ការដែលគួរចូលទៅអង្គុយឱប ។ល។ សេចក្ដីនេះនឹងប្រសើរជាង ដូច្នេះ ។ ភ្ជាប់សេចក្ដីថា ព្រះមានព្រះភាគ កាលទ្រង់សម្ដែងនូវទុក្ខ ( ដែលមានការបរិភោគកាមគុណ ៥ ដែលទាក់ទងជាមួយមាតុគ្រាមជាបច្ច័យ ) ហើយក៏ទ្រង់សម្ដែងនូវទុក្ខ ( ដែលមានការថ្វាយអភិវាទជាដើមជាបច្ច័យ ) ។

បទថា **វាលរជ្ជុយា** ប្រែថា ខ្សែដែលធ្វើដោយរោមកន្ទុយសត្វ ។ ខ្សែនោះ គ្រោតគ្រាតរឹងក្រៃលែង ។ ពាក្យថា **គប្បីខាត់ស្បែក** គឺគប្បីខាត់ដោយអំណាច ការរូស ។ បទថា **តេលធោតាយ** ប្រែថា លាបដោយប្រេង ។ បទថា **បច្ចោរស្មឹ** គឺ **បដិឧរស្មឹ** ប្រែថា ចំដើមទ្រូង អធិប្បាយថា ចំត្រង់កណ្ដាលទ្រូង ។ បទថា **អយោសង្កុនា** បានដល់ដង្កាប់ ។ បទថា **ផេណុទ្ទេហកំ** ( ពុះឡើងក្ដៅច្រូចច្រា ) គឺធ្វើឲ្យពុលឡើងក្ដៅច្រូចច្រា មានន័យថា ធ្វើឲ្យពុលដែលមានអាការផ្សេងៗ ច្រើនឲ្យតាំងឡើង ។

ទុក្ខដែលជារបស់ក្ដៅ ព្រោះភាពជាទុក្ខមានប្រមាណក្រៃលែងជាងទុក្ខក្នុងការអង្គុយឱបគំនរភ្លើង ជាផលរបស់កាមសុខនេះ ព្រោះហេតុនោះ កាមសុខនេះ ទើបឈ្មោះថា មានផលជាទុក្ខក្ដៅក្រៃលែង

ជានទុក្ខ ក្នុងការអង្គុយឱបគំនរភ្លើង អធិប្បាយថា សុខរបស់អ្នកទម្លាយនូវសីលហើយ គឺអ្នកទ្រុស្តសីល អ្នកមិនលះនូវកាមសុខ នឹងមានបានមកពីណា រមែងមិនមានដល់គេឡើយ ។ បទថា **សាទនេ** បានដល់ **សាទិយនេ** ( ព្រោះការរីករាយ ) ។ បទថា **យំ** គឺសេចក្តីរីករាយក្នុងការធ្វើអញ្ជលីកម្ម ។ ពាក្យថា សម្រាប់បុគ្គលមិនមានសីល គឺសម្រាប់បុគ្គលទ្រុស្តសីល ។ ពាក្យថា ត្រូវកម្ចាត់ គឺត្រូវសេចក្តីវិនាសនៃសីលប្រទូសរ៉ាយ ។ ពាក្យថា ត្រូវជីក គឺត្រូវជីកដោយការជីកយកមូលនៃកុសលធម៌ទាំងឡាយ, ម្យ៉ាងទៀត មានអធិប្បាយថា មានគុណក្នុងខ្លួនត្រូវជីករំលើងហើយ ។ បទថា ចាកភ័យទាំងពួង គឺចាកភ័យទាំងពួង មានភ័យ គឺការតិះដៀលខ្លួនឯងជាដើម ។ ឈ្មោះថា ចាកសុខក្នុងអធិគមទាំងពួង គឺចាប់តាំងពីឧបចារឈានឡើងទៅ ។

ពាក្យថា ដោយអាការផ្ទុយគ្នាចំពោះអាការ ដែលពោលមកបានដល់ ដោយអាការជាចំណែកផ្ទុយគ្នា ចំពោះអាការដែលពោលទុកក្នុងសីលវិបត្តិ គឺដោយពាក្យថា ជាអ្នកដែលជាទីស្រឡាញ់របស់ទេវតា និងមនុស្សទាំងឡាយ ដូច្នេះជាដើម ។ ក្នុងពាក្យថា **សូម្បីក្លិនកាយរបស់ភិក្ខុអ្នកមានសីល ក៏ធ្វើនូវបាមោជ្ជដល់ទេវតាទាំងឡាយបាន** ដូច្នេះ គប្បីអធិប្បាយគាថា ដែលថា **គន្ធោ ឥសីនំ ចិរទក្ខិតានំ**

ដូច្នេះជាដើមឲ្យពិស្ដារចុះ ។ សេចក្ដីពេញរបស់គាថា ដែលលើកមកមានពាក្យប្រែថា ក្លិនរបស់ពួកឥសីទាំងឡាយ អ្នកមានវត្តដែលសមាទានមកអស់កាលជាយូរ ឃ្លាតផុតចាកកាយហើយ រមែងផ្សាយទៅតាមខ្យល់បពិត្រលោកដ៏ចម្រើន ខ្ញុំម្ចាស់ត្រូវការនូវក្លិននោះដែលដូចជាភួងផ្កាឈើ ក្រអូបលើសស: ព្រោះថា ក្នុងក្លិននេះ ពួកទេវតាទាំងឡាយមិនសម្គាល់ថាជាបដិកូលឡើយ ដូច្នេះ ។

បទថា **អវិឃាតី** ប្រែថា គ្មានការប្រហារ ។ ការក្ដៅក្រហាយមានការសម្លាប់ ការឃុំឃាំងជាដើម ឈ្មោះថា អាសវៈដែលមានក្នុងបច្ចុប្បន្ន បានដល់ អន្តរាយទាំងឡាយ ។ ឈ្មោះថា មូលនៃទុក្ខទាំងឡាយដែលមានក្នុងភពខាងមុខ បានដល់ ភាពជាបុគ្គលទ្រុស្ដសីល ។ មានទីបំផុតដែលកន្លងបានហើយ ឈ្មោះថា **អច្ចន្ត** ( ដល់ទីបំផុត ) ។ ឈ្មោះថា **សន្តា** ( ស្ងប់ ) គឺស្ងប់គ្រប់ពេល ព្រោះមិនមានភាពខ្វល់ខ្វាយ គឺ **កិលេសបរិឡាហ** ( ភាពក្ដៅរោលរាល គឺកិលេស ) ។

ពាក្យថា ភ័យខ្លាច គឺញាប់ញ័រដោយការញាប់ញ័រ គឺញាណ ។

ពាក្យថា គប្បីញុំាងសីលឲ្យផូរផង់ គឺគប្បីធ្វើឲ្យបរិសុទ្ធ ។

( ចប់ បរមត្ថមញ្ជូសា សំវណ្ណនា វិសុទ្ធិមគ្គ )

# បរិច្ឆេទទី ១

## សីលនិទ្ទេស ក្នុងបករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

## ដែលខ្ញុំម្ចាស់ធ្វើដើម្បីប្រយោជន៍ដល់បាមោជ្ជនៃសាធុជន ដូច្នេះឯង

........................

# ធុតង្គនិទ្ទេស

ព្រោះហេតុដែលព្រះយោគីអ្នកបានសមាទាននូវសីលហើយ គួរធ្វើការសមាទានធុតង្គ ( តទៅ ) កាលធ្វើយ៉ាងនោះ សីលរបស់លោកត្រូវបានលាងមន្ទិល ហើយដោយទឹក គឺគុណ មានសេចក្តីប្រាថ្នាតិច និងសេចក្តីសន្តោស ការជុសខាត់ ភាពស្ងប់ ការមិនសន្សំ ( នៃកិលេស ) ការប្រារព្ធសេចក្តីព្យាយាម និងភាពជាអ្នកចិញ្ចឹមងាយ ជាដើម នឹងជាសីលបរិសុទ្ធល្អ ឯវត្តទាំងឡាយរបស់លោកក៏ដល់ព្រមផងដែរ អ្នកមានសមាចារទាំងពួងបរិសុទ្ធដោយគុណ គឺសីល និងវត្តដែលរកទោសមិនបានដូច្នេះហើយ នឹងជាអ្នកឈ្មោះថា តាំងនៅក្នុងអរិយវង្ស ( ជាប្រពៃណីរបស់ព្រះអរិយៈជាម្ចាស់ទាំងឡាយ ) ៣ ប្រការដែលជាវង្សចាស់គួរសម្រេចអរិយវង្សប្រការគម្រប់៤ពោល គឺភាពជាអ្នកមានភាវនាជាទីរីករាយបាន ព្រោះហេតុនោះ យើងនឹងផ្តើមធុតង្គកថានៅពេលឥឡូវនេះ ដើម្បីញុំាងគុណទាំងឡាយ មានការប្រាថ្នាតិច សន្តោសជាដើម ដែលជាហេតុផូរផង់នៃសីល មានប្រការដូចដែលបានពោលហើយ ឲ្យដល់ព្រមតទៅ, មែនពិតធុតង្គ ១៣ប្រការ ព្រះមានព្រះភាគ ទ្រង់បានអនុញ្ញាតទុកសម្រាប់កុលបុត្តទាំងឡាយ អ្នកលះបង់លោកាមិសៈបាន មិនអាល័យក្នុងរូបកាយ និងជីវិតប្រាថ្នា

នឹងញុំាងអនុលោមប្បដិបទាឲ្យសម្រេចតែម្យ៉ាង ធុតង្គ ១៣ គឺ

**១-បំសុកូលិកង្គ** អង្គរបស់ភិក្ខុ អ្នកមានកិរិយាទ្រទ្រង់នូវចីវរដែលដល់នូវភាពគួរខ្ពើម ជាប្រក្រតី ។

**២-តេចីវរិកង្គ** អង្គរបស់ភិក្ខុ អ្នកមានកិរិយាទ្រទ្រង់នូវត្រៃចីវរ ជាប្រក្រតី។

**៣-បិណ្ឌបាតិកង្គ** អង្គរបស់ភិក្ខុ អ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាត ជាប្រក្រតី។

**៤-សបទានចារិកង្គ** អង្គរបស់ភិក្ខុ អ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតតាមលំដាប់ផ្ទះ ជាប្រក្រតី ។

**៥-ឯកាសនិកង្គ** អង្គរបស់ភិក្ខុ អ្នកមានកិរិយាបរិភោគភោជនតែក្នុងអាសនៈមួយ ជាប្រក្រតី ។

**៦-បត្តបិណ្ឌិកង្គ** អង្គរបស់ភិក្ខុ អ្នកមានកិរិយាបរិភោគភោជនតែក្នុងបាត្រមួយ ជាប្រក្រតី ។

**៧-ខលុបច្ឆាភត្តិកង្គ** អង្គរបស់ភិក្ខុ អ្នកមានកិរិយាមិនបរិភោគនូវភត្តដែលខ្ជួន ហាមភោជនរួចហើយ ទើបបានមកក្នុងកាលជាខាងក្រោយ ជាប្រក្រតី ។

**៨-អារញ្ញិកង្គ** អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅអាស្រ័យក្នុងព្រៃជាប្រក្រតី ។

៩-រុក្ខមូលិកង្គ អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅអាស្រ័យទៀបគល់ឈើជាប្រក្រតី ។

១០-អព្ភោកាសិកង្គ អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅអាស្រ័យក្នុងទីវាលស្រឡះ ជាប្រក្រតី ។

១១-សោសានិកង្គ អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅអាស្រ័យក្នុងព្រៃស្មសាន ជាប្រក្រតី ។

១២-យថាសន្ថតិកង្គ អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅតែក្នុងទីសេនាសនៈ ដែលសង្ឃសម្តែងឲ្យជាប្រក្រតី ។

១៣-នេសជ្ជិកង្គ អង្គរបស់ភិក្ខុ អ្នកមានកិរិយាហាមឃាត់នូវឥរិយាបថដេក ហើយនៅដោយឥរិយាបថអង្គុយ ជាប្រក្រតី ។

វិនិច្ឆ័យក្នុងធុតង្គនោះ គប្បីជ្រាបដោយអត្ថ ដោយបកិណ្ណកមានលក្ខណៈជាដើម ១ ដោយការសមាទាន ១ ដោយវិធីប្រតិបត្តិ ១ ដោយប្រភេទ ១ ដោយការបែកធ្លាយ ១ ដោយអានិសង្សនៃធុតង្គនោះៗ ១ ដោយកុសលត្តិកៈ ១ ដោយការចែកសព្ទ មានធុតង្គសព្ទជាដើម ១ ដោយសង្ខេប និងដោយពិស្តារ ។

## វិនិច្ឆ័យដោយអត្ថ

ក្នុងបទទាំងឡាយនោះ នឹងវិនិច្ឆ័យដោយអត្ថមុន សំពត់ណា

ដែលដូចជាគំនរធូលីក្នុងទីនោះៗ ដោយអត្ថថា ជាពុំនូក ព្រោះដាក់នៅលើគំនរធូលីក្នុងទីទាំងឡាយមានច្រកចូល និងព្រៃស្មសានព្រមទាំងគំនរសំរាមជាដើម ក្នុងទីណាមួយ ព្រោះដូច្នោះសំពត់នោះ ទើបឈ្មោះថា **បង្សុកូល** ( សំពត់ដូចគំនរធូលី ), ម្យ៉ាងទៀត សំពត់ឈ្មោះថា បង្សុកូល ព្រោះទៅកាន់ភាវៈនៃសំពត់ដែលបុគ្គលគួរខ្ពើម អធិប្បាយថា ដល់នូវភាពជាសំពត់ដែលគួរខ្ពើមដូចធូលី ការទ្រទ្រង់នូវសំពត់បង្សុកូលដែលមានពាក្យអធិប្បាយបានហើយយ៉ាងនោះ ឈ្មោះថា បង្សុកូល ការទ្រទ្រង់នូវសំពត់បង្សុកូលជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះភិក្ខុនោះទើបឈ្មោះថា បង្សុកូលិកៈ អង្គនៃភិក្ខុបង្សុកូលិកៈនោះ លោកហៅថា **បង្សុកូលិកង្គ** ។

ហេតុ លោកហៅថា អង្គ ។ ព្រោះដូច្នោះ គប្បីជ្រាបថា ពាក្យថា អង្គជាឈ្មោះនៃការសមាទានដែលជាហេតុនៃភាពជាបង្សុកូលិកៈរបស់ភិក្ខុនោះ ។

ដោយន័យតែមួយដូចគ្នា ( ការទ្រទ្រង់ ) ត្រៃចីវរ ពោលគឺសង្ឃាដី ឧត្តរាសង្គៈ អន្តរវាសកៈ ជាប្រក្រតីនៃភិក្ខុនោះ ហេតុនោះភិក្ខុនោះ ទើបឈ្មោះថា **តេចីវរិក** អង្គនៃភិក្ខុតេចីវរិកៈនោះ ឈ្មោះថា **តេចីវរិកង្គ** ។

ការធ្លាក់ចុះនៃដុំអាមិសពោល គឺភិក្ខានោះឯង ឈ្មោះថា បិណ្ឌ-

បាត ម្យ៉ាងទៀត ការធ្លាក់ចុះនៃដុំបាយដែលជនទាំងឡាយដទៃ ឲ្យហើយនោះឯង ឈ្មោះថា បិណ្ឌបាត មានពាក្យអធិប្បាយថា ការធ្លាក់ចុះក្នុងបាត្រនៃដុំបាយដែលបុគ្គលដទៃឲ្យ ។ ភិក្ខុណាស្វែងរក គឺចូលទៅកាន់ត្រកូលនោះៗ ស្វែងរកនូវបិណ្ឌបាតនោះ ហេតុនោះ ភិក្ខុនោះឈ្មោះថា បិណ្ឌបាតិក ( អ្នកស្វែងរកបិណ្ឌបាត ) ន័យម្យ៉ាងទៀត ការធ្លាក់ទៅដើម្បីដុំបាយជាវត្តរបស់ភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះឈ្មោះថា បិណ្ឌបាតី ។ ពាក្យថា ធ្លាក់ទៅ( ក្នុងទីនេះ ) មានន័យថាត្រាច់ទៅ ។

**បិណ្ឌបាតី** នោះឯង ឈ្មោះថា បិណ្ឌបាតិកៈ អង្គនៃភិក្ខុបិណ្ឌបាតិកៈនោះ ឈ្មោះថា បិណ្ឌបាតិកង្គ ( អង្គនៃភិក្ខុអ្នកមានការត្រាច់ទៅបិណ្ឌបាតជាវត្ត ) ។

ការរំលង ហៅថា ទាន ការប្រាសចាកទានៈ ឈ្មោះថា អបទាន អធិប្បាយថា មិនរំលង ការទៅណាប្រព្រឹត្តទៅដោយអបទាន ការប្រព្រឹត្តិទៅនោះ ឈ្មោះថា **សបទាន** អធិប្បាយថា ត្រាច់ទៅ វៀរចាកការរំលង គឺត្រាច់ទៅតាមលំដាប់ផ្ទះ ការត្រាច់ទៅដោយប្រាសចាកការរំលងនេះ ជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា **សបទានចារី** សបទានចារីនោះឯងជាសបទានចារិកៈ អង្គនៃភិក្ខុអ្នកសបទានចារិកៈនោះ ឈ្មោះថា **សបទានចារិកង្គ** ។

ការឆាន់នៅក្នុងអាសនៈតែមួយ ឈ្មោះថា **ឯកាសន** ការឆាន់នៅក្នុងអាសនៈ ១ នោះឯង ជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា **ឯកាសនិក** អង្គនៃភិក្ខុឯកាសនិកៈនោះ ឈ្មោះថា **ឯកាសនិកង្គ** ។

ចំពោះតែដុំបាយក្នុងបាត្រប៉ុណ្ណោះ ព្រោះហាមភោជនទី ២ ឈ្មោះថា បត្តបិណ្ឌ ( ការកាន់យកបត្តបិណ្ឌៈនោះ ក៏ឈ្មោះថា បត្តបិណ្ឌៈ ) ឥឡូវនេះ ធ្វើសេចក្ដីសម្គាល់នូវបត្តបិណ្ឌៈក្នុង ( អត្ថ គឺ ) ការកាន់យកតែដុំបាយនៅក្នុងបាត្រជាប្រក្រតីរបស់ភិក្ខុនោះហេតុនោះទើបឈ្មោះថា បត្តបិណ្ឌិក ( អ្នកមានការកាន់យកតែដុំបាយជាប្រក្រតី ) អង្គនៃភិក្ខុបត្តបិណ្ឌិកៈនោះ ឈ្មោះថា **បត្តបិណ្ឌិកង្គ** ។

ពាក្យថា **ខលុ** ជានិបាតចុះក្នុងអត្ថបដិសេធភត្ត ដែលភិក្ខុជាអ្នកហាម ( ភត្ត ) ហើយបានមកជាខាងក្រោយ ឈ្មោះថា **បច្ឆាភត្ត** ការឆាន់បច្ឆាភត្តនោះ ក៏ឈ្មោះថា **បច្ឆាភត្ត** ព្រោះធ្វើការសម្គាល់នូវបច្ឆាភត្តក្នុង ( អត គឺ ) ការឆាន់បច្ឆាភត្តនោះ, ការឆាន់បច្ឆាភត្ត ជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា **បច្ឆាភត្តិក** ( អ្នកមានការឆាន់បច្ឆាភត្តជាប្រក្រតី ) ភិក្ខុមិនមែនជាអ្នកមាន ការឆាន់បច្ឆាភត្តជាប្រក្រតី ឈ្មោះថា **ខលុបច្ឆាភត្តិកៈ**, ពាក្យថា បច្ឆាភត្តនេះជាឈ្មោះនៃការឆាន់អតិរិត្តភោជន ដែលហាមដោយអំណាច

នៃការសមាទាន ( មានន័យថា មិនមែនហាមដោយសិក្ខាបទ តែហាមដោយការសមាទាន ) តែក្នុងអដ្ឋកថាពោលថា សត្វបក្សីម្យ៉ាង ឈ្មោះថា **ខលុ** សត្វនោះបេះផ្លែឈើបាន ( មួយផ្លែ ) ហើយ ( ចៃដន្យ ) របូតធ្លាក់ទៅ រមែងមិនស៊ីផ្លែឈើដទៃទៀតទេ ( ក្នុងថ្ងៃនោះ ) ភិក្ខុនេះក៏ដូច្នោះ ហេតុនោះ ទើបឈ្មោះថា **ខលុបច្ឆាភត្តិកៈ** ( អ្នកមិនឆាន់បច្ឆាភត្ត ជាប្រក្រតីដូចសត្វខលុ ) អង្គនៃភិក្ខុខលុបច្ឆាភត្តិកៈនោះ ឈ្មោះថា **ខលុបច្ឆាភត្តិកង្គ** ។

ការចូលទៅក្នុងព្រៃ ឈ្មោះថា **អារញ្ញ** ការចូលទៅក្នុងព្រៃនោះជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា **អារញ្ញិកៈ** ( អ្នកមានការចូលទៅក្នុងព្រៃជាប្រក្រតី ) អង្គនៃភិក្ខុអារញ្ញិកៈនោះ ឈ្មោះថា **អារញ្ញិកង្គ** ។

ការចូលនៅត្រង់គល់ឈើគឺរុក្ខមូលការចូលនៅត្រង់គល់ឈើនោះ ជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា **រុក្ខមូលិកៈ** អង្គនៃភិក្ខុរុក្ខមូលិកៈនោះ ឈ្មោះថា **រុក្ខមូលិកង្គ** ។

សូម្បីន័យក្នុង **អព្ភោកាសិកង្គ** និង **សោសានិកង្គ** ក៏ដូចន័យនេះឯង ។

សេនាសនៈដែលក្រាលទុកហើយយ៉ាងណានោះ ឈ្មោះថា យថាសន្ថត ។ ពាក្យថា **យថាសន្ថ** នេះ ជាឈ្មោះនៃសេនាសនៈ

ដែលសេនាសនបញ្ញាបកៈ រៀបចំឲ្យជាដំបូងយ៉ាងនេះថា **ឥទំ តុយ្ហំ បាបុណាតិ** ( សេនាសនៈនេះគួរដល់លោក ) ការដែលនៅក្នុងសេនាសនៈ ដែលក្រាលហើយយ៉ាងណានោះ ជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា **យថាសន្ថតិក** អង្គនៃភិក្ខុយថាសន្ថតិកៈនោះ ឈ្មោះថា **យថាសន្ថតិកង្គ** ។

ការវៀរចាកការដេកចេញ ( សម្រេចឥរិយាបថ ) នៅដោយការអង្គុយជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះឈ្មោះថា នេសជ្ជិក អង្គនៃភិក្ខុ **នេសជ្ជិកៈ** នោះ ឈ្មោះថា **នេសជ្ជិកង្គ** ។ អង្គទាំងឡាយនេះ ទាំងអស់ ឈ្មោះថា ធុតង្គ ព្រោះហេតុជាអង្គនៃភិក្ខុដែលឈ្មោះថា ធុត ព្រោះភាពជាអ្នកកម្ចាត់កិលេសបាន ដោយការសមាទាននោះៗ ម្យ៉ាងទៀត ឈ្មោះថា **ធុតង្គ** ព្រោះមានញាណដែលបានវោហារថា ធុត ព្រោះហេតុថា ជាគ្រឿងកម្ចាត់កិលេសជាអង្គ ។ ន័យម្យ៉ាងទៀត អង្គទាំងឡាយនោះ ឈ្មោះថា ធុត ព្រោះកម្ចាត់ធម៌ដែលជាសត្រូវទាំងឡាយបានផង ជាអង្គនៃការបដិបត្តិផង ហេតុនោះ ទើបឈ្មោះថា ធុតង្គ ។

ក្នុងបទទាំងឡាយនោះ គប្បីជ្រាបវិនិច្ឆ័យដោយអត្ថដូចពោលមក ដូច្នេះ ជាលំដាប់ដំបូងសិន ។

## លក្ខណាទិចតុក្កៈរបស់ធុតង្គ
## វិនិច្ឆ័យអំពីលក្ខណៈជាដើម

ធុតង្គទាំងអស់នេះ មានសមាទានចេតនាជាលក្ខណៈ មែនពិតសូម្បីពាក្យនេះ លោកក៏បានពោលទុកថា អ្នកសមាទាន បានដល់បុគ្គលធម៌ជាគ្រឿងសមាទាន បានដល់ ចិត្ត និងចេតសិក សមាទានចេតនា ជាតួធុតង្គរបស់ដែលហាម គឺវត្ថុ ម្យ៉ាងទៀត ធុតង្គទាំងអស់នោះ មានការកម្ចាត់សេចក្តីល្មោភជាកិច្ច មានការប្រាសចាកការឡេះឡោះ ជាអាការប្រាកដ មានការប្រាថ្នាតិចជាបទដ្ឋាន ។

ក្នុងបទទាំងឡាយនោះគប្បីជ្រាបវិនិច្ឆ័យដោយបកិណ្ណកៈមានលក្ខណៈ ជាដើមដូច្នេះ ។

## វិនិច្ឆ័យអំពីការសមាទាន
## និងវិធី (បដិបត្តិ) ជាដើម

ការវិនិច្ឆ័យក្នុង ៥ បទ មានបទថា ដោយការសមាទាន និងវិធី ( បដិបត្តិ ) ជាដើម គប្បីជ្រាបដូចតទៅ

ធុតង្គទាំងអស់នោះ កាលព្រះមានព្រះភាគ ទ្រង់មានព្រះជន្មនៅឡើយ គប្បីសមាទាននៅក្នុងសម្នាក់របស់ព្រះសាស្តាកាលទ្រង់

បរិនិព្វានទៅហើយ គប្បីសមាទាននៅក្នុងសម្នាក់ព្រះមហាសាវក កាលមិនមានព្រះមហាសាវក គប្បីសមាទាននៅក្នុងសម្នាក់ព្រះខីណាស្រព... ព្រះអនាគាមី... ព្រះសកទាគាមី... ព្រះសោតាបន្ន... ភិក្ខុទ្រទ្រង់ព្រះត្រៃបិដក... ភិក្ខុទ្រទ្រង់វិនយបិដក... ភិក្ខុអ្នកទ្រទ្រង់ឯកបិដក... ព្រះឯកសង្គីតិកៈ ( ភិក្ខុទ្រទ្រង់និកាយណាមួយ ) ព្រះអដ្ឋកថាចារ្យ កាលមិនមានព្រះអដ្ឋកថាចារ្យ គប្បីសមាទានក្នុងសម្នាក់ភិក្ខុអ្នកទ្រទ្រង់ធុតង្គ...កាលមិនមានលោកអ្នកទ្រទ្រង់ធុតង្គគប្បីបោសសម្អាតលានព្រះចេតិយ ហើយអង្គុយប្រហោងពោលសមាទាន ដូចជាពោលក្នុងសម្នាក់របស់ព្រះសម្មាសម្ពុទ្ធចុះ សូម្បីសមាទានខ្លួនឯងក៏ប្រើបានដូចគ្នា ។ ឯក្នុងការសមាទានខ្លួនឯងក៏ប្រើបាននេះ គប្បីពោលរឿងសេចក្តីប្រាថ្នាតិចក្នុងធុតង្គរបស់ព្រះថេរៈ ជាបងរបស់បងប្អូនពីរនាក់ក្នុងចេតិយបព៌ត ( ជានិទស្សនៈ ) នេះជាពាក្យពោលដោយទូទៅមុនសិន ។

# មហាដីកា

## ពណ៌នាធុតង្គនិទ្ទេស

បុគ្គលឈ្មោះថា អ្នកប្រាថ្នាតិច ព្រោះអត្ថថា មានសេចក្តីប្រាថ្នាតិច បានដល់ អ្នកដែលប្រាសចាកសេចក្តីត្រេកអរក្នុងបច្ច័យ ។ ភាវៈនៃបុគ្គលអ្នកប្រាថ្នាតិចនោះ ឈ្មោះថា សេចក្តីប្រាថ្នាតិច មានសេចក្តីថា ភាពជាអ្នកមានអធ្យាស្រ័យមិនលោភ ។ ការរីករាយស្មើ ការរីករាយតាមរបស់ដែលមាន ឬការរីករាយតាមវត្ថុរបស់ខ្លួន ឈ្មោះថា **សន្តុដ្ឋិ, សន្តុដ្ឋិ** នោះឯងជា **សន្តុដ្ឋិតា** ( សេចក្តីសន្តោស ) បានដល់ការរីករាយក្នុងបច្ច័យទាំងឡាយតាមដែលបាន គឺប៉ុណ្ណោះក៏បាន មិនប្រាថ្នាដទៃទៀត ។ម្យ៉ាងទៀត ត អក្សរ ក្នុងបទថា **សន្តុដ្ឋិតាទីហិ** ជាតួធ្វើការភ្ជាប់បទ ។ ម្យ៉ាងទៀត មានបាឋៈថា **សន្តុដ្ឋិ អាទីហិ** ដូច្នេះ ។

ពាក្យថា គុណទាំងឡាយនោះ បានដល់ គុណទាំងឡាយមានការប្រាថ្នាតិចជាដើម ដែលជាហេតុនៃសេចក្តីផូរផង់របស់សីល ។

បទថា **សម្បាតេតុំ** ប្រែថា បំណងនឹងធ្វើឲ្យដល់ព្រម ។ ពិតហើយ គុណទាំងឡាយនោះប៉ុណ្ណោះ ដែលព្រះយោគីបានមកដោយសេចក្តីបរិសុទ្ធិនៃសីល រមែងដល់ព្រម ក៏ដោយធុតធម៌ទាំងឡាយ ។

ពាក្យថា ការសមាទានធុតង្គ បានដល់ ការកាន់យកដោយប្រពៃ

នូវអង្គកម្មាត់ គឺហេតុដែលញ៉ាំញីនូវកិលេសទាំងឡាយនោះឯង ។

បទថា ឯវំ ប្រែថា កាលបើដូច្នោះ មានន័យថា កាលបើបាន សមាទានធុតង្គហើយ ។ បទថា អស្ស យោគ យោគិនោ ប្រែថា របស់យោគីនោះ ។ ឈ្មោះថា ការជុសខាត់ គឺការខាត់ បានដល់ ការជុសខាត់ ការធ្វើឲ្យស្រោល ស្តើងនូវកិលេសទាំងឡាយដោយ ប្រពៃនោះឯង ។

ឈ្មោះថា ភាពស្ងប់ បានដល់ភាពជាអ្នកមានកាយតាំងនៅក្នុង សេចក្តីស្ងប់ ដែលជាឧបាយនៃការស្ងប់ចិត្ត ។ ឈ្មោះថា ការមិនសន្សំ បានដល់ ការបដិបត្តិ ធ្វើឲ្យកិលេសទាំងឡាយមិនចម្រើន គឺមិនសន្សំ ទុកក្នុងសន្តានរបស់បុគ្គលនោះ ។ ឈ្មោះថា ការប្រារព្ធសេចក្តីព្យា-យាម គឺភាពជាអ្នកបានប្រារព្ធសេចក្តីព្យាយាមហើយ ដោយទាក់ទង ជាមួយកិច្ច មានការមិនធ្វើបាបទាំងពួង ដែលមិនទាន់កើតឡើង ឲ្យ កើតឡើងជាដើម ។ ឈ្មោះថា ភាពជាបុគ្គលចិញ្ចឹមងាយ គឺជាបុគ្គល ដែលឧបដ្ឋាកទាំងឡាយគួរចិញ្ចឹមរក្សាបានដោយងាយ ដែលសម្រេច ពីភាពជាបុគ្គលប្រាថ្នាតិចជាដើម តាមដែលពោលហើយ បានដល់ ភាពជាបុគ្គលដែលគេចិញ្ចឹមបានយ៉ាងងាយស្រួល ។

ដោយ អាទិ-ស័ព្ទ ( ដែលប្រែថា ជាដើម ) លោកសង្គ្រោះយក គុណទាំងឡាយ មានភាពជាអ្នកមានកិច្ចតិច ភាពជាអ្នកប្រព្រឹត្តស្រោល

ជាដើមទុក ។ សីលតាមដែលសមាទានហើយនោះឯង ឈ្មោះថា នឹងបរិសុទ្ធល្អ ព្រោះភាពជាអ្នកនៅឆ្ងាយពីធម៌ ដែលជាបដិបក្ខ ។ វត្តទាំងឡាយ គឺធុតធម៌ទាំងឡាយ ឈ្មោះថា នឹងដល់ព្រម គឺនឹងបរិបូរ ឬនឹងសម្រេចផល ។

សេចក្ដីសន្ដោសដោយចីវរ បិណ្ឌបាត និងសេនាសនៈ តាមមាន តាមបាន ដែលដល់នូវភាពមាំទាំ តាំងនៅដោយភាពជាប្រពៃណីរបស់ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម តាំងពីដើមយ៉ាងណា លោកអាចារ្យពោលថា តាំងមាំក្នុងអរិយវង្ស ៣ ខាងដើមដូច្នេះ សំដៅយកភាវៈដែលតាំងមាំក្នុងសេចក្ដីសន្ដោសនោះ ។

បុគ្គលឈ្មោះថា **ភាវនារាម** ( មានភាវនាជាទីរីករាយ ) ព្រោះអត្ថថា មានភាវនាជាអារាមជាទីគួររីករាយ ភាវៈនៃភាវនារាមនោះឈ្មោះថា **ភាវនារាមតា** (ភាពជាអ្នកមានភាវនាជាទីរីករាយ) បានដល់ភាពជាអ្នកប្រកបត្រូវក្នុង សមថភាវនា និងវិបស្សនាភាវនា ។

ភ្ជាប់សេចក្ដីបាលីថា **យស្មា អធិគមារហោ ភវិស្សតិ តស្មា** ប្រែថា ព្រោះហេតុជាអ្នកដែលគួរដល់ការសម្រេចដូច្នោះ ។

លាភ និងសក្ការៈជាដើម ឈ្មោះថា **លោកាមិស** ( អាមិសក្នុងលោក ) ព្រោះត្រូវតណ្ហាស្ទាបអង្អែលបាន និងព្រោះជារបស់ទាក់ទងក្នុងលោក ។ វិបស្សនាភាវនា ឈ្មោះថា **អនុលោមប្បដិបទា** ព្រោះ

អនុលោមដល់ការសម្រេចព្រះនិព្វាន ។

ពាក្យថា ដោយអត្ថ គឺដោយខ្លឹមសាររបស់ពាក្យ ។ ពាក្យថា ដោយប្រភេទ គឺដោយការបែក ។ ពាក្យថា ដោយការបែកធ្លាយ គឺដោយការវិនាស ។ ពាក្យថា ស័ព្ទទាំងឡាយមាន ធុត-ស័ព្ទ ជាដើមបានដល់ ស័ព្ទថា ធុត-ស័ព្ទថា ធុតវាទ-ស័ព្ទថា ធុតធម្ម និងស័ព្ទថា ធុតង្គ ។

បទថា **សមាសព្យាសតោ** ប្រែថា ដោយសង្ខេប និងដោយពិស្តារ ។

បទថា **រថិកា** ប្រែថា ច្រកចូល ។ បទថា **សង្ការកូដាទីនំ** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថ គឺនិទ្ធារណៈ ។ បទថា **អព្ភុគ្គតដ្ឋេន** ប្រែថា ដោយការសម្គាល់ថា នៅខាងលើ ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា កូល-ស័ព្ទ មានអត្ថថា **សមុស្សយ** ( ដែលលើកឡើងទីទួល ត្រើយកោះ ) ក្នុងប្រយោគថា **នទិយា កូលំ** ត្រើយនៃទន្លេជាដើមដូច្នេះ ទើបពោលថា ឈ្មោះថា **បង្សុកូល** ព្រោះអត្ថថា **ដូចគំនរធូលី** ដូច្នេះ ។

កុ-ស័ព្ទ ក្នុងសេចក្តីថា គួរខ្ពើម, ឧល-ស័ព្ទ មានអត្ថថា ដល់ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា អធិប្បាយថា ដល់នូវភាពគួរខ្ពើម ដូច្នេះ, ន័យម្យ៉ាងទៀត សំពត់ ឈ្មោះថា បង្សុកូល ព្រោះអត្ថថា ទៅ គឺប្រព្រឹត្តទៅ ដល់នូវភាពគួរខ្ពើម ដូចធូលី ។ ការ

ទ្រទ្រង់សំពត់បង្សុកូល ( បង្សុកូលធារណា ) ឈ្មោះថា បង្សុកូល ដោយលុបបទចុង ( គឺបទថា **ធារណៈ** ប្រែថា ការទ្រទ្រង់ ), ភិក្ខុ ឈ្មោះថា **បង្សុកូលិក** ព្រោះអត្ថថា មានការទ្រទ្រង់សំពត់បង្សុកូល នោះជាប្រក្រតី ដូចពាក្យថា **អាបូបិក** ( អ្នកមានការស៊ីនំជាប្រក្រតី ) ដូច្នេះ ។ ហេតុ ឈ្មោះថា អង្គ ព្រោះអត្ថថា ទៅ គឺដល់នូវភាពជាហេតុ ព្រោះអាងផលរបស់ខ្លួន ។

លោកហៅបុគ្គលថា **បង្សុកូលិក** ដោយធម៌ណា, ធម៌ ពោល គឺសមាទានចេតនានោះ ឈ្មោះថា បង្សុកូលិកង្គ ព្រោះអត្ថថា ជាអង្គ នៃបុគ្គល ដែលឈ្មោះថា បង្សុកូលិកនោះ ។ ព្រោះហេតុនោះ ទើប លោកពោលថា បង្សុកូលិកស្ស ដូច្នេះជាដើម ។ បទថា **តស្ស យោគ សមាទានស្ស** ប្រែថា នៃការសមាទាននោះ ។ ចេតនា ឈ្មោះថា ការ សមាទាន ព្រោះអត្ថថា ជាហេតុ ឲ្យកាន់យកដោយប្រពៃ ។

ពាក្យថា ដោយន័យដូចគ្នានោះឯង មានន័យថា ការទ្រទ្រង់ សំពត់បង្សុកូល ឈ្មោះថា បង្សុកូល, ភិក្ខុអ្នកមានការទ្រទ្រង់សំពត់ បង្សុកូលជាប្រក្រតីនោះ ឈ្មោះថា បង្សុកូលិក, អង្គរបស់ភិក្ខុអ្នក ទ្រទ្រង់សំពត់បង្សុកូលជាប្រក្រតីនោះ បានដល់ សមាទានចេតនា ហៅថា បង្សុកូលិកង្គ យ៉ាងណា ដោយន័យនៃអត្ថរបស់ពាក្យនេះ នោះឯង ការទ្រទ្រង់ចីវរ ៣ ផ្ទាំង ឈ្មោះថា **តិចីវរ**, ភិក្ខុ អ្នកមាន

ការទ្រទ្រង់ចីវរ ៣ ផ្ទាំងនោះ ជាប្រក្រតី ឈ្មោះថា **តេចីវរិក** អង្គនៃភិក្ខុ ឈ្មោះថា **តេចីវរិក** នោះ បានដល់ សមាទានចេតនា គប្បីជ្រាបថា ហៅថា **តេចីវរិកង្គ** ដូច្នេះ ។ ក្នុងចីវរ ៣ ផ្ទាំងនោះ មានសង្ឃាដីជាដើមប៉ុណ្ណោះ មានសមញ្ញា ( ឈ្មោះចំពោះ ) ថា ត្រៃចីវរ, ក្នុងសំពត់រុំបូស សំពត់ចាំវស្សាជាដើម មិនមានសមញ្ញាថា ត្រៃចីវរទេ ព្រោះហេតុនោះ លោកអាចារ្យកាលនឹងសម្តែងដល់ត្រៃចីវរទាំងឡាយនោះ តាមសភាវៈដែលមាន ទើបពោលថា ពោល គឺសង្ឃាដី ឧត្តរាសង្គៈ និងអន្តរវាសកៈ ដូច្នេះ ។

ពាក្យថា **បិណ្ឌបាតនោះ** មានន័យថា ភិក្ខុឈ្មោះថា **បិណ្ឌបាតិក** ព្រោះអត្ថថា ស្វែងរកបិណ្ឌបាត ពោល គឺដុំបាយដែលជនទាំងឡាយដាក់ទៃប្រគេន នឹងមានការធ្លាក់ចុះទៅក្នុងបាត្រ, ដូចជាពាក្យថា **ពាទរិក សាមាកិក** ជាដើម ដូច្នោះ ។ ឈ្មោះថា **បិណ្ឌបាតី** នោះឯងជា បិណ្ឌ-បាតិក, ដូចជា **ភទ្ទ** នោះឯងជា **ភទ្ទក** ដូច្នោះ ។ ឈ្មោះថា ការដាច់ជាផ្នែកៗ គឺការដាច់ជាចំណែកៗ បានដល់ មិនជាការប្រព្រឹត្តិទៅរកចន្លោះមិនបាន ។ ឈ្មោះថា ការមិនដាច់ជាផ្នែកៗ ក៏ដោយការបដិ-សេធន៍នូវការដាច់ជាផ្នែកៗ នោះ គឺការមិនដាច់ជាចំណែកៗ បានដល់ការប្រព្រឹត្តិទៅដោយមិនរំលង ។

បទថា **សហ អបទានេន** ប្រែថា ការប្រព្រឹត្តិទៅជាមួយនឹង

ការមិនដាច់ចន្លោះ ។ លោកអាចារ្យបំណងសម្ដែងនូវភាវៈដោយបទថា **សបទានំ** ជាកិរិយាវិសេសនៈ ( ពន្យល់កិរិយា ) និងស្ថានទីដែលមានការមិនដាច់ចន្លោះនោះ ទើបលោកពោលថា អធិប្បាយថា វៀរចាកការដាច់ចន្លោះ បានដល់ តាមលំដាប់ផ្ទះ ដូច្នេះ ។

ពាក្យថា កន្លែងអាសនៈតែ ១ ដោយការអង្គុយរបៀបតែមួយប៉ុណ្ណោះ មិនត្រូវឥរិយាបថដទៃខណ្ឌឲ្យដាច់ពីគ្នា ( មិនផ្លាស់ឥរិយា-បថ ) ។

ក្នុងពាក្យថា ដុំបាយក្នុងបាត្រ នេះ ក្នុងទីនេះបំណងយកប្រភេទនៃវត្ថុ, មិនមែនពាក្យសាមញ្ញទេ ។

លោកអាចារ្យកាលសម្ដែងថាឯវអក្សរ(ដែលប្រែថាប៉ុណ្ណោះ) បានសម្ដែងពន្យល់ទុកហើយ ដោយជាពាក្យដែលដកទុក ទើបពោលថា ក្នុងបាត្រមួយ ប៉ុណ្ណោះតែម្យ៉ាងដូច្នេះ ។ កាលនឹងសម្ដែងថា នេះជាទេសនាដែលធ្វើការលុបបទចុង ទើបលោកពោលថា ព្រោះស័ព្ទថា **បត្តបិណ្ឌ** ប្រើក្នុងការសម្គាល់ថា កាន់យកនូវដុំបាយដូច្នេះ ( គឺ **បត្តបិណ្ឌគហណំ** លុបបទថា **គហណំ** នៅសល់ តែ **បត្តបិណ្ឌំ** ) ។ សូម្បីក្នុងបទដទៃៗ ក្រៅពីនេះ ក៏មានន័យដូច្នេះឯង ។

ភត្ត ដែលភិក្ខុបានមកបន្ទាប់ពីការហាមភត្តនោះឯង ឈ្មោះថាបច្ឆាភត្ត ។ ព្រោះ ខលុ-ស័ព្ទ ជាស័ព្ទប្រាប់បដិសេធ ទើបលោក

អាចារ្យកាន់យក ន អក្សរ ដែលមានអត្ថដូចនឹង ខលុ-ស័ព្ទនោះ ហើយពោលថា **ន បច្ឆាភត្តិកោ** ( មិនមែនបច្ឆាភត្តិកៈ ) ដូច្នេះ ។ធម៌ ដែលជាវិស័យរបស់សិក្ខាបទ ព្រះមានព្រះភាគហាមទុក ក៏ដោយ សិក្ខាបទនោះឯង ។ធម៌ណាមិនមែនជាវិស័យនៃសិក្ខាបទនោះ(ដែល ទ្រង់មិនបានហាមទុកដោយសិក្ខាបទ) ធម៌នោះឯងជាវិស័យនៃការ សមាទាន ( គឺភិក្ខុហាម ឬបដិសេធដោយការសមាទានធុតង្គ ) ព្រោះ ហេតុនោះ ទើបលោកអាចារ្យពោលថា ( ពាក្យថា បច្ឆាភត្តនេះ ជាឈ្មោះ ) នៃអតិរិត្តភោជនដែលភិក្ខុបដិសេធហើយដោយអំណាច ការសមាទាន ) ដូច្នេះ ។

មានពាក្យដែលគួរពោលទាំងអស់ដោយន័យថា ការនៅអា-ស្រ័យក្នុងទីវាល ឈ្មោះថា អព្ភោកាស ។ ការនៅអាស្រ័យក្នុងព្រៃ ស្មសាន ឈ្មោះថា **សុសាន** ។ ភិក្ខុឈ្មោះថា អព្ភោកាសិក ព្រោះ អត្ថថា មានការអាស្រ័យនៅក្នុងទីវាលនោះ ជាប្រក្រតីដូច្នេះជាដើម ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ក៏មានន័យដូច្នេះឯង ដូច្នេះ ។

សេនាសនៈ ដូចសេនាសនៈតាមដែលគេរៀបចំទុកឲ្យ ឈ្មោះ ថា **យថាសន្ថត** បានដល់ សេនាសនៈតាមដែលគេឧទ្ទិសឲ្យពីដើម។ ភិក្ខុអ្នកកាន់ធុតង្គខនេះ រមែងទទួលយកសេនាសនៈនោះ មិនបដិសេធ

ដោយទាក់ទងថា សេនាសនៈ នេះមានសង្កើចច្រើន មានក្លិនស្អុយ ដូច្នេះជាដើម ។ ព្រោះហេតុនោះឯង ទើបលោកអាចារ្យពោលថា សេនាសនៈនេះសមនឹងលោកម្ចាស់ ដូច្នេះជាដើម ។

លោកពោលដល់ការដេកថា **សយនំ** ។ ពាក្យថា ដោយការសមាទាននោះៗ គឺដោយការសមាទានធុតង្គខាងបង្សុកូលិកង្គជាដើមនោះៗ ។ពាក្យថា ហេតុព្រោះភាពជាអ្នកកម្ចាត់កិលេស គឺហេតុព្រោះភាពជាអ្នកញាំញីកិលេសចេញបាន មានន័យថា ហេតុ ព្រោះភាពជាអ្នកលះបង់បាបធម៌ មានតណ្ហា និងឧបាទានជាដើមបាន ដោយអំណាចតទង្គប្បហាន ។ក្នុងទីនេះបំណងយកអង្គដែលជាហេតុកម្ចាត់នូវកិលេសទាំងឡាយថា អង្គនៃភិក្ខុអ្នកឈ្មោះថាធុត,មិនមានបំណងយកអង្គដទៃយ៉ាងណាមួយនោះទេ, មយ៉ាងទៀត អត្ថថា នៃភិក្ខុឈ្មោះថា ធុត នេះកើតបានដោយសភាវៈលើសអត្ថដទៃ ។

ដោយពាក្យថា **មានញាណជាអង្គ** នេះ លោកអាចារ្យបើកបង្ហាញដល់សេចក្តីដែលការសមាទានធុតង្គទាំងឡាយនោះ មានញាណជាអធិបតី ។ ពាក្យថា របស់ការបដិបត្តិ គឺរបស់សម្មាបដិបត្តិមានសីលជាដើម ។ ចេតនាដែលប្រព្រឹត្តទៅដោយអំណាចនៃការសមាទាន ឈ្មោះថា សមាទាន ព្រោះអត្ថថា ជាគ្រឿងកាន់យកដោយល្អ,ធុតង្គទាំងឡាយឈ្មោះថា មានសមាទានចេតនាជាលក្ខណៈព្រោះ

អត្ថថា មានចេតនា ដែលឈ្មោះថា សមាទាននោះ ជាលក្ខណៈ ។ សេចក្ដីនេះ សមតាមដែលព្រះអដ្ឋកថាចារ្យពោលទុកក្នុងបករណ៍អដ្ឋកថា ថា សម្បយុត្តធម៌ទាំងឡាយ ( គឺចិត្ត និងចេតសិក ) ប្រាកដហើយដោយភាពជា **ករណ** ( គ្រឿងធ្វើ គឺគ្រឿងសមាទាន ) ថា **យេន** ព្រោះភាវៈដែលញុំាងកិរិយា គឺការសមាទាន ឲ្យសម្រេច ដូច្នេះ ។

ការកាន់យកដោយសមាទានចេតនាចាត់ជាធុតង្គ សូម្បីចេតនាក្នុងការរក្សា ក៏ចាត់ជាធុតង្គដូចគ្នា ព្រោះមានសមាទានចេតនានោះជាមូល ។

តណ្ហាចារ ( ការប្រព្រឹត្តិទៅនៃតណ្ហា ) ឈ្មោះថា សេចក្ដីល្មោភ ព្រោះអត្ថថា ប្ញូន់យកនូវភណ្ឌៈ គឺកុសលដោយខ្លួនឯង និងអ្នកដទៃជាពីរផ្លូវ ឈ្មោះថា មានការញុំាញុីនូវសេចក្ដីល្មោភជាកិច្ច ព្រោះមានកិច្ចកម្ចាត់នូវតណ្ហាចារៈនោះ ។ព្រោះហេតុនោះឯង ទើបប្រាកដដោយភាវៈដែលមិនល្មោភ, ឬថា ញុំាងការមិនល្មោភនោះឲ្យប្រាកដ ព្រោះហេតុនោះ ទើបឈ្មោះថា **មានការមិនល្មោភជាបច្ចុប្បដ្ឋាន** ។

ពាក្យថា **មានអរិយធម៌ជាបទដ្ឋាន** បានដល់ មានធម៌ មានសីលដែលបរិសុទ្ធជាដើម ជាបទដ្ឋាន ។

ពាក្យថា គួរសមាទានក្នុងសម្នាក់របស់ព្រះមានជោគនោះឯងនេះ លោកអាចារ្យពោលទុកដើម្បីការមិនធ្វើលំដាប់ឲ្យដាច់ទៅ ដូចបុគ្គលអ្នកអាស្រ័យព្រះរាជានោះចិញ្ចឹមជីវិត មិនពោលខឹមសារដែល

សមគួរដល់ពាក្យដែលខ្លួន ប្រកាសទុកក្នុងសម្នាក់ព្រះរាជាឲ្យប្រាស ចាកទៅដោយចំណែកមួយដូច្នោះ ។

សូម្បីការសមាទានក្នុងសម្នាក់បុគ្គលដ៏សេស ក៏មានន័យដូចគ្នា ។

ពាក្យថា របស់លោកអ្នកទ្រទ្រង់សង្គីតិមួយ គឺរបស់លោកអ្នកទ្រទ្រង់នូវនិកាយណាមួយ ក្នុងបណ្ដានិកាយទាំង ៥ មានទីឃនិកាយជាដើម ។ ពាក្យថា របស់ព្រះអដ្ឋកថាចារ្យ បានដល់ របស់លោកអ្នកដែលមានបែបផែនជំនាញខាង អដ្ឋកថាជាពិសេសនោះឯង ។

បទថា **ឯត្ត** បានដល់ ក្នុងហេតុការណ៍ទាំងឡាយរហូតដល់ការសមាទានដោយខ្លួនឯង ។

ពាក្យថា រឿងភាពជាអ្នកប្រាថ្នាតិចក្នុងធុតង្គរបស់ព្រះថេរៈជាបង បានដល់ រឿងដែលមានមកហើយយ៉ាងនេះថា មានរឿងមកថា ព្រះថេរៈនោះជានេសជ្ជិកៈ, មិនមាននរណាដឹងថា លោកនោះ ជានេសជ្ជិកៈ ។ យូរមក ថ្ងៃមួយក្នុង ពេលកណ្ដាលយប់ ព្រះថេរៈប្អូនឃើញលោកអង្គុយលើគ្រែ ដោយពន្លឺនៃផ្លេកបន្ទោរ ទើបសួរថា លោកដ៏ចម្រើន លោកជានេសជ្ជិកឬ ។ ព្រះថេរៈ ( ជាបង ) ព្រោះភាពជាអ្នកប្រាថ្នាតិចក្នុងធុតង្គ ទើបប្រាសដេកក្នុងពេលនោះឯងភ្លាម ហើយសមាទានជាថ្មីនៅពេលក្រោយ ។

( ចប់ មហាដីកា )

# ១-បង្សុកូលិកង្គ

## ការសមាទានបង្សុកូលិកង្គ

បង្សុកូលិកង្គ មានការសមាទានដោយពាក្យ ២ យ៉ាងនេះ ពាក្យណាមួយថា

**១.គហបតិទានចីវរំ បដិក្ខិបាមិ ខ្ញុំម្ចាស់ សូមវៀរចាកនូវសំពត់ដែលជារបស់គហបតីប្រគេន ។**

**២.បង្សុកូលិកង្គំ សមាទិយាមិ ខ្ញុំម្ចាស់ សូមសមាទានអង្គនៃភិក្ខុ អ្នកទ្រទ្រង់នូវសំពត់បង្សុកូលជាប្រក្រតី ។**

នេះជាវិធីសមាទានក្នុងបង្សុកូលិកង្គនេះ ។

## វិធី (បដិបត្តិ) ក្នុងបង្សុកូលិកង្គ

ក្នុងបណ្តាសំពត់ ( ដែលរាប់ថាជាសំពត់បង្សុកូល ) គឺ

១. សោសានិក សំពត់ដែលគេបោះបោលក្នុងព្រៃស្មសាន ។

២. បាបណិក សំពត់ដែលគេបោះបោលតាមផ្លូវចូលផ្សារ ។

៣. រថិយចោឡ សំពត់ដែលគេបោះបោលតាមប្រកផ្លូវ ។

៤. សង្ការចោឡ សំពត់ដែលគេបោះបោលនៅគំនរសំរាម ។

៥. សោត្ថិយ សំពត់ដែលគេជូតមន្ទិលគភ៌ហើយបោល ។

៦.ឆ្នានចោឡ សំពត់ដែលគេបណ្តាញភ្លូត គេយកទៅទទួរគ្រប អ្នកជំងឺជិតទាំងក្បាល ហើយគេផ្លូតទឹកឲ្យ ចប់កិច្ច គេយកទៅបោះ ចោល ។

៧. តិត្ថចោឡ សំពត់ដែលគេចោលនៅក្បែរកំពង់ងូតទឹក ។

៨.គតបច្ចាគត សំពត់ដែលមនុស្សអ្នកទៅកាន់ព្រៃស្មសានដល់ ត្រឡប់មកវិញ គេបោះចោល ។

៩.អគ្គិទឌ្ឍ សំពត់ដែលភ្លើងឆេះត្រង់ណាមួយកន្លែងហើយ ម្ចាស់គេបោះចោល ។

១០.គោខាយិត សំពត់ដែលគោអន្ទៀមត្រង់ណាមួយ ហើយ ម្ចាស់គេបោះចោល ។

១១.ឧបចិកាខាយិត សំពត់ដែលកណ្ដៀរស៊ីត្រង់ណាមួយ ហើយម្ចាស់គេបោះចោល ។

១២.ឧន្ទូរខាយិត សំពត់ដែលកណ្ដុរកាត់ត្រង់ណាមួយ ហើយ ម្ចាស់គេបោះចោល ។

១៣.អន្តច្ឆិន្ន សំពត់ដែលរេចជាយ ហើយគេបោះចោល ។

១៤.ទសច្ឆិន្ន សំពត់ដែលដាច់ជាយ ហើយគេបោះចោល ។

១៥.ធជាហដ សំពត់ដែលគេលើកធ្វើជាទង់ ហើយបោះចោល ។

១៦. ថូបចីវរ សំពត់ដែលគេរុំព័ទ្ធជុំបូកធ្វើពលីកម្ម ហើយ

បោះចោល ។

១៧.សមណចីវរ សំពត់របស់ភិក្ខុផងគ្នា ។

១៨.អភិសេកិក សំពត់ដែលគេចោលត្រង់កន្លែងអភិសេកស្តេច ។

១៩.ឥទ្ធិមយ ចីវរដែលសម្រេចដោយឫទ្ធិ គឺចីវរដែលឯហិភិក្ខុឲ្យ ។

២០.បន្ថក សំពត់ដែលជ្រុះនៅតាមផ្លូវមិនប្រាកដម្ចាស់ ។

២១.វាតាហដា សំពត់ដែលខ្យល់ក្ងួចអណ្តែតទៅ មិនមានម្ចាស់តាម ។

២២.ទេវទត្តិយ សំពត់ដែលទេវតាផ្តល់ឲ្យ ។

២៣.សាមុទ្ទិស សំពត់ដែលរលកសមុទ្រផាត់ប្រានទៅលើគោក ។

បណ្តាសំពត់ទាំងឡាយនេះណាមួយ ព្រះយោគីដែលបានសមាទានធុតង្គហើយ គប្បីកាន់យកមកហែកយកសាច់សំពត់ដែលផុយរលួយបោះចោល យកសាច់សំពត់ដែលនៅល្អមកធ្វើជាចីវរ លើកលែងតែសំពត់ចីវរដែលគេប្រគេនដល់ដៃ ហើយប្រើចុះ ។

បណ្តាសំពត់ទាំងឡាយនោះ សំពត់ដែលនៅក្នុងព្រៃស្មសានឈ្មោះថា សោសានិក, សំពត់ដែលនៅតាមផ្លូវចូលផ្សារ ឈ្មោះថា

**បាបណិក** សំពត់ដែលជនទាំងឡាយត្រូវការបុណ្យ ហើយទុកចោលតាមច្រកផ្លូវមាត់បង្អួច ឈ្មោះថា **រថិយចោឡ**, ផ្ទាំងសំពត់ដែលគេបោះចោលលើគំនរសំរាម ឈ្មោះថា **សង្ការចោឡ**, សំពត់ដែលគេជូតមន្ទិលគភ៌ ហើយបោះចោល ឈ្មោះថា **សោត្ថិយ** បានឮថា មាតារបស់តិស្សអមាត្យ ប្រើសំពត់ដែលមានតម្លៃរាប់សែនជូតមន្ទិលគភ៌ ហើយបោះចោលតាមផ្លូវដើរឈ្មោះ **តាលវេឡី** ដោយមានបំណងថា ភិក្ខុអ្នកទ្រទ្រង់សំពត់បង្សុកូល ជាវត្តទាំងឡាយនឹងកាន់យកភិក្ខុទាំងឡាយកាន់យក ( សំពត់នោះ ) ដើម្បី ( ប៉ះចីវរ ) ដែលរហែកប៉ុណ្ណោះ, បុគ្គលទាំងឡាយ ដែលគ្រូបាប់ខ្មោចឲ្យងូតទឹកដល់ក្បាលហើយ ( ផ្លាស់ ) បោះចោលសំពត់នោះទៅ ដោយសម្គាល់ថា សំពត់នោះជាសំពត់ចង្រៃសំពត់ ( ដែលគេផ្លាស់បោះចោលទៅ ) នោះឈ្មោះថា **ន្ហានចោឡ**, សំពត់ចាស់ៗ ដែលគេបោះចោលតាម កំពង់ងូតទឹក ឈ្មោះថា **តិត្ថចោឡ**, មនុស្សទាំងឡាយចូលទៅព្រៃស្មសាន ពេលត្រឡប់មកវិញងូតទឹកហើយ បោះសំពត់ណាចោល សំពត់នោះឈ្មោះថា **គតបច្ចាគត**, សំពត់ដែលភ្លើងឆេះចំណែកខ្លះ ឈ្មោះថា **អគ្គិទឌ្ឍ**, មនុស្សទាំងឡាយតែងបោះចោលសំពត់នោះ ដូចគ្នានឹងសំពត់ ( ៥ យ៉ាង ) មានសំពត់ ឈ្មោះថា **គោខាយិត** ជាដើម ប្រាកដច្បាស់ហើយ សូម្បីសំពត់នោះៗ មនុស្សទាំងឡាយបោះចោលដូចគ្នា សំពត់ដែល

មនុស្សទាំងឡាយ កាលឡើងទូកចងធ្វើជាទង់ហើយ ទើបទៅ ឈ្មោះថា **ធជាហដ** ភិក្ខុកាន់យកសំពត់នោះ នៅពេលផុត កន្ទុយភ្នែកមនុស្សទាំងឡាយនោះក៏គួរ សូម្បីសំពត់ដែលគេចងជាទង់បក្ខ ទុកក្នុងយុទ្ធភូមិ កាលទាហានទាំងសងខាងចេញទៅហើយ ភិក្ខុកាន់យកសំពត់នោះក៏គួរ, សំពត់ដែលគេហ៊ុំដំបូកកណ្ដៀរធ្វើពលីកម្ម ឈ្មោះថា **ថូបចីវរ**, សំពត់របស់ ភិក្ខុផងគ្នា ឈ្មោះថា **សមណចីវរ**, សំពត់ដែលគេបោះបោលក្នុងស្ថានទីរាជាភិសេក ឈ្មោះថា **អភិសេកិក**, ចីវររបស់ឯហិភិក្ខុ ឈ្មោះថា **ឥទ្ធិមយ**, សំពត់ ដែលជ្រុះក្នុងវវាងផ្លូវ ឈ្មោះថា **បន្ថក** ចំពោះសំពត់ដែលជ្រុះដោយការភ្លេចសតិ របស់ម្ចាស់សំពត់នោះ ភិក្ខុគួររក្សាទុកមួយរយៈ ហើយទើបគួរកាន់យក, សំពត់ដែលខ្យល់ផាត់ទៅធ្លាក់ក្នុងទីឆ្ងាយ ឈ្មោះថា **វាតាហដ** ភិក្ខុកាលមិនឃើញម្ចាស់របស់កាន់យកសំពត់នោះក៏គួរ,សំពត់ដែលទេវតាទាំងឡាយថ្វាយ ដូចជាសំពត់ដែលទេវតាថ្វាយចំពោះព្រះអនុរុទ្ធត្ថេរ ដូច្នោះ ឈ្មោះថា **ទេវទត្តិយ**, សំពត់ដែលរលកសមុទ្រផាត់ឡើងលើគោក ឈ្មោះថា **សាមុទ្ទិយ** ។

ចំណែកសំពត់ណាដែលទាយកពោលពាក្យថា **សង្ឃស្ស ទេម** (ខ្ញុំម្ចាស់ទាំងឡាយថ្វាយដល់សង្ឃ) ថ្វាយក្ដី ភិក្ខុស្វែងទៅសូមសំពត់បានមកក្ដី សំពត់នោះមិនមែនជាសំពត់បំសុកូលទេ ។ សូម្បីសំពត់

ដែលភិក្ខុផងគ្នាឲ្យសំពត់ណា ដែលចីវរភាជកៈចែកឲ្យតាមលំដាប់វស្សាក្តី ចីវរប្រចាំសេនាសនៈក្តី សំពត់នោះក៏មិនមែនជាសំពត់បំសុកូលដែរ, សំពត់ដែលចីវរភាជកៈ មិនបានចែកឲ្យប៉ុណ្ណោះ ទើបជាសំពត់បំសុកូល, សូម្បីក្នុងសំពត់បំសុកូលប្រភេទនោះ សំពត់ណាដែលទាយកលះទុកក្បែរជើងរបស់ភិក្ខុ ( អង្គណាមួយ ) តែភិក្ខុនោះ ( កាន់យកទៅ ) ប្រគេនដល់ដៃរបស់បំសុកូលិកភិក្ខុ ( លះម្តងទៀត ) សំពត់នោះ ឈ្មោះថា **ឯកតោសុទ្ធិក** ( បរិសុទ្ធតែម្ខាង ), សំពត់ណាដែលទាយកប្រគេនដល់ដៃ ( ភិក្ខុរូបណាមួយ ) ហើយភិក្ខុនោះ ( នាំទៅ ) លះចោលនៅក្បែរជើង ( របស់បំសុកូលិកភិក្ខុ ) សូម្បីសំពត់នោះក៏ជា **ឯកតោសុទ្ធិក**, សំពត់ណាដែលទាំងទាយកលះបង់ចោលក្បែរជើងរបស់ភិក្ខុ ( អង្គណាមួយ ) ទាំងភិក្ខុនោះក៏លះ ( ដល់បំសុកូលិកភិក្ខុ ) ដោយវិធីតែមួយដូចគ្នា សំពត់នោះទើបជា **ឧភតោសុទ្ធិក** ( បរិសុទ្ធទាំងសងខាង ), សំពត់ណាដែលភិក្ខុបានមកព្រោះ ( ទាយក ) ដាក់ ( ប្រគេន ) ដល់ដៃហើយ ភិក្ខុនោះក៏ ( នាំទៅ ) ដាក់ ( ប្រគេន ) ដល់ដៃ ( របស់បំសុកូលិកភិក្ខុ ) ដូចគ្នា សំពត់នោះឈ្មោះថា ចីវរ ( បំសុកូល ) ប្រភេទមិនឧក្រិដ្ឋ ។

បំសុកូលិកភិក្ខុដឹងសេចក្តីផ្សេងគ្នា នៃសំពត់បំសុកូលនេះយ៉ាងនេះហើយទើប គួរប្រើចីវរចុះ នេះជាវិធី ( បដិបត្តិ ) ក្នុងបំសុ-

កូលិកង្គនេះ ។

## ប្រភេទនៃបង្សុកូលិកភិក្ខុ

ចំណែក ប្រភេទ គប្បីជ្រាបដូចតទៅនេះ គឺ

បង្សុកូលិកភិក្ខុមាន ៣ ជំពូក គឺ

១. អ្នកកាន់យកថ្នាក់ ឧក្រិដ្ឋ ។

២. អ្នកកាន់យកថ្នាក់ កណ្តាល ។

៣. អ្នកកាន់យកថ្នាក់ ទាប ។

ក្នុង ៣ ជំពូកនោះ អ្នកកាន់យកតែសំពត់ដែលធ្លាក់ចុះក្នុងព្រៃស្មសានប៉ុណ្ណោះ ឈ្មោះថា អ្នកកាន់យកយ៉ាងឧក្រិដ្ឋ ។ អ្នកកាន់យកចីវរដែលអ្នកប្រាថ្នាបុណ្យលះបង់ចោលដោយគិតថាបព្វជិតនឹងកាន់យកដូច្នោះ ឈ្មោះថា អ្នកកាន់យកយ៉ាងកណ្តាល ។ អ្នកកាន់យកសំពត់ដែលគេដាក់ប្រគេនក្បែរជើង ឈ្មោះថា អ្នកកាន់យកយ៉ាងទាប ។

## ការបែកធ្លាយនៃបង្សុកូលិកង្គ

ធុតង្គរបស់បង្សុកូលិកភិក្ខុទាំង ៣ ជំពូកនោះ ជំពូកណាមួយក៏ដោយ រមែងបែកធ្លាយ ក្នុងខណៈដែលលោករីករាយនឹងសំពត់ដែលគ្រហស្ថថ្វាយតាមការពេញចិត្តរបស់ខ្លួន ។នេះជាការបែកធ្លាយ

ក្នុងបង្សុកូលិកង្គនេះ ។

## អានិសង្សនៃបង្សុកូលិកង្គ

ចំណែក **អានិសង្ស** គប្បីជ្រាបដូចតទៅនេះ

១.កើតមានការបដិបត្តិដែលសមគួរដល់និស្ស័យតាមព្រះបាលី ( ប្រាប់អនុសាសន៍ ) សេចក្តីថា បព្វជ្ជាអាស្រ័យបង្សុកូលចីវរ ។

២. បានតាំងនៅក្នុងអរិយវង្សខ.ទី ១ ។

៣. មិនលំបាកព្រោះការថែរក្សា ។

៤. ជាអ្នកមិនប្រព្រឹត្តទៅក្នុងការទាក់ទងនឹងអ្នកដទៃ ។

៥. មិនមានការភ័យខ្លាចព្រោះចោរភ័យ ។

៦. មិនមានតណ្ហាព្រោះការប្រើប្រាស់ ។

៧. មានបរិក្ខារជាសមណសារូប ។

៨. មានបច្ច័យតាមដែលព្រះមានព្រះភាគទ្រង់ត្រាស់សរសើរទុកថា ជារបស់តិចតួចផង ជារបស់រកបានដោយងាយផង ជារបស់មិនមានទោសផង ។

៩. ជាអ្នកគួរជ្រះថ្លា ។

១០. ធុតធម៌ មានការប្រាថ្នាតិចជាដើម អំណោយផង ។

១១. សម្មាបដិបត្តិចម្រើនផង ។

១២. ធ្វើឲ្យពួកជនដែលកើតជំនាន់ក្រោយ កើតនូវទិដ្ឋានុគតិផង ។

## អវសានគាថាក្នុងបំសុកូលិកង្គ

ព្រះបរមក្សត្រ ដែលទ្រទ្រង់នូវគ្រឿងក្រោះល្អក្នុងទីចម្បាំងយ៉ាងណា ព្រះយោគីអ្នកទ្រទ្រង់នូវសំពត់បំសុកូលចីវរ ល្អក្នុងកិរិយាពិឃាតនូវមារសេនា ក៏យ៉ាងនោះ ។

អម្បាលតែព្រះសម្ពុទ្ធ ដែលជាបរមគ្រូនៃសត្វលោក ម្ដេចគង់ព្រះអង្គអាចលះបង់នូវសំពត់ទាំងឡាយដ៏ថ្លៃថ្លាមានសំពត់ដែលបានមកពីដែនកាសីជាដើម ហើយមកទ្រទ្រង់នូវសំពត់បំសុកូលចីវរនោះបាន ព្រោះហេតុនោះព្រះយោគី កាលរឭកឃើញនូវពាក្យបដិញ្ញារបស់ខ្លួន ( សំដៅយកពាក្យបដិញ្ញា ដែលឧបសម្បទាចារ្យប្រាប់និស្ស័យថា **បំសុកូលចីវរ និស្សាយ បព្វជ្ជា** ដូច្នេះជាដើម, ហើយខ្លួនទទួលថា **អាម ភន្តេ** ដូច្នេះ ) គប្បីជាអ្នកត្រេកអរក្នុងបំសុកូលចីវរ ដ៏សមគួរដល់សេចក្ដីព្យាយាមចុះ ។ នេះឯងជាពាក្យពោលអំពីការសមាទានវិធី ( បដិបត្តិ ) ប្រភេទ ការបែកធ្លាយ និងអានិសង្សក្នុងបំសុកូលិកង្គជាបទដំបូង ។

# មហាដីកា

## ពណ៌នាកថាពោលដោយបង្សុកូលិកង្គ

ក្នុងបទថា **គហបតិទានចីវរំ** ( ចីវរដែលជាទានរបស់គហបតីថ្វាយ ) នេះ គប្បីឃើញថា សូម្បីសមណៈទាំងឡាយ ក៏ចាត់ចូលជាពួកគហបតីដូចគ្នាសម្រាប់ភិក្ខុដែលកាន់យកយ៉ាងឧក្រិដ្ឋ ព្រោះភាពដែលសមណៈជាអ្នកថ្វាយ ។ ចីវរដែលគេដាក់ទុកចោលព្រោះគិតថា បព្វជិតនឹងកាន់យក ដូចនេះ គប្បីចាត់ជាគហបតីចីវរ តែមិនគប្បីចាត់ជាគហបតីទានចីវរដូច្នេះ ។ ក្នុងពាក្យថា **ដោយពាក្យនិយាយ** (២ ពាក្យថា) **ក្នុងពាក្យណាមួយ** នេះ សួរថា ធុតង្គ ឈ្មោះថា ដែលបានសមាទានហើយ ដោយពាក្យពោលសមាទាន ក៏លើកទុកសិនចុះ តែថា នឹងឈ្មោះថា បានសមាទានហើយដោយពាក្យពោលបដិសេធបានដូចម្តេច ? ឆ្លើយថា ឈ្មោះថា ជាការសមាទានហើយ ដោយពាក្យពោលបដិសេធក៏បាន ព្រោះជាការយល់គ្នាបាន ដោយការសម្គាល់ដូចជាកាលពោលថា ភិក្ខុទេវទត្ត មិនឆាន់ក្នុងពេលថ្ងៃ ដូច្នេះ ក៏រមែងយល់បានដោយការសម្គាល់ថា រមែងឆាន់ក្នុងពេលយប់ ដូច្នេះ ព្រោះបើវៀរអាហារចេញហើយ ភិក្ខុទេវទត្តនោះ មិនមានការតាំងនៅនៃរាងកាយបានយូរឡើយ ដូច្នេះយ៉ាងណា សូម្បីក្នុងរឿងនេះ ក៏ដូច្នោះ

សូម្បីភិក្ខុបដិសេធគហបតីទានចីវរនោះក៏រមែងទទួលយកនូវចីវរដទៃក្រៅពីគហបតីទានចីវរនោះ ដែលយល់គ្នាដោយការសម្គាល់ហើយ តែម្យ៉ាង ព្រោះវៀរចាកចីវរចេញ ក៏មិនមានការតាំងនៅក្នុងព្រះពុទ្ធសាសនាបានដែរ ។

ដោយពាក្យថា ភិក្ខុសមាទានធុតង្គហើយយ៉ាងនេះជាដើម ជាវិធីការកាន់យកវិធីបដិបត្តិក្នុងបង្សុកូលិកង្គ ។ សំពត់ដែលភិក្ខុបានក្នុងព្រៃស្មសាន ឈ្មោះថា **សោសានិក** ។ សំពត់នោះ ព្រោះហេតុដែលជ្រុះក្នុងព្រៃ ព្រោះត្រូវបុគ្គលពួក ខ្លះបោះចោលក្នុងព្រៃស្មសាននោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **សំពត់ដែលជ្រុះក្នុងព្រៃស្មសាន** ដូច្នេះ ។ សូម្បីសំពត់ដែលឈ្មោះថា **បាបណិក** ក៏គប្បីជ្រាបតាមន័យដែលពោលហើយនេះចុះ ។ ឈ្មោះថា **ផ្លូវឈ្មោះថាតាល វទ្បី** បានដល់ ផ្លូវធំមួយខ្សែក្នុងស្រុក ចំណែកអាចារ្យពួកខ្លះពោលថា បានដល់ ផ្លូវមួយខ្សែក្នុងក្រុងអនុរាធបុរៈដូច្នេះ ។ **សំពត់ឈ្មោះថា** ត្រូវភ្លើងព្រៃឆេះ ចំណែកខ្លះ ព្រោះអត្ថថា មានចំណែកខ្លះត្រូវភ្លើងព្រៃឆេះ ។ អាចារ្យពួកខ្លះពោលថា សំពត់ដែលជ្រុះនៅតាមផ្លូវកន្លងទៅច្រើនថ្ងៃ ភិក្ខុទើបគួរកាន់យកបានដូច្នេះ ។ អាចារ្យមួយពួកទៀតពោលថា កន្លងទៅ ២-៣ ថ្ងៃក៏គួរកាន់យកបាន ដូច្នេះ ។

ពាក្យថា **រក្សាទុកមួយរយៈ** គឺរង់ចាំវេលាមួយរយៈតូច ។ សូម្បី

សំពត់ដែលត្រូវខ្យល់ផាត់ឲ្យធ្លាក់ចុះ ក៏ដូចសំពត់ដែលជ្រុះដោយការភ្លេចសតិរបស់អ្នកដែលជាម្ចាស់វត្ថុ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា សូម្បីមិនជួបម្ចាស់របស់ ក៏គួរនឹងកាន់យកសំពត់នោះបានដូច្នេះ ។ ព្រោះដូច្នោះ ភិក្ខុគួររង់ចាំពេលវេលាមួយរយៈតូចហើយទើបគួរកាន់យក ។

ដើម្បីនឹងការពារសេចក្ដីសង្ស័យ សំពត់ដែលទាយកពោលថា ពួកខ្ញុំម្ចាស់ សូមថ្វាយដល់ព្រះសង្ឃ ដូច្នេះ ហើយថ្វាយឲ្យក្ដី សំពត់ដែលបានមកដោយទាក់ទងនឹងការទៅដើម្បីសុំសំពត់ក្ដី តាំងពីកាលដែលបានមក គួរជាសមណចីវរបាន ឬមិនបានហ្ន៎ ! ដូច្នេះ ទើបលោកអាចារ្យពោលថា **សំពត់នោះមិនចាត់ជាសំពត់បង្សុកូល** ដូច្នេះ ។

ពិតហើយ សំពត់ដែលទាយកពោលថ្វាយជាដើមក្ដី មិនបានចូលក្នុងប្រភេទសំពត់ណាៗ ក្នុងឋានៈដែលឧប្បត្តិ ២៣ យ៉ាង ។

គ្រានោះ ដើម្បីនឹងសម្ដែងការចែកនូវសំពត់បង្សុកូល ចំពោះលក្ខណៈក្នុងសំពត់ដែលភិក្ខុផងគ្នាប្រគេន ប្រភេទឧក្រិដ្ឋនិងមិនឧក្រិដ្ឋដោយបំណងតែមួយ ដូចគ្នានេះ ទើបលោកអាចារ្យពោលថា សូម្បីសំពត់ដែលភិក្ខុផងគ្នាប្រគេន ដូច្នេះជាដើម ។

ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **ចែកឲ្យ** បានដល់ ចីវរដែលភិក្ខុទាំងឡាយ ថ្វាយចំពោះសង្ឃ ឬដល់គណៈ ក៏ប្រគេនដល់ភិក្ខុ

ទាំងឡាយតាមលំដាប់វស្សា ។

ពាក្យថា **សេនាសនចីវរ** បានដល់ចីវរដែលគេធ្វើជាសេនាសនៈជាស្រេច ហើយ ( ពោល ) ថ្វាយថា **សូមភិក្ខុនៅក្នុងសេនាសនៈ នេះប្រើប្រាស់ចុះ** ដូច្នេះ ។

សូម្បីពាក្យថា **សំពត់នោះមិនចាត់ជាសំពត់បំសុកូល** ក៏មានមានន័យថា មិនមែនជាសំពត់បង្សុកូល ក៏ដោយហេតុដែលបានពោលហើយក្នុងកាលមុន និងព្រោះភាពជាសំពត់ដែលគេចែកឲ្យ ព្រោះហេតុនោះ ទើបលោកពោលថា មិនបានចែកឲ្យតែប៉ុណ្ណោះ ទើបជាសំពត់បង្សុកូលដូច្នេះ ។ ពាក្យថា ( សូម្បីសំពត់បំសុកូលប្រភេទនោះ ) **សូម្បីសំពត់ដែលមិនបានចែកឲ្យ** មានន័យថា សំពត់ដែលមិនបានចែកឲ្យ គឺសំពត់ដែលភិក្ខុប្រគេនយ៉ាងណា សូម្បីក្នុងសំពត់នោះលោកអាចារ្យបំណាងនឹងសម្ដែងខ្លឹមសារនេះថា ភិក្ខុអង្គណាប្រគេនចីវរឲ្យ ចីវរភិក្ខុប្រគេនឲ្យនោះ ឈ្មោះថា បរិសុទ្ធតែម្ខាង ព្រោះភិក្ខុនោះមានការអើពើ និងការគោរពក្នុងការបានមក និងក្នុងការប្រគេនទៅ ចែកចំពោះបុគ្គលម្នាក់គត់ ។ ឈ្មោះថា មានសេចក្ដីបរិសុទ្ធិទាំងពីរខាង ព្រោះមានការអើពើ និងការគោរព ក្នុងការធ្វើទាំងពីរ ( ទាំងការបានមកទាំងការប្រគេន ) និងឈ្មោះថា មានភាពជាចីវរដែលមិនឧក្រិដ្ឋ ក៏ព្រោះមិនមានការអើពើ និងការគោរពនោះ ដូច្នោះ ទើប

លោកពោលថា សំពត់ដែលពួកទាយកដូច្នេះជាដើម បំណងថា ត្រូវតែជាសំពត់ ដែលសមណៈទុកក្បែរជើង ។

ពាក្យថា របស់ភិក្ខុអង្គណាមួយ គឺរបស់ភិក្ខុអង្គណាមួយក្នុងបណ្ដាភិក្ខុ ៣ ជំពូក មានភិក្ខុអ្នកកាន់យកប្រភេទឧក្រិដ្ឋជាដើម ។

បទថា **រុចិយា** ប្រែថា ការពេញចិត្ត ។ បទថា **ខន្តិយា** ( ការពេញចិត្ត ) បានដល់ ការពេញចិត្ត គឺសម្ងំមិនដាក់ភ្នែក ។

ពាក្យថា មានការបដិបត្តិដែលសមគួរដល់និស្ស័យ មានន័យថា ក្នុងបណ្ដានិស្ស័យ ៤ ដែលអាចារ្យប្រាប់ក្នុងពេលឧបសម្បទាបានចំពោះនូវខ.បដិបត្តិដែលសមគួរចំពោះនិស្ស័យខ.ទី ២តាមដែលខ្ញុំបានប្រកាសទុក ។ ពាក្យថា មិនមានទុក្ខព្រោះការរក្សាចីវរ ព្រោះបង្សុកូលចីវរ មិនជាទីតាំងនៃសេចក្ដីលោភ ។ ឈ្មោះថា មិនមានតណ្ហាក្នុងការបរិភោគ ព្រោះសំពត់បំសុកូលមានភាពសៅហ្មងយ៉ាងវិសេស ។ ឈ្មោះថា មានភាពជាអ្នកគួរជ្រះថ្លា ព្រោះនាំមកនូវសេចក្ដីជ្រះថ្លាដល់បុគ្គលទាំងឡាយដទៃ ។ ឈ្មោះថា គុណទាំងឡាយ មានការប្រាថ្នាតិចជាដើម មានការសម្រេចជាផល ព្រោះការរក្សាធុតង្គភិក្ខុអាចធ្វើឲ្យសម្រេចបានដោយគុណទាំងឡាយ មានសេចក្ដីប្រាថ្នាតិចជាដើមនោះឯង ។ ការសមាទាននូវធុតធម៌ទាំងឡាយ ហើយធ្វើឲ្យប្រព្រឹត្តទៅក៏ត្រឹមតែដើម្បីធ្វើឲ្យសម្មាបដិបត្តិកាន់តែខ្ពស់ឡើងទៅ

ឲ្យដល់ព្រមប៉ុណ្ណោះ ព្រោះហេតុនោះ ទើបលោកហៅថា មានការចម្រើននូវសម្មាបដិបត្តិដូច្នេះ ។

ពាក្យថា ដើម្បីកម្ចាត់មារនិងសេនា គឺដើម្បីកម្ចាត់ ដើម្បីញាំញីមារ និងកងទ័ពរបស់មារ ។ ភិក្ខុឈ្មោះថា **យតិ** ( អ្នកសង្រួម ) ព្រោះអត្ថថា សង្រួម គឺសង្រួមដោយល្អតាមផ្លូវកាយ វាចា និងចិត្ត ។ ប្រកបសេចក្ដីថា **សំពត់បង្សុកូល** ណាដែលទ្រង់ជាគ្រូរបស់លោកក៏ទ្រង់ប្រើប្រាស់នរណា ដែលថាមិនទ្រទ្រង់នូវសំពត់បំសុកូលនោះដូច្នេះ ។ ម្យ៉ាងទៀត ព្រោះហេតុថា ព្រះមានជោគជាគ្រូរបស់លោកក៏គង់ទ្រទ្រង់សំពត់បង្សុកូល ព្រោះដូច្នោះ នរណានឹងមិនទ្រទ្រង់នូវសំពត់បង្សុកូលនោះ ព្រោះដូច្នេះ យំ-ស័ព្ទ និង តំ-ស័ព្ទ មានការសម្ព័ន្ធគ្នាតែម្យ៉ាង ។ ពាក្យថា កាលតាមរលឹកដល់ពាក្យបេ្ដជ្ញា គឺកាលតាមរឭកដល់ពាក្យបេ្ដជ្ញាដែលខ្លួនប្រកាសហើយ ចំពោះមុខសង្ឃ មានអាចារ្យជាប្រមុខក្នុងសាលា ឧបសម្បទាថា **អាម ភន្តេ** ដូច្នេះ ។

ពណ៌នាកថា បង្សុកូលិកង្គ ចប់

( ចប់ មហាដីកា )

## ២–តេចីវរិកង្គ

## វិធីសមាទានតេចីវរិកង្គ

*តេចីវរិកង្គ នៅបន្ទាប់ពីបង្សុកូលិកង្គនោះ រមែងមានការសមាទាន ដោយពាក្យ ២ នេះ ពាក្យណាមួយ គឺ*

**១. ចតុត្ថចីវរំ បដិក្ខិបាមិ** *ខ្ញុំព្រះករុណាសូមហាមឃាត់នូវចីវរជាគម្រប់ ៤ ។*

**២. តេចីវរិកង្គំ សមាទិយាមិ** *ខ្ញុំព្រះករុណាសូមសមាទាននូវអង្គរបស់ភិក្ខុ អ្នកមានតែចីវរ ៣ ជាប្រក្រតី ។*

## វិធី (បដិបត្តិ) ក្នុងតេចីវរិកង្គ

*តេចីវរិកភិក្ខុនោះ បានសំពត់សម្រាប់ធ្វើចីវរមកហើយ នៅមិនទាន់បានធ្វើ ព្រោះមិនសប្បាយក្តី ចាត់ចែងវាស់កាត់មិនទាន់ក្តី គ្រឿងឧបករណ៍មានម្ជុលជាដើមរកមិនទាន់បានក្តី ដរាបណា គប្បីរក្សាទុកបានដរាបនោះ ។ មិនមានទោស ព្រោះការរក្សាទុកជាបច្ច័យនោះទេ តែថា តាំងពីត្រឹមជ្រលក់ហើយទៅ នឹងទុកដាក់តទៅទៀតមិនបានឡើយ បើទុកដាក់តទៅទៀត លោកចាត់ថា ជាមហាចោរផ្នែកខាងធុតង្គ ។ នេះជាវិធី ( បដិបត្តិ ) ក្នុង* **តេចីវរិកង្គ** *។*

## ប្រភេទនៃតេចីវរិកង្គ

ពោលដោយប្រភេទសូម្បីប្រភេទតេចីវរិកៈនោះក៏មាន៣ជំពូក ក្នុង ៣ ជំពូកនោះ លោកកាន់យកប្រភេទឧក្រិដ្ឋ ក្នុងពេលជ្រលក់សំពត់គប្បីជ្រលក់អន្តរវាសកៈ(ស្បង់)ឬឧត្តរាសង្គ(ចីពរ)(សំពត់ណាមួយ)មុន(កាលដែលសំពត់ជ្រលក់ស្ងួតហើយ)ក៏យកសំពត់នោះមកស្លៀក ហើយទើបជ្រលក់សំពត់មួយផ្ទាំងទៀត ( កាលឧត្តរាសង្គស្ងួតហើយ)គប្បីស្លៀកឧត្តរាសង្គនោះ ហើយទើបជ្រលក់សង្ឃាដី តែយកសង្ឃាដីស្លៀកមិនគួរ នេះជាវត្តក្នុងសេនាសនៈចុងស្រុក សម្រាប់ភិក្ខុតេចីវរិកៈនោះ ។ ចំណែកអ្នកជាអារញ្ញិកៈ នឹងជ្រលក់ ២ ផ្ទាំង ក្នុងពេលតែមួយក៏បាន តែគប្បីអង្គុយនៅត្រង់កន្លែងដែលជិតៗ ( សំពត់ ) នោះឲ្យល្មម តែឃើញមនុស្សណាមួយដើរមក អាចនឹងទាញយកចីវរមកគ្របលើខ្លួនបានទាន់ពេល ។

ចំណែកភិក្ខុអ្នកកាន់យកជាកណ្តាលតាមប្រក្រតី បើមានសំពត់កាសាវៈសម្រាប់ប្រើប្រាស់នៅក្នុងរោងជ្រលក់អាចនឹងស្លៀកដណ្តប់នូវសំពត់កាសាវៈនោះ ហើយជ្រលក់នូវចីវររបស់ខ្លួនក៏គួរ ។

ភិក្ខុថ្នាក់ទាប អាចស្លៀកដណ្តប់នូវសំពត់ចីវររបស់ភិក្ខុផងគ្នា ហើយជ្រលក់នូវចីវររបស់ខ្លួនបាន សូម្បីសំពត់កម្រាលដែលមាន

នៅក្នុងសេនាសនៈនោះ ក៏គួរដល់លោក តែនឹងរក្សាទុក ( ប្រើប្រាស់ជានិច្ច ) មិនគួរ តែបើខ្ទិចីវររបស់ភិក្ខុ ដែលត្រូវគ្នាស្មៀកក្នុងពេលជ្រលក់នោះក៏បាន ( ច្បាប់សីហឡ និងច្បាប់អឺរ៉ុបថា បាន តែច្បាប់ថៃថា មិនបាន យកតាមច្បាប់ខ្មែរថា បាន ត្រូវគ្នាជាមួយនឹងច្បាប់សីហឡ និងច្បាប់អឺរ៉ុប ) ។

តេចីវរភិក្ខុទាំង ៣ ថ្នាក់នេះ បើនឹងបន្ថែមសំពត់អង្សកមួយមកទៀត ឲ្យជាគម្រប់ ៤ ក៏បាន តែសំពត់អង្សកនោះត្រូវមានកម្រិតទទឹង ១ ចំអាម បណ្តោយ ៣ ហត្ថ ទើបគួរ ។

## ការបែកធ្លាយនៃតេចីវរិកង្គ

ធុតង្គរបស់ភិក្ខុតេចីវរិកៈទាំង ៣ ថ្នាក់នេះ រមែងបែកធ្លាយក្នុងខណៈដែលលោកទទួលត្រេកអរនូវចីវរជាគម្រប់ ៤ នោះឯង នេះជាការបែកធ្លាយក្នុង តេចីវរិកង្គ ។

## អានិសង្សនៃតេចីវរិកង្គ

ចំណែកអានិសង្សមានដូច្នេះ គឺគុណទាំងឡាយដូចដែលពោលតទៅនេះគឺ រមែងសម្រេច ( ដល់ភិក្ខុតេចីវរិកៈ ) គឺ

**១.ភិក្ខុតេចីវរិកៈ** រមែងជាអ្នកសន្តោសដោយចីវរល្មមតែនឹងរក្សាកាយដោយការសន្តោសនោះ ( ទៅទីណា ) លោកកាន់យក

( ចីវរនោះ ) ទៅបាន ដូចបក្សីនាំយកស្លាបទៅដូច្នោះ ។

២-មានកិច្ចដែលគប្បីធ្វើតិច ។

៣-មិនមានការសន្សំសំពត់ ។

៤-ភាពជាអ្នកប្រព្រឹត្តស្រាល ។

៥-លះបង់សេចក្តីល្មោភក្នុងអតិរេកចីវរបាន ។

៦-ធ្វើការពេញចិត្តក្នុងសំពត់ដែលជាកប្បិយៈ ។

៧-មានការប្រព្រឹត្តិដុសខាត់កិលេស ។

៨-ធុតធម៌មានការប្រាថ្នាតិចសម្រេចជាផល ។

## អវសានគាថាក្នុងតេចីវរិកង្គ

ព្រះយោគីជាអ្នកមានបញ្ញា អ្នកដឹងនូវរសនៃសេចក្តីសុខដែលកើតពីសេចក្តីសន្តោស លោករមែងលះបង់នូវចំណង់ក្នុងសំពត់ដែលលើសកំណត់ លោករមែងវៀរបង់នូវកិរិយាសន្សំទុកនូវសំពត់ លោកទ្រទ្រង់តែចីវរ ៣ ប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះយោគីដ៏ប្រសើរកាលប្រាថ្នាដើម្បីត្រាច់ទៅជាសុខ គប្បីធ្វើនូវសេចក្តីរីករាយក្នុងធុតង្គដែលលោកកំណត់ត្រឹមចីវរ ៣ ជាប់ទៅជាមួយ ហាក់ដូចជាសត្វបក្សីដែលត្រាច់ទៅមានតែស្លាបជាប់ទៅដូច្នោះ ។

នេះជាពាក្យពណ៌នាអំពីការសមាទាន វិធី ( បដិបត្តិ ) ប្រភេទការបែកធ្លាយ និងអានិសង្សក្នុង **តេចីវរិកង្គ** ។

## មហាដីកា

## កថាពណ៌នាអំពីតេចីវរិកង្គ

ពាក្យថា សំពត់ចីវរទី ៤ អធិប្បាយថា បានដល់ សំពត់ចីវរទី ៤ ដែលគួរដល់ការស្លៀកនិងដណ្តប់ ព្រោះសំពត់អង្រែកមិនមែនជាសំពត់ដែលត្រូវបដិសេធ ។

ក្នុងពាក្យថា ដោយពាក្យណាមួយនេះ មានពាក្យណាដែលគួរពោលដល់ពាក្យនោះ មានន័យដូចដែលខ្ញុំម្ចាស់បានពោលហើយក្នុងបទមុននោះឯង ។ គប្បីភ្ជាប់ យាវ-ស័ព្ទ ចូលតែបទមួយថា **យាវ ន សក្កោតិ** ដរាបប៉ុណ្ណោះ នៅមិនអាចធ្វើបាន, **យាវ ន លភតិ** ដរាបប៉ុណ្ណោះ នៅមិនទាន់បាន ( ពិចារណា ), **យាវ ន សម្បជ្ជតិ** ដរាបប៉ុណ្ណោះ ( គ្រឿងធ្វើដោយដៃ ) នៅមិនព្រមដូច្នេះចុះ ។

ពាក្យថា **នៅមិនព្រម** គឺនៅមិនទាន់សម្រេច ។ ពាក្យថា **ទោសព្រោះការរក្សាទុកជាបច្ច័យ** មិនមាន គឺទោសព្រោះការសៅហ្មងនៃធុតង្គ ហេតុព្រោះការសន្សំការរក្សាទុកមិនមាន ។

ពាក្យថា **កន្លែងដែលជិត** គឺកន្លែងដែលជិតចីវរ ។ សំពត់ដែលប្រើប្រាស់ ( គឺស្លៀក ) ក្នុងខណៈជ្រលក់ ឈ្មោះថា សំពត់កាសាវៈសម្រាប់ស្លៀកជ្រលក់ ។

ឈ្មោះថា **សំពត់ដែលត្រៀមទុកជាគ្រឿងក្រាលក្នុងសេនាសនៈនោះ** បានដល់ សំពត់របស់ខ្លួនក៏ដោយ សំពត់របស់អ្នកដទៃក៏ដោយ ដែលតាំងទុកជាប្រចាំ ដោយទាក់ទងជាមួយគ្រឿងក្រាលក្នុងសេនាសនៈនោះ ។ អាចារ្យជាច្រើនពោលថា ក្នុងអដ្ឋកថា មានពាក្យពោលទុកថា សំពត់អង្សកែចាត់ជាសំពត់បរិក្ខារ (សំពត់ដែលត្រូវប្រើក្រៅពីត្រៃចីវរ ហៅថា សំពត់បរិក្ខារ ដូចជាស្រោមបាត្រ ថង់ យាមជាដើម) ព្រោះហេតុនោះ សំពត់ទាំងពីរយ៉ាងនេះ គឺសំពត់កម្រាល ១ សំពត់អង្សកែ ១ សូម្បីតាំងនៅក្នុងឋានៈនៃអតិរេកចីវរ ក៏មិនធ្វើឲ្យធុតង្គបែកធ្លាយ ដូច្នេះ ។

ពាក្យថា តែនឹងរក្សាទុកមិនគួរ មានន័យថា មិនគួរសម្រាប់ភិក្ខុអ្នកជា **តេចីវរិកៈ** ដោយទាក់ទងជាមួយនឹងការប្រើប្រាស់ជាប្រចាំ ព្រោះលោកអនុញ្ញាត ទុកចំពោះតែពេលជ្រលក់សំពត់ប៉ុណ្ណោះ ។

ពាក្យថា សំពត់អង្សកែ បានដល់ សំពត់ពាក់លើស្មា ។

ពាក្យថា (ដោយចីវរ) ជាគ្រឿងរក្សាកាយ គឺដោយចីវរដែលជាគ្រឿងរក្សាកាយឲ្យផុតពីអន្តរាយ គឺខ្យល់ និងកម្ដៅថ្ងៃ ។

ពាក្យថា សមាទានហើយនោះឯង គឺកាន់យកហើយនោះឯង ។

ពាក្យថា ភាពជាអ្នកមានវត្ថុដែលគួរប្រាថ្នាតិច គឺភាពជាអ្នកមានកិច្ចតិច ។

ពាក្យថា ភាពជាអ្នកប្រើល្មមប្រមាណក្នុងវត្ថុដែលជាកប្បិយៈ មានន័យថាក្នុងបណ្តាសំពត់ច្រើនផ្ទាំងសូម្បីព្រះសាស្តាអនុញ្ញាតទុកទាក់ទងនឹងសំពត់ក្រាលអង្គុយជាដើម និងដោយទាក់ទងនឹងសំពត់បរិក្ខារ ក៏ព្រោះមានភាពជាអ្នកតាំងនៅក្នុងចីវរ ៣ផ្ទាំងប៉ុណ្ណោះ ។ ឈ្មោះថា នាំយកតែស្លាបទៅ ព្រោះអត្ថថា ប្រព្រឹត្តទៅព្រមជាមួយនឹងការទៅដោយស្លាប ។ បក្សី ឈ្មោះថា បក្ខី ប្រែថា ដែលមានស្លាប ។

ពណ៌នាកថាដោយ តេចីវរិកង្គ ចប់

( ចប់ មហាដីកា )

# ៣ –បិណ្ឌបាតិកង្គ

## ការសមាទានបិណ្ឌបាតិកង្គ

សូម្បីបិណ្ឌបាតិកង្គ ក៏មានការសមាទានដោយពាក្យ ២ យ៉ាង នេះ ពាក្យណាមួយ គឺ

១.អតិរេកលាភំ បដិក្ខិបាមិ ខ្ញុំម្ចាស់សូមវៀរចាកអតិរេកលាភ ។

២.បិណ្ឌបាតិកង្គំ សមាទិយាមិ ខ្ញុំម្ចាស់សូមសមាទានអង្គរបស់ភិក្ខុ អ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតជាប្រក្រតី ។

## វិធី (បដិបត្តិ) ក្នុងបិណ្ឌបាតិកង្គ

បិណ្ឌបាតិកភិក្ខុនោះមិនគួររើករាយក្នុងភត្ត ១៤ យ៉ាង គឺ

១-សង្ឃភត្តំ ភត្តដែលគេប្រគេនចំពោះសង្ឃទូទៅ ។

២-ឧទ្ទេសកភត្តំ ភត្តដែលគេឧទ្ទិសចំពោះភិក្ខុ ១ អង្គក្តី ២ អង្គក្តី អំពីសម្នាក់សង្ឃ ហើយប្រគេន ។

៣-និមន្តនំ ភត្តដែលគេនិមន្តភិក្ខុយកទៅប្រគេន ។

៤-សលាកភត្តំ ភត្តដែលគេប្រគេនតាមស្លាក ។

៥-បក្ខិកំ ភត្តដែលគេប្រគេនប្រចាំបក្ខ ។

៦-ឧបោសថិកំ ភត្តដែលគេប្រគេនរាល់ថ្ងៃឧបោសថ ។

៧-បាដិបទិកំ ភត្តដែលគេប្រគេនរាល់ថ្ងៃបាដិបទ ( ថ្ងៃដើមបក្ខ

គឺ ២ កើត ឬ ១ រោច ) ។

**៨-អាគន្តុកភត្តំ** ភត្តដើម្បីភិក្ខុជាអាគន្តុកៈ ។

**៩-គមិកភត្តំ** ភត្តសម្រាប់ភិក្ខុដែលរៀបធ្វើដំណើរផ្លូវឆ្ងាយ ។

**១០-គិលានភត្តំ** ភត្តដើម្បីភិក្ខុអាពាធ ។

**១១-គិលានុបដ្ឋាកភត្តំ** ភត្តដើម្បីភិក្ខុអ្នករក្សាភិក្ខុអាពាធ ។

**១២-វិហារភត្តំ** ភត្តប្រចាំវិហារ ។

**១៣-ធុរភត្តំ** ភត្តដែលគេតម្កល់ទុកក្នុងផ្ទះមានធុរៈ ( កន្លែងនេះធ្លាប់ប្រែថា **ធុរភត្ត** ឬ **និច្ចភត្ត** ភត្តដែលគេថ្វាយជាប្រចាំ ) ហើយប្រគេន ។

**១៤-វារភត្ត** ភត្តដែលគេដាក់វេនគ្នាប្រគេន ។

តែភត្តទាំងឡាយណា បើទាយកមិនបានពោល (បេញឈ្មោះ) ដោយន័យជាដើមថា សូមលោកទាំងឡាយទទួលសង្ឃភត្ត ដូច្នេះ ( ជាដើម ) ពោលថា ( សូមសង្ឃទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំ ) ឬថា សូមលោកទាំងឡាយទទួលភិក្ខា ដូច្នេះ ហើយថ្វាយ, បិណ្ឌបាតិកភិក្ខុនឹងរីករាយក្នុងភត្តនោះក៏គួរ, **និរាមិសសលាក** ( ស្លាកដែលមិនមានអាមិស ) ចំពោះសង្ឃភត្តី ភត្តដែលគេធ្វើ ( ប្រគេន ) ក្នុងវិហារក្តី រមែងគួរដោយពិត នេះជាវិធី ( បដិបត្តិ ) នៃបិណ្ឌបាតិកភិក្ខុនោះ ។

## ប្រភេទនៃបិណ្ឌបាតិកង្គ

ការពោលដោយប្រភេទ សូម្បីបិណ្ឌបាតិកភិក្ខុនេះ ក៏មាន ៣ ជំពូក ក្នុង ៣ ជំពូកនោះ អ្នកដែលកាន់យ៉ាងឧក្រិដ្ឋរមែងទទួលភិក្ខា ដែលទាយកនាំមក ( ប្រគេនពីផ្ទះ ) ខាងមុខក៏បាន ( ពីផ្ទះ ) ខាងក្រោយក៏បាន ឈរនៅត្រង់ទ្វារផ្ទះតែមួយ សូម្បីបុគ្គល ( ផ្ទះផ្សេងៗ មកសុំ ) ទទួលបាត្រក៏ឲ្យ ហើយទទួលភិក្ខាដែលគេនាំមក ថ្វាយក្នុងពេលត្រឡប់វិញក៏បាន តែ ( វៀរចាកបិណ្ឌបាត ) អង្គុយចុះហើយ មិនត្រូវ ទទួលភិក្ខា ( ទៀត ) ក្នុងថ្ងៃនោះ ។ អ្នកកាន់ថ្នាក់កណ្ដាល សូម្បីអង្គុយចុះហើយ ក៏អាចទទួលបាន ( ទៀត ) ក្នុងថ្ងៃនោះ តែមិនទទួល ( និមន្ត ) ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ អ្នកកាន់ថ្នាក់ទាបអាចទទួល ( និមន្ត ) ដើម្បីឆាន់ក្នុងថ្ងៃស្អែកក៏បាន ក្នុងថ្ងៃតទៅទៀតក៏បាន បិណ្ឌបាតរបស់ភិក្ខុទាំងពីរប្រភេទនោះ រមែងមិនបានសេចក្ដីសុខក្នុងការរស់នៅដោយសេរី អ្នកកាន់ថ្នាក់ឧក្រិដ្ឋប៉ុណ្ណោះ ទើបបាន ( ដូច ) មានរឿងពោលថា ក្នុងស្រុកមួយមាន ( ការសម្ដែងធម្មកថា ), ពោលដល់អរិយវង្ស បិណ្ឌបាតិកភិក្ខុ អ្នកកាន់យកថ្នាក់ឧក្រិដ្ឋ បានពោលនឹងបិណ្ឌបាតិកភិក្ខុទាំងពីរប្រភេទថា អាវុសោ យើងទៅស្ដាប់ធម៌ជាមួយគ្នាចុះ ក្នុងភិក្ខុពីរអង្គនោះ មួយអង្គពោលថា លោកដ៏ចម្រើន

ខ្ញុំម្ចាស់ត្រូវគេនិមន្តឲ្យអង្គុយ, មួយអង្គទៀតពោលថា លោកដ៏ចម្រើន ខ្ញុំម្ចាស់ក៏បានទទួលនិមន្ត ដើម្បីឆាន់នៅថ្ងៃស្អែកនេះរបស់ទាយកម្នាក់ ភិក្ខុទាំងពីរអង្គនោះបានវិនាសចាកប្រយោជន៍ ដោយប្រការដូច្នេះ ។ ចំណែកលោកដែលកាន់យកថ្នាក់ឧក្រិដ្ឋ និមន្តទៅបិណ្ឌបាតតាំងពីព្រលឹម ( ឆាន់ហើយ ) ក៏ទៅ បានសោយនូវធម្មរសហើយ ។

## ការបែកធ្លាយនៃបិណ្ឌបាតិកង្គ

ធុតង្គរបស់បិណ្ឌបាតិកទាំង ៣ ជំពូកនេះ រមែងបែកធ្លាយក្នុងខណៈដែលរីករាយនឹងអតិរេកលាភ មានសង្ឃភត្តជាដើមនោះឯង នេះជាសេចក្ដីបែកធ្លាយ ក្នុងបិណ្ឌបាតិកង្គនេះ ។

## អានិសង្សនៃបិណ្ឌបាតិកង្គ

ចំណែកអានិសង្សមានដូចតទៅនេះគឺ

១-មានការបដិបត្តិដែលសមគួរដល់និស្ស័យតាមព្រះបាលីថា បព្វជ្ជាអាស្រ័យការបរិភោគដុំបាយដែលស្វែងរកដោយកម្លាំងស្មង ។

២-បានតាំងនៅក្នុងអរិយវង្សទី ២ ។

៣-ជាអ្នកប្រព្រឹត្តទៅមិនទាក់ទងជាមួយអ្នកដទៃ ។

៤-មានបច្ច័យតាមដែលព្រះមានព្រះភាគ ទ្រង់សរសើរទុកថា ជារបស់តិចតួចផង ជារបស់រកបានដោយងាយផង ជារបស់មិនមាន

ទោសផង ។

៥-ញ៉ាំញីការរួញរាចេញបាន ។

៦-មានអាជីវៈបរិសុទ្ធ ។

៧-បានបំពេញសេក្ខិយបដិបត្តិ ។

៨-មិនចាំបាច់ចិញ្ចឹមអ្នកដទៃ ។

៩-បានធ្វើសេចក្តីអនុគ្រោះអ្នកដទៃ ។

១០-លះបង់មានះបាន ។

១១-ហាមតណ្ហាក្នុងរសបាន ។

១២-មិនត្រូវអាបត្តិព្រោះគណភោជនសិក្ខាបទ បរម្បរភោជនសិក្ខាបទ និងចារិតសិក្ខាបទ ។

១៣-មានការប្រព្រឹត្តិសមគួរដល់ធុតធម៌ទាំងឡាយ មានសេចក្តីប្រាថ្នាតិចជាដើម ។

១៤-សម្មាបដិបត្តិចម្រើនឡើង ។

១៥-បានអនុគ្រោះពពួកជនដែលកើតជំនាន់ក្រោយ ។

## អវសានគាថាក្នុងបិណ្ឌបាតិកង្គ

ព្រះយោគាវចរជាអ្នកសន្តោសក្នុងភោជន គឺដុំបាយដែលគេពូតជាពុំនូតៗ មានកិរិយាចិញ្ចឹមជីវិត មិនជាប់ដោយបុគ្គលដទៃ មាន

សេចក្តីល្មោភក្នុងអាហារលះបង់បានហើយ លោកអាចត្រាច់ទៅក្នុងទិសទាំង ៤ បាន មិនទទាក់ទទាម លោករមែងបន្ទោបង់នូវសេចក្តីខ្ជិលច្រអូសបាន អាជីវៈរបស់លោកសោតក៏ស្អាតបរិសុទ្ធ ព្រោះហេតុនោះ ភិក្ខុអ្នកមានប្រាជ្ញាល្អ មិនគប្បីមើលងាយនូវដំណើរត្រាច់ទៅដើម្បីបិណ្ឌបាតនោះឡើយ ។ មែនពិត បិណ្ឌបាតិកភិក្ខុអ្នកចិញ្ចឹមតែខ្លួនឯង ១ មិនចិញ្ចឹមអ្នកដទៃបែបនេះទេវតាទាំងឡាយតែងស្រឡាញ់រាប់អាន ជួយឃុំគ្រងរក្សា កុំតែប្រព្រឹត្តព្រោះអាស្រ័យលាភ និងសេចក្តីសរសើរ ។

នេះជាពាក្យពណ៌នាអំពីការសមាទាន វិធី ( បដិបត្តិ ) ប្រភេទការបែកធ្លាយ និងអានិសង្សក្នុងបិណ្ឌបាតិកង្គនេះ ។

# មហាដីកា

## ពណ៌នាអំពីបិណ្ឌបាតិកង្គ

ពាក្យថា **អតិរេកលាភ** គឺលាភដែលកើតពីលាភ គឺភិក្ខាចារ ដែលពោលទុកយ៉ាងនេះថា **បិណ្ឌិយាលោបភោជនំ និស្សាយ** អាស្រ័យភោជន គឺដុំបាយដែលគប្បីស្វែងរកដោយស្មងដូច្នេះ មានន័យថា បានដល់ សង្ឃភត្តជាដើម ។ ភត្តដែលទាយកថ្វាយដល់ព្រះសង្ឃទាំងអស់ ឈ្មោះថា **សង្ឃភត្ត** ។ ភត្តដែលទាយកថ្វាយចោះចំពោះភិក្ខុ ២-៣ រូប ឈ្មោះថា **ឧទ្ទេសភត្ត** ។ ភត្តដែលទាយកថ្វាយក្នុង ១ បក្ខ មួយថ្ងៃ ឈ្មោះថា **បក្ខិបក្ខភត្ត** ។ ភត្តដែលទាយកថ្វាយ រៀងរាល់ថ្ងៃឧបោសថ ឈ្មោះថា **ឧបោសថិកភត្ត** ។ ភត្តដែលទាយកថ្វាយក្នុងថ្ងៃ បដិបទ ឈ្មោះថា **បាដិបទិកភត្ត** ។ ភត្តដែលទាយកថ្វាយប្រចាំវិហារ ឈ្មោះថា **វិហារភត្ត** ។ ភត្តដែលទាយកថ្វាយតាំងទុកក្នុងកុដិនៅក្បែរ ( វិហារ ) នោះឯង ឈ្មោះថា **ធុរភត្ត** ។ ភត្តដែលបុគ្គលទាំងឡាយ មានពួកអ្នកស្រុកជាដើម ថ្វាយតាមវារៈ ឈ្មោះថា **វារភត្ត** ។

ដោយ **អាទិ**-ស័ព្ទ ( ដែលប្រែថា ជាដើម ) ក្នុងពាក្យថា **សង្ឃភត្តំ គណ្ហាតិអាទិនា** ដោយន័យជាដើមថា សូមលោកទាំងឡាយទទួលសង្ឃភត្ត ដូច្នេះ រួមយកឧទ្ទេសភត្តជាដើមផង ។

ពាក្យថា **កាលដែលភិក្ខុរីករាយក៏គួរ** មានន័យថា កាលដែលភិក្ខុនឹងរីករាយក៏គួរ ព្រោះជាភត្តដែលត្រូវពោលដល់ ដោយន័យអមៗថា **ភិក្ខា** ។ ស្លាកដែលទាក់ទងជាមួយភេសជ្ជៈជាដើម ឈ្មោះថា **និរាមិសសលាក** ចំណែកអាចារ្យច្រើននាក់ពោលថា ស្លាកដែលវៀរចាក **យាវកាលិកសលាក** ( ស្លាកដែលប្រើបាន ជាប្រចាំអស់កាលជានិច្ច ) ឈ្មោះថា **និរាមិសសលាក** ។ ពាក្យថា ភត្តដែលគេធ្វើក្នុងវិហារ មានន័យថា ពួកឧបាសកឧបាសិកាដាំស្លភត្តក្នុងវិហារនេះ នោះឯង ហើយត្រៀមភត្តក្នុងវិហារនោះឯង ដោយសម្គាល់ថា ពួកយើងនឹងថ្វាយដល់ព្រះគុណម្ចាស់គ្រប់អង្គ ភត្តនោះរមែងគួរដល់ភិក្ខុអ្នកជាបិណ្ឌបាតិកៈ ។

ពាក្យថា នាំមក គឺទាយកទទួលបាត្រ ( ទៅដាក់ភិក្ខា ) ហើយនាំចេញពីផ្ទះ ។

ពាក្យថា អង្គុយចុះហើយក្នុងថ្ងៃនោះ គឺអង្គុយចុះហើយក្នុងថ្ងៃនោះ ព្រោះតែងតែទទួលពាក្យរបស់ទាយកដែលពោលថា លោកដ៏ចម្រើន សូមលោកទាំងឡាយកុំនិមន្តទៅបិណ្ឌបាតឡើយ ពួកខ្ញុំម្ចាស់នឹងនាំភិក្ខាមកក្នុងវិហារតែម្តង ដូច្នេះ ។

ពាក្យថា សុខក្នុងការនៅយ៉ាងឥស្សរៈ គឺសុខក្នុងភាពជាអ្នកនៅមិនទាក់ទងជាមួយអ្នកដទៃ ។ ពាក្យថា **ទេសនាអរិយវង្ស** បានដល់

ធម្មកថា ដែលប្រកបដោយអរិយវង្សសូត្រ ។ ពាក្យថា **ធម្មរស** បានដល់ រស មានការរីករាយចិត្តជាដើម ដែលប្រកបដោយធម៌ ។

ឈ្មោះថា មានការញ៉ាំញីនូវការខ្ជិលច្រអូសចេញបាន ព្រោះការអាស្រ័យ កម្លាំងស្មងស្វែងរកបិណ្ឌបាត ។ ឈ្មោះថា **មានភាពជាអ្នកមានអាជីវបរិសុទ្ធិ** ក៏ព្រោះមានការស្វែងរកអាហារតាមវិធីដែលទ្រង់ត្រាស់ទុកថា **យថាបិ ភមរោ បុប្ផំ** ជាដើម ( សេចក្ដីពេញក្នុងគាថានេះប្រែថា មុនីគប្បីចូលទៅក្នុងស្រុក ឲ្យដូចជាឃ្មុំមិនញ៉ាំងផ្កាពណ៌ និងក្លិន ឲ្យទ្រុឌទ្រោមខូច គ្រេបយកតែរស ហើយហើរចេញទៅដូច្នោះ ) ។

សេក្ខិយធម៌ទាំងឡាយមាន **សុប្បដិច្ឆន្នគមន** ( ភាពជាអ្នកមានកាយបិទបាំង រៀបរយហើយដើរទៅ ) ជាដើម រមែងដល់ព្រមបាន ចំពោះភិក្ខុអ្នកចូលទៅកាន់លំដាប់ផ្ទះជានិច្ចប៉ុណ្ណោះ ព្រោះហេតុនោះ ទើបឈ្មោះថា បានធ្វើសេក្ខិយ បដិបត្តិឲ្យបរិបូរណ៍ ។

ឈ្មោះថា មានភាពជាអ្នកមិនចិញ្ចឹមអ្នកដទៃ ព្រោះភាពជាអ្នកដឹងប្រមាណ ក្នុងការទទួល និងព្រោះមិនមានការនៅដោយការស្និទ្ធស្នាល ។ ឈ្មោះថា មានការធ្វើដែលអនុគ្រោះដល់អ្នកដទៃ ព្រោះការទទួលយកដុំបាយត្រឹមតែបន្តិចបន្តួចក្នុង ១ ត្រកូល ។

ឈ្មោះថា លះបង់មានះបាន ព្រោះមានឋានៈទាបដោយការ

ចិញ្ចឹមជីវិតតាមវិធីទាបបំផុត ។

សេចក្ដីនេះសមដូចដែលទ្រង់ត្រាស់ទុកថា

***អន្តមិទំ ភិក្ខវេ ជីវិកានំ យទិទំ បិណ្ឌោល្យំ*** ម្នាលភិក្ខុទាំងឡាយ ការត្រាច់ទៅបិណ្ឌបាតនេះ គឺជាការចិញ្ចឹមជីវិតតាមវិធីទាបបំផុត នៃបណ្ដាវិធីចិញ្ចឹមជីវិតទាំងឡាយដូច្នេះជាដើម ។

ឈ្មោះថា ការពារតណ្ហាក្នុងរសបាន ព្រោះការញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភត្តដែលលាយឡំគ្នា ។ ឈ្មោះថា មិនត្រូវអាបត្តិព្រោះសិក្ខាបទទាំងឡាយ មានគណភោជនសិក្ខាបទជាដើម ដោយសារការមិនទទួលនិមន្ត ។

ភិក្ខុ ឈ្មោះថា ***ចាតុទ្ទិសោ*** ( មិនជាប់ជានិច្ចក្នុងទិសទាំង ៤ ) ព្រោះអត្ថថា ប្រព្រឹត្តទៅបានក្នុងទិសទាំង ៤ ដោយភាពជាអ្នកទៅបានមិនទើសទាក់ ។ សេចក្ដីថា ***អាជីវស្ស វិសុជ្ឈតិ*** ប្រែថា អាជីវៈរបស់លោកទើបហ្មត់ចត់ ។ ពាក្យថា អ្នកចិញ្ចឹមខ្លួនឯង មានន័យថា ភិក្ខុ ឈ្មោះថា ជាអ្នកចិញ្ចឹមខ្លួនឯង ដោយបច្ច័យទាំងឡាយដែលជារបស់តិចតួច មិនមានទោស និងរកបានដោយងាយ ។ ព្រោះការចិញ្ចឹមខ្លួនឯងនេះ នោះឯង ទើបឈ្មោះថា មិនមែនជាអ្នកចិញ្ចឹមអ្នកដទៃ ដោយការដែលមិនត្រូវចិញ្ចឹមអ្នកដទៃ សូម្បីសទ្ធិវិហារិកជាដើម ហេតុព្រោះជាអ្នកនៅតែម្នាក់ឯង ។ លោកអាចារ្យសម្ដែងភាពជាអ្នក

ប្រព្រឹត្តស្រាល ដោយការត្រាច់ទៅដោយចីវរដែលជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតដែលជាគ្រឿងរក្សាផ្ទៃ, ភាពជាបុគ្គលចិញ្ចឹមងាយ, ភាពជាអ្នកប្រាថ្នាតិច និងសេចក្ដីសន្ដោសទុកក្នុងបទទាំងពីរ ( ជាអ្នកចិញ្ចឹមខ្លួនឯង ១ ជាអ្នកមិនចិញ្ចឹមអ្នកដទៃ ១ ) ។

ពាក្យថា សូម្បីទេវតាទាំងឡាយក៏ស្រឡាញ់រាប់អាន មានន័យថា សូម្បីទេវតាទាំងឡាយ មានសក្កទេវរាជជាដើម ក៏ចូលចិត្តប្រាថ្នា គឺប្រាថ្នាចំពោះបិណ្ឌបាតិកភិក្ខុជាអ្នកមាំទាំ គឺស្វាត់ហើយ ព្រោះភាពជាអ្នកមានកាយកម្ម វចីកម្ម និងមនោកម្មស្ងប់ហើយ ហួសពីការប្រៀបបាន ជាអ្នកមានសតិអស់កាលទាំងពួង ព្រោះការប្រកបព្រមដោយសតិ និងភាពធ្លាតយ៉ាងក្រៃលែង ។ កាលធ្វើសេចក្ដីរាប់អានជាច្រើនឲ្យកើតឡើងក្នុងគុណ មានសីលជាដើម របស់បិណ្ឌបាតិកភិក្ខុនោះ ក៏រមែងធ្វើការយកចិត្តទុកដាក់ឲ្យកើតឡើង ចាំបាច់ពោលថ្វីដល់មនុស្សទាំងឡាយ ។

សេចក្ដីថា បើអ្នកនោះជាអ្នកមិនអាស្រ័យលាភសក្ការៈ និងសេចក្ដីសរសើរ ពិត គឺមិនជាអ្នកសង្ឃឹមលាភជាដើមនោះ ។

កថាពណ៌នាដោយ បិណ្ឌបាតិកង្គ ចប់

( ចប់ មហាដីកា )

## ៤-សបទានចារិកង្គ

## វិធីសមាទានសបទានចារិកង្គ

សបទានចារិកង្គ ក៏មានការសមាទានដោយពាក្យពីរពាក្យនេះ ពាក្យណាមួយ គឺ

១. លោលុប្បចារំ បដិក្ខិបាមិ ខ្ញុំព្រះករុណាសូមឃាត់នូវកិរិយាត្រាច់ទៅបិណ្ឌបាតតាមភាពដែលល្មោភ ។

២. សបទានចារិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវអង្គនៃភិក្ខុ អ្នកមានកិរិយាត្រាច់ទៅដើម្បីបិណ្ឌបាត រៀងតាមលំដាប់នៃផ្ទះជាប្រក្រតី ។

## វិធី (បដិបត្តិ) ក្នុងសបទានចារិកង្គ

សបទានចារិកង្គភិក្ខុនោះ វេលាដែលចូលទៅកាន់ទ្វារស្រុក ត្រូវឈរកំណត់ មើលក្រែងជួនមានភ័យអន្តរាយ ប្រសិនបើមានអន្តរាយណាមួយហើយ រំលងទៅកាន់ស្រុកភូមិដទៃក៏បាន ។ ពុំនោះបើផ្ទះណាច្រកត្រង់ណា ដែលចំណាំតែមិនបានអ្វីបន្តិចបន្តួចសោះនោះត្រូវសម្គាល់ថាមិនមែនជាស្រុកហើយគប្បីបង្ហួសទៅកាន់ទីដទៃក៏គួរ លោកមិនបានភោជនតិចតួចនៅត្រង់ទ្វារផ្ទះណា ឬត្រង់ច្រកណា ឬផ្ទះណា គប្បីធ្វើអគាមសញ្ញា ហើយត្រាច់ទៅកាន់ទីដទៃទៀតចុះ តែ

បើធ្លាប់បានអ្វីបន្តិចបន្តួចត្រង់ទីណា នឹងបង្អួសទីនោះមិនបានឡើយ ភិក្ខុនេះគប្បីចូលទៅកាន់ស្រុកអំពីព្រឹកបន្តិច ការពារក្រែងត្រូវលះបង់នូវទីដែលមិនសប្បាយដោយមានអន្តរាយជាដើម ហើយបង្អួសទៅកាន់ទីដទៃទៀត កុំឲ្យហួសពេល ។ បើមានមនុស្សទាំងឡាយកំពុងថ្វាយទានក្នុងវិហារ ឬគេជួបប្រទះកណ្តាលផ្លូវ ហើយគេយកបាត្រទៅដាក់ចង្ហាន់មកប្រគេន ក៏គួរទទួលបាន ។

ភិក្ខុនេះ កាលបើកំពុងដើរទៅតាមផ្លូវ បើជួបប្រទះស្រុកក្នុងវេលាភិក្ខាចារ មិនត្រូវរំលងហួសឡើយ ទោះបីមិនបានភិក្ខាសោះក្តី បានបន្តិចបន្តួចក្តី ក៏ត្រូវតែត្រាច់ទៅតាមលំដាប់នៃផ្ទះ ។

នេះជាវិធី ( បដិបត្តិ ) នៃសបទានចារិកង្គនោះ ។

## ប្រភេទនៃសបទានចារិកង្គ

សបទានចារិកង្គភិក្ខុនេះ ក៏មានការចែកទៅជា ៣ ថ្នាក់ដូចគ្នា ភិក្ខុថ្នាក់ឧក្រិដ្ឋនឹងទទួលយកនូវចង្ហាន់ដែលគេនាំមកអំពីខាងមុខក្តី ពីខាងក្រោយក្តីពុំបាន ពុំនោះ ដល់ត្រឡប់មកវិញ ហើយទាយកគេយកចង្ហាន់តាមមកប្រគេនក្តី ក៏ទទួលពុំបាន ដូចគ្នា តែបើឈរនៅទៀបទ្វារផ្ទះ ហើយទាយកនាំយកបាត្រទៅដាក់ចង្ហាន់មកប្រគេនខ្លួនចាំតែទទួលបាត្រនោះវិញ គួរ ។ ពិតហើយ ក្នុងធុតង្គនេះ ( ភិក្ខុអ្នក

កាន់យ៉ាងឧក្រិដ្ឋ ) ស្មើដោយព្រះកសប្បត្ថេរមិនមាន ដូច្នោះ សូម្បីទទួលបាត្ររបស់ព្រះថេរៈក៏បានដូចគ្នា ។

ភិក្ខុថ្នាក់កណ្តាល រមែងទទួលភិក្ខាដែលគេនាំមកពីមុខក្តី ពីខាងក្រោយក្តីក៏បាន កាលបើត្រឡប់មកវិញគេនាំយកមកថ្វាយក៏បាន តែបើឈរនៅជិតទ្វារផ្ទះ ហើយទាយកនាំយកបាត្រទៅដាក់ចង្ហាន់មកប្រគេន ខ្លួនចាំតែទទួលបាត្រវិញនោះគួរ, តែមិនត្រូវអង្គុយរង់ចាំភិក្ខា ដោយការមិនអង្គុយរង់ចាំភិក្ខាយ៉ាងនេះ ឈ្មោះថា អនុលោមតាមភិក្ខុកាន់បិណ្ឌបាតថ្នាក់ឧក្រិដ្ឋ ។

ភិក្ខុថ្នាក់មុទុ ( ទាប ) ទោះបីអង្គុយរង់ចាំ ( ភិក្ខា ) ដូច្នោះក៏បានឲ្យតែនៅក្នុងថ្ងៃនោះ ។

## ធុតង្គបែកធ្លាយក្នុងសបទានចារិកង្គ

ធុតង្គរបស់សបទានចារិកភិក្ខុ ទាំង ៣ ជំពូកនេះ កាលបើត្រាច់ទៅបិណ្ឌបាត ដោយភាពល្មោភកើតឡើង រមែងបែកធ្លាយដូចគ្នាទាំង ៣ ។

## អានិសង្សក្នុងសបទានចារិកង្គ

ចំណែកអានិសង្សមានដូចតទៅនេះ គឺ

១-ភាពជាបុគ្គលថ្មីអស់កាលជានិច្ចក្នុងត្រកូលទាំងឡាយ ។

២-ភាពជាបុគ្គលល្អដូចដួងចន្ទ ព្រោះមិនមានការជាប់ជំពាក់ក្នុងត្រកូលទាំងពួង ។

៣-លះបង់នូវសេចក្ដីកំណាញ់ត្រកូលបាន ។

៤-ភាពជាអ្នកមានសេចក្ដីអនុគ្រោះស្មើក្នុងត្រកូលទាំងអស់ ។

៥-មិនមានទោសក្នុងការចូលទៅកាន់ត្រកូល ។

៦-មានកិរិយាមិនទទួលត្រេកអរនូវពាក្យដែលគេហៅរកដោយការនិមន្ត ។

៧- ភាពជាអ្នកមិនមានសេចក្ដីត្រូវការដោយភិក្ខា ដែលគេនាំមកឲ្យ ។

៨- ភាពជាអ្នកមានកិរិយាប្រព្រឹត្តដ៏សមគួរដល់អប្បិច្ឆតាគុណជាដើម ។

## អវសានគាថាក្នុងសបទានចារិកង្គ

សបទានចារិកង្គភិក្ខុក្នុងសាសនានេះ ជាបុគ្គលល្អប្រៀបដូចជាដួងព្រះចន្ទ ជាបុគ្គលថ្មីជានិច្ចក្នុងត្រកូលទាំងឡាយ ជាអ្នកមិនកំណាញ់ត្រកូល មានសេចក្ដីអនុគ្រោះស្មើចំពោះទាយកទាំងអស់ ជាបុគ្គលផុតស្រឡះចាកទោសដែលកើតពី កិរិយាចូលទៅកាន់ត្រកូល ព្រោះហេតុនោះ ភិក្ខុដែលមានបញ្ញា កាលបើប្រាថ្នា ត្រាច់ទៅលើ

ផែនដីដោយសេរី ក៏ត្រូវលះបង់នូវកិរិយាត្រាច់ទៅ ដើម្បីបិណ្ឌបាត តាមភាពដែលល្មោភ ត្រូវមានចក្ខុសម្លឹងចុះក្រោម ត្រូវក្រឡេកមើល ត្រឹមមួយជួរនឹម ហើយគប្បីប្រព្រឹត្តនូវ **សបទានចារិកង្គ** នោះចុះ ។

នេះជាពាក្យពណ៌នា ការសមាទាន វិធី ( បដិបត្តិ ) ប្រភេទ ការបែកធ្លាយ និងអានិសង្សក្នុងសបទានចារិកង្គនេះ ។

# មហាដីកា

## ពណ៌នាអំពីសបទានចារិកង្គ

ពាក្យថា ភិក្ខុនេះ គឺ ភិក្ខុជាសបទានចារិកៈនេះ ។

ពាក្យថា មុនវេលា គឺបានដល់ វេលានោះឯង ។

ពាក្យថា ស្ថានទីដែលមានអន្តរាយ គឺស្ថានទីដែលចូលទៅបានដោយលំបាក ព្រោះទាក់ទងជាមួយនឹងការមានអន្តរាយជាដើម ។

ពាក្យថា ខាងមុខ គឺខាងមុខភិក្ខុដែលកំពុងដើរតាមថ្នល់ ដែលមិនទាន់ចូលទៅកាន់ផ្ទះនោះឯង ។ ពាក្យថា ដែលលោកប្រគល់បាត្របានដល់ ដែលព្រះថេរៈប្រគល់បាត្រនៅត្រង់មាត់ទ្វាររបស់សក្កទេវរាជ ដែលក្លែងខ្លួនជាជាងតម្បាញ ។ ភិក្ខុដែលជាបិណ្ឌបាតិកៈប្រភេទឧក្រិដ្ឋ រមែងមិនអង្គុយទទួលភិក្ខា ក្នុងថ្ងៃនោះ ព្រោះហេតុនោះ ( ភិក្ខុកាន់យកថ្នាក់កណ្តាល ) ទើបឈ្មោះថា អនុលោមតាមភិក្ខុអ្នកកាន់យកថ្នាក់ឧក្រិដ្ឋនោះ ។

ឈ្មោះថា ភាពជាអ្នកថ្មីអស់កាលជានិច្ចក្នុងត្រកូលទាំងឡាយ ព្រោះមិនមានការធ្លាប់ស្គាល់គ្នា ហេតុព្រោះមិនមានការចូលទៅ ជាប្រចាំក្នុងត្រកូលណាៗ ។ ឈ្មោះថា ភាពជាបុគ្គលល្អដូចដួងចន្ទ ព្រោះការមានចិត្តមិនជាប់ក្នុងត្រកូលទាំងឡាយ និងព្រោះមានភាពត្រជាក់ ។

ព្រោះមិនមានចិត្តហួងហែងក្នុងត្រកូលទាំងឡាយ ទើបមានការលះបង់នូវសេចក្ដីកំណាញ់ក្នុងត្រកូលទាំងឡាយនោះបាន ។

ឈ្មោះថា ភាពជាអ្នកមានការអនុគ្រោះស្មើក្នុងត្រកូលទាំងអស់ ព្រោះភាពជាភិក្ខុមានការស្វែងរកនូវប្រយោជន៍មិនមានការបែងចែក។ ការកាន់យករួមគ្នា និងភាពជាអ្នកស្និទ្ធស្នាលក្នុងត្រកូលទាំងឡាយជាដើម ឈ្មោះថា ទោស ក្នុងភាពជាកុលុបកភិក្ខុ ។

ពាក្យថា មិនមានការត្រេកអរនឹងពាក្យដែលគេហៅរក គឺមិនត្រូវការ ទទួលការហៅឈ្មោះដែលទាក់ទងនឹងការនិមន្ត ។

ពាក្យថា ដែលគេនាំមកឲ្យ គឺដោយការនាំមកចំពោះនូវភិក្ខា ។

ពាក្យថា ការត្រាច់ទៅដោយសេរី គឺការត្រាច់ទៅដោយការពេញចិត្ត ។

ពណ៌នាអំពីសបទានចារិកង្គ ចប់

( ចប់ មហាដីកា )

# ៥-ឯកាសនិកង្គ

## វិធីសមាទានឯកាសនិកង្គ

បន្ទាប់អំពីសបទានចារិកង្គមក នឹងពណ៌នាអំពីឯកាសនិកង្គតទៅ ក្នុងឯកាសនិកង្គនេះ ក៏មានបាលីសម្រាប់សមាទានជា ២ បែបដូចគ្នា

**១-នានាសនភោជនំ បដិក្ខិបាមិ** ខ្ញុំព្រះករុណាសូមឃាត់នូវកិរិយាបរិភោគ ភោជនក្នុងអាសនៈផ្សេងៗ ។

**២-ឯកាសនិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុអ្នកមានកិរិយាបរិភោគនូវភោជន តែក្នុងអាសនៈ ១ជាប្រក្រតី ។

## វិធី (បដិបត្តិ) ក្នុងឯកាសនិកង្គ

ឯកាសនិកង្គនោះ កាលអង្គុយក្នុងសាលាឆាន់ មិនត្រូវអង្គុយលើថេរាសនៈឡើយ ត្រូវកំណត់អាសនៈដែលសមគួរដល់ខ្លួនជាមុនសិនសឹមអង្គុយ បើកំពុងឆាន់ មិនទាន់រួច ហើយអាចារ្យ ឬឧបជ្ឈាយ៍និមន្តមកដល់ ក៏គួរនឹងក្រោកទៅធ្វើវត្តបាន ចំណែកឯព្រះតិបិដ្ឋក-ចូឡាភយត្ថេរពោលថា អាសនៈគប្បីរក្សា ការឆាន់គប្បីរក្សា (មិនឲ្យធុតង្គ) បែកធ្លាយក៏ដោយ តែព្រះភិក្ខុនេះជាអ្នកឆាន់រួចហើយ ព្រោះ

ហេតុនោះ ចូរធ្វើវត្តចុះ តែមិនត្រូវត្រឡប់មកឆាន់ភោជនទៀតឡើយ ។

នេះជាវិធី (បដិបត្តិ) នៃឯកាសនិកង្គភិក្ខុនោះ ។

## ប្រភេទនៃឯកាសនិកង្គ

ពោលដោយប្រភេទឯកាសនិកភិក្ខុនេះមាន ៣ ថ្នាក់

ភិក្ខុថ្នាក់ឧក្រិដ្ឋ តែលូកដៃចុះទៅក្នុងភោជនណាហើយ ទោះបីភោជននោះ តិចក្តី ច្រើនក្តី ក៏ត្រូវឆាន់តែប៉ុណ្ណោះ នឹងទទួលភោជនដទៃទៀតមិនបានឡើយ តែបើមនុស្សទាំងឡាយគេគិតឃើញ ព្រះថេរៈនេះមិនបានឆាន់ចង្ហាន់សោះ ឬឆាន់តែបន្តិចបន្តួច ហើយគេនាំយកសប្បិជាដើមមកប្រគេន វត្ថុទាំងនោះបើភិក្ខុទទួលដើម្បីប្រើប្រាស់ជាភេសជ្ជៈបាន បើទទួលដើម្បីជាអាហារមិនបានឡើយ ។

ភិក្ខុថ្នាក់កណ្តាល បើភត្តក្នុងបាត្រមិនទាន់អស់ដរាបណា ក៏អាចនឹងទទួលភោជនដទៃបានដរាបនោះ ។ ភិក្ខុនេះ ឈ្មោះថា **ភោជន-បរិយន្តិកោ** មានទីបំផុតត្រឹមភោជន ។

ភិក្ខុថ្នាក់មុទុ បើមិនទាន់ក្រោកចាកអាសនៈដរាបណា ក៏អាចដើម្បីឆាន់នូវភោជនដទៃបានដរាបនោះ ។ ភិក្ខុនេះ ឈ្មោះថា **ឧទក-បរិយន្តិកោ** មានទីបំផុតត្រឹមទឹកដូច្នេះក៏បាន ព្រោះថា បើមិនទាន់ទទួលទឹកលាងបាត្រដរាបណានៅឆាន់ បានដរាបនោះ ឬនឹងហៅថា

អាសនបរិយន្តិកោ មានទីបំផុតត្រឹមអាសនៈ ដូច្នេះក៏បាន ព្រោះថា បើមិនទាន់ក្រោកចាកអាសនៈដរាបណា នៅឆាន់បាន ដរាបនោះ ។

## ធុតង្គបែកធ្លាយក្នុងឯកាសនិកង្គ

ធុតង្គរបស់ភិក្ខុទាំង ៣ថ្នាក់នេះ រមែងបែកធ្លាយក្នុងខណៈដែលភិក្ខុទាំងនោះបរិភោគភោជនក្នុងអាសនៈផ្សេងៗ នេះជាការបែកធ្លាយក្នុងឯកាសនិកង្គនេះ ។

## អានិសង្សក្នុងឯកាសនិកង្គ

អានិសង្សមានដូចតទៅនេះ គឺ

១-ភាពជាអ្នកមានអាពាធតិច ។

២-ភាពជាអ្នករស់នៅមិនលំបាក គឺមិនមានទុក្ខលំបាកក្នុងសរីរៈ

៣-មានកិរិយាក្រោកឡើងរហ័ស ។

៤-មានកម្លាំងមាំមួន ។

៥-មានកិរិយានៅជាសុខសប្បាយ ។

៦-មិនត្រូវអាបត្តិព្រោះបច្ច័យ នៃកិរិយាបរិភោគនូវអនតិរិត្តភោជន ( ភោជនដែលភិក្ខុហាមភោជនរួចហើយ ដល់ក្រោកចាកអាសនៈនោះទៅ ទើបបានមកជាខាងក្រោយ ហើយមិនបានធ្វើវិនយកម្មឲ្យគួរ ) ( **បឋមបវារណាសិក្ខាបទ** ) ។

៧-មានកិរិយាបន្ទន់នូវចំណង់ក្នុងរស ។

៨- ភាពជាអ្នកមានការប្រព្រឹត្តិសមគួរដល់អប្បិច្ឆតាគុណជាដើម ។

## អវសានគាថាក្នុងឯកាសនិកង្គ

រោគទាំងឡាយ ដែលមានការបរិភោគនូវភោជនជាបច្ច័យឲ្យកើត រមែងមិនបៀតបៀននូវព្រះយោគី អ្នកត្រេកអរក្នុងការបរិភោគនូវភោជនតែក្នុងអាសនៈ ១ ឡើយ ព្រោះហេតុនោះ ព្រះយោគីអ្នកមានចិត្តបរិសុទ្ធ គប្បីញុំាងសេចក្តីត្រេកអរ ឲ្យកើតឡើងក្នុងឯកាស-និកង្គ ដែលជាហេតុនៃការនៅជាសុខសប្បាយ ដែលភិក្ខុត្រេកអរក្នុងសល្លេខគុណដ៏ស្អាតប្រព្រឹត្តចុះ ។

នេះជាការពណ៌នាការសមាទាន វិធី ( បដិបត្តិ ) ប្រភេទ ការបែកធ្លាយ និងអានិសង្សក្នុងឯកាសនិកង្គនេះ ។

# មហាដីកា

## ពណ៌នាអំពីឯកាសនិកង្គ

បទថា នានាសនភោជនំ ប្រែថា ការឆាន់លើអាសនៈច្រើនកន្លែង មានការសម្គាល់ថា មិនឆាន់ដោយការអង្គុយតែមួយគ្រាប៉ុណ្ណោះ តែឆាន់អាហារដោយការអង្គុយតែមួយលើក ។

ពាក្យថា ( អាសនៈ ) ដែលសមគួរ បានដល់ ( អាសនៈ ) ដែលមានសភាព សមគួរ គឺដែលគួរតាំងទុកតាមលំដាប់ ។ ពាក្យថា ការដែលលោកក្រោកឡើងធ្វើវត្តរមែងគួរ គឺកាលដែលលោកធ្វើវត្តរមែងត្រឹមត្រូវ ។ ឈ្មោះថា វត្ត បានដល់ កិច្ចដែលគប្បីធ្វើក្នុងបុគ្គលដែលតាំងនៅក្នុងឋានៈគួរគោរពនោះឯង ។ ដើម្បីនឹងសម្តែងវិធីបដិបត្តិក្នុងវត្តនោះ ទើបលោកអាចារ្យពោលដល់វាទៈរបស់ ព្រះថេរៈដែលថា ការអង្គុយក៏ដោយ ភោជនក៏ដោយ នឹងគប្បីរក្សាទុកដូច្នេះជាដើម ។

វាទៈរបស់ព្រះថេរៈនោះ មានខ្លឹមសារថា ការអង្គុយនឹងគប្បីរក្សាឯកាសនិក ភិក្ខុដែលកំពុងឆាន់ ក៏មានការពោលអធិប្បាយថា មិនគួរក្រោកឡើងរហូតដល់ឆាន់រួច ព្រោះធុតង្គមានការបែកធ្លាយបាន ឬភោជននឹងរក្សាភិក្ខុអ្នកមិនទាន់ បានឆាន់ឲ្យផុតពីការបែកធ្លាយនៃធុតង្គ មានសេចក្តីថា គួរក្រោកឡើងបានដរាបណាដែលនៅមិនទាន់

បានឆាន់ អធិប្បាយថា តែព្រោះហេតុទី ២ សេចក្តីនោះមិន មានក្នុងវារៈនេះ ព្រោះដូច្នោះ ទើបត្រូវរក្សាការធ្វើវត្ត កុំរក្សាធុតង្គដូច្នេះ ។

ព្រោះហេតុនោះ ទើបលោកពោលថា **តែថាភិក្ខុរូបនេះ** ដូច្នេះជាដើម ។

ដោយពាក្យថា **ដើម្បីជាភេសជ្ជៈប៉ុណ្ណោះ** នេះ លោកសម្តែងថា សូប្បីភោជន មានទឹកដោះជូរជាដើម រមែងសមគួរដោយទាក់ទងក្នុងការប្រើជា ភេសជ្ជៈប៉ុណ្ណោះ ។

ពាក្យថា **ភាពជាអ្នកមានអាពាធតិច** គឺភាពជាអ្នកមិនមានរោគ ។

ពាក្យថា **ភាពជាអ្នកមានទុក្ខតិច** គឺភាពជាអ្នកមិនលំបាកបានដល់ មិនមានទុក្ខក្នុងសរីរៈ ។

ពាក្យថា **មានសភាពរហ័សរហួន** បានដល់ មានការផ្លាស់ប្តូរាងកាយបានរហ័ស ។

ពាក្យថា មានកម្លាំង គឺមានកម្លាំងនៃសរីរៈ ។

ពាក្យថា នៅជាផាសុក គឺនៅជាសុខ ។ ពាក្យសូប្បីទាំងអស់នេះជាបទ ដែលហាមភាពវិការ ( ភាពខុសប្រក្រតី ) ដែលកើតឡើងព្រោះការឆាន់ច្រើនដង ជាបច្ច័យ ។

បទថា រុជា ប្រែថា រោគទាំងឡាយ ។

ពាក្យថា មិនញុំាំងកម្មរបស់ខ្លួន ( ឲ្យវិនាសអស់ទៅ ) បានដល់

មិនធ្វើ **យោគកម្ម** ( ការបំពេញព្យាយាម ) របស់ខ្លួនឲ្យវិនាស អស់ទៅ ទាំងមុនពេលឆាន់ទាំងក្រោយពេលឆាន់ អធិប្បាយថា មិនធ្វើឲ្យវិនាសបាត់បង់ទៅ ដោយការមិនវល់អំពល់ក្នុងការឆាន់ច្រើនផង និងដោយភាពមិនមានរោគ ។

ចប់ កថាពោលដោយឯកាសនិកង្គ

( ចប់ មហាដីកា )

## ៦-បត្តបិណ្ឌិកង្គ

## ការសមាទានបត្តបិណ្ឌិកង្គ

សូម្បីបត្តបិណ្ឌិកង្គ ក៏មានការសមាទានដោយពាក្យទាំងពីរនេះ ពាក្យណាមួយ គឺ

**១-ទុតិយភាជនំ បដិក្ខិបាមិ** ខ្ញុំព្រះករុណា សូមឃាត់នូវភាជនៈជាគម្រប់ពីរ ។

**២-បត្តបិណ្ឌិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុ អ្នកមានកិរិយាបរិភោគនូវភោជនទៅក្នុង បាត្រ ១ ជាប្រក្រតី ។

## វិធី(បដិបត្តិ)ក្នុងបត្តបិណ្ឌិកង្គ

បត្តបិណ្ឌិកភិក្ខុនោះ ក្នុងវេលាហុតបបរ កាលបានម្ហូបដាក់ក្នុងភាជនៈហើយ គួរឆាន់ម្ហូបមុន ឬឆាន់បបរមុនក៏បាន ព្រោះបើយើងលាយម្ហូបចុះក្នុងបបរ កាលម្ហូប មានប្រហុកជាដើម ដាក់ចូលក្នុងបបរនឹងបដិកូល គួរខ្ពើម កាលភិក្ខុឆាន់ គប្បីធ្វើឲ្យជារបស់មិនជាបដិកូលសិនសឹមឆាន់ ទើបគួរ ។ហេតុនោះ សេចក្ដីនេះ ខ្ញុំព្រះករុណាពោលសំដៅយកម្ហូបបែបនោះ តែវត្ថុណាជារបស់មិនគួរខ្ពើម ដូចជាទឹកឃ្មុំ និងស្ករផែន វត្ថុនោះ គប្បីដាក់ចូលទៅបាន តែកាលនឹងទទួល

( វត្ថុនោះ ) គប្បីទទួលតែល្មមប្រមាណប្រើដៃ ( ម្ខាង ) កាន់បន្ទែស្រស់ និងជំរឡូងទៅ ឆាន់ក៏គួរ តែបើមិនធ្វើដូច្នោះ ក៏ត្រូវដាក់ចុះក្នុងបាត្របុំណ្ណោះ ក៏ព្រោះហាមភាជនៈទី ២ របស់ដទៃសូម្បីស្លឹកឈើយកមកដាក់ ក៏មិនគួរឡើយ ។

នេះជាវិធី ( បដិបត្តិ ) នៃបត្តបិណ្ឌិកភិក្ខុនោះ ។

## ប្រភេទនៃបត្តបិណ្ឌិកភិក្ខុ

ពោលដោយប្រភេទ បត្តបិណ្ឌិកភិក្ខុនេះ ក៏មាន ៣ ជំពូក ក្នុង ៣ ជំពូកនោះ សម្រាប់អ្នកកាន់ថ្នាក់ឧក្រិដ្ឋ នឹងចោលកាក ( ល្មមឆាន់បាន ) ក៏មិនគួរ វៀរតែកាកអំពៅ ( ដោយហោចទៅសូម្បី ) បេះដុំបាយត្រី សាច់ និងនំ ( ជាចំណែកៗ ) ក៏មិនគួរ ( ព្រោះនាំឲ្យកើតរសតណ្ហា ) ។

ភិក្ខុអ្នកកាន់ថ្នាក់កណ្តាល ប្រើដៃបេះឆាន់ក៏គួរ ភិក្ខុអ្នកកាន់ថ្នាក់កណ្តាលនេះ ទើបឈ្មោះថា ហត្ថយោគី ( យោគីដៃ ) ។

ចំណែកភិក្ខុអ្នកកាន់ថ្នាក់ទាប ឈ្មោះថា **បត្តយោគី** ( យោគីបាត្រ ) សម្រាប់អ្នកកាន់ថ្នាក់ទាបនោះ វត្ថុណាអាចដាក់ចុះក្នុងបាត្របាន អាចបេះវត្ថុនោះដោយដៃ ឬដោយធ្មេញទំពាស៊ីបានទាំងអស់ ។

## ការបែកធ្លាយនៃបត្តបិណ្ឌិកង្គ

ធុតង្គរបស់បត្តបិណ្ឌិកភិក្ខុទាំង ៣ ជំពូកនេះ រមែងបែកធ្លាយក្នុងខណៈដែលត្រេកអរក្នុងភាជនៈទី ២ ។ នេះ គឺជាការបែកធ្លាយក្នុងបត្តបិណ្ឌិកង្គ ។

## អានិសង្សនៃបត្តបិណ្ឌិកង្គ

ចំណែកអានិសង្សមានដូចតទៅនេះគឺ

១-បន្ទោបង់តណ្ហាក្នុងរសផ្សេងៗ បាន ។

២-លះបង់ការល្មោភច្រើន ( ក្នុងអាហារ ) បាន ។

៣-ជាអ្នកឃើញនូវប្រមាណនៃប្រយោជន៍ក្នុងអាហារ ។

៤-មិនមានសេចក្តីលំបាកក្នុងការរក្សាភាជនៈមានថាសជាដើម ។

៥-មិនជាអ្នករាយមាយ ( សារ៉ាំ ) ក្នុងការបរិភោគ ។

៦-មានការប្រព្រឹត្តិសមគួរដល់ធុតធម៌មានការប្រាថ្នាតិចជាដើម ។

## អវសានគាថាក្នុងបត្តបិណ្ឌិកង្គ

បុគ្គលឯណា នឹងគប្បីជាអ្នកមានភ្នែកដាក់ចុះ លះបង់នូវភាពរាយមាយក្នុងភោជនផ្សេងៗ ជាអ្នកមានវត្តល្អ គាស់រំលើងឫសគល់នៃរសតណ្ហាចោល ដូចជាដីកឫសឈើចោល ជាអ្នកមានចិត្តបរិសុទ្ធ ទ្រទ្រង់ទុកនូវសេចក្តីសន្តោស ហាក់ដូចជាទ្រទ្រង់ទុកនូវរូបកាយ

របស់ខ្លួន ( អាច ) បរិភោគអាហារ ( ចម្រុះ ) បាន ( បុគ្គលនេះ ) ក៏គឺ បត្តបិណ្ឌិកភិក្ខុនោះឯង ។

នេះជាពាក្យពណ៌នា ការសមាទាន វិធី ( បដិបត្តិ ) ប្រភេទ ការបែកធ្លាយ និងអានិសង្សនៃបត្តបិណ្ឌិកង្គនេះ។

# មហាដីកា

## ពណ៌នាកថាក្នុងបត្តបិណ្ឌិកង្គ

ពាក្យថា គួរធ្វើមិនឲ្យជារបស់បដិកូលហើយបរិភោគ អធិប្បាយថា កាលបរិភោគនូវអាហារដែលជាបដិកូល ក៏នឹងគប្បីមានការតាំងនៅមិនបានក៏បាន ។

ពាក្យថា គួរនឹងទទួលយកល្មមប្រមាណប៉ុណ្ណោះ សេចក្តីថា មិនគប្បីទទួលយកច្រើន ដោយគិតថា យើងទទួលយកត្រឹមតែភាជនៈ ១ ប៉ុណ្ណោះ ដូច្នេះហើយ ត្រូវចោលទៅ ។ ពាក្យថា បន្ទោបង់តណ្ហាក្នុងរសផ្សេងៗ បាន គឺបន្ទោបង់ តណ្ហាក្នុងភោជន មានរសផ្សេងៗ បាន ។

បុគ្គលឈ្មោះថា អ្នកលោភច្រើន ព្រោះអត្ថថា មានសេចក្តីត្រូវការក្នុងរសផ្សេងៗ ដែលតាំងនៅក្នុងភាជនៈផ្សេងៗ ភាជនៈនោះ ភាជនៈនេះ,ភាវៈនៃបុគ្គលដែលជាអ្នកលោភនោះឈ្មោះថាការប្រាថ្នាច្រើន បានដល់ លះបង់សេចក្តីប្រាថ្នាច្រើននោះបាន ។

ពាក្យថា **ជាអ្នកឃើញប្រមាណនៃប្រយោជន៍ក្នុងអាហារ** គឺជាអ្នកមិនធ្វើនូវចំណង់ក្នុងរសផ្សេងៗ ដែលមិនលាយឡំគ្នា ឃើញត្រឹមតែប្រយោជន៍ ដែលព្រះមុនីទ្រង់អនុញ្ញាតទុកក្នុងអាហារ ។ ព្រោះការ

ដែលភិក្ខុអ្នកកាន់យកម្ហូប ដែលដាក់នៅក្នុងភាជនៈទាំងឡាយរំលែក ជា ១ភាជន៍ៗមានការនឹកទៅក្នុងភាជន៍នោះៗទើបគប្បីជាអ្នកបរិភោគ រាយមាយ, សម្រាប់ភិក្ខុអ្នកសម្គាល់ ចំពោះតែអាហារ ដែលនៅក្នុង តែបាត្រមួយនេះ មិនអាចជាអ្នករាយមាយក្នុងការបរិភោគយ៉ាងនោះ ឡើយ ព្រោះហេតុនោះ ទើបលោកពោលថា មានភាពជាអ្នកមិនរាយ មាយក្នុងការបរិភោគ ដូច្នេះ ។ ពាក្យថា មានភ្នែកដាក់ចុះ គឺមានចក្ខុ សម្លឹងចុះក្រោម ព្រោះភាពជាអ្នកសម្គាល់នៅតែក្នុងបាត្រ ។

ពាក្យថា គប្បីបរិភោគ គឺអាចទឹងបរិភោគ ។

ចប់ កថាពណ៌នាបត្តបិណ្ឌិកង្គ

( ចប់ មហាដីកា )

# ៧-ខលុបច្ឆាភត្តិកង្គ

## ការសមាទានខលុបច្ឆាភត្តិកង្គ

សូម្បីខលុបច្ឆាភត្តិកង្គក៏មានការសមាទានដោយពាក្យទាំងពីរបែបនេះណាមួយក៏បាន

**១-អតិរិត្តភោជនំ បដិក្ខិបាមិ** ខ្ញុំព្រះករុណាសូមវៀរចាកភោជនដែលជាអតិរិត្តភោជន ។

**២-ខលុបច្ឆាភត្តិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុដែលមិនឆាន់បច្ឆាភត្តជាប្រក្រតី ។

## វិធី (បដិបត្តិ) ក្នុងខលុបច្ឆាភត្តិកង្គ

ក៏ភិក្ខុខលុបច្ឆាភត្តិកនោះ ហាមភត្តហើយ នឹងឲ្យធ្វើភោជនជាកប្បិយហើយ ឆាន់ទៀតមិនបានឡើយ ។

នេះជា វិធី ( បដិបត្តិ ) នៃខលុបច្ឆាភត្តិកភិក្ខុនោះ ។

## ប្រភេទនៃខលុបច្ឆាភត្តិកភិក្ខុ

ពោលដោយប្រភេទ សូម្បីខលុបច្ឆាភត្តិកភិក្ខុនេះ ក៏មាន ៣ ជំពូក ក្នុង ៣ ជំពូកនោះ លោកដែលកាន់ថ្នាក់ឧក្រិដ្ឋ ដែលហៅថាហាមនូវភោជននោះ មិនដែលមាននៅក្នុងដុំបាយជាដំបូងឡើយ លុះ

ត្រាតែភិក្ខុកំពុងលេបចូលនូវដុំបាយជាដំបូងនោះ ហើយឃាត់នូវភោ-ជនដទៃ ទើបបានឈ្មោះថា ហាម គឺថា បើភិក្ខុមិនទាន់បានឆាន់សោះទោះបីឃាត់នូវភោជនដទៃ ក៏មិនបានឈ្មោះថា ហាម លុះតែបានឆាន់ខ្លះ ដោយហោចទៅសូម្បីត្រឹមតែមួយដុំ ហើយឃាត់នូវភោជនដទៃ ទើបបានឈ្មោះថា ហាម ព្រោះហេតុនោះ ភិក្ខុថ្នាក់ឧក្រិដ្ឋតែហាមភោជនយ៉ាងនេះហើយ នឹងឆាន់នូវដុំបាយជាគម្រប់ពីរមិនបានឡើយ ។

ភិក្ខុថ្នាក់កណ្ដាល ភោជនណាដែលខ្លួនកំពុងឆាន់ ហើយហាមនូវភោជនដទៃ ក៏អាចនឹងឆាន់នូវភោជនដែលខ្លួនកំពុងឆាន់នោះត្រាតែអស់បាន តែនឹងឆាន់ភោជនដទៃទៀតមិនបានឡើយ ។

ភិក្ខុថ្នាក់ទាប បើមិនទាន់ក្រោកចាកអាសនៈដរាបណា នៅឆាន់បានដរាបនោះ ។

## ការបែកធ្លាយនៃខលុបច្ឆាភត្តិកង្គ

ធុតង្គរបស់ខលុបច្ឆាភត្តិកភិក្ខុទាំង ៣ជំពូកនេះរមែងបែកធ្លាយក្នុងខណៈ ដែលលោកហាម ( ភោជន ) ហើយឲ្យធ្វើជាកប្បិយឆាន់ នេះជាការបែកធ្លាយក្នុង ខលុបច្ឆាភត្តិកង្គនេះ ។

## អានិសង្សនៃខលុបច្ឆាភត្តិកង្គ

ចំណែកអានិសង្សមានដូចតទៅនេះ

១-ជាអ្នកឆ្ងាយអំពីការត្រូវអាបត្តិ ព្រោះឆាន់អនតិរិត្តភោជន ។

២-មិនមានការណែនពោះ ។

៣-មិនមានការសន្សំអាមិស ។

៤-( ឆាន់ហើយ ) មិនចាំបាច់ស្វែងរកទៀត ។

៥-មានការប្រព្រឹត្តិសមគួរដល់ធុតធម៌ មានការប្រាថ្នាតិចជាដើម ។

## អវសានគាថាក្នុងខលុបច្ឆាភត្តិកង្គ

ខលុបច្ឆាភត្តិកយោគីមានបញ្ញា រមែងមិនលំបាកក្នុងការស្វែងរក មិនធ្វើសន្និ បាត់នូវភាពតឹងពោះ ព្រោះហេតុនោះ ព្រះយោគីអ្នកប្រាថ្នានឹងកម្ចាត់នូវទោសទាំងឡាយ គប្បីសេពធុតង្គនេះ ដែលព្រះសុគតជាម្ចាស់ ទ្រង់សរសើរ ដែលជាហេតុឲ្យកើតសេចក្តីចម្រើនដោយគុណ មានគុណ គឺសេចក្តីសន្តោសជាដើម ហោង ។

នេះជាពាក្យពណ៌នាការសមាទាន វិធី (បដិបត្តិ) ប្រភេទ ការបែកធ្លាយ និងអានិសង្សក្នុងខលុបច្ឆាភត្តិកង្គនេះ ។

## មហាដីកា

## កថាពោលដោយខលុបច្ឆាភត្តិកង្គ

ភោជនឯណា ដែលគេនាំចូលទៅប្រគេនដល់ភិក្ខុអ្នកកំពុងឆាន់ ព្រោះការបដិសេធន៍នៃភិក្ខុនោះ ភោជននោះ ចាត់ជាភោជនលើសកំណត់ ព្រោះហេតុនោះ ទើបហៅថា **អតិរិត្តភោជន** ឈ្មោះថា **មិនគួរធ្វើភោជនឲ្យជាកប្បិយហើយ ឆាន់ទៀត**, ក៏ព្រោះធុតង្គនេះ មានអតិ-រិត្តភោជននោះជាវិស័យ ( គឺជាវត្ថុដែលធុតង្គនេះត្រូវបដិសេធ ) ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **នេះជាវិធីបដិបត្តិនៃភិក្ខុអ្នកកាន់ខលុបច្ឆាភត្តិកនោះ** ដូច្នេះ ។

ពាក្យថា ( ហាមភត្តហើយ ) **ក្នុងភោជនណា** គឺ ( ហាមភត្តហើយ ) ក្នុងភោជន ដែលលោកកំពុងឆាន់ឯណា ឈ្មោះថា ឆាន់បានតែភោជននោះប៉ុណ្ណោះ គឺឆាន់ភោជនដទៃមិនបាន ។ អាបត្តិព្រោះការឆាន់អនតិរិត្តភោជនជាបច្ច័យ ឈ្មោះថា អាបត្តិព្រោះការឆាន់អនតិ-រិត្តភោជន, ឈ្មោះថា ភាពជាអ្នកឆ្ងាយចាកអាបត្តិនោះ គឺការមិនត្រូវអាបត្តិ ។ ឈ្មោះថា ការណែនពោះ បានដល់ ភាពស្រវឹង គឺភាពជាអ្នកធ្វើពោះឲ្យពេញ, ឈ្មោះថា មិនមានភាពណែនពោះនោះ ក៏ព្រោះការធ្វើអត្តភាពឲ្យប្រព្រឹត្តទៅ ស្ងប់ដោយបិណ្ឌបាតមួយដុំ ។ ឈ្មោះ

ថា មិនមានការសន្សំអាមិស ព្រោះមិនមានការប្រើប្រាស់វត្ថុដែលសន្សំទុក ។

ឈ្មោះថា មិនប្រព្រឹត្តទៅកាន់ភាពលំបាក ព្រោះការស្វែងរកក៏ដោយ ទាក់ទិនជាមួយការដែលត្រូវស្វែងរកទៀត ។ ព្រោះញ៉ាំងភាពចម្រើននៃគុណទាំងឡាយ មានសេចក្តីសន្តោសជាដើម ដែលជុសខាត់ ( កិលេស ) យ៉ាងក្រៃលែងឲ្យកើតឡើង ឈ្មោះថា ហេតុ ញ៉ាំងភាពចម្រើននៃគុណទាំងឡាយ មានសេចក្តីសន្តោសជាដើមឲ្យកើតឡើង ។ ពាក្យថា ធុតង្គប្រការនេះ គឺមាតិកា **ខលុបច្ឆាភត្តិកង្គ** ។

ចប់ កថាពណ៌នាខលុបច្ឆាភត្តិកង្គ

( ចប់ មហាដីកា )

# ៨–អារញ្ញិកង្គ

## ការសមាទានអារញ្ញិកង្គ

សូម្បីអារញ្ញិកង្គ ក៏មានការសមាទានដោយពាក្យ ២ ពាក្យនេះ ពាក្យណាមួយ ក៏បាន

**១–គាមន្តសេនាសនំ បដិក្ខិបាមិ ខ្ញុំព្រះករុណាសូមវៀរចាក សេនាសនៈក្នុងចន្លោះស្រុក ។**

**២–អារញ្ញិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទានអង្គ នៃភិក្ខុអ្នក មានកិរិយានៅព្រៃជាប្រក្រតី ។**

## វិធី(បដិបត្តិ)ក្នុងអារញ្ញិកង្គ

ក៏អារញ្ញិកភិក្ខុនោះគប្បីលះបង់សេនាសនៈចន្លោះស្រុកចោល ហើយញុំាងអរុណឲ្យតាំងឡើងក្នុងព្រៃចុះ ។

## វិនិច្ឆ័យសេនាសនៈព្រៃ

ស្រុកព្រមទាំងឧបចារៈស្រុកនោះឯង ឈ្មោះថា សេនាសនៈ ចន្លោះស្រុក ក្នុងពាក្យនោះ ស្រុកមានខ្ទម ១ ឬច្រើនខ្ទងក៏ដោយ មានរបងព័ទ្ធ ឬមិនមានរបងព័ទ្ធក៏ដោយ មានមនុស្សរស់នៅក៏ដោយ ឬមិនមានមនុស្សរស់នៅក៏ដោយ យ៉ាងណាមួយ ឈ្មោះថា ស្រុក ដោយហោចទៅ សូម្បីក្រុមរទេះណាៗ ដែលចតស្នាក់នៅ លើសពី

៤ ខែ ក៏ឈ្មោះថា ស្រុក សម្រាប់ស្រុកដែលមានរបងព័ទ្ធ បើមាន ឥន្ទខីល ( ធរណីទ្វារ ) ពីរជាន់ ដូចអនុរាធបុរៈ ទីដែលដុំដីធ្លាក់ដោយ មជ្ឈិមបុរសដ៏មានកម្លាំង ឈរត្រង់ឥន្ទខីលជាន់ខាងក្នុង ( គ្រវែងទៅ ពេញទំហឹង ) ឈ្មោះថា ឧបចារៈស្រុក ព្រះវិន័យធរទាំងឡាយពោល ថា លក្ខណៈម្យ៉ាងនៃលេឌ្ឌុបាតនោះ ក៏គឺរួមយកក្នុងទីដែលធ្លាក់ចុះ នៃដុំដីដែលគ្រវែងទៅ ( ពេញកម្លាំង ) នៃពួកក្មេងកំលោះ កាលនឹង សម្ដែងកម្លាំងរបស់ខ្លួន លាតដៃគ្រវែងដុំដីទៅ ( ដោយកម្លាំង ) ដូច្នោះ ចំណែកអាចារ្យខាងព្រះសូត្រពោលថា ខាងក្នុងទីដែលធ្លាក់ចុះនៃដុំដី ដែលគ្រវែងទៅ ( ល្មម ) ប្រហែលគ្មានឹងដេញក្អែក ឈ្មោះថា លេឌ្ឌុបាត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងស្រុកដែលគ្មានរបងថា ស្ត្រីឈរត្រង់ទ្វារ ផ្ទះដែលនៅ ក្រោយគេបង្អស់បាចទឹកទៅដល់ទីណា ទីទឹកធ្លាក់នោះ ឈ្មោះថា ឧបចារៈផ្ទះ លេឌ្ឌុបាតទី ១ ដោយន័យដែលពោលហើយ អំពីឧបចារៈផ្ទះនោះ ឈ្មោះថា ឧបចារៈ ស្រុក, លេឌ្ឌុបាតទី ២ ជា ឧបចារៈនៃស្រុក ។

ចំណែកព្រៃ ពោលតាមផ្លូវព្រះវិន័យ លោកពោលទុកថា ទី ទាំងពួង វៀរតែស្រុក និងឧបចារនៃស្រុកចេញនោះ ឈ្មោះថា ព្រៃ ។ ផ្លូវព្រះអភិធម្មពោលថា ទីទាំងពួងខាងក្រៅអំពីឥន្ទខីលចេញទៅ

ឈ្មោះថា ព្រៃ ។ តែលក្ខណៈដែលពោលខាងផ្លូវព្រះសូត្រថា ទីមានរយៈចម្ងាយ ៥០០ ធ្នូរ យ៉ាងតិច ឈ្មោះថា សេនាសនៈព្រៃ, នេះជាលក្ខណៈក្នុងពាក្យថា ព្រៃ នេះ ។ សេនាសនៈព្រៃនោះ សម្រាប់ស្រុកដែលមានរបងព័ទ្ធ គប្បីកំណត់វាស់អំពីឥន្ទខីលដោយធនូរបស់អាចារ្យដែលវាស់ ហើយសម្រាប់ស្រុកដែលមិនមានរបងព័ទ្ធ គប្បីកំណត់វាស់ ចាប់ផ្ដើមអំពីលេឌ្ឌុបាតទី ១ រហូតដល់របងវិហារ ។ ក្នុងអដ្ឋកថាព្រះវិន័យទាំងឡាយពោលថា បើវិហារដែលមិនមានរបងសេនាសនៈដែលនៅដើមគេ ឬរោងភត្ត ឬកន្លែងប្រជុំជាប្រចាំ ដើមពោធិ៍ ឬចេតិយណា សូម្បីថា នៅឆ្ងាយអំពីសេនាសនៈចេញទៅ គប្បីធ្វើទីនោះឲ្យជាដែនកំណត់សម្រាប់វាស់ចុះ ។

ចំណែកក្នុងអដ្ឋកថា មជ្ឈិមនិកាយពោលថា គប្បីវាស់ឧបចារៈសូម្បីឧបចារៈវិហារ ត្រង់ទៅក្នុងរវាង ២ លេឌ្ឌុបាត ដូចវាស់ឧបចារៈស្រុក ។ នេះជាប្រមាណ ក្នុងវិធីវាស់នេះ ។ សូម្បីបើស្រុកនៅជិតភិក្ខុនៅក្នុងវិហារបានឮសំឡេងអ្នកស្រុក តែមិនអាចនឹងដើរត្រង់ទៅ ( កាន់ស្រុកនោះ ) បាន ព្រោះមានភ្នំ ឬស្ទឹងជាដើម ខណ្ឌនៅក្នុងរវាងនោះ ផ្លូវណាដែលជាផ្លូវធម្មតារបស់ស្រុកនោះ សូម្បីបើនឹងត្រូវទៅដោយទូក ក៏គប្បីកាន់យក ៥០០ ធ្នូរ ដោយផ្លូវនោះ ។ តែភិក្ខុណាក្រែងបិទផ្លូវត្រង់ទីនោះៗ ( ដែលជាផ្លូវដើរត្រង់ទៅកាន់ស្រុកបាន

មិនដល់ ៥០០ ជួរធ្នូ ) ចោល ដើម្បីញ៉ាំងអង្គនៃស្រុកជិតឲ្យដល់ព្រម ( គឺដើម្បីដើរវាងអែបទៅឲ្យបានកំណត់ ៥០០ ជួរធ្នូ ដូចលក្ខណៈស្រុកជិត មានស្រីងវ័ណ្ណដូចពោលខាងដើម ) ភិក្ខុនោះ ឈ្មោះថាធុតង្គចោរ ។ ក៏បើឧបជ្ឈាយ៍ ឬអាចារ្យរបស់អារញ្ញិកភិក្ខុមានជំងឺ អារញ្ញិកភិក្ខុរកទីសប្បាយ ( កន្លែងដែលថែទាំអាចារ្យ ) មិនបាន ក៏គប្បីនាំលោកទៅកាន់សេនាសនៈក្នុងស្រុក ឧបដ្ឋាកលោកចុះ ។ តែអារញ្ញិកភិក្ខុ គប្បីចេញទៅពីងងឹត ញ៉ាំងអរុណឲ្យរះឡើងក្នុងទីដែលប្រកបដោយអង្គ ។ បើក្នុងវេលាអរុណរះឡើង អាពាធរបស់អាចារ្យរើឡើង ក៏គួរធ្វើកិច្ចដើម្បីលោកនោះចុះ ។ មិនគប្បីជាធុតង្គសុទ្ធិក ( អ្នកគិតតែអំពីរក្សាធុតង្គឲ្យបរិសុទ្ធតែម្យ៉ាង ) នោះឡើយ ។

## ប្រភេទនៃអារញ្ញិកង្គ

ពោលដោយប្រភេទ សូម្បីអារញ្ញិកភិក្ខុនេះក៏មាន ៣ជំពូក ក្នុង ៣ ជំពូកនោះ លោកអ្នកកាន់ថ្នាក់ឧក្រិដ្ឋ ត្រូវញ៉ាំងអរុណឲ្យតាំងឡើងក្នុងព្រៃរហូតអស់កាលទាំងពួង ។

អ្នកកាន់ថ្នាក់កណ្តាល រមែងបានដើម្បីនឹងនៅក្នុងសេនាសនៈក្នុងស្រុកអស់កាល ៤ ខែ ដែលជារដូវភ្លៀង ។

អ្នកកាន់ថ្នាក់ទាប រមែងបានដើម្បីនឹងនៅ ៤ ខែ នាហេមន្តរដូវផង ។

## ការបែកធ្លាយនៃអារញ្ញិកង្គ

ក៏កាលអារញ្ញិកង្គទាំង ៣ ពួកនេះ មកអំពីព្រៃក្នុងវេលាដែលបានកំណត់ទុកហើយយ៉ាងណា កំពុងស្តាប់ធម៌ក្នុងសេនាសនៈក្នុងស្រុក សូម្បីរហូតដល់អរុណរះឡើង ធុតង្គក៏រមែងមិនបែកធ្លាយ ស្តាប់ធម៌ហើយទៅ សូម្បីអរុណរះឡើងក្នុង រវាងផ្លូវធុតង្គក៏មិនបែកធ្លាយ តែបើព្រះធម្មកថិកក្រោកចាកអាសនៈហើយ អារញ្ញិកភិក្ខុគិតថា ដេកបន្តិចសិន ហើយសឹមទៅ ដូច្នេះ ហើយដេករហូតដល់អរុណរះឡើង ឬថា ញ៉ាំងអរុណឲ្យរះឡើងក្នុងសេនាសនៈក្នុងស្រុក តាមការពេញចិត្តរបស់ខ្លួន ធុតង្គរមែងបែកធ្លាយដោយពិត ។នេះជាការបែកធ្លាយក្នុងអារញ្ញិកង្គនេះ ។

## អានិសង្សនៃអារញ្ញិកង្គ

ចំណែកអានិសង្សមានដូច្នេះ គឺ

១-អារញ្ញិកភិក្ខុធ្វើសេចក្តីសម្គាល់ថា ព្រៃ ទុកក្នុងចិត្ត រមែងជាអ្នកគួរដើម្បីនឹងបានសមាធិដែលនៅមិនទាន់បានខ្លះ ដើម្បីនឹងរក្សាសមាធិដែលបានហើយខ្លះ ។

២-សូម្បីព្រះមានជោគ ក៏ទ្រង់សរសើរចំពោះអារញ្ញិកភិក្ខុ ដូចដែលទ្រង់ត្រាស់ថា ម្នាលនាគិតៈ ព្រោះហេតុនោះ តថាគតមានចិត្តត្រេកអរដោយការនៅព្រៃ របស់ភិក្ខុនោះ ។

៣-អន្តរាយទាំងឡាយមានរូប ដែលមិនជាទីសប្បាយជាដើម

រមែងមិនរំខានចិត្តរបស់អារញ្ញិកភិក្ខុដែលនៅក្នុងសេនាសនៈដ៏ស្ងាត់ ។

៤-លោករមែងបាត់ការភ័យខ្លាច ។

៥-រមែងលះបង់ការជាប់ជំពាក់ក្នុងជីវិតបាន ។

៦-រមែងត្រេកអរក្នុងរសនៃសេចក្តីសុខដែលកើតអំពីវិវេក ។

៧-ភាពជាអ្នកទ្រទ្រង់សំពត់បង្សុកូលជាដើម រមែងជាភាវៈសមសួនដល់លោក ។

## អវសានគាថាក្នុងអារញ្ញិកង្គ

អ្នកមានវត្តដ៏ស្ងាត់ មិនច្រឡូកច្រឡំ ( ជាមួយអ្នកដទៃ ) ត្រេកអរក្នុងសេនាសនៈដែលស្ងាត់ អាចញ៉ាំងព្រះវិន័យរបស់ព្រះលោកនាថជាម្ចាស់ ឲ្យទ្រង់ត្រេកអរព្រោះការនៅព្រៃ ការអាស្រ័យនៅក្នុងព្រៃតែម្នាក់ឯង រមែងបានសេចក្តីសុខឯណា សូម្បីទេវតាព្រមទាំងព្រះឥន្ទ្រ ក៏មិនបានរសនៃសេចក្តីសុខនោះដែរ ហើយព្រះយោគីនោះឯងទ្រទ្រង់ទុកនូវសំពត់បង្សុកូល បីដូចជាគ្រឿងក្រោះ ចូលកាន់សង្គ្រាម គឺព្រៃមានធុតង្គដ៏សេសជាអាវុធ ក៏អាចនឹងឈ្នះមារព្រមទាំងពាហនៈ បានមិនយូរឡើយ ព្រោះហេតុនោះ ភិក្ខុដែលជាបណ្ឌិតគប្បីធ្វើសេចក្តីត្រេកអរ ក្នុងការនៅព្រៃចុះ ។

នេះជាពាក្យពណ៌នាការសមាទាន វិធី ( បដិបត្តិ ) ប្រភេទ ការបែកធ្លាយ និងអានិសង្សក្នុងអារញ្ញិកង្គនេះ ។

# មហាដីកា

## ពណ៌នាអារញ្ញិកង្គ

ក្នុងពាក្យថា គប្បីលះសេនាសនៈចន្លោះស្រុកចេញ ហើយញ៉ាំងអរុណឲ្យរះឡើងក្នុងព្រៃចុះ នេះលោកអាចារ្យបំណងសម្ដែងសេនាសនៈក្នុងស្រុក និងព្រៃដោយភាវៈដែលមាននៅ ( ក្នុងព្រះបាលី ) ទើបផ្ដើមពាក្យថា ក្នុងពាក្យថា សេនាសនៈក្នុងស្រុកនោះ ( គឺ ) ស្រុកព្រមជាមួយនឹងឧបចារស្រុក ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ លោកអាចារ្យពោលថា ស្រុក និងឧបចារៈស្រុកនោះឯងឈ្មោះថា សេនាសនៈចន្លោះស្រុក ដូច្នេះ ព្រោះភាពដែលសេនាសនៈចន្លោះស្រុកជាប់ទាក់ទងចូលក្នុងស្រុក ។ ភ្ជាប់សេចក្ដីថា សូម្បីរទេះមួយគ្រឿងក៏ឈ្មោះថា ស្រុក ។ បទថា ឥន្ទខីលា ប្រែថា ធរណីទ្វារ ។ ពាក្យថា នៃសេនាសនៈចន្លោះស្រុកនោះ បានដល់ ការចោលដុំដីឲ្យធ្លាក់ទៅ ។ ដោយបរិយាយព្រះវិន័យ លក្ខណៈរបស់ព្រៃមកហើយក្នុងបារាជិកសិក្ខាបទអទិន្នាទាន ។ ពិតណាស់ ក្នុងសិក្ខាបទមាតិកានេះ លក្ខណៈរបស់ព្រៃមកក្នុងគោលកំណត់ដល់ស្ថានទីនៃការលួចទុកដោយមិនសល់ថា គាមា វា អរញ្ញា វា អំពីស្រុកក្ដី អំពីព្រៃក្ដីជាដើម ( សេចក្ដីទាំងអស់ថា ភិក្ខុណាមួយកាន់យករបស់ដែលគេ

មិនបានឲ្យអំពីស្រុកក្តី អំពីព្រៃក្តី រាប់ថាជាការលួច ។ល។ ភិក្ខុកាន់យករបស់ដែលគេមិនបានឲ្យយ៉ាងនោះ យ៉ាងនេះចាត់ជាបារាជិករកសង្វាសគ្មាន ) លោកអាចារ្យបំណងនឹង សម្តែងនូវស្រុក និងព្រៃទាំងពីរយ៉ាងនោះ មិនធ្វើឲ្យលាយឡំគ្នា ទើបពោលថា **ទីទាំងពួងលើកលែងតែស្រុក** ដូច្នេះជាដើម ។

ពិតណាស់ ក្នុងផ្លូវលោក ទីជិតស្រុកក៏រមែងដល់នូវការរាប់ថាជាស្រុកផងដែរ តែបើពោលដោយនិប្បរិយាយ ស្ថានទីដែលផុតទៅអំពីស្រុក ក៏អាចចាត់ថា ជាព្រៃបានដែរ ព្រោះហេតុនោះ ក្នុងព្រះអភិធម្មទើបទ្រង់ត្រាស់ទុកថា **និក្ខមិត្វា ពហិ ឥន្ទខីលា សព្វមេតំ អរញ្ញំ** ខាងក្រៅអំពីឥន្ទខីលចេញទៅទីទាំងអស់នេះ ឈ្មោះថា ព្រៃ ដូច្នេះ ។ដោយបរិយាយក្នុងព្រះសូត្រ ទ្រង់ត្រាស់សំដៅយកភិក្ខុដែលនៅក្នុងព្រៃដែលមកហើយក្នុងអរញ្ញិកសិក្ខាបទថា ស្ថានទីមានរយៈចម្ងាយ ៥០០ ជួរធ្នូ យ៉ាងតិច ដូច្នេះ ។ពិតណាស់ ភិក្ខុរូបនោះ លោកមិនពោលក្នុងព្រះសូត្រថា ជាអ្នកដែលនៅក្នុងព្រៃមានសេនាសនៈដ៏ស្ងាត់ ហេតុ ព្រោះការនៅក្នុងព្រៃ ដែលមានបរិយាយព្រះវិន័យ ( ត្រូវជាព្រៃដែលមានបរិយាយក្នុងព្រះសូត្រ ) ។ តែពេលនេះជាការពណ៌នាព្រះសូត្រ ព្រោះហេតុនោះ ក្នុងទីនេះ ពាក្យបរិយាយក្នុងព្រះសូត្រប៉ុណ្ណោះ ជាប្រមាណក្នុងបទទាំងពួង ។ ព្រោះហេតុនោះ

លោកអាចារ្យកាលនឹងសម្ដែងពោលនូវលក្ខណៈ (របស់ព្រៃ) ដែលមកក្នុង ព្រះសូត្រនេះប៉ុណ្ណោះ ដែលគួរកាន់យក ដូច្នេះ ទើបលោកពោលដល់វត្ថុវិធីទុក ដោយពាក្យថា សេនាសនៈព្រៃនោះ ។ល។ ដោយដងផ្លូវនៃអាចារ្យដែលដាក់ចុះដូច្នេះជាដើម ។

ក៏ព្រោះហេតុនោះ ទើបលោកបានពោលដល់ន័យក្នុងអដ្ឋកថា **មជ្ឈិមនិកាយ** ទុកផងដែរថា ពាក្យរបស់ **អដ្ឋកថាមជ្ឈិមនិកាយ** នេះជាប្រមាណក្នុងការវាស់នេះ ដូច្នេះ ។

ពាក្យថា **បិទផ្លូវអំពីទីនោះៗ** បានដល់ បិទផ្លូវតូច និងផ្លូវធំក្នុងទីនោះៗ ។ ភិក្ខុឈ្មោះថា ( រមែងដឹង ) ជាអ្នកមានធុតង្គបរិសុទ្ធ គឺជាអ្នកខ្វល់ខ្វាយក្នុងការធ្វើធុតង្គឲ្យបរិសុទ្ធ ។ ពាក្យថា (មកអំពីព្រៃ) ក្នុងវេលាតាមដែលកំណត់ មានសេចក្ដីថា សម្រាប់ភិក្ខុអ្នកកាន់ថ្នាក់ឧក្រិដ្ឋទាំង ៣ វេជូវ, សម្រាប់ភិក្ខុអ្នកកាន់ថ្នាក់កណ្ដាល ត្រឹម ២ វេជូវ, សម្រាប់ភិក្ខុអ្នកកាន់ថ្នាក់ទាបត្រឹម ១ វេជូវ ។ ឈ្មោះថា ធុតង្គមិនបែកធ្លាយ សូម្បីក្នុងកាលតាមដែលកំណត់ទុកនោះ ក៏ព្រោះសេចក្ដីដែលនៅមានឧស្សាហៈ ។

ពាក្យថាយើងដេកបន្តិចសិនហើយសឹមទៅជាការដែលលោកអធិប្បាយថា **ធុតង្គ** រមែងបែកធ្លាយបានព្រោះការធូរថយនៃចិត្ត ។

ពាក្យថា កាលមនសិការសេចក្ដីសម្គាល់ថានៅព្រៃ មានសេចក្ដីថា លោកអាចារ្យពោលថា រមែងជាអ្នកដែលគួរនឹងបាន ។ល។ដែល

នឹងរក្សាទុកបាននូវសមាធិដែលបានហើយដូច្នេះ ក៏ព្រោះមានមនសិការថា យើងនឹងនៅដោយវិវេក ឬថា យើងគួរធ្វើកាយវិវេកតាមដែលបានហើយឲ្យជារបស់មានប្រយោជន៍ ដូច្នេះ ។

ឈ្មោះថា រមែងធ្វើចិត្តរបស់អ្នក គឺរបស់ភិក្ខុអ្នកនៅព្រៃឲ្យរាយមាយមិនបាន ក៏ព្រោះការមិនចូលដល់គន្លង ( នៃទ្វារ ) ។ ឈ្មោះថា ជាអ្នកប្រាសចាកភាពភ័យខ្លាច ក៏ព្រោះមានភាពស្និទ្ធស្នាលជាមួយភាពស្ងប់ស្ងាត់ ។ ឈ្មោះថា លះបង់ការជាប់ជំពាក់ក្នុងជីវិតបាន ក៏ព្រោះការធ្វើខ្លួនឲ្យជាអ្នកថ្វាយចំពោះភាពខ្លាចស្លាប់ទៅនៅក្នុងព្រៃដែលមានអន្តរាយច្រើននោះឯង ។ ឈ្មោះថា ត្រេកអរនឹងរសនៃសេចក្តីសុខ ដែលកើតអំពីភាពស្ងប់ស្ងាត់ គឺបានសោយ ព្រោះមិនមានការប្រឡូកប្រឡំដោយពួកមនុស្ស ។

បទថា **អារាធយន្តោ** ប្រែថា ញ៉ាំងឲ្យត្រេកអរ ។ លោកពោលទុក ព្រោះធ្វើទុកក្នុងចិត្តថា ធុតង្គអារញ្ញិកង្គនេះ ហាក់បីដូចជាពាហនៈរបស់ព្រះយោគី ព្រោះភាពដែលវិវេកជាទីតាំងនៃគោលបដិបត្តិតាមដែលទ្រង់អនុសាសន៍ ។

**អវសេស ធុតាយុធោ** មានន័យថា មានធុតធម៌ដ៏សេស ជាអាវុធ ។

ចប់ ពណ៌នាអំពីអារញ្ញិកង្គ

( ចប់ មហាដីកា )

## ៩–រុក្ខមូលិកង្គ

## ការសមាទានរុក្ខមូលិកង្គ

សូម្បីរុក្ខមូលិកង្គ ក៏មានការសមាទានដោយពាក្យទាំងពីរយ៉ាង នេះ ពាក្យណាមួយថា

១–ឆន្នំ បដិក្ខិបាមិ ខ្ញុំព្រះករុណាសូមវៀរចាកទីប្រក់បាំង ។

២–រុក្ខមូលិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទានអង្គ របស់ភិក្ខុ ដែលមានការនៅទៀបគល់ឈើ ជាប្រក្រតី ។

## វិធី (បដិបត្តិ) ក្នុងរុក្ខមូលិកង្គ

ក៏រុក្ខមូលិកភិក្ខុនោះ គប្បីវៀរដើមឈើទាំងនេះចោល គឺដើម ឈើដែលតាំង នៅរវាងព្រំដែន ដើមឈើជាចេតិយ ដើមឈើមានជ័រ ដើមឈើកំពុងមានផ្លែ ដើមឈើកំពុងមានផ្កា ដើមឈើមានសត្វ ប្រចៀវ ដើមឈើមានប្រហោង ដើមឈើដែលនៅកណ្តាលវត្ត ហើយ ចូរយកដើមឈើដែលនៅជាយៗ វត្តចុះ ។

នេះជាវិធី ( បដិបត្តិ ) នៃរុក្ខមូលិកង្គ ។

## ប្រភេទនៃរុក្ខមូលិកង្គ

ពោលដោយប្រភេទ សូម្បីរុក្ខមូលិកភិក្ខុនេះ ក៏មាន ៣ ជំពូក

ក្នុង ៣ ជំពូកនោះ អ្នកកាន់ថ្នាក់ឧក្រិដ្ឋ កាលចង់ដើមឈើហើយ (សម្គាល់ដើមឈើហើយ)នឹងប្រើអ្នកជទៃឲ្យបោសប្រាស(ទីកន្លែង) ឲ្យតាមពេញចិត្តមិនបានទេ ត្រូវប្រើជើងបោសស្លឹកឈើ កម្ទេចកម្ទី ហើយនៅចុះ ។

អ្នកកាន់យ៉ាងកណ្តាល នឹងពឹងអ្នកដែលមកក្នុងទីនោះ ដោយ បៃជន្យឲ្យ ( ជួយ ) បោសសម្អាតឲ្យក៏បាន ។

អ្នកកាន់ថ្នាក់ទាប នឹងហៅអ្នកធ្វើការវត្ត និងសមណុទ្ទេសមក ជួយជម្រះ ( កន្លែង ) ធ្វើឲ្យរាបស្មើ ហើយកៀរខ្សាច់ធ្វើរបងព័ទ្ធជុំវិញ ជាស្រេចហើយ ទើបនៅក៏បាន តែក្នុងថ្ងៃដែលមានការធ្វើមហកម្ម ( ការបូជា ) រុក្ខមូលិកភិក្ខុកុំអង្គុយ នៅក្នុងទីនោះគប្បីអង្គុយក្នុងទីដទៃ ដែលកំបាំង ( មិនសម្តែងខ្លួនព្រោះភាពប្រាថ្នាតិច ) ។

## ការបែកធ្លាយនៃរុក្ខមូលិកង្គ

ក៏ឯធុតង្គនៃរុក្ខមូលិកភិក្ខុទាំង ៣ ជំពូកនេះ រមែងបែកធ្លាយ ក្នុងខណៈដែលលោកសម្រេចការនៅក្នុងទីប្រក់បាំង ។

( ចំណែក ) ព្រះអង្គុត្តរភាណកាចារ្យទាំងឡាយពោលថា ( ធុតង្គនេះបែក ) ក្នុងខណៈដែលលោកកំពុងដឹង ហើយញ៉ាំងអរុណ ឲ្យរះឡើងក្នុងទីប្រក់បាំងនេះ ជាការបែកធ្លាយក្នុងរុក្ខមូលិកង្គនេះ ។

## អានិសង្សនៃរុក្ខមូលិកង្គ

ចំណែកអានិសង្សមានដូចតទៅនេះ គឺ

១-កើតការបដិបត្តិសមគួរដល់អធ្យាស្រ័យឡើងឯងតាមព្រះបាលី ( ប្រាប់អនុសាសន៍ ) ថា **រុក្ខមូលសេនាសនំ និស្សាយ បព្វជ្ជា** ការបព្វជ្ជាអាស្រ័យ គល់ឈើជាទីដេក ទីអង្គុយ ។

២-ប្រើប្រាស់បច្ច័យ តាមដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ជារបស់បន្តិចបន្តួចផង រកបានងាយផង មិនមានទោសផង ។

៣-បាននូវអនិច្ចសញ្ញា ដោយហេតុបានឃើញនូវការប្រែប្រួលនៃស្លឹកឈើរឿយៗ ។

៤-មិនមានសេចក្តីកំណាញ់ក្នុងសេនាសនៈ និងភាពត្រេកអរក្នុងការងារ ( កសាង ) ។

៥-បាននៅជាមួយរុក្ខទេវតាទាំងឡាយ ។

៦-មានភាពប្រព្រឹត្តិសមគួរដល់ធុតធម៌ មានការប្រាថ្នាតិចជាដើម។

## អវសានគាថាក្នុងរុក្ខមូលិកង្គ

ទីលំនៅរបស់ភិក្ខុអ្នកស្ងប់ គឺជាទីដែលព្រះពុទ្ធជាម្ចាស់ដ៏ប្រសើរទ្រង់សរសើរ និងត្រាស់ថា និស្ស័យ ( របស់បព្វជ្ជា ) វត្តស្មើដោយ

គល់ឈើនឹងមានមកពីទីណា ព្រោះថា ភិក្ខុអ្នកមានវត្តល្អ កាលនៅទៀបគល់ឈើដ៏ស្ងាត់ ដែលជាទីនាំចេញនូវអាវាសមច្ឆរិយៈ ជាទីដែលទេវតាបរិបាល ឃើញស្លឹកឈើទាំងឡាយ ( ដែលនៅខ្ចី ) ពណ៌ក្រហម ( ហើយក៏ប្រែជា ) ពណ៌ខៀវ និងពណ៌លឿង ហើយក៏ជ្រុះទៅរមែងជកនូវសេចក្តីសម្គាល់ថា ទៀងចេញបាន ព្រោះហេតុនោះ ភិក្ខុអ្នកមានបញ្ញាឃើញច្បាស់ ទើបមិនគួរមើលងាយគល់ឈើដែលជាទីស្ងាត់ ដែលជាទីនៅរបស់លោកអ្នកត្រេកអរក្នុងភាវនា ដែលរាប់ថា ជាមរតករបស់ព្រះពុទ្ធជាម្ចាស់នោះឡើយ ។

នេះជាពាក្យពណ៌នាការសមាទាន វិធី ( បដិបត្តិ ) ប្រភេទ ការបែកធ្លាយ និងអានិសង្សក្នុងរុក្ខមូលិកង្គនេះ ។

# មហាដីកា

## ពណ៌នារុក្ខមូលិកង្គ

ពាក្យថា ទីប្រក់ប៉ាំង បានដល់ ទីដែលគេប្រើគ្រឿងប្រក់ប៉ាំង មានឥដ្ឋជាដើម ប្រក់ប៉ាំងទុក មានន័យថា ទីស្នាក់អាស្រ័យ ។ ពាក្យថា ដើមឈើមានក្នុងរវាងព្រំដែន បានដល់ ដើមឈើដែលដុះនៅជិតព្រះរាជអាណាចក្រ ខេត្តរបស់ព្រះរាជា ២ ចំណែក ។ ពិតណាស់ ក្នុងស្ថានទីនោះ កងកម្លាំងរបស់ព្រះរាជាទាំងនោះ នឹងចូលទៅធ្វើការច្បាំងគ្នានៅចន្លោះទីនោះៗ សូម្បីពួកចោរដែលជាអ្នកបួនក្នុងរវាងផ្លូវ ក៏ជួបជុំគ្នានៅទីនោះ មិនព្រមឲ្យភិក្ខុបានអង្គុយជាសុខ ។ ពាក្យថា ដើមឈើជាចេតិយ បានដល់ ដើមឈើដែលមនុស្សទាំងឡាយយល់ឃើញគ្រប់គ្នាថា មានទេវតាអាស្រ័យនៅ ទើបជាការដែលមិនស្ងាត់អំពីពពួកមនុស្សទាំងឡាយដែលចូលទៅដើម្បីបូជា ។

ឈ្មោះថា ដើមឈើមានជ័រ បានដល់ ដើមកំញានជាដើម ។

ឈ្មោះថា ដើមឈើមានប្រចៀវ បានដល់ ដើមឈើដែលប្រចៀវចូលទៅសេព ។ ដើមឈើទាំងឡាយ មានដើមឈើដែលមានក្នុងរវាងព្រំដែនជាដើម មានអន្តរាយ និងរកសេចក្តីវិវេកបាន ដោយលំបាក ព្រោះហេតុនោះ ទើបលោកអាចារ្យពោលទុកថា វៀរចាក

ដើមឈើទាំងនោះចេញ ដូច្នេះ ។ ពាក្យថា ស្លឹកឈើដែលធ្លាក់នៅ គឺស្លឹកឈើដែលជ្រុះចាកដើម ។

ឈ្មោះថា ការអន្ទ័យនៅក្នុងទីដែលជាទីកំបាំង ក៏ដើម្បីបិទបាំងភាពជារុក្ខមូលិកភិក្ខុ ។ ការសម្រេចការនៅក្នុងទីប្រក់បាំង រមែងមានដើម្បីប្រយោជន៍ដល់កិច្ចទាំងឡាយ មានការស្តាប់ធម៌ជាដើម ។ ព្រោះហេតុនោះ អាចារ្យបង្រៀន **គម្ពីរអង្គុត្តរនិកាយ** ទើបពោលថា ព្រោះហេតុត្រឹមតែជ្រាបហើយក៏ញុំាងអរុណឲ្យរះឡើងក្នុងទីប្រក់បាំង ដូច្នេះ ពាក្យថា ព្រោះឃើញភាពប្រែប្រួល គឺការរលត់ទៅក្នុងខណៈៗ នៃដើមឈើ ឬស្លឹកឈើទាំងឡាយរឿយៗ ។

ពាក្យថា (មិនមាន) សេចក្តីកំណាញ់ក្នុងសេនាសនៈនិងសេចក្តីត្រេកអរក្នុងការងារ គឺសេចក្តីកំណាញ់ក្នុងទីលំនៅ (អាវាសមច្ឆរិយៈ និងសេចក្តីត្រេកអរ ក្នុងការងារកសាង ) ។

ពាក្យថា ( មានការរស់នៅរួម) ជាមួយទេវតាទាំងឡាយ គឺជាមួយពួករុក្ខទេវតាទាំងឡាយ ។ ពិតណាស់ សូម្បីពួកទេវតាទាំងនោះ កាលអាស្រ័យនៅ ត្រង់វិមានដែលតាំងនៅត្រង់ដើមឈើទាំងឡាយ ក៏ឈ្មោះថា អាស្រ័យនៅត្រង់ដើមឈើទាំងឡាយ ។ សូម្បីរុក្ខមូលិកភិក្ខុនេះ ក៏ឈ្មោះថា នៅរួមគ្នា ( ជាមួយរុក្ខទេវតា ) ត្រង់ដើមឈើទាំងឡាយ ។ ពាក្យថា ទ្រង់សរសើរ គឺទ្រង់សរសើរ ហើយដោយ

ពាក្យថា ជារបស់បន្ទិចបន្តួចផង ដូច្នេះជាដើម និងត្រាស់ហើយ ថា ជានិស្ស័យយ៉ាងនេះថា **រុក្ខមូលសេនាសនំ និស្សាយ បព្វជ្ជា** បព្វជ្ជា អាស្រ័យសេនាសនៈគល់ឈើដូច្នេះ ។ ឈ្មោះថា មានពណ៌ក្រហម ចាស់ក្នុងពេលដែលនៅខ្ចី ។ ឈ្មោះថា មានពណ៌ខៀវ ក្នុងវេលា កណ្ដាលៗ, ឈ្មោះថា មានពណ៌លឿង ក្នុងពេលចាស់ ។ ឈ្មោះថា ធ្លាក់ទៅ ក៏ដោយអំណាចការស្ងួតស្រពោន ។ កាលឃើញនូវដើម និងស្លឹកទាំងឡាយដោយប្រចក្សយ៉ាងនេះ ឈ្មោះថា រមែងបន្ទោបង់ គឺលះបង់និច្ចសញ្ញាបាន, លោកមានតែអនិច្ចសញ្ញាប៉ុណ្ណោះតាំងមាំ ហើយ ។

ព្រោះហេតុដែលការប្រសូតិ ការត្រាស់ដឹង ការប្រកាសធម្មចក្រ និងការបរិនិព្វានរបស់ព្រះសាស្ដា កើតឡើងត្រង់គល់ឈើនោះឯង ដូច្នេះ ទើបលោកពោលថា គល់ឈើជាមរតករបស់ព្រះពុទ្ធជាម្ចាស់ ដូច្នេះ ។

ចប់ ការពណ៌នារុក្ខមូលិកង្គ

( ចប់ មហាដីកា )

## ១០-អព្ភោកាសិកង្គ

## ការសមាទានអព្ភោកាសិកង្គ

សូម្បីអព្ភោកាសិកង្គ ក៏មានការសមាទានដោយពាក្យពីរយ៉ាង នេះ ពាក្យណាមួយក៏បាន

**១-ឆន្នញ្ច រុក្ខមូលញ្ច បដិក្ខិបាមិ** ខ្ញុំព្រះករុណាសូមវៀរចាកទី ប្រក់បាំងផង គល់ឈើផង ។

**២-អព្ភោកាសិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាន អង្គរបស់ ភិក្ខុ ដែលមានការនៅកណ្ដាលវាលជាប្រក្រតី ដូច្នេះ ។

## វិធី (បដិបត្តិ) ក្នុងអព្ភោកាសិកង្គ

ឯការចូលទៅកាន់រោងឧបោសថ ដើម្បីស្ដាប់ធម៌ក្ដី ដើម្បីធ្វើ ឧបោសថក្ដី រមែងគួរដល់អព្ភោកាសិកភិក្ខុនោះ បើកាលលោកចូល ទៅហើយ ភ្លៀងធ្លាក់ចុះមកសោត កាលភ្លៀងកំពុងធ្លាក់ កុំដើម្បីចេញ លុះភ្លៀងរាំងសឹមចេញទៅ **អព្ភោកាសិកភិក្ខុ** នោះចូលទៅកាន់រោង ឆាន់ ឬរោងភ្លើង ធ្វើវត្តក្ដី ( ចូលទៅ ) **អាបុច្ឆា** ( និមន្ត ) ភិក្ខុថេរៈ ដោយភត្តាហារក្នុងរោងឆាន់ក្ដី កាលឲ្យឧទ្ទេស (រៀនយក) ចូលទៅ សូម្បីទីប្រក់បាំងក្ដី ជញ្ជូនគ្រឿងសេនាសនៈក្ដី មានគ្រែ តាំងជាដើម ដែលទុករាយប៉ាយនៅខាងក្រៅចូលទៅទុកនៅខាងក្នុង (ទីប្រក់បាំង)

ក្តី រមែងគួរ ( គ្រប់យ៉ាង ) បើដើរផ្លូវកាន់បរិក្ខាររបស់ភិក្ខុដែលចាស់វស្សាជាងទៅ កាលភ្លៀងធ្លាក់ លោកចូលកាន់សាលាដែលតាំងនៅនាកណ្តាលផ្លូវក៏គួរ បើមិនមានកាន់អ្វីរត់ទៅដោយសង្ឃឹមថានឹងជ្រកក្នុងសាលា រមែងមិនគួរ តែគប្បីដើរដោយប្រក្រតី ចូលទៅឈរនៅរហូតដល់ភ្លៀងរាំង ទើបទៅហោង ។

នេះជាវិធី (បដិបត្តិ) នៃអព្ភោកាសិកភិក្ខុ ន័យសូម្បីរុក្ខមូលិកភិក្ខុ ក៏ដូចន័យនេះ ។

## ប្រភេទនៃអព្ភោកាសិកភិក្ខុ

ពោលដោយប្រភេទ សូម្បីអព្ភោកាសិកភិក្ខុនេះក៏មាន ៣ជំពូកក្នុង ៣ ជំពូកនោះ សម្រាប់អ្នកកាន់ថ្នាក់ឧក្រិដ្ឋ ចូលទៅអាស្រ័យ ( ម្ញប់ ) ដើមឈើ ឬភ្នំ ឬផ្ទះ រមែងមិនគួរ ត្រូវធ្វើចីវរកុដិ ( សន្ទឹងត្រដាងចីវរ ) នៅកណ្តាលវាលចុះ ។

សម្រាប់អ្នកកាន់ថ្នាក់ណ្តាល នឹងចូលទៅអាស្រ័យ ( ម្ញប់ ) ឈើ ភ្នំ និងផ្ទះ ( តែ ) មិនចូលទៅខាងក្នុង ក៏គួរ ( ខាងក្នុងសម្រាប់ដើមឈើ គឺគល់ ( ឬម្ញប់ ), សម្រាប់ភ្នំ គឺឯកទេសនៃភ្នំ ដូចជាញក, សម្រាប់ផ្ទះ គឺសំយាបផ្ទះ ) ។

សម្រាប់អ្នកកាន់ថ្នាក់ទាប សូម្បីញកភ្នំដែលមនុស្សមិនបានប្រក់បាំង ( បន្ថែម ) សូម្បីជម្រកធ្វើអំពីមែកឈើ អំពីសំពត់ សូម្បី

ខ្ទម ( ដែលគេចោល ) ដែលតាំងនៅក្នុងស្រែនោះៗ ដែលអ្នកចាំស្រែជាដើម បោះបង់ចោល រមែងគួរ ( ទាំងអស់ ) ។

## ការបែកធ្លាយក្នុងអព្ភោកាសិកង្គ

ធុតង្គនៃអព្ភោកាសិកភិក្ខុទាំង ៣ពួក រមែងបែកធ្លាយក្នុងខណៈដែលលោកទៅកាន់ទីប្រក់បាំងក្តី គល់ឈើក្តី ដើម្បីជ្រកនៅ ។ចំណែកព្រះអង្គុត្តរភាណកាចារ្យទាំងឡាយពោលថា ( ធុតង្គនេះរមែងបែកធ្លាយ ) ក្នុងខណៈដែលលោកដឹងហើយ ញុំាងអរុណឲ្យរះឡើងក្នុងទីប្រក់បាំងក្តី គល់ឈើក្តីនោះ នេះជាការបែកធ្លាយក្នុងអព្ភោកាសិ-កង្គនេះ ។

## អានិសង្សនៃអព្ភោកាសិកង្គ

ចំណែកអានិសង្សមានដូចតទៅនេះ គឺ

១-កាត់អាវាសបលិពោធបាន ។

២-បន្ទោបង់ថីនមិទ្ធៈបាន ។

៣-មិនមានទីកន្លែងដែលជាប់ជំពាក់ ។

សមដូចពាក្យសរសើរថា ភិក្ខុទាំងឡាយអាស្រ័យនៅមិនជាប់ក្នុងទីកន្លែង ត្រាច់ទៅមិនមានទីជាប់ជំពាក់ ដូចម្រឹគទាំងឡាយ ដូច្នេះ។

៤-ជាភិក្ខុមានទិស ៤ ( ត្រាច់ទៅ ) ។

៥-មានការប្រព្រឹត្តិសមគួរដល់ធុតធម៌ មានការប្រាថ្នាតិចជាដើម ។

## អវសានគាថាក្នុងអព្ភោកាសិកង្គ

ព្រោះហេតុដែលភិក្ខុកាលនៅក្នុងអព្ភោកាស ដែលមិនមែនជាទីលំបាករក មានមណី គឺដួងផ្កាយដេរដាសជាពិតាន មានប្រទីប គឺដួងចន្ទជះរស្មីភ្លឺស្វាង សមគួរដល់ភាវៈនៃអនាគារិយជន (លោក) មានចិត្ត (មិនជាប់ជំពាក់) ដូចជាចិត្តម្រឹគ បន្ទោបង់ថីនមិទ្ធៈបាន អាស្រ័យសេចក្ដីដែលមានភាវនាជាទីត្រេកអរមែងនឹងបានជួបភាពឆ្ងាញ់នៃបវិវេករសមិនយឺតយូរឡើយ ព្រោះហេតុនោះឯង ភិក្ខុអ្នកមានបញ្ញា គប្បីជាអ្នកត្រេកអរក្នុងអព្ភោកាសហោង ។

នេះជាពាក្យពណ៌នាការសមាទាន វិធី (បដិបត្តិ) ប្រភេទ ការបែកធ្លាយ និងអានិសង្សក្នុងអព្ភោកាសិកង្គ ។

# មហាដីកា

## ពណ៌នាអព្ភោកាសិកង្គ

កាលពោលថា ខ្ញុំព្រះករុណាសូមបដិសេធគល់ឈើ ដូច្នេះ ត្រឹមតែប៉ុណ្ណោះ ក៏ជាការដែលមិនបដិសេធទីប្រក់បាំងឡើយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ខ្ញុំព្រះករុណាសូមបដិសេធទីប្រក់បាំង និងគល់ឈើ ដូច្នេះ ។ ពិតណាស់ ការសមាទានធុតង្គនឹងសម្រេចបានដោយការបដិសេធ គឺវៀរចាកដោយប្រការទាំងពួង មិនមែនសម្រេចបានដោយប្រការដទៃឡើយ ។

ពាក្យថា ដើម្បីការស្តាប់ធម៌ មានសេចក្តីថា អព្ភោកាសិកភិក្ខុនេះនោះឯង សូម្បីកាលនឹងពោលធម៌ ដើម្បីការតាមរក្សាចិត្តរបស់អ្នកស្តាប់ទាំងឡាយ នៅក្នុងថ្ងៃឧបោសថជាដើម ត្រូវអ្នកទាំងនោះអារាធនាហើយការដែលនឹងចូលទៅក្នុងទីប្រក់បាំងរមែងគួរតែពេលពោលធម៌ស្រេចហើយ គួរទៅត្រង់ទីវាលប៉ុណ្ណោះ សូម្បីវុឌ្ឍមូលភិក្ខុក៏មានន័យនេះដូចគ្នា ។ ពាក្យថា ដើម្បីប្រយោជន៍ដល់ឧបោសថ គឺដើម្បីឧបោសថកម្ម ។

ពាក្យថា នឹងប្រាប់ឧទ្ទេស គឺនឹងឲ្យឧទ្ទេស ( បង្រៀន ) ដល់ភិក្ខុដទៃ ។

ពាក្យថា ឲ្យប្រាប់ឧទ្ទេស គឺនឹងកាន់យកឧទ្ទេសដោយខ្លួនឯង ( នឹងរៀន ) ។

ពាក្យថា សាលាដែលតាំងនៅក្នុងរវាងផ្លូវ បានដល់ សាលាដែលគប្បីចូលត្រង់ទៅបាន មិនចាំបាច់គេចចុះអំពីផ្លូវ ដូចសាលាក្នុងសីហឡទ្វីប ។ ឈ្មោះថាការដែលនឹងដើរទៅដោយរហ័សរមែងមិនគួរ ព្រោះរកភាពជាសមណសារូបមិនបាន អធិប្បាយថា នឹងមិនមានការបែកធ្លាយនៃធុតង្គ ដរាបទល់គ្នារហូតដល់ភ្លៀងរាំង ហើយទើបទៅ ។ ឈ្មោះថា ខាងក្នុងនៃដើមឈើ បានដល់ គល់ឈើ។

ចំណែកពាក្យថា ទីដែលដូចគ្នានឹងញកនៃភ្នំចាត់ជាចំណែកដែលជាភ្នំ ។

ពាក្យថា បរិវេណដែលមិនត្រូវប្រក់បាំង បានដល់ បរិវេណដែលនៅខាងលើដែលគេមិនបានធ្វើទុកដោយជាជំបូលយ៉ាងសង្ខេប ( យ៉ាងតិចតួច ) ដោយប្រការដែលទឹកភ្លៀងនឹងមិនសាចចូលទៅខាងក្នុង ។ តែប្រសិនបើជាញកភ្នំ ដែលទឹកភ្លៀងសាចចូលទៅខាងក្នុងបាន ក៏ចាត់ជាទីវាលយ៉ាងសង្ខេបបាន ព្រោះហេតុនោះ ការដែលលោកនឹងចូលទៅ ( នៅ ) ក្នុងញកភ្នំនោះរមែងគួរ ។ ពាក្យថា ស៊ុមមែកឈើ បានដល់ស៊ុមដែលគេប្រើមែកឈើទាំងឡាយប្រក់ទុករង្វើលៗ ( មិនជិតល្អ ) ។ ឈ្មោះថា សំពត់បាំង បានដល់ សំពត់ទាំង

គ្រោតគ្រាតទាំងរឹង, អធិប្បាយថា ធុតង្គរមែងបែកធ្លាយក្នុងខណៈដែលចូលទៅ វៀរតែស្ថានទីមានញកភ្នំជាដើម តាមដែលពោលហើយ ។ ពាក្យថា ដឹងហើយ គឺចូលទៅកាន់គល់ឈើ ទីប្រក់ប៉ាំងដើម្បីកិច្ច មានការស្តាប់ធម៌ជាដើម ដោយការអន្ទុយ ដឹងហើយថា អរុណនឹងរះឡើងក្នុងពេលឥឡូវនេះ ដូច្នេះ ។ សេចក្តីមិនអផ្សុកក្នុងការចូលទៅនៅក្នុងទីណាៗ សូម្បីគល់ឈើ រមែងមានបានមួយរំពេច ( តែ ) ក្នុងទីទាំងនោះ គប្បីមានអាវាសបលិពោធ ( សេចក្តីកង្វល់ក្នុងទីលំនៅ ) ដែលនាំឲ្យមានការជាប់ជំពាក់ ចំណែកក្នុងទីវាលមិនមាន ព្រោះហេតុនោះ លោកអាចារ្យទើបពោលអានិសង្ស គឺការកាត់អាវាសបលិពោធបានទុកក្នុងមាតិកានៃ **អព្ភោកាសិកង្គ** នេះប៉ុណ្ណោះ ។

ពាក្យថា មានភាពសមចំពោះព្រះតម្រាស់ត្រាស់សរសើរ គឺមានភាពសមចំពោះព្រះតម្រាស់ដែលត្រាស់សរសើរថាមិនជាប់ក្នុងទីកន្លែងដូច្នេះ ព្រោះភាពមិនមានអាល័យ ។ ពាក្យថា មិនមានការជាប់ជំពាក់ មានសេចក្តីថា ព្រោះមិនមានការហួងហែងក្នុងទីលំនៅ ទើបមិនមានការជាប់ជំពាក់ក្នុងទីលំនៅនោះ ។ឈ្មោះថា ជាអ្នកទៅបានគ្រប់ទិសទាំង ៤ ព្រោះមិនមានសេចក្តីត្រិះរិះកង្វល់ថា ក្នុងទិសនោះមិនមានទីដែលជាលំនៅ ព្រោះដូច្នោះ យើងមិនអាចនឹងទៅក្នុង

ទិសនោះបានដូច្នេះ ។

ពាក្យថា ( មានចិត្ត ) ដូចម្រឹគ គឺមានចិត្តដូចជាចិត្តរបស់ម្រឹគ ព្រោះមិនមាន សេចក្តីហួងហែង ( ក្នុងទីលំនៅ ) ។

បទថា **សិតោ** ប្រែថា អាស្រ័យ ។

បទថា **វិន្ទតិ** ប្រែថា រមែងបាន ។

ចប់ កថាពណ៌នាអព្យាកាសិកន្ត

( ចប់ មហាដីកា )

# ១១-សោសានិកង្គ

## ការសមាទានសោសានិកង្គ

សូម្បី សោសានិកង្គ ក៏មានការសមាទានដោយពាក្យពីរយ៉ាង នេះ ពាក្យណាមួយថា

**១- ន សុសានំ បដិក្ខិបាមិ ខ្ញុំព្រះករុណា សូមវៀរចាកទីដែល មិនមែន ជាព្រៃស្មសាន ។**

**២-សោសានិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាន** អង្គនៃភិក្ខុ ដែលមានការនៅក្នុងព្រៃស្មសាន ជាប្រក្រតីដូច្នេះ ។

## វិធី(បដិបត្តិ)ក្នុងសោសានិកង្គ

ក៏ឯមនុស្សទាំងឡាយ កាលនៅក្នុងស្រុកកំណត់ទីណាមួយទុក ថា ទីនេះជាព្រៃស្មសាន សោសានិកភិក្ខុនោះគប្បីនៅក្នុងទីនោះព្រោះ ថាទីនោះកាលសាកសពនៅមិនទាន់បានដុត ក៏មិនទាន់រាប់ថា ជាព្រៃ ស្មសាន តែថាចាប់ផ្តើមអំពីដុតសពហើយទៅ សូម្បីគេបោះបង់ចោល ១២ ឆ្នាំ ក៏រាប់ថាជាព្រៃស្មសានបាន ក៏ឯសោសានិកអ្នកនៅក្នុងព្រៃ ស្មសាននោះ

១-មិនគួរធ្វើកន្លែងផ្សេងៗ មានខ្ទមដំបូលស្មើសម្រាប់ចង្ក្រម ជាដើម ត្រូវតាំងគ្រែទុករៀបចំទឹកឆាន់ ទឹកប្រើប្រាស់ ហើយប្រកាស

ធម៌ (ក្នុងព្រៃស្មសាននោះ) ព្រោះថា ធុតង្គមាតិកានេះធ្ងន់ ហេតុនោះ សោសានិកភិក្ខុគួរជាអ្នកមិនប្រមាទ ប្រាប់ព្រះសង្ឃត្ថេរ ឬអាជ្ញាធរផ្លូវរាជការឲ្យជ្រាប ដើម្បីការពារអន្តរាយ ដែលកើតឡើង ហើយសឹមទៅ ។

២-កាលចង្ក្រមគប្បីធ្មេ្មៀងមើលជើងថ្កុរផង ។

៣-កាលទៅព្រៃស្មសានវិញ គប្បីចៀសវាងផ្លូវធំ ហើយទៅតាមផ្លូវក្រោចុះ ។

៤-គប្បីកំណត់អារម្មណ៍ឲ្យចាំច្បាស់ក្នុងវេលាថ្ងៃ ដោយការកំណត់ទុកយ៉ាងនោះ វានឹងមិនធ្វើឲ្យខ្លាចសម្រាប់លោកក្នុងពេលយប់ ។

៥-អមនុស្សទាំងឡាយ សូម្បីវានឹងត្រាច់បន្ទឺសំឡេងស្រែកទៅក៏កុំប្រហារ វាដោយវត្ថុអ្វីៗ ឡើយ ។

៦-សោសានិកភិក្ខុនឹងខានទៅព្រៃស្មសានសូម្បីមួយថ្ងៃរមែងមិនគួរ ។

ព្រះអង្គុត្តរភាណកាចារ្យពោលថា ញុំាំងមជ្ឈិមយាមឲ្យអស់ទៅក្នុងព្រៃស្មសាន ហើយត្រឡប់មកវិញក្នុងបច្ឆិមយាមក៏គួរ ។

៧-ចំណីស៊ីចុកដែលអមនុស្សចូលចិត្តដូចជានំរោយល្ង បាយលាយសណ្តែកត្រី សាច់ ទឹកដោះស្រស់ ប្រេង ទឹកអំពៅ សោសានិក

ភិក្ខុមិនគួរបរិភោគឡើយ ។

៨-មិនគួរចូលទៅកាន់ផ្ទះនៃត្រកូលឡើយ ។

នេះជាវិធី ( បដិបត្តិ ) នៃសោសានិកភិក្ខុ ។

## ប្រភេទនៃសោសានិកភិក្ខុ

ពោលដោយប្រភេទ សូម្បីសោសានិកភិក្ខុនេះក៏មាន ៣ ជំពូក ក្នុង ៣ ជំពូកនោះ អ្នកកាន់ថ្នាក់ឧក្រិដ្ឋ គប្បីនៅតែក្នុងព្រៃស្មសាន ដែល ( មានលក្ខណៈ ៣ គឺ ) មានការដុតសាកសពជាប្រចាំ មានសាកសព ( មើល ) មិនដាច់រយៈ និងមានសំឡេងយំជានិច្ច ។

សម្រាប់អ្នកកាន់ថ្នាក់កណ្ដាល ក្នុងព្រៃស្មសាន ដែលមានលក្ខណៈ ១ ក្នុងបណ្ដាលក្ខណៈ ៣ នោះ ក៏បាន ។

សម្រាប់អ្នកកាន់ថ្នាក់ទាប នៅក្នុងព្រៃស្មសាន គ្រាន់តែបានលក្ខណៈព្រៃស្មសាន តាមន័យដែលបានពោលហើយ ក៏បាន ។

## ការបែកធ្លាយនៃសោសានិកង្គ

ក៏ធុតង្គនៃសោសានិកភិក្ខុទាំង ៣ ជំពូកនេះ រមែងបែកធ្លាយព្រោះសម្រេចការនៅក្នុងទីដែលមិនមែនជាព្រៃស្មសាន, ( ចំណែក ) ព្រះអង្គុត្តរភាណកាចារ្យពោលថា (ធុតង្គនេះបែក) ក្នុងថ្ងៃដែលលោកមិនទៅព្រៃស្មសាន ។

នេះជាការបែកធ្លាយក្នុងសោសានិកង្គនេះ ។

## អានិសង្សនៃសោសានិកង្គ

ចំណែកអានិសង្សមានដូចតទៅនេះ

១-បានមរណានុស្សតិ ។

២-នៅដោយភាពមិនប្រមាទជាប្រក្រតី ។

៣-សម្រេចបានអសុភនិមិត្ត ។

៤-បន្ទោបង់កាមរាគៈបាន ។

៥-ឃើញសភាពរបស់រាងកាយរឿយ ៗ ។

៦-មានសេចក្តីសង្វេគខ្លាំង ។

៧-លះបង់នូវសេចក្តីស្រវឹង មានការស្រវឹងក្នុងការមិនមានរោគជាដើម ។

៨-គ្របសង្កត់ការភ័យខ្លាចបាន ។

៩-ជាទីគោរពសរសើរនៃអមនុស្សទាំងឡាយ ។

១០-មានការប្រព្រឹត្តិសមគួរដល់ធុតធម៌ មានការប្រាថ្នាតិចជាដើម ។

## អវសានគាថាក្នុងសោសានិកង្គ

ក៏ព្រោះអំណាចនៃមរណានុស្សតិ ( រឭកដល់សេចក្តីស្លាប់

រឿយៗ ) ទោសដែលនឹងគប្បីកើតឡើង ព្រោះសេចក្ដីប្រមាទទាំងឡាយ រមែងមិនធ្លាក់ត្រូវសោសានិកភិក្ខុ សូម្បីតែដេកលក់ទៅហើយម្យ៉ាងវិញទៀត ចិត្តរបស់លោកឃើញសាកសពច្រើនៗ រមែងមិនធ្លាក់ទៅកាន់អំណាចនៃកាមរាគៈ លោកនឹងកើតសង្វេគធំមិនចូលជិតសេចក្ដីស្រវឹងឡើយទាំងព្យាយាមនឹងរកតែសេចក្ដីរំលត់ ( ទុក្ខ ) ដោយផ្លូវដ៏ប្រពៃ ព្រោះហេតុនោះ ភិក្ខុដែលមានចិត្តបង្អោនទៅកាន់ព្រះនិព្វាន ទើបគួរសេពសោសានិកង្គនេះ ព្រោះជាធុតង្គដែលនាំមកនូវគុណជាអនេកហោង ។

នេះជាពាក្យពណ៌នា ការសមាទាន វិធី ( បដិបត្តិ ) ប្រភេទ ការបែកធ្លាយ និងអានិសង្សក្នុងសោសានិកង្គ ។

# មហាដីកា

## ពណ៌នាសោសានិកង្គ

បទថា នសុសានំ ប្រែថា ទីដទៃក្រៅពីព្រៃស្មសាន ន អក្សរមានអត្ថថា ដទៃ អធិប្បាយថា បានដល់ទីលំនៅដែលវៀរចាកលក្ខណៈនៃព្រៃខ្មោច ។

ពាក្យថា មិនគួរនៅក្នុងស្ថានទីនោះ គឺមិនគួរនៅក្នុងទីដែលគេកំណត់គ្នាថា ជាព្រៃស្មសាន ព្រោះថា លក្ខណៈនៃព្រៃខ្មោចមិនមែនសម្រេចដោយគ្រាន់ត្រឹមតែឈ្មោះនោះទេ ។ ព្រោះហេតុនោះ ទើបលោកពោលថា ន ហិ ដូច្នេះជាដើម ។ តែបើចាប់ផ្ដើមពីកាលដែលដុតហើយ ។ល។ក៏ឈ្មោះថា ជាព្រៃស្មសានហើយ ព្រោះដល់លក្ខណៈជាព្រៃស្មសាន ដោយហោចគ្រាន់តែទីដែលសាកសពដេកនៅ ។ ពិតណាស់ ទីដែលសាកសពដេក លោកហៅថា ព្រៃស្មសាន ។

លោកអាចារ្យដើម្បីសម្ដែងថា ដែលឈ្មោះថា សោសានិកភិក្ខុគប្បីជាអ្នកមានកិច្ចតិច មានការប្រព្រឹត្តិស្រាល ទើបពោលថា ក៏ភិក្ខុកាលនឹងទៅក្នុងព្រៃខ្មោចនោះ ដូច្នេះជាដើម ។ ពាក្យថា ធុន់ គឺរក្សាបានដោយលំបាក ។ ដើម្បីនឹងសម្ដែងភាពជាធុតង្គ ដែលរក្សាបានដោយលំបាកនោះឯង ទើបលោកពោលថា ព្រោះដូច្នោះ ដូច្នេះជា

ដើម ។

ក្នុងពាក្យទាំងនោះពាក្យថា ដើម្បីជាប្រយោជន៍ដល់ការការពារអន្តរាយ ដែលកើតឡើងបាន មានសេចក្តីថា ពួកចោរទាំងឡាយទាំងដែលមិនទាន់បាន ធ្វើកម្ម (គឺការប្លន់) ទាំងដែលបានធ្វើកម្មហើយគិតថា ឈ្មោះថាព្រៃចោលខ្មោច គឺជាទីកំបាំងអំពីភ្នែកមនុស្សទាំងឡាយដូច្នេះ ទើបមកជួបជុំគ្នា កាលពួកចោរឃើញម្ចាស់ទ្រព្យក្នុងទីនោះគេក៏ចោលរបស់របរទុកក្នុងទីជិតភិក្ខុ ហើយគេចទៅ មនុស្សទាំងឡាយ ក៏នឹងចាប់ភិក្ខុ ដោយចោទថា ជាចោរ ហើយវាយបាន ព្រោះដូច្នោះ ទើបគួរប្រាប់ព្រះសង្ឃត្ថេរក្នុងវិហារ ឬអាជ្ញាធរដែនដីរបស់ព្រះរាជាដែលប្រចាំនៅទីនោះ ឲ្យជ្រាបភាពជាសោសានិកភិក្ខុរបស់ខ្លួន ហើយគប្បីជាអ្នកមិនប្រមាទ ដោយប្រការដែលអន្តរាយមានសភាពដូច្នេះ ឬអន្តរាយដទៃ ទៀតនឹងមានមិនបាន ។

លោកអាចារ្យបំណងសេចក្តីថា ក្នុងវេលាណាមិនមានជើងថ្កូរនៅពីមុខភិក្ខុកំពុងចង្ក្រម សូម្បីក្នុងវេលានោះ ដើម្បីនឹងញុំាងភាពសង្វេគឲ្យកើតឡើង លោកក៏គួរដោះចេញនូវអត្តទិដ្ឋិក្នុងទីនោះ ដូច្នេះទើបលោកពោលថា គប្បីធ្មៀងមើលជើងថ្កូរ ដូច្នេះ ។

ឈ្មោះថា គួរទៅតាមផ្លូវក្រៅ ក៏ដើម្បីភាពមិនប្រាកដ (បិទបាំង) ភាព ដែលខ្លួនជាសោសានិកភិក្ខុ ។

ពាក្យថា អារម្មណ៍ មានន័យថា គួរកំណត់អារម្មណ៍ជាស្រេចក្នុងវេលាថ្ងៃ ដោយន័យថា នេះដំបូក នេះដើមឈើ នេះដង្គត់ឈើដូច្នេះជាដើម ក្នុងព្រៃស្មសាននោះ ។

ពាក្យថា វត្ថុដែលគួរខ្លាច បានដល់ អារម្មណ៍មានដំបូកជាដើមដែលធ្វើសេចក្ដីខ្លាចឲ្យកើតឡើង ។ ពួកអមនុស្ស លោកមិនគួរប្រើវត្ថុណាៗ មានដុំដី ដុំថ្មជាដើមប្រទូស្តវា ដោយគិតថា វាមកលេងត្រង់ទីក្បែរៗ ។ លោកហៅនំអំបែងថា នំរោយល្ង ។ បាយលាយសណ្ដែកឈ្មោះថា បាយច្របល់សណ្ដែក ។ ដោយ អាទិ-ស័ព្ទ (ដែលប្រែថាជាដើម ) ។ ក្នុងពាក្យថា គុឡាទិ ( ទឹកអំពៅជាដើម ) លោករួមយកនំដែលមានទឹកអំពៅ និងល្ងជាដើម និងនំបង់ខ្លាញ់ ។

ពាក្យថាមិនគួរចូលទៅកាន់ផ្ទះនៃត្រកូលព្រោះភាពដែលលោកជាប់ ដោយក្លិនសព និងព្រោះមានបិសាចជាប់តាមទៅ ។

ការដុតសពរាល់ៗ ថ្ងៃ ឈ្មោះថា ការដុតសពជាប្រចាំ ។ ការដែលពួកញាតិរបស់អ្នកដែលស្លាប់ ទៅដល់ព្រៃស្មសាននោះហើយស្រែកយំរាល់ៗ ថ្ងៃ ឈ្មោះថា ការយំជាប្រចាំ ។ ពាក្យថា ដោយន័យដែលបានពោលហើយ គឺដោយន័យ ដែលបានពោលហើយថាគឺថា ចាប់ផ្ដើមពីកាលដែលដុតហើយជាដើម ។ អាចារ្យអ្នកបង្រៀនអង្គុត្តរនិកាយពោលថា ( រមែងបែកធ្លាយ ) ក្នុងថ្ងៃដែលមិនទៅ

ព្រៃស្មសាន ដូច្នេះ ព្រោះលោកបំណងយកថា គួរនឹងត្រឡប់វិញក្នុងបច្ឆិមយាម ដូច្នេះ ។

ឈ្មោះថា បានមរណស្សតិ ក៏ព្រោះការឃើញសាកសពក្នុងព្រៃស្មសានអស់កាលជានិច្ច ។ ព្រោះការបានមរណស្សតិនោះឯង ទើបមានភាពជាអ្នកនៅ ដោយសេចក្ដីមិនប្រមាទជាប្រក្រតី ។ ឈ្មោះថា បានសម្រេចអសុភនិមិត្ត ក៏ព្រោះការឃើញសាកសពមនុស្សស្លាប់ដែលគេចោលត្រង់ព្រៃស្មសាននោះ ។

ព្រោះការបានសម្រេចនូវអសុភនិមិត្តនោះឯង ទើបមានការបន្ទោបង់កាមរាគៈបាន ។

ឈ្មោះថា មានការឃើញសភាពរបស់កាយបានរឿយៗ ក៏ព្រោះមាន ការកំណត់នូវភាវៈដែលសរីរៈមិនស្អាត មានក្លិនស្អុយ និងគួរខ្ពើមបានជាច្រើន ។ ព្រោះមានការឃើញសភាពរបស់កាយរឿយៗនោះ និងព្រោះការបានមរណស្សតិ ទើបមានភាពជាអ្នកច្រើនដោយសេចក្ដីសង្វេគ ។ ឈ្មោះថា មានការលះបង់សេចក្ដីស្រវឹង មានការស្រវឹងក្នុងភាពមិនមានរោគ ការស្រវឹងក្នុងភាពជាកំលោះ ជាក្រមុំ និងភាពស្រវឹងក្នុងជីវិតបាន ព្រោះការឃើញមនុស្សឈឺ និងមនុស្សដែលទ្រុឌទ្រោមព្រោះជរា ដែលស្លាប់ទៅហើយក្នុងព្រៃស្មសាននោះឲ្យ ។ ឈ្មោះថា មានសេចក្ដីអត់ធន់ចំពោះសេចក្ដីភ័យខ្លាច ក៏ព្រោះ

គ្របសង្កត់ភ័យទាំងតូច ទាំងធំបាន ។ សេចក្ដីព្យាយាមដោយត្រូវផ្លូវ រមែងកើតឡើងដល់បុគ្គល ដែលមានចិត្តសង្វេគ ព្រោះហេតុនោះ ទើបមានភាពជាអ្នកដែលពួកអមនុស្សគួរគោរពបូជា ។

ពាក្យថា អ្នកស្ងប់ដល់ការដេកលក់ គឺអ្នកដេកលក់ទៅហើយ អធិប្បាយថា ស្ងប់ក្នុងការយល់សប្តិ ។

ចប់ កថាពណ៌នាសោសានិកង្គ

( ចប់ មហាដីកា )

# ១២-យថាសន្ថតិកង្គ

## ការសមាទានយថាសន្ថតិកង្គ

សូម្បីយថាសន្ថតិកង្គ ក៏មានការសមាទានដោយពាក្យពីរយ៉ាង នេះ ពាក្យណាមួយក៏បាន

១-សេនាសនលោលុប្បំ បដិក្ខិបាមិ ខ្ញុំព្រះករុណា សូមវៀរចាក នូវភាពល្មោភ ក្នុងសេនាសនៈ ។

២-យថាសន្ថតិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាន អង្គរបស់ភិក្ខុ អ្នកមានការនៅក្នុងសេនាសនៈ តាមដែលគេចាត់ឲ្យ ជាប្រក្រតីដូច្នេះ ។

## វិធី (បដិបត្តិ) ក្នុងយថាសន្ថតិកង្គ

ឯយថាសន្ថតិកភិក្ខុនោះ សេនាសនៈណាដែលសេនាសន-គាហាបកៈចង្អុលចែកឲ្យថា សេនាសនៈនេះសម្រាប់លោក ក៏គប្បីត្រេកអរដោយសេនាសនៈនោះមិនគប្បី ( ជ្រើសរើស ) ធ្វើភិក្ខុដទៃឲ្យត្រូវផ្លាស់ ( សេនាសនៈ ) នេះជាវិធី ( បដិបត្តិ ) នៃយថាសន្ថតិកភិក្ខុ ។

## ប្រភេទនៃយថាសន្ថតិក

ពោលដោយប្រភេទសូម្បីយថាសន្ថតិកភិក្ខុនេះក៏មាន ៣ជំពូក

ក្នុង ៣ ជំពូកនេះ អ្នកកាន់ថ្នាក់ឧក្រិដ្ឋ រមែងមិនសួរចំពោះសេនាសនៈ ដែលបានសម្រាប់ខ្លួនថា នៅជិត ឬនៅឆ្ងាយឡើយ ឬថា អន្តរាយផ្សេងៗ មានអមនុស្សនិងទីឃជាតិជាដើមរំខាន ឬទេ ថាក្តៅ ឬថាត្រជាក់ ឬទេ ។

អ្នកកាន់ថ្នាក់កណ្តាល សួរបាន តែទៅពិនិត្យមើលមិនបាន ។

អ្នកកាន់ថ្នាក់ទាប ទៅពិនិត្យមើល បើសេនាសនៈដែលចែកឲ្យនោះ មិនត្រូវចិត្ត លោកអាចកាន់យកសេនាសនៈដទៃក៏បាន ។

## ការបែកធ្លាយនៃយថាសន្ថតិកង្គ

ធុតង្គរបស់ យថាសន្ថតិកភិក្ខុ ៣ ជំពូកនេះ រមែងបែកធ្លាយក្នុងកាលដែលល្មមរាប់បានថា សេចក្តីល្មោភក្នុងសេនាសនៈកើតឡើង ។ នេះជាការបែកធ្លាយក្នុងយថាសន្ថតិកង្គនេះ ។

## អានិសង្សនៃយថាសន្ថតិកង្គ

ចំណែកអានិសង្សមានដូចតទៅនេះ

១-បានធ្វើតាមឱវាទដែលទ្រង់ត្រាស់ទុកថា យំ លទ្ធំ តេន តុដ្ឋព្វំ បានវត្ថុណា គប្បីត្រេកអរដោយវត្ថុនោះ ។

២-ផ្តល់ ឬស្វែងរកប្រយោជន៍ឲ្យដល់សព្រហ្មចារី ( មិនរំខានឲ្យផ្លាស់សេនាសនៈ ) ។

៣-លះបង់សេចក្តីកំណាត់ថា អាក្រក់ ឬប្រណីត ។

៤-លះបង់សេចក្តីត្រេកអររីករាយបាន ។

៥-បិទទ្វារនៃសេចក្តីប្រាថ្នាច្រើន ។

៦-មានការប្រព្រឹត្តិសមគួរដល់ធុតធម៌ មានការប្រាថ្នាតិចជាដើម ។

## អវសានគាថាក្នុងយថាសន្ថតិកង្គ

អ្នកប្រព្រឹត្តក្នុងយថាសន្ថតិកៈជាអ្នកត្រេកអរដោយសេនាសនៈដែលខ្លួនបាន ( មិនជ្រើសរើសថា ល្អ-អាក្រក់ ) រមែងដេកជាសុខសូម្បីក្នុងទីដែលក្រាលដោយស្មៅ ក្នុងសេនាសនៈយ៉ាងល្អ ក៏លោកមិនជាប់ចិត្តបានសេនាសនៈដែលអាក្រក់ក៏មិនអន់ចិត្តជួយអនុគ្រោះសព្រហ្មចារីដែលថ្មី ( ឲ្យបានសេនាសនៈនៅ ) ព្រោះហេតុនោះ ភិក្ខុអ្នកមានមេធា គប្បីប្រកបរឿយៗ នូវភាពជាអ្នកត្រេកអរក្នុងសេ-នាសនៈតាមដែលគេចាត់ឲ្យ ដែលជាវត្តជាប្រចាំនៃពួកព្រះអរិយៈជាវត្ត ដែលព្រះមុនីជាម្ចាស់ទ្រង់សរសើរហើយ ។

នេះជាពាក្យពណ៌នាការសមាទាន វិធី ( បដិបត្តិ ) ប្រភេទ ការបែកធ្លាយ និងអានិសង្សក្នុងយថាសន្ថតិកង្គនេះ ។

# មហាដីកា

## ពណ៌នាយថាសន្ថតិកង្គ

ក្នុងការដែលចៅអធិការនៃសេនាសនៈឲ្យកាន់យកសេនាសនៈ ការធ្វើឲ្យអ្នកដទៃផ្លាស់ទៅហើយ ទើបកាន់យកការសាកសួរថា សេនាសនៈនេះល្អ ឬសេនាសនៈនេះមិនល្អ ដូច្នេះ និងការទៅមើល ឈ្មោះថា សេចក្តីល្មោភក្នុងសេនាសនៈ ។ បទថា **គោដ្ឋព្វំ** ប្រែថា គប្បីត្រេកអរ ។

ភិក្ខុអ្នកកាន់ថ្នាក់ឧក្រិដ្ឋ រមែងមិនសួរថា នៅជិត ព្រោះមានទីកន្លែងនៅជាយបំផុតវិហារ ឬថា នៅឆ្ងាយហួសពីស្ថានទីប្រជុំគ្នានៃពពួកមនុស្សជាដើម ព្រោះធុតង្គរបស់លោកមានការសៅហ្មងបាន សូម្បីដោយការសាកសួរ ។

ពាក្យថាដើម្បីនឹងទៅមើលគឺដើម្បីនឹងទៅមើលដោយអំណាចសេចក្តីល្មោភ ។ ពាក្យថា ប្រសិនបើសេនាសនៈនោះ មិនពេញចិត្តដល់លោកគឺប្រសិនបើសេនាសនៈតាមដែលគេឲ្យកាន់យកនោះមិនពេញចិត្ត ព្រោះភាពដែលមិនជាផាសុកដល់លោកដែលជាយថា-សន្ថតិកភិក្ខុ ។ សម្រាប់ភិក្ខុអ្នកកាន់ថ្នាក់ទាប កាលមិនទាន់មានរោគ ការដែលលះបង់សេនាសនៈដែលគេឲ្យកាន់យកចោល ហើយកាន់

យកសេនាសនៈដទៃ ចាត់ជាការល្មោភ ។ សម្រាប់ភិក្ខុអ្នកកាន់ថ្នាក់កណ្តាល ការទៅមើលចាត់ជាការល្មោភ ។ សម្រាប់ភិក្ខុអ្នកកាន់ថ្នាក់ឧក្រិដ្ឋ ការសួរ ចាត់ជាការល្មោភ ។ ក្នុងការដែលភិក្ខុ សូម្បីគ្រប់ពួកឲ្យអ្នកដទៃត្រូវផ្លាស់ទៅ ហើយទើបកាន់យក មិនមានពាក្យដែលត្រូវពោលសោះឡើយ (គឺចាត់ជាភាពល្មោភពិតប្រាកដមិនចាំបាច់ពោលដល់ទេ ) ។

ឈ្មោះថា មានភាពជាអ្នកស្វែងរកប្រយោជន៍ដល់សំលាញ់អ្នកប្រព្រឹត្តព្រហ្មចរិយៈ ក៏ដោយការដែលមិនធ្វើឲ្យសំលាញ់អ្នកប្រព្រឹត្តព្រហ្មចរិយៈ សូម្បីខ្លួន គប្បីបញ្ជាឲ្យផ្លាស់បានត្រូវផ្លាស់ទៅ ។ ដោយភាវៈនោះ ចាត់ថាមានការប្រព្រឹត្តិ សមគួរដល់ករុណាវិហារ ។ ឈ្មោះថា លះសេចក្តីកំណត់ថាអាក្រក់ ថាប្រណីតបាន ព្រោះមិនធ្វើការបែងចែក ថាល្អ ថាមិនល្អ ។ ដោយការលះបង់សេចក្តីកំណត់ថាអាក្រក់ ថាប្រណីត នោះចាត់ថា ជាការប្រព្រឹត្តិសមគួរដល់លក្ខណៈរបស់បុគ្គលមិនញាប់ញ័រ ។

ព្រោះហេតុនោះឯង ទើបមានការលះបង់សេចក្តីត្រេកអរ និងសេចក្តីទាស់ ចិត្តបាន ។ ឈ្មោះថា បិទទ្វារ នៃសេចក្តីប្រាថ្នាច្រើន ក៏ដោយការមិនឲ្យឱកាស ។

ពាក្យថា សេចក្តីត្រេកអរក្នុងសេនាសនៈតាមដែលគេចាត់ចែង

ឲ្យ គឺសេចក្តីត្រេកអរក្រៃលែងក្នុងសេនាសនៈតាមដែលគេឲ្យកាន់យក គឺតាមដែលគេឲ្យ ។

ចប់ ការពណ៌នាយថាសន្ថតិកង្គ

( ចប់ មហាដីកា )

## ១៣–នេសជ្ជិកង្គ

## ការសមាទាននេសជ្ជិកង្គ

សូម្បីនេសជ្ជិកង្គ ក៏មានការសមាទានដោយពាក្យពីរនេះពាក្យណាមួយក៏បាន:

១-សេយ្យំ បដិក្ខិបាមិ ខ្ញុំព្រះករុណា សូមឃាត់នូវឥរិយាបថដេក ។

២-នេសជ្ជិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុ ដែលមានការសម្រេចឥរិយាបថនៅ ដោយការអង្គុយជាប្រក្រតីដូច្នេះ ។

## វិធី (បដិបត្តិ) ក្នុងនេសជ្ជិកង្គ

ក៏ឯនេសជ្ជិកង្គភិក្ខុនោះ ក្នុង ៣ យាមនៃរាត្រី ក្រោកឡើងចង្រ្កមអស់យាម ១ ព្រោះក្នុងឥរិយាបថទាំងឡាយ ការដេកប៉ុណ្ណោះមិនគួរ ។

នេះជាវិធី ( បដិបត្តិ ) នៃនេសជ្ជិកភិក្ខុ ។

## ប្រភេទនៃនេសជ្ជិកភិក្ខុ

ពោលដោយប្រភេទ សូម្បីនេសជ្ជិកភិក្ខុនេះ ក៏មាន ៣ ជំពូក ក្នុង ៣ ជំពូកនោះ សម្រាប់អ្នកកាន់ថ្នាក់ឧក្រិដ្ឋ ទីបង្អែកក្ដី សំពត់សម្រាប់ត្រួបោមក្បាលជង្គង់ក្ដី សំពត់សម្រាប់តោងក្ដី មិនគួរទាំង

អស់ ។

សម្រាប់អ្នកកាន់ថ្នាក់កណ្តាល របស់ ៣ យ៉ាងនោះ យ៉ាងណាមួយក៏ប្រើបាន ។

សម្រាប់អ្នកកាន់ថ្នាក់ទាប សូម្បីភ្នាក់ដៃ សំពត់សម្រាប់ត្របោមក្បាលជង្គង់ សំពត់សម្រាប់តោងខ្នើយ ( សម្រាប់ផ្អែក ) សូម្បីកៅអីដែលប្រកបដោយអង្គ ៥ កៅអីដែលប្រកបដោយអង្គ ៧ ក៏ប្រើបាន ។

កៅអីដែលគេធ្វើមានបង្អែកខ្នង ឈ្មោះថា បញ្ចង្គ, កៅអីដែលគេធ្វើមានបង្អែកខ្នង និងភ្នាក់ដៃទាំងសងខាង ( ឆ្វេង-ស្តាំ ) ឈ្មោះថា សត្តង្គ,បានឮថា មនុស្សទាំងឡាយបានធ្វើកៅអីសត្តង្គនោះ(ប្រគេន) ព្រះតិបិដ្ឋចូឡាភយត្ថេរបាន ជាព្រះអនាគាមី ហើយបរិនិព្វាន ។

## ការបែកធ្លាយនៃនេសជ្ជិកង្គ

ក៏ឯធុតង្គនៃនេសជ្ជិកង្គទាំង ៣ ជំពូកនេះ រមែងបែកធ្លាយក្នុងខណៈល្មមថា ជាការដេកចុះទៅ ។

នេះជាការបែកធ្លាយក្នុងនេសជ្ជិកង្គនេះ ។

## អានិសង្សនៃនេសជ្ជិកង្គ

ចំណែកអានិសង្សមានដូចតទៅនេះ គឺ

១-កាត់គ្រឿងចងចិត្តដែលពោលក្នុងបាលីថាភិក្ខុប្រកបរឿយៗ

នូវសេចក្ដីសុខក្នុងការដេក សុខក្នុងការទម្រេតខ្លួន សុខក្នុងការដេកលក់ ដូច្នេះហៅលបាន ។

២-មានការងាយស្រួលក្នុងការប្រកបកម្មដ្ឋានទាំងពួង ។

៣-មានឥរិយាបថគួរឲ្យជ្រះថ្លា ។

៤-ជាអ្នកសមដែលនឹងធ្វើសេចក្ដីព្យាយាម ។

៥-សម្មាបដិបត្តិចម្រើនឡើងដោយល្អ ។

## អវសានគាថាក្នុងនេសជ្ជិកង្គ

ព្រោះហេតុដែលព្រះយោគីអង្គុយពត់ភ្នែក តាំងកាយឲ្យត្រង់រមែងញាំងហឫទ័យរបស់មារឲ្យញាប់ញ័រ ភិក្ខុអ្នកលះសេចក្ដីសុខក្នុងការដេក សុខក្នុងការលក់ ប្រារព្ធសេចក្ដីព្យាយាម ត្រេកអរក្នុងការអង្គុយ ញាំងព្រៃគឺតបធម៌ឲ្យរុងរឿង រមែងបានបីតិសុខ ដែលប្រាសចាកអាមិស ព្រោះហេតុនោះ ភិក្ខុអ្នកមានបញ្ញាគួរបំពេញឲ្យល្អនូវនេសជ្ជិកង្គហោង ។

នេះជាពាក្យពណ៌នា ការសមាទាន វិធី ( បដិបត្តិ ) ប្រភេទ ការបែកធ្លាយ និងអានិសង្សនៃនេសជ្ជិកង្គ ។

# មហាដីកា

## ពណ៌នានេសជ្ជិកង្គ

បទថា **សេយ្យំ** បានដល់ **សេយ្យ** ដែលជាលក្ខណៈរបស់ឥរិយាបថ ( គឺត្រូវ ប្រែថា ការដេកនោះឯង ព្រោះពាក្យថា **សេយ្យ** ប្រែថា ទីដេកក៏បាន ) ក៏ព្រោះមានការបដិសេធន៍ការដេកនោះៗ ឯងទីដេកទាំងឡាយមានយ៉ាងនេះថា គ្រែ ពូកជាដើម ដែលជាប្រយោជន៍ដល់ការដេកនោះ ក៏មានការត្រូវបដិសេធន៍ផងដែរ ។

ម្យ៉ាងវិញទៀត ការដេកប៉ុណ្ណោះជាវត្ថុដែលត្រូវវៀរក្នុងធុតង្គមាតិកានេះ ព្រោះពាក្យថា **នេសជ្ជិក** ក្នុងទីនេះបំណងយកសេចក្ដីថាបានដល់ អ្នកមានប្រក្រតីបដិសេធការដេក ហើយនៅដោយការអង្គុយនោះឯង ។ ឥរិយាបថក្រៅពីនេះមិនមែនជាវត្ថុដែលត្រូវវៀរទេ ព្រោះលោកមិនបានត្រូវការយ៉ាងនោះនិងព្រោះជាយ៉ាងនោះមិនបាន ។ពិតណាស់ លោកប្រាថ្នាឥរិយាបថដែលជាចំណែកនៃសេចក្ដីខ្ជិលប្រអូសដោយភាពជា វត្ថុដែលត្រូវវៀរចាកក្នុងធុតង្គមាតិកានេះ មិនប្រាថ្នាឥរិយាបថក្រៅពីនេះទេ ហើយនរណាៗ ក៏មិនអាចនឹងធ្វើកាយឲ្យប្រព្រឹត្តទៅយ៉ាងនោះបាន ព្រោះហេតុនោះ ការដេកប៉ុណ្ណោះ ជាវត្ថុដែលត្រូវវៀរក្នុងធុតង្គមាតិកានេះ ។ ព្រោះហេតុនោះ ទើបលោក

អាចារ្យពោលថា **នេសជ្ជិក** ភិក្ខុនោះ ដូច្នេះជាដើម ។ គប្បី ( ក្រោកឡើង ) ចង្ក្រមចុះ មិនគប្បីគិតថា យើងជាភិក្ខុកាន់យកការអង្គុយជាប្រក្រតីដូច្នេះឡើយ ហើយទ្រាំអង្គុយនៅអស់រាត្រី គ្រប់យាមនោះទេ ។

ពិតណាស់ រាងកាយដែលត្រូវឥរិយាបថដទៃអនុគ្រោះ រមែងជារបស់គួរដល់មនសិការ ។

កៅអី ឈ្មោះថា បញ្ចង្គ ដោយអង្គ ៥ ទាំងនេះគឺ ជើងទាំង ៤ បង្អែក ១ ។ អាចារ្យមួយពួកទៀតពោលថា បញ្ចង្គ ដោយមៅគ្រែ ៤ កំណាត់ និងដោយបង្អែក ខ្នង ១ ដូច្នេះ ។ លោកអាចារ្យបំណងនឹងការពារ ការកាន់យកនៃនេសជ្ជិកភិក្ខុ ដោយភ្ជាក់ដៃត្រង់សងខាងទាំង ២ និងត្រង់ខាងខ្នងយ៉ាងសុខដែលថា មិនមានអ្វីប្លែកផ្សេងពីភិក្ខុអ្នកមិនកាន់នេសជ្ជិក ដូច្នេះ ទើបលើកព្រះអភយត្ថេរជាតួយ៉ាងថា ព្រះថេរៈជាព្រះអនាគាមី ហើយបរិនិព្វានទៅដូច្នេះ ។

គប្បីឃើញភាពជាករណសាធនៈ នៃធម៌ដែលកាត់កិលេសជាគ្រឿងជាប់ជំពាក់ថា ឈ្មោះថា **ឧបច្ឆេទនំ** ព្រោះអត្ថថា ជាគ្រឿងកាត់ដូច្នេះចុះ ។ ឈ្មោះថា មានការងាយស្រួលក្នុងការប្រកបរឿយៗ នូវកម្មដ្ឋានទាំងពួង ក៏ព្រោះការអង្គុយជាចំណែកនៃការមិនស្ងួតចិត្ត និងការមិនរាយមាយ ។ ព្រោះហេតុនោះឯង ទើបបានភាពជាអ្នកមានឥរិយាបថគួរឲ្យជ្រះថ្លា ។ ឈ្មោះថា មានភាពស័ក្តិ សមចំពោះការ

ប្រារព្ធសេចក្តីព្យាយាម បានដល់ ភាពជាអ្នកសមគួរដល់ការប្រព្រឹត្តិសេចក្តីព្យាយាមបានជានិច្ចកាល ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា មានការបម្រើនសម្មាបដិបត្តិ ។ បទថា **បណិធាយ** ប្រែថា តាំង ។ បទថា **តន្នុំ** បាន ដល់  កាយកំណាត់លើ ។ បទថា **វិកម្បេតិ** ប្រែថា រមែងញ៉ាំងហឫទ័យរបស់មារឲ្យញាប់ញ័រ អធិប្បាយថា ធ្វើការបញ្ឈប់សេចក្តីត្រូវការ ( របស់មារ ) បាន ។ ពាក្យថា វត្ត ( ក្នុងពាក្យថា **នេសជ្ជិកវត្ត** ) បានដល់ ធុតង្គ ។

ចប់ ការពណ៌នានេសជ្ជិកង្គ

( ចប់ មហាដីកា )

# បកិណ្ណកកថា

## ទាក់ទងជាមួយធុតង្គ

តទៅនេះជាពាក្យពណ៌នាតាមបន្ទាប់នៃគាថានេះគឺ

**កុសលត្តិកតោ ចេវ ។បេ។ វិញ្ញាតព្វោ វិនិច្ឆយោ វិនិច្ឆ័យ... គប្បីជ្រាប...** ដោយកុសលត្តិក ១ ដោយចំណែកសត្វ មាន ធុត សត្វជាដើម ១ ដោយសង្ខេប និងដោយពិស្តារជាដើម ១ ។

## វិនិច្ឆ័យដោយកុសលត្តិកៈ

ក្នុងបទទាំងនោះបទថា ដោយកុសលត្តិក មានសេចក្តីថា ធុតង្គទាំងអស់ជាកុសលក៏មាន ជាអព្យាកតក៏មាន ទាក់ទងដោយអ្នករក្សាដែលជាបុថុជ្ជន ជាព្រះសេក្ខៈ និងព្រះខីណាស្រព ( តែ ) ធុតង្គដែលជាអកុសលមិនមាន ។ចំណែកបុគ្គលណា គប្បីពោលថា ធុតង្គសូម្បីជាអកុសលក៏មាន ដោយព្រះបាលី មានជាអាទិថា ភិក្ខុមានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ ហើយជាអារញ្ញិក ដូច្នេះ, អ្នកនោះគួរត្រូវពោលថា យើងមិនបាននិយាយថា ភិក្ខុមានចិត្តជាអកុសល រមែងមិននៅព្រៃ, ថាការនៅក្នុងព្រៃរបស់ភិក្ខុណាមាននៅ ភិក្ខុនោះឈ្មោះថា **អារញ្ញិក**, ហើយអារញ្ញិកភិក្ខុនោះ គប្បីជាអ្នកមានសេចក្តីប្រាថ្នាលាមកក៏មាន ជាអ្នកប្រាថ្នាតិច ក៏មាន, ក៏ ( ពាក្យនេះ )

បានពោលទុកហើយ ( ក្នុងពេលអធិប្បាយអត្ថនៃពាក្យថា ធុតង្គ ) ថា អង្គទាំងនេះឈ្មោះថា ធុតង្គ ព្រោះជាអង្គនៃភិក្ខុដែលឈ្មោះថា ធុត ហេតុជាអ្នកកម្ចាត់កិលេសបាន ដោយការសមាទាននោះៗ ម្យ៉ាងទៀត ឈ្មោះថា **ធុតង្គ** ព្រោះមានញាណ ដែលបានវោហារថា **ធុត** ហេតុជាគ្រឿងកម្ចាត់កិលេសជាអង្គ ម្យ៉ាងទៀត អង្គទាំងនេះឈ្មោះថា **ធុត** ព្រោះកម្ចាត់ទោសដែលជាសឹកសត្រូវផង ជាអង្គនៃការបដិបត្តិផង សូម្បីព្រោះហេតុនោះ ទើបឈ្មោះថា ធុតង្គ ដូច្នេះ បុគ្គលណាដែលនឹងគប្បីមានធុតង្គទាំងនោះជាអង្គ បានឈ្មោះថាជា ធុត ( អ្នកកម្ចាត់កិលេសបាន)ដោយរកអកុសលមិនមាន,អកុសលដែលនឹងជាហេតុឲ្យធុតង្គ បានឈ្មោះថា ធុតង្គ ព្រោះធ្វើអកុសលឲ្យជាអង្គកម្ចាត់កិលេសណាៗ បានមិនមាន, ទាំង អកុសលនឹងកម្ចាត់បដិបក្ខទោសមានការល្មោភក្នុងចីវរជាដើម ក៏មិនបាន, អង្គនៃការបដិបត្តិក៏មិនបាន ព្រោះហេតុនោះ ពាក្យថា ធុតង្គជាអកុសលមិនមាន នេះទើបជាពាក្យដែលពោលល្អហើយ ។

ចំណែកធុតង្គរបស់ភិក្ខុអង្គណាធុតទៅអំពីកុសលត្តិក ពោលតាម ( សេចក្តីពិតទៅ ) ធុតង្គរបស់ភិក្ខុទាំងនោះមិនមានតែម្តង វត្ថុដែលមិនមាននឹងបានឈ្មោះថា ជាធុតង្គ ព្រោះកម្ចាត់អ្វី សូម្បីការខុសចំពោះព្រះបាលី ( ឲ្យ ) សមាទានធុតគុណទាំងឡាយ ហើយ

ប្រព្រឹត្ត គ្រាន់តែជាការកាន់យករបស់អ្នកទាំងនោះប៉ុណ្ណោះ ព្រោះដូច្នោះ ពាក្យរបស់អ្នកទាំងឡាយនោះ ទើបមិនគួរកាន់យក នេះជាពាក្យពណ៌នាដោយកុសលត្តិកជាលំដាប់ដំបូងសិន ។

## វិនិច្ឆ័យដោយចែកធុតាទិសត្តុ

ក្នុងមាតិកាថា ដោយចែកសត្តុមាន ធុត-សត្តុជាដើមនោះគប្បីជ្រាប **ធុត** គប្បីជ្រាប **ធុតវាទ** គប្បីជ្រាប **ធុតធម្ម** ទាំងឡាយ គប្បីជ្រាបការសេពធុតង្គថា ជាសប្បាយសម្រាប់នរណា ។

## ធុត

ក្នុងបទទាំងនោះបទថា **ធុត** សំដៅយកបុគ្គលអ្នកមានកិលេសកម្ចាត់ហើយ ១ សំដៅយកធម៌ដែលជាគ្រឿងកម្ចាត់កិលេស ១ ។

## ធុតវាទ

ក្នុងបទថា **ធុតវាទ** គប្បីជ្រាបថា បុគ្គលជាធុត តែមិនមែនជាធុតវាទក៏មាន, បុគ្គលមិនជាធុត តែជាធុតវាទក៏មាន, បុគ្គលជាធុតទាំងជាធុតវាទក៏មាន ។

ក្នុងបុគ្គល ៤ ជំពូកនោះ បុគ្គលណាកម្ចាត់កិលេសទាំងឡាយរបស់ខ្លួន ដោយធុតង្គតែមិនដឹកនាំប្រៀនប្រដៅអ្នកដទៃដោយធុតង្គដូចព្រះពាកុលត្ថេរ លោកជាធុត តែមិនជាធុតវាទ ដូចលោកពោល

ទុកថា អ្នកដែលជាធុត តែមិនជាធុតវាទនេះ នោះ គឺព្រះពាកុលៈ ។ ចំណែកបុគ្គលណា មិនកម្ចាត់កិលេសទាំងឡាយរបស់ខ្លួន ដោយធុតង្គ បានតែដឹកនាំប្រៀនប្រដៅអ្នកដទៃៗ ដោយធុតង្គ ដូចព្រះឧបនន្ទត្ថេរ លោកនេះមិនជាធុត តែជាធុតវាទ ដូចលោកពោលទុកថា អ្នកដែលមិនជាធុត តែជាធុតវាទនេះនោះ គឺព្រះឧបនន្ទសាក្យបុត្ត ។ បុគ្គលណាមិនមានទាំងពីរផ្លូវ ដូចជាព្រះលោឡុទាយី បុគ្គលនេះមិនឈ្មោះថា **ធុត** ទាំងធុតវាទ ដូចលោកពោលទុកថា អ្នកដែលមិនមានទាំងធុត ទាំងធុតវាទនេះនោះ គឺព្រះលោឡុទាយី ។

ចំណែកបុគ្គលណាដល់ព្រមទាំង ២ ផ្លូវ ដូចព្រះធម្មសេនាបតី ដែលមានទាំងធុត ទាំងធុតវាទ ដូចលោកពោលទុកថា អ្នកដែលមានទាំងធុត ទាំងធុតវាទនេះ នោះ គឺព្រះសារីបុត្ត ដូច្នេះ ។

## ធុតធម្ម

មាតិកាថា គប្បីជ្រាបធុតធម៌ទាំងឡាយនោះ មានវិនិច្ឆ័យថា ធម៌ ៥ ប្រការ ដែលជាបរិវាររបស់ធុតង្គចេតនាទាំងនេះ គឺ **អប្បិច្ឆតា** ( សេចក្តីប្រាថ្នាតិច ), **សន្តុដ្ឋិតា** ( សេចក្តីសន្តោស ), **សល្លេខតា** ( ការបដិបត្តិជុសខាត់កិលេស ), **បវិវេកតា** ( ការនៅស្ងប់ស្ងាត់ ), **ឥទមត្ថិតា** ( សេចក្តីដឹងថា វត្ថុនេះមានប្រយោជន៍ ) ឈ្មោះថា **ធុតធម្ម**

ដោយព្រះបាលីថា ( ភិក្ខុដែលមានការនៅព្រៃ ជាប្រក្រតី ) ព្រោះអាស្រ័យសេចក្ដីប្រាថ្នាតិច ដូច្នេះជាដើម ។

ក្នុងធម៌ទាំងនោះ **អប្បិច្ឆតា** និង **សន្តុដ្ឋិតា** រាប់ចូលក្នុងអលោភៈ, **សល្លេខតា** និង **បវិវេកតា** រាប់ចូលក្នុងធម៌ទាំង ២ គឺ អលោភៈ និងអមោហៈ, **ឥទមត្ថិតា** បានដល់ បញ្ញានោះឯង ។ ធម៌ទាំង ២ ( គឺ អលោភៈ និងអមោហៈ ) នោះ ភិក្ខុអ្នកប្រព្រឹត្តធុតង្គ រមែងកម្ចាត់សេចក្ដីលោភក្នុងវត្ថុដែលត្រូវហាមទាំងឡាយបាន ដោយអលោភៈ, កម្ចាត់សេចក្ដីវង្វេង ដែលបិទបាំងទោសក្នុងវត្ថុដែលត្រូវហាម ទាំងនោះ នោះឯង បានដោយអមោហៈ ។

ម្យ៉ាងទៀត រមែងកម្ចាត់កាមសុខល្លិកានុយោគ ដែលប្រព្រឹត្តទៅក្នុងការសេពបច្ច័យទាំងឡាយដែលទ្រង់អនុញ្ញាត ចេញបានដោយអលោភៈ, កម្ចាត់អត្តកិលមថានុយោគ ដែលប្រព្រឹត្តទៅក្នុងផ្លូវតឹងតែងហួសប្រមាណនៅក្នុងធុតង្គទាំងឡាយបាន ដោយអមោហៈ, ព្រោះហេតុនោះ ធម៌ ៥ ប្រការនេះ គប្បីជ្រាបថា ជាធុតធម្ម ។

## ធុតង្គ

មាតិកាថា គប្បីជ្រាបធុតង្គទាំងឡាយ មានន័យថា គប្បីជ្រាបធុតង្គ ១៣ គឺបង្សុកូលិកង្គ ។ល។ នេសជ្ជិកង្គ ធុតង្គទាំងនេះបានពោល

ហើយ ទាំងដោយអត្ថ និងដោយបកិណ្ណកៈ មានលក្ខណៈជាដើម ។

## ធុតង្គសេវនា

មាតិកាថា ការសេពធុតង្គជាសប្បាយសម្រាប់អ្នកណានោះ អធិប្បាយថា ការសេពធុតង្គជាសប្បាយសម្រាប់អ្នកជារាគចរិត និង មោហចរិត ព្រោះហេតុអ្វី ព្រោះការសេពធុតង្គជាទុក្ខាបដិបទា (បដិ-បត្តិលំបាក) និងជាសល្លេខវិហារ (ប្រព្រឹត្តយ៉ាងតឹងរឹង) ដែលរាគៈរមែងស្ងប់ ព្រោះអាស្រ័យទុក្ខាបដិបទា, មោហៈ អ្នកដែលមិនប្រមាទរមែងលះបង់បាន ព្រោះអាស្រ័យសល្លេខបដិបត្តិ ។

ម្យ៉ាងទៀត ក្នុងធុតង្គទាំងនេះ ការសេពអារញ្ញិកង្គ និងរុក្ខមូលិ-កង្គជាសប្បាយ សូម្បីទោសចរិត ព្រោះកាលបុគ្គលទោសចរិតនោះ នៅក្នុងទីនោះមិនមានអ្នកណាប៉ះពាល់រំខានក្នុងព្រៃ និងគល់ឈើនោះ សូម្បីទោសៈក៏រមែងស្ងប់ដែរ នេះជាពាក្យពណ៌នាដោយចែកស័ព្ទ មាន ធុត-ស័ព្ទជាដើម ។

## វិនិច្ឆ័យដោយ សង្ខេប និង ពិស្តារ

## ដោយសង្ខេប

មាតិកាថា ដោយសង្ខេប និងដោយពិស្តារនោះ មានវិនិច្ឆ័យថា ក៏ធុតង្គ ទាំងនេះដោយសង្ខេបមាន ៨ យ៉ាង គឺអង្គជាប្រធាន ៣

អង្គដែលមិនលាយឡំគ្នា ៥ ។ ក្នុងអង្គទាំង ៣ នេះ សបទានចារិកង្គ ឯកាសនិកង្គ អព្ភោកាសិកង្គ ជាអង្គប្រធាន ដោយការរក្សាសបទាន-ចារិកង្គ ក៏ត្រូវរក្សាបិណ្ឌបាតិកង្គផងដែរ និងកាលរក្សាឯកាសនិកង្គ សូម្បីបត្តបិណ្ឌិកង្គ និងខលុបច្ឆាភត្តិកង្គ ក៏នឹងជាការដែលត្រូវរក្សាយ៉ាងល្អផងដែរ,កាលរក្សាអព្ភោកាសិកង្គនឹងមានអ្វីឈ្មោះថាត្រូវរក្សារុក្ខមូលិកង្គ និងយថាសន្ថតិកង្គនោះ ដូច្នេះធុតង្គទើបមាន ៨ ប៉ុណ្ណោះ គឺអង្គ ប្រធាន ៣ នេះ និងអង្គមិនលាយឡំគ្នា ៥ នេះ គឺអារញ្ញិកង្គ បង្សុកូលិកង្គ តេចីវរិកង្គ នេសជ្ជិកង្គ សោសានិកង្គ ។

ដោយសង្ខេបម្យ៉ាងទៀត មាន ៤ ដូច្នេះ គឺទាក់ទងដោយចីវរ ២ ទាក់ទង ដោយបិណ្ឌបាត ៥ ទាក់ទងដោយសេនាសនៈ ៥ ទាក់ទង ដោយវីរិយៈ ១, ក្នុង ៤ យ៉ាងនោះ នេសជ្ជិកង ជាអង្គទាក់ទងដោយ វីរិយៈ ក្រៅពីនេះ និយាយច្បាស់ ហើយ ។

ដោយសង្ខេបម្យ៉ាងទៀត ធុតង្គទាំងអស់នោះមាន ២ ដោយទីអាស្រ័យ គឺអាស្រ័យបច្ច័យ ១២ អាស្រ័យវីរិយៈ ១ សូម្បីបាត់ជាអង្គដែលគួរសេពក៏ជា ២ ដូចគ្នា ក៏ភិក្ខុណាសេពធុតង្គ កម្មដ្ឋានចម្រើនឡើង ភិក្ខុនោះក៏គួរសេព កាលភិក្ខុណាសេពហើយ កម្មដ្ឋានវិនាស ភិក្ខុនោះក៏មិនគួរសេព, ម្យ៉ាងទៀត សូម្បីអ្នកសេពក៏ដោយ មិនសេពក៏ដោយ កម្មដ្ឋានក៏គង់ចម្រើនមិនវិនាស កាល (គិត) អនុគ្រោះដល់

ជនជំនាន់ក្រោយក៏គួរសេព, សូម្បីសេពក៏ដោយ មិនសេពក៏ដោយ កម្មដ្ឋានក៏មិនចម្រើន ក៏គួរសេពដូចគ្នា ដើម្បីជាវាសនាតទៅ, ធុតង្គ ចែកជា ២ ក៏បាន ដោយចាត់ជាអង្គដែលគួរសេព និងមិនគួរសេព ដូច្នេះឯង ។

សូម្បីក្នុងអដ្ឋកថាទាំងឡាយ ក៏ពោលសង្ខេបទុកថា ធុតង្គទាំងពួងនោះចែក តែយ៉ាងដោយអំណាចនៃចេតនា ព្រោះចេតនាក្នុងការសមាទានធុតង្គជាចេតនាតែមួយប៉ុណ្ណោះ ដូច្នេះ អាចារ្យខ្លះពោលទុកថា ចេតនាយ៉ាងណា ធុតង្គក៏យ៉ាងនោះ ( ធុតង្គ ក៏គឺចេតនា ) ។

## ដោយពិស្តារ

ចំណែកដោយពិស្តារ ធុតង្គមាន ៤២ គឺសម្រាប់ភិក្ខុ ១៣ សម្រាប់ ភិក្ខុនី ៨ សម្រាប់សាមណេរ ១២ សម្រាប់សិក្ខមានា និងសាមណេរី ៧ សម្រាប់ឧបាសក ឧបាសិកា ២ ក៏បើព្រៃស្មសានបានលក្ខណៈជាអារញ្ញិកង្គនៅក្នុងទីវាលសោត សូម្បីភិក្ខុមួយរូបក៏អាចសេពធុតង្គបានទាំងអស់គ្រប់មាតិកាក្នុងពេលតែ ១, សម្រាប់ភិក្ខុនី អារញ្ញិកង្គ និងខលុបច្ឆាភត្តិកង្គ ទាំងពីរមាតិកានេះទ្រង់ហាមទុកដោយសិក្ខាបទ, អង្គ ៣ គឺអព្ភោកាសិកង្គ រុក្ខមូលិកង្គ សោសានិកង្គនេះ ភិក្ខុនីរក្សាលំបាក ព្រោះការនៅវៀរចាកសព្រហ្មចារី មិនគួរដល់ភិក្ខុនី

ក៏ឯក្នុងទី ដូច្នោះ ស្ត្រីសំឡាញ់ដែលមានធន្ទះស្មើគ្នា រកបានដោយលំបាក បើសិនរកបានវិញ ក៏មិនផុតអំពីការនៅប្រឡូកប្រឡំគ្នា កាលបើដូច្នោះ ភិក្ខុនីកាលបើសេពធុតង្គដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ មិនសម្រេចដល់លោកឡើយ គប្បីជ្រាបថា ព្រោះការដែលមិនអាចសេពយ៉ាងនេះ ធុតង្គសម្រាប់ភិក្ខុនីទាំងឡាយគប្បីដក ៥ ចេញនៅសល់៨ប៉ុណ្ណោះ ។ម្យ៉ាងទៀតបណ្ដាធុតង្គតាមដែលពោលហើយ វៀរតែតេចីវរិកង្គចេញ សល់ ១២ គប្បីជ្រាបថា ជាអង្គសម្រាប់សាមណេរ, ៧ ជាអង្គសម្រាប់សិក្ខមានា និងសាមណេរី, ចំណែកសម្រាប់ឧបាសកឧបាសិកា មានធុតង្គ ២ ព្រោះធុតង្គ គឺឯកាសនិកង្គ បត្តបិណ្ឌិកង្គនេះប៉ុណ្ណោះសមគួរផង អាចសេពបានផង ដូច្នេះដោយពិស្តារមាន ៤២ ដោយប្រការដូច្នេះឯង ។ នេះជាពាក្យពណ៌នាដោយសង្ខេប និងពិស្តារ ។

ឯកថាដោយធុតង្គ ក៏ជាវត្តដែលភិក្ខុគប្បីសមាទានដើម្បីញ៉ាំងគុណទាំងឡាយ មានសេចក្ដីប្រាថ្នាតិច និងសន្ដោសជាដើម ដែលជាគ្រឿងបរិសុទ្ធផូរផង់នៃសីល មានប្រការដូចពោលហើយ ឲ្យដល់ព្រមក្នុង វិសុទ្ធិមគ្គ ដែលទ្រង់សម្ដែងដោយផ្លូវសីល សមាធិ បញ្ញា ដោយព្រះគាថាដែលផ្ដើមឡើងថា **សីលេ បតិដ្ឋាយ នរោ សបញ្ញោ** នេះជាពាក្យដែលពោលហើយដោយកថាមគ្គត្រឹមប៉ុណ្ណោះ ។

# មហាដីកា

## បកិណ្ណកកថាទាក់ទងនឹងធុតង្គ

ធុតង្គទាំងឡាយទាក់ទងដោយអ្នកសមាទានដែលជាព្រះសេក្ខៈ និងបុថុជ្ជន ក៏ជាកុសលទាក់ទងដោយអ្នកសមាទាន ដែលជាព្រះខីណាស្រពក៏ជាអព្យាកតៈ ។

ក្នុងបុគ្គលទាំងនោះ ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយ រមែងរក្សាធុតង្គដើម្បីធ្វើគោលបដិបត្តិឲ្យពេញលេញ, ព្រះខីណាស្រពទាំងឡាយ រមែងរក្សាធុតង្គ ដើម្បីការនៅជាសុខ ។

ពាក្យថា ធុតង្គជាអកុសលក៏មាន មានអធិប្បាយថា ការសេពធុតង្គរមែងមានបានដោយចិត្តជាអកុសល ពាក្យនោះមិនត្រឹមត្រូវ, បព្វជិតមានភាពជាអ្នក នៅព្រៃជាប្រក្រតី ដោយអកុសលចិត្តណា អកុសលចិត្តនោះមិនឈ្មោះថា ធុតង្គឡើយ ។ ព្រោះហេតុអ្វី ព្រោះមិនមានលក្ខណៈ ( នៃធុតង្គ ) ។ ពិតណាស់ ភាវៈនៃបុគ្គលក្តី ញាណក្តី ចេតនាក្តី ដែលឈ្មោះថា ធុតហេតុ ក៏ព្រោះកម្ចាត់នូវកិលេសទាំងឡាយបានជាអង្គ, ភាវៈនោះ រមែងមិនមានក្នុងអកុសលធម៌ទាំងឡាយ ។

ព្រោះដូច្នោះ ដើម្បីសម្តែងសេចក្តីនេះថា ភិក្ខុនឹងឈ្មោះថា ជាអារញ្ញិកជាដើម ដោយហេតុគ្រាន់តែនៅព្រៃជាដើម ក៏ដោយចុះតែថា

មិនមែនមានអគ្គទាំងឡាយ មានអារញ្ញិកជាដើមនោះទេ ដូច្នេះ ទើបលោកអាចារ្យពោលថា យើងមិនសូមពោលថា ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឥមានិ** ប្រែថា ធុតង្គទាំងនេះ ។ ជាពាក្យដែលបានពោលហើយក្នុងការសម្តែងអធិប្បាយអត្ថរបស់ពាក្យខាងដើម អធិប្បាយថា នរណាៗ នឹងឈ្មោះថាជាធុត ដោយន័យថា កម្ចាត់កិលេសទាំងឡាយដោយអកុសលមិនមាន ។ ដែលជាភិក្ខុអ្នកមានអគ្គ គឺការសមាទានទាំងនេះ ។ លោកអាចារ្យសម្តែងថា ធុតង្គដែលជាអកុសលមិនមានទុក សូម្បីដោយអត្ថវិកប្ប ( គោលកំណត់ន័យរបស់ធុតង្គ ) ដំបូងនេះ ។

ពាក្យថា និង (សម្រាប់ការសមាទាន... ធ្វើអកុសលឲ្យជាអគ្គ) អកុសលនឹងកម្ចាត់បាបយ៉ាងណាៗ បានមិនមាន មានន័យថា អកុសលនឹងកម្ចាត់បាបណាៗ បាន មិនមានឡើយ ព្រោះមិនមែនជាធម៌ដែលជាបដិបក្ខគ្នា ។

បទថា **យេសំ** មានន័យថា សម្រាប់ការសមាទានទាំងឡាយគប្បីហៅបានថា **ធុតង្គ** ទាំងនោះ ព្រោះធ្វើអកុសលនោះឲ្យជាអគ្គ ដូចធ្វើញាណឲ្យជាអគ្គ ។ សូម្បីដោយវិកប្បទី ២ នេះ លោកសម្តែងថា ធុតង្គដែលជាអកុសលមិនមាន ។

ពាក្យថា **ទាំងអកុសល** ( នឹងកម្ចាត់បាប ។ល។ ជាដើម ជា

ពាក្យប្រកបសេចក្តីដោយទាក់ទងជាមួយអត្ថវិកប្បទី ៣ ។ ពាក្យថា ព្រោះដូច្នោះជាដើម ជាពាក្យនិយាយបញ្ជាក់ដល់អត្ថន័យដែលបាន ពោលហើយនោះឯង ។

ពាក្យថា ភិក្ខុរូបណា លោកអាចារ្យពោលសំដៅយកភិក្ខុដែល នៅក្នុងអភយគិរីវិហារ ។ ពិតណាស់ ភិក្ខុទាំងនោះពោលថា ឈ្មោះ ថា ធុតង្គ ជាបញ្ញត្តិ ។ លោកអាចារ្យបំណាងសម្តែងថា កាលបើយ៉ាង នោះ សូម្បីអត្ថថា កម្ចាត់កិលេសទាំងឡាយក្តី ភាពជាធម៌ដែលគួរ សមាទានក្តី ក៏គប្បីមានមិនបាន ព្រោះភាពដែលធុតង្គនោះមិនមាន ដោយបរមត្ថ ព្រោះហេតុនោះ ពាក្យរបស់ភិក្ខុដែលនៅក្នុងអភយគិរី វិហារនោះ រមែងខុសជាមួយព្រះបាលី ដូច្នេះទើបលោកពោលថា (សូម្បីភិក្ខុពួកណាមានធុតង្គ) ដែលឈ្មោះថា **ខុសអំពីកុសលត្តិក** ដូច្នេះជាដើម ។

ពាក្យថា ព្រោះហេតុនោះ មានន័យថា ព្រោះហេតុដែលទោស ទាំងនេះ ភិក្ខុលំបាកនឹងការពារបានដោយធម៌ដែលជាចំណែករបស់ បញ្ញត្តិ ព្រោះហេតុនោះ ពាក្យរបស់ភិក្ខុពួកនោះ បណ្ឌិតមិនគួរកាន់ យក មានន័យថា គប្បីកាន់យកធម៌ ដែលជាចំណែកនៃចេតនា ដែល មានន័យដូចបានពោលហើយទាំងនោះ ។ ព្រោះហេតុដែលលោក សង្គ្រោះធុតគុណទាំងនេះ ដោយបទដំបូង និងបទទី៣ ក្នុងកុសលត្តិកៈ

បាន, ដូច្នោះបណ្ឌិតគប្បីសម្ដែងការសង្គ្រោះធុតគុណទាំងនោះ សូម្បីដោយបទទាំងឡាយនៃតិក: និងទុក: ដ៏សេសតាមសមគួរយ៉ាងនេះ គឺធុតគុណ ដែលសម្បយុត្តជាមួយសុខវេទនាក៏មាន ធុតគុណដែលសម្បយុត្តជាមួយអទុក្ខមសុខវេទនាក៏មាន ធុតគុណដែលមានវិបាកធម៌ជាធម្មតាក៏មាន ធុតគុណដែលមិនមានវិបាកធម៌ជាធម្មតាក៏មាន ធុតគុណដែលជាអនុបាទិន្នុបាទានិយធម៌ (មិនបានត្រូវឧបាទានប្រកាន់ខ្ជាប់ដោយភាពជាផលរបស់កម្ម តែជាអារម្មណ៍របស់ឧបាទានបាន) ក៏មានធុតគុណដែលជាអសង្កិលិដ្ឋសង្កិលេសិកធម៌ ( មិនបានត្រូវកិលេសធ្វើឲ្យសៅហ្មង តែជាអារម្មណ៍របស់កិលេសបាន ) ក៏មានជាដើម ។

ព្រះអរហន្តសូម្បីគ្រប់អង្គឈ្មោះថាធុតកិលេសបុគ្គល(បុគ្គលអ្នកកម្ចាត់កិលេសហើយ ) ក៏ពិត តែថា ក្នុងទីនេះ លោកបំណងយកព្រះវីណាស្រេពអ្នកកម្ចាត់កិលេស ដោយមិនមានការសេពធុតង្គជាប្រកផ្លូវ តាំងនៅថាជាធុត កិលេសបុគ្គល បុគ្គលអ្នកកម្ចាត់កិលេសហើយ ។ ព្រះអរិយមគ្គ សូម្បីទាំងអស់ ក៏ដូចយ៉ាងនោះ, ឈ្មោះថាធម៌ជាគ្រឿងកម្ចាត់កិលេសដោយនិប្បរិយាយ (ត្រង់),ដោយពិសេសក៏បានដល់មគ្គជាន់ខ្ពស់ ( អរហត្តមគ្គ ) ។ តែដោយបរិយាយ ( អម ) បានដល់ វិបស្សនាញាណជាដើម ។

ដោយការកំណត់យ៉ាងទាប គប្បីឃើញថា បានដល់ ញាណដែលសម្បយុត្ត ជាមួយចេតនាក្នុងធុតង្គ ។ លោកអាចារ្យ កាលសម្តែងសព្ទថា **ធុត** ទុកយ៉ាងនេះ ហើយបំណងសម្តែងអត្ថន័យក្នុងធុតវាទ-សព្ទ ដែលគប្បីសម្តែងថា ព្រោះហេតុ ដែលសូម្បីបុគ្គលជាធុតវាទក៏មាន ២ ជំពូក ដោយបែកទៅតាមបុគ្គលដែល ឈ្មោះថា ធុត ដូចបុគ្គលឈ្មោះថា **ធុត** សឹងមាន ២ ជំពូក ដោយបែកទៅតាមបុគ្គលដែលឈ្មោះថា **ធុតវាទ** ដូច្នេះ ព្រោះដូច្នោះ ក្នុងអធិការនេះទើបកើតជាពួក ៤ ដោយទាក់ទងជាមួយបុគ្គលដែលជា **ធុត ធុតវាទ** ទាំងនោះ ហើយបុគ្គលដែលបដិសេធ ( គឺមិនជាបុគ្គលទាំងពីរជំពូកនោះ ) ដូច្នេះនោះ ទើបពោលថា បុគ្គល ឈ្មោះថា ធុត ក៏មាន ដូច្នេះជាដើម ។

សព្ទថា **តយិទំ ជានិបាត**, សព្ទថា **តយិទំ** នោះមានអត្ថន័យថា **សោ អយំ** ដូច្នេះ ។ ពាក្យថា ឈ្មោះថា **ធុតធម្ម** មានន័យថា ឈ្មោះថា **ធុតធម្ម** ព្រោះធ្វើ អធិប្បាយថា ជាធម៌ដែលឧបការៈដល់ចេតនាក្នុងធុតង្គ ដែលបានឈ្មោះថា **ធុត** ព្រោះប្រព្រឹត្តទៅដោយអំណាចការកម្ចាត់បាបធម៌ទាំងឡាយ ដែលជាបដិបក្ខចោលបាន ដោយការសេពធុតង្គ ។ ឈ្មោះថា **អប្បិច្ឆតា** សេចក្តីប្រាថ្នាតិច និង **សន្តុដ្ឋិតា** សេចក្តីសន្តោស ដោយសភាវៈក៏បានដល់ អលោភៈ ព្រោះប្រព្រឹត្ត

ទៅ ដោយអាការដែលមិនលោភក្នុងបច្ច័យទាំងឡាយ ដែលមិនទាន់បានទទួល និងដែលបានទទួលហើយ ។ **សល្លេខតា** ការជុសខាត់នូវកិលេស និង **បវិវេកតា** ភាពស្ងប់ស្ងាត់ រួមចូលក្នុងធម៌ ២ យ៉ាងទាំងនេះ គឺអលោភៈ អមោហៈ ព្រោះជាការជុសខាត់ គឺជាការកាត់ផ្តាច់បាន ដែលសង្កិលេសទាំងឡាយ មានសេចក្តីលោភជាដើម ដែលមានការចង់បានក្នុងបច្ច័យជាដើម ជាហេតុ (និង) ព្រោះជាការធ្វើចិត្តឲ្យស្ងប់ចាកភាពប្រឡូកប្រឡំ ដែលមានប្រភេទជាភាពប្រឡូកប្រឡំ ដោយពួកគណៈជាដើម បានដល់ ជាធម៌ដែលឈានចុះក្នុងខាងក្នុងអលោភៈ និងអមោហៈនោះ ទាក់ទិនចូលក្នុងអលោភៈ និងអមោហៈនោះដោយជាការប្រព្រឹត្តិទៅយ៉ាងពិសេសនៃធម៌គឺអលោភៈ និងអមោហៈទាំងពីរនោះ ។

បុគ្គលអ្នកមានប្រយោជន៍ដោយកុសលធម៌ទាំងនេះឈ្មោះថា ឥទមត្ថិ ដែលបានឈ្មោះថា បព្វជិត គួរជាអ្នកតាំងនៅក្នុងធុតង្គទាំងឡាយ មានបង្សុកូលិកង្គជាដើម ព្រោះហេតុនោះ អ្នកសមាទាននឹងរក្សាធុតង្គគុណទាំងឡាយតាម ដែលទ្រង់ប្រៀនប្រដៅទុកដោយញាណណា ញាណនោះ ឈ្មោះថា **ឥទមត្ថិតា** ( ភាវៈនៃបុគ្គលដែលមានប្រយោជន៍ដោយកុសលធម៌ទាំងនេះ) ។ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ឥទមត្ថិតា** បានដល់ ញាណនោះឯង ដូច្នេះ ។

ពាក្យថា ក្នុងវត្ថុទាំងឡាយដែលត្រូវបដិសេធ បានដល់ ក្នុងវត្ថុទាំងឡាយ មានគហបតីចីវរជាដើម ដែលគប្បីបដិសេធដោយធុតង្គទាំងឡាយនោះៗ ។

ពាក្យថា ( កម្ចាត់ ) **លោភៈ** គឺ ( កម្ចាត់ ) តណ្ហា ។ ពាក្យថា ក្នុងវត្ថុទាំងនោះ នោះឯង គឺក្នុងវត្ថុទាំងឡាយដែលត្រូវបដិសេធ ។ ពាក្យថា ដែលបិទបាំងទោស គឺបិទបាំងទោស មានទុក្ខព្រោះការរក្សាការប្រព្រឹត្តិអាស្រ័យអ្នកដទៃ និងចោរភ័យជាដើម ។

ពាក្យថា ( បច្ច័យទាំងឡាយ ) ដែលទ្រង់អនុញ្ញាតទុក គឺបច្ច័យទាំងឡាយ មានកម្រាលរោមសត្វ និងសំពត់ដណ្តប់ជាដើម ដែលមានផស្សៈជាសុខ ដែលព្រះសាស្តាទ្រង់អនុញ្ញាតទុកដោយទាក់ទងជាមួយការប្រើប្រាស់ យ៉ាងប្រាសចាកឆន្ទរាគៈ ។ បទថា **បដិសេវនមុខេន** ប្រែថា ដោយ ( អាស្រ័យ ) ការសេពជាប្រក្រតី មានន័យថា ដោយអាស្រ័យការសេពនោះជាលេស ( ឧបាយ ) ។

បទថា **អតិសល្លេខមុខេន** ប្រែថា ដោយអាស្រ័យការបដិបត្តិដុសខាត់យ៉ាងក្រៃលែងជាប្រក្រតីផង មានន័យថា ដោយទាក់ទិនជាមួយការបដិសេធន៍ទាំងឡាយ សូម្បីដែលសមគួរ ( សេពបាន ) នៃភិក្ខុអ្នកកាន់ថ្នាក់ឧក្រិដ្ឋ ។

រាគៈ មានការធ្វើដែលស្រណុកសុខស្រួលជាទីពឹងអាស្រ័យ

ទើបមិនបានការ តាំងមាំក្នុងគោលបដិបត្តិដោយលំបាក ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ក៏ព្រោះអាស្រ័យទុក្ខាបដិបទា រាគៈទើបស្ងប់បានដូច្នេះ ។

ដែលបានឈ្មោះថា **សល្លេខធម៌** ( ធម៌ជុសខាត់កិលេស ) រមែងមានដល់បុគ្គលអ្នកមានសម្បជញ្ញៈ កាលមានសម្បជញ្ញៈ មោហៈក៏មិនអាចតាំងនៅបាននោះឡើយ ព្រោះមានការមិនប្រមាទជាប្រក្រតី ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា សម្រាប់បុគ្គលដែលមិនប្រមាទ ព្រោះអាស្រ័យសល្លេខនោះ មោហៈទើបត្រូវលះបង់ទៅដូច្នេះ ។ បទថា **ឯត្ថ** ប្រែថា ក្នុងបណ្ដាធុតង្គទាំងនេះ ។

បទថា **តត្ថ** គឺទីព្រៃ ឬគល់ឈើ ។ បទថា **សីសង្គានិ** ប្រែថា អង្គដែលជាប្រធានមានន័យថា បានដល់អង្គដែលប្រសើរបំផុតហេតុព្រោះរួមយកអង្គ សូម្បីដទៃៗ ប្រការខ្លះចូលគ្នាបាន ដោយមិនមានប្រការដែលជំទាស់គ្នា និងដោយភាវៈដែលធ្វើបានងាយ ។ ពាក្យថា អង្គដែលប្រកបគ្នាមិនបាន គឺអង្គដែលវៀរ ចាកការលាយឡំគ្នាបានជាមួយអង្គណាៗ ជាការពោលបានថា បានដ់ លអង្គដែលចែកជាអង្គតែមួយនោះឯង ។ ឈ្មោះថា កម្មដ្ឋានរមែងចម្រើនឡើង អធិប្បាយថា កាលបុគ្គលរាគចរិត មោហចរិត សូម្បីជាទោសចរិត សេពធុតង្គប្រការខ្លះ កម្មដ្ឋានរមែងចម្រើនឡើង ។

កម្មដ្ឋាន ឈ្មោះថា វិនាសទៅសម្រាប់ភិក្ខុអ្នកអត់ធន់មិនបាន នូវការបដិបត្តិសៅហ្មង ព្រោះភាពនៃខ្លួនជាមនុស្សស្រុខមាលជាតិ អធិប្បាយថា សម្រាប់ភិក្ខុអ្នកមានជាតិជាមហាបុរស កម្មដ្ឋានឈ្មោះថា រមែងចម្រើនតែម្យ៉ាង ។

កម្មដ្ឋាន ឈ្មោះថាមិនចម្រើនឡើង ក៏សម្រាប់ភិក្ខុអ្នកប្រាសចាកឧបនិស្ស័យ ។

ឈ្មោះថា មែនពិត ធុតង្គមានមួយប៉ុណ្ណោះ ក៏ព្រោះមានភាវៈជាចេតនា ដូចជាមានតែមួយ ព្រោះអត្ថថា ជាគ្រឿងកម្ចាត់កិលេស ។ ព្រោះហេតុនោះ ទើបលោកពោលថា គឺសមាទានចេតនាដូច្នេះ ។

លោកអាចារ្យកាលពោលថា ធុតង្គទាំងឡាយចាត់ថាមាន ៤២ ដោយទាក់ទិនជាមួយបុគ្គលទាំងឡាយ ដែលសមាទានរក្សាធុតង្គទាំង ១៣ ដូច្នេះហើយ បំណងនឹងសម្ដែងថា ភិក្ខុទាំងឡាយមានការរក្សាធុតង្គទាំង ១៣ បាន ព្រមគ្នាតែម្ដង ទើបពោលថា ក៏ប្រសិនបើ ដូច្នេះជាដើម ។ ក្នុងធុតង្គទាំងនោះ លោកពោលថា ភិក្ខុ ( សូម្បីមួយរូប ) រមែងអាចនឹងសេពធុតង្គទាំងអស់បានក្នុងគ្រាមួយ ជាមួយគ្នា ដូច្នេះ គប្បីមានពាក្យសួរថា កាលភិក្ខុនៅក្នុងទីវាល នឹងមានរុក្ខមូលិកង្គបានយ៉ាងណា ?

គប្បីមានពាក្យឆ្លើយថា អំពីពាក្យសមាទានដែលថា ខ្ញុំម្ចាស់

សូមបដិសេធទីប្រក់បាំង, ខ្ញុំម្ចាស់សូមសមាទានអង្គ នៃភិក្ខុអ្នកនៅគល់ឈើជាប្រក្រតី ដូច្នេះ ក៏គប្បីឃើញបានថា ធុតង្គ (រុក្ខមូលិកង្គ) រមែងបែកធ្លាយបាន ព្រោះហេតុ គ្រាន់តែថា ញ៉ាំងអរុណឲ្យរះឡើងក្នុងទីប្រក់បាំងមិនមែនក្នុងទីកណ្ដាលវាលព្រោះដូច្នោះសូម្បីរុក្ខមូលិ-កង្គនោះ ក៏រកប្រការខូចខាតមិនបានឡើយ ( សូម្បីកាលនៅក្នុងទីវាល ) ព្រោះមិនមានហេតុនៃការបែកធ្លាយ ។

**យថាសន្ថតិកង្គ** ក៏រកប្រការខូចខាតមិនបានយ៉ាងនោះដូចគ្នា ព្រោះមិនមានសេចក្ដីល្មោភក្នុងសេនាសនៈ ។

( សម្រាប់ភិក្ខុនី ) **អារញ្ញិកង្គ** ទ្រង់ហាមទុកដោយសិក្ខាបទប្រការ ដែលពោលដោយការនៅផ្លូវឆ្ងាយចាកពួកគណៈ, ខលុបច្ឆា-ភត្តិកង្គ ក៏រមែងថយចុះទៅដោយអនតិរិត្តភោជនសិក្ខាបទ ការដែលភិក្ខុនីនឹងធ្វើភោជនឲ្យជាសំណល់ ហើយឆាន់រមែងមិនបាន ។ ក៏ការសមាទានធុតង្គ រមែងមាន ដើម្បីលះបង់ភាពល្មោភក្នុងវត្ថុដែលជាកប្បិយៈ ( ត្រឹមត្រូវតាមពុទ្ធានុញ្ញាត ), មិនមែនក្នុងវត្ថុដែល ជាអក-ប្បិយៈ (មិនត្រឹមត្រូវតាមពុទ្ធានុញ្ញាត) ទេ, លោកធ្វើអធិប្បាយទុកថា ព្រោះត្រូវហាមទុកដោយសិក្ខាបទនោះឯង ។ ទើបមានធុតង្គ ៨ប៉ុណ្ណោះ សំពត់ទាំង ៥ ព្រមទាំងសំពត់ក្រវាត់ទ្រូងជាដើម របស់ភិក្ខុនីក៏ដល់នូវការរាប់ថា ជា **តិចីវរ** ( ចីវរ ៣ ផ្ទាំង ) នោះឯង ។ ពាក្យថា

(ក្នុងធុតង្គទាំងឡាយ) តាមដែលពោលហើយ គឺក្នុងធុតង្គ ១៣ប្រការ ដែលពោលទុកសម្រាប់ភិក្ខុទាំងឡាយ វៀរតែតិចីវរិកង្គចេញដ៏សេស ១២ មានដល់សាមណេរទាំងឡាយ ព្រោះមិនមានវិន័យកម្ម ខ.អធិ-ដ្ឋានចីវរ ៣ ផ្ទាំង ។ ពាក្យថា ៧ ខ មានន័យថា ក្នុងធុតង្គ ៨ ខ ដែលពោលទុកសម្រាប់ភិក្ខុនីថយចុះទៅ ១ ខ ក៏សល់ ៧ ខ ព្រោះមិនមានវិន័យកម្ម ខ.អធិដ្ឋានចីវរ ៣ ចីវរ ៣ ផ្ទាំង ។ លោកពោលថា ៧ ខ មានដល់សិក្ខមានាទាំងឡាយ និងសាមណេរីដូច្នេះ, ព្រោះធ្វើពាក្យថា វៀរលែងតេចីវរិកង្គចេញ ដូច្នេះ នេះឲ្យជាប់តាមទៅនោះឯង ។ ពាក្យថា ដែលសមគួរ បានដល់ ដែលសមគួរដល់ភាព ជាឧបាសក ឧបាសិកា នោះឯង ។

### បរិច្ឆេទទី ២

### ឈ្មោះ ធុតង្គនិទ្ទេស ក្នុងបករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

ខ្ញុំម្ចាស់បានធ្វើដើម្បីជាប្រយោជន៍ដល់បាមោជ្ជនៃសាធុជន ដូច្នេះឯង

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៤

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយធំសុផាត

# ឈ្មោះសប្បុរសប្រគេនសម្ភារៈ មានកុំព្យូទ័រជាដើម ក្នុងកិច្ចការទោរជាធម្មទាន

✵ឧបាសិកា ហម យិម

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក បួ ស៊ីផូ ឧបាសិកា ថែ ស៊ីវន ព្រមទាំងបុត្រ

ឧបាសិកា បួ ចន្ថា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា បួ ដាវី កញ្ញា អ៊ឹង មុយហៀក

✵លោកម្ចាស់ សោម ហួន

លោកគ្រូធម្មាចារ្យ អឿ សៅ ( ទក្ខប្បញ្ញោ )

ឧបាសក ប៊ូ ហោនាង ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យឹម សំណាង ឧបាសិកា យឹម ច័ន្ទបូ(LAURA) +បុត្រធីតា

ឧបាសិកា លីប៉ុលីន ស៊ីមប៊ូ កូនក្មួយ ប៊ុន ឡុង,សេង ឈិនដានេត

លោកអាចារ្យ ផាត សារឿយ ឧបាសិកា វ៉ាត់ អម +បុត្រធីតា

ឧបាសក សៅ ហ៊ិន ឧបាសិកា មាស មូនីកា +បុត្រធីតា

ឧបាសក សួស ចាន់ធី ឧបាសិកា ឡុង សេង +បុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ចាន់ កាន់ជួន +បុត្រធីតា

ឧបាសក ម៉ៅ ផុន+សាបូរ៉ាក់ សុខ( SABOREAK SOK )

ឧបាសក យក់ ស៊ីមូរ៉ា ឧបាសិកា តាន់ វ៉ាណា

ឧបាសក អ៊ឹង រិទ្ធី ឧបាសិកា ជូធារី

ឧបាសក មាស សារ៉េត

ឧបាសក លឹម ស៊ាង

ឧបាសក ឈុន គឹមអេង

❋ឧបាសក ឈុំ គីម គឹមហោ ឧបាសិកា គួ ប៊ុនគាង

ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ

ឧបាសក សារុន សេងហួរ ឧបាសិកា ឈុំ សុរីណែត

ឧបាសក ឈុំ សុរិណា (ហៅប៊ុន ឃីម) ឧបាសិកា ណៃ គឹមហុង

ឧបាសក ឈុំ សុបូរី ឧបាសិកា កើត កុលាប

❋ឧបាសិកា ច័ន្ទ បុប្ផាណា

ឧបាសក ស្ដួន សុធីរ

ឧបាសិកា ស្ដួន កល្យាណ

ឧបាសិកា ស្ដួន ចរណៃ

ឧបាសិកា ស្ដួន កញ្ញារ័ត្ន

❋ឧបាសិកា ម៉ក់ នាង ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមថៃ និងភរិយា ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមលន់ និងភរិយា ព្រមទាំងកូនចៅ

ឧបាសិកា តាំង លាងនិម និងស្វាមី ព្រមទាំងកូនចៅ

❋ពុទ្ធសាសនបណ្ឌិត្យ អ្នកគ្រូ ម៉ម សុខហេង+ពុទ្ធបរិស័ទ+សៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន
ឧបាសិកា នួង ឈុំ សោភ័ណ រស្មី
ឧបាសក ជោគ ឌី ឧបាសិកា ដុះ ចំណាន
ឧបាសិកា វិញ ពូន

❋ឧបាសក ឡាំ ធៀន ឧបាសិកា សឺន ចន្ថា
ឧបាសក លឹម សេងយូ ឧបាសិកា ឡាំ ចាន់សុភី
ឧបាសក ឡាំ ចាន់ណា ឧបាសិកា ទុច ចាន់សាក់គ្រីយ៉ា
ឧបាសក ឡាំ ដារណ្ណ ឧបាសិកា ឡាំ ចាន់រ៉ាវី

❋ឧបាសក ជុំ លាង ឧបាសិកា ចៀម អ៊ួន ព្រមទាំងបុត្រ ញោម ឥម្ទុន្នីនិងជូ ញោម ហាន ញោម រ៉ែន ញោម ភ័ណ្ឌ ញោម សុមនា ញោម ជោត ញោម មាស សុភា ញោម ឡៃ លី កញ្ញា ញោម ឆាង ញោម ជីង ឡេង ញោម អៀម ញោម ភួង ញោម អុំភា ញោម សុភា ញោម វល័ក្ខ ញោម ធាលី លីណា ញោម ថាក ញោម ផារិន ញោម ឈឿន ញោម ឡាង ញោម ស៊ិន ញោម ភាព សារឿន ញោម ហ៊ន ញោម ប៊ូ សៀកលីវ ញោម យក់ រ៉ាន់ថា ។

❋ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណ ឧបាសក អ៊ុន សេរី លោក ដែង រស្មី និងអ្នកស្រី ដុង កុយយ៉ា ព្រមទាំងបុត្រ

❋ឧបាសក អ៊ីង ហ្គេចឡេង ឧបាសិកា តាំង ប៉ោជីង ព្រមទាំងបុត្រ

លោក ផៃ ហេង អ្នកស្រី អ៊ឹង ស៊ីវគៀង ព្រមទាំងបុត្រ

លោក ភួ ពុយ អ្នកស្រី អ៊ឹង ណាងពិន ព្រមទាំងបុត្រ

លោក អ៊ឹង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ

លោក ប៊ុ ទី អ្នកស្រី តាំង ប៉េគិម ព្រមទាំងបុត្រ

ឧបាសិកា ជា នាង និងស្វាមី ព្រមទាំងបុត្រ

✵ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ

ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

✵ឧបាសិកា សាម៉ុល គឹមធន និងអ្នកម្តាយ

ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ

លោក សេង យុវនាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុភនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អៀន ភី + អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ

ញោម ហ៊ឺ ជាង + ជាមុយហាង + គុយ លឹម + សេង មុយនី

ញោម ចៅ ជីវ ស៊ុយលៀប+ប៉ៃ អេង+គឹម ធី+ខៀវ វ៉ន+ គឹម

ញោម នឿង+យាយ ធឹង+គួង ភាង+សេីន គា+សឿង+គឹម អាង

ញោម សេង ឆេង+ផាន់ វ៉ាន់+យាយ រុ+ឡាំម៉ាលី+ជាន សុផាត

យាយ ម៉ៅ + ពៅ + ឈួន+ ក. កាក់ខ្សែន+ ហ៊ីង+ ថៃ ង៉ា+ រី រុត្ន
ញោមអ្នកគ្រូ វ៉ាន់ + យុវសិស្ស អ៊ុំ រតនា + សាមណេរ អ៊ុំ វីរៈ
ញោមថៃ ង៉ាថ្មគោល+អ្នកស្រី លេង យ៉ុង+តី លី+នាង ឈៀត
ញោម ហ៊ីង+នាង មៀន+អូនប៉ុច+ ឡាត វ៉ាន់យិន+ ម៉ម សុខហេង
ញោម គឹម ឡេង+ តាំង វេន+ យុន+ យាយ ធុច + យាយ យន
ញោម ហ៊ន ស៊ម ញោម អឿន កី+វ៉ាន់ ស៊ុនឡាយ+ផល្លី+សវ៉ាមី
ញោម ឡុង សាវី+ជា សុខហ៊ាង+គុយ លីម+សេង ទូច+ស៊ីវ ទី
ញោម ណោ ហេ្គចណៃ+វ៉ាន់ សុផានី+សា វឿន+សំ គី+ចាន់ ណាក់
ញោម ធាក់+យឿត និងស្វាមី+ហួត អេង+អាវ សុវណ្ណី+ណា ស៊ី
ញោម យាយ នៅ+ឈុន គាវ+ យាយ ឌី+ សំ វ៉ាន់នី+ គឹម អ៊ី
ញោម អៀប សានួន+ យាយ ហឿន+យាយ ឡាំ+កេន សេងមុំ
ស ខាន់ថង+ស៊ី ណាត+យឿន+ចាន់ នី+ផន សារ៉ែន+កោ ហុង ។

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

លោកម្ចាស់ សោម ហួន
លោកគ្រូធម្មបណ្ឌិត ( ទក្ខប្បញ្ញោ ) អឿ សៅ
ឧបាសិកា ធឹក ស្រ៊ន ព្រមទាំងកូនប្រុស អ៊ឹង រិទ្ធី និងភរិយា
ឧបាសក ប៊ូហោ នាង ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យេម សំណាង ឧបាសិកា យេម ឡូរ៉ា ព្រមទាំងបុត្រ
ឧបាសក សៅ ហ៊ាន ឧបាសិកា មាស ម៉ូនីកា ព្រមទាំងបុត្រ
ឧបាសក ឈៀង សារឿន ឧបាសិកា ឈុំ ធដា ព្រមទាំងបុត្រធីតា
ឧបាសក ម៉ៅ វង្ស ឧបាសិកា ឆាន់ កាន់ជួង ព្រមទាំងបុត្រ
ឧបាសក និន ហាក់ ឧបាសិកា លុយ ចាន់ថន ព្រមទាំងបុត្រ
ឧបាសិកា ម៉ី ចាន់រ៉ាវី ព្រមទាំងបុត្រធីតា
ឧបាសិកា យ៉ក់ ស៊ុម៉ូរ៉ា ព្រមទាំងបុត្រ
ឧបាសិកា វ៉ាន់ចាន់ ព្រមទាំងបុត្រធីតា
ឧបាសិកា ខៀវ ណាត ព្រមទាំងបុត្រធីតា

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឆាយ អ៊ុីវស៊ាង ឧបាសិកា ហុង គឹមសែ កូន+ចៅ
ឧបាសិកា យូ ស៊ាងនទួលី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅអូស្ត្រាលីមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ប៊ុន ហេង ឧបាសិកា ជុំ សុខុម
ឧបាសិកា ហេង ស្រីជា ឧបាសិកា ហេង ស្រីចន្ទ
ឧបាសិកា ហេង គន្ធា ឧបាសក ហេង សុកត្រ័

# នាមពុទ្ធបរិស័ទនៅខេត្តបាត់ដំបងមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឈុំ គឹមហោ ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ

ឧបាសក សោម សាខន ឧបាសិកា ឈុំ គឹមហួយ ព្រមទាំងកូន

ឧបាសក អ៊ឹង ហ៊ិចឡេង ឧបាសិកា តាំង ប៉េងជីង ព្រមទាំងកូនចៅ

ឧបាសក វៀម ឈឹន ឧបាសិកា ប៊ូ ម៉ុន ព្រមទាំងកូនចៅ

ឧបាសក ញ៉ែម មឿន ឧបាសិកា វៀម ថុល ព្រមទាំងកូនចៅ

ឧបាសក អ៊ុង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក នាង ប៉ា ឧបាសិកា តែម ធារីម ព្រមទាំងកូនចៅ

ឧបាសក សៅ ស៊ុន្ទូរា ឧបាសិកា ប៊ុន មុំ ព្រមទាំងកូនចៅ

ឧបាសក ណូ ស្វេង ឧបាសិកា សោម គឹមលួន ព្រមទាំងកូនចៅ

ឧបាសិកា ងិន យ៉ុន ឧបាសិកា សួស សុខា ព្រមទាំងកូនចៅ

ឧបាសិកា សោម គឹមលៀម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា គឹម ធរី និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ទាវ គឹមយក់ ឧបាសិកា អ៊ឹម គឹមជីវ

ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ឡាំ ម៉ាលី

ឧបាសិកា ហួត អេង ឧបាសិកា ឡោ សាយហ៊ិច

ឧបាសិកា ង៉ែត យូអេង ព្រមទាំងកូនក្មួយ

ឧបាសិកា ហោ ភាព ព្រមទាំងកូនក្មួយ

ឧបាសិកា អ៊ុក នៅ ព្រមទាំងបុត្រ

ឧបាសិកា សៀង ព្រមទាំងបុត្រ

## នាមពុទ្ធបរិស័ទនៅស្ទឹងមានជ័យភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសិកា ឆេង ស៊ីម ព្រមទាំងបុត្រ ធីតា និងចៅ

លោក លី ហុង អ្នកស្រី ផាណារី ព្រមទាំងបុត្រ ធីតា

លោក ផូ ចាន់ថន អ្នកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា

លោក លីម ចាន់ឌី អ្នកស្រី ទេព ចិន្តា ព្រមទាំងបុត្រ ធីតា

កញ្ញា ហុង លីដា

លោក ហុង សុវណ្ណតារា អ្នកស្រី លីម ចាន់មុនីរ័ត្ន ព្រមទាំងបុត្រ

ឧបាសក ហុង សុវណ្ណារិទ្ធ

ឧបាសក ហុង សុវណ្ណារ៉េត

លោក ហុង ប៊ុនឡុង

ឧបាសក ហ៊ុន ហេងគង់ ឧបាសិកា ទូច សារុន ព្រមទាំងកូនចៅ

ឧបាសិកា ធុយ ឈីវអូន ព្រមទាំងកូនចៅ

ឧបាសក យ៉ែម យ៉ន ឧបាសិកា យ៉ង់ ទូច ព្រមទាំងកូនចៅ

ឧបាសក មិន ម៉ាង ឧបាសិកា ឈិន គីមហ៊ាន ព្រមទាំងកូនចៅ

ឧបាសិកា ជា សុផល ព្រមទាំងកូនចៅ

ឧបាសិកា មៀច យ៉ន ព្រមទាំងកូនចៅ

ឧបាសិកា មុំ សុន ព្រមទាំងកូនចៅ

លោក លន់ វ៉ាន់ថា អ្នកស្រី មុំ ដាន់ ព្រមទាំងបុត្រ ធីតា

លោក ចាប សោភ័ត អ្នកស្រី មុំ ដា ព្រមទាំងបុត្រ ធីតា

ឧបាសិកា ប៉ោ យេកលៀង ព្រមទាំងបុត្រ ធីតា និងចៅ

លោក រស់ ប៊ុនឡេង អ្នកស្រី ឡេង ស៊ីនី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ឈួន សុ ព្រមទាំងកូនចៅ

ឧបាសិកា ថ្លាង តាំងគៀន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ែន នាង ព្រមទាំងកូនចៅ

ឧបាសិកា អៀង នីម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ដារ៉ុង ព្រមទាំងកូនចៅ

ឧបាសិកា គឹម សេង ព្រមទាំងកូនចៅ

ឧបាសិកា ហួយ ជន ព្រមទាំងកូនចៅ

ឧបាសិកា រ័ត្ន សុផល ព្រមទាំងកូនចៅ

អ្នកស្រី ជុន បូណ៌មី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ជា ព្រមទាំងកូនចៅ

ឧបាសិកា គឹម អាន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ស៊ីយន ព្រមទាំងកូនចៅ

លោក កេត ចាន់តារា

លោក កេត សំបូរ និងកុមារី សុជាតា

ឧបាសិកា ជា រួចទៀង ព្រមទាំងកូនចៅ

ឧបាសក ជី សុខអៀម ឧបាសិកា តាំង ស៊ូអេង ព្រមទាំងកូនចៅ

ឧបាសិកា តាំង ស៊ូហៀង ព្រមទាំងកូនចៅ

ឧបាសិកា ជី ញ៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ខៀវ សុធី ហៅ អ៊ំម៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ទូច ព្រមទាំងកូនចៅ

ឧបាសក ឡាយ ឧបាសិកា លន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ហ៊ិន ព្រមទាំងកូនចៅ

ឧបាសិកា មិល មម ព្រមទាំងកូនចៅ

ឧបាសក រស់ ស្រេង ឧបាសិកា ឡា ហ៊ុយឡេង ព្រមទាំងកូនចៅ

ឧបាសិកា ឡា ស៊ីវឡេង ព្រមទាំងកូនចៅ

ឧបាសិកា គី ប៊ួយ ព្រមទាំងកូនចៅ

លោក យឹម សារ៉ាវិទ្ធ អ្នកស្រី រស់ ចិន្តា ព្រមទាំងបុត្រ

កុមារា យាន ពិសិដ្ឋ

ឧបាសិកា យន សាក ព្រមទាំងកូនចៅ

ឧបាសិកា ហោ យិចឡាំង ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ិន ចាន់ថា ព្រមទាំងកូនចៅ

ឧបាសិកា ជី ជុន ព្រមទាំងកូនចៅ

ឧបាសិកា ស៊ិន ឡាច ព្រមទាំងកូនចៅ

ឧបាសក ប៊ុន បួន ឧបាសិកា យុត សួរ ព្រមទាំងកូនចៅ

លោក ផាន សុបិន អ្នកស្រី សំ សុវណ្ណមល្លិកា ព្រមទាំងបុត្រ

បងស្រី ណៅ សុភី និងប្អូនស្រី ណៅ សុផល

ឧបាសិកា ឈឹន សុន ព្រមទាំងកូនចៅ

លោក ម៉ាន់ រិទ្ធី អ្នកស្រី អួន សារ៉េត ព្រមទាំងបុត្រ

លោក ឱម ឡូត អ្នកស្រី ស៊ុំ ស្រីពៅ ព្រមទាំងបុត្រ

លោក ម៉ាន់ សារឿន អ្នកស្រី ម៉ម សុធា ព្រមទាំងបុត្រ

លោក ស៊ុម សារ៉ាន់ អ្នកស្រី លី សុខរ៉េត ព្រមទាំងបុត្រ

ឧបាសក ទិត្យ លី ឧបាសិកា ហេងវណ្ណា ព្រមទាំងកូនចៅ

ឧបាសិកា ថោង គឹមលន់ ព្រមទាំងកូនចៅ

ឧបាសិកា ប៊ូ ប៊ុក ព្រមទាំងកូនចៅ

ឧបាសិកា ប៉េ សារ៉ា ឧបាសក ម៉ុី ធារី

ឧបាសិកា ម៉ៅ ណារី ព្រមទាំងកូនចៅ

ឧបាសក ប៉ៃ ស៊ីថា ឧបាសិកា ងួន សាលីន ព្រមទាំងកូនចៅ

ឧបាសិកា ប៊ូច សាមុត ព្រមទាំងកូនចៅ

ឧបាសក សៅ ម៉េង ឧបាសិកា ថោង វង្ស ព្រមទាំងកូនចៅ

ឧបាសិកា ថោង រ៉េត ព្រមទាំងកូនចៅ

ឧបាសិកា សេក ម៉ាន ព្រមទាំងកូនចៅ

ឧបាសិកា ច័ន្ទ សោភ័ណ្ឌ

ឧបាសក ជូ បូរិន ឧបាសិកា ហែម យ៉ានី ព្រមទាំងកូនចៅ

ឧបាសក ឃ្លោក ម៉ាន ឧបាសិកា ផូ ឡា ព្រមទាំងកូនចៅ

ឧបាសក ហាន គង់ ឧបាសិកា តេង លីគាង ព្រមទាំងកូនចៅ

ឧបាសិកា ឱម សុផាត ព្រមទាំងកូនចៅ

ឧបាសិកា ម៉ៅ សុផានី ព្រមទាំងកូនចៅ

លោក លឹម លី អ្នកស្រី ជាវ ប៊ួយ ព្រមទាំងបុត្រ

ឧបាសិកា សោម សូត្រ ព្រមទាំងកូនចៅ

ឧបាសិកា អ៊ុយ សុខុន និងកូន ឈុន ពុធជារី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមយន់ ព្រមទាំងកូនចៅ

ឧបាសិកា យិន មួយឡាង ឧបាសិកា យិន មួយហួ ព្រមទាំងកូនចៅ

ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ជីតា ព្រមទាំងកូនចៅ

ឧបាសិកា កាំង ប៉ោទៀង និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា យ៉ា សុខគីម ព្រមទាំងកូនចៅ

ឧបាសិកា គីក អេងគី ព្រមទាំងកូនចៅ

ឧបាសិកា ទី សុជី +បុត្រ ហែម តុលា

## នាមពុទ្ធបរិស័ទនៅស្រុកថ្មគោលមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក តាំង ម៉េង ឧបាសិកា លី ហ៊ុយស៊ីម ព្រមទាំងកូនចៅ

ឧបាសក លី ប៊ុនយូរ ឧបាសិកា យ៉ាន ស៊ី ព្រមទាំងកូនចៅ

លោក លី ប៊ុនហាក់ អ្នកស្រី តាំង ស៊ីវទៀង ព្រមទាំងបុត្រ

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈក្នុងការងារធម្មទាន

| | |
|---|---|
| ១- ឧបាសក ប៉េង តាំងហៃ | ឧបាសិកា ហ៊ួ គឹមហៀក |
| ២- ឧបាសក ស្រេង ស្រ៊ាង | ឧបាសិកា គិម ចន្ថា |
| ៣- ឧបាសក ឡាយ សុខុម | ឧបាសិកា គី គឹមហាប់ |
| ៤- ឧបាសិកា បួ ម៉ាឡា | ឧបាសក បញ្ញា |
| ៥- ឧបាសិកា ង៉ែង យូអេង | ឧបាសិកា មាស ម៉ូនីកា |
| ៦- ឧបាសក លឹម ខូង | ឧបាសិកា កែវ អុន |
| ៧- ឧបាសិកា កែវ កល្យាណ | ឧបាសិកា ឡឹក ពេញចិត្ត |
| ៨- ឧបាសិកា ស៊ឹន ចន្ថា | លោក ឡាំ ដាវណ្ណ |
| ៩- ឧបាសិកា គួ ប៊ុនគាង | ឧបាសិកា ឈុំ គីមហួយ |
| ១០- ឧបាសិកា នេត្រ នរិន្ទ | ឧបាសិកា តាំង ប៉ោងជីង |
| ១១-ឧបាសិកា ឱម លក្ខណា | ឧបាសិកា ហេង ច័ន្ទបុញ្ញវត្តី |
| ១២-ឧបាសិកា គី យក់បួយ | ឧបាសិកា ឈុន ណាត |

| | |
|---|---|
| ១៣-ឧបាសិកា អ៊ុឹង រិទ្ធារី | ឧបាសិកា សៀក ឆាយគីម |
| ១៤-ឧបាសិកា វៀម ថុល | ឧបាសិកា ម៉ៅ នី |
| ១៥-ឧបាសិកា សន ឈៀត | ឧបាសក ឡាន សុខុម |
| ១៦-ឧបាសិកា គី វណ្ណហាក់ | ឧបាសិកា ប៉ុន ណម |
| ១៧-ឧបាសិកា សួន កល្យាណ | ឧបាសិកា ភួង ភក្តី |
| ១៨-ឧបាសក អ៊ុឹង វ៉ៃយ៉ា | ឧបាសក កុយ សាមន |
| ១៩-ឧបាសក ហុង សុវណ្ណារិទ្ធ | ឧបាសក ហុង សុវណ្ណារ៉េត |

តម្លៃបោះពុម្ពក្នុង ១ ក្បាល ២$ × ១០០០ ក្បាល = ២០០០ $

ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទ មានបំណងចង់ចូលរួមបោះពុម្ព សៀវភៅជាធម្មទាននោះ សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទនេះ ០៧៧ ៦៦ ៦៦ ៣៨, ០៨៨៨ ៧៧ ៩៩ ៦៦, ០១២ ៣០៥ ៧៦៦ ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ

**-ជីវប្រវត្តិពុទ្ធឧបាសិកា** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀត តែប៉ុណ្ណោះ ។

**-វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ** សព្វថ្ងៃនេះ បានធ្វើសម្រេច

ជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៨៣៣ ទំព័រ ។

-*គម្ពីរអភិធម្មត្ថសង្គហៈ* និង *វិភាវិនីដីកា* សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៦៥០ ទំព័រជាង ។

-*អភិធម្មត្ថសង្គហៈ* និង *បរមត្ថទីបនីដីកា* សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៩៨៩ ទំព័រជាង ។

-*គម្ពីរអភិធម្មាវតា* សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័រ រួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥៩៧ ទំព័រ ។

-*មិលិន្ទបញ្ហា* សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥០០ ទំព័រ ។

-ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងរាបចំធ្វើនៅ គម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថា បញ្ចូលជាមួយគ្នា ដោយដាក់ព្រះត្រៃបិដកហើយ ដាក់ព្រះអដ្ឋកថាពីខាងក្រោមព្រះត្រៃបិដក ក្នុងការបញ្ចូលគម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថាជាមួយគ្នានោះ ព្រះត្រៃបិដកយកតាមបិដកខ្មែរយើង ដែលមាន ១១០ ក្បាល ។

-ព្រះត្រៃបិដកខ្មែរយើងដែលមាន ១១០ ក្បាល បានវាយកុំព្យូទ័រ

ចប់ហើយ ( ០១.០៥.២០១០, ២៧.០៣.២០១១ ) ។

-ការដាក់ព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ ដែលធ្វើសម្រេចជាស្ថាពរនោះ មានដូចខាងក្រោមនេះ គឺ

**-គម្ពីរវិន័យបិដក** បានធ្វើរួចជាស្រេចហើយ **មានចំនួន ១៤ ភាគ**

**-គម្ពីរទីឃនិកាយ** បានធ្វើរួចជាស្រេចហើយ **មានចំនួន ៦ ភាគ**

**-គម្ពីរមជ្ឈិមនិកាយ** បានធ្វើរួចជាស្រេចហើយ **មានចំនួន ៩ ភាគ**

**-គម្ពីរសំយុត្តនិកាយ** បានធ្វើរួចជាស្រេចហើយ **មានចំនួន ១១ ភាគ**

**-គម្ពីរអង្គុត្តរនិកាយ** បានធ្វើរួចជាស្រេចហើយ **មានចំនួន ១៣ ភាគ**

**-គម្ពីរខុទ្ទកនិកាយ** ប្រែបាន **៣៧ ភាគហើយ**

សរុបការប្រែព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ សព្វថ្ងៃនេះ **បានចំនួន ៩០ ក្បាលជាងហើយ** ។

## សៀវភៅដែលប្រមូលរៀបរៀង និងបោះពុម្ពហើយដោយ
## ខ្ញុំព្រះករុណា អាត្មាភាព
## ✍ យង់ សុផាត ✍

-ជីវប្រវត្តិព្រះអសីតិមហាសាវក មាន ៨ ភាគ ពីភាគ ១ ដល់ភាគ ៨

-ជីវប្រវត្តិព្រះអសីតិមហាសាវក **មាន ៤ ភាគ** ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា មាន ៤ ភាគ ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសក មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-ជីវប្រវត្តិព្រះពុទ្ធឧបាសក **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-រឿងរ៉ាវដែលទាកទងនឹងពុទ្ធស្ថាន **មាន ៥ ភាគ** ពីភាគ ១ ដល់ភាគ ៥

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស មាន ១ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស មាន ៤ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស មាន ៣ ភាគ

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា ភាគ ១-២

-ធម៌សូត្រឧទ្ទេសមស្ការបែបសម័យទំនើប

-គម្ពីរសារត្ថសង្គហៈ ភាគ ១

-គម្ពីរមហាសតិប្បដ្ឋានភាវនា

-ពុទ្ធប្បវត្តិ

សូមអនុមោទនាធម្មទាន !!!

សីល សមាធិ បញ្ញា

សមាគមធម្មឋានអរិយវង្សយស់សុខាត